人人生而自由,在尊严和权利上一律...



ALL HUMAN
BEINGS ARE
BORN FREE
AND...

Все люди рождаются
свободными и...





# សិទ្ធិមនុស្ស

## កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ



*Tous les êtres humains*
*naissent libres et...*



يولد جميع الناس أحرارًا...

Todos los seres humanos
nacen libres e...



N° 8 - 2005

INTER-PARLIAMENTARY UNION

OFFICE OF THE UNITED NATIONS
HIGH COMMISSIONER FOR HUMAN RIGHTS

# សិទ្ធិមនុស្ស ៖ កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ ភាសាខ្មែរ

بنـــی آدم اعضای یکدیگرنـــد — که در آفرینش ز یک گوهرند
چو عضوی بدرد آورد روزگـار — دگـــــر عضوها را نماند قرار
تو کز محنت دیگران بی غمی — نشایـــد که نامت نهند آدمی

The sons of Adam are like the limbs of the same body.
For they share the same essence in creation.
When one limb is put to pain
The other limbs cannot remain at rest
O thou who do not feel the sufferings of mankind
Thou deservest not to be called a human being.

Sadi, Gulistan (The Rose Garden, 1258)

**កំណត់របស់អ្នកនិពន្ធ :**

កូនសៀវភៅនេះ ត្រូវបាននិពន្ធដោយ Mr. Manfred Nowak នាយកវិទ្យាស្ថានសិទ្ធិមនុស្ស Ludwig Boltzmann នៅសាកលវិទ្យាល័យវីយែន និងជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិផ្នែកទារុណកម្ម ដែលមានការរួមវិភាគទានពី Mr. Jeroen Klok (OHCHR) និង Ms. Ingeborg Schwarz (IPU) ។

**សេចក្តីពន្យល់បានទទួលពី :**

*សហភាពអន្តរសភា (IPU):* សមាជិកគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្ស របស់សមាជិកសភាៈ Ms. Ann Clwyd (ចក្រភពអង់គ្លេស) Mr. Juan Pablo Letelier (ឈីលី) Mr. Mohamane Ousmane (នីជឺ ) Ms. Veronika Nedvědová (សាធារណរដ្ឋឆេក) និង Mr. Mahinda Samarasinghe (ស្រីលាំងកា) និង មន្ត្រីនានារបស់សហភាពអន្តរសភា (IPU)ៈ Mr. Anders B. Johnsson និង Mr. Rogier Huizenga ។

*ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) :* Mr. Zdzislaw Kedzia, Ms. Jane Connors, Mr. Markus Schmidt និង Mr. Julian Burger.

Original version: English
Cover design by Aloys Robellaz, les Studios Lolos, Carouge, Switzerland
Printed in France by SADAG, Bellegarde-sur-Valserine

## អារម្ភកថា

សិទ្ធិមនុស្សបានជ្រួតជ្រាបយ៉ាងជ្រាវជ្រៅទៅក្នុងសន្ទរកថា នយោបាយចាប់តាំងពីសង្គ្រាមលោកលើកទី២ មក។ ការតស៊ូដើម្បីសេរីភាព រួចចាកផុតពីការជិះជាន់ និងទុក្ខវេទនា មានចំណាស់ប្រហាក់ប្រហែលនឹងមនុស្សជាតិយើងនេះដែរ។ មានការប្រមាថមើលងាយដ៏ធំធេងលើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ ដែលបានកើតឡើងនៅកំឡុងពេលសង្គ្រាមលោកនោះហើយ និងសេចក្ដីត្រូវការឱ្យមានការទប់ស្កាត់អំពើយង់ឃ្នង បែបនេះនាពេលអនាគត ដែលបានដាក់មនុស្សជាតិជាចំណុចស្នូលឡើងវិញ និងនាំឱ្យមានការចងក្រងជាក្រឹត្យក្រមនៅថ្នាក់អន្តរជាតិស្ដីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននានា។ មាត្រា ១ នៃធម្មនុញ្ញសហប្រជាជាតិប្រកាសថា "ដោយពង្រីក ហើយនិងលើកទឹកចិត្តក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាព-ជាសារៈសម្រាប់មនុស្សទូទៅ ឥតសំគាល់ ជាតិ ភេទ ភាសា ឬ សាសនា " គឺជាវត្ថុបំណងមួយរបស់ស្ថាប័នអន្តរជាតិនេះ។

សេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស ដែលបានអនុម័តឡើងដោយមហាសន្និបាតសហប្រជា ជាតិនៅឆ្នាំ ១៩៤៨ គឺជាជំហានដំបូងឆ្ពោះទៅរកការសម្រេចវត្ថុបំណងនេះ។ គេយល់ថាសេចក្ដីថ្លែងការណ៍ជាសកលនេះ គឺជាការបកស្រាយផ្លូវការលើពាក្យ "សិទ្ធិមនុស្ស" នៅក្នុងធម្មនុញ្ញសហប្រជាជាតិ។ សេចក្ដីថ្លែងការណ៍ជាសកល រួមជាមួយនឹងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលទាំងពីរនេះត្រូវបានអនុម័តនៅឆ្នាំ ១៩៦៦ បង្កើតបានជាធម្មនុញ្ញអន្តរជាតិស្ដីពីសិទ្ធិមនុស្ស។ ចាប់តាំងពីឆ្នាំ ១៩៤៨ មក សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ត្រូវបាន

ចងក្រងជាលិខិតុបករណ៍រាប់រយមុខ ដោយមានទាំងដាក់កាតព្វកិច្ចផ្លូវច្បាប់ និងមិនដាក់កាតព្វកិច្ចផ្លូវច្បាប់ នៅថ្នាក់សកល និងថ្នាក់តំបន់ ពាក់ព័ន្ធដល់ស្ទើរតែគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅរបស់មនុស្ស និង គ្របដណ្ដប់ទូលំទូលាយលើសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ដូច្នេះហើយបានជាការប្រមូលចងក្រងច្បាប់សិទ្ធិមនុស្សភាគច្រើន បានចប់សព្វគ្រប់ពេញលេញហើយ។ ដូចដែលអតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ Mr. Kofi Annan បានបញ្ជាក់ថា ការងារដែលត្រូវពុះពារជាចំបងបច្ចុប្បន្ននេះ គឺត្រូវអនុវត្តតាម បទដ្ឋានក្រឹត្យក្រមទាំងឡាយដែលបានអនុម័តរួចហើយនោះ។

នៅក្នុងបណ្ដាឆ្នាំកន្លងទៅនេះ មានផ្ដោតការយកចិត្តទុកដាក់កាន់តែច្រើនឡើង ចំពោះស្ថាប័នរដ្ឋសភា ព្រោះជាស្ថាប័នរដ្ឋមួយ ដែលតាមរយៈស្ថាប័ននេះពលរដ្ឋប្រើប្រាស់ សិទ្ធិរបស់គេដែលមានចែងក្នុងមាត្រា ២១ នៃសេចក្ដីថ្លែងការណ៍ជាសកល ក្នុងការរួមចំណែកក្នុងដំណើរកិច្ចការសាធារណៈរបស់ប្រទេសជាតិ។ ជាការពិតណាស់ថា ប្រសិនបើចង់ឱ្យសិទ្ធិមនុស្សក្លាយជាការពិតសម្រាប់មនុស្សគ្រប់រូបរដ្ឋសភាត្រូវដើរតួនាទីរបស់ខ្លួនឱ្យពេញលេញ និងឆ្ពោះទៅរកទិសដៅនេះ ដោយប្រើអំណាចជាក់លាក់ដែលខ្លួនមាន ដូចជា អំណាចតាក់តែងច្បាប់អំណាចអនុម័តថវិកាជាតិ និង អំណាចត្រួតពិនិត្យលើរដ្ឋាភិបាល។

ក្នុងនាមជាអង្គការមួយដែលចែករំលែកការព្រួយបារម្ភរបស់អង្គការសហប្រជាជាតិទៅលើសិទ្ធិមនុស្ស សហភាពអន្តរសភា **IPU** (Inter Parliamentary Union) ស្វះស្វែងពង្រឹងតួនាទីរបស់រដ្ឋសភានានាឱ្យទៅជាស្ថាប័នគាំពារសិទ្ធិមនុស្ស។ សកម្មភាពទាំងឡាយ ដែលអង្គការនេះ បានអនុវត្តក្នុងរយៈពេលកន្លងមកក្នុងទិសដៅនេះ បានបង្ហាញថា សមាជិករដ្ឋសភាតែងតែបានដឹងតិចតួចបំផុត អំពីក្របខ័ណ្ឌច្បាប់អន្តរជាតិ ស្ដីពីសិទ្ធិមនុស្ស កាតព្វកិច្ចនានា ដែលប្រទេសរបស់ពួកគេបានទទួលយក តាមរយៈ ការចុះហត្ថលេខា លើសន្ធិសញ្ញាសិទ្ធិមនុស្ស ព្រមទាំងស្ថាប័នសិទ្ធិមនុស្ស និងយន្តការនានាទាំងថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ ដែលត្រូវបានបង្កើត

ឡើង ដើម្បីឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សទាំងនោះ។ ជាការពិតណាស់ មានការងារជាច្រើនទៀត ដែលសមាជិកសភាអាចធ្វើទៅបាន ដើម្បីជាគុណប្រយោជន៍ដល់សិទ្ធិមនុស្ស។

ដូច្នេះហើយបានជា មានសំណូមពរថា សហភាពអន្តរសភា (IPU) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដែលជាស្ថាប័នសហប្រជាជាតិមួយទទួលអាណត្តិ ជាក់លាក់សម្រាប់លើកស្ទួយ និងការពារការប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គួរតែបោះពុម្ពផ្សាយកូនសៀវភៅមួយដែលមានព័ត៌មានជាមូលដ្ឋានអំពីសិទ្ធិមនុស្ស និងប្រព័ន្ធអន្តរជាតិ និងថ្នាក់តំបន់ ដើម្បីលើកស្ទួយ និងការពារសិទ្ធិទាំងនោះ។

ភារកិច្ចរៀបរៀង*កូនសៀវភៅ* នេះ ត្រូវបានប្រគល់ជូនទៅអ្នកឯកទេសសិទ្ធិមនុស្សដ៏ល្បីល្បាញម្នាក់ ឈ្មោះ Mr. Manfred Nowak ដែលបច្ចុប្បន្ននេះ ជាអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិខាងវិស័យទារុណកម្ម។ ក្នុងការបំពេញបេសកកម្មនេះ គាត់បានដកស្រង់យកមតិយោបល់ និងការណែនាំរបស់គណៈកម្មាធិការនៃសហភាពអន្តរសភាទទួលបន្ទុកផ្នែកសិទ្ធិមនុស្សរបស់សមាជិកសភា ព្រមទាំងមន្ត្រីរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងមន្ត្រីនានារបស់ហភាពអន្តរសភា (IPU)។

មិនពិបាកនឹងយល់ទេថា ថ្វីត្បិតតែនិយាមបទដ្ឋាន និងគោលការណ៍សិទ្ធិមនុស្ស ដែលត្រូវបានរៀបរៀងឡើងដោយសហគមន៍អន្តរជាតិក៏ដោយ ក៏យើងនៅតែស្ថិតនៅឆ្ងាយពីការរស់នៅក្នុងពិភពលោកមួយដែល "មិនមានការភ័យខ្លាច និងខ្វះខាត" ដែលស្ថាបនិកនានានៃអង្គការសហប្រជាជាតិប្រាថ្នាចង់បាន ។ ដូច្នោះហើយបានជាអង្គការទាំងពីរ មានក្តីសង្ឃឹមថា កូនសៀវភៅនេះនឹងក្លាយជាលិខិតុបករណ៍ចម្បងមួយ សម្រាប់សមាជិកសភាទូទាំងពិភពលោក អាចវាស់សកម្មភាពនីតិកម្ម ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និងភាពជាតំណាងរាស្ត្ររបស់ពួកគេ

ទៅលើកាតព្វកិច្ចសិទ្ធិមនុស្សដែលប្រទេស គេបានទទួលយក និង អាចជួយពួកគេឱ្យដើរតួនាទីសំខាន់ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស នៅក្នុងប្រទេសក៏ដូចជានៅលើពិភពលោកទាំងមូល ។



**Louise Arbour**
ឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)



**Anders B. Johnsson**
អគ្គលេខាធិការ
សហភាពអន្តរសភា (IPU)

# តើកូនសៀវភៅនេះមានខ្លឹមសារអ្វីខ្លះ?

ផ្នែកទី ១ និយាយអំពីទិដ្ឋភាពនៃគោល ការណ៍ទូទៅដែលគ្របដណ្តប់ច្បាប់សិទ្ធិមនុស្ស និង កាតព្វកិច្ចនានា ដែលរដ្ឋទទួលយក នៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សៀវភៅនេះ បង្ហាញក្របខ័ណ្ឌច្បាប់ថ្នាក់តំបន់ និងអន្តរជាតិ នៅក្នុងវិស័យសិទ្ធិមនុស្ស និងពន្យល់អំពីការ ប្រព្រឹត្តទៅនៃអង្គការសិទ្ធិមនុស្សថ្នាក់តំបន់ និងថ្នាក់អន្តរជាតិផ្សេងៗ ដោយរួមមានទាំង អង្គការទាំងឡាយដែលតាមឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចម្បងៗ ផងដែរ។

នៅក្នុងផ្នែកទី ២ នៃជំពូកទី ១១សង្កត់ធ្ងន់ទៅលើសកម្មភាពអ្នកតំណាងរាស្ត្រក្នុងការលើក ស្ទួយ និង ការពារសិទ្ធិមនុស្ស។ ជំពូកនេះផ្តល់ឧទាហរណ៍ជាក់ស្តែងអំពីអ្វីដែលរដ្ឋសភា និង សមាជិកសភាអាច ធ្វើទៅបាននៅក្នុងវិស័យនេះ។ ប្រអប់ " អ្វីដែលអ្នកអាចធ្វើ " បង្ហាញ បញ្ជីសកម្មភាពបែប នោះ។

ជំពូកទី ១២ និង ទី ១៣ មានគោលបំណងពិពណ៌នាអំពីខ្លឹមសារចម្បងនៃសិទ្ធិនីមួយៗ ដែលបានធានានៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងផ្តល់ចម្លើយចំពោះ សំណួរទាំងឡាយដូចជា : តើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌មានន័យ ដូចម្តេច? ឬ តើសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យមានន័យដូចម្តេច ?។ ជំពូកទាំងនេះ រៀបរាប់តែ សិទ្ធិជាមូលដ្ឋានដែលនឹងត្រូវបរិយាយលំអិតនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ហើយមិន រាប់បញ្ចូលសិទ្ធិមានទ្រព្យសម្បត្តិឡើយ។

# សិទ្ធិមនុស្ស
# កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ

## មាតិការ

**អារម្ភកថា** ............................................................................................ iii

### ផ្នែកទី ១

**ជំពូកទី ១ : តើសិទ្ធិមនុស្សជាអ្វី?**................................................................................១

និយមន័យ ................................................................................................១

គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន..................................................................៦

សិទ្ធិមនុស្ស និង អធិបតេយ្យភាពរបស់រដ្ឋ...........................................................១៥

លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងរដ្ឋសភា.......................................................១៦

**ជំពូកទី ២ : អ្វីខ្លះជាកាតព្វកិច្ចរបស់រដ្ឋចំពោះសិទ្ធិមនុស្ស?** ..........................................១៩

**ជំពូកទី ៣ : លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ**..........................................................៣១

ការកកើតឡើងនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ..........................................................៣១

កម្រងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ................................................................ ៣២

សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ..........................................................................៣៤

លិខិតុបករណ៍សិទ្ធិមនុស្សដទៃទៀតរបស់អង្គការសហប្រជាជាតិ.............៣៧

**ជំពូកទី ៤ :** **តើរដ្ឋាភិបាលអាចធ្វើការរិតត្បិតលើសិទ្ធិមនុស្សបានដែរឬទេ?** ....................៤១
ឧកម្រិតព្រំដែន ....................................................................................៤២
ការព្យួរសិទ្ធិមនុស្សក្នុងស្ថានភាពមានអាសន្ន ............................................៤៥
ឧក្សាទុកចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់អន្តរជាតិ ឬ ថ្នាក់តំបន់ .............. ៤៦
វិធានការប្រឆាំងភេរវកម្ម និង សិទ្ធិមនុស្ស ...............................................៤៧

**ជំពូកទី ៥:** **ស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សរបស់ អង្គការសហប្រជាជាតិ** ..........................................................................៥៣
សមាជិកភាព និងការប្រព្រឹត្តទៅ ............................................................ ៥៤
នីតិវិធីធ្វើរបាយរាយការណ៍ ...................................................................... ៥៤
នីតិវិធីបណ្តឹងបុគ្គល ................................................................................ ៥៨
នីតិវិធីបណ្តឹងរវាងរដ្ឋ និងរដ្ឋ ................................................................... ៦០
នីតិវិធីស៊ើបអង្កេតនៅក្រោម CAT និងពិធីសារបន្ថែមលើ CEDAW .......៦៣
ប្រព័ន្ធនៃការធ្វើទស្សនៈកិច្ចទៀងទាត់ទៅកាន់មន្ទីរឃុំឃាំង ដែលបង្កើតឡើងតាមពិធីសារបន្ថែមនៃ CAT.............................................៦៤

**ជំពូកទី ៦:** **ប្រព័ន្ធការពារសិទ្ធិមនុស្សផ្អែកលើធម្មនុញ្ញ ក្រោមគណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ** ..........................................**៦៧**
នីតិវិធីសម្ងាត់លេខ “១៥០៣” ...........................................................៦៧
នីតិវិធីពិសេស ......................................................................................៧០
អនុគណៈកម្មការទទួលបន្ទុកការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ......៧៣

**ជំពូកទី ៧: ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស .........៧៥**

**ជំពូកទី ៨: សមាហរណកម្មសិទ្ធិមនុស្សទៅក្នុងការងាររបស់អង្គការសហប្រជាជាតិ.......៨១**

សិទ្ធិមនុស្សនៅក្នុងមហាសន្និបាត និងកម្មវិធីអចិន្ត្រៃយ៍របស់ខ្លួន ............... ៨៣

សិទ្ធិមនុស្ស និងក្រុមប្រឹក្សាសន្តិសុខ ....................................................៨៤

សិទ្ធិមនុស្ស និង" គ្រួសារអង្គការសហប្រជាជាតិ :.....................................៨៤

**ជំពូកទី ៩: សន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់ និងការតាមឃ្លាំមើល ...............................៨៩**

ទ្វីបអាហ្វ្រិក ..........................................................................................៨៩

ទ្វីបអាមេរិក..........................................................................................៩២

តំបន់អារ៉ាប់ .........................................................................................៩៤

តំបន់អាស៊ី និងប៉ាស៊ីហ្វិក .....................................................................៩៥

ទ្វីបអឺរ៉ុប ..............................................................................................៩៦

**ជំពូកទី ១០: ការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព:** តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) .....៩៩

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY)

និង តុលាការ ឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ICTR) .......... ១០០

តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ..................................................១០១

កម្រងគោលការណ៍សម្រាប់ការពារនិងលើកស្ទួយសិទ្ធិមនុស្ស តាមរយៈ

វិធានការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ...............................................១០៨

## ផ្នែកទី ២

**ជំពូកទី ១១: តួនាទីរបស់សមាជិកសភា**

**ក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស ............................... ១១៣**

គោលការណ៍មូលដ្ឋាន ............................... ១១៣

វិធានការសភាក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ............... ១១៨

**ជំពូកទី ១២: អ្វីដែលសមាជិកសភាគួរយល់ដឹងអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

**ដែលមាននៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ............... ១៥១**

សិទ្ធិរស់រានមានជីវិត ............................... ១៥១

ហាមប្រាមការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត

ដែល ឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប :

សិទ្ធិទទួលបានបូរណភាព និងសេចក្តី ថ្លៃថ្នូរផ្ទាល់ខ្លួន ............... ១៦៩

សិទ្ធិទទួលបានសេរីភាពផ្ទាល់ខ្លួន ............................... ១៧៩

ការគ្រប់គ្រងវិស័យយុត្តិធម៌ :

សិទ្ធិទទួលបានការកាត់ទោសដោយត្រឹមត្រូវ............................... ១៨៤

សិទ្ធិទទួលបានជីវិតឯកជន និងការការពារជីវិតគ្រួសារ ............... ១៩២

សេរីភាពក្នុងការធ្វើដំណើរ ............................... ២០៤

សេរីភាពខាងការគិត ខាងសម្បជញ្ញៈ និងខាងសាសនា ............... ២១០

សេរីភាពក្នុងការមានមតិ និងសម្តែងមតិ ............................... ២១៥

សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និង សេរីភាព

ខាងសមាគម ............................... ២៣១

សិទ្ធិក្នុងការចូលរួមនៅក្នុងរដ្ឋាភិបាល ............................... ២៣៦

**ជំពូកទី ១៣: អ្វីដែលសមាជិកសភាគួរយល់ដឹងអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ...២៤៥**

និន្នាការសង្គម និងសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ ......................................២៤៥

សិទ្ធិទទួលបានសន្តិសុខសង្គម ..........................................................២៥៦

សិទ្ធិធ្វើការងារ និង សិទ្ធិនៅកន្លែងធ្វើការ ...............................................២៦០

សិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ ....................................................២៦៥

សិទ្ធិទទួលបានការអប់រំ .....................................................................២៩៣

**សេចក្តីសន្និដ្ឋានចុងក្រោយ ..........................................................................៣០១**

**បញ្ជីអក្សរបំព្រួញ ....................................................................................៣០៣**

**ឧបសម្ពន្ធ័ ១ :** សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ...........................................៣០៥

**ឧបសម្ពន្ធ័ ២ :** កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ .................. ...៣១៧

**ឧបសម្ពន្ធ័ ៣ :** កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ .............៣៥១

**ឧបសម្ពន្ធ័ ៤ :** លិខិតុបករណ៍អន្តរជាតិដែលមាននៅលើអ៊ិនធឺណែត............................ ៣៧០

# ជំពូកទី ១
# អ្វីខ្លះជាសិទ្ធិមនុស្ស ?

## និយមន័យ

### សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមនុស្សជាតិគ្រប់រូបមានជាប់មកពីកំណើត

សិទ្ធិមនុស្ស គឺជាសិទ្ធិជាមូលដ្ឋានបំផុតរបស់មនុស្សជាតិ។ សិទ្ធិទាំងនេះកំណត់ទំនាក់ទំនងរវាងបុគ្គលឯកជន និងរចនាសម្ព័ន្ធអំណាច ជាពិសេសគឺរដ្ឋ។ សិទ្ធិមនុស្ស កំណត់ព្រំដែនរបស់រដ្ឋ ហើយនៅពេលជាមួយគ្នា តម្រូវឱ្យរដ្ឋ ចាប់យកវិធានការវិជ្ជមាន ដើម្បីធានាឱ្យមានបរិយាកាសមួយដែលជួយប្រជាជនទាំងអស់អាចប្រើប្រាស់សិទ្ធិរបស់ពួកគេបាន។ ប្រវត្តិសាស្ត្រមនុស្សជាតិប្រមាណ២៥០ឆ្នាំកន្លងមកនេះ បានចេញជារូបរាងឡើងដោយការតស៊ូ ដើម្បីបង្កើតនូវបរិយាកាសមួយបែបនោះ។ ចាប់ផ្តើមពីបដិវត្តន៍បារាំង និងអាមេរិកកាំង នៅចុងសតវត្សទី១៨ គំនិតស្តីពីសិទ្ធិមនុស្សបានជំរុញឱ្យមានចលនាបដិវត្តន៍ជាច្រើន ដែលបង្កើតឱ្យមានរបបផ្តល់អំណាច និងការត្រួតពិនិត្យលើអ្នកអនុវត្តន៍អំណាច ជាពិសេសរដ្ឋាភិបាល។

### សិទ្ធិមនុស្ស គឺជាការបូកផ្សំនៃសិទ្ធិបុគ្គល និងសិទ្ធិសមូហភាព ដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋ និងនៅក្នុងច្បាប់អន្តរជាតិ

រដ្ឋាភិបាលនិងអ្នកកាន់ការដទៃទៀតត្រូវស្ថិតនៅក្រោមកាតព្វកិច្ចគោរព ការពារ និងបំពេញសិទ្ធិមនុស្ស ដែលទាំងនេះ នឹងបង្កើតបានជាមូលដ្ឋានសំរាប់សិទ្ធិមានកម្មសិទ្ធិស្របច្បាប់ និង

សិទ្ធិទទួលបានសំណង ក្នុងករណីដែលពុំមានការបំពេញកាតព្វកិច្ច (មើលជំពូកទី២)។ ទាមការពិត លទ្ធភាពដើម្បីដាក់ពាក្យបណ្ដឹងទាមទារសំណងនិងស្នើឱ្យកែតម្រូវ ញែកសិទ្ធិមនុស្សឱ្យឃើញភាពខុសគ្នាអំពីគោលការណ៍នៃក្រមខណ្ឌសីលធម៌ ឬសាសនា។ បើមើលពីជ្រុងផ្លូវច្បាប់វិញ សិទ្ធិមនុស្ស អាចកំណត់បានថា ជាការបូកផ្សំនៃសិទ្ធិបុគ្គល និងសិទ្ធិសមូហភាពដែលទទួលស្គាល់ដោយរដ្ឋអធិបតេយ្យ និងដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋទាំងនោះ និងនៅក្នុងច្បាប់អន្តរជាតិ។ ចាប់តាំងពីសង្គ្រាមលោកលើកទី២ អង្គការសហប្រជាជាតិ បានដើរតួនាទីដឹកនាំក្នុងការកំណត់ឱ្យច្បាស់លាស់ និងលើកស្ទួយសិទ្ធិមនុស្ស ដែលពេលនោះបានរីកចម្រើនជាចម្បងតែនៅក្នុងរង្វង់រដ្ឋជាសមាជិក។ ជាលទ្ធផល សិទ្ធិមនុស្ស ត្រូវបានចងក្រងជាក្រមនៅក្នុងសន្ធិសញ្ញា និងលិខិតុបករណ៍ក៏រិតអន្តរជាតិ និងតំបន់ផ្សេងៗ ដែលរដ្ឋភាគច្រើនបានផ្ដល់សច្ចាប័នទទួលយក ហើយសព្វថ្ងៃនេះ បានក្លាយជាប្រព័ន្ធមួយ ដែលត្រូវគេទទួលស្គាល់ជាសកល។

## សិទ្ធិមនុស្សមានមុខព្រួញច្រើន

សិទ្ធិមនុស្សគ្របដណ្ដប់ទិដ្ឋភាពទាំងអស់នៃជីវិត។ ការអនុវត្តន៍សិទ្ធិទាំងអស់នេះ នាំឱ្យស្ត្រីនិងបុរស អាចរៀបចំ និងកំណត់ជីវិតរបស់ខ្លួនក្នុងសេរីភាព សមភាព និងគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ សិទ្ធិមនុស្ស រួមមានសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គម-កិច្ច និងវប្បធម៌ សិទ្ធិសមូហភាពរបស់ប្រជាជន ក្នុងការសម្រេចចិត្តដោយខ្លួនឯង សិទ្ធិមានសមភាព ទទួលបានការអភិវឌ្ឍន៍ មានសន្តិភាព និងមានបរិយាកាសរស់នៅស្អាតបាត។ ទោះបីជាធ្លាប់មាន -និងជួនកាលកំពុងតែមាន- ការជជែកវែកញែកថា សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលត្រូវបានស្គាល់ផងដែរថាជា "សិទ្ធិជំនាន់ទីមួយ" គឺឈរនៅលើទស្សនៈដែលថា រដ្ឋមិនជ្រៀតជ្រែកទៅក្នុងកិច្ចការឯកជន ចំណែកឯសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬ "សិទ្ធិជំនាន់ទី២" វិញ តម្រូវឱ្យរដ្ឋធ្វើសកម្មភាពវិជ្ជមាននោះ បច្ចុប្បន្នមានការទទួលស្គាល់

**ប្រអប់ទី១**

## ឧទាហរណ៍អំពីសិទ្ធិមនុស្ស៖
## សេរីភាព សិទ្ធិ និងការហាមប្រាមទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស

### ក្នុងវិស័យសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

សិទ្ធិរស់រានមានជីវិត

សេរីភាពរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អនុស្សធម៌ ឬបន្ថោកបន្ទាប ។

សេរីភាពរួចផុតពីទាសភាព ភាពជាខ្ញុំបម្រើ និងពលកម្មដោយបង្ខំ

សិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន

សិទ្ធិរបស់បុគ្គលជាប់ឃុំឃាំងក្នុងការទទួលបានការប្រព្រឹត្តមកលើខ្លួនដោយមនុស្សធម៌

សេរីភាពក្នុងការដើរហើរ

សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌

ការហាមប្រាមច្បាប់ព្រហ្មទណ្ឌប្រតិសកម្ម

សិទ្ធិទទួលស្គាល់ថាជាមនុស្សនៅចំពោះមុខច្បាប់

សិទ្ធិឯកជន

សេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា

សេរីភាពក្នុងការបញ្ចេញមតិ និងយោបល់

ការហាមប្រាមការឃោសនាដែលនាំឱ្យមានសង្គ្រាម និងការញុះញង់ឱ្យមានការស្អប់ខ្ពើមជាតិសាសន៍ ពូជសាសន៍ ឬស្អប់ខ្ពើមសាសនា

សេរីភាពក្នុងការប្រជុំ

សេរីភាពក្នុងការបង្កើតសមាគម និងការចូលរួមជាមួយសមាគម

សិទ្ធិរៀបការ និងបង្កើតគ្រួសារ

សិទ្ធិរួមចំណែកក្នុងកិច្ចការសាធារណៈ ការបោះឆ្នោត ការឈរឈ្មោះបោះឆ្នោត និង

សិទ្ធិទទួលបានសេវាសាធារណៈ ។

សិទ្ធិទទួលបានភាពស្មើគ្នានៅចំពោះមុខច្បាប់ និងគ្មានការរើសអើង ។

**ក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

សិទ្ធិមានការងារធ្វើ

សិទ្ធិទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ និងដែលអំណោយផល

សិទ្ធិបង្កើតសហជីព និងចូលរួមក្នុងសហជីព

សិទ្ធិទទួលបានសន្តិសុខសង្គម

ការការពារជីវិតគ្រួសារ

សិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យ រួមមានម្ហូបអាហារ សំលៀកបំពាក់ និងផ្ទះសម្បែង

សិទ្ធិទទួលបានសុខភាព

សិទ្ធិទទួលបានការអប់រំ

**ក្នុងវិស័យសិទ្ធិសមូហភាព**

សិទ្ធិរបស់ប្រជាជនក្នុង

- ស្វ័យសម្រេច
- ការអភិវឌ្ឍន៍
- ប្រើប្រាស់ដោយសេរីនូវទ្រព្យសម្បត្តិរបស់ខ្លួន និងធនធានធម្មជាតិ
- ការមានសន្តិភាព
- មានបរិយាកាសរស់នៅប្រកបដោយសុខមាលភាព

សិទ្ធិសមូហភាពដទៃទៀត

- សិទ្ធិជនជាតិភាគតិចក្នុងការមានសញ្ជាតិ មានជាតិពន្ធុ មានសាសនា និងមានភាសា
- សិទ្ធិជនជាតិដើមភាគតិច

យ៉ាងទូលំទូលាយថា ដើម្បីឱ្យសិទ្ធិមនុស្សក្លាយទៅជាការពិត រដ្ឋ និងសហគមន៍អន្តរជាតិទាំងឡាយ ត្រូវឈានទៅបង្កើតលក្ខខណ្ឌនិងក្របខ័ណ្ឌច្បាប់ដែលចាំបាច់សម្រាប់ការអនុវត្តន៍សិទ្ធិមនុស្សទាំងស្រុង។ ពាក្យថា "ជំនាន់" និយាយយោង ទៅលើភាសាដែលគេប្រើនៅក្នុងរយៈពេលនៃសង្គ្រាមត្រជាក់។ បច្ចុប្បន្ននេះ គឺគេផ្តោតលើគោលការណ៍សកលភាព ភាពមិនអាចបំបែកបាន និងអន្តរអាស្រ័យ(ភាពពឹងពាក់គ្នាទៅវិញទៅមក) នៃសិទ្ធិមនុស្សទាំងអស់។

**ប្រអប់ទី ២**

## សិទ្ធិក្នុងការអភិវឌ្ឍន៍

សិទ្ធក្នុង**ការ**អភិវឌ្ឍន៍ ដាក់មនុស្សនៅចំណុចស្នូលនៃដំណើរការអភិវឌ្ឍន៍ ហើយទទួលស្គាល់ថាមនុស្សត្រូវតែជាអ្នកចូលរួមជាចម្បង និងជាអ្នកទទួលផលពីការអភិវឌ្ឍន៍នោះ។

សេចក្តីថ្លែងការណ៍ជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានការអភិវឌ្ឍនីចែងថា :

១. "...បុគ្គលគ្រប់រូប និងប្រជាជនទាំងអស់មានសិទ្ធិចូលរួម ផ្តល់វិភាគទាន និងអាស្រ័យផលពីការអភិវឌ្ឍន៍នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលនៅក្នុងនោះ សិទ្ធិ និងសេរីភាពជាមូលដ្ឋានទាំងអស់ អាចសម្រេចទៅបាន" ហើយ

២. "សិទ្ធិដើម្បក្នុង**ការ**អភិវឌ្ឍន៍ ក៏មានន័យផងដែរថា ជាការធ្វើឱ្យសម្រេចបានទាំង ស្រុងនូវសិទ្ធិរបស់ប្រជាជនក្នុងការសម្រេចចិត្តដោយខ្លួនឯង រួមទាំងការអនុវត្តន៍សិទ្ធិ ដែលមិន-អាចកាត់ផ្តាច់ពីគ្នាបាន នូវអធិបតេយ្យភាពទាំងស្រុងរបស់ពួកគេ ទៅលើទ្រព្យសម្បត្តិ និងធនធានធម្មជាតិទាំងអស់ ដោយអាស្រ័យទៅតាមបញ្ញត្តិនានា ដែលពាក់ពន្ធ័ទៅនឹងកតិកាសញ្ញាអន្តរជាតិទាំងពីរស្តីពីសិទ្ធិមនុស្ស។"

សិទ្ធិក្នុង**ការ**អភិវឌ្ឍន៍ ឈរលើគោលការណ៍នៃការមិនអាចចែកចេញពីគ្នាបាន និងគោលការណ៍អន្តរអាស្រ័យ (ភាពពឹងពាក់គ្នាទៅវិញទៅមក) នៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់។ គួរផ្តោតការយកចិត្តទុកដាក់ស្មើគ្នា និងមានការពិចារណាជាបន្ទាន់ ទៅលើការអនុវត្តន៍ ការលើកកំពស់ និងការការពារ-សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ នៃខែកញ្ញា ឆ្នាំ ២០០០ បានកំណត់ការកាត់បន្ថយភាពក្រីក្រថា ជា-ទិសដៅគោលដែលគ្របដណ្តប់លើដំណើរការអភិវឌ្ឍន៍។ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ បានសម្រេចចិត្តថានឹងឈានទៅដល់គោលដៅទាំងនោះ ដែលភាគច្រើនឱ្យបានមុនឆ្នាំ ២០១៥។ គោលដៅទាំងនោះ រួមមាន ការកាត់បន្ថយឱ្យបានពាក់កណ្តាលនៃសមាមាត្រប្រជាជនដែលរស់នៅ ដោយសារប្រាក់ចំណូលតិចជាងមួយដុល្លារក្នុងមួយថ្ងៃ និងដែលរងគ្រោះដោយការអត់ឃ្លានសម្រេចឱ្យបានការអប់រំបឋមសិក្សាជាសកលសម្រាប់កុមារា កុមារី កាត់បន្ថយអត្រាមរណភាពកុមារឱ្យបាន ២/៣, កាត់បន្ថយអាត្រាមរណភាពរបស់មាតាឱ្យបាន ៣/៤, ប្រយុទ្ធប្រឆាំងជម្ងឺអេដស៍, ជម្ងឺគ្រុនចាញ់ និងជម្ងឺឆ្លងផ្សេងៗទៀត, ធានាស្ថិរភាពបរិស្ថាន និងបង្កើតភាពជាដៃគូជាសាកល ដើម្បីការអភិវឌ្ឍន៍ (សម្រាប់បញ្ជីរាយទិសដៅទាំងអស់សូមមើលប្រអប់ ៧៦)

# គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន

## សិទ្ធិមនុស្សមានលក្ខណៈសកល

*“សិទ្ធិមនុស្សមិនមែនជាទ្រឹស្តីចម្លែកសំរាប់វប្បធម៌ណាឡើយ ហើយសិទ្ធិមនុស្សមានកំណើត នៅគ្រប់ជាតិសាសន៍ទាំងអស់ ។ សិទ្ធិទាំងនោះមានលក្ខណៈសកល ។”*

*លោក កូហ្វី អាណាន់ អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ*
*ថ្លែងនៅសាកលវិទ្យាល័យតេហេរ៉ង់ ក្នុងទិវាសិទ្ធិមនុស្ស ថ្ងៃ១០ ធ្នូ ឆ្នាំ១៩៩៧*

សិទ្ធិមនុស្សមានលក្ខណៈសកល ព្រោះសិទ្ធិមនុស្ស ឈរលើគោលការណ៍ នៃសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់ៗរូប ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ជាតិពន្ធុ ឬដើមកំណើតសង្គម សាសនា ភាសា សញ្ជាតិ អាយុ ភេទ ពិការភាព ឬលក្ខណៈលេចធ្លោផ្សេងៗឡើយ ។ ដោយហេតុថា សិទ្ធិមនុស្សត្រូវបានទទួលយកដោយរដ្ឋ និងប្រជាជនទាំងអស់ សិទ្ធិទាំងនេះត្រូវបានអនុវត្តស្មើៗគ្នា ដោយគ្មានការរើសអើងចំពោះបុគ្គលណាឡើយ ហើយមានលក្ខណៈដូចគ្នាសម្រាប់មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែង ។

ប្រអប់ទី ៣

## សិទ្ធិមនុស្ស ៖ ជាទស្សនទានរបស់បច្ចឹមប្រទេស ?

ភាពជាសកលរបស់សិទ្ធិមនុស្សពេលខ្លះក៏ជួបការលំបាកក្នុងដំណើរការអនុវត្ត ដោយហេតុថា ទស្សនទាននេះ មានលំនាំដើមពីបច្ចឹមប្រទេស ដែលជាផ្នែកមួយនៃអាណានិគមនីបែបថ្មី ហើយដែលបាន ផ្សព្វផ្សាយនៅទូទាំងពិភពលោក ។ ការស្រាវជ្រាវមួយដែលបោះពុម្ពផ្សាយដោយអង្គការ UNESCO នៅឆ្នាំ ១៩៦៨[១] បានបង្ហាញយ៉ាងច្បាស់ថា សេចក្តីប៉ងប្រាថ្នាដ៏ជ្រាលជ្រៅ ដោយសង្កត់ធ្ងន់លើសិទ្ធិមនុស្សនោះ មានទាក់ទងទៅនឹងទស្សនទានដូចតទៅ ៖ ទស្សនទានយុត្តិធម៌ បូរណភាព និង សេចក្តីថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ សេរីភាពរួចផុតពីការគាបសង្កត់ ការធ្វើទុក្ខបុកម្នេញ និងការចូលរួមរបស់បុគ្គល ម្នាក់ៗនៅក្នុងការប្រឹង ប្រែងជាសមូហភាព ដែលកំពុងតែជួបប្រទះនៅគ្រប់អរិយធម៌ និងគ្រប់រយៈកាល ។ សព្វថ្ងៃនេះ ភាពជាសកលរបស់សិទ្ធិមនុស្សបានកើតឡើង ដោយសារតែកត្តាជាក់ស្តែង ដែលប្រជាជាតិភាគច្រើន ដែលមានភាពគ្រប់ដណ្តប់ទាំងស្រុងលើប្រពៃណីនៃវិស័យវប្បធម៌ សាសនា និងនយោបាយ បានអនុមត័ និងផ្តល់សច្ចាប័នលើលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗ ។

## សិទ្ធិមនុស្ស មិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន

សិទ្ធិមនុស្សមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន ដោយហេតុថា គ្មានបុគ្គលណាម្នាក់អាចត្រូវគេដកហូតសិទ្ធិមនុស្សរបស់ខ្លួនបានឡើយ លើកលែងតែ ក្នុងកាលៈទេសផ្លូវច្បាប់ ដែលមានកំណត់ច្បាស់លាស់ ។ ឧទាហរណ៍ សិទ្ធិទទួលបានសេរីភាពរបស់មនុស្សម្នាក់ អាចនឹងត្រូវបានដាក់កំហិត ប្រសិនបើបុគ្គលនោះ ត្រូវបានតុលាការរកឃើញថាបានប្រព្រឹត្តបទល្មើស ។

[១] Le Droit d'être un homme អត្ថបទសម្រាំង ដែលត្រូវបានរៀបចំក្រោមការដឹកនាំរបស់លោក Jeanne Hersch UNESCO និងRobert Laffont ១៩៦៨ ។

## សិទ្ធិមនុស្សមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន ហើយមានលក្ខណៈពឹងអាស្រ័យគ្នាទៅវិញទៅមក

សិទ្ធិមិនអាចបំបែកបាន ហើយមានការពឹងអាស្រ័យគ្នាទៅវិញទៅមក។ ដោយហេតុថា សិទ្ធិមនុស្ស នីមួយៗពាក់ព័ន្ធ និងពឹងអាស្រ័យទៅនឹងសិទ្ធិដទៃទៀត ការរំលោភ-សិទ្ធិណាមួយនោះ អាចនឹងប៉ះពាល់ដល់ការអនុវត្តន៍សិទ្ធិផ្សេងៗទៀត។ ឧទាហរណ៍ សិទ្ធិរស់រានមានជីវិត ត្រូវបានបុរេសន្មត់ឱ្យគោរពសិទ្ធិមានម្ហូបអាហារ និងសិទ្ធមានកំរិតជីវភាពរស់នៅសមរម្យ។ សិទ្ធិឈរឈ្មោះបោះឆ្នោតដើម្បីមុខតំណែងសាធារណៈ បញ្ជាក់ន័យប្រយោលថា ត្រូវមានសិទ្ធិទទួលការអប់រំជាមូលដ្ឋាន។ ការការពារសិទ្ធិសង្គមកិច្ច និង-សិទ្ធិសេដ្ឋកិច្ច សន្មត់រួចជាស្រេចនូវសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការជួបប្រជុំ និងក្នុងការបង្កើតសមាគម។ សមស្របដូចគ្នានេះដែរ គឺសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនិងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏មានលក្ខណៈបំពេញបន្ថែម និងមាន-សារៈសំខាន់ស្មើៗគ្នាទៅលើសេចក្ដីថ្លៃថ្នូរ និងបូរណភាពរបស់មនុស្ស គ្រប់រូប។ ការគោរពចំពោះសិទ្ធិទាំងអស់ជាការចាំបាច់មុនអ្វីៗទាំងអស់ សម្រាប់សន្តិភាព និងការអភិវឌ្ឍន៍ប្រកបដោយចិរភាព។

សហគមន៍អន្តរជាតិបានអះអាងបញ្ជាក់អំពីលក្ខណៈគប់ជ្រុងជ្រោយរបស់សិទ្ធិមនុស្ស នៅក្នុងសន្និសិទពិភពលោកស្ដីពីសិទ្ធិមនុស្ស នៅទីក្រុង Vienna នាឆ្នាំ ១៩៩៣។

*“សិទ្ធិមនុស្សទាំងអស់មានលក្ខណៈសកល មិនអាចបែងចែកបានទេ ពឹងអាស្រ័យគ្នាទៅវិញទៅមក និងមានការពាក់ព័ន្ធទៅវិញទៅមក។ សហគមន៍អន្តរជាតិត្រូវចាត់ទុក សិទ្ធិមនុស្សរួមគ្នាជាសកល ដោយសមភាព និងសមធម៌ ឈរលើមូលដ្ឋានស្មើគ្នា និងដោយ ផ្ដល់សារសំខាន់ដូចៗគ្នា។ នៅពេលដែលត្រូវចងចាំជានិច្ចដល់សារៈសំខាន់នៃលក្ខណៈពិសេសថ្នាក់តំបន់ និងថ្នាក់ជាតិ ហើយនិងមូលដ្ឋានសាសនា វប្បធម៌ និងប្រវត្តិសាស្ត្រផ្សេងៗគ្នានោះ រដ្ឋទាំងអស់មានកាតព្វកិច្ច ដោយមិនគិតពីប្រព័ន្ធវប្បធម៌ សេដ្ឋកិច្ច*

*និងនយោបាយរបស់ខ្លួន ត្រូវលើកកំពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់”* ។

*សន្និសិទពិភពលោកស្តីពីសិទ្ធិមនុស្សនៅ Vienna ឆ្នាំ ១៩៩៣*
*សេចក្តីថ្លែងការណ៍ទីក្រុង Vienna និងកម្មវិធីសកម្មភាព, កថាខ័ណ្ឌទី៥*

**ប្រអប់ទី ៤**

### សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច មិនអាចកាត់ចេញពីគ្នាបាន

លោក Amartya Sen អ្នកទទួលពានរង្វាន់ណូបែលខាងសេដ្ឋកិច្ច បានផ្តល់តឹកតាង តាមការពិសោធន៍ថា សិទ្ធិមនុស្សទាំងអស់មិនអាចកាត់ផ្តាច់ពីគ្នាបាន ហើយមានការអាស្រ័យគ្នាទៅវិញទៅមក។ ឧទាហរណ៍ នៅក្នុងការស្រាវជ្រាវ អំពីភាពអត់ឃ្លាន គាត់បានរកឃើញថា ទាំងនៅក្នុងចំណោមប្រទេសអ្នកមាន និងប្រទេសអ្នកក្រ កាលណាប្រជាធិបតេយ្យមានដំណើរ ការល្អ ភាពអត់ឃ្លានធ្ងន់ធ្ងរក៏មិនមានដែរ ពីព្រោះ នៅក្នុងរដ្ឋបែបនោះ ក្នុងចំណោមប្រព័ន្ធផ្សេងៗ ទំនងជាមានប្រព័ន្ធឃោសនាជាអ្នកអំពាវនាវឱ្យមានការយកចិត្តទុកដាក់គិតគូរដល់ភាពអត់ឃ្លានដែលអាចកើតឡើង ហើយគណបក្សនយោបាយ និងសាធារណៈក៏ចាត់វិធានការឆ្លើយតប។ ប្រជាធិបតេយ្យ ធ្វើឱ្យសភា រដ្ឋាភិបាល និង អ្នកនយោបាយផ្សេងៗទៀត ដឹងអំពីគ្រោះថ្នាក់នៃការធ្វើមិនដឹងមិនឮចំពោះគ្រោះថ្នាក់បែបនេះ។[២]

[២] Amartya Sen ភាពក្រីក្រ និង ទុរ្ភិក្ស : អត្ថបទនិពន្ធស្តីពីការផ្តល់សិទ្ធិ និង ការដកសិទ្ធិ Clarendon Press ១៩៨២។

## គោលការណ៍នៃការមិនរើសអើង

ការរំលោភសិទ្ធិមនុស្សដ៏អាក្រក់បំផុតខ្លះ កើតចេញពីការរើសអើងប្រឆាំងនឹងក្រុមមនុស្សណាមួយ។ ដូច្នេះសិទ្ធិទទួលបានភាពស្មើគ្នា និងគោលការណ៍នៃការមិនរើសអើង ដែលត្រូវបានកំណត់ច្បាស់នៅក្នុងសន្ធិសញ្ញាថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ គឺជាចំណុចកណ្ដាលនៃសិទ្ធិមនុស្ស។ សិទ្ធិទទួលបានភាពស្មើគ្នាតម្រូវឱ្យរដ្ឋធានាឱ្យមានការគោរពសិទ្ធិមនុស្ស ដោយគ្មានការរើសអើងទៅលើមូលហេតុណាមួយឡើយ រួមមាន ៖ ភេទ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត សញ្ជាតិ ជាតិពន្ធ ឬដើម កំណើតសង្គម សមាជិកភាពនៃជាតិភាគតិច ទ្រព្យសម្បត្តិ កំណើត អាយុ ពិការភាព ជម្រើសផ្លូវភេទ និងឋានៈសង្គម ឬឋានៈផ្សេងទៀត។ ជាញឹកញយណាស់ លក្ខណៈវិនិច្ឆ័យនៃការរើសអើងដែលរដ្ឋ ឬអ្នកដើរតួដែលមិនមែនជារដ្ឋ បានយកមកប្រើដើម្បីទប់ស្កាត់ ក្រុមមនុស្ស-ណាមួយ មិនឱ្យអនុវត្តបានពេញលេញនូវសិទ្ធិមនុស្សទាំងស្រុង ឬក៏ផ្នែកណាមួយនៃសិទ្ធិទាំងនោះ តែងតែឈរលើលក្ខណៈអស់ទាំងនោះ។

**ប្រអប់ទី ៥**

### ការហាមប្រាមការរើសអើង

គ្មានការរើសអើង គឺជាសសរស្ដម្ភនៃសិទ្ធិមនុស្ស

ភាពខុសគ្នានៅក្នុងច្បាប់ត្រូវតែមានមូលដ្ឋាននៃភាពខុសគ្នានៅក្នុងអង្គហេតុ

ការបែងចែកតម្រូវឱ្យមានការបញ្ជាក់ដោយមានហេតុផលត្រឹមត្រូវ

គោលការណ៍នៃសមមាត្រភាពត្រូវតែយកមកអនុវត្តតាម

លក្ខណៈដែលបានប្រើពីមុន ហើយដែលនៅតែប្រើជាមូលហេតុនៃការរើស អើង រួមមាន ភេទ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត សញ្ជាតិ ជាតិពន្ធ ឬដើមកំណើតសង្គម សមាជិកភាព នៃជាតិភាគតិច ទ្រព្យសម្បត្តិ កំណើត អាយុ ពិការភាព ជម្រើសផ្លូវភេទ និងឋានៈសង្គម ឬឋានៈផ្សេងទៀត។

## ភាពខុសគ្នានៅក្នុងអង្គហេតុអាចប្រើជាសំអាងទៅលើភាពខុសគ្នានៅក្នុងច្បាប់

ការញែកឱ្យឃើញភាពខុសគ្នាទាំងអស់ មិនមែនសុទ្ធតែបង្កើតការរើសអើងទេ។ ភាពខុសគ្នានៃអង្គហេតុ ឬ ភាពខុសគ្នានៃច្បាប់ដែលឈរលើលក្ខណៈវិនិច្ឆ័យសមហេតុផល និង-មានទិសដៅ អាចយកមកអនុវត្តបាន។ បន្ទុកផ្តល់ភស្តុតាងនឹងត្រូវធ្លាក់ទៅលើរដ្ឋាភិបាលពោលគឺ រដ្ឋាភិបាលត្រូវបង្ហាញឱ្យហើយថា ការបែងចែកទាំងឡាយណាដែលយកមកអនុវត្ត ត្រូវតែសមហេតុផល និងមានទិសដៅពិតប្រាកដ។

**ប្រអប់ទី ៦**

### ភាពខុសគ្នាដែលមានយុត្តិកម្មទាក់ទងទៅនឹងការងារ

គោលការណ៍ណែនាំពីររបស់សហភាពអឺរ៉ុប ស្តីពីសមភាពរវាងពូជសាសន៍ និងសមភាពក្នុងការងារ[៣] ផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលអាចអនុញ្ញាតឱ្យមានការប្រព្រឹត្តខុសៗគ្នា នៅក្នុងកាលៈទេសៈលើកលែងមួយចំនួន។ ដូច្នេះការប្រព្រឹត្តខុសគ្នានេះ ត្រូវបានអនុញ្ញាតឱ្យអនុវត្តចំពោះករណីមួយចំនួនតូច ដែល-ទាក់ទងការងារទាំងឡាយណា ដែលការបំពេញការងារនោះ ជាក់ស្តែងតម្រូវឱ្យមានការបែងចែកនៅលើមូលដ្ឋានទាំងនោះ ដូចជាពូជសាសន៍ ដើមកំណើត ជាតិពន្ធ សាសនា ឬជំនឿ ពិការភាព អាយុ ឬជម្រើសផ្លូវភេទ។ ឧទាហរណ៍ក្នុងន័យនេះ រួមមាន ៖ ការងារជាអ្នកសម្តែង ឬអ្នកបង្ហាញម៉ូដ ដែលយថាភាព និងភាពប្រាកដនិយមនៃការងារនោះអាចតម្រូវឱ្យអ្នកសម្តែងមានអាយុ ឬប្រភពដើមជាក់លាក់ និងមានតួនាទីអ្វីមួយនៅក្នុងព្រះវិហារ ឬនៅក្នុងអង្គការប្រហាក់ប្រហែលគ្នានេះ ហើយដែលតួនាទីនោះមានទំនាក់ទំនងជាមួយសាធារណៈជន (មិនដូចការងារដទៃទៀត នៅក្នុងអង្គការដដែលនោះទេ ដូចជាការងារក្នុងការិយាល័យ ឬការងារលើម្ហូបអាហារ) ដែលបុគ្គលិកដែលបំពេញតួនាទីនេះត្រូវតែមានជំនឿ និងការស្ម័គ្រខ្លួន សមស្រប។

---

[៣] សេចក្តីបង្គាប់របស់ក្រុមប្រឹក្សា លេខ ២០០០/៤៣/ EC ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០០ ស្តីពី-ការអនុវត្តន៍គោលការណ៍ប្រព្រឹត្តកម្មស្មើគ្នារវាងបុគ្គល ដោយពុំគិតអំពីដើមកំណើតជាតិសាសន៍ រឺជាតិពន្ធ និង លេខ ២០០០/៧៨/ EC ចុះថ្ងៃទី២៧ ខែវិច្ឆិការ ឆ្នាំ២០០០ ស្តីពីការបង្កើតក្របខណ្ឌទូទៅសំរាប់ប្រព្រឹត្តកម្មស្មើគ្នា នៅក្នុងការងារ និងអាជីព។

## ក្រុមមនុស្សខ្លះអាចទទួលបានសិទ្ធិពិសេស

គោលការណ៍នៃសមភាព ភាពជាសកល និងភាពមិនរើសអើង មិនបានបដិសេធការទទួលស្គាល់ក្រុមមនុស្សខ្លះ ដែលត្រូវតែទទួលបានសិទ្ធិពិសេស ព្រោះសមាជិកនៃក្រុមនោះត្រូវការការការពារពិសេស។ ប្រការនេះ គឺជាមូលហេតុដែលលិខិតុបករណ៍សិទ្ធិមនុស្សមួយចំនួន ត្រូវបានរៀបចំឡើងដើម្បីការពារសិទ្ធិនៃក្រុមមនុស្សដែលមានសេចក្តីត្រូវការពិសេសដូចជា : ស្ត្រី ជនបរទេស ជនគ្មានប្រទេស ជនភៀសខ្លួន ជនផ្លាស់លំនៅដ្ឋាន ជនជាតិភាគតិច ជនជាតិដើមភាគតិច អនីតិជន មនុស្សមានពិការភាព ពលករចំណាកស្រុក និងជនជាប់ឃុំឃាំង ។ ទោះជាយ៉ាងនេះក្តី សិទ្ធិសម្រាប់ក្រុមមនុស្សពិសេសមាន ភាពចុះសម្រុងគ្នាជាមួយគោលការណ៍សកលភាព តែនៅពេលណាដែលសិទ្ធិទាំងនោះ មានមូលហេតុ ឬទិសដៅពិសេស ដូចជាភាពងាយរងគ្រោះ ឬមានប្រវត្តិរើសអើងប្រឆាំងនឹងក្រុមនោះ។ បើពុំនោះសោតទេការផ្តល់សិទ្ធិពិសេសអាចសន្មត់បានថាជាបុព្វសិទ្ធិ ដែលស្មើគ្នាទៅនឹងការរើស អើងប្រឆាំងនឹងក្រុមដទៃទៀត ។

**ប្រអប់ទី ៧**

### សិទ្ធិពិសេសៗរបស់ជនពិការ : ឧទាហរណ៍

នៅចក្រភពអង់គ្លេស ច្បាប់ស្តីពីការរើសអើងប្រឆាំងពិការភាពឆ្នាំ ១៩៩៥ តម្រូវឱ្យនិយោជក "ធ្វើការលៃសម្រួលសមស្រប" ដល់ការចាត់ចែងការងារ និងទីបរិវេណការងារដើម្បីទទួលយកកម្មករជាជនពិការឱ្យចូលធ្វើការងារ។ ច្បាប់នោះមានដាក់ចេញយ៉ាងលំអិតនូវប្រភេទនៃវិធានការ ដែលតម្រូវឱ្យមាន ។ វិធានការនេះ រួមមាន ការកែតម្រូវទីបរិវេណ និងគ្រឿងបរិក្ខា ដើម្បីផ្ទេរអ្នកមានពិការភាពទៅធ្វើការងារនៅកន្លែងសមស្រប ចាត់តាំងឡើងវិញនូវភារៈកិច្ចខ្លះរបស់ពួកគេទៅឱ្យបុគ្គលិកដទៃទៀត ហើយរៀបចំឱ្យមានម៉ោងធ្វើការឆ្លាស់គ្នា។

## វិធានការពិសេសបណ្ដោះអាសន្ន

ដើម្បីកែតម្រូវឡើងវិញនូវផលប៉ះពាល់រយៈពេលវែងដោយសារការរើសអើងពីអតីតកាល ចាំបាច់ត្រូវឱ្យមានវិធានការពិសេសបណ្ដោះអាសន្ន។ អនុសាសន៍ទូទៅលេខ ២៥[៤] នៅក្នុង-មាត្រា ៤នៃអនុសញ្ញា ស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)[៥] បានកំណត់វិធានការផ្សេងៗ មួយចំនួនធំក្នុងវិស័យនីតិបញ្ញត្តិ នីតិប្រតិបត្តិ រដ្ឋបាល ឬលិខិតុបករណ៍និយ័តកម្មផ្សេងៗទៀត គោលនយោបាយ និងការអនុវត្តន៍ផ្សេងៗ ដូចជា កម្មវិធីគាំទ្រតាមសហគមន៍ ការលៃបម្រុង និង/ឬការផ្ទេរធនធាន ការអនុគ្រោះកំណត់អ្នកដែលត្រូវជ្រើសរើសឱ្យធ្វើការ ការផ្ដល់ការងារឱ្យធ្វើ ការតម្លើងឋានៈ ការលើក-ទិសដៅជាតួលេខដោយមានកំណត់ក្របខ័ណ្ឌពេលវេលា និងប្រព័ន្ធកូតា។

---

[៤] ស្ថាប័ននានា ដែលឃ្លាំមើលការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តិសិទ្ធិមនុស្សអន្តរជាតិ បរិយាយយ៉ាងល្អិតល្អន់អំពីសិទ្ធិ និង កាតព្វកិច្ចផ្សេងៗ ដែលរដ្ឋមាននៅក្នុង "អនុសាសន៍ទូទៅនានា" និង "ការផ្ដល់យោបល់ទូទៅនានា"។ សម្រាប់ព័ត៌មានលំអិត សូមអានជំពូកទី៥។

[៥] សម្រាប់ព័ត៌មានបន្ថែមស្ដីពី CEDAW និង សភា សូមមើល *អនុសញ្ញាស្ដីពីការបំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និង ពិធីសារបន្ថែមនៃអនុសញ្ញានេះ : កូនសៀវភៅសម្រាប់សមាជិកសភា* IPU ហ្ស៊ឺណែវ ២០០៣។

## ប្រអប់ទី ៨

### ចំណាត់ការវិជ្ជមាន : ឧទាហរណ៍

នៅប្រទេស Norway ការិយាល័យទទួលពាក្យបណ្តឹងទាក់ទងសមភាពយេនឌ័រ (Gender Equality Ombudsman) ក្នុងរយៈពេលថ្មីៗនេះ បានផ្តោតទៅលើបុរសនៅក្នុងបរិបទសមភាពយេនឌ័រ។ ជាលទ្ធផល ច្បាប់ឈប់លំហែរមាតុភាពត្រូវបានធ្វើវិសោធនកម្ម ដើម្បីផ្តល់សិទ្ធិដល់បុរសដែរ។ ការកែប្រែមួយដែលបានធ្វើឡើងនោះ គឺការឈប់សម្រាក ៤ អាទិត្យត្រូវបានបំរុងទុកសម្រាប់ឪពុក។ ប្រសិនបើឪពុកនោះខកខានមិនបានប្រើសិទ្ធិ ដែលត្រូវបានស្គាល់ថាជា "កូតាឪពុក" នោះទេ គ្រួសារនោះនឹងបាត់បង់សិទ្ធិដែលផ្តល់ឱ្យសម្រាប់ ការសម្រាកនេះ។ "កូតាឪពុក" ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ១៩៩៣ ហើយ រយៈពេល២ឆ្នាំបន្ទាប់មក ចំនួនភាគរយនៃអ្នកទើបក្លាយជាឪពុកថ្មីៗដែលឈប់សម្រាកលំហែរបិតុភាព បានកើនឡើងពី ៤៥%ទៅ ៧០%។ ការិយាល័យទទួលពាក្យបណ្តឹងនេះ (Ombudsman) បានស្នើបន្ថែមនូវកម្មវិធីទប់ស្កាត់ការរើសអើងជាប្រយោជន៍ ដល់បុរស ក្នុងការងារមួយចំនួន ទាក់ទងនឹងការថែរក្សាកូន ដើម្បីធ្វើឱ្យសក្តានុពលរបស់បុរសសកម្មឡើងនៅក្នុងវិស័យនេះ ហើយដែលនឹងជួយទប់ស្កាប់ មិនឱ្យមានការបែងចែកយេនឌ័រនៅក្នុងទីផ្សារពលកម្ម ហើយដែលជួយផ្តល់ឱ្យកូនៗនូវទស្សនៈថ្មីមួយស្តីពីតួនាទីយេនឌ័រ (ក្នុងការថែទាំកូនចៅ)។

ឧទាហរណ៍ ប្រពន្ធ័កូតាបណ្តោះអាសន្នដែលបានតាក់តែងសម្រាប់ប្រព្រឹត្តកម្មដោយយកចិត្តទុកដាក់ចំពោះស្ត្រី ដើម្បីឱ្យស្ត្រីមានការងារធ្វើជាក់លាក់ មានសិទ្ធិពឹងពាក់ស្ថាប័នធ្វើសេចក្តីសម្រេចផ្នែកនយោបាយ ឬទទួលបានការអប់រំថ្នាក់ឧត្តមសិក្សា អាចចាត់ទុកថាជាវិធានការទប់ស្កាត់ការរើសអើងប្រឆាំងស្ត្រីក៏បាន ដើម្បីឈានទៅសម្រេចសមភាពយេនឌ័រនៅក្នុងវិស័យដែលជាប្រពៃណី ស្ត្រីតែងតែមានសម្លេងតំណាងតិចតួច និងទទួលរងនូវការរើសអើង។

នៅក្រោមមាត្រា៤ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)មានការលើកទឹកចិត្តចំពោះវិធានការបណ្ដោះអាសន្នទាំងនោះ។ ដូច្នេះមិនត្រូវចាត់ទុកជាការរើសអើងប្រឆាំងនឹងបុរសទេ។ ទោះជាយ៉ាងណាក្តី លុះត្រាណាគោលបំណងនៃសមភាពក្នុងការទទួលបានឱកាស និងទទួលបានប្រព្រឹត្តកម្មសមស្រប បានសម្រេចហើយ នោះវិធានការទាំងនេះត្រូវតែបញ្ឈប់។ បើមិនដូច្នោះទេ វិធានការទាំងនេះនឹងក្លាយទៅជាឯកសិទ្ធិសម្រាប់ស្ត្រី ដោយគ្មានហេតុផលយុត្តិកម្ម ហើយបណ្តាលឱ្យក្លាយទៅជាការរើសអើងប្រឆាំងបុរស។

យោងតាមអនុសាសន៍ទូទៅលេខ ២៥ មិនចាំបាច់ឱ្យមានភស្តុតាងស្តីពីអតីតការរើសអើងសម្រាប់ចាត់វិធានការបែបហ្នឹងទេ ពោលគឺ ក្នុងពេលដែលការអនុវត្តន៍វិធានការបណ្ដោះអាសន្នតែងតែកែតម្រូវដល់ផលវិបាកនៃអតីតការរើសអើងប្រឆាំងស្ត្រី កាតព្វកិច្ចរបស់រដ្ឋ ជាភាគីក្រោមអនុសញ្ញាដើម្បីលើកកំពស់ឋានៈស្ត្រីទៅជាឋានៈមួយតាមព្រឹត្តន័យ ឬឱ្យមាន សមភាពដ៏សំខាន់ទៅនឹងបុរស ក៏កើតមានឡើងដោយមិនចាំបាច់គិតដល់ភស្តុតាងនៃរើសអើងពីអតីតកាលដែរ។

## សិទ្ធិមនុស្ស និង អធិបតេយ្យភាពរបស់រដ្ឋ

នៅអតីតកាល ពេលដែលសិទ្ធិមនុស្សនៅត្រូវបានចាត់ទុកថា ជាកិច្ចការផ្ទៃក្នុងរបស់ប្រទេសមួយ ប្រទេសដទៃទៀត និងសហគមន៍អន្តរជាតិត្រូវបានរារាំងមិនឱ្យធ្វើការជ្រៀតជ្រែកទេ ទោះបីជាមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុត ដូចជាការប្រល័យពូជសាសន៍ក៏ដោយ។ ការប្រកាន់យកវិធីបែបនេះ ដែលយកអធិបតេយ្យភាពជាតិជា-មូលដ្ឋាន ជួបនឹងការប្រឈមជាខ្លាំងនៅក្នុងសតវត្សទី ២០ ជាពិសេសគឺ ដោយសកម្មភាពរបស់ពួកណាហ្ស៊ី អាល្លឺម៉ង់ និងអំពើឃោរឃៅនៅក្នុងពេលមានសង្គ្រាមលោកលើកទី២ ។ បច្ចុប្បន្ន ការលើកកំពស់ និងការការពារសិទ្ធិមនុស្សត្រូវបានចាត់ទុកថា ជាការព្រួយបារម្ភ

និង ការទទួលខុសត្រូវស្របច្បាប់របស់សហគមន៍អន្តរជាតិ ។ ក៏ប៉ុន្តែ ភាពមិនស្របគ្នារវាង-*កាតព្វកិច្ចស្របច្បាប់សកល* និង*អធិបតេយ្យភាពរបស់រដ្ឋ* អាចនឹងដោះស្រាយបានតែទៅតាមករណីនីមួយៗប៉ុណ្ណោះ ដោយឱ្យស្របទៅតាម*គោលការណ៍សមមាត្រ* ដែលតាមគោលការណ៍នេះ សកម្មភាពណាមួយ ដែលរដ្ឋបានចាប់យកដោយដើរតាមទស្សនៈនៃភាពជាសកល មិនត្រូវធ្វើឱ្យលើសពីការចាំបាច់ដើម្បីធ្វើឱ្យសម្រេចបាននូវការគោរពតាមគោលការណ៍សិទ្ធិមនុស្សឡើយ ។

*ការលើកកំពស់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានត្រូវតែ-ចាត់ទុកជាវត្ថុបំណង អទិភាពរបស់អង្គការសហប្រជាជាតិ ដែលស្របទៅតាមគោលការណ៍ និងគោលបំណងរបស់ខ្លួន ជាពិសេសគឺគោលបំណងសហប្រតិបត្តិការអន្តរជាតិ ។ នៅក្នុងក្របខ័ណ្ឌនៃគោលបំណង និងគោលការណ៍ទាំងនេះ ការលើកកំពស់ និងការការពារ-សិទ្ធិមនុស្សទាំងអស់ គឺជាកង្វល់ស្របច្បាប់របស់សហគមន៍អន្តរជាតិ ។*

*សន្និសិទពិភពលោកស្តីពីសិទ្ធិមនុស្សទីក្រុង Vienna ឆ្នាំ ១៩៩៣*
*និងសេចក្តីថ្លែងការណ៍ និងកម្មវិធីសកម្មភាពទីក្រុង Vienna, កថាខណ្ឌទី៤*

## ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងរដ្ឋសភា

ក្នុងអំឡុងទសវត្សរ៍កន្លងទៅ ទំនាក់ទំនងទៅវិញទៅមករវាងប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ត្រូវបានគេលើកយកមកសិក្សាយ៉ាងទូលំទូលាយ ។ ប្រជាធិបតេយ្យលែងត្រូវបានចាត់ទុកថា ត្រឹមតែជាកម្រងដំណើរការច្បាប់សម្រាប់រដ្ឋធម្មនុញ្ញ និងសម្រាប់ប្រើអំណាចនយោបាយតែប៉ុណ្ណោះហើយ ក៏ប៉ុន្តែ ជាមួយនឹងសិទ្ធិមនុស្ស ប្រជាធិបតេយ្យត្រូវបានចាត់ទុកថា ជាមធ្យោបាយការពារ និង លើកកំពស់សេចក្តីថ្លៃថ្នូររបស់មនុស្ស ។ នៅឆ្នាំ ១៩៩៥ សហភាពអន្តរសភា បានផ្តើមដំណើរការព្រាងសេចក្តីថ្លែងការណ៍ជាសកលស្តីពីប្រជាធិបតេយ្យ

ដើម្បីធ្វើឱ្យខ្ចាត និយាមអន្តរជាតិជឿនលឿនទៅមុខ និងដើម្បីរួមចំណែកដល់ប្រជាធិបតេយ្យ រូបនីយកម្ម ដែលកំពុងប្រព្រឹត្តទៅនៅទូទាំងសកលលោក។ នៅក្នុងសេចក្តីថ្លែងការណ៍ ដែលអនុម័តនៅឆ្នាំ ១៩៩៧ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស មានការទាក់ទងគ្នាយ៉ាងជិត ជិត ដែលអាចចាត់ទុកបានថា មិនអាចបំបែកបាន។

ប្រជាធិបតេយ្យស្ថិតនៅជុំវិញគំនិតដែលថា ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិស្មើគ្នាដើម្បីឱ្យមានសម្លេងនៅក្នុងការធ្វើសេចក្តីសម្រេចនានា ដែលមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។ សិទ្ធិចូលរួមនៅក្នុងកិច្ចការសាធារណៈនេះ មានចែងនៅក្នុងមាត្រា២១ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (CCPR) ។ ប៉ុន្តែដើម្បីឱ្យពលរដ្ឋអាចអនុវត្តសិទ្ធិនោះដោយប្រសិទ្ធភាពបាន ពួកគេត្រូវតែទទួលបានសិទ្ធិផ្សេងៗទៀត ដូចជា សេរីភាពក្នុងការ-បញ្ចេញមតិ សេរីភាពជួបប្រជុំ និងសិទ្ធិជាមូលដ្ឋានក្នុងវិស័យសង្គម និងសេដ្ឋកិច្ច។ ស្ថាប័ននានាដែលជួយបង្កលក្ខណៈឱ្យប្រជាជនអាចត្រួតពិនិត្យ និងចូលរួមបាន គឺជាស្ថាប័ន ដែលត្រូវការជាចាំបាច់មុនគេ។ រដ្ឋសភា ដែលជាអង្គស្ថាប័នអធិបតេយ្យ កើតឡើងតាមរយៈការបោះឆ្នោតដោយសេរី យុត្តិធម៌ និងទៀងទាត់តាមកាលកំណត់ ដើម្បីធានាឱ្យមានរដ្ឋាភិបាលដែលជារដ្ឋាភិបាលរបស់ប្រជាជនដើម្បីប្រជាជន និងកើតឡើងដោយប្រជាជននោះ គឺជាស្ថាប័នគន្លឹះរបស់ប្រជាធិបតេយ្យ។ ក្នុងឋានៈជាស្ថាប័នមានសមត្ថភាពបង្កើតច្បាប់ និងរក្សាគោលនយោបាយ និងសកម្មភាព របស់អង្គនីតិប្រតិបត្តិ ឱ្យស្ថិតនៅក្រោមការពិនិត្យពិច័យរបស់ខ្លួនជាប្រចាំ រដ្ឋសភាក៏អាច ដើរតួនាទីគន្លឹះនៅក្នុងការលើកកំពស់ និងការពារ-សិទ្ធិមនុស្ស។ លើសពីនេះទៀត រដ្ឋសភាបង្កើតក្របខណ្ឌច្បាប់ដែលធានាឯករាជ្យភាពរបស់តុលាការ និងនីតិរដ្ឋដែលជាគ្រឹះសីមារបស់ប្រជាធិបតេយ្យ និងការការពារ-សិទ្ធិមនុស្ស។ ដោយសារហេតុផលអស់ទាំងនេះ រដ្ឋសភាមានសារៈសំខាន់ណាស់សម្រាប់ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

*" ជាគំនិតមួយដ៏ឧត្តុងឧត្តម ប្រជាធិបតេយ្យមានបំណងជាពិសេសរក្សា និង លើកកំពស់សេចក្តីថ្លៃថ្នូរ និង សិទ្ធិជាមូលដ្ឋានរបស់បុគ្គលម្នាក់ៗ ដើម្បីសម្រេចបានយុត្តិធម៌សង្គម ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់សហគមន៍ ពង្រឹងភាពស្អិតជាប់គ្នារបស់សង្គម ធ្វើឱ្យប្រសើរឡើងដល់ភាពស្ងប់ស្ងាត់របស់ជាតិ ព្រមទាំងបង្កើតបរិយាកាសមួយដែលអំណោយផលដល់សន្តិភាពអន្តរជាតិ។ ក្នុងរូបភាពជារដ្ឋាភិបាលប្រជាធិបតេយ្យជាមធ្យោបាយដ៏ល្អបំផុត ដើម្បីធ្វើឱ្យគោលបំណងទាំងនេះបានសម្រេច។ ប្រជាធិបតេយ្យគឺជាប្រព័ន្ធនយោបាយតែមួយគត់ ដែលមានសមត្ថភាពធ្វើស្វ័យកែតម្រូវ "។*

*សហភាពអន្តរសភា សេចក្តីថ្លែងការណ៍ជាសកល*
*ស្តីពីប្រជាធិបតេយ្យ Cairo Sept 1997 កឋាខ័ណ្ឌទី៣*

# ជំពូកទី ២ ៖

## អ្វីខ្លះជាកាតព្វកិច្ចរបស់រដ្ឋចំពោះសិទ្ធិមនុស្ស?

ជាគោលការណ៍ ទោះបីជាសិទ្ធិមនុស្សអាចត្រូវបានរំលោភដោយបុគ្គល ឬក្រុមណាមួយ ហើយតាមពិត ការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តឡើងដើម្បីប្រឆាំងនឹងទិសដៅសកលភាវូបនីយកម្មដោយតួអង្គមិនមែនរដ្ឋ (ដូចជា សាជីវកម្មឆ្លងដែន ឧក្រិដ្ឋកម្មដែលមានការរៀបចំភេរវកម្មអន្តរជាតិ កងទ័ពព្រៃ និងយោធាប្រតិព័ទ្ធ និងអង្គការអន្តររដ្ឋាភិបាលផងក៏មាន) កាន់តែមានចំនួនច្រើនឡើង នៅក្រោមច្បាប់អន្តរជាតិបច្ចុប្បន្ន *មានតែរដ្ឋទេ ដែលត្រូវបានសន្មត់ថាមានកាតព្វកិច្ចផ្ទាល់ទាក់ទងនឹងសិទ្ធិមនុស្ស*។

ដោយក្លាយទៅជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រដ្ឋត្រូវទទួលយកកាតព្វកិច្ចទូលំទូលាយចំនួនបីគឺ ៖ ភារកិច្ចគោរព ការពារ និងបំពេញ។ នៅពេលដែលតុល្យភាពរវាង-កាតព្វកិច្ច និងភារកិច្ចទាំងនេះ អាចខុសគ្នាទៅតាមទិដ្ឋភាពនៃសិទ្ធិដែល ពាក់ព័ន្ធកាតព្វកិច្ច និងភារកិច្ចទាំងនោះ ជាគោលការណ៍ ភារកិច្ចទាំងនេះ ត្រូវអនុវត្តទៅលើគ្រប់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនិងគ្រប់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ លើសពីនេះទៅទៀត រដ្ឋមានកាតព្វកិច្ចត្រូវផ្តល់ដំណោះស្រាយចំពោះការរំលោភលើសិទ្ធិមនុស្សនៅកំរិតជាតិ។

## តើ "កាតព្វកិច្ចគោរព" មានន័យយ៉ាងដូចម្តេច?

"កាតព្វកិច្ចគោរព " របស់រដ្ឋមានន័យថា រដ្ឋមានកាតព្វកិច្ចត្រូវទប់ស្កាត់ខ្លួនឯងពីការរារាំង រំខាន។ កាតព្វកិច្ចនេះ ហាមប្រាមសកម្មភាពខ្លះៗ ពីសំណាក់រដ្ឋាភិបាលដែលអាចធ្វើឱ្យខូច ខាតដល់ការទទួលបាននូវសិទ្ធិផ្សេងៗ។ ឧទាហរណ៍ សិទ្ធិទទួលបានការអប់រំ មានន័យថា រដ្ឋាភិបាល ត្រូវគោរពសេរីភាពរបស់ឪពុកម្តាយ ក្នុងការបង្កើតសាលាឯកជន និងធានា ដល់ការអប់រំ អំពីសីលធម៌ និងសាសនាដល់កូនៗរបស់គេ ស្របទៅតាមជំនឿរបស់គេផ្ទាល់។

## តើ "កាតព្វកិច្ចការពារ" មានន័យដូចយ៉ាងម្តេចខ្លះ?

"កាតព្វកិច្ចការពារ" តម្រូវឱ្យរដ្ឋការពារបុគ្គលទាំងឡាយប្រឆាំងនឹងការរំលោភបំពាន ពីតួអង្គមិនមែនរដ្ឋ។ ជាថ្មីម្តងទៀត សិទ្ធិទទួលបានការអប់រំ អាចជាឧទាហរណ៍មួយ។ សិទ្ធិកុមារក្នុងការទទួលបានការអប់រំ ត្រូវតែការពារដោយរដ្ឋឱ្យរួចផុតពីការរារាំងរំខាន និងការបញ្ចុះបញ្ចូលពីតតិយជន រាប់ទាំង មាតាបិតា គ្រួសារ គ្រូបង្រៀន និងសាលារៀន សាសនា និកាយ បក្សសម្ព័ន្ធ និងក្រុមហ៊ុនអាជីវកម្ម។ ក្នុងកាតព្វកិច្ចនេះ រដ្ឋទទួលបានការ វាយតម្លៃខ្ពស់មួយផ្នែកធំ។ ឧទាហរណ៍ សិទ្ធិទទួលបូរណភាពបុគ្គល និងសន្តិសុខផ្ទាល់ខ្លួន តម្រូវឱ្យរដ្ឋប្រយុទ្ធ ប្រឆាំងនឹងបាតុភូតរីករាយដាលនៃអំពើហឹង្សាក្នុងគ្រួសារទៅលើស្ត្រី និងកុមារ ទោះបីជាគ្រប់អំពើហឹង្សា ដែលប្តីប្រព្រឹត្តលើប្រពន្ធ ឬឪពុកម្តាយប្រព្រឹត្តលើកូន មិនមែនសុទ្ធតែជាការរំលោភ សិទ្ធិមនុស្សដែលរដ្ឋត្រូវតែទទួលខុសត្រូវនោះក៏ដោយ ក៏ រដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវក្នុងការចាត់វិធានការវិជ្ជមាន ដើម្បីកាត់បន្ថយអំពើ ហឹង្សាក្នុងគ្រួសារ ក្នុងទម្រង់ជាច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ច្បាប់គ្រួសារ ឬច្បាប់រដ្ឋបាល ការបណ្តុះបណ្តាលនគរបាល និងមន្ត្រីតុលាការ ឬការផ្សព្វផ្សាយការយល់ដឹងទូទៅ។

ប្រអប់ទី ៩

## កាតព្វកិច្ចរបស់រដ្ឋចំពោះការគោរព ការការពារ និងការបំពេញៈ ឧទាហរណ៍

### សិទ្ធិរស់រានមានជីវិត

| | |
|---|---|
| ការគោរព | នគរបាលមិនត្រូវយកជីវិតជនសង្ស័យដោយចេតនា ដើម្បីរារាំងជន នោះមិនឱ្យរត់គេចខ្លួន ក្នុងពេលមានបទល្មើសតូចតាច ដូចជាចោរកម្ម ជាដើម ។ |
| ការការពារ | ការវាយប្រហារដែលគំរាមកំហែងដល់អាយុជីវិតដោយបុគ្គលម្នាក់ទៅលើជនដទៃ ( ដូចជា ការប៉ុនប៉ងធ្វើមនុស្សឃាត ) ត្រូវតែជាបទល្មើស ដែលត្រូវផ្តន្ទាទោសស្រប តាមច្បាប់ព្រហ្មទណ្ឌជាតិ ។ នគរបាល ត្រូវ ស៊ើបអង្កេតបទល្មើសនេះឱ្យបានត្រឹមត្រូវ ដើម្បីនាំខ្លួនជនប្រព្រឹត្តបទល្មើសទៅតុលាការដើម្បីកាត់ទោសទៅតាមច្បាប់ ។ |
| ការបំពេញ | អាជ្ញាធរត្រូវចាត់វិធានការតាមផ្លូវច្បាប់ និងផ្លូវរដ្ឋបាលដើម្បីកាត់បន្ថយឱ្យបានច្រើនឡើងៗនូវមរណភាពកុមារ និងមរណភាពប្រភេទផ្សេងៗ ទៀត ដែលបុព្វហេតុនៃមរណភាពនេះអាចត្រូវប្រយុទ្ធប្រឆាំងបាន ។ |

### ការហាមប្រាមអំពើទារុណកម្ម ឬ ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

| | |
|---|---|
| ការគោរព | នគរបាលមិនត្រូវប្រើទារុណកម្មដើម្បីសួរចម្លើយជនជាប់ឃុំឡើយ ។ |
| ការការពារ | អាជ្ញាធរត្រូវចាត់វិធានការតាមផ្លូវច្បាប់ និងវិធានការផ្សេងៗទៀត ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ។ |
| ការបំពេញ | អាជ្ញាធរត្រូវបណ្តុះបណ្តាលមន្ត្រីនគរបាលអំពីរបៀបសួរចម្លើយ ដែលអាចទទួលយកបាន ។ |

### សិទ្ធិបោះឆ្នោត

| | |
|---|---|
| ការគោរព | អាជ្ញាធរមិនត្រូវជ្រៀតជ្រែកក្នុងនីតិវិធីបោះឆ្នោត ហើយត្រូវគោរពលទ្ធផលនៃការបោះឆ្នោត ។ |

| | |
|---|---|
| ការការពារ | អាជ្ញាធរត្រូវរៀបចំឱ្យមានការបោះឆ្នោតដោយសម្ងាត់ ដើម្បីបញ្ចៀសការគំរាមកំហែងពីជនមានអំណាច (ដូចជាអ្នកនយោបាយ មេបក្សសម្ព័ន្ធ ឬ គ្រួសារ ឬ និយោជក) ។ |
| ការបំពេញ | អាជ្ញាធរត្រូវរៀបចំឱ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ហើយធានាថាមានប្រជាពលរដ្ឋចំនួនច្រើនតាមដែលអាចធ្វើបាន អាច ទៅបោះឆ្នោត។ |

### សិទ្ធិខាងសុខភាព

| | |
|---|---|
| ការគោរព | អាជ្ញាធរមិនត្រូវរិតត្បិតលើសិទ្ធិខាងសុខភាពឡើយ ដូចជាតាមរយៈ ការមិនឱ្យមានកូនដោយបង្ខំ ឬការធ្វើពិសោធន៍ផ្នែកពេទ្យ ។ |
| ការការពារ | ការធ្វើកាយវិកលកម្មលើប្រដាប់បន្តពូជស្ត្រី ត្រូវតែហាមឃាត់ និងលុបបំបាត់ ។ |
| ការបំពេញ | ត្រូវមានមន្ទីរពេទ្យគ្រប់គ្រាន់ និងកន្លែងថែទាំសុខភាពសាធារណៈ ផ្សេងៗទៀតត្រូវផ្តល់សេវាដល់មនុស្សគ្រប់រូបឱ្យបានស្មើៗគ្នា ។ |

### សិទ្ធិទទួលបានម្ហូបអាហារ

| | |
|---|---|
| ការគោរព | អាជ្ញាធរមិនត្រូវចាត់វិធានការណាដែលរារាំងដល់សិទ្ធិទទួលបានម្ហូបអាហារគ្រប់គ្រាន់ឡើយ (ឧទាហរណ៍ដូចជា ការបណ្តេញចេញពីដីធ្លីតាមអំពើចិត្ត) |
| ការការពារ | អាជ្ញាធរត្រូវអនុម័តច្បាប់ ឬចាត់វិធានការផ្សេងៗ ដើម្បីទប់ស្កាត់អ្នកមានអំណាច ឬអង្គការផ្សេងៗ កុំឱ្យរំលោភលើសិទ្ធិទទួបានម្ហូបអាហារ (ឧទាហរណ៍ ក្រុមហ៊ុន ដែលធ្វើឱ្យមានជាតិពុលដល់កន្លែងផ្គត់ផ្គង់ទឹក ឬម្ចាស់ដីបណ្តេញកសិករចេញពីដីធ្លី) ។ |
| ការបំពេញ | អាជ្ញាធរត្រូវអនុវត្តគោលនយោបាយនានា ដូចជា ការកែទម្រង់ដីស្រែ ចំការដើម្បីធានាដល់សិទ្ធិទទួលបានម្ហូបអាហារគ្រប់គ្រាន់របស់ប្រជា ពលរដ្ឋ និងធានាថាក្រុមជនដែលងាយរងគ្រោះអាចចិញ្ចឹមខ្លួនឯងបាន ។ |

## តើកាតព្វកិច្ចបំពេញមានន័យដូចម្តេច?

នៅក្រោម "កាតព្វកិច្ចបំពេញ" រដ្ឋត្រូវបានតម្រូវឱ្យចាត់វិធានការវិជ្ជមាន ដើម្បីធានាថា សិទ្ធិមនុស្ស អាចអនុវត្តទៅបាន។ ឧទាហរណ៍ ដូចជា ទាក់ទងនឹងសិទ្ធិទទួលបានការអប់រំ រដ្ឋត្រូវផ្តល់វិធី និងមធ្យោបាយនានា ដើម្បីឱ្យមានការអប់រំនៅថ្នាក់បឋមសិក្សាមានលក្ខណៈជាកាតព្វកិច្ច និងដោយឥតគិតថ្លៃសម្រាប់ជនគ្រប់រូប និងការអប់រំនៅថ្នាក់មធ្យមសិក្សាដោយឥតគិតថ្លៃ ឧត្តមសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំ សម្រាប់មនុស្សពេញវ័យ និងការលុបបំបាត់អនក្ខរកម្ម (រាប់បញ្ចូលទាំងវិធានការផ្សេងៗទៀត មានដូចជា ការបង្កើតឱ្យមានសាលារៀនសាធារណៈឱ្យបានគ្រប់គ្រាន់ ឬជួល ឬ ផ្តល់ប្រាក់ខែដល់គ្រូឱ្យបាន សមរម្យ។

## គោលការណ៍នៃការធ្វើឱ្យសម្រេចបានជាបណ្តើរៗ

គោលការណ៍នៃការធ្វើឱ្យសម្រេចជាបណ្តើរៗ អនុវត្តទៅលើកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋ ក្នុង-ការបំពេញ និងការការពារ។ ឧទាហរណ៍ដូចជា សិទ្ធិខាងសុខភាពមិនអាចធានាបានថាមនុស្សគ្រប់រូបមាន សុខភាពល្អបាននោះទេ។ ប៉ុន្តែ សិទ្ធិនេះ ដាក់កាតព្វកិច្ចឱ្យរដ្ឋបង្កើត និងរក្សាប្រព័ន្ធសុខភាពសាធារណៈដែលជាគោលការណ៍ អាចធានាដល់សិទ្ធិទទួលបានសេវាសុខភាពជាមូលដ្ឋានគ្រប់ៗគ្នា ស្របតាមសមត្ថភាព សេដ្ឋកិច្ច ប្រពៃណីសង្គម និងវប្បធម៌ របស់ប្រទេសរៀងៗខ្លួន និងដោយគោរពតាមបទដ្ឋានអប្បបរមា អន្តរជាតិ។ ការធ្វើឱ្យបានសម្រេចជាបណ្តើរៗ មានន័យថា រដ្ឋាភិបាលគួរតែកំណត់ទិសដៅ និងបទដ្ឋាន ដើម្បីកាត់បន្ថយជាបណ្តើរៗ នូវអត្រាមរណៈភាពរបស់កុមារ បង្កើនចំនួនវេជ្ជបណ្ឌិតតាមអត្រាភាគពាន់នៃចំនួនប្រជាពលរដ្ឋ បង្កើនភាគរយនៃចំនួនប្រជាពលរដ្ឋដែលទទួលបានការចាក់ថ្នាំបង្ការជំងឺឆ្លង ជំងឺរាតត្បាតមួយចំនួន ឬធ្វើឱ្យប្រសើរឡើងទីកន្លែងផ្តល់សេវាសុខភាពមូលដ្ឋានទាំងឡាយ...។ ល។ ជាក់ស្តែង ដោយគ្មានការរំលោភលើកាតព្វកិច្ចបំពេញរបស់រដ្ឋាភិបាល ទៅលើសិទ្ធិខាងសុខភាព ក៏រិតសុខភាព នៅក្នុងប្រទេសក្រីក្រ អាចទាប-ជាងប្រទេសអ្នកមាន។ អវត្តមានទាំងស្រុងនៃវិធានការវិជ្ជមានដើម្បីធ្វើឱ្យប្រសើរឡើង

ដល់ប្រព័ន្ធសុខភាពសាធារណៈ វិធានការដើរថយក្រោយ ឬការផាត់ចេញដោយចេតនាចំពោះក្រុមណាមួយ (ដូចជាស្ត្រី និងក្រុមសាសនា ឬជាតិពន្ធភាគតិច) មិនឱ្យមានសិទ្ធិទទួលបានសេវាសុខភាព អាចបណ្តាលឱ្យមានការ រំលោភសិទ្ធិខាងសុខភាពបាន ។

**ប្រអប់ ១០**

## សិទ្ធិទទួលបានដំណោះស្រាយ
## តាមរយៈសន្ធិសញ្ញាសិទ្ធិមនុស្សនៅថ្នាក់អន្តរជាតិ និងថ្នាក់តំបន់

តាមមាត្រា២ (៣) នៃ CCPR រដ្ឋភាគីត្រូវ "ធានាថា (ក)...ជនណា ដែលសិទ្ធិ ឬសេរីភាពរបស់ខ្លួន.... ត្រូវបានរំលោភ ត្រូវទទួលបានការដោះស្រាយប្រកប ដោយប្រសិទ្ធភាព" ហើយត្រូវធានាថា (ខ) ជនទាំងឡាយណាដែលប្តឹងទាមទារឱ្យមានការដោះ ស្រាយបែបនេះ ត្រូវមាន-សិទ្ធិ "ទទួលបានការកំណត់សម្រេចពីតុលាការមានសមត្ថកិច្ច អាជ្ញាធរនីតិប្រតិបត្តិ ឬពីអាជ្ញាធរនីតិបញ្ញត្តិ ឬ ពីអាជ្ញាធរមានសមត្ថកិច្ចណាផ្សេងទៀត ដែលមានចែងដោយប្រព័ន្ធច្បាប់របស់រដ្ឋ" និងត្រូវ "បង្កើតឱ្យមានលទ្ធភាពទទួលបាន ដំណោះស្រាយតាមផ្លូវតុលាការ" ។

មាត្រា ១៣ នៃអនុសញ្ញាដើម្បីការពារដល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់អឺរ៉ុបចែងថា : "ជនគ្រប់រូប ដែលសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ពួកគេ ដូចមានចែងនៅក្នុងអនុសញ្ញានោះ ត្រូវបាន រំលោភ ត្រូវទទួលបានការដោះស្រាយមួយប្រកបដោយ ប្រសិទ្ធភាពចំពោះមុខអាជ្ញាធរជាតិ..." ។

មាត្រា ២៥ (១) នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់អាមេរិក (ដែលត្រូវបានគេស្គាល់ ផងដែរថាជាកតិកាសញ្ញា San Josė, Costa Rica) កំណត់មធ្យោបាយដោះស្រាយនេះ ជាសិទ្ធិមួយដោយឡែកមួយ : "មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការដោះស្រាយមួយ ដែលសាមញ្ញ និងឆាប់រហ័ស ឬវិធីដោះស្រាយដ៏មាន ប្រសិទ្ធភាពណាមួយផ្សេងទៀត នៅចំពោះមុខតុលាការ ឬសាលាជម្រះក្តីមួយដែលមានសមត្ថកិច្ច ដើម្បីការពារប្រឆាំងនឹងអំពើផ្សេងៗ ដែលរំលោភសិទ្ធិជាមូលដ្ឋានរបស់គេ ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់របស់រដ្ឋ ដែលពាក់ព័ន្ធ ឬដោយអនុសញ្ញានេះ ..." ។

## តើកាតព្វកិច្ចផ្តល់មធ្យោបាយដោះស្រាយនៅថ្នាក់ជាតិ មានន័យយ៉ាងដូចម្តេច?

បន្ថែមទៅលើការទាមទារដ៏សំខាន់នេះ គោលគំនិតពិតៗក្នុងវិស័យសិទ្ធិនេះ តម្រូវឱ្យមានលទ្ធភាពក្នុងការទទួលបានដំណោះស្រាយនៅថ្នាក់ជាតិ ដែលមានដូចជា អាជ្ញាធរតុលាការ នីតិប្រតិបត្តិ នីតិបញ្ញត្តិ ឬ អាជ្ញាធរផ្សេងទៀត នៅពេលដែលសិទ្ធិមួយ ត្រូវបានគេរំលោភ។ ដូច្នេះ ជនគ្រប់រូប ដែលអះអាងថាសិទ្ធិរបស់ខ្លួន មិនទទួលបានការគោរព ត្រូវតែអាចស្វែងរក*មធ្យោបាយ ដោះស្រាយដ៏មានប្រសិទ្ធភាព* នៅចំពោះមុខស្ថាប័នមានសមត្ថកិច្ចក្នុងប្រទេស ដែលមានអំណាចផ្តល់ដំណោះស្រាយត្រឹមត្រូវស្របច្បាប់ ព្រមទាំងមានអំណាចធ្វើឱ្យគេអនុវត្តតាមសេចក្តីសម្រេចរបស់ខ្លួន ដែលជាស្ថាបន័នោះ។

## សិទ្ធិស្វែងរកការជួយដោះស្រាយពីតុលាការខ្ពស់ជាងថ្នាក់ជាតិ

សិទ្ធិស្វែងរកដំណោះស្រាយទៅកាន់តុលាការសិទ្ធិមនុស្សអន្តរជាតិ នៅពេលដែលគ្រប់មធ្យោបាយសម្រាប់ស្វែងរកដំណោះស្រាយនៅថ្នាក់ជាតិ ដែលបានប្រើប្រាស់រួចអស់ហើយនោះ ត្រូវបានទទួលយកតែផ្នែកខ្លះប៉ុណ្ណោះ។ តាមនីតិវិធីទំនើប ដែលបង្កើតឡើងក្រោមអនុសញ្ញាអឺរ៉ុបដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន បុគ្គលទាំងឡាយ អាចដាក់បណ្តឹងឧទ្ធរណ៍ទៅតុលាការសិទ្ធិមនុស្សអចិន្ត្រៃយ៍របស់អឺរ៉ុប ដែលការវិនិច្ឆ័យរបស់តុលាការនេះជាប់កាតព្វកិច្ចខាងផ្លូវច្បាប់។ បញ្ញត្តិត្រូវបានបង្កើតឡើងដើម្បីផ្តល់សិទ្ធិឱ្យបុគ្គលទាំងឡាយអាចដាក់ញត្តិប្តឹងតវ៉ា ទៅតុលាការសិទ្ធិមនុស្សអន្តរជាតិ ស្របតាមអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់អាមេរិក ប៉ុន្តែបច្ចុប្បន្ននេះ សិទ្ធិនេះមិនអាចប្រើបានទៀតទេ នៅក្រោមសន្ធិសញ្ញាអង្គការសហប្រជាជាតិ ។(សំរាប់ជាព័តិមានលំអិត សូមមើលជំពូកទី ៥ និងទី៩)។

## សិទ្ធិទទួលបានសំណងព្យសនកម្ម

សិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព មានន័យជាប្រយោលថា ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស មានសិទ្ធិទទួលបានសំណងពីព្យសនកម្មដែលបានទទួលរង។ ដូច្នេះកាតព្វកិច្ចរបស់រដ្ឋ ត្រូវនាំយកមកកាត់ទោសតាមច្បាប់ ជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភនេះ រួមទាំងមន្ត្រីសាធារណៈ ឬភ្នាក់ងាររដ្ឋ ហើយត្រូវចាត់វិធានការផ្សេងៗ ដើម្បីទប់ស្កាត់កុំឱ្យមានការរំលោភនេះកើតមានឡើងជាថ្មីទៀត។ ប្រអប់ទី ១១ រាយបញ្ជីទម្រង់ផ្សេងៗនៃការសងជម្ងឺចិត្ត។

**បអប់ ១១**

**សិទ្ធិជនរងគ្រោះក្នុងការទទួលសំណងព្យសនកម្ម
បន្ទាប់ពីមានការរំលោភលើសិទ្ធិមនុស្ស :**

**បដិទាន:** ការដោះលែងអ្នកជាប់ឃុំឃាំងឱ្យរួចខ្លួនវិញ ការធ្វើឱ្យទ្រព្យសម្បត្តិដូចស្ថានភាព ឡើងវិញ ។

**ការធ្វើឱ្យពេញចិត្ត:** ធ្វើការសុំទោសជាសាធារណៈ គណៈកម្មការរកការពិត ការស៊ើបអង្កេតលើឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកប្រព្រឹត្តការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។

**ការស្តារនីតិសម្បទា:** វិធានការផ្នែកច្បាប់ វេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងផ្នែកសង្គមផ្សេងៗទៀត ដើម្បីជួយសង្គ្រោះឱ្យសះស្បើយឡើងវិញ ឧទាហរណ៍ បង្កើតមជ្ឈមណ្ឌលសម្រាប់ស្តារនីតិសម្បទា សម្រាប់អ្នកដែលរងគ្រោះដោយការធ្វើទារុណកម្ម ។

**ការសងជំងឺចិត្ត:** ការចេញសងការខូចខាតផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ។

**ធានាថាមិនមានការកើតឡើងវិញ:** ធ្វើការកែប្រែផ្នែកច្បាប់រដ្ឋបាល វិធានការដាក់វិន័យ ។

## មធ្យោបាយដោះស្រាយចំពោះការរំលោភសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

បទបញ្ញត្តិទាំងឡាយថែងអំពីសិទ្ធិទទួលបានមធ្យោបាយដោះស្រាយ ដែលបានរៀបរាប់ខាងលើ (សូមមើលប្រអប់ទី ១០) និយាយយោងជាចម្បងទៅលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ ចំណែកឯសន្ធិសញ្ញាដែលទាក់ទង ទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចជា កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) និងធម្មនុញ្ញសង្គមអឺរ៉ុប មិនមានបទបញ្ញត្តិស្រដៀងគ្នានេះទេ។ មូលហេតុគឺថា ការវិនិច្ឆ័យនៅថ្នាក់ជាតិ និងអន្តរជាតិ ទៅលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅតែចោទជាសំណួរនៅឡើយពីសំណាក់រដ្ឋាភិបាលជាច្រើន និងពីសំណាក់អ្នកប្រាជ្ញខាងសិទ្ធិមនុស្សផងដែរ ។ ភាពខុសគ្នារវាងសិទ្ធិមនុស្សទាំងពីរប្រភេទនេះ កើតមាននៅពេលមានការពិភាក្សាដេញដោលអំពីមនោគមវិជ្ជានៅក្នុងសម័យសង្គ្រាមត្រជាក់ ។ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅពេលនោះ ត្រូវបានគេយល់យ៉ាងងាយថាជាសិទ្ធិ "អវិជ្ជមាន" សុទ្ធសាធ ដែលមានទិសដៅប្រឆាំងនឹងការជ្រៀតជ្រែករបស់រដ្ឋាភិបាល ចំណែកឯសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានគេមើលឃើញថាជា "សិទ្ធិជាកម្មវិធី" ពោលគឺជាការទាមទារខាងនយោបាយ ដែលតម្រូវឱ្យមានវិធានការវិជ្ជមានពីរដ្ឋ ដែលមានគោលបំណងជាតួយ៉ាង ធានាឱ្យមានការងារធ្វើសុខភាពល្អ និងសន្តិសុខសង្គមពេញលេញចំពោះមនុស្សគ្រប់រូប ។ "សិទ្ធិជាកម្មវិធី" ទាំងនេះ ត្រូវបានចាត់ទុកថា មិនអាចអនុវត្តបានដោយតុលាការបានទេ។

តុលាការលើសពីថ្នាក់ជាតិ ដូចជាតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប ឬ តុលាការអន្តរសិទ្ធិមនុស្សរបស់អាមេរិក បានចេញសេចក្តីសម្រេចថា រដ្ឋទាំងឡាយត្រូវចាត់វិធានការដើម្បីធានាឱ្យមានការគោរពដល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ឧទាហរណ៍ រដ្ឋត្រូវបង្កើតប្រព័ន្ធតុលាការមួយដែលមានសមត្ថភាពបំពេញកាតព្វកិច្ច ក្នុងការធានាឱ្យមាន

ការកាត់ក្តីដោយយុត្តិធម៌នៅក្នុងរយៈពេលសមហេតុផលមួយ។ ក្នុងករណីមានការចោទប្រកាន់អំពីការធ្វើទារុណកម្ម ការបាត់ខ្លួនដោយបង្ខំ ឬការសម្លាប់ក្រៅច្បាប់ រដ្ឋត្រូវស៊ើបអង្កេតផ្ទៃក ឧក្រិដ្ឋកម្មឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីនាំជនប្រព្រឹត្តបទល្មើស ទៅកាត់ទោសតាមច្បាប់ និងផ្តល់សំណងជំងឺចិត្ត ឬផ្តល់សំណងព្យសនកម្មផ្សេងៗទៀតដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ។

យន្តការដូចគ្នានេះ ក៏អាចបង្កើតផងដែរ សម្រាប់បញ្ហាទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ។ ដូចបានបញ្ជាក់ពីខាងលើ តុលាការអន្តរជាតិមានសមត្ថភាព-អាចធ្វើការសម្រេចតាមនីតិវិធីតុលាការ ដែលរដ្ឋមិនបានបំពេញតាមកាតព្វកិច្ចវិជ្ជមានរបស់ខ្លួន ទាក់ទងនឹងវិស័យសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ឧទាហរណ៍ ដូចជាកាតព្វកិច្ចរៀបចំឱ្យមានប្រព័ន្ធតុលាការឱ្យស្របទៅតាមកិច្ចធានា ជាអប្បបរមាដែលមានចែងនៅក្នុងមាត្រា ៦ នៃអនុសញ្ញាអឺរ៉ុប ដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាន (សិទ្ធិទទួលបាន ការជំនុំជម្រះដោយយុត្តិធម៌ )។ ដូច្នេះ គេអាចអះអាងបានថា តុលាការដដែលនេះ អាចនឹងត្រូវបានផ្តល់ដើម្បីសម្រេចថាតើរដ្ឋបានបំពេញកាតព្វកិច្ចវិជ្ជមានរបស់ខ្លួន ក្នុងការរៀបចំប្រព័ន្ធសាលា ស្របទៅតាមការធានាជាអប្បបរមានូវសិទ្ធិទទួលការអប់រំ ដូចមានចែងក្នុងមាត្រា ១៣ និង ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ CESCR ដែរឬទេ ? ឬថាតើប្រព័ន្ធ សុខភាពសាធារណៈរបស់រដ្ឋនោះស្របទៅតាមការធានា ជាអប្បបរមានូវសិទ្ធិទទួលបានសុខភាពផ្លូវចិត្ត និងផ្លូវកាយក្នុងកំរិតខ្ពស់បំផុត ដូចមានចែងនៅក្នុងមាត្រា ១២ នៃ CESCR ដែរឬទេ ?

ប៉ុន្តែ ស្ទើរតែពុំទាន់មានតុលាការអន្តរជាតិណាមួយនៅឡើយទេ ដែលត្រូវបានផ្តល់អាណត្តិការងារ ឱ្យធ្វើការវិនិច្ឆ័យលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ មានការលើកលែងតែមួយ គឺតុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស ដោយអនុលោមតាមមាត្រា ១៩ (៦

) នៃពិធីសារបន្ថែមឆ្នាំ ១៩៨៨ នៃអនុសញ្ញាអាមេរិក ស្តីពីសិទ្ធិមនុស្ស ក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានអនុញ្ញាតឱ្យធ្វើការសម្រេចលើពាក្យបណ្តឹងជាលក្ខណៈបុគ្គល ដែលទាក់ទងទៅនឹងសិទ្ធិទទួលការអប់រំ និងសិទ្ធិរៀបចំបង្កើតសហជីព ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសិទ្ធិមនុស្សសម្រាប់ប្រទេស Bosnia និង Herzegovina ដែលអនុលោមតាមឧបសម្ព័ន្ធ ៦ នៃកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ ១៩៩៥ នៅ Dayton បានចេញសេចក្តីសម្រេចក្នុងករណីជាច្រើនទាក់ទង នឹងការរើសអើងជាក់ស្តែង ឬការចោទប្រកាន់អំពីការរើសអើង ក្នុងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ផ្សេងៗមួយចំនួន ។ ទោះបីជា សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស ធ្វើឡើងនៅទីក្រុង Vienna នៅឆ្នាំ ១៩៩៣ បានសម្រេចបង្កើនល្បឿនការរៀបចំសេចក្តីព្រាងពិធីសារបន្ថែមមួយសម្រាប់កតិកា សញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីកំណត់សិទ្ធិឱ្យបុគ្គលអាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក៏ដោយ (ដែលជាស្ថាប័នមានតែអ្នកជំនាញដូចតុលាការ ដូចគ្នាទៅនឹងស្ថាប័នឃ្លាំមើលសិទ្ធិសញ្ញារបស់អង្គការសហប្រជាជាតិដែរ) ក៏មានរដ្ឋាភិបាលជាច្រើនកំពុងតែរារាំងដល់ការបង្កើតដ៏មានសារៈសំខាន់នេះ ។

**ប្រអប់ទី ១២**

### សមត្ថកិច្ចរបស់តុលាការក្នុងស្រុក(ជាតិ) នៅក្នុងវិស័យ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ : ឧទាហរណ៍

នៅក្នុងប្រទេសខ្លះ តុលាការក្នុងស្រុកត្រូវបានផ្តល់អំណាចក្នុងការសម្រេចលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ ប្រព័ន្ធយុត្តិសាស្ត្រនៅប្រទេសអាហ្វ្រិកខាងត្បូងផ្តល់ជាឧទាហរណ៍ សមហេតុផលមួយ ដែលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានដូចជាសិទ្ធិទទួលបាន ម្ហូបអាហារ សិទ្ធិទទួលបានការថែទាំសុខភាព និងសិទ្ធិមានផ្ទះសម្បែង ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ គឺអាចនឹងត្រូវបានដាក់ឱ្យអនុវត្តដោយតុលាការ ។

នៅក្នុងរឿងក្តី Grootboom (រវាងរដ្ឋាភិបាល នៃសាធារណៈរដ្ឋអាហ្វ្រិកខាងត្បូងទល់នឹង Irene Grootboom និងអ្នកដទៃទៀត CCT ១១/00) តុលាការធម្មនុញ្ញ បានសម្រេចទុកជាឧទាហរណ៍។ រដ្ឋាភិបាលអាហ្វ្រិកខាងត្បូង បានប្តឹងឧទ្ធរណ៍រឿងក្តីនេះ នៅពេលដែលតុលាការជាន់ខ្ពស់ ទីក្រុងខេប បញ្ជាឱ្យខ្លួនផ្តល់ជម្រក (តង់ បង្គន់ចល័ត ការផ្គត់ផ្គង់ទឹកទៀងទាត់ ) ដល់កុមារ និងឪពុកម្តាយមួយក្រុមដែលគ្មានផ្ទះសម្បែង ។ ក្រុមនេះបានរស់នៅក្នុងជម្រកមិន ផ្លូវការមួយដែលមានទឹកលិចនៅពេលភ្លៀងធ្លាក់ បន្ទាប់មកក្រុមនេះ ក៏បានរើទៅកន្លែងមួយផ្សេងទៀត ដែលនៅទីនោះ ពួកគេត្រូវបានគេបណ្តេញចេញ ហើយខ្ទមដ៏កំសត់របស់ពួកគេ ត្រូវបានដុតបំផ្លាញចោលអស់ ។ ក្រុមនេះក៏លែងមានផ្ទះសម្បែង សម្រាប់រស់នៅទាំងស្រុង ពីព្រោះលំនៅដ្ឋានដើមរបស់ពួកគេត្រូវបានអ្នកដទៃចូលមកកាន់កាប់អស់ ដូច្នេះ ពួកគេក៏ទៅរស់នៅជាជនអនាធិបតេយ្យ នៅលើទីលានកីឡា។ ក្រុមនេះក៏ដាក់ពាក្យបណ្តឹង ទៅតុលាការជាន់ខ្ពស់ ទាមទារសិទ្ធិទទួលបានផ្ទះសម្បែង និងសិទ្ធិកុមារ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ពាក្យបណ្តឹងទាមទារសិទ្ធិមានផ្ទះសម្បែង ត្រូវបរាជ័យ ព្រោះតុលាការយល់ឃើញថា រដ្ឋបានចាត់វិធានការ "សមហេតុផល " ដើម្បីឆ្ពោះទៅរកការធ្វើឱ្យសម្រេចបាន នូវសិទ្ធិនេះជាបណ្តើរៗតាម "ធនធានដែលរដ្ឋមាន" ។ ប៉ុន្តែ តាមស្មារតីនៃរដ្ឋធម្មនុញ្ញ ដែល-ធានាដល់សិទ្ធិមានទីជម្រករបស់កុមារ និងស្របតាមផលប្រយោជន៍ល្អបំផុតសម្រាប់កុមារ តុលាការក៏បានកំណត់ថាកុមារ និងឪពុកម្តាយរបស់គេមានសិទ្ធិទទួលបានជម្រក ដែលត្រូវផ្តល់ដោយរដ្ឋ ។

គេអាចត្រូវការពេលវេលាជាច្រើនឆ្នាំ ដើម្បីអះអាងថា សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌នេះ គឺ មិនមាន ហេតុផលណាដែលត្រូវបដិសេធឡើយ ដោយសារតែបញ្ហាកើតមានជាបន្តបន្ទាប់ដូចតទៅ : រដ្ឋាភិបាលបដិសេធមិនអនុញ្ញាតឱ្យតុលាការក្នុងប្រទេស និងអន្តរជាតិធ្វើការវិនិច្ឆ័យលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានការវិនិច្ឆ័យពាក់ព័ន្ធតិចតួច ដោយតុលាការ ហើយអង្គហេតុនេះ យ៉ាងហោចណាស់ត្រូវបានចាត់ទុកជាភស្តុតាងដែលថា សិទ្ធិទាំងនេះ មិនមានលក្ខណៈសម្បត្តិត្រូវដោះស្រាយតាមផ្លូវតុលាការ ឬក៏មានលក្ខណៈ សម្បត្តិត្រូវដោះស្រាយតាមផ្លូវតុលាការតិចជាង សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

# ជំពូកទី ៣៖
# លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ

## ការកកើតឡើងនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ បានកើតឡើងក្នុងសតវត្សទី ១៩ នៅពេលដែលច្បាប់អន្តរជាតិបានបង្កើត ឱ្យមានឡើងនូវលទ្ធិមួយ ដែលនៅក្នុងនោះ "ការធ្វើអន្តរាគមន៍ផ្នែកមនុស្សធម៌" ត្រូវបានគេយល់ថា មានភាពស្របច្បាប់ នៅក្នុងករណីទាំងឡាយណាដែលរដ្ឋមួយបានប្រព្រឹត្តដោយផ្ទាល់នូវអំពើសោកនាដកម្ម ដែល "ធ្វើឱ្យរន្ធត់តក់ស្លុតដល់មនសិការនៃមនុស្សជាតិ"។ ក្រោយមកទៀត ឥទ្ធិពលរបស់ចលនាកាកបាទក្រហម និង ការបង្កើតឡើងនូវអង្គការពលកម្មអន្តរជាតិ (ILO) នៅឆ្នាំ ១៩១៩ បាននាំទៅរកការបង្កើតឡើងជាបន្តបន្ទាប់ នូវសន្និសញ្ញាទីក្រុងហ្សឺណែវ[៦] និងបណ្តាសន្និសញ្ញាអន្តរជាតិដំបូងៗគេ ដែល-បង្កើតឡើងសម្រាប់ការពារកម្មករ ធ្វើការក្នុងផ្នែកឧស្សាហកម្ម ពីការកេងប្រវ័ញ្ចដ៏ធ្ងន់ធ្ងរ និងដើម្បីធ្វើឱ្យប្រសើរឡើងដល់លក្ខខណ្ឌការងាររបស់ពួកគេ។ សន្និសញ្ញានានាស្តីពីជនជាតិភាគតិចដែលបានបង្កើតឡើង ក្រោយសង្គ្រាមលោកលើកទី១ បានប្រឹងប្រែងការពារសិទ្ធិជនភាគតិចជាតិពន្ធ និងដែលមានភាសាផ្សេងគ្នា ហើយដែលជួនកាលត្រូវបានគេយល់ថាជាដើមហេតុ

[៦] សម្រាប់ព័ត៌មានបន្ថែម ស្តីពីអនុសញ្ញាទីក្រុងហ្សឺណែវ និង ច្បាប់មនុស្សធម៌ សូមមើល *ការគោរពច្បាប់មនុស្សធម៌អន្តរជាតិ: សៀវភៅសំរាប់សមាជិកសភា* IPU ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៩៩

ដែលនាំឱ្យមានលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសម័យទំនើប។ ប៉ុន្តែ បើនិយាយឱ្យពិតទៅ សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សមុនគេបង្អស់ ដែលត្រូវបានអនុម័តឡើងនៅក្នុងឆ្នាំ ១៩២៦ ហើយបានចូលជាធរមាននៅឆ្នាំបន្ទាប់ គឺសន្ធិសញ្ញាស្តីពីទាសភាព។

## កម្រងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស

ដោយមានការបង្កើតឡើងនូវអង្គការសហប្រជាជាតិ នាឆ្នាំ ១៩៤៥ "*ការលើកកំពស់ និង-ការជំរុញឱ្យ មានការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន សម្រាប់មនុស្សគ្រប់រូប ដោយគ្មានការរើសអើងជាតិសាសន៍ ភេទ ភាសា ឬសាសនា*"[៧] បានក្លាយជាគោលដៅជាមូលដ្ឋានមួយ ក្នុងចំណោមគោលដៅជាច្រើន ដែលសហគមន៍អន្តរជាតិបានខំស្វះស្វែង។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨) ផ្តល់នូវការបកស្រាយដ៏តឹងរឹង ដំបូងគេមួយទៅលើពាក្យ "សិទ្ធិមនុស្ស" ដូចដែលត្រូវបានប្រើនៅក្នុងធម្មនុញ្ញនោះ ហើយបើទោះបីជាវាមិនត្រូវបានគេរៀបចំជាសេចក្តីព្រាង ឬអនុម័តឱ្យក្លាយជាលិខិតុបករណ៍មានប្រសិទ្ធភាពផ្លូវច្បាប់ក៏ដោយ ក៏សេចក្តីប្រកាសដែលចំណាស់ច្រើនជាង ៥០ ឆ្នាំមកហើយនោះ អាចត្រូវបានចាត់ទុកថា ជាស្តង់ដាទូទៅមួយស្តីពីសិទ្ធិមនុស្ស នាពេលបច្ចុប្បន្ននេះ។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តក្នុងរយៈពេលពីរឆ្នាំ ក៏ប៉ុន្តែត្រូវចំណាយពេលជាង ២០ឆ្នាំ ដើម្បីព្រមព្រៀងគ្នាលើអត្ថបទនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (CCPR) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR)។ បន្ទាប់ពីចំណាយពេល ៦ ឆ្នាំ ក្នុងការរៀបចំសេចក្តីព្រាងកតិកាសញ្ញាទាំងពីរនេះ ត្រូវបានបញ្ចប់នៅក្នុងគណៈកម្មការមនុស្សអង្គការ

[៧] ធម្មនុញ្ញអង្គការសហប្រជាជាតិ ផ្នែកទី ១ មាត្រា ១ កថាខណ្ឌទី ៣។

សហប្រជាជាតិនៅឆ្នាំ ១៩៥៤ ក៏ប៉ុន្តែ មហាសន្និបាតសហប្រជាជាតិ ចំណាយពេល ១២ ឆ្នាំថែមទៀត ដើម្បីធ្វើការអនុម័តលើកតិកាសញ្ញាទាំងនោះ។ វាស៊ីពេល ១០ ឆ្នាំបន្ថែមទៀត រហូតដល់ទទួលបានលិខិតុបករណ៍នៃការផ្តល់សច្ចាប័នជាចាំបាច់ចំនួន ៣៥ ហើយនៅទីបញ្ចប់ កតិកាសញ្ញាទាំងពីរ បានចូលជាធរមាន (នៅឆ្នាំ ១៩៧៦)។ មានតែសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ហើយនិងកតិកាសញ្ញាទាំងពីរនេះតែប៉ុណ្ណោះទេ ដែលជាលិខិតុបករណ៍សិទ្ធិមនុស្សទូទៅរបស់អង្គការសហប្រជាជាតិ។ ដោយបូកផ្សំជាមួយពិធីសារ-បន្ថែមចំនួនពីរទៀតរបស់ CCPR (១៩៦៦ និង ១៩៨៩) លិខិតុបករណ៍ទាំងនេះជាធម្មតា ត្រូវបានគេចាត់ទុកថាជា "កម្រងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស"។

*"សេចក្តីប្រកាស គឺជាឯកសារដែលគ្មានកាលកំណត់ និងដ៏មានឥទ្ធិពល ដែលទាក់ទាញឱ្យមានសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅពីមនុស្សជាតិ ដើម្បីរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ សមភាព និងសន្តិសុខ។ សេចក្តីប្រកាសនេះ ផ្តល់នូវស្តង់ដាអប្បបរមាផ្សេងៗ និងបានជួយ កែប្រែបញ្ហាសីលធម៌ ទាំងឡាយ ឱ្យក្លាយទៅជាក្របខ័ណ្ឌដែលមានប្រសិទ្ធភាព ផ្លូវច្បាប់..."។*

*Sergio Vieira de Mello*
*អតីតឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស*
*សារដែលបានថ្លែងនៅក្នុងឱកាសទិវាសិទ្ធិមនុស្ស ១០ ធ្នូ ឆ្នាំ ២០០២។*

**ប្រអប់ ១៣**

## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

ក្រោមការដឹកនាំរបស់ឥស្សរជនដ៏ឧត្តុង្គឧត្តម ដូចជាលោកស្រី Eleanor Roosevelt លោក René Cassin និង លោក Charles Malik គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានទទួលជោគជ័យ ក្នុងការតាក់តែងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សតែក្នុងរយៈពេលពីរឆ្នាំប៉ុណ្ណោះ។ សេចក្តីប្រកាសនេះ ត្រូវបានអនុម័តដោយមហាសន្និបាត នៅថ្ងៃទី ១០ ធ្នូ ឆ្នាំ ១៩៤៨។

សេចក្តីប្រកាសនេះមានចែងអំពីសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងសិទ្ធិរបស់ជនគ្រប់រូប "ក្នុងការទទួលបាននូវសណ្តាប់ធ្នាប់សង្គម និងអន្តរជាតិដែលនៅក្នុងនោះសិទ្ធិ និងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ អាចត្រូវធ្វើឱ្យសម្រេចបានយ៉ាងពេញលេញ "។ ទោះបីជាសេចក្តីប្រកាសនេះ មិនមែនជាឯកសារដែលមានប្រសិទ្ធភាពផ្លូវច្បាប់ ហើយរដ្ឋសង្គមនិយមនានានិងប្រទេសអាហ្វ្រិកខាងត្បូង បានធ្វើអនុបវាទនៅពេលដែលឯកសារនេះត្រូវបានផ្តល់ការអនុម័តក៏ដោយ ក៏សេចក្តីប្រកាសនេះ បានទទួលភាពរុងរឿងទាំងផ្នែកសីលធម៌ និងផ្នែកនយោបាយ ទៅជាលិខិតុបករណ៍ដែលមានអំណាចធំធេងមួយ ដោយសំដែងពីការយល់ដឹងរបស់អង្គការសហប្រជាជាតិ ទៅលើវិស័យសិទ្ធិមនុស្ស។ បច្ចុប្បន្ននេះ សេចក្តីប្រកាសនេះ បានដើរតួនាទីជាប្រព័ន្ធមូលដ្ឋានគ្រឹះដ៏រឹងមាំនៃធម្មនុញ្ញ ដើម្បីការពារដល់សិទ្ធិមនុស្ស (សូមមើលជំពូកទី៨)។ សេចក្តីប្រកាសនេះ រួមជាមួយនិងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (CCPR) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) និងពិធីសារបន្ថែមពីរទៀតរបស់ CCPR បង្កើតបានជាក្រមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។

## សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ

ក្រមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ត្រូវបានដាក់បន្ថែមដោយមានលិខិតុបករណ៍ជាប់កាតព្វកិច្ចជាក់លាក់មួយចំនួនថែមទៀត។ សន្ធិសញ្ញាខ្លះត្រូវបានស្ថិតក្រោមការត្រួតពិនិត្យដោយស្ថាប័នឃ្លាំមើលនានា ហើយរួមជាមួយនិងកតិកាសញ្ញាចំនួនពីរទៀត បង្កើតបានជាលិខិតុបករណ៍ពេញលេញ ដែលជាធម្មតា ត្រូវបានគេនិយាយយោងសំដៅថាជាសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ (សូមមើលជំពូកទី ៥)។ លិខិតុបករណ៍បន្ថែមទាំងនេះរួមមាន :

អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ (CERD អនុម័ត នៅឆ្នាំ ១៩៦៥ ចូលជាធរមាននៅឆ្នាំ ១៩៦៩)

អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW អនុម័តនៅឆ្នាំ ១៩៧៩ ចូលជាធរមាន នៅឆ្នាំ ១៩៨១) ។

អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT អនុម័តនៅឆ្នាំ ១៩៨៤ ចូលជាធរមាននៅឆ្នាំ ១៩៨៧) ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC អនុម័តនៅឆ្នាំ ១៩៨៩ ចូលជាធរមាននៅឆ្នាំ ១៩៩០) ។

អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ (ត្រូវបានគេស្គាល់ថាជាអនុសញ្ញាស្តីពីកម្មករទេសន្តរប្រវេសន៍ ឬ CMW អនុម័ត នៅឆ្នាំ ១៩៩០ ចូលជាធរមាន នៅឆ្នាំ ២០០៣) ។

ប្រអប់ ១៤

## ការរៀបចំសេចក្តីព្រាង និងការអនុម័តសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍ពាក់ព័ន្ធនានា

គ្រប់សន្ធិសញ្ញាសិទ្ធិមនុស្ស និងសេចក្តីប្រកាសសំខាន់ៗទាំងអស់ ត្រូវបានអនុម័តដោយអង្គមហាសន្និបាតអង្គការសហប្រជាជាតិ ជាអង្គស្ថាប័នតែមួយគត់ ដែលគ្រប់រដ្ឋសមាជិកទាំងអស់ចំនួន ១៩១ ប្រទេស នាពេលបច្ចុប្បន្ននេះ មានវត្តមានតំណាងរបស់ខ្លួន ដោយមានរដ្ឋនីមួយៗមានសម្លេងឆ្នោតមួយ ។ ដំណើររៀបចំសេចក្តីព្រាងតែងតែចាប់ផ្តើម ពីការអនុម័តយកសេចក្តីប្រកាសមួយដែលមិនជាប់កាតព្វកិច្ច ដោយផ្តល់និយមន័យរួមមួយ ហើយបន្ទាប់មក ក៏បន្តធ្វើក្នុងទម្រង់ភារកិច្ចកាន់តែលំបាកឡើង ដើម្បីអភិវឌ្ឍឱ្យទៅជាស្តង់ដា ដែលជាប់កាតព្វកិច្ចខាងផ្លូវច្បាប់ ។

ជាទូទៅ អត្ថបទនៃលិខិតុបករណ៍សិទ្ធិមនុស្ស ត្រូវបានរៀបចំជាសេចក្តីព្រាងដំបូងដោយគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលជាធម្មតាធ្វើប្រតិភូកម្មដំហានដំបូងនៃការរៀបចំសេចក្តីព្រាងនេះ ឱ្យទៅអនុគណៈកម្មការអចិន្ត្រៃយ៍ទទួលបន្ទុកការលើកស្ទួយ និង

ការការពារសិទ្ធិមនុស្ស (សូមមើលជំពូកទី ៨) ឬឱ្យទៅក្រុមការងារមួយ ដែលគណៈកម្មការនេះបង្កើតឡើងសម្រាប់គោលបំណងនោះ (ឧទាហរណ៍ នៅពេលសរសេរតាក់តែង ក្រុមការងារមួយបែបនេះ បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញាមួយស្តីពីការបាត់ខ្លួនដោយបង្ខំ)។ ដំណើរការនៃការរៀបចំសេចក្តីព្រាងនៅក្នុងគណៈកម្មការ និង អង្គការស្ថាប័នដ៏ទៃទៀតរបស់គណៈកម្មការនេះ ជាទូទៅ ចំណាយពេលយ៉ាងហោចណាស់ជាច្រើនឆ្នាំ ហើយអាចត្រូវប្រើពេលរហូតដល់ពីរទសវត្សទៀតផង។

ពេលណាដែលអត្ថបទនោះ ត្រូវបានអនុម័តដោយគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ជាធម្មតា ដំណើរការនៃការរៀបចំសេចក្តីព្រាងនឹងមានល្បឿនលឿនទៅមុខ។ បន្ទាប់មក អត្ថបទនោះត្រូវតែទទួលការអនុម័តយល់ព្រមដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច។ ជាធម្មតា កិច្ចការនេះត្រូវបានធ្វើឡើងតែក្នុងកិច្ចប្រជុំតែមួយគត់ប៉ុណ្ណោះ។ ជាចុងក្រោយ សេចក្តីព្រាងនេះ ត្រូវតែទទួលបានការពិភាក្សា និងអនុម័តជាផ្លូវការដោយ មហាសន្និបាត ហើយជាពិសេស ដោយគណៈកម្មាធិការទីបីទទួលបន្ទុកកិច្ចការសង្គមកិច្ច មនុស្សធម៌ និងវប្បធម៌។ កាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗ មិនមែនជារឿងធម្មតាទេ សម្រាប់គណៈកម្មាធិការទីបីនេះ ក្នុងការរៀបចំសេចក្តីព្រាងអត្ថបទនេះសារជាថ្មី ដោយសឹងតែចាប់ផ្តើមពីដំបូងឡើងវិញ។ ក៏ប៉ុន្តែ កាលពីប៉ុន្មានឆ្នាំថ្មីៗនេះ សេចក្តីសម្រេចផ្នែកនយោបាយសំខាន់ៗ ត្រូវបានធ្វើឡើងនៅក្នុង គណៈកម្មការ ហើយការងារនៅក្នុងមហាសន្និបាត ក៏ត្រូវបានកំរិតឱ្យធ្វើការដោះស្រាយលើបញ្ហាដែលនៅសេសសល់បន្តិចបន្តួច ក្នុងរង្វង់នៃការប្រជុំមួយលើក ឬពីរលើក។

នៅពេលដែលសន្ធិសញ្ញាណាមួយត្រូវបានអនុម័តដោយមហាសន្និបាតដែលជាធម្មតា ដោយការសម្រេចជាឯកច្ឆ័ន្ទនោះ សន្ធិសញ្ញាត្រូវបានបើកឱ្យមានការ *ចុះហត្ថលេខា និងការផ្តល់សច្ចាប័នដោយរដ្ឋសមាជិកនានា*។ សន្ធិសញ្ញានេះនឹងចូលជាធរមាន បន្ទាប់ពីបានទទួលលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកតាមចំនួនកំណត់ជាក់លាក់រួចមក។

## លិខិតុបករណ៍សិទ្ធិមនុស្សដទៃទៀតរបស់អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ និងបណ្តាភ្នាក់ងារជំនាញរបស់ខ្លួនបានអនុម័តលិខិតុបករណ៍សិទ្ធិមនុស្សដទៃទៀតជាច្រើន ដែលផ្តោតលើក្រុមជាក់លាក់នានា ដូចជាស្ត្រី ជនភៀសខ្លួន ជនបរទេស និងជនគ្មានរដ្ឋ ជនជាតិភាគតិច និងជនជាតិដើមភាគតិច អ្នកជាប់ពន្ធនាគារ ជនមានពិការភាព កុមារ នីតិជន និងជនរងគ្រោះដោយសារឧក្រិដ្ឋកម្មជាដើម។ លិខិ-តុបករណ៍ជាសកលបន្ថែមទៀត ដោះស្រាយទៅលើការរំលោភសិទ្ធិមនុស្សចម្បងៗ ដូចជាទាសភាព ទារុណកម្ម ការបាត់ខ្លួនដោយបង្ខំ អំពើប្រល័យពូជសាសន៍ ការងារដោយបង្ខំ និងភាពមិនអត់ឱនផ្នែកសាសនា ឬផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាសិទ្ធិមនុស្សជាក់លាក់ផ្សេងទៀតនៅក្នុងវិស័យអប់រំ ការងារការអភិវឌ្ឍន៍ ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ អាពាហ៍ពិពាហ៍ និងសេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពខាងព័ត៌មាន។

បញ្ជីពិស្តារមួយនៃលិខិតុបករណ៍សិទ្ធិមនុស្ស មានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធទី ៤។

**ប្រអប់ ១៥**

### ជំហាននានា ក្នុងការកំណត់និយមន័យ និងការអនុវត្តនស្តង់ដាសិទ្ធិមនុស្ស

**សេចក្តីប្រកាស : បង្កើតស្តង់ដាមិនជាប់កាតព្វកិច្ច**

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)

សេចក្តីប្រកាសរបស់អាមេរិកស្តីពីសិទ្ធិមនុស្ស (១៩៤៨)

**សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលជាប់កាតព្វកិច្ច**

កតិកាសញ្ញារបស់អង្គការសហប្រជាជាតិ (១៩៦៦-១៩៧៦)

អនុសញ្ញាអឺរ៉ុប សម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (១៩៥០-១៩៥៣)

អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (១៩៦៩-១៩៧៨)

ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ (១៩៨១-១៩៨៦)

**ការអនុវត្តន៍ : ស្ថាប័នឃ្លាំមើលសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនានា**

នីតិវិធីនៃបណ្តឹង

នីតិវិធីធ្វើរបាយការណ៍

នីតិវិធីស៊ើបអង្កេត

ប្រព័ន្ធនៃការធ្វើទស្សនកិច្ចជាទៀងទាត់

ប្រអប់ ១៦

## យុត្តិសាស្ត្រស្តីពីសិទ្ធិមនុស្ស

បណ្តាសន្ធិសញ្ញា និងអនុសញ្ញាស្តីពីសិទ្ធិមនុស្ស គឺជាលិខិតុបករណ៍ដែលរស់រវើក ដែលត្រូវបានបង្កើតឡើងជាប្រចាំ តាមរយៈយុត្តិសាស្ត្ររបស់*តុលាការ និងស្ថាប័នជំនាញអន្តរជាតិ* ដែលទទួលខុសត្រូវឃ្លាំមើលជាអន្តរជាតិ។ ស្ថាប័នទាំងនេះ បានផ្តល់ការបកស្រាយប្រកបដោយថាមពលទៅលើស្តង់ដាចម្បងៗ នៃលិខិតុបករណ៍ទាំងនោះ ទូលំទូលាយលើសពីអត្ថន័យដើមរបស់វា ដោយសម្របសម្រួលបទបញ្ញត្តិនៃលិខិតុបករណ៍ទាំងនោះ ទៅតាមកាលៈទេសៈ បច្ចុប្បន្ន។ ឧទាហរណ៍ ការហាមប្រាមការប្រព្រឹត្ត ឬការដាក់ទោសទណ្ឌបែបអមនុស្សធម៌ និងបន្ថោកបន្ទាប ក្រោម-មាត្រា ៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (១៩៥០) កាលពីដំបូងឡើយ ពុំមានបំណងអនុវត្តទៅលើទម្រង់នៃទណ្ឌកម្មលើរូប កាយបន្តិចបន្តួចឡើយ (ដូចជា ករណីដែលត្រូវបានអនុវត្តនៅតាមសាលារៀននៅចក្រភពអង់គ្លេសជាដើម) ក៏ប៉ុន្តែក្នុងការសម្របខ្លួនទៅតាមអនុសញ្ញា ដែលជាលិខិតុបករណ៍ ដ៏រស់រវើកមួយនោះ តុលាការអឺរ៉ុបទទួលបន្ទុកសិទ្ធិមនុស្ស បានរកឃើញថា តាមមាត្រា ៣ នេះ គ្មានទម្រង់នៃការដាក់ទណ្ឌកម្ម

ណាមួយលើរូបកាយ ត្រូវបានអនុញ្ញាតឡើយ។ ស្រដៀងគ្នានេះដែរ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (សូមមើលជំពូកទី ៥) បានរកឃើញថា សិទ្ធិទទួលបានសន្តិសុខបុគ្គលដែលបានធានានៅក្នុងមាត្រា ៩នៃCCPR ព្រមទាំងសិទ្ធិទទួលបានសេរីភាពនោះ មិនដែលមានបំណងធ្វើការបង្រួមរបួតទៅដល់ធ្វើឱ្យបាត់បង់សេរីភាពជាផ្លូវការ នោះទេ។ នៅក្នុងសេចក្តីសម្រេចជាប្រវត្តិសាស្ត្រមួយ (ករណីរបស់ Delgado Páez *ជាមួយ និង ប្រទេសកូឡុំប៊ី* 195/1985) គណៈកម្មាធិការ បានសម្រេចថា រដ្ឋនានាមិនអាចព្រងើយកន្តើយទៅលើការគំរាមកំហែងដល់សន្តិសុខផ្ទាល់ខ្លួនរបស់ជនមិនត្រូវបានគេឃុំខ្លួន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឡើយ ហើយរដ្ឋទាំងនោះ មានកាតព្វកិច្ចត្រូវចាត់វិធានការសមរម្យ និង សមហេតុផលដើម្បីការពារពួកគេ។

## ជំពូកទី ៤ :

## តើរដ្ឋាភិបាលអាចធ្វើការរិតត្បិតទៅលើសិទ្ធិមនុស្សបានដែរឬទេ?

សិទ្ធិមនុស្សខ្លះ ដូចជា ការហាមប្រាមការធ្វើទារុណកម្ម និងទាសភាព *គឺជាសិទ្ធិត្រូវមានដាច់ខាត*។ ការអនុវត្តន៍បច្ចេកទេសសួរចម្លើយ ដោយធ្វើទារុណកម្ម ដូចដែលបានកំណត់ន័យនៅក្នុងមាត្រា ១ របស់ CAT ដូចជាការឆក់ខ្សែភ្លើង និងវិធីផ្សេងទៀត ដែលបណ្តាលឱ្យមានការឈឺចាប់ខាងផ្លូវកាយ ឬផ្នែកសតិអារម្មណ៍ធ្ងន់ធ្ងរ មិនអាចយកមកធ្វើជាអំណះអំណាងបានទេ ទោះជាផ្អែកលើមូលហេតុណាក៏ដោយ រួមទាំងនៅក្នុងផ្នែកប្រឆាំងភេរវកម្មផងដែរ ដែលក្នុងកាលៈទេសៈបែបនោះត្រូវបានអះអាងថា ជាសេចក្តីត្រូវការចាំបាច់ដើម្បីឱ្យជនជាប់ឃុំផ្តល់ព័តិមានអំពីការវាយប្រហារភេរវកម្ម ដែលជិតនឹងកើតឡើងក្នុងពេលខាងមុខ។

រដ្ឋត្រូវបានអនុញ្ញាតឱ្យទទួលបាន*ការពេញចិត្តមួយកំរិត* ទាក់ទងនឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរព ការពារ និងបំពេញ លើសិទ្ធិមនុស្សភាគច្រើន។ កាតព្វកិច្ចភាគច្រើន ក្នុង-ចំណោមកាតព្វកិច្ចទាំងនេះ គឺស្ថិតនៅក្រោមការធ្វើឱ្យសម្រេចបានដោយជឿន លឿនទៅមុខ ហើយ-ដូច្នេះ ក្នុងការវាយតម្លៃថាតើរដ្ឋមួយបានរំលោភលើកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនដែរឬទេនោះ គេត្រូវតែធ្វើការពិចារណាលើស្ថានភាពពិសេសផ្នែកសង្គមកិច្ច នយោបាយ សេដ្ឋកិច្ច សាសនា និងវប្បធម៌របស់សង្គមនីមួយៗរបស់រដ្ឋនីមួយៗ។ ស្របគ្នានេះដែរ គោលការណ៍ជាសកលរបស់សិទ្ធិមនុស្សអនុវត្ត ជាចម្បងតែទៅលើអត្ថន័យស្នូលរបស់សិទ្ធិមនុស្សប៉ុណ្ណោះ

វិញរដ្ឋាភិបាលវិញ គឺមានអំណាចធំទូលាយសមល្មមក្នុងការអនុវត្តន៏សិទ្ធិមនុស្សសមស្រប ទៅតាមផលប្រយោជន៏ជាតិរបស់ខ្លួន តាមរយៈខរក្សាទុក ខដកហូត ឬខកំណត់ព្រំដែន នានា ហើយនិងតាមរយៈគោលការណ៍នៃការធ្វើឱ្យបានសម្រេចជាបណ្តើរៗ។

## ខ កម្រិតព្រំដែន

កាតព្វកិច្ចគោរពសិទ្ធិមនុស្សជាច្រើន ត្រូវស្ថិតនៅក្រោម ខ ដែលគេហៅថា ខ កម្រិតព្រំដែន។ ការអនុវត្តន៏សេរីភាពផ្នែកនយោបាយ ដូចជាសេរីភាពក្នុងការបញ្ចេញមតិ ការប្រជុំ និងការបង្កើតសមាគម ត្រូវធ្វើឡើងដោយមានកាតព្វកិច្ច និងការទទួលខុសត្រូវ ផ្សេងៗ ហើយហេតុដូច្នេះ ការអនុវត្តន៏សេរីភាពនេះ អាចស្ថិតនៅក្រោមទម្រង់ការ លក្ខខណ្ឌការដាក់កំរិត និងការដាក់ទោសផ្សេងៗ ដើម្បីជាប្រយោជន៏ដល់សន្តិសុខជាតិ បូរណភាពដែនដី ឬសុវត្ថិភាពសាធារណៈ ការទប់ស្កាត់កុំឱ្យមានចលាចល ឬឧក្រិដ្ឋកម្ម ការពារដល់សុខភាពសាធារណៈ ឬសីលធម៌ ឬការពារដល់កិត្តិស័ព្ទ ឬសិទ្ធិ និងសេរីភាព របស់អ្នកដទៃទៀត។ ប្រសិនបើ មនុស្សប្រើប្រាស់សេរីភាពរបស់ខ្លួនមិនត្រឹមត្រូវក្នុងការ និយាយស្តី និងចូលរួមក្នុងបាតុកម្ម ដើម្បីញុះញង់ឱ្យមានការស្អប់ខ្ពើមជាតិសាសន៏ ឬ សាសនា ដើម្បីឃោសនាឱ្យមានសង្គ្រាម ឬដើម្បីញុះញង់អ្នកដទៃឱ្យប្រព្រឹត្តអំពើឧក្រិដ្ឋ រដ្ឋាភិបាលមានកាតព្វកិច្ចមួយក្នុង ការរារាំងដល់ការអនុវត្តន៏សេរីភាពទាំងនេះ ដើម្បីការពារ សិទ្ធិមនុស្សរបស់អ្នកដទៃផ្សេងទៀត។ ប៉ុន្តែ *ទោះជាយ៉ាងណាក៏ដោយការជ្រើសរើសជ្រែក ការដាក់កំរិត និង ការដាក់ទោសណាមួយត្រូវតែស្របទៅតាមច្បាប់ក្នុងប្រទេស ហើយត្រូវ តែមានលក្ខណៈចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងទាំងនោះ និងផលប្រយោជន៏ជាតិ នៅក្នុងសង្គមប្រជាធិបតេយ្យ។ ទោះនៅក្នុងករណីណាក៏ ដោយរដ្ឋត្រូវតែបង្ហាញឱ្យឃើញនូវ ភាពចាំបាច់ក្នុងការដាក់កំរិតទាំងនោះ ហើយចាត់វិធានការទាំងឡាយណាដែលសមាមាត្រ ទៅនឹងគោលបំណង ដែលត្រឹមត្រូវតាមច្បាប់តែប៉ុណ្ណោះ។*

ប្រអប់ ១៧

## សិទ្ធិ សេរីភាព និងការហាមឃាត់នានា ដែលមិនស្ថិតនៅក្រោមការដកហូត ទោះបីជាក្នុងពេលមានសង្គ្រាមក៏ដោយ

### នៅក្រោមមាត្រា ៤ នៃ CCPR

សិទ្ធិរស់រានមានជីវិត

ការហាមប្រាមការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

ការហាមប្រាមអំពើទាសភាព និងភាពជាខ្ញុំបម្រើ

ការហាមប្រាមការឃុំខ្លួន ដោយការជំពាក់បំណុល

សិទ្ធិរួចផុតពីប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

សិទ្ធិទទួលបានការទទួលស្គាល់ថាជាបុគ្គលម្នាក់នៅចំពោះមុខច្បាប់

សេរីភាពខាងគំនិត សម្បជញ្ញៈ និងសាសនា

### នៅក្រោមមាត្រា ១៥ នៃអនុសញ្ញាអឺរ៉ុប សម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

សិទ្ធិរស់រានមានជីវិត លើកលែងតែការស្លាប់ដោយសារសកម្មភាពនៃសង្គ្រាមស្របច្បាប់

ការហាមប្រាមការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប

ការហាមប្រាមអំពើទាសភាព និងភាពជាខ្ញុំបំរើ

សិទ្ធិរួចផុតពីប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

### នៅក្រោមមាត្រា ២៧ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស

សិទ្ធិទទួលបានលក្ខណៈបុគ្គលតាមផ្លូវច្បាប់

សិទ្ធិរស់រានមានជីវិត

សិទ្ធិទទួលបានប្រព្រឹត្តកម្មប្រកបដោយក្តីមេត្តា

- ការហាមប្រាមអំពើទាសភាព
- សិទ្ធិរួចផុតពីប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ
- សេរីភាពខាងគំនិត សម្បជញ្ញៈ និងសាសនា
- សិទ្ធិមានសញ្ជាតិ
- សិទ្ធិចូលរួមក្នុងរដ្ឋាភិបាល
- សិទ្ធិទទួលបានដំណោះស្រាយតាមផ្លូវតុលាការ
- សិទ្ធិមានឈ្មោះ
- សិទ្ធិក្នុងការមានគ្រួសារ
- សិទ្ធិក្នុងការមានកូន

ប្រអប់ ១៨

## ការដាក់កម្រិត ដែលត្រឹមត្រូវតាមច្បាប់

- ខរក្សាទុក
- វិធានការដកហូត ក្នុងករណីមានអាសន្ន
- ហាមប្រាមការប្រើប្រាស់សិទ្ធិមនុស្សដោយមិនត្រឹមត្រូវ
- ខកំណត់ព្រំដែន ត្រូវតែៈ
  - ស្របតាមច្បាប់ក្នុងប្រទេស
  - បំរើឱ្យគោលបំណងដែលត្រឹមត្រូវតាមច្បាប់
  - មានលក្ខណៈសមាមាត្រ

ប្រអប់ ១៩

## ការដាក់កំរិត ដែលត្រឹមត្រូវតាមច្បាប់ : ឧទាហរណ៍មួយចំនួន អំពីយុត្តិសាស្ត្រ

វាគឺជាភារកិច្ចនៃស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ ក្នុងការវាយតម្លៃទៅលើករណីនីមួយៗថាតើទម្រង់នៃការជ្រៀតជ្រែកណាមួយ បំរើឱ្យ *គោលបំណងដែលត្រឹមត្រូវតាមច្បាប់* ដែរឬទេ តើវាផ្អែក

លើ *ច្បាប់ក្នុងប្រទេស* ដែលមានសុពលភាព និងអាចមើល ឃើញជាមុនដែរឬទេ និងមាន *លក្ខណៈសមាមាត្រ* ដែរ ឬទេ។ ឧទាហរណ៍ តុលាការ អឺរ៉ុបទទួលបន្ទុកសិទ្ធិមនុស្សបានបកស្រាយ ខ ដាក់កំរិតព្រំដែនពាក់ព័ន្ធនានានៅក្នុងតុលាការនេះ ក្នុងរបៀបមួយដែលមួយផ្នែក ផ្តល់ឱ្យរដ្ឋាភិបាលនូវការពេញចិត្តក្នុងកំរិតមួយទូលំទូលាយគួរសម រីឯមួយផ្នែកទៀតតម្រូវឱ្យ រដ្ឋាភិបាលទាំងនោះបង្ហាញនូវ *សេចក្តីត្រូវការចាំបាច់បន្ទាន់មួយនៅក្នុងសង្គម* ដើម្បីវិនិច្ឆ័យឱ្យបាន ត្រឹមត្រូវដល់ការរិតត្បិតទាំងនោះ។ ឧទាហរណ៍ តុលាការនេះមិនបានទទួលអំនាស់អំណាងដែលរដ្ឋាភិបាលអៀកឡង់ បានផ្តល់ថា ការហាមប្រាមជាទូទៅលើ ការរួមភេទដោយមនុស្សមានភេទដូចគ្នានៅក្រោមច្បាប់ ព្រហ្មទណ្ឌរបស់អៀកឡង់ មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យមួយដើម្បីការពារសីលធម៌ សាធារណៈនោះទេ ដោយសារនៅតាមសង្គមឯទៀតៗនៃទ្វីបអឺរ៉ុបមិនមានច្បាប់ណាដែលអាចយក មកប្រៀបធៀបបាន នោះវាពុំមានសេចក្តីត្រូវការចាំបាច់បន្ទាន់ណាមួយក្នុងសង្គមសំរាប់ដាក់កំរិត ជ្រាលជ្រៅទៅលើសិទ្ធិឯកជននោះឡើយ។

## ការព្យួរកាតព្វកិច្ចសិទ្ធិមនុស្សក្នុងស្ថានភាពមានអាសន្ន

ក្នុងពេលមានសង្គ្រាម មានកុប្បកម្ម មានគ្រោះមហន្តរាយធម្មជាតិ ឬភាពអាសន្នសាធារណៈ ផ្សេងទៀត (ដូចជា ការវាយប្រហារដោយភេរវករជាដើម) ដែលបង្កឱ្យមានការគំរាមកំហែងធ្ងន់ធ្ងរដល់អាយុជីវិតរបស់ជាតិមួយ រដ្ឋាភិបាលអាចចាត់វិធានការព្យួរ កាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនបាន ប្រសិនបើបំពេញនូវលក្ខខណ្ឌដូចខាងក្រោមនេះ :

- ត្រូវតែប្រកាសដាក់ប្រទេសក្នុងស្ថានភាពមានអាសន្ន
- វិធានការដាក់លាក់ក្នុងការដកហូតសិទ្ធិចេញពីសន្ធិសញ្ញាអន្តរជាតិមួយ ត្រូវតែជូនដំណឹងជាផ្លូវការទៅអង្គការអន្តរជាតិ ដែលមានសមត្ថកិច្ច និងរដ្ឋភាគីឯទៀតៗ
- ការដកហូតសិទ្ធិ ត្រូវបានអនុញ្ញាតតែក្នុងករណីដែលស្ថានការណ៍បានតម្រូវឱ្យតែប៉ុណ្ណោះ
- ការដកហូតសិទ្ធិនេះ ត្រូវលុបចោលវិញភ្លាម នៅពេលដែលស្ថានការណ៍អនុញ្ញាតសិទ្ធិនានា ដែលស្ថិតក្រោមការដកហូតបាន

សិទ្ធិដែលមិនស្ថិតក្នុងចំណោមសិទ្ធិទាំងឡាយណា ដែលមិនអនុញ្ញាតឱ្យដកហូតទេ (សូមមើលប្រអប់ ១៧)។

## ខ.រក្សាទុកចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់អន្តរជាតិ និងថ្នាក់តំបន់

ក្នុងករណីមួយចំនួន រដ្ឋអាចចេញសេចក្តីថ្លែងការណ៍ បន្ទាប់ពីការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការចូលជាសមាជិកលើសន្ធិសញ្ញាមួយ។ សេចក្តីថ្លែងការណ៍បែបនេះ អាចដាក់ចំណងជើងថា "ការរក្សាទុក" "សេចក្តីប្រកាស" "ការយល់ឃើញ" "សេចក្តីប្រកាសបកស្រាយ" ឬ "សេចក្តីថ្លែង ការណ៍បកស្រាយ"។

មាត្រា ១៩ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាបញ្ជាក់ច្បាស់ថា នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកទៅលើសន្ធិសញ្ញាមួយ រដ្ឋអាចសំដែងការរក្សាទុករបស់ខ្លួនបាន ប្រសិនបើ:

១. ការរក្សាទុក មិនត្រូវបានហាមប្រាមដោយសន្ធិសញ្ញានោះ
២. សន្ធិសញ្ញា មិនបានចែងថា មានតែការរក្សាទុកជាក់លាក់ ដែលមិនបានដាក់បញ្ចូលក្នុងការរក្សាទុក ដែលមានបញ្ហាប៉ុណ្ណោះអាចធ្វើបាន ឬ
៣. ក្នុងករណីដែលមិនស្ថិតក្នុងប្រភេទទាំងពីរខាងលើនេះទេ ការរក្សាទុក មិនមាន-វិសមតិភាពទៅនឹងកម្មវត្ថុ និងគោលបំណងរបស់សន្ធិសញ្ញា។

ក្នុងករណីដែលសន្ធិសញ្ញាមិនបានចែងអំពីការរក្សាទុកនេះទេ ហើយការរក្សាទុកនេះ ត្រូវបានបង្កើតឡើង និងបន្ទាប់មក ត្រូវបានផ្សព្វផ្សាយឱ្យបានដឹងនោះ រដ្ឋនានាដែលពាក់ព័ន្ធ មាន-រយៈពេល ១២ ខែ ដើម្បីជំទាស់ទៅនឹងការរក្សាទុកនោះ ដោយគិតចាប់ផ្តើមពីកាលបរិច្ឆេទនៃការជូនដំណឹងនោះ ឬកាលបរិច្ឆេទដែលរដ្ឋនោះ សំដែងការយល់ព្រមរបស់ខ្លួន ទទួលយកការចងកាតព្វកិច្ចដោយសន្ធិសញ្ញានោះ ដោយកាលបរិច្ឆេទមួយណាក៏បានឱ្យតែកើតឡើងក្រោយ គេ (សូមមើលមាត្រា ២០(៥) នៃអនុសញ្ញាទីក្រុងវីយែន ឆ្នាំ ១៩៦៩)។

ប្រសិនបើសន្ធិសញ្ញាមិនបានចែងទេ រដ្ឋអាចដកការរក្សាទុក ឬដកការជំទាស់ទៅនឹងការរក្សាទុកទាំងស្រុង ឬដោយផ្នែកខ្លះនៅពេលណាក៏បាន។

## វិធានការប្រឆាំងភេរវកម្ម និងសិទ្ធិមនុស្ស

*កម្រងអត្ថបទសង្ខេបនៃយុត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិ និងអង្គការថ្នាក់ តំបន់ស្តីពីការការពារសិទ្ធិមនុស្សនៅ ក្នុងអំឡុងពេលប្រឆាំងអំពើភេរវកម្ម* ដែលត្រូវបានផ្សព្វផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) កាលពីខែកញ្ញា ឆ្នាំ ២០០៣ ផ្តល់នូវកម្រងនៃការដកស្រង់ជាច្រើនពីយុត្តិសាស្ត្រនៃស្ថាប័នសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងអង្គការផ្សេងៗទៀត (ជាពិសេស អង្គការតំបន់ អាហ្វ្រិក អាមេរិក និងអឺរ៉ុប)។

*កម្រងអត្ថបទសង្ខេប*នេះបង្ហាញឱ្យឃើញថា អំឡុងពេលសកម្មភាពប្រឆាំងនឹងអំពើភេរវកម្ម បញ្ហាមួយចំនួន ត្រូវបានរកឃើញថាមានការពាក់ព័ន្ធជាពិសេសទៅនឹងបញ្ហាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ បញ្ហាបែបនេះមួយ គឺនិយមន័យនៃពាក្យភេរវកម្ម។ ទោះបីជាពាក្យនេះមិនទាន់ត្រូវបានកំណត់និយមន័យជាក់លាក់ក៏ដោយក៏រដ្ឋនានា បានយល់ព្រមលើធាតុ សំខាន់ៗមួយចំនួននៃនិយមន័យរបស់វារួចទៅហើយ។ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ១៩៩៤ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីថ្លែងការណ៍ស្តីពីវិធានការបំបាត់អពើភេរវកម្មអន្តរជាតិ (A/RES/49/ 60)។ សេចក្តីថ្លែងការណ៍នោះបានលើកឡើងថា អំពើភេរវកម្ម មានរួមបញ្ចូលនូវ "*អំពើឧក្រិដ្ឋដែលមានបំណង ឬដែលធ្វើការគណនាដើម្បីបង្កឱ្យមានភាពភ័យតក់ស្លុត នៅក្នុងចំណោមសាធារណៈជនទូទៅ ក្រុមមនុស្សមួយក្រុម ឬបុគ្គលជាក់លាក់ទាំងឡាយ ដើម្បីគោលបំណងខាងនយោបាយ* " ហើយថែមទាំងបន្ថែមថា អំពើរបៀបនេះ " *ទោះក្នុងកាលៈទេសៈ ណាក៏ដោយ មិនត្រូវយកធ្វើជា*

*អំណោះអំណាងបានទេ ទោះបីជាមានការគិតគូរទៅលើបញ្ហានយោបាយ ទស្សនៈវិជ្ជាមនោគមវិជ្ជា ជាតិសាសន៍ ជាតិពន្ធ សាសនា ឬសារជាតិផ្សេងទៀត ដែលអាចត្រូវបានគេប្រើប្រាស់សំរាប់ធ្វើជាអំណោះអំណាងលើអំពើទាំងនេះនោះ"* ។

បញ្ហាភេរវកម្ម និងសិទ្ធិមនុស្ស បានក្លាយជាបញ្ហាគួរឱ្យបារម្ភជាយូរមកហើយ ចំពោះកម្មវិធី សិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក៏ប៉ុន្តែ ការដោះស្រាយលើបញ្ហានេះកាន់តែមានភាពបន្ទាន់ឡើងបន្ទាប់ពីការវាយប្រហារនៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០១ និងការកើនឡើងនៃអំពើភេរវកម្មនៅទូទាំងពិភពលោក។ នៅក្នុងកិច្ចប្រជុំពិសេសមួយរបស់គណៈកម្មាធិការប្រឆាំងអំពើភេរវកម្មរបស់ក្រុមប្រឹក្សាសន្តិសុខ ជាមួយអង្គការថ្នាក់អន្តរជាតិ ថ្នាក់តំបន់នានា និងអង្គការថ្នាក់អនុតំបន់ជាច្រើន នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០០៣ លោកអគ្គលេខាធិការ កូហ្វីអាណាន់ បានថ្លែងថាៈ

*"ការឆ្លើយតបរបស់យើងចំពោះអំពើភេរវកម្ម ព្រមទាំងកិច្ចខិតខំរបស់យើងក្នុងការរារាំង និងទប់ស្កាត់អំពើនេះ គឺគួរលើកស្ទួយសិទ្ធិមនុស្ស ដែលពួកភេរវជនមានបំណងចង់បំផ្លាញ។ ការគោរព-សិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន និងនីតិរដ្ឋ គឺជាឧបករណ៍ដ៏សំខាន់បំផុតនៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ពោលគឺនៅក្នុងពេលមានភាពតានតឹង មិនត្រូវលះបង់បុព្វសិទ្ធិនេះឡើយ"* ។

ស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិខ្លះ បានសំដែងការព្រួយបារម្ភថា វិធានការប្រឆាំងនឹងអំពើភេរវកម្មអាចរំលោភទៅលើសិទ្ធិមនុស្ស ។ ឧទាហរណ៍ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ និងអ្នកជំនាញការឯករាជ្យ បានថ្លែងនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី១០ របស់ខ្លួន ដែលធ្វើឡើងនៅទីក្រុងហ្សឺណែវ កាលពីខែមិថុនា ឆ្នាំ ២០០៣ ថាៈ

*"ទោះបីជាពួកគេ (អ្នករាយការណ៍ពិសេស និងអ្នកជំនាញការឯករាជ្យនានា) រួបរួមគ្នាដើម្បីថ្កោលទោសអំពើភេរវកម្មក៏ដោយ ក៏ពួកគេបានបង្ហាញកង្វល់យ៉ាងខ្លាំង ទៅលើភាព*

*ចេះតែកើនឡើងជាលំដាប់នូវគោលនយោបាយ ច្បាប់ និងការអនុវត្តនីផ្សេងៗ ដែលបានធ្វើឡើងដោយប្រទេសជាច្រើន ក្នុងនាមការប្រយុទ្ធប្រឆាំងអំពើភេរវកម្មដែលធ្វើឱ្យប៉ះពាល់អវិជ្ជមានដល់ការទទួលបានជាក់ស្តែងនូវសិទ្ធិមនុស្ស ដូចជា សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។*

*ពួកគេផ្តោតការយកចិត្តទុកដាក់ទៅលើគ្រោះថ្នាក់ ដែលមានជាប់ជាមួយនឹងការប្រើប្រាស់ដោយមិនរើសមុខនូវពាក្យ "ភេរវកម្ម " និងការរើសអើងប្រភេទថ្មីមួយ ដែលកើតមានឡើង ។ ពួកគេទាំងនោះមានការសោកស្តាយចំពោះហេតុការណ៍ ដែលថា នៅក្រោមលេសនៃការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម អ្នកការពារសិទ្ធិមនុស្សត្រូវបានគំរាមកំហែង ហើយក្រុមងាយរងគ្រោះនានា បានក្លាយជាគោលដៅ និងត្រូវបានគេរើសអើង ដោយផ្អែកលើមូលដ្ឋាននៃដើមកំណើត និងឋានៈសង្គម សេដ្ឋកិច្ច ជាពិសេស ជនអន្តោប្រវេសន្ត ជនភៀសខ្លួន និង-អ្នកស្វែងរកសិទ្ធិជ្រកកោន ជនជាតិដើម និងជនដែលធ្វើការតស៊ូដើម្បីទាមទារសិទ្ធិលើដីធ្លីរបស់ពួកគេ ឬធ្វើការតស៊ូប្រឆាំងនឹងផលប៉ះពាល់អវិជ្ជមានដោយសារគោលនយោបាយសកលភាវូបនីយកម្មសេដ្ឋកិច្ច "*

នៅក្រោមលក្ខខណ្ឌជាក់លាក់បំផុត អំពើភេរវកម្មអាចវិនិច្ឆ័យត្រឹមត្រូវដល់ស្ថានភាព មាន-អាសន្នដែលសិទ្ធិមួយចំនួនអាច ស្ថិតនៅក្រោមការដកហូត ស្របតាម CCPR និងលិខិតុបករណ៍សិទ្ធិមនុស្សនៅថ្នាក់តំបន់នានា។ ទោះជាយ៉ាងនេះក៏ដោយ នៅក្រោមបញ្ញត្តិដដែលនេះ សិទ្ធិមនុស្សមួយចំនួនមិនត្រូវស្ថិតក្រោមការព្យួរបានទេ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ (សូមមើលប្រអប់ ១៧) ។

តាម CCPR និង លិខិតុបករណ៍សិទ្ធិមនុស្សនៅថ្នាក់តំបន់នានា ការដកហូតសិទ្ធិដទៃទៀតក្រៅពីសិទ្ធិដែលបានរៀបរាប់ខាងលើ ត្រូវបានអនុញ្ញាតឱ្យធ្វើបានតែនៅក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ ពោលគឺត្រូវតែមានលក្ខណៈពិសេស ត្រូវមានពេលកំណត់យ៉ាងច្បាស់លាស់

ទៅតាមទំហំដែលតម្រូវដោយភាពបន្ទាន់បង្ខំនៃស្ថានភាព ស្ថិតក្រោមការត្រួតពិនិត្យយ៉ាងទៀងទាត់ និងស្របតាមកាតព្វកិច្ចទាំងឡាយដូចមានចែងដោយច្បាប់អន្តរជាតិ ហើយមិនត្រូវបង្កឱ្យមានការរើសអើងឡើយ ។ លើសពីនេះទៀត វាតម្រូវឱ្យរដ្ឋជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ឬអង្គការថ្នាក់តំបន់ដែលពាក់ព័ន្ធអំពីបញ្ញត្តិ ដែលត្រូវបានដកហូត និងមូលហេតុនៃការដកហូតទាំងនោះ ។

បន្ថែមលើកាតព្វកិច្ចផ្សេងទៀតរបស់រដ្ឋ ដូចមានចែងដោយច្បាប់អន្តរជាតិ គណៈកម្មការសិទ្ធិមនុស្ស បានរៀបចំបញ្ជីសិទ្ធិផ្សេងៗដែលសិទ្ធិទាំងនោះមិនត្រូវស្ថិតក្រោមការដកហូតឡើយ បន្ថែមលើសិទ្ធិដែលបញ្ជាក់នៅក្នុងមាត្រា ៤ នៃ CCPR ។ សិទ្ធិទាំងនោះ រួមមាន :

ជនគ្រប់រូប ដែលត្រូវបានគេដកហូតសេរីភាពត្រូវតែទទួលបានការប្រព្រឹត្តមកលើខ្លួនដោយគោរពដល់សេចក្តីថ្លៃថ្នូរ ។ ការចាប់ជាចំណាប់ខ្មាំង ការចាប់ពង្រត់ និង-ការឃុំខ្លួន ដែលពុំមានការទទួលស្គាល់ត្រូវបានហាមឃាត់ ។

ប្រជាជនដែលជាជនជាតិភាគតិច ត្រូវទទួលបានការការពារ

ការបណ្តេញចេញដោយខុសច្បាប់ ឬការផ្ទេរប្រជាជនដោយបង្ខំ ត្រូវបានហាមឃាត់ និង

"គ្មានការប្រកាសភាពមានអាសន្ន.... ត្រូវបានយកមកប្រើជាលេស សម្រាប់រដ្ឋភាគីមួយធ្វើការឃោសនា ឱ្យមានសង្គ្រាម ឬជម្រុញឱ្យមានការស្អប់ខ្ពើមទៅលើជនជាតិ ជាតិសាសន៍ ឬសាសនា ដែលបង្កើតជាការញុះញង់នាំឱ្យកើតមានការរើសអើង អរិភាព ឬអំពើហិង្សាបានឡើយ " ។

លើសពីនេះទៀត ដោយហេតុថា សិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវអំឡុង ពេលមានជម្លោះបងាប់អាវុធ ត្រូវបានធានាយ៉ាងជាក់ច្បាស់ ដូចមានចែក្នុងច្បាប់មនុស្សធម៌អន្តរជាតិ នោះគណៈកម្មការសិទ្ធិមនុស្ស បានយល់ឃើញថាគោល ការណ៍នីត្យានុកូលភាព និងនីតិរដ្ឋ តម្រូវឱ្យមានការគោរពចំពោះគោលការណ៍មូលដ្ឋាននៃការជំនុំជម្រះដោយត្រឹមត្រូវ អំឡុងពេល

ស្ថានភាពមានគ្រោះអាសន្ន។ គណៈកម្មការបានសង្កត់ធ្ងន់ថា ចាំបាច់ត្រូវតែប្រកាន់ខ្ជាប់នូវការពារសិទ្ធិទាំងនោះ ដែលត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់ថា ជាសិទ្ធិដែលមិនអាចត្រូវដកហូតបាន ហើយជាសិទ្ធិដែលត្រូវបានការពារដោយការធានាតាមនីតិវិធី រួមទាំងជារឿយៗ ការធានាតាមផ្លូវតុលាការទៀតផង។

តាម CCPR និងលិខិតុបករណ៍សិទ្ធិមនុស្សនៅថ្នាក់តំបន់នានា គោលការណ៍នៃភាពចាំបាច់ និង គោលការណ៍នៃភាពសមាមាត្រ ត្រូវអនុវត្តនៅពេលដែលមានការអនុញ្ញាតជាពិសេស ដើម្បីដាក់កម្រិតព្រំដែនលើសិទ្ធិខ្លះ សម្រាប់តែគោលបំណងជាក់លាក់ត្រឹមត្រូវតាមច្បាប់ និងមានការកំណត់ច្បាស់លាស់ ក្រៅពីស្ថានភាពមានគ្រោះអាសន្ន។ វិធានការដែលបានចាត់ឡើង ត្រូវមានលក្ខណៈសមរម្យ និងមានលទ្ធភាពរំលោភបំពានតិចបំផុតក្នុងការធ្វើឱ្យសម្រេចបាននូវគោលបំណងរបស់ខ្លួន។ ឆន្ទានុសិទ្ធិ ដែលបានផ្តល់ទៅឱ្យអាជ្ញាធរ ដើម្បីធ្វើសកម្មភាពក្នុងវិស័យនោះ មិនត្រូវធ្វើដោយស្រេចអំពើចិត្តនោះទេ ។ នៅគ្រប់ករណីទាំងអស់ គោលការណ៍នៃការមិនរើសអើងត្រូវតែគោរព ហើយកិច្ចប្រឹងប្រែងពិសេសៗ ត្រូវតែធ្វើឡើង ដើម្បីរក្សាការពារដល់សិទ្ធិជនងាយរងគ្រោះនានា។ វិធានការប្រឆាំងអំពើភេរវកម្ម ដែលសំដៅដោយឡែកតែទៅលើក្រុមជនជាតិ ឬសាសនា ជាក់លាក់ណានោះគឺផ្ទុយទៅនឹងគោលការណ៍សិទ្ធិមនុស្ស ហើយអាចបង្កឱ្យមានការងើបឡើង នូវការរើសអើង និងការប្រកាន់ពូជសាសន៍។

# ជំពូកទី ៥ ៖

# ស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

ការអនុវត្តន៍តាមកាតព្វកិច្ចរៀងៗខ្លួនរបស់រដ្ឋភាគីនានា ទៅតាមសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗចំនួនប្រាំពីរ (សូមមើលជំពូកទី ៣) ត្រូវបានពិនិត្យឃ្លាំមើលដោយស្ថាប័នជំនាញចំនួនប្រាំពីរ ដែលត្រូវបានគេស្គាល់ថា ជាស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញា ឬស្ថាប័នសន្ធិសញ្ញា។

គណៈកម្មាធិការសិទ្ធិមនុស្ស (CCPR)

គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR)

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងពូជសាសន៍ (CERD)

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)

គណៈកម្មាធិការប្រឆាំងទារុណកម្ម (CAT)និងអនុគណៈកម្មាធិការបង្ការទារុណកម្ម (SPT)

គណៈកម្មាធិការសិទ្ធិកុមារ (CRC)

គណៈកម្មាធិការទទួលបន្ទុកការការពារសិទ្ធិកម្មករអន្តោប្រវេសន្ត និងសមាជិកគ្រួសាររបស់ពួកគេ (CMW)

លើកលែងតែគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច នៅឆ្នាំ១៩៨៥ ស្ថាប័នទាំងអស់ខាងលើនេះ ត្រូវបានបង្កើតឡើងដោយលិខិតុបករណ៍របស់ខ្លួនរៀងៗខ្លួន ហើយត្រូវបានបង្កើតឡើងភ្លាមៗ បន្ទាប់ពីសន្ធិសញ្ញាទាំងនោះ ចូលជាធរមាន។

## សមាជិកភាព និងការប្រព្រឹត្តទៅ

គណៈកម្មាធិការ CCPR, CESCR, CERD និង CRC មានអ្នកជំនាញ ១៨ រូប ក្នុងគណៈកម្មាធិការនីមួយៗ គណៈកម្មាធិការ CAT និង CMW មានអ្នកជំនាញ ១០រូប ហើយគណៈកម្មាធិការ CEDAW មានអ្នកជំនាញ ២៣រូប។ សមាជិកគណៈកម្មាធិការទាំងនេះ ត្រូវបានជ្រើសតាំងដោយរដ្ឋភាគី នានានៃសន្ធិសញ្ញានីមួយៗ( លើកលែងតែគណៈកម្មាធិការ CESCR ដែលត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច) ដោយឈរលើមូលដ្ឋាន ត្រឹមត្រូវនៃការបែងចែកទៅតាមតំបន់ ភូមិសាស្ត្រឱ្យបានសមភាព។ គណៈកម្មាធិការ CCPR និង CRC ជួបប្រជុំបីដងក្នុងមួយឆ្នាំ គណៈកម្មាធិការ CMW ជួបប្រជុំតែម្តង និងស្ថាប័នសន្ធិសញ្ញាផ្សេងទៀតជួបប្រជុំពីរដងក្នុងមួយឆ្នាំ។ លើកលែងតែគណៈកម្មាធិការ CEDAW ដែលត្រូវបានផ្តល់សេវាកម្មដោយផ្នែកវឌ្ឍនភាពស្ត្រីរបស់សហប្រជាជាតិ (UNDAW) នៃនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ (DESA) ដែលស្ថិតនៅក្នុងទីស្នាក់ការធំរបស់អង្គការសហប្រជាជាតិ នាបូរីញូវយ៉ក ស្ថាប័នសន្ធិសញ្ញាផ្សេងទៀត ត្រូវបានផ្តល់សេវាកម្មដោយការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស OHCHR នៅទីក្រុងហ្សឺណែវ។

## នីតិវិធីធ្វើរបាយការណ៍

### កាតព្វកិច្ចរបស់រដ្ឋ

នីតិវិធីរាយការណ៍របស់រដ្ឋ គឺជានីតិវិធីជាប់កាតព្វកិច្ចតែមួយគត់ដែលត្រូវបានប្រើប្រាស់ចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗទាំងប្រាំពីរ។ រដ្ឋាភិបាលមានកាតព្វកិច្ចដាក់របាយ

ការណ៍បឋមមួយជូនស្ថាប័នឃ្លាំមើលការអនុវត្តសន្ធិសញ្ញា បន្ទាប់មក មានដាក់របាយការណ៍តាមកាលកំណត់នានាទៀត និងរបាយការណ៍ជាបន្ទាន់ ឬរបាយការណ៍ផ្សេងទៀតតាមការស្នើសុំរបស់ស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញា។ ស្ថាប័នសន្ធិសញ្ញាផ្តល់ជូនរដ្ឋនានានូវគោលការណ៍ណែនាំនានា ដើម្បីជួយជ្រោមជ្រែងរដ្ឋទាំងនោះ ក្នុងការរៀបចំរបាយការណ៍។

និយាយជាទូទៅ របាយការណ៍ទាំងនោះត្រូវបានរំពឹងថានឹងត្រូវផ្តល់នូវព័ត៌មានអប្បបរមាដូចខាងក្រោមនេះ:

- វិធានការទាំងអស់ដែលបានអនុម័តដោយរដ្ឋ ក្នុងការផ្តល់សុពលភាពដល់សិទ្ធិនានាដែលមានចែងនៅក្នុងសន្ធិសញ្ញា
- ការធ្វើឱ្យរីកចម្រើនដល់ការប្រាស្រ័យសិទ្ធិទាំងនោះ
- ព័ត៌មានដែលទទួលបានពីបទពិសោធន៍ពាក់ព័ន្ធនានា ដោយរួមទាំងទិន្នន័យស្ថិតិ ផងដែរ
- បញ្ហា និងការលំបាកទាំងអស់ ដែលប៉ះពាល់ដល់ការអនុវត្តសន្ធិសញ្ញានៅក្នុងប្រទេស

តាមច្បាប់ របាយការណ៍របស់រដ្ឋ ត្រូវបានព្រាងដោយរដ្ឋាភិបាលនីមួយៗ។ ក៏ប៉ុន្តែ ដើម្បីធានានូវភាពពេញលេញ និងភាពសត្យានុម័ត ការចូលរួមក្នុងការរៀបចំរបាយការណ៍នេះ ពីសំណាក់ស្ថាប័នផ្សេងទៀត (ជាពិសេសសភា) គណៈកម្មការជាតិសិទ្ធិមនុស្ស និងការិយាល័យប្រជាពលរដ្ឋ (Ombudsman) និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធនានា ព្រមទាំងអង្គការសង្គមស៊ីវិល ត្រូវបានចាត់ទុកថា អាចផ្តល់ការប្រឹក្សាយោបល់បាន។

## ការពិនិត្យរបាយការណ៍របស់រដ្ឋ

ស្ថាប័នសន្ធិសញ្ញានានា វិភាគលើរបាយការណ៍របស់រដ្ឋ ហើយពិភាក្សារបាយការណ៍ទាំងនោះ នៅក្នុងសម័យប្រជុំជាសាធារណៈ ដោយមានវត្តមានអ្នកតំណាងនានារបស់

រដ្ឋនោះផង។ ថ្វីត្បិតតែគណៈកម្មាធិការ មានបំណងពិភាក្សាជាមួយរដ្ឋាភិបាល ក្នុងន័យស្ថាបនាក៏ដោយ ក៏អ្នកតំណាងនានារបស់រដ្ឋនោះ អាចត្រូវប្រឈមនឹងសំណួរ និង ចំណាប់អារម្មណ៍នានា ដែលមានលក្ខណៈរិះគន់ធ្ងន់ៗ ពីសំណាក់សមាជិកគណៈកម្មាធិការ។ នៅចុងបញ្ចប់នៃការពិនិត្យ របាយការណ៍របស់រដ្ឋនីមួយៗ ស្ថាប័នសន្ធិសញ្ញា អនុម័តសេចក្ដីសង្កេតសន្និដ្ឋាន និង មតិយោបល់ ព្រមទាំងអនុសាសន៍នានា ដែលត្រូវផ្សព្វផ្សាយជាបន្តបន្ទាប់នៅចុងបញ្ចប់នៃសម័យប្រជុំនោះ ហើយត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ស្ថាប័នសន្ធិសញ្ញា។ រដ្ឋទាំងឡាយ ត្រូវបានរំពឹងថា នឹងអនុវត្តតាមអនុសាសន៍ទាំងនេះ ហើយនៅក្នុងរបាយការណ៍លើកក្រោយរបស់ខ្លួន រដ្ឋទាំងនោះ នឹងផ្ដល់ព័ត៌មានអំពីវិធានការនានាដែលធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ទាំងនោះ។ គណៈកម្មាធិការ ក៏សុំឱ្យរដ្ឋភាគីធ្វើរបាយការណ៍ជាក់លាក់ម្ដងម្កាល ជាពិសេសនៅក្នុងស្ថានភាពមានអាសន្ន ឬនៅក្នុងករណីផ្សេង ទៀតដែលពាក់ព័ន្ធទៅនឹង ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។

## តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល និងអង្គការផ្សេងទៀត

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិនានា តាមដានយ៉ាងយកចិត្តទុកដាក់ លើការ-ពិនិត្យរបាយការណ៍របស់រដ្ឋ និងផ្ដល់ឱ្យអ្នកជំនាញនៃគណៈកម្មាធិការនូវព័ត៌មានពាក់ព័ន្ធ ឬរហូតដល់អាចដាក់របាយ ការណ៍ស្រមោលថែមទៀតផង។ គណៈកម្មាធិការ CCPR, CESCR និង CRC អនុញ្ញាតឱ្យអង្គការក្រៅ រដ្ឋាភិបាលដើរតួនាទីសកម្មមិន ដាច់ខាតមួយ និងសំដែងមតិ យោបល់នៅក្នុងកិច្ចប្រជុំពិសេសនានា។ ទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ ដូចជា ILO និង UNESCO និងស្ថាប័នផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ត្រូវបានអញ្ជើញឱ្យជួយឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញា។ ជាពិសេស អង្គការ UNICEF (មូលនិធិសហប្រជាជាតិសម្រាប់កុមារ) ដោយមានបណ្ដាញការិយាល័យប្រចាំប្រទេសនៅទូទាំងពិភពលោកផ្ដល់ឱ្យគណៈកម្មាធិការ CRC នូវការជួយជ្រោមជ្រែង

យ៉ាងសកម្ម និងមានតម្លៃ ក្នុងភារកិច្ចដ៏ឧត្តុងឧត្តមនៃការឃ្លាំមើលការអនុវត្តអនុសញ្ញាសិទ្ធិកុមារ នៅក្នុងរដ្ឋភាគីចំនួន ១៩២ប្រទេស។

## សេចក្តីពន្យល់ទូទៅចេញដោយស្ថាប័នឃ្លាំមើលការអនុវត្តន៏សន្ធិសញ្ញា

ស្ថាប័នសន្ធិសញ្ញាអនុម័ត និងបោះពុម្ពផ្សាយនូវ *សេចក្តីពន្យល់ទូទៅ* ឬ*អនុសាសន៏ទូទៅ* ពាក់ព័ន្ធនឹងបទបញ្ញត្តិ និងកាតព្វកិច្ចនានា ដែលមានចែងនៅក្នុងសន្ធិសញ្ញានីមួយៗរៀងៗខ្លួន។ ឯកសារទាំងនេះ ឆ្លុះបញ្ចាំងពីបទពិសោធន៏របស់គណៈកម្មាធិការនានា ក្នុងនីតិវិធីធ្វើរបាយការណ៏ និងបង្កើតបានជាប្រភព ដែលមានអំណាចជាផ្លូវការមួយ ក្នុងការបកស្រាយលិខិតុបករណ៏សិទ្ធិមនុស្សនានា។

**ប្រអប់ ២០**

### កន្លែងទទួលព័ត៌មានអំពីការងាររបស់ស្ថាប័នឃ្លាំមើលការអនុវត្តន៏សន្ធិសញ្ញា

ព័ត៌មានពិស្តារស្តីពីស្ថាប័នសន្ធិសញ្ញាទាំងអស់ និងការទទួលបាននូវសេចក្តីពន្យល់ទូទៅ ឬ អនុសាសន៏នានា របស់ស្ថាប័នទាំងនោះ អាចរកបានតាមគេហទំព័រ http://www.ohchr.org/english/bodies/index.htm ។ គោលការណ៏ណែនាំមួយចំនួនទៀតក៏អាចរកបានតាមគេហទំព័រ **http://www.ohchr.org/english/contact** ។

**ទំនាក់ទំនងព័តិមានរបស់ OHCHR:**

អាស័យដ្ឋានសម្រាប់ផ្ញើសំបុត្រៈ OHCHR- Palais des Nations
8-14 Avenue de la Paix
CH-1211 Geneva 10
Switzerland

ទូរស័ព្ទៈ +41 (22) 917 9000

ទូរសារៈ +41 (22) 917 9008

## នីតិវិធីបណ្តឹងបុគ្គល

ពិធីសារបន្ថែមលើ CCPR និង CEDAW និងបញ្ញត្តិតាមការជ្រើសរើសក្នុង CERD, CAT និងអនុសញ្ញាស្តីពី កម្មករអន្តោប្រវេសន៍ ចែងអំពីនីតិវិធីសម្រាប់បណ្តឹងជាបុគ្គល (ដែលហៅថា "បណ្តឹងជាឯកត្តបុគ្គល")។ នីតិវិធីស្រដៀងគ្នាមួយ ត្រូវបានរំពឹងថានឹងធ្វើឡើង នៅក្នុងពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ដែលកំពុងត្រូវបានព្រាងឡើងនាពេលបច្ចុប្បន្ននេះ នៅក្នុងគណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ (សព្វថ្ងៃនេះ គឺជាក្រុមប្រឹក្សាសិទ្ធិមនុស្ស)។

ក្រោមបទបញ្ញត្តិទាំងនោះ ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋភាគីកាន់តែច្រើនថែមទៀត នោះ (សូមមើលប្រអប់ ២២) បុគ្គលណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋភាគី ដែល (ក)- អះអាងថាខ្លួនជា ជនរងគ្រោះម្នាក់ពីការរំលោភសិទ្ធិមនុស្ស និង(ខ) បានប្រើអស់គ្រប់លទ្ធភាពដែលមាននៅក្នុងប្រទេសក្នុងការស្វែងរក ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយនោះ មានសិទ្ធិដាក់ពាក្យបណ្តឹងទៅស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញា ដែលមានសមត្ថកិច្ច។ គណៈកម្មាធិការ ពិនិត្យពាក្យបណ្តឹងនេះ តាមនីតិវិធីសំងាត់ និងមានលក្ខណៈស្រដៀងតុលាការ ហើយជាចុងក្រោយ ចេញសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចមួយ(ហៅថា"ទស្សនៈ សេចក្តីស្នើ ឬអនុសាសន៍ចុងក្រោយ")ដែលប្រកាសថា ពាក្យបណ្តឹងនេះ មិនអាចទទួលយកបាន (ប្រសិនបើ មិនឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវជាផ្លូវការ) ឬអាចទទួលយកបាន ហើយនៅក្នុងករណីចុងក្រោយនេះ គណៈកម្មាធិការដាក់ចេញនូវទស្សនៈយល់ឃើញមួយរបស់ខ្លួន ដល់អង្គសេចក្តី(ដោយសំរេចថាតើសិទ្ធិមនុស្សរបស់ម្ចាស់បណ្តឹងនោះ ត្រូវបានរំលោភបំពានដែរឬទេ)។

## ប្រអប់ ២១

# នីតិវិធីបណ្ដឹង

ឧទាហរណ៍នៃពិធីសារបន្ថែមទី១ លើ CCPR

ពាក្យបណ្ដឹងពីបុគ្គលម្នាក់ ដែលអះអាងថា ជាជនរងគ្រោះពីការរំលោភសិទ្ធិ CCPR

គណៈកម្មាធិការសិទ្ធិមនុស្ស

នីតិវិធីនៃការអាចទទួលយកពាក្យបណ្ដឹង

ការទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ដោយរដ្ឋភាគី ( មាត្រា១ នៃពិធីសារបន្ថែម)

ការប្រើអស់លទ្ធភាពនូវវិធីដោះស្រាយក្នុងប្រទេស ( មាត្រា២ មាត្រា ៥(២)(ខ) នៃ ពិធីការបន្ថែម)

ពាក្យបណ្ដឹងមានលក្ខណៈមិនអនាមិក និងមិនទ្រគោះបោះបោក ( មាត្រា៣ នៃពិធីសារ បន្ថែម)

ភាពស្របគ្នាជាមួយ បទបញ្ញត្តិរបស់ CCPR ( មាត្រា៣ នៃពិធីសារបន្ថែម)

អវត្តមានការពិនិត្យជួនគ្នា ក្រោមនីតិវិធីអន្តរជាតិមួយផ្សេងទៀត ( មាត្រា៥(២)(ក) នៃពិធីសារបន្ថែម )

មានខ្លឹមសារគ្រប់គ្រាន់នៃការចោទប្រកាន់( ករណីដែលមើលឃើញជាក់ស្ដែងតាមមាត្រា២

មិនអាចទទួលយកបា

ចំណាត់ការដល់អង្គសេចក្ដី

រដ្ឋ/បុគ្គល

ការពិនិត្យ និងការពិភាក្សា ( ជាសម្ងាត់)

សេចក្ដីសំរេច

បុគ្គល

រដ្ឋភាគី

## នីតិវិធីបណ្ដឹងរវាងរដ្ឋ និងរដ្ឋ

CCPR CERD CAT និងអនុសញ្ញាស្ដីពីកម្មករអន្តោរប្រវេសន្ត ចែងអំពីនីតិវិធី បណ្ដឹងរវាងរដ្ឋ និងរដ្ឋ ដែលនៅក្នុងនោះរដ្ឋភាគីមួយមានសិទ្ធិដាក់ពាក្យបណ្ដឹងទៅកាន់គណៈកម្មាធិការពាក់ព័ន្ធ ដោយអះអាងថា រដ្ឋភាគីមួយផ្សេងទៀត មិនបានបំពេញកាតព្វកិច្ចតាមសន្ធិសញ្ញារបស់ខ្លួនទេ។ នីតិវិធីនេះ មានមូលដ្ឋានឈរលើវិធានប្រតិបត្តិដែលចែងថា តាមច្បាប់អន្តរជាតិ រដ្ឋភាគីនីមួយៗ មានប្រយោជន៏ខាងផ្លូវច្បាប់ចំពោះគ្រប់រដ្ឋភាគីដទៃទៀត ក្នុងការបំពេញបានតាមកាតព្វកិច្ចរបស់ខ្លួនរៀងៗខ្លួន។

**ប្រអប់ ២២**

**ការទទួលយកនីតិវិធីបណ្ដឹងជាឯកត្តបុគ្គលដោយរដ្ឋនានា និងប្រសិទ្ធភាពរបស់នីតិវិធី**

**ការផ្ដល់សច្ចាប័នលើពិធីសារបន្ថែមទី១ នៃ CCPR (គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០០៤ មានរដ្ឋភាគីចំនួន១០៤) រួមមានៈ**

អាល់ស្សេរី អង់ហ្គោឡា អាហ្សង់ទីន អាមេនី អូស្ត្រាលី អូទ្រីស អាហ៊្សែបៃហ្សង់ បាបេដូ បែលឡារុស បែលហ្ស៊ិក បេណាំង បូលីវី បូស្នីនិងអែហ្សេហ្គូវីន ប៊ុលហ្គារី ប៊ីគីណាហ្វាសូ កាមេរូន កាណាដា ខេបវែដ សាធារណៈរដ្ឋអាហ្វ្រិកកណ្ដាល ឆាដ ឈីលី កូឡុំប៊ី កុងហ្គោ កូស្តារីកា កូឌីវ័រ ក្រូអាត ស៊ីព សាធារណៈរដ្ឋឆែក សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដាណឺម៉ាក ដ្សីប៊ូទី សាធារណៈរដ្ឋដូមីនីកាំង អេក្វាដ័រ អែលសាវ៉ាដ័រ អេក្វាទ័រហ្គីនី អេស្តូនី ហ្វាំងឡង់ បារាំង ហ្គាំប៊ី ហ្សកហ្ស៊ី អាល្លឺម៉ង់ ហ្គាណា ក្រិច ហ្គាតេម៉ាឡា ហ្គីនី ហ្គូយ៉ាណា ហុងគ្រី អ៊ីស្លង់ អៀកឡង់ អ៊ីតាលី គៀកគីស្ថាន ឡាត់វី ឡេសូតូ លីបង់អារ៉ាប់ ឡេចតិនស្តែន លីទុយអានី លុចសំបួរ ម៉ាដាហ្គាស្កា ម៉ាឡាវី ម៉ាលី ម៉ាល់តា កោះម៉ូរីស មិចស៊ិចកូ ម៉ុងហ្គោលី ណាមីប៊ី នេប៉ាល់ ហុល្លង់ ណូវែលស្សេឡង់ នីការ៉ាហ្គ័រ នីហ្សេរីយ៉ា ណ័រវែស ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉េរូ ហ្វីលីពីន ប៉ូឡូញ ព័រទុយហ្គាល់ សាធារណៈរដ្ឋកូរ៉េ រ៉ូម៉ានី សហព័ន្ធរុស្សី សាំងវ៉ាំងសង់និងហ្គ្រេណាឌីន សាំងម៉ារីណូ

សេណេហ្គាល់ ស៊ែបនិងម៉ុងតេណេក្រូ ស៊ីសែល សេរ៉ាឡេអូន ស្លូវ៉ាគី ស្លូវ៉ានី សូម៉ាលី អាហ្វ្រិកខាងត្បូង អេស្ប៉ាញ ស្រីលង្កា ស៊ូរីណាម ស៊ុយអែត តាហ្ស៊ីគីស្ថាន អតីតៈសាធារណៈ រដ្ឋយូហ្គោស្លាវីនៃរដ្ឋម៉ាសេដូនី តូហ្គូ ទូមីនីស្តង់ អ៊ុយហ្គាន់ដា អ៊ុយក្រែន អ៊ុយរុយហ្គាយ អ៊ូបេគីស្តង់ វេណេហ្ស៊ុយអេឡា និងហ្សំបី ។

**ការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃ CEDAW (គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០០៤ មានរដ្ឋភាគីចំនួន៦៨) រួមមានៈ**

អាល់បានី អង់ដូរ៉ា អូទ្រីស អាហ្សែបៃហ្សង់ បង់ក្លាដែស បែលឡារុស ប៊ែលហ្ស៊ិក បឺលីស បូលីវី បូស្នីនិងអែហ្សេហ្គូវីន ប្រេស៊ីល កាណាដា កូស្តារីកា ក្រូអាត ស៊ីព សាធារណៈរដ្ឋឆែក ដាណឺម៉ាក សាធារណៈរដ្ឋដូមេនីកាំង អេក្វាដ័រ ហ្វាំងឡង់ បារាំង ហ្គាបុង ហ្សកហ្ស៊ី អាល្លឺម៉ង់ ក្រិច ហ្គាតេម៉ាឡា ហុងហ្គារី អ៊ីស្លង់ អៀកឡង់ អ៊ីតាលី កាហ្សាក់ស្តង់ គៀកគីស្ថាន ឡេសូតូ លីបង់អារ៉ាប់ ឡេចតិនស្តែន លីទុយអានី លុចសំបួរ មាលី ម៉ិចស៊ិចកូ ម៉ុងហ្គោលី ណាមីប៊ី ហុល្លង់ ណូវ៉ែលស្សេឡង់ នីហ្សេរីយ៉ា ន័រវ៉ែស ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉េរូ ហ្វីលីពីន ប៉ូឡូញ ព័រទុយហ្គាល សហព័ន្ធរុស្ស៊ី សេណេហ្គាល់ ស៊ែបនិង ម៉ុងតេណេក្រូ ស្លូវ៉ាគី ស្លូវ៉ានី កោះសូឡូម៉ុង អេស្ប៉ាញ ស្រីលង្កា ស៊ុយអែត ថៃ អតីតៈសាធារណៈរដ្ឋយូហ្គោស្លាវីនៃរដ្ឋម៉ាសេដូនី ទីម័រខាងកើត ទួគី អ៊ុយក្រែន អ៊ុយរ៉ាហ្គាយ និងវេណេហ្ស៊ុយអេឡា។

**ការទទួលយកនីតិវិធីបណ្តឹងជាឯកត្តបុគ្គលតាមមាត្រា២២នៃ CAT (គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០០៤ មានរដ្ឋភាគីចំនួន៥៦)**

អាល់សេរី អាហ្សង់ទីន អូស្ត្រាលី អូទ្រីស ប៊ែលហ្ស៊ិក បូស្នីនិងអែហ្សេហ្គូវីន ប៊ុលហ្គារី ប៊ូរុនឌី កាមេរូន កាណាដា ឈីលី អាហ្សែបៃហ្សង់ កូស្តារីកា ក្រូអាត ស៊ីប្រឹស សាធារណៈរដ្ឋឆែក ដាណឺម៉ាក អេក្វាដ័រ ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ហ្គាណា ក្រិច ហ្គាតេម៉ាឡា ហុងគ្រី អ៊ីស្លង់ អៀកឡង់ អ៊ីតាលី ឡេចតិនស្តែន លុចសំបួរ ម៉ាល់តា ម៉ិចស៊ិចកូ ម៉ូណាកូ ហុល្លង់ ណូវ៉ែលស្សេឡង់ ន័រវ៉ែស ប៉ារ៉ាហ្គាយ ប៉េរូ ប៉ូឡូញ ព័រទុយហ្គាល់ សហព័ន្ធរុស្ស៊ី សេណេហ្គាល់ ស៊ែបនិងម៉ុងតេណេក្រូ ស៊ីសែល ស្លូវ៉ាគី ស្លូវ៉ានី អាហ្វ្រិកខាងត្បូង អេស្ប៉ាញ ស៊ុយអែត ស្វីស តូហ្គូ ទុយនេស៊ី ទួគី អ៊ុយក្រែន អ៊ុយរ៉ាហ្គាយ និង វេណេហ្ស៊ុយអេឡា ។

**ការទទួលយកនីតិវិធីបណ្តឹងជាឯកត្តបុគ្គលតាមមាត្រា ១៤ នៃ CERD （គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០០៤ មានរដ្ឋភាគី ចំនួន ៤៥ ）**

អាល់សេរី អូស្ត្រាលី អូទ្រីស អាហ្សែបៃហ្សង់ ប៊ែលហ្សិក ប្រេស៊ីល ប៊ុលហ្គារី ឈីលី កូស្តារីកា សាធារណៈរដ្ឋឆែក ស៊ីព ដាណឺម៉ាក អេក្វាដ័រ ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ហុងគ្រី អ៊ីស្លង់ អៀកឡង់ អ៊ីតាលី ឡិចតិនស្តែន លុចសំបួរ ម៉ាល់តា ម៉ិចស៊ិចកូ ម៉ូណាកូ ហុល្លង់ ន័រវ៉ែស ប៉េរូ ប៉ូឡូញ ព័រទុយហ្គាល់ សាធារណៈរដ្ឋកូរ៉េ រ៉ូម៉ានី សហព័ន្ធរុស្ស៊ី សេណេហ្គាល់ ស៊ែប និងម៉ុងតេណេហ្គ្រូ ស្លូវ៉ាគី ស្លូវ៉ានី អាហ្វ្រិកខាងត្បូង អេស្ប៉ាញ ស៊ុយអែត ស្វីស អតីតៈសាធារណៈរដ្ឋយូហ្គោស្លាវីនៃរដ្ឋម៉ាសេដូនី អ៊ុយក្រែន អ៊ុយរ៉ាហ្គាយ និងវេណេហ្ស៊ុយអេឡា ។

## ប្រសិទ្ធភាព

ការពិនិត្យសើរើតាមនីតិវិធីបណ្តឹងជាឯកត្តបុគ្គល មានប្រសិទ្ធភាពបំផុត តាមពិធីសារបន្ថែមទី១ នៃ CCPR: គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០០៤ គឺ ២៧ឆ្នាំបន្ទាប់ពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្ស （គឺស្ថាប័នឃ្លាំមើលការអនុវត្តន៍ សន្ធិសញ្ញា CCPR） បានទទួលសំណុំរឿង ចំនួនច្រើនជាង ១៣០០ ករណី ហើយបានចេញសេចក្តីសម្រេចបានចំនួន ៤៨០ ករណី ។

នៅខែមេសា ឆ្នាំ២០០៤ គណៈកម្មាធិការ CAT ដែលបានបង្កើតឡើងនៅឆ្នាំ១៩៨៧ បានទទួលសំណុំរឿង ចំនួន ២៤២ ករណី ហើយបានចេញសេចក្តីសម្រេចចំនួនច្រើនជាង ៩០ ករណី ។ ទោះជាយ៉ាងនេះក៏ដោយសំណុំរឿង ភាគច្រើនមិនពាក់ព័ន្ធ ទៅនឹងការចោទប្រកាន់ដោយផ្ទាល់ ពីការធ្វើទារុណកម្មនៅក្នុងរដ្ឋភាគីនោះទេ ប៉ុន្តែជាករណី រំលោភបំពានលើគោលការណ៍នៃការមិន បញ្ជូនត្រឡប់ទៅវិញ （ឬ "គោលការណ៍មិនធ្វើមាតុភូមិនិវត្តន៍" ដែលមានចែងនៅក្នុងមាត្រា ៣ នៃអនុសញ្ញានេះ） ដែលទាក់ទងទៅនឹងការអះអាងរបស់ជនបរទេស ដែលថា ការបណ្តេញចេញ ឬការធ្វើបត្យាប័នដោយរដ្ឋនានា （ភាគច្រើននៅអឺរ៉ុប） នឹងដាក់ឱ្យពួកគេប្រឈមនឹងទារុណកម្ម នៅក្នុងប្រទេសកំណើតរបស់ពួកគេ ឬប្រទេសដែលពួកគេ នឹងត្រូវបញ្ជូនទៅ ។

នៅខែមីនា ឆ្នាំ២០០៤ គណៈកម្មាធិការ CERD ដែលជាស្ថាប័នសន្ធិសញ្ញាចាស់ជាងគេ （បង្កើតឡើងនៅ ឆ្នាំ១៩៧០） បានទទួលសំណុំរឿងតែចំនួន ៣៣ ករណីតែប៉ុណ្ណោះ ហើយបានចេញសេចក្តីសម្រេចចំនួន ១៥ ករណី ។

នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ៣១ ស្តីពីសារជាតិនៃកាតព្វកិច្ចគតិយុត្តិទូទៅរបស់រដ្ឋភាគីនៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ CCPR គណៈកម្មាធិការសិទ្ធិមនុស្ស កោតសរសើរដល់រដ្ឋភាគីនូវទស្សនៈដែលថា រដ្ឋភាគីណាដែល រំលោភបំពានសិទ្ធិនានា ដែលត្រូវបានធានាការពារដោយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ CCPR រដ្ឋភាគីនោះ សក្តិសមនឹងការយកចិត្តទុកដាក់របស់ខ្លួន។ គណៈកម្មាធិការគូសបញ្ជាក់ថា "ដើម្បីទាញការយកចិត្តទុកដាក់ចំពោះការបំពាន ដែលអាចប្រព្រឹត្តរំលោភលើកាតព្វកិច្ចកតិកាសញ្ញាដោយរដ្ឋភាគីនានា និងដើម្បីអំពាវនាវឱ្យរដ្ឋ ភាគីទាំងនោះ អនុវត្តតាមកាតព្វកិច្ច កតិកាសញ្ញារបស់ខ្លួន គួរត្រូវចាត់ទុកថាជាការឆ្លុះបញ្ចាំងនៃផលប្រយោជន៍ ធម្មានុភាពរបស់សហគមន៍ មិនមែនចាត់ទុកជាអំពើអមិត្តនោះទេ" ។

គណៈកម្មាធិការនានា ត្រូវបានរំពឹងថានឹងពិនិត្យលើពាក្យបណ្តឹងនៅក្នុងកិច្ចប្រជុំបិទទ្វារ ហើយប្រសិន បើចាំបាច់ គណៈកម្មាធិការនឹងចាត់តាំងឱ្យមានគណៈកម្មការផ្សះផ្សារចំពោះកិច្ចមួយ ដើម្បីស៊ើបអង្កេត និង ដោះស្រាយបញ្ហារវាងរដ្ឋដែលពាក់ព័ន្ធ។ ទោះបីជានីតិវិធីបណ្តឹងរវាងរដ្ឋនិងរដ្ឋនៅចំពោះមុខគណៈកម្មាធិការ CERD ជាកាតព្វកិច្ចចាំបាច់របស់រដ្ឋនានាក៏ដោយ (គឺមានន័យថា រដ្ឋភាគីណាមួយ ក្នុងចំណោមរដ្ឋភាគីទាំង ១៦២ មានសិទ្ធិដាក់ពាក្យបណ្តឹងចោទប្រកាន់រដ្ឋភាគីផ្សេងទៀតអំពី ការរើសអើងពូជសាសន៍) ក៏ពុំមានបណ្តឹងណាមួយ រវាងរដ្ឋនិងរដ្ឋត្រូវបានប្តឹងមកស្ថាប័នឃ្លាំមើលការអនុវត្តន៍ សន្ធិសញ្ញាណាមួយរបស់អង្គការសហប្រជាជាតិនោះឡើយ រហូតមកដល់ពេលនេះ។

## នីតិវិធីស៊ើបអង្កេតនៅក្រោម CAT និងពិធីសារបន្ថែមលើ CEDAW

អនុសញ្ញា CAT និងពិធីសារបន្ថែមលើ CEDAW ចែងអំពីនីតិវិធីនៃការស៊ើបសួរ *suo moto* ដោយស្ថាប័នសន្ធិសញ្ញានីមួយៗ (ត្រូវបានស្គាល់ផងដែរថាជា "ការស៊ើបសួរតាមញត្តិផ្ទាល់ខ្លួនរបស់ស្ថាប័នសន្ធិសញ្ញា")។ ការស៊ើបសួរនេះ អាចត្រូវបានផ្តួចផ្តើមឡើងបានប្រសិនបើគណៈកម្មាធិការទទួលបានព័ត៌មានគួរឱ្យទុកចិត្ត និងសមហេតុផលថា ការធ្វើ

ទារុណកម្ម ឬការរើសអើងប្រឆាំងនឹងស្ត្រី ត្រូវបានគេអនុវត្តជាប្រព័ន្ធ នៅក្នុងទឹកដីនៃរដ្ឋភាគីណាមួយ។ ស្ថាប័នសន្ធិសញ្ញា ដែលផ្តើមធ្វើការ ស៊ើបសួរបែបនេះ អាចបំពេញបេសកកម្មស្រាវជ្រាវស្វែងរកការពិតទៅ កាន់ប្រទេសដែលពាក់ព័ន្ធនឹងរឿងបែបនេះ ក្នុងករណី ដែលមានការយល់ព្រមពីរដ្ឋាភិបាលរបស់ប្រទេសនោះ។ ដំណើរការទាំងអស់ត្រូវទុកជាការសម្ងាត់ ប៉ុន្តែគណៈកម្មាធិការអាចធ្វើសេចក្តីសង្ខេបមួយ អំពីលទ្ធផលនៃការស៊ើបសួរនេះ ដាក់ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។ រហូតមកដល់ពេលបច្ចុប្បន្ននេះ គណៈកម្មាធិការ CAT បានធ្វើការស៊ើបសួរ ចំនួនប្រាំមួយករណីរួចមកហើយ (ពាក់ព័ន្ធទៅ នឹងប្រទេសអេហ្ស៊ីប ម៉ិច-ស៊ិចកូ ប៉េរូ ស៊ែប និង ម៉ុងតេណេហ្គ្រូ ស្រីលង្កា និងប្រទេសទួគី)។ គណៈកម្មាធិការ CEDAW បានផ្តួចផ្តើមនីតិវិធី នៃការស៊ើបសួររបស់ខ្លួនមួយពាក់ព័ន្ធនឹងប្រទេសម៉ិចស៊ិចកូ។

## ប្រព័ន្ធនៃការធ្វើទស្សនៈកិច្ចទៀងទាត់ទៅកាន់មន្ទីរឃុំឃាំងដែលបង្កើតឡើងតាមពិធីសារបន្ថែមនៃ CAT

ពិធីសារបន្ថែមនៃ CAT ដែលធ្វើឡើងនៅខែធ្នូ ឆ្នាំ២០០២[៨] ចែងពីប្រព័ន្ធនៃការធ្វើទស្សនៈកិច្ចទៀងទាត់មួយទៅកាន់កន្លែងឃុំឃាំងនានា ដោយស្ថាប័នអន្តរជាតិមួយ គឺអនុគណៈកម្មាធិការបង្ការទារុណកម្មនៃ គណៈកម្មាធិការប្រឆាំងទារុណកម្ម និង ដោយស្ថាប័នជាតិនានា។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើង ដើម្បីបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក។ ស្ថាប័នអន្តរជាតិ និងស្ថាប័នជាតិបង្កើតនិងដាក់ចេញនូវអនុសាសន៍នានាជូនរដ្ឋាភិបាលពាក់ព័ន្ធ។ ខណៈដែលអនុសាសន៍របស់ស្ថាប័នជាតិ អាចត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន អនុសាសន៍ និងសេចក្តីសង្កេតរបស់អនុគណៈកម្មាធិការអន្តរជាតិ អាចចេញផ្សាយជាសាធារណៈ តែក្នុងករណីណាដែលរដ្ឋភាគីណាមួយ មិនអនុវត្តតាមកាតព្វកិច្ចសន្ធិសញ្ញា របស់ខ្លួនតែប៉ុណ្ណោះ។

[៨] ត្រឹមខែ សីហា ឆ្នាំ ២០០៥ ពិធីសារបន្ថែមនេះ ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋចំនួន ១១។ ពិធីសារតម្រូវ-អោយមានការផ្តល់សច្ចាប័នដោយរដ្ឋ ចំនួន ២០ ដើម្បីអោយពិធីសារនេះ ចូលជាធរមាន។

## ប្រអប់ ២៣

# សេចក្ដីសង្ខេបទៅលើនីតិវិធី

| សន្ធិសញ្ញា | កាលបរិច្ឆេទនៃការអនុម័ត/ការចូលជាធរមាន | ស្ថាប័ន | សមាជិក-ភាព | សមាជិក បោះឆ្នោតជ្រើសតាំងដោយ | របាយការណ៍របស់រដ្ឋ | ពាក្យ បណ្ដឹងរវាងរដ្ឋនិងរដ្ឋ | ពាក្យ បណ្ដឹងជាឯកត្តបុគ្គល | ការស៊ើបសួរ *Suo moto* |
|---|---|---|---|---|---|---|---|---|
| **CAT** | ១២ ធ្នូ ១៩៨៤/ ២៦ មិថុនា ១៩៨៧ | គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម | ១០ | រដ្ឋភាគី | ជាកាតព្វកិច្ច តាមមាត្រា ១៩ | ជាជំរើសតាមមាត្រា ២១ | ជាជំរើស តាមមាត្រា ២២ | ជាកាតព្វកិច្ច (មានលទ្ធភាពមិនជ្រើសយកបាន) មាត្រា ២០ និង២៨ |
| **CCPR** | ១៦ ធ្នូ ១៩៦៦/ ២៣ មីនា ១៩៧៦ | គណៈកម្មាធិការសិទ្ធិមនុស្ស | ១៨ | រដ្ឋភាគី | ជាកាតព្វកិច្ច តាមមាត្រា ៤០ | ជាជំរើស តាមមាត្រា ៤១ និង៤២ | ពិធីសារបន្ថែមទី១ | |
| **CEDAW** | ១៨ ធ្នូ ១៩៧៩/ ៣ កញ្ញា ១៩៨១ | គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី | ២៣ | រដ្ឋភាគី | ជាកាតព្វកិច្ច តាមមាត្រា ១៨ | | ពិធីសារបន្ថែម | ពិធីសារបន្ថែម តាមមាត្រា៨ និង១០ (មានលទ្ធភាពមិនជ្រើសយកបាន) |
| **CERD** | ២១ ធ្នូ ១៩៦៥/ ៤ មករា ១៩៦៩ | គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងពូជសាសន៍ | ១៨ | រដ្ឋភាគី | ជាកាតព្វកិច្ច តាមមាត្រា ៩ | ជាកាតព្វកិច្ច តាមមាត្រា ១១ ១២ និង ១៣ | ជាជំរើស តាមមាត្រា ១៤ | |
| **CESCR** | ១៦ ធ្នូ ១៩៦៦/ ៣ មករា ១៩៧៦ | គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៨ | ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមកិច្ច | ជាកាតព្វកិច្ច តាមមាត្រា ១៦ និង ១៧ | | សេចក្ដីព្រាងពិធីសារបន្ថែម | |
| **CMW** | ១៨ ធ្នូ ១៩៨៩/ ១ កក្កដា ២០០៣ | គណៈកម្មាធិការទទួលបន្ទុក កម្មករអន្តោប្រវេសន៍ | ១០ | រដ្ឋភាគី | ជាកាតព្វកិច្ច តាមមាត្រា ៧៣ | មាត្រា ៧៦ (មិនទាន់ចូលជាធរមាន) | មាត្រា ៧៧ (មិនទាន់ចូលជាធរមាន | |
| **CRC** | ២០ វិច្ឆិកា ១៩៨៩/ ២ កញ្ញា ១៩៩០ | គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ | ១៨ | រដ្ឋភាគី | ជាកាតព្វកិច្ច តាមមាត្រា ៤៤ | | | |

## ជំពូកទី ៦ :

## ប្រព័ន្ធការពារសិទ្ធិមនុស្សផ្អែកលើធម្មនុញ្ញ ក្រោមគណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ

គណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ គឺជាស្ថាប័ននយោបាយដ៏សំខាន់បំផុតមួយរបស់អង្គការសហប្រជាជាតិនៅក្នុងវិស័យសិទ្ធិមនុស្ស។ គណៈកម្មការនេះបានវិវត្តន៍ ជាបន្តបន្ទាប់ ហើយក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ បានបង្កើតនីតិវិធីផ្សេងៗជាច្រើន ដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្សសំខាន់ៗ និងឆ្លើយតបទៅនឹងញត្តិបណ្តឹងរាប់ពាន់ករណី ដែលខ្លួនបានទទួលជាទៀងទាត់ពីអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយ ដែលអះអាងថាមានការរំលោភសិទ្ធិមនុស្ស។

### នីតិវិធីសម្ងាត់លេខ “១៥០៣”

នៅក្រោមនីតិវិធីសម្ងាត់នេះ (ហៅថា "នីតិវិធី ១៥០៣" ដោយសារសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចលេខ ១៥០៣ (XLVIII) ចុះថ្ងៃ ទី២៧ ខែឧសភា ឆ្នាំ ១៩៧០ បង្កើតជាមូលដ្ឋានផ្លូវច្បាប់របស់គណៈកម្មការនេះ) នៅរៀងរាល់ឆ្នាំ ក្រុមការងារ-ពិសេសមួយនៃអនុគណៈកម្មការលើកស្ទួយនិងការពារសិទ្ធិមនុស្ស ធ្វើការសិក្សាលើញត្តិរាប់ពាន់របស់ឯកត្តបុគ្គល ដើម្បីស្វែងកំណត់ថាតើមានប្រទេសណាមួយ បង្ហាញឱ្យឃើញពី "ទម្រង់ស៊ីសង្វាក់មួយនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងគួរឱ្យជឿជាក់បាន"។ "ស្ថានភាពប្រទេស" បែបនេះ ត្រូវបានបញ្ជូនបន្តទៅក្រុមការងារបុរេសម័យប្រជុំមួយ ហើយដែលជាចុងក្រោយ នឹងត្រូវដាក់ជូនសម័យប្រជុំពេញអង្គរបស់គណៈកម្មការតែម្តង។

នៅក្នុងកិច្ចប្រជុំជាសំងាត់មួយ ដែលមានតែតំណាងរបស់រដ្ឋសមាជិកចូលរួមនោះ គណៈកម្មការអាចសម្រេចធ្វើ សេចក្ដីសន្និដ្ឋានពីការពិនិត្យរបស់ខ្លួន ថាដាក់ប្រទេសនោះឱ្យស្ថិតនៅក្រោមការតាមឃ្លាំមើល (ដែលអាចមានរយៈពេលច្រើនឆ្នាំ) ឬក៏ធ្វើការស៊ើបអង្កេតពេញលេញ និងជាសម្ងាត់មួយ ដោយមានការជួយជ្រោមជ្រែងពីសំណាក់អ្នករាយការណ៍ពិសេស ឬពីគណៈកម្មាធិការចំពោះកិច្ចមួយ ឬជាវិធានការចុងក្រោយ ប្រសិនបើស្ថានភាពនោះមិនបានប្រសើរឡើងវិញទេ ហើយ/ឬបើរដ្ឋាភិបាលនោះ បដិសេធមិនព្រមសហការនោះទេ នឹង"ធ្វើឱ្យដឹងឮជាសាធារណៈ"។"ការធ្វើឱ្យដឹង ឮជាសាធារណៈ"នេះ មានការបន្តតាមត្រួត-ពិនិត្យទៅលើស្ថានភាពរបស់ប្រទេសនោះទៀត ក្រោមនីតិវិធីពិសេស មួយនៃនីតិវិធីពិសេសនានា ដូចបានរៀបរាប់ខាងក្រោម។

ប្រអប់ ២៤

## គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ គឺជាគណៈកម្មការប្រតិបត្តិមួយក្នុងចំណោមគណៈកម្មការជាច្រើនរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច។ ក្នុងឋានៈជាស្ថាប័ននយោបាយមួយរបស់អង្គការសហប្រជាជាតិ គណៈកម្មការនេះ មានសមាសភាពជាតំណាងនៃរដ្ឋសមាជិក ដែលត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ដែលសមាសភាពគណៈកម្មការ បានកើនឡើងក្នុងរយៈពេលកន្លងមកនេះ (បច្ចុប្បន្នមានចំនួន ៥៣ នាក់)។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋដទៃទៀត អង្គការអន្តររដ្ឋាភិបាលនានា និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មការក្នុងឋានៈជាអ្នកសង្កេតការណ៍ និងអាចចូលរួមផ្ដល់មតិ និងដាក់សេចក្ដីសង្កេត ជាលាយលក្ខណ៍អក្សរជូនគណៈកម្មការបានទៀតផង។ សម័យប្រជុំប្រចាំឆ្នាំរបស់គណៈកម្មការនេះ ត្រូវប្រព្រឹត្តទៅនៅ Palais des Nations នៅ ទីក្រុងហ្សឺណែវ ក្នុងខែមីនា និងខែមេសា ដែលមានរយៈពេលប្រាំមួយសប្ដាហ៍ ហើយជាការពិត នេះគឺជាសន្និសីទ-សិទ្ធិមនុស្សដ៏ធំមួយ ចូលរួមដោយប្រតិភូចំនួនប្រមាណ ៣០០០ នាក់ ដោយរួមមានទាំងប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រី អ្នកការពារសិទ្ធិមនុស្ស និងអ្នកកាសែត ដែលចូលរួមពិភាក្សា-

ជាសាធារណៈ លើគ្រប់បញ្ហាសិទ្ធិមនុស្សសំខាន់ៗ ។ ចាប់តាំងពីឆ្នាំ១៩៩០មក គណៈកម្មការនេះបាន រៀបចំកិច្ច ប្រជុំបន្ទាន់ជាច្រើនពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សនៅអតីត ប្រទេសយូហ្គោស្លាវី "រវ៉ាន់ដា ទីម័រខាងកើត និងដែនដីកាន់កាប់របស់ប៉ាឡេស្ទីន ។ គណៈកម្មការនេះ បានបង្កើតអនុគណៈកម្មការ លើកស្ទួយ និងការពារសិទ្ធិមនុស្ស ដែលមានអ្នកជំនាញឯករាជ្យចំនួន ២៦ រូប ហើយបំពេញ តួនាទីជាអ្នកផ្តល់យោបល់ដល់គណៈកម្មការ ( សូមមើលជំពូកទី ៦) ។

ក្នុងឆ្នាំកន្លងទៅថ្មីៗនេះ មានការរិះគន់កាន់តែច្រើនឡើងៗលើសមត្ថភាពរបស់ គណៈកម្មការនេះ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។ ដូចដែលអគ្គលេខាធិការអង្គការសហប្រជាជាតិលោក កូហ្វី អាណាន់ បានលើកឡើងនៅក្នុងរបាយការណ៍របស់លោកស្តីពីកំណែទម្រង់ អង្គការសហប្រជាជាតិ[៥] ថា "រដ្ឋទាំងឡាយ ដែលបានសុំចូលជាសមាជិកនៃគណៈកម្មការនេះ មិនមែនដើម្បីពង្រឹង សិទ្ធិមនុស្សទេ ប៉ុន្តែដើម្បីការពារខ្លួនពួកគេពីការរិះគន់ ឬក៏ដើម្បីរិះគន់ ប្រទេសផ្សេងទៀតទៅ វិញទេ" ។ ដូច្នេះ ហើយបានជាលោកស្នើឱ្យដាក់ជំនួសគណៈកម្មការនេះ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស អចិន្ត្រៃយ៍មួយមានទំហំតូចជាងមុន ដែលសមាជិករបស់ក្រុមប្រឹក្សានេះត្រូវបានជ្រើសតាំងផ្ទាល់ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ។ ក្រុមប្រឹក្សានេះនឹងបំពេញមុខងារដូចជាសភា ត្រួតពិនិត្យសម្រាប់ពិនិត្យមើលគ្នាទៅវិញទៅមករវាងប្រទេសនិងប្រទេសដូចគ្នា និងមាន-អាណត្តិការងារ វាយតម្លៃលើការបំពេញរាល់កាតព្វកិច្ចសិទ្ធិមនុស្សនៃរដ្ឋទាំងអស់ ។

រដ្ឋជាសមាជិករបស់គណៈកម្មការ នៅឆ្នាំ២០០៥ (មុននឹងរំលាយ រួចបង្កើតជាក្រុមប្រឹក្សាសិទ្ធិមនុស្ស ) រួមមាននេះ : អាហ្សង់ទីន អាមេនី អូស្ត្រាលី ប៊ូតាន ប្រេស៊ីល បេគីណាហ្វាសូ កាណាដា ចិន កុងហ្គោ សាធារណៈរដ្ឋដូមេនីកាំង កូស្តារីកា គុយបា អេក្វាដ័រ អេហ្ស៊ីប អេរីចទ្រា អេត្យូពី ហ្វាំងឡង់ បារាំង ហ្គាបុង អាល្លឺម៉ង់ កាតេម៉ាឡា ហ្គីនី ហុងឌុយរ៉ាស់ ហុងគ្រី ឥណ្ឌា ឥណ្ឌូនេស៊ី អៀកឡង់ អ៊ីតាលី ជប៉ុន កេនយ៉ា ម៉ាឡេស៊ី ម៉ូរីតានី ម៉ិចស៊ិចកូ នេប៉ាល់ ហុល្លង់ នីហ្សេរីយ៉ា ប៉ាគីស្ថាន ប៉ារ៉ាហ្គាយ ប៉េរូ កាតា សាធារណៈរដ្ឋកូរ៉េ រូម៉ានី សហព័ន្ធរុស្ស៊ី អារ៉ាប់ប៊ីសាអូឌីត អាហ្វ្រិកខាងត្បូង ស្រីលង្កា ស៊ូដង់ ស្វាហ្ស៊ីឡែន តូហ្គោ អ៊ុយក្រែន ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងហ្ស៊ីមបាវ៉េ ។

---

[៥] A/59/2005, ទំព័រ ៤៥ វាក្យខ័ណ្ឌទី១៨២ និង ១៨៣ ។

## នីតិវិធីពិសេស

អនុលោមតាមសេចក្តីសម្រេចលេខ ១២៣៥ (XLII) របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ១៩៦៧ គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានបង្កើតនីតិវិធីពិសេសមួយចំនួន ដើម្បីដោះស្រាយបញ្ហាចោទប្រកាន់នានានៃការរំលោភសិទ្ធិមនុស្ស។ នីតិវិធីទាំងនេះ រួមមានការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការធ្វើរបាយការណ៍ជា សាធារណៈអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស ឬនៅក្នុងដែនដីជាក់លាក់ណាមួយ (ក្រោមអាណត្តិប្រចាំប្រទេស) ឬការរំលោភសិទ្ធិមនុស្សធំៗ ដែលត្រូវបានចោទឡើងនៅជុំវិញពិភពលោក (ក្រោមអាណត្តិតាមប្រធានបទ)។

នីតិវិធីទាំងនេះ អាចយកទម្រង់តាមអាណត្តិការងារមួយ ដែលអនុវត្តដោយ អ្នករាយការណ៍ពិសេស តំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិ អ្នកជំនាញការឯករាជ្យ ឬក្រុមការងារ។ ភារកិច្ចរបស់នីតិវិធីពិសេស រួមមាន ការអំពាវនាវជាបន្ទាន់ ការធ្វើទស្សនៈកិច្ចទៅកាន់ប្រទេសនានា និងការតាក់តែងឡើងនូវស្តង់ដានានា។

## អាណត្តិការងារតាមប្រទេស

ប្រសិនបើស្ថានភាពនៅក្នុងប្រទេសជាក់លាក់ណាមួយ ត្រូវបានយកមកពិចារណា បង្ហាញថាមានទម្រង់មួយនៃការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និងជាប្រព័ន្ធ នោះគណៈកម្មការ អាចអនុម័តសេចក្តីសម្រេចមួយ ធ្វើការថ្កោលទោសដល់ប្រទេសនោះ និង/ឬ អាចអនុញ្ញាត ឱ្យមានការស៊ើបអង្កេតពេញលេញមួយ ដោយអ្នកជំនាញការម្នាក់ទៅលើស្ថានភាពរបស់ប្រទេសនោះ។ អាណត្តិការងារតាមប្រទេស ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ដោយគណៈកម្មការនេះ។

ប្រអប់ ២៥

## យន្តការឃ្លាំមើលតាមប្រធានបទរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (ខែមេសា ឆ្នាំ២០០៥)

| ប្រធានបទ | ចាប់តាំងពី | អាណត្តិការងារ |
|---|---|---|
| ការបាត់ខ្លួនដោយចាប់បង្ខំ ឬដោយមិនស្ម័គ្រចិត្ត | ១៩៨០ | ក្រុមការងារ |
| ការសម្លាប់ក្រៅតុលាការ ដោយខុសច្បាប់ និងដោយបំពាន | ១៩៨២ | អ្នករាយការណ៍ពិសេស |
| ទារុណកម្ម | ១៩៨៥ | អ្នករាយការណ៍ពិសេស |
| សេរីភាពសាសនា ឬជំនឿ | ១៩៨៦ | អ្នករាយការណ៍ពិសេស |
| ការប្រើប្រាស់ទាហានស៊ីឈ្នួល | ១៩៨៧ | អ្នករាយការណ៍ពិសេស |
| ការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ | ១៩៩០ | អ្នករាយការណ៍ពិសេស |
| ការឃុំខ្លួនដោយបំពាន | ១៩៩១ | ក្រុមការងារ |
| ជនភៀសសឹក | ១៩៩២ | តំណាងរបស់អគ្គលេខាធិការ |
| ពូជសាសន៍និយម ការរើសអើងពូជសាសន៍ ការស្អប់ជនបរទេស និងភាពមិន អត់ឱនដែលពាក់ព័ន្ធ | ១៩៩៣ | អ្នករាយការណ៍ពិសេស |
| ការលើកស្ទួយ និងការការពារសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិយោបល់ | ១៩៩៣ | អ្នករាយការណ៍ពិសេស |
| ជនបាត់ខ្លួននៅអតីតយូហ្គោស្លាវី | ១៩៩៤-១៩៩៧ | អ្នកជំនាញការ |
| អំពើហឹង្សាប្រឆាំងនឹងស្ត្រី | ១៩៩៤ | អ្នករាយការណ៍ពិសេស |
| ឯករាជ្យភាពរបស់ចៅក្រម និងមេធាវី | ១៩៩៤ | អ្នករាយការណ៍ពិសេស |
| ចលនាដោយខុសច្បាប់ និងការចាក់ចោលផលិតផល និងកាកសំណល់ដែល មានជាតិពុល និងគ្រោះថ្នាក់ | ១៩៩៥ | អ្នករាយការណ៍ពិសេស |
| សិទ្ធិមនុស្ស និងទុរគតភាពហួសហេតុ | ១៩៩៨ | អ្នកជំនាញការឯករាជ្យ |
| សិទ្ធិទទួលបានការអប់រំ | ១៩៩៨ | អ្នករាយការណ៍ពិសេស |

| ប្រធានបទ | ចាប់តាំងពី | អាណត្តិការងារ |
|---|---|---|
| សិទ្ធិមនុស្សរបស់ជនអន្តោប្រវេសន្ត | ១៩៩៩ | អ្នករាយការណ៍ពិសេស |
| គោលនយោបាយកែតម្រូវរចនាសម្ព័ន្ធ | ២០០០ | អ្នកជំនាញការឯករាជ្យ |
| អ្នកការពារសិទ្ធិមនុស្ស | ២០០០ | តំណាងពិ-សេសរបស់អគ្គលេខាធិការ |
| សិទ្ធិទទួលបានលំនៅដ្ឋាន | ២០០០ | អ្នករាយការណ៍ពិសេស |
| សិទ្ធិទទួលបានស្បៀងអាហារ | ២០០០ | អ្នករាយការណ៍ពិសេស |
| សិទ្ធិមនុស្ស និងសេរីភាពជា-មូលដ្ឋានរបស់ជនជាតិដើមភាគតិច | ២០០១ | អ្នករាយការណ៍ពិសេស |
| សំណួរតាមផ្លូវច្បាប់ ទាក់ទងនឹងការបាត់ខ្លួន | ២០០១ | អ្នកជំនាញការឯករាជ្យ |
| សិទ្ធិទទួលបានសេវាកម្មសុខភាព | ២០០២ | អ្នករាយការណ៍ពិសេស |
| បញ្ហានានានៃការរើសអើងពូជ-សាសន៍ចំពោះប្រជាជនដែលមាន ដើមកំណើត-អាហ្វ្រិក | ២០០២ | ក្រុមការងារ |
| ជំរើសនានា ស្ដីពីការបកស្រាយពិធីសារបន្ថែមលើ CESCR | ២០០៣ | ក្រុមការងាគ្មានកំណត់រយៈកាល |
| និទណ្ឌភាព | ២០០៤ | អ្នកជំនាញការឯករាជ្យ |
| ភេរវកម្ម | ២០០៤ | អ្នកជំនាញការឯករាជ្យ |
| ជួញដូរមនុស្ស | ២០០៤ | អ្នករាយការណ៍ពិសេស |
| សិទ្ធិមនុស្ស និងសាមគ្គីអន្តរជាតិ | ២០០៥ | អ្នកជំនាញការឯករាជ្យ |
| ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ពេលប្រយុទ្ធប្រឆាំងនឹងភេរវកម្ម | ២០០៥ | អ្នករាយការណ៍ពិសេស |
| ការប្រើប្រាស់ទាហានស៊ីឈ្នួលជាមធ្យោបាយនៃការរំលោភសិទ្ធិមនុស្ស និងរា-រាំងដល់ការអនុវត្តន៍សិទ្ធិក្នុងការស្វ័យសម្រេចរបស់ប្រជាជន | ២០០៥ | ក្រុមការងារ |
| សិទ្ធិមនុស្សរបស់ជនអន្តោប្រវេសន្ត | ២០០៥ | អ្នករាយការណ៍ពិសេស |

## អាណត្តិការងារតាមប្រធានបទ

អ្នករាយការណ៍ពិសេសតាមប្រធានបទ តំណាងរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អ្នកជំនាញការ ឬក្រុមការងារ អាចធ្វើការស៊ើបអង្កេតទៅលើហេតុការណ៍កើតឡើងនៃការរំលោភសិទ្ធិមនុស្សជាក់លាក់នៅគ្រប់ប្រទេស ហើយអាចធ្វើទស្សនៈកិច្ចទៅដល់ទីកន្លែងកើតហេតុតែម្តង ដោយអាស្រ័យលើការយល់ព្រមពីរដ្ឋសាមី។ អាណត្តិការងារ តាមប្រធានបទនេះ ត្រូវបានពិនិត្យឡើងវិញរៀងរាល់បីឆ្នាំម្តង ដោយគណៈកម្មការ។

## អនុគណៈកម្មការទទួលបន្ទុកការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស

អនុគណៈកម្មការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ដែលជាអង្គភាពផ្តល់យោបល់ជូនគណៈកម្មការ ធ្វើការសិក្សាស្រាវជ្រាវ ជួយតាក់តែងព្រាងបទដ្ឋានថ្មីៗ និងធ្វើការស៊ើបអង្កេត។ រៀងរាល់ខែសីហា អនុគណៈកម្មការនេះ កោះប្រជុំនៅទីក្រុងហ្សឺណែវ សម្រាប់រយៈពេលបីសប្តាហ៍ ហើយបណ្តារដ្ឋ អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា ចូលរួមក្នុងកិច្ចប្រជុំនេះ ក្នុងនាមជាអ្នកសង្កេតការណ៍។ ភារកិច្ចជាច្រើនរបស់អនុគណៈកម្មការនេះ ត្រូវបានប្រគល់ទៅឱ្យអ្នកជំនាញការ ម្នាក់ៗដែលត្រូវបានតែងតាំងឱ្យធ្វើជាអ្នករាយការណ៍ពីបញ្ហាជាក់លាក់នានា ឬក៏ត្រូវបានប្រគល់ទៅឱ្យក្រុមការងារនានា។

ជាបន្ថែមទៅលើក្រុមការងារទទួលបន្ទុកផ្នែកទំនាក់ទំនង ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុង "នីតិវិធីសម្ងាត់លេខ ១៥០៣" និងក្រុមការងារនានាដែលបានបង្កើតជាយូរមកហើយទទួលបន្ទុកលើទម្រង់សម័យទំនើបនៃទាសភាព ជនជាតិដើម និងជនជាតិភាគតិចដែលបំរើជាវេទិកាសម្រាប់ការពិភាក្សាលើបញ្ហាសំខាន់ៗ ទាំងឡាយ រវាងរដ្ឋាភិបាលនានា អង្គការក្រៅរដ្ឋាភិបាល ជនរងគ្រោះ និងតំណាងរបស់ក្រុមពាក់ព័ន្ធនានានោះ ក្រុមការងារថ្មីៗ ត្រូវបានបង្កើតឡើង ដើម្បីដាក់ឱ្យទទួលបន្ទុកលើសាជីវកម្មឆ្លងប្រទេស និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌។

# ជំពូកទី ៧ :
# ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក៏ដូចជា ការិ-យាល័យស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ដែរ ត្រូវបាន បង្កើតឡើងតាមការស្នើសុំដដែលៗពីអង្គការក្រៅរដ្ឋាភិបាល ដែលនាំមុខនានា ដូចជា អង្គការលើកលែងទោសអន្តរជាតិ និងរដ្ឋាភិបាលខ្លះ។ មានការឯកភាពជាទូទៅពីការ-បង្កើតការិយាល័យនេះ ដោយប្រតិភូមកពី ១៧១ ប្រទេស ដែលបានចូលរួមនៅក្នុង សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស(នៅទីក្រុងវីយែន ឆ្នាំ១៩៩៣) ហើយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត សេចក្តីសម្រេចចិត្ត លេខ៤៨/១៤១ បង្កើតតំណែងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនេះ មានឋានៈស្មើនឹង អគ្គលេខារងអង្គការសហប្រជាជាតិ និងមានតួនាទីជា "មន្ត្រីអង្គការ សហប្រជាជាតិទទួលខុសត្រូវជា ចម្បងលើសកម្មភាពសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ"។

នៅក្នុងសេចក្តីសម្រេចចិត្តដដែលនោះ មហាសន្និបាតអង្គការសហប្រជាជាតិបាន រៀបរាប់នូវការទទួលខុសត្រូវជាក់លាក់របស់ឧត្តមស្នងការ ដូចមានខាងក្រោមនេះ:

> លើកស្ទួយ និងការពារការទទួលបានប្រកបដោយប្រសិទ្ធភាព ដោយមនុស្សគ្រប់រូប នូវរាល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងដោយរួមទាំង សិទ្ធិទទួលបានការអភិវឌ្ឍន៍ជាដើម។

ផ្តល់សេវាប្រឹក្សាយោបល់ ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុង-វិស័យសិទ្ធិមនុស្សដល់រដ្ឋដែល ស្នើសុំជំនួយទាំងនោះ ។

សម្របសម្រួលកម្មវិធីអប់រំ និងព័ត៌មានសាធារណៈរបស់អង្គការសហប្រជាជាតិក្នុងវិស័យសិទ្ធិមនុស្ស ។

ដើរតួនាទីយ៉ាងសកម្ម ក្នុងការដកចេញនូវឧបសគ្គនានាដល់ការទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងក្នុងការបង្ការមិនឱ្យមានការបន្តការរំលោភសិទ្ធិមនុស្ស នៅទូទាំងពិភពលោក ។

ចូលរួមសន្ទនាជាមួយរដ្ឋាភិបាល ដើម្បីធានាដល់ការគោរពសិទ្ធិមនុស្ស ។

បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សំរាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ។

សម្របសម្រួលសកម្មភាពនៃការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ។

ធ្វើសនិទានកម្ម សម្របតាម ពង្រឹង និងធ្វើឱ្យកាន់តែប្រសើរឡើងដល់យន្តការអង្គការសហប្រជាជាតិ ក្នុងវិស័យសិទ្ធិមនុស្ស ដើម្បីបង្កើនប្រសិទ្ធភាព និងសមត្ថភាពរបស់អង្គការសហប្រជាជាតិ ។

អាស្រ័យហេតុនេះ បេសកកម្មរបស់ OHCHR រួមមាន ការការពារ និងការលើកស្ទួយសិទ្ធិមនុស្សទាំងអស់សម្រាប់មនុស្សទាំងអស់គ្នា ។ បេសកកម្មនេះ សំដៅពង្រឹងកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងផ្តល់ឱ្យស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាអង្គការសហប្រជាជាតិ និងយន្តការពិសេសនានា ដែលត្រូវបានបង្កើតដោយគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នូវការគាំទ្រប្រកបដោយគុណភាព ។ OHCHR សហការជាមួយស្ថាប័នអង្គការសហប្រជាជាតិផ្សេងទៀត ដើម្បីដាក់បញ្ចូលបទដ្ឋានសិទ្ធិមនុស្សទៅក្នុងការងាររបស់ប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូល ។

OHCHR ចូលរួមក្នុងការសន្ទនាជាមួយរដ្ឋាភិបាលនានាអំពីបញ្ហាសិទ្ធិមនុស្ស ជាមួយនឹងទស្សនៈ មួយដើម្បីកសាងសមត្ថភាពរបស់ប្រទេសនោះ ក្នុងវិស័យសិទ្ធិមនុស្ស និងដើម្បីបង្កើនការគោរពសិទ្ធិមនុស្ស។ OHCHR ក៏ផ្តល់សេវាប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសផងដែរ នៅពេលណាមានការស្នើសុំ ហើយលើកទឹកចិត្តរដ្ឋាភិបាលនានាឱ្យបន្តការអភិវឌ្ឍន៍ស្ថាប័នជាតិ និងនីតិវិធីឱ្យមានប្រសិទ្ធភាពដល់ការការពារសិទ្ធិមនុស្ស។

វត្តមាន OHCHR នៅតាមប្រទេសមួយចំនួន ត្រូវបានបង្កើតឡើង ដើម្បីធានាថា បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ត្រូវបានអនុវត្ត និងសម្រេចបានជាបណ្តើរៗ នៅទូទាំងប្រទេស ទាំងផ្នែកច្បាប់ និងទាំងក្នុងការអនុវត្តន៍ជាក់ស្តែង។ គោលបំណងនេះ ក៏ត្រូវបានបន្តធ្វើផងដែរ ដោយការកសាងសមត្ថភាពសិទ្ធិមនុស្សថ្នាក់ជាតិ និងកសាងស្ថាប័នជាតិនានាសំរាប់សិទ្ធិមនុស្ស។ វាក៏ត្រូវបានលើកយកមកនិយាយផងដែរ តាមរយៈការអនុវត្តន៍អនុសាសន៍របស់ស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញា និងយន្តការនៃគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងតាមរយៈការលើកស្ទួយវប្បធម៌សិទ្ធិមនុស្ស។

លក្ខខណ្ឌដ៏ចាំបាច់មួយសម្រាប់ភាពជោគជ័យនៃវត្តមានរបស់OHCHR នៅតាមប្រទេស គឺរដ្ឋាភិបាល ស្ថាប័នជាតិ អង្គការក្រៅរដ្ឋាភិបាល និងក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេស ត្រូវទទួលបានការផ្តល់អំណាចឱ្យកាន់តែច្រើនឡើង ដើម្បីពួកគេអាចអនុវត្តសកម្មភាពទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សបានដោយខ្លួនឯង នៅក្នុងបរិបទនៃយុទ្ធសាស្រ្តថ្នាក់តំបន់ និងអនុតំបន់។

## ប្រអប់ ២៦

## សិទ្ធិមនុស្សក្នុងសកម្មភាពជាក់ស្តែង: OHCHR នៅតាមប្រទេស

### វត្តមានសំខាន់ៗតាមប្រទេស:

បូស្ន៊ីនិងហឺហ្សេហ្គូវីន ប៊ូរុនឌី កម្ពុជា កូឡុំប៊ី សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ និង ស៊ែប និង ម៉ុងតេណេក្រូ។

### ផ្នែកសិទ្ធិមនុស្សរបស់បេសកកម្មសន្តិភាពអង្គការសហប្រជាជាតិ:

អាប់កាហ្ស៊ី/ហ្ស៊កហ្ស៊ី អាហ្វហ្គានីស្ថាន សាធារណៈរដ្ឋអាហ្វ្រិកកណ្តាល កូឌីវ័រ សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ អេត្យូពី/អេរីចទ្រា ហ្គីនី-ប៊ីសូ អ៊ីរ៉ាក់ (នឹងត្រូវបង្កើត) លីបេរីយ៉ា សេរ៉ាឡេអូន តាជីគីស្ថាន និងទីម័រខាងកើត។

### ការិយាល័យថ្នាក់តំបន់

ទីក្រុងអាដីសអាបាបានៃប្រទេសអេត្យូពីទីក្រុងអាល់ម៉ាទីនៃប្រទេសកាហ្សាក់ស្ថាន ទីក្រុងបាំងកក នៃប្រទេសថៃ ទីក្រុងបៃយ៉ារូតនៃប្រទេសលីបង់ ទីក្រុងព្រីតូរីយ៉ានៃប្រទេសអាហ្វ្រិកខាងត្បូង ទីក្រុងសាន់ត្យាហ្គូនៃប្រទេសឈីលី ទីក្រុងតាស្កេននៃប្រទេសអ៊ូបេគីស្ថាន (នឹងត្រូវបង្កើត) និងទីក្រុងយ៉ាវ៉ាន់ដេនៃប្រទេសកាមេរូន។

### កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស

អង់ហ្គោឡា អាហ្សែបៃហ្សាន់ ប្រេស៊ីល អេក្វាដ័រ អែលសាវ៉ាដ័រ ហ្គាតេម៉ាឡា ម៉ិចស៊ិចកូ ម៉ុងហ្គោលី នេប៉ាល់ នីការ៉ាហ្គ័រ ប៉ាឡេស្ទីន ហ្វីលីពីន សូម៉ាលី ស្រីលង្កា និងស៊ូដង់។

## ប្រអប់ ២៧

### ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

បន្ទាប់ពីអាជីពនៅក្នុងមុខងារការទូតនៅប្រទេសអេក្វាដ័រ លោក José Ayala-Lasso បានក្លាយជាឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សដំបូងគេនៅឆ្នាំ ១៩៩៤។ អ្នកស្នងតំណែងបន្តពីគាត់គឺលោកស្រី Mary Robinson អតីតប្រធានាធិបតីនៃប្រទេសអៀកឡង់។ លោកស្រីបានក្លាយជាអ្នកទទួលខុសត្រូវលើកម្មវិធីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ចំពេលដែលមានកំណែទម្រង់រចនាសម្ព័ន្ធ : នៅពេលដែលលោកស្រី ត្រូវបានតែងតាំងនោះ បុគ្គលិករបស់លោកស្រី និងមជ្ឈមណ្ឌលសិទ្ធិមនុស្ស ត្រូវបានបង្រួមចូលគ្នាទៅជាការិយាល័យតែមួយនៃឧត្តមស្នងការអង្គការសហប្រជាជាតិ (OHCHR)។ នៅក្រោមការដឹកនាំរបស់លោកស្រី ការិយាល័យឧត្តមស្នងការបានជំរុញទៅមុខ ដើម្បីប្រឈមទៅនឹងបញ្ហាសិទ្ធិមនុស្សដែលកំពុងតែមានស្រាប់ និងកំពុងតែកើត ឡើងប្រកបដោយប្រសិទ្ធភាពជាងមុន ហើយប្រមែប្រមូលកម្លាំងរបស់អ្នកដើរតួថ្មីៗ នៅក្នុងការខំស្វះស្វែងជាសកល ដើម្បីធ្វើឱ្យមានវប្បធម៌សកលមួយនៃការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋាន។ បន្ទាប់ពីមានប្រវត្តិការងារដ៏គួរឱ្យសរសើរជាមួយអង្គការសហប្រជាជាតិក្នុងការដោះស្រាយបញ្ហាប្រឈមមួយចំនួនផ្នែកមនុស្សធម៌ និងការរក្សាសន្តិភាពរបស់ពិភពលោកដ៏សែនស្មុគស្មាញ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០០២ លោក Sergio Vieira de Mello បានក្លាយជាឧត្តមស្នងការទី៣។ នៅខែឧសភា ឆ្នាំ២០០៣ លោកត្រូវបាន ស្នើសុំដោយអគ្គលេខាធិការឱ្យសំរាកការងារពីOHCHR រយៈពេលបួនខែ ដើម្បីទៅបំរើការងារជាតំណាងពិសេស របស់អគ្គលេខាធិការ ប្រចាំនៅប្រទេសអ៊ីរ៉ាក់ ជាទីដែលលោក ត្រូវបានគេសម្លាប់យ៉ាងសែនខ្លោចផ្សានៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣។ ការិយាល័យឧត្តមស្នងការ ត្រូវបានដឹកនាំដោយឧត្តមស្នងការស្តីទី គឺលោក Bertrand Ramcharan ពីប្រទេស ហ្គុយយ៉ាណា រហូតដល់មានការតែងតាំងឧត្តមស្នងការថ្មី។ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៤ មក OHCHR ត្រូវបានដឹកនាំដោយលោក ស្រី Louise Arbour ជាអតីត : ចៅក្រមតុលាការកំពូលរបស់ប្រទេសកាណាដា ហើយពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ២០០០

លោកស្រី ជាប្រធានព្រះរាជអាជ្ញានៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតៈ យូហ្គោស្លាវី និងរវ៉ាន់ដា។ ក្នុងសមត្ថកិច្ច លោកស្រីជាព្រះរាជអាជ្ញា លោកស្រីបានធ្វើការចោទប្រកាន់អតីតប្រធានាធិបតីយូហ្គោស្លាវី និងសែប៊ី គឺលោក Slobodan Milosevic ក្នុងចំណោមឧក្រិដ្ឋជនដទៃទៀត ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទង នឹងអំពើឃោឃៅដែលប្រព្រឹត្តនៅកូសូវ៉ូ។ ការចោទប្រកាន់លោក Slobodan Milosevic គឺជាការចោទប្រកាន់ទីមួយទៅលើប្រមុខរដ្ឋដែលកំពុងកាន់អំណាច។

លក្ខខណ្ឌដ៏ចាំបាច់មួយសម្រាប់ភាពជោគជ័យនៃវត្តមានរបស់ OHCHR នៅ-តាមប្រទេស គឺរដ្ឋាភិបាល ស្ថាប័នជាតិ អង្គការក្រៅរដ្ឋាភិបាល និងក្រុមការ-ងារអង្គការសហប្រជាជាតិ ប្រចាំប្រទេស ត្រូវទទួលបានការផ្តល់អំណាចឱ្យកាន់តែច្រើនឡើង ដើម្បីពួកគេអាចអនុវត្ត សកម្មភាពទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សបានដោយខ្លួនឯង នៅក្នុងបរិបទនៃយុទ្ធសាស្ត្រ ថ្នាក់តំបន់ និងអនុតំបន់។

# ជំពូកទី ៨

# សមាហរណកម្មសិទ្ធិមនុស្សទៅក្នុងការងាររបស់អង្គការសហប្រជាជាតិ

ការលើកស្ទួយសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន គឺជាវត្ថុបំណងដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិ។ ដើម្បីសម្រេចបំណងប្រាថ្នានោះ អង្គការសហប្រជាជាតិបានអនុម័តគោលនយោបាយស្តីពី "ការធ្វើសមាហរណកម្មសិទ្ធិមនុស្ស " ដូចជាការធានាថាសិទ្ធិមនុស្សដែលជាប្រធានបទមួយពាក់ព័ន្ធគ្រប់វិស័យទាំងអស់ ត្រូវបានយកមកគិតគូរពិចារណាដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធអង្គការសហប្រជាជាតិ។ អាស្រ័យហេតុនេះបន្ថែមលើគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលនៅតែជាស្ថាប័នសិទ្ធិមនុស្សមួយចម្បងគេនោះ ការកើនឡើងជាលំដាប់នូវចំនួន ទីភ្នាក់ងារជំនាញឯកទេស កម្មវិធី មូលនិធិ និងស្ថាប័នផ្សេងទៀត របស់អង្គការសហប្រជាជាតិ បាននឹងកំពុងអភិវឌ្ឍសកម្មភាពលើកស្ទួយ និងការពារសិទ្ធិមនុស្ស។

សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សនៅទីក្រុងវីយែន (១៩៩៣) និងសេចក្តីសម្រេចចិត្តជាបន្តបន្ទាប់របស់មហាសន្និបាតអង្គការសហប្រជាជាតិ និងគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអំពាវនាវឱ្យអង្គការសហប្រជាជាតិបង្កើតឱ្យមានកម្មវិធីជំនួយមួយចំនួនតាមសំណើរបស់រដ្ឋាភិបាលពាក់ព័ន្ធ។ កម្មវិធីទាំងនេះ គួរតែលើកយកមកពិភាក្សាអំពីកំណែទម្រង់ច្បាប់ជាតិ និងការបង្កើតនិង/ឬការពង្រឹងស្ថាប័នជាតិ និងរចនាសម្ព័ន្ធ

ពាក់ព័ន្ធនានា ដើម្បីលើកស្ទួយសិទ្ធិមនុស្ស នីតិរដ្ឋ និងប្រជាធិបតេយ្យ ការផ្តល់ជំនួយក្នុងការបោះឆ្នោត និងការលើកកំពស់ការយល់ដឹងអំពីសិទ្ធិ មនុស្សតាមរយៈការបណ្តុះបណ្តាល ការបង្រៀន និងការអប់រំ ការចូលរួមដ៏សកម្មពីសំណាក់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលនានា ។

កម្មវិធីកំណែទម្រង់របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានផ្តើមធ្វើនៅឆ្នាំ១៩៩៧ បានអំពាវនាវឱ្យមានការធ្វើសមាហរណកម្មសិទ្ធិមនុស្សទៅក្នុងការងាររបស់ប្រព័ន្ធអង្គការសហប្រជាជាតិទាំងមូល និងបានអំពាវនាវឱ្យបង្កើតឧបករណ៍ជាក់ស្តែងសម្រាប់អនុវត្តផែនការទីក្រុងវីយែន ។ លទ្ធផលនេះគឺមានការរីកចំរើននៅក្នុងគោលនយោបាយ និងសកម្មភាពសិទ្ធិមនុស្សរបស់កម្មវិធី និង ទីភ្នាក់ងារអង្គការសហប្រជាជាតិជាច្រើន ។

ការបោះពុម្ពផ្សាយរបាយការណ៍ឆ្នាំ២០០១ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែល-មានចំណងជើង ថា*ការពង្រឹងអង្គការសហប្រជាជាតិ : របៀបវារៈសំរាប់ការផ្លាស់ប្តូរបន្ថែមទៀត* (A/57/387) តំណាងឱ្យការអភិវឌ្ឍន៍ មួយសំខាន់ថែមទៀត ។ នៅក្នុងរបាយការណ៍កំណែទម្រង់លើកទីពីរនោះ អគ្គលេខាធិការបានបញ្ជាក់ឡើងវិញថា ការលើកស្ទួយ និងការការពារសិទ្ធិមនុស្សបង្កើតបានជា "លក្ខខណ្ឌតម្រូវដ៏រឹងមាំមួយសម្រាប់ឱ្យសម្រេចបាននូវចក្ខុវិស័យ របស់ធម្មនុញ្ញអង្គការសហប្រជាជាតិនៃពិភពលោកមួយប្រកបដោយយុត្តិធម៌ និងសន្តិភាព " ។ គោលបំណងចម្បងគឺការ កសាងសមត្ថភាពប្រតិបត្តិការផ្នែកមនុស្សធម៌ និងផ្នែកអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ដើម្បីផ្តល់លទ្ធភាពឱ្យពួកគេអាចជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋសមាជិកនានា ក្នុងការបង្កើត និងការពង្រឹងប្រព័ន្ធលើកស្ទួយ និងការការពារសិទ្ធិមនុស្សថ្នាក់ជាតិ ដែលស្របតាមបទដ្ឋាននិងគោលការណ៍ សិទ្ធិមនុស្សអន្តរជាតិ ។ កថាខ័ណ្ឌទី ៥០ នៃ របាយការណ៍នោះមានខ្លឹមសារដូចតទៅ:

"ក្នុងកថាខ័ណ្ឌទី២៥ និងទី ២៦នៃសេចក្តីថ្លែងការណ៍សហសវត្ស រដ្ឋសមាជិកនានា បានសម្រេចពង្រឹងសមត្ថភាពរបស់ខ្លួននៅតាមប្រទេស ដើម្បីអនុវត្តគោលការណ៍ និងប្រតិបត្តិ-

ការផ្ដែកសិទ្ធិមនុស្ស ដោយរួមទាំងសិទ្ធិជនជាតិភាគតិច សិទ្ធិស្ត្រី សិទ្ធិកុមារ និងសិទ្ធិជនអន្តោប្រវេសន្តជាដើម។ ការកសាងស្ថាប័នសិទ្ធិមនុស្សរឹងមាំនានានៅតាមប្រទេស គឺជាអ្វីដែលទៅពេលអនាគតដ៏វែងខាងមុខនឹងធានាបានថា សិទ្ធិមនុស្សត្រូវបានគេការពារ និងវិវត្តន៍ទៅមុខក្នុងលក្ខណៈមួយ ប្រកបដោយនិរន្តរភាព។ ដូច្នេះហើយបានជាការដាក់ ឬការពង្រឹងប្រព័ន្ធការពារសិទ្ធិមនុស្សថ្នាក់ជាតិនៅតាមប្រទេសនីមួយៗ ដែលឆ្លុះបញ្ចាំងទៅលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនោះ គួរតែជាវត្ថុបំណងដ៏ចម្បងមួយ របស់អង្គការសហប្រជាជាតិ។ សកម្មភាពទាំងនេះមានសារៈសំខាន់ជាពិសេស នៅក្នុងបណ្ដាប្រទេសដែលទើបចាកផុតពីជំលោះ"។

## សិទ្ធិមនុស្សនៅក្នុងមហាសន្និបាត និងកម្មវិធីអចិន្ត្រៃយ៍របស់ខ្លួន

មហាសន្និបាត ជាស្ថាប័ននីតិបញ្ញត្តិមួយខ្ពស់ជាងគេបំផុតរបស់អង្គការសហប្រជាជាតិ ដែលមិនត្រឹមតែធានាឱ្យមានការអនុម័តអនុសញ្ញាសិទ្ធិមនុស្ស សេចក្ដីថ្លែងការណ៍ គោលការណ៍ វិធាន និងលិខិតុបករណ៍មួយឈុតគួរឱ្យចាប់អារម្មណ៍ប៉ុណ្ណោះទេ ថែមទាំងពិភាក្សានៅគ្រប់សម័យប្រជុំទាំងអស់ ជាពិសេសនៅក្នុងគណៈកម្មាធិការទី៣ ទទួលបន្ទុកកិច្ចការសង្គមកិច្ច មនុស្សធម៌ វប្បធម៌ និង ស្ថានភាពសិទ្ធិមនុស្សជាក់ស្ដែង នៅក្នុងរដ្ឋជាច្រើន និងអនុម័តសេចក្ដីសម្រេចចិត្តនានា ដែលពាក់ព័ន្ធនឹងបញ្ហាទាំងនោះផងដែរ។

កម្មវិធី មូលនិធិ និងស្ថាប័នជាច្រើនរបស់អង្គការសហប្រជាជាតិ ដូចជា កម្មវិធី អភិវឌ្ឍន៍សហប្រជាជាតិ (UNDP) កម្មវិធីស្បៀងអាហារពិភពលោក (WFP) មូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) កម្មវិធីសហប្រជាជាតិសម្រាប់ការតាំងលំនៅដ្ឋាន មនុស្សជាតិ និងទីក្រុង (UN-HABITAT) សកលវិទ្យាល័យសហប្រជាជាតិ (UNU) ការិយាល័យឧត្ដមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR) ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) សូមមើលជំពូកទី ៧) អនុវត្តសកម្មភាពសំខាន់ៗនៅក្នុងវិស័យសិទ្ធិមនុស្ស។

## សិទ្ធិមនុស្ស និង ក្រុមប្រឹក្សាសន្តិសុខ

ក្រុមប្រឹក្សាសន្តិសុខ ដែលជាស្ថាប័នតែមួយគត់របស់អង្គការសហប្រជាជាតិ ដែលមានសមត្ថកិច្ចអនុម័ត សេចក្តីសម្រេចចិត្តដែលភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ និងដាក់ឱ្យអនុវត្តសេចក្តីសម្រេចចិត្តទាំងនេះ ក្នុងករណីណាដែលរដ្ឋសមាជិកមិនគោរពតាមនោះ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះបានដើរតួនាទីកាន់តែសកម្មឡើងនៅក្នុងវិស័យសិទ្ធិមនុស្ស។ បច្ចុប្បន្ននេះ សិទ្ធិមនុស្សបង្កើតបានជាផ្នែកមួយសំខាន់នៃប្រតិបត្តិការរក្សាសន្តិភាព និងប្រតិបត្តិការកសាងសន្តិភាព ហើយមានអ្នកជំនាញការសិទ្ធិមនុស្សជាច្រើនត្រូវបានដាក់ពង្រាយនៅតាមប្រទេសនានា ដើម្បីឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅក្នុងបរិបទក្រោយជំលោះ ហើយជួយជ្រោមជ្រែងប្រទេសទាំងនោះក្នុងការពង្រឹងនីតិរដ្ឋ ក្នុងការកសាងប្រព័ន្ធតុលាការមួយឯករាជ្យ ក្នុង-ការជួយពង្រឹងការងារ អនុវត្តច្បាប់ក្នុងការគ្រប់គ្រងពន្ធនាគារ និងក្នុងការបង្កើតគណៈកម្មការជាតិសិទ្ធិមនុស្ស និងស្ថាប័នដទៃទៀត ដែលចាំបាច់សម្រាប់ការការពារសិទ្ធិមនុស្ស។ បន្ថែមលើនេះទៀត ដោយ សារមានករណីកើនឡើងកាន់តែច្រើន ក្រុមប្រឹក្សាសន្តិសុខបានចាត់ទុកការរំលោភសិទ្ធិមនុស្សដ៏កំរោល និងជាប្រព័ន្ធថា ជាការគំរាមកំហែងសន្តិភាព ហើយជាលទ្ធផលក៏បានចាត់វិធានការតាមជំពូកទី VII នៃធម្មនុញ្ញសហប្រជាជាតិ ដោយដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងទណ្ឌកម្មឯទៀត ដោយអនុញ្ញាតឱ្យប្រើប្រាស់កំលាំងយោធា និង-បង្កើតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ ចំពោះករណីទាំងនេះ (សូមមើលជំពូកទី ១០)។

## សិទ្ធិមនុស្ស និង "គ្រួសារអង្គការសហប្រជាជាតិ"

ប្រព័ន្ធអង្គការសហប្រជាជាតិ ត្រូវបានហៅក្រៅផ្លូវការថាជា "គ្រួសារអង្គការសហប្រជាជាតិ" ដែល-មានអង្គការសហប្រជាជាតិ និងទីភ្នាក់ងារជំនាញឯកទេសផ្សេងៗកាន់តែច្រើនឡើងៗ ដែលជាអង្គការអន្តររដ្ឋាភិបាលឯករាជ្យតាមផ្លូវច្បាប់ ដោយរក្សាទំនាក់ទំនងពិសេសជាមួយអង្គការសហប្រជាជាតិ ផ្អែកតាមកិច្ចព្រមព្រៀងជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច

ក្រោមមាត្រា ៦៣ នៃធម្មនុញ្ញសហប្រជាជាតិ។ អាស្រ័យហេតុនេះ គោលនយោបាយ "សមាហរណកម្មសិទ្ធិមនុស្ស" របស់អង្គការសហប្រជាជាតិក៏អនុវត្តផងដែរចំពោះទីភ្នាក់ងារជំនាញឯកទេសទាំងនេះដែលក្នុងនោះទីភ្នាក់ងារភាគច្រើន មានប្រវត្តិយូរអង្វែងក្នុងសកម្មភាពទាក់ទងនឹងសិទ្ធិមនុស្សជាក់លាក់។

**ប្រអប់ ២៨**

## ស្ថាប័នសហប្រជាជាតិសំខាន់ៗ ដែលសកម្មក្នុងវិស័យសិទ្ធិមនុស្ស

### ទីភ្នាក់ងារជំនាញឯកទេស

អង្គការពលកម្មអន្តរជាតិ (ILO)

អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ (FAO)

អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌សហប្រជាជាតិ (UNESCO)

អង្គការសុខភាពពិភពលោក (WHO)

### កម្មវិធី និងមូលនិធិ

អង្គការ UNICEF (មូលនិធិសហប្រជាជាតិសម្រាប់កុមារ)

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)

មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី (UNIFEM)

កម្មវិធីសហប្រជាជាតិសម្រាប់ការតាំងលំនៅដ្ឋានមនុស្សជាតិ និងទីក្រុង (UN-HABITAT)

ទីភ្នាក់ងារសហប្រជាជាតិដើម្បីសង្គ្រោះ និងការងារសម្រាប់ជនភៀសខ្លួនប៉ាឡេស្ទីននៅតំបន់មជ្ឈឹមបូព៌ា (UNRWA)

កម្មវិធីស្បៀងអាហារពិភពលោក (WFP)

### វិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល

វិទ្យាស្ថានសហប្រជាជាតិសម្រាប់ការបណ្តុះបណ្តាល និងសិក្សាស្រាវជ្រាវ (UNITAR)

វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលអន្តរជាតិនៃអង្គការសហប្រជាជាតិ ដើម្បីចម្រើនស្ត្រី (INSTRAW)

វិទ្យាស្ថានសិក្សាស្រាវជ្រាវសហប្រជាជាតិ សម្រាប់ការអភិវឌ្ឍន៍សង្គម (UNRISD)

**ស្ថាប័នដែលបង្កើតដោយក្រុមប្រឹក្សាសន្តិសុខ**

សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY)

សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់ប្រទេសរ៉្វាន់ដា (ICTR)

**អង្គភាពផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិ**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

ការិយាល័យស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR)

សកលវិទ្យាល័យសហប្រជាជាតិ (UNU)

**ប្រអប់ ២៩**

## ជំនួយបច្ចេកទេសចំពោះរដ្ឋ និងចំពោះសភា

### ជំនួយបច្ចេកទេសរបស់ OHCHR ក្នុងវិស័យសិទ្ធិមនុស្ស

កម្មវិធីសហប្រតិបត្តិការបច្ចេកទេសអង្គការសហប្រជាជាតិនៅក្នុងវិស័យសិទ្ធិមនុស្ស ជួយដល់រដ្ឋនានាតាមការស្នើសុំ ដើម្បីកសាង និងពង្រឹងរចនាសម្ព័ន្ធជាតិទាំងឡាយ ដែលមានផលប៉ះពាល់ដោយផ្ទាល់លើការគោរពសិទ្ធិមនុស្សទូទៅ និង ការពង្រឹងនីតិរដ្ឋ។

អង្គភាពទាំងឡាយនៃកម្មវិធីនេះ ផ្តោតលើការដាក់បញ្ចូលបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ទៅក្នុងច្បាប់ និង គោលនយោបាយជាតិ ដោយកសាង និងពង្រឹងស្ថាប័នជាតិឱ្យមានសមត្ថភាពលើកស្ទួយ និងការពារសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ តាមរយៈការតាក់តែងផែនការសកម្មភាពជាតិសម្រាប់លើកស្ទួយ និងការពារសិទ្ធិមនុស្ស ដោយផ្តល់ការអប់រំ និងវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្ស និងលើកស្ទួយវប្បធម៌សិទ្ធិមនុស្ស។ ជំនួយឧបត្ថម្ភបែបនេះ

ធ្វើឡើងក្នុងទម្រង់ជាការផ្តល់សេវាពិគ្រោះយោបល់ជាមួយអ្នកជំនាញការ ផ្តល់វគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ អាហារូបករណ៍ សម្រាប់ការស្រាវជ្រាវ ជំនួយហិរញ្ញវត្ថុ ការផ្តល់ព័ត៌មាន និងការប្រមូល ចងក្រងឯកសារ និងការវាយតម្លៃអំពីសេចក្តីត្រូវការផ្នែកសិទ្ធិមនុស្ស នៅថ្នាក់ជាតិ ។

អង្គការសហប្រជាជាតិ ចាត់ទុកកិច្ចសហប្រតិបត្តិការបច្ចេកទេសថាជាកិច្ចការបន្ថែមទៅលើការឃ្លាំមើល និងការស៊ើបអង្កេតក្រោមកម្មវិធីសិទ្ធិមនុស្ស មិនមែនជាកិច្ចការជំនួសនោះទេ។ ដូចបានបញ្ជាក់នៅក្នុងរបាយការណ៍ពាក់ព័ន្ធនានារបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ និងសេចក្តីសម្រេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការផ្តល់សេវាពិគ្រោះយោបល់ និងជំនួយបច្ចេកទេស មិនកាត់បន្ថយការទទួលខុសត្រូវរបស់រដ្ឋាភិបាលលើស្ថានភាពសិទ្ធិមនុស្សនៅក្នុងដែនដីរបស់ខ្លួនឡើយ ហើយក៏មិនធ្វើឱ្យប្រទេសនោះរួចផុតពីការតាមដានពិនិត្យមើល ក្រោមនីតិវិធីនានារបស់អង្គការសហប្រជាជាតិ សមស្រប ក៏ទេដែរ ។

**ជំនួយបច្ចេកទេសសហភាពអន្តរសភា (IPU)**

IPUផ្តល់សេវាពិគ្រោះយោបល់លើកិច្ចការទាំងមូលរបស់សភា ជាពិសេសលើតួនាទី រចនាសម្ព័ន្ធ និងរបៀបធ្វើការរបស់សភាជាតិមួយ ។ កម្មវិធីរបស់ IPU រួមមានគំរោងបណ្តុះ បណ្តាលបុគ្គលិកសភា ផ្តល់ធនធានខាងសម្ភារៈ និងបរិក្ខា និងរៀបចំសិក្ខាសាលាអំពី ប្រធានបទដែលជាសារប្រយោជន៍ជាក់លាក់ដល់សមាជិកសភា។ គំរោងភាគច្រើនក្នុង ចំណោមគំរោងទាំងនោះលើកឡើងអំពីបញ្ហាសិទ្ធិមនុស្ស និងបញ្ហាយេនឌ័រ ។ ក្នុងស្មារតីនោះ IPU សហការយ៉ាងជិតស្និទ្ធ ជាមួយ UNDP និង OHCHR ។ ព័ត៌មានបន្ថែមស្តីពីជំនួយ បច្ចេកទេសរបស់ IPU អាចរកបានតាមរយៈលេខាធិការដ្ឋានរបស់ IPU ។

**អង្គការពលកម្មអន្តរជាតិ (ILO)** ជាភ្នាក់ងារសំខាន់មួយ ដែលធ្វើការក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច ដូចជា សិទ្ធិទទួលបានការងារធ្វើ សិទ្ធិទទួលបានការប្រព្រឹត្តស្មើភាពគ្នា និងត្រឹមត្រូវ និងសិទ្ធិទទួលបានលក្ខខណ្ឌការងារប្រកបដោយសុខភាព សិទ្ធិបង្កើតសហជីព រួមទាំងសិទ្ធិធ្វើកូដកម្ម និងសិទ្ធិចរចាជាសមូហភាព ព្រមទាំងមានបទបញ្ញត្តិពាក់ព័ន្ធ ដូចជាការហាមប្រាមការងារដោយបង្ខំ ការហាមប្រាមពលកម្មកុមារតាមទម្រង់ណាមួយដែលធ្ងន់ធ្ងរបំផុត និងហាមប្រាមការរើសអើងក្នុងការជួលកម្មករ និងការរើសអើងនៅកន្លែងធ្វើការ ។

ILO ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៩ ហើយដែលបាន ប្រតិបត្តិការការងារផ្អែកលើ "ប្រព័ន្ធត្រីភាគី " ដែលបានដាក់តំណាងរបស់និយោជក និង តំណាងនិយោជិតនៅលើមូលដ្ឋានមួយស្មើភាពគ្នា ឬប្រហាក់ប្រហែលគ្នាជាមួយនឹងតំណាងរបស់រដ្ឋាភិបាលនោះ អង្គការនេះបានបង្កើតសន្ធិសញ្ញាអន្តរជាតិជាមូលដ្ឋាន អនុសាសន៍ និងនីតិវិធីជាច្រើន សម្រាប់ការពារសិទ្ធិសេដ្ឋកិច្ច និង សិទ្ធិមនុស្សផ្សេងៗ ទៀត។

**អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌សហប្រជាជាតិ (UNESCO)** ជាទីភ្នាក់ងារសំខាន់មួយក្នុងវិស័យសិទ្ធិវប្បធម៌ (ជាពិសេសសិទ្ធិទទួលបានការអប់រំ) ហើយបានបង្កើតលិខិតុបករណ៍ និងនីតិវិធីជាច្រើនដើម្បីការពារសិទ្ធិទាំង នោះ។ UNESCO ដើរតួនាទីសំខាន់មួយក្នុងការអនុវត្តន៍ទិសដៅសហសវត្សសហប្រជាជាតិ សម្រាប់ការអប់រំសិទ្ធិ មនុស្ស (១៩៩៥ ដល់ ២០០៤) ហើយនិងការលើកស្ទួយវប្បធម៌សកលមួយសម្រាប់ សិទ្ធិមនុស្ស និង សន្តិភាព។

**អង្គការសុខភាពពិភពលោក (WHO)** ជាទីភ្នាក់ងារសំខាន់មួយ សម្រាប់លើកស្ទួយ និងការពារសិទ្ធិមានសុខភាពល្អ ហើយក្នុងចំណោមភារកិច្ចជាច្រើនទៀត អង្គការនេះ បានអភិវឌ្ឍកម្មវិធីពិភពលោកមួយប្រកបដោយជោគជ័យស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍។

**អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ (FAO)** ជាទីភ្នាក់ងារធំជាងគេបំផុតក្នុងចំណោម ទីភ្នាក់ងារជំនាញឯកទេសនានា ហើយជាអ្នកដើរតួសំខាន់មួយក្នុងការលើកស្ទួយ និងការការពារសិទ្ធិមានចំណីអាហារ ដែលជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗបំផុតជាច្រើនក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ទិសដៅអភិវឌ្ឍន៍ដ៏ចម្បងនេះ ត្រូវបានអនុម័តយល់ព្រមដោយប្រមុខរដ្ឋ និងរដ្ឋាភិបាលប្រមាណជា ១៥០ ប្រទេស ក្នុងអំឡុងពេលជំនួបកំពូលសហសវត្ស ដែលបានរៀបចំឡើងនៅខែកញ្ញា ឆ្នាំ២០០០។

# ជំពូកទី ៩
# សន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់ និង ការតាមឃ្លាំមើល

បន្ថែមលើប្រព័ន្ធការពារសិទ្ធិមនុស្សឈរលើមូលដ្ឋាន នៃធម្មនុញ្ញសហប្រជាជាតិ ដែលអនុវត្តលើរដ្ឋទាំងអស់ និងប្រព័ន្ធឈរលើមូលដ្ឋាននៃសន្ធិសញ្ញាសហប្រជាជាតិ ដែល អនុវត្តតែលើរដ្ឋសមាជិកប៉ុណ្ណោះនោះ រដ្ឋជាច្រើននៅទ្វីបអាហ្វ្រិក អាមេរិក និងអឺរ៉ុប បានទទួលយកកាតព្វកិច្ចសិទ្ធិមនុស្សដែលជាប់កាតព្វកិច្ចនៅថ្នាក់តំបន់ ហើយបាន យល់ព្រម ឱ្យមានការឃ្លាំមើលជាអន្តរជាតិ។ មិនទាន់មានសន្ធិសញ្ញាសិទ្ធិមនុស្ស និង យន្តការឃ្លាំមើល ថ្នាក់តំបន់ ត្រូវបានអនុម័ត នៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៅឡើយ ទេ។

## ទ្វីបអាហ្វ្រិក

នៅឆ្នាំ១៩៨១ រដ្ឋសមាជិករបស់អង្គការសហភាពអាហ្វ្រិក ដែលតាំងពីពេលនោះ មកបាន ក្លាយជាសហភាព អាហ្វ្រិក (AU) បានអនុម័តធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិ ប្រជាពលរដ្ឋ ដែលបានចូលជាធរមាននៅខែតុលា ឆ្នាំ១៩៨៦។ វាជាសន្ធិសញ្ញា សិទ្ធិមនុស្សទូទៅមួយ ហើយត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋសមាជិកទាំង ៥៣ នៃសហភាព អាហ្វ្រិក។ ដូចដែលចំណងជើងរបស់វាបានបញ្ជាក់ផងដែរ បន្ថែមលើសិទ្ធិពលរដ្ឋ សិទ្ធិ នយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សន្ធិសញ្ញាថ្នាក់តំបន់នេះក៏ចែងអំពីសិទ្ធិ សមូហភាពរបស់ប្រជាជនក្នុងការទទួលបានសមភាព សិទ្ធិស្វ័យសម្រេច ឆន្ទានុសិទ្ធិ លើទ្រព្យសម្បត្តិ

និងធនធានធម្មជាតិ ការអភិវឌ្ឍន៍ សន្តិភាព និងសន្តិសុខជាតិនិងអន្តរជាតិ និង "បរិយាកាយដ៏ពេញចិត្តជាទូទៅមួយ " ។ ទោះជាសិទ្ធិសាមគ្គីភាពរបៀបនេះ ដែលត្រូវបានគេហៅថា ជាសិទ្ធិមនុស្ស "ជំនាន់ទី៣" មានសារៈសំខាន់ផ្នែកនយោបាយជាដុំកំភួនក៏ដោយ ក៏ខ្លឹមសារគតិយុត្តិក្នុងសន្ធិសញ្ញាដែលជាប់កាតព្វកិច្ចនេះ នៅមានការជជែកគ្នានៅឡើយ (សូមមើលជំពូកទី ២) ។ បន្ថែមលើធម្មនុញ្ញនេះ AU បានអនុម័តសន្ធិសញ្ញា ក្នុងវិស័យ ការពារសិទ្ធិជនភៀសខ្លួន និងសិទ្ធិកុមារ ។

ធម្មនុញ្ញនេះ មានចែងអំពីនីតិវិធីដាក់ពាក្យបណ្តឹងនៅចំពោះមុខគណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ ដែលមានទីស្នាក់ការធំនៅទីក្រុង Banjul ប្រទេសហ្គំប៊ីយ៉ា ។ ដោយសារតែពាក្យបណ្តឹងអាចដាក់ ដោយជនណាម្នាក់ក៏បាន (រួមទាំង រដ្ឋនានា ដែលអាចដាក់ពាក្យបណ្តឹងអន្តររដ្ឋ និង បុគ្គលណាមួយ ឬអង្គភាពសមូហភាពណាមួយ ដូចជាអង្គការក្រៅរដ្ឋាភិបាល ក្រុមគ្រួសារ ក្រុមបក្សសម្ព័ន្ធ សហគមន៍ ឬក្រុមផ្សេងៗទៀត) នោះ ដូច្នេះ សំណួរផ្លូវច្បាប់ទាក់ទងនឹងឋានៈជនរងគ្រោះ មិនកើតមាននោះទេ ។ គណៈកម្មការអាហ្វ្រិកមិនបើកសវនាការលើពាក្យ បណ្តឹងដាច់ដោយឡែកទេ ប៉ុន្តែបើកសវនាការតែលើពាក្យបណ្តឹងទាំងឡាយណា ដែលបង្ហាញអំពីអត្ថិភាពនៃបែបផែនរំលោភសិទ្ធិមនុស្សនិងសិទ្ធិប្រជាពលរដ្ឋដ៏ធ្ងន់ធ្ងរ និងក្នុងទ្រង់ទ្រាយធំ ។ ក្នុងករណីរបៀបនេះ គណៈកម្មការអាហ្វ្រិកអាច ធ្វើការសិក្សាស៊ីជម្រៅបាន លុះត្រាតែមានការស្នើសុំពីសភានៃប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ដែលជាស្ថាប័ននយោបាយ មួយខ្ពស់បំផុតរបស់ AU ។ បន្ថែមលើនីតិវិធីបណ្តឹងនេះ គណៈកម្មការពិនិត្យផងដែរ លើរបាយការណ៍របស់រដ្ឋនានាក្រោមនីតិវិធីមួយស្រដៀងគ្នានឹងនីតិវិធីដែលស្ថាប័នសន្ធិសញ្ញាសហប្រជាជាតិអនុវត្តដែរ ។

ពិធីសារបន្ថែមមួយលើធម្មនុញ្ញអាហ្វ្រិក ដែលត្រូវបានអនុម័តនៅឆ្នាំ១៩៩៨ ហើយដែលចែងអំពីការបង្កើតតុលាការសិទ្ធិមនុស្សនិងសិទ្ធិប្រជាពលរដ្ឋអាហ្វ្រិក បានចូលជាធរមាននៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៤ ។

ប្រអប់ ៣០

## សន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់

### ក្រុមប្រឹក្សាអឺរ៉ុប

អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (១៩៥០-១៩៥៣) និងពិធីសារបន្ថែម។

ធម្មនុញ្ញសង្គមកិច្ចអឺរ៉ុប (១៩៦១-១៩៦៥) ពិធីសារបន្ថែម និងធម្មនុញ្ញសង្គមកិច្ចអឺរ៉ុប ដែលបានធ្វើវិសោធន កម្ម (១៩៩៦-១៩៩៩)។

អនុសញ្ញាអឺរ៉ុបស្តីពីឋានៈគតិយុត្តិរបស់កម្មករអន្តោប្រវេសន្ត (១៩៧៧-១៩៨៣)។

អនុសញ្ញាអឺរ៉ុបស្តីពីការបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលអមនុស្សធម៌ ឬ បន្ថោកបន្ទាប (១៩៨៧-១៩៨៩)។

ធម្មនុញ្ញអឺរ៉ុបសម្រាប់ភាសាតំបន់ និងភាសាជនជាតិភាគតិច (១៩៩២-១៩៩៨)។

អនុសញ្ញាក្របខណ្ឌសម្រាប់ការពារជនជាតិភាគតិចថ្នាក់ជាតិ (១៩៩៥-១៩៩៨)។

អនុសញ្ញាអឺរ៉ុបស្តីពីការអនុវត្តន៍សិទ្ធិកុមារ (១៩៩៦-២០០០)។

អនុសញ្ញាស្តីពីសិទ្ធិមនុស្ស និង ឱសថជីវសាស្រ្ត (១៩៩៧-១៩៩៩)។

អនុសញ្ញាអឺរ៉ុបស្តីពីសញ្ជាតិ (១៩៩៧-២០០០)។

### អង្គការនៃរដ្ឋអាមេរិក

អនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស (១៩៦៩-១៩៧៨) និង ពិធីសារបន្ថែម។

អនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មលើអំពើទារុណកម្ម (១៩៨៥-១៩៨៧)។

អនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការបង្ការ ការដាក់ទណ្ឌកម្ម និងការបំបាត់អំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ (១៩៩៤-១៩៩៥)។

អនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការបាត់ខ្លួនបុគ្គលដោយបង្ខំ (១៩៩៤-១៩៩៦)។

អនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការជួញដូរអនីតិជនថ្នាក់អន្តរជាតិ (១៩៩៤-១៩៩៧)។

អនុសញ្ញាអន្តរអាមេរិកកាំងស្តីពីការបំ ាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹង ជនពិការ (១៩៩៩-២០០១) ។

**សហភាពអាហ្វ្រិក (អតីតអង្គការសហភាពអាហ្វ្រិក)**

ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និង សិទ្ធិប្រជាពលរដ្ឋ (១៩៨១-១៩៨៦) ។

អនុសញ្ញាស្តីពីទិដ្ឋភាពជាក់លាក់ទាំងឡាយនៃបញ្ហាជនភៀសខ្លួននៅអាហ្វ្រិក (១៩៦៩-១៩៧៤) ។

អនុសញ្ញាស្តីពីសិទ្ធិ និង សុខុមាលភាពកុមារអាហ្វ្រិក (១៩៩០-១៩៩៩) ។

## ទ្វីបអាមេរិក

ប្រព័ន្ធអន្តរអាមេរិកកាំងសម្រាប់ការពារសិទ្ធិមនុស្ស មានដំណើរការពីរដាច់ដោយឡែកពីគ្នា ដែលមួយផ្អែកលើធម្មនុញ្ញរបស់អង្គការរដ្ឋអាមេរិក (OAS) និងមួយទៀត ផ្អែកលើកតិកាសញ្ញា ទីក្រុង San José ប្រទេស កូស្តារីកា (អនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស) ។ ទន្ទឹមនឹង ដំណើរការដែលផ្អែកលើធម្មនុញ្ញនេះ អាចអនុវត្តទៅលើរដ្ឋសមាជិកទាំងអស់របស់ OAS នោះ អនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្សជាប់កាតព្វកិច្ចផ្លូវច្បាប់ តែលើរដ្ឋភាគីប៉ុណ្ណោះ ។ អនុសញ្ញានេះ ដែលបានអនុម័តនៅឆ្នាំ១៩៦៩ ហើយបានចូលជាធរមាន តាំងពីឆ្នាំ១៩៧៨ មកនោះ ផ្តោតលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ប៉ុន្តែត្រូវបាន បំពេញបន្ថែមដោយពិធីសារ-បន្ថែមមួយ (១៩៨៨-១៩៩៩) ដែលមានចែងអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ ថែមពីលើនេះទៀត OAS បានអនុម័តសន្ធិសញ្ញាពិសេសនានា ស្តីពីការបាត់ខ្លួនដោយបង្ខំ ការធ្វើទារុណកម្ម អំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ ការជួញដូរ អនីតិជនថ្នាក់អន្តរជាតិ និង-ការរើសអើងប្រឆាំងនឹងជនពិការ ។

អនុសញ្ញានេះមានចែងអំពីនីតិវិធីដាក់ពាក្យបណ្តឹងអន្តររដ្ឋ និងបណ្តឹងបុគ្គលទៅ គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិក (IACHR) ជាស្ថាប័នតាមឃ្លាំមើលមួយ មានលក្ខណៈ

ស្រដៀងគ្នានឹងតុលាការដែលមានទីតាំងនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី និងតុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង ដែលតាំងនៅទីក្រុង San José ( ប្រទេស កូស្តារីកា) ។ ក្នុងចំណោមរដ្ឋសមាជិកចំនួន ៣៥ របស់ OAS មានតែរដ្ឋ ២៥ ប៉ុណ្ណោះ ដែលជាភាគីនៃអនុសញ្ញានេះ ។ នៅចំពោះមុខគណៈកម្មការអន្តរអាមេរិក មានតែប្រព័ន្ធទន់ខ្សោយជាងគេដែលផ្អែកលើធម្មនុញ្ញប៉ុណ្ណោះត្រូវអនុវត្តចំពោះរដ្ឋ ១០ ដែលមិនបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ហើយយុត្តាធិការរបស់តុលាការអន្តរអាមេរិកកាំង គឺជាជំរើសសំរាប់តែរដ្ឋទាំងឡាយណា ដែលជាភាគីនៃអនុសញ្ញានេះប៉ុណ្ណោះ ។

ភាគច្រើនលើសលុបនៃពាក្យបណ្តឹងរាប់ពាន់ ដែលបានដាក់ប្តឹងតាមប្រព័ន្ធនេះ ត្រូវបានដោះស្រាយដោយគណៈកម្មការអន្តរអាមេរិកតែប៉ុណ្ណោះ ដែលការប្រកាសមិនទទួល-ពាក្យបណ្តឹងទាំងនេះ បង្កលក្ខណៈងាយស្រួលឱ្យមាន ដំណោះស្រាយប្រកបដោយមិត្តភាព ឬបោះពុម្ពផ្សាយសេចក្តីសន្និដ្ឋាននានារបស់ខ្លួនក្នុងរបាយការណ៍ដោយផ្អែកលើអង្គសេចក្តី ។ របាយការណ៍របៀបនេះ មានបញ្ចូលអនុសាសន៍មិនជាប់កាតព្វកិច្ចមួយចំនួន ដែលតាម-ការអនុវត្តន៍ជាក់ស្តែង និងជារឿយៗត្រូវបានរដ្ឋាភិបាលសាមីមិនអើពើ ។ អ្នកប្តឹងទាំងនោះមិនមានសិទ្ធិយកសំណុំរឿងរបស់ខ្លួន ទៅប្តឹងនៅចំពោះមុខតុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំងបានទេ មានតែរដ្ឋពាក់ព័ន្ធ និងគណៈកម្មការនោះប៉ុណ្ណោះ ទើបអាចធ្វើបាន ។ ដោយអនុលោមទៅតាមវិធាននៃនីតិវិធីដែលទើបបានកែប្រែថ្មីៗនេះ ទោះបីជាគណៈកម្មការបានផ្តើមបញ្ជូនសំណុំរឿងកាន់តែច្រើនទៅតុលាការក៏ដោយ ក៏រហូតមកទល់ពេលនេះមានតែសំណុំរឿងបុគ្គលចំនួនប្រហែល ៥០ ប៉ុណ្ណោះ ដែលតុលាការនេះបានសម្រេចចេញសាលក្រមស្ថាពរ ដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ។ សំណុំរឿងទាំងនោះ ប្តឹងពីការរំលោភសិទ្ធិមនុស្ស នៅប្រទេសមួយចំនួននៃទ្វីបអាមេរិកខាងត្បូង និងអាមេរិក-កណ្តាល ។ គេកំណត់បានថាការរំលោភសិទ្ធិមនុស្សដ៏កំរោល និងជាប្រព័ន្ធ (រួមមាន ការធ្វើទារុណកម្ម ការសម្លាប់ តាមទំនើងចិត្ត និងការបាត់ខ្លួនដោយបង្ខំ) ពិតជាបានកើតឡើងក្នុងចំណោមប្រទេសទាំងនោះ ភាគច្រើន ហើយតុលាការបានដាក់ចេញនូវវិធានការទូលំទូលាយនៃ

សំណងជួសជុលលើសពីសំណងជាទឹកប្រាក់ទៅទៀត ជូនដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។

ក្រៅពី "យុត្តាធិការលើវិវាទប្បដិវិវាទ" របស់ខ្លួន (សមត្ថកិច្ចបើកសវនាការជំនុំជម្រះក្តីរវាងភាគីបណ្តឹង) តុលាការនេះក៏មានសមត្ថកិច្ចផងដែរ ក្នុងការផ្តល់យោបល់ណែនាំលើការបកស្រាយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ (ជាពិសេស អនុសញ្ញាអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស) ហើយវាយតម្លៃលើភាពស្របគ្នារវាងច្បាប់ជាតិ និងសន្ធិសញ្ញាទាំងនេះ។

## តំបន់អារ៉ាប់

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៤ រដ្ឋសមាជិករបស់សម្ព័ន្ធអារ៉ាប់ បានអនុម័តធម្មនុញ្ញអារ៉ាប់ស្តីពីសិទ្ធិមនុស្ស ក៏ប៉ុន្តែគ្មានរដ្ឋណាមួយក្នុងចំណោមរដ្ឋសមាជិកទាំង ២២ របស់សម្ព័ន្ធនេះ បានចុះហត្ថលេខាលើធម្មនុញ្ញនេះទេ។ នៅខែមីនា ឆ្នាំ២០០៣ ក្រុមប្រឹក្សាសម្ព័ន្ធអារ៉ាប់បានសម្រេចធ្វើពង្រាងធម្មនុញ្ញនោះសារឡើងវិញ ដើម្បីស្របតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ គណៈកម្មាធិការនៃអ្នកជំនាញការ ដែលមានសមាជិកអារ៉ាប់របស់ស្ថាប័នតាមឃ្លាំមើលសន្ធិសញ្ញាសហប្រជាជាតិ ត្រូវបានបង្កើតឡើងដោយផ្អែកលើអនុស្សារណៈយោគយល់មួយ ដែលបានចុះហត្ថលេខាដោយសម្ព័ន្ធនៃរដ្ឋអារ៉ាប់ និង OHCHR នៅខែមេសា ឆ្នាំ២០០២ ដើម្បីជួយជ្រោមជ្រែងសម្ព័ន្ធអារ៉ាប់ក្នុងកិច្ចការ នោះ។ ពង្រាងដែលស្នើឡើងដោយអ្នកជំនាញការទាំងនោះ ត្រូវបានទទួលយកដោយគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកសិទ្ធិមនុស្សរបស់សម្ព័ន្ធអារ៉ាប់ ក្នុងការធ្វើពង្រាងឡើងវិញនេះ។ បន្ទាប់មកពង្រាងនោះ ត្រូវបានដាក់ជូនពិភាក្សាជាចុងក្រោយ និងអនុម័តនៅក្នុងជំនួបកំពូលមួយនៃសម្ព័ន្ធរដ្ឋអារ៉ាប់ ក្នុងខែឧសភា ឆ្នាំ២០០៤ ជាកន្លែងដែលធម្មនុញ្ញនោះ ត្រូវបានអនុម័តយល់ព្រម ។ រដ្ឋអារ៉ាប់មួយចំនួន កំពុងដំណើរការផ្តល់សច្ចាប័នលើធម្មនុញ្ញនោះ។

ទោះបីជា OHCHR បានសំដែងការព្រួយបារម្ភអំពីបទបញ្ញត្តិមួយចំនួននៃ ធម្មនុញ្ញ ក្នុងទម្រង់បច្ចុប្បន្នរបស់វាក៏ដោយ ក៏បទបញ្ញត្តិថ្មីៗមានលក្ខណៈទំនើបច្រើនជាងបទបញ្ញត្តិមុនៗទាក់ទងនឹងបញ្ហាផ្សេងៗ ដូចជា ស្ថានភាពក្នុងគ្រាមានអាសន្ន កិច្ចធានាការពារដល់ ការជំនុំជម្រះដោយយុត្តិធម៌ ទាសភាព អំពើហឹង្សាលើផ្លូវភេទ ពិការភាព និង-ការជួញដូរ។ ដោយសារធម្មនុញ្ញនេះ មានចែងអំពីយន្តការតាមឃ្លាំមើល ដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិផងដែរនោះ ការអនុម័តលើ លិខិតុបករណ៍នេះបានបើកផ្លូវឱ្យមានការបង្កើតយន្តការការពារ និងលើកស្ទួយសិទ្ធិមនុស្សថ្នាក់តំបន់មួយថែមទៀត។ ទោះជាយ៉ាងនេះក៏ដោយ ប្រព័ន្ធថ្មីនេះ មិនបានគិតដល់នីតិវិធីបណ្តឹងជាបុគ្គលឡើយ ក៏ប៉ុន្តែមាត្រា ៥២ នៃធម្មនុញ្ញនេះមានចែងអំពីលទ្ធភាពក្នុងការអនុម័តពិធីសារបន្ថែមផ្សេងៗទៀត។

## តំបន់អាស៊ី និង ប៉ាស៊ីហ្វិក

នៅអាស៊ីនិងប៉ាស៊ីហ្វិកមិនមានអនុសញ្ញាថ្នាក់តំបន់ស្តីពីសិទ្ធិមនុស្សទេ។ ទោះជាយ៉ាងនេះក៏ដោយ តាមរយៈ OHCHR ប្រទេសនានានៅក្នុងតំបន់បានយកចិត្តទុកដាក់លើការពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដើម្បីលើកស្ទួយការគោរពសិទ្ធិមនុស្ស។ នៅក្នុងសិក្ខាសាលាថ្នាក់តំបន់អាស៊ីនិងប៉ាស៊ីហ្វិកមួយចំនួន ជាពិសេស សិក្ខាសាលាមួយដែលធ្វើនៅទីក្រុងតេអេរ៉ង់ ក្នុងឆ្នាំ១៩៩៨ នោះ ក្របខណ្ឌនៃកិច្ចសហការមួយត្រូវបានបង្កើតឡើង ហើយមានការយល់ព្រមជាឯកច្ឆ័ន្ទលើគោលការណ៍ផ្សេងៗ និងវិធីសាស្ត្រ "សាងសង់ស្ពានចម្លងពីមួយទៅមួយ" និង "ជាជំហានៗ" ដែលអាចឈានទៅដល់ការរៀបចំថ្នាក់តំបន់ តាមរយៈការពិគ្រោះយោបល់ទូលំទូលាយ ក្នុងចំណោមរដ្ឋាភិបាលនានា។ មានការយល់ព្រមថា ការរៀបចំនៅថ្នាក់តំបន់ ត្រូវលើកអំពីសេចក្តីត្រូវការ និងបញ្ហាអាទិភាពផ្សេងៗដែលកំណត់ដោយ

រដ្ឋាភិបាលនៅក្នុងតំបន់។ តួនាទី មុខងារ ភារកិច្ច លទ្ធផល និងសម្មិទ្ធិផលនានា នឹងត្រូវកំណត់ដោយការយល់ព្រមជាឯកច្ឆ័ន្ទ។

## ទ្វីបអឺរ៉ុប

គោលបំណងចម្បងរបស់ក្រុមប្រឹក្សាអឺរ៉ុប គឺការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។ បន្ទាប់ពីបានបង្កើត ភ្លាមនៅឆ្នាំ១៩៤៩ ក្រុមប្រឹក្សានេះបានផ្តើមតាក់តែងអនុសញ្ញាអឺរ៉ុបសម្រាប់ការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានចុះហត្ថលេខា នៅឆ្នាំ១៩៥០ ហើយបានចូលជាធរមាននៅឆ្នាំ១៩៥៣។ អនុសញ្ញាអឺរ៉ុប និង ពិធីសារបន្ថែមរបស់វា បង្កើតបានជាសន្ធិសញ្ញាសិទ្ធិមនុស្សទូទៅមួយ ដែលផ្តោតលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ រីឯសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានចែងក្នុងធម្មនុញ្ញសង្គមកិច្ចអឺរ៉ុប (១៩៦១-៦៥) និងពិធីសារបន្ថែម និងក្នុងវិសោធនកម្មនានារបស់ធម្មនុញ្ញនេះ (វិសោធនកម្មធម្មនុញ្ញសង្គមកិច្ចអឺរ៉ុប ឆ្នាំ១៩៩៦-៩៩)។ បន្ថែមលើនេះ ក្រុមប្រឹក្សាអឺរ៉ុបបានអនុម័តសន្ធិសញ្ញាពិសេសមួយចំនួនក្នុងវិស័យការពារទិន្នន័យកម្មករ អន្តោប្រវេសន្ត ជនជាតិភាគតិច ការបង្ការទារុណកម្ម និងឱសថជីវសាស្ត្រ។

បច្ចុប្បន្ននេះ អនុសញ្ញាអឺរ៉ុបមានចែងអំពីប្រព័ន្ធតាមឃ្លាំមើលសិទ្ធិមនុស្សបែបទំនើប បំផុតមួយនៅកំរិតអន្តរជាតិ ។ ក្រោមមាត្រា៣៤ នៃអនុសញ្ញាអឺរ៉ុប ជនណាមួយអង្គការក្រៅរដ្ឋាភិបាល ឬក្រុមបុគ្គលណាមួយ ដែលអះអាងថាជាជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស នៅក្រោមអនុសញ្ញានិងពិធីសាររបស់វា ដែលបានប្រព្រឹត្តដោយរដ្ឋសមាជិកណាមួយក្នុងចំណោមរដ្ឋសមាជិកបច្ចុប្បន្នទាំង ៤៦ របស់ក្រុមប្រឹក្សាអឺរ៉ុបនេះ ក្រោយពីបានប្រើអស់លទ្ធភាពក្នុងការ ស្វែងរកមធ្យោបាយដោះស្រាយក្នុងប្រទេសរួចហើយនោះ មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការសិទ្ធិមនុស្សអឺរ៉ុបបាន ដែលមានទីតាំងនៅទីក្រុងស្ត្រាប៊ួរ

Strabourg (ប្រទេសបារាំង)។ ប្រសិនបើរកឃើញថាមានការរំលោភមែន តុលាការនេះ អាចបំពេញតាមបំណងរបស់ភាគីរងគ្រោះ។ សេចក្តីសម្រេចរបស់តុលាការនេះ គឺជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា និងជាប់កាតព្វកិច្ចផ្លូវច្បាប់លើរដ្ឋភាគីនានា។ ការអនុវត្តនីសេចក្តីសម្រេចទាំងនោះ ស្ថិតនៅក្រោមការឃ្លាំមើលរបស់គណៈកម្មាធិការរដ្ឋមន្ត្រី ដែលជាស្ថាប័ននយោបាយខ្ពស់ជាងគេបំផុតរបស់ក្រុមប្រឹក្សាអឺរ៉ុប។

ក្រោមពិធីសារនៃធម្មនុញ្ញសង្គមកិច្ចអឺរ៉ុប ដែលចូលជាធរមានក្នុងឆ្នាំ១៩៩៨ អង្គការខ្លះអាចដាក់ពាក្យបណ្តឹង ទៅគណៈកម្មាធិការអឺរ៉ុបទទួលបន្ទុកសិទ្ធិសង្គមកិច្ចបាន។ ពេលណាបណ្តឹងនោះត្រូវបានប្រកាសថាអាចទទួលយកបាន នីតិវិធីមួយនឹងត្រូវដាក់ឱ្យដំណើរការដើម្បីគណៈកម្មាធិការធ្វើសេចក្តីសម្រេចលើអង្គសេចក្តី។ សេចក្តីសម្រេចនេះ ត្រូវបញ្ជូនក្នុងរបាយការណ៍មួយទៅឱ្យភាគីពាក់ព័ន្ធ និងគណៈកម្មាធិការរដ្ឋមន្ត្រី ដែលនឹងផ្សព្វផ្សាយ-ជាសាធារណៈ ក្នុងរយៈពេលបួនខែ។ នៅចុងបញ្ចប់ គណៈកម្មាធិការរដ្ឋមន្ត្រីអនុម័តសេចក្តីសម្រេចមួយ ដែលក្នុងនោះគណៈកម្មាធិការនេះ អាចផ្តល់អនុសាសន៍ថា រដ្ឋពាក់ព័ន្ធត្រូវចាត់វិធានការជាក់លាក់មួយចំនួន ដើម្បីធានាថា ត្រូវធ្វើឱ្យស្ថានភាពនោះស្របទៅតាមធម្មនុញ្ញវិញ។

# ជំពូកទី ១០

# ការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ（ICC）

ឧក្រិដ្ឋកម្មដ៏អាក្រក់បំផុត និងគួរឱ្យភ័យរន្ធត់មួយចំនួន ដែលមនុស្សជាតិបានដឹង ដូចជាឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយរួមទាំងការធ្វើ-ទារុណកម្មជាប្រព័ន្ធ ការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការបាត់ខ្លួនដោយបង្ខំ ត្រូវបានប្រព្រឹត្តនៅជុំវិញពិភពលោកនាសតវត្សទី២០នេះ អំឡុងពេលនៃសង្គ្រាមអន្តរជាតិ នៅក្នុងជំលោះថ្នាក់តំបន់ និងនៅពេលមានសន្តិភាព។ ភាគច្រើនលើសលុបនៃអ្នកប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ធ្វើឱ្យតក់ស្លុតយ៉ាងជ្រៅលជ្រៅដល់សម្បជញ្ញៈមនុស្សជាតិ[១០] មិនត្រូវបានគេផ្តន្ទាទោសឡើយ។

កិច្ចប្រឹងប្រែងដំបូងបំផុត ត្រូវបញ្ចប់និទណ្ឌភាពរបៀបនេះ បានធ្វើឡើងក្រោយពីសង្គ្រាមលោកលើកទី២ បានបញ្ចប់ គឺនៅពេលដែលក្រុមសម្ព័ន្ធមិត្តបានបង្កើតសាលាក្តីយោធាអន្តជាតិនៅ Nuremberg និងទីក្រុងតូក្យូ ដែលបេសកកម្ម ទាំងស្រុងរបស់តុលាការនេះ គឺនាំយកឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗមកប្រឈមមុខនឹងយុត្តិធម៌។ ដូច្នេះហើយបានជាសាលាក្តីទាំងនេះ មានពាក់ព័ន្ធខ្លាំងទៅនឹងការអនុវត្តន៏ច្បាប់មនុស្សធម៌អន្តរជាតិ ដែលជាច្បាប់ស្តីពីជំលោះប្រដាប់អាវុធ។

[១០] លក្ខន្តិកៈទីក្រុងរ៉ូម របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ（ICC）បុព្វកថា

តាំងពីពេលនោះមក ការផ្តោតអារម្មណ៍បានផ្លាស់ប្តូរជាបណ្តើរៗ។ បច្ចុប្បន្ននេះច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិគ្រប ដណ្តប់ទាំងទៅលើឧក្រិដ្ឋកម្មសង្គ្រាម (ដែលអាចប្រព្រឹត្តតែនៅពេលមានជំលោះប្រដាប់អាវុធ) និង ទាំង"ឧក្រិដ្ឋនានា ទាក់ទងនឹងសិទ្ធិមនុស្ស "ធ្ងន់ធ្ងរ ដូចជា អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ដែលអាចប្រព្រឹត្តទាំងក្នុងពេលមានសន្តិភាព ក៏ដូចជាក្នុងពេលមានសង្គ្រាម)។ ទោះបីជាការបង្កើត"តុលាការព្រហ្មទណ្ឌអន្តរជាតិមួយនេះ ត្រូវបានគេគិតឃើញតាំងពីដើមឆ្នាំ ១៩៤៨ មកម្ល៉េះ ដែលបានចែងត្រង់មាត្រា ៦ នៃអនុសញ្ញាសហប្រជាជាតិស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក៏ដោយ ក៏តុលាការរបៀបនេះទើបតែបង្កើតដំបូងគេនៅឆ្នាំ ១៩៩៣ ប៉ុណ្ណោះ តាមរយៈសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ ដែលត្រូវបានអនុម័តនៅក្រោមជំពូកទី VII នៃធម្មនុញ្ញសហប្រជាជាតិ ហើយពាក់ព័ន្ធទាំងស្រុងទៅលើអតីតប្រទេសយូហ្គោស្លាវី។

## តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និង តុលាការ ឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ ប្រទេសរ្វ៉ាន់ដា (ICTR)

តាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ៨២៧ (១៩៩៣) សមត្ថកិច្ចរបស់តុលាការឧក្រិដ្ឋកម្ម អន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដើម្បីកាត់សេចក្តីលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះត្រូវបានកម្រិតត្រឹម តែសកម្មភាពទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃវិវាទប្រដាប់អាវុធប៉ុណ្ណោះ។ សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ៩៥៥ (១៩៩៤) បានបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មួយឆ្នាំក្រោយមក ហើយផ្តល់សមត្ថកិច្ចសម្រាប់កាត់សេចក្តីថ្នាក់ដឹកនាំដែលប្រព្រឹត្តបទល្មើសប្រល័យពូជសាសន៍នៅប្រទេស រ្វ៉ាន់ដា និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធផ្សេងៗ ដោយមិនបាននិយាយដល់ជម្លោះប្រដាប់អាវុធនោះឡើយ។

## តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)

ដូចគ្នាទៅនឹងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាដែរ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) មិនបានកម្រិតសមត្ថកិច្ចត្រឹមតែវិវាទប្រដាប់អាវុធទេ ។ បង្កើតឡើងបន្ទាប់ពីការអនុម័តលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ICC ទទួលបន្ទុកលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានទ្រង់ទ្រាយធំជាច្រើនទៀត ដោយមិនចាំបាច់មាន ឬមិនមានវិវាទប្រដាប់អាវុធឡើយ ជាបន្ថែមទៅលើឧក្រិដ្ឋកម្មសង្គ្រាម។ លក្ខន្តិកៈទីក្រុងរ៉ូម បានតាក់តែងឡើងផ្អែកលើគោលគំនិតនៃការទទួលខុសត្រូវរបស់រដ្ឋចំពោះការរំលោភសិទ្ធិមនុស្ស ដោយបន្ថែមការទទួលខុសត្រូវរបស់បុគ្គល ទាំងភ្នាក់ងាររបស់រដ្ឋ និងភ្នាក់ងារមិនមែនជារបស់រដ្ឋ ចំពោះការរំលោភទាំងឡាយណាធ្ងន់ធ្ងរ និងមានលក្ខណៈជាប្រព័ន្ធ។ ដូច្នេះ គេអាចសន្និដ្ឋានថា ជាជ័យជំនះដ៏សំខាន់មួយក្នុងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ដែលជាមូលហេតុដ៏ចម្បងមួយនាំឱ្យមានការរំលោភ ហើយក៏ជាការអភិវឌ្ឍន៍មួយគួរអោយកត់សំគាល់បំផុត និងប្រកបដោយភាពច្នៃប្រឌិត ក្នុងការការពារសិទ្ធិមនុស្សថ្នាក់អន្តរជាតិ។

*"អស់រយៈពេលជាងមួយសតវត្សមកហើយ ដែលមនុស្សជាច្រើនជំនាន់តៗគ្នាបានអភិវឌ្ឍគ្រឹះនៃបទដ្ឋានច្បាប់ និងសីលធម៌មួយ ដែលរីកចំរើនជាលំដាប់ និងដ៏គួរឱ្យចាប់អារម្មណ៍យ៉ាងខ្លាំងដោយផ្អែកលើការគោរពដល់សេចក្តីថ្លៃថ្នូរ របស់បុគ្គល។ ប៉ុន្តែ តុលាការនេះ គឺជាស្ថាប័នអន្តរជាតិដំបូងគេ និងជាអចិន្ត្រៃយ៍តែមួយគត់ ដែលមានអំណាចនាំយកបុគ្គលនានាមកជំនុំជម្រះ ទោះជាពួកគេជាអ្នកណាក៏ដោយ ដែលទទួលខុសត្រូវចំពោះការរំលោភដ៏អាក្រក់បំផុតទៅលើសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ។ នៅទីបំផុត យើង*

*មានលិខិតុបករណ៍មួយ ដើម្បីប្រែក្លាយពាក្យសំដីដ៏ពិរោះ ឱ្យទៅជាសកម្មភាពពិតប្រាកដ...”*

*លោក Sergio Vieira de Mello*

*អតីតឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស*

*សេចក្តីថ្លែងការណ៍ នាឱកាសនៃពិធីសម្ភោធ ICC នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣។*

ប្រអប់ ៣១

## លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)

ត្រូវបានអនុម័តនៅថ្ងៃទី១៧ កក្កដា ឆ្នាំ១៩៩៨ ដោយ ១២០ សម្លេង ទល់នឹង ៧ សម្លេង (ប្រទេស ចិន អ៊ីរ៉ាក់ អីស្រាអែល លីបី អារ៉ាប់ ចាមាហ៊ីរីយ៉ា កាតា សហរដ្ឋអាមេរិក យេម៉ែន) ដោយមាន ២១ សម្លេងអនុបវាទ។

ចុះហត្ថលេខាដោយរដ្ឋចំនួន ១៣៩

ផ្តល់សច្ចាប័នដោយរដ្ឋចំនួន ៩៩ (គិតត្រឹមខែមិថុនា ឆ្នាំ ២០០៥)

**កាលបរិច្ឆេទសំខាន់ៗ**

ចូលជាធរមាន: ១ កក្កដា ឆ្នាំ ២០០២

ការបោះឆ្នោតជ្រើសរើសចៅក្រម ១៨ នាក់របស់តុលាការ ដោយសន្និបាតរបស់រដ្ឋភាគី: ខែកុម្ភៈ ឆ្នាំ ២០០៣

ការបោះឆ្នោតជ្រើសរើសព្រះរាជអាជ្ញាតុលាការគឺ Luis Moreno Ocampo ដោយសន្និបាតរបស់រដ្ឋភាគី : ២១ មេសា ២០០៣។

ប្រអប់ ៣២

## ទស្សនទាន និងយុត្តាធិការរបស់ ICC

### ហេតុអ្វីបាន ICC ត្រូវបានបង្កើតឡើង ?

ដើម្បីបញ្ចប់និទណ្ឌភាព

ដើម្បីជួយបញ្ចប់វិវាទនានា

ដើម្បីធ្វើអោយជនប្រព្រឹត្តល្មើសញញើតនាពេលអនាគត

ដើម្បីចាត់ការជំនួស នៅពេលដែលស្ថាប័នយុត្តិធម៌ឧក្រិដ្ឋកម្មក្នុងប្រទេសមិនមានសមត្ថភាព ឬមិនមានឆន្ទៈចាត់ការ ហើយដោះស្រាយជាមិត្តភាពលើភាពចន្លោះប្រហោងរបស់សាលាក្តីពិសេស ចំពោះកិច្ចការនានា (ដូចជា សាលាក្តីដែលបង្កើតសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ្វ៉ាន់ដា)

### តើយុត្តាធិការរបស់ ICC ត្រូវបានកំណត់ដូចម្តេចនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម?

មាត្រា ៥: ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់ ICC មាន : អំពើប្រល័យពូជ សាសន៍[១១] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[១២] និងឧក្រិដ្ឋកម្មសង្គ្រាម

[១១] ប្រល័យពូជសាសន៍ កើតមានឡើងនៅពេលដែលសកម្មភាពនានា ត្រូវបានគេប្រព្រឹត្តឡើងដោយមានចេតនាដើម្បីបំផ្លាញទាំងមូល ឬផ្នែកខ្លះនៃក្រុមប្រជាជាតិ ជាតិពន្ធ ជាតិសាសន៍ ឬ សាសនាមួយ" លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា ៦។

[១២] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបាន "គេប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារ ក្នុងលក្ខណៈរាលដាលគ្រប់ទីកន្លែង និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល "។ បទឧក្រិដ្ឋនេះរួមមាន : ឃាតកម្ម ការសំលាប់ផ្តាច់ពូជ ការដាក់ជាទាសភាព ការនិរទេស ការផ្លាស់ទីប្រជាជនដោយបង្ខំ ការដាក់ឃុំឃាំង ទារុណកម្ម ការរំលោភសេពសន្ថវៈ ទាសភាពផ្លូវភេទ ពេស្យាចារដោយបង្ខំ ការពរពោះដោយបង្ខំ ការបង្ខំមិនអោយមានកូន ទំរង់ផ្សេងទៀតនៃអំពើហឹង្សាផ្លូវភេទ ការកាត់ទោសប្រឆាំងនឹងក្រុម ឬប្រទេសប្រជាជនដែលគេស្គាល់បាន បង្ខំអោយមានការបាត់ខ្លួន គោលនយោបាយតឹងរឹងនៃការបែងចែកជាតិសាសន៍នៃរបបអាផាថេត(នៅអាហ្វ្រិកខាងត្បូង) និង សកម្មភាពអមនុស្សធម៌ស្រដៀងគ្នានេះ ដែលបង្កអោយមានការឈឺចាប់ និង-ការរងរបួស ធ្ងន់ធ្ងរ ដោយចេតនាទៅលើរាងកាយ ឬ ទៅលើសុខភាពផ្នែកគំនិត និង រាងកាយ។ ដូចគ្នាមាត្រា ៧។

មាត្រា ២៥: បុគ្គល (រូបវន្តបុគ្គល) គ្រប់រូបត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម នៅក្នុងរង្វង់យុត្តាធិការរបស់ ICC ប្រសិនបើបុគ្គលនោះ-ក្នុងឋានៈជាបុគ្គលតែម្នាក់ឯង ឬរួមគ្នា ឬតាមរយៈបុគ្គលណាមួយទៀត ក៏ដោយបានប្រព្រឹត្តបញ្ជា ឬផ្តល់គំនិតឱ្យប្រព្រឹត្តបទឧក្រិដ្ឋ របៀបនោះ ឬជំរុញបញ្ចុះបញ្ចូល ផ្តល់ជំនួយ ញុះញង់ ឬជ្រោមជ្រែងក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនោះ។

មាត្រា ១១: ICC មានយុត្តាធិការតែទៅលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តបន្ទាប់ពីការចូលជាធរមាននៃលក្ខន្តិកៈនេះតែប៉ុណ្ណោះ (១ កក្កដា ២០០២) នៅលើទឹកដីនៃរដ្ឋភាគីមួយ ឬដោយជនជាតិនៃរដ្ឋភាគីណា មួយ នៅទីកន្លែងណាមួយក៏ដោយជុំវិញពិភពលោក។

**តើអ្នកណាអាចបញ្ជូនសំណុំរឿងទៅតុលាការនេះបាន?**

រដ្ឋភាគីមួយ (មាត្រា ១៤)

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (មាត្រា ១៣ (ខ))

ព្រះរាជអាជ្ញារបស់ ICC ដែលផ្តើមការស៊ើបអង្កេតតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ដោយផ្អែកលើព័ត៌មានគួរឱ្យទុកចិត្ត ដែលបានទទួលពីរដ្ឋនានា អង្គការក្រៅរដ្ឋាភិបាល ជនរងគ្រោះ ឬដោយប្រភពផ្សេងទៀត (មាត្រា ១៥)។

**ទំនាក់ទំនងរវាង ICC នឹងតុលាការផ្សេងទៀត**

*ICC និង តុលាការជាតិ* **:** តុលាការជាតិមានយុត្តាធិការលើគ្រប់សំណុំរឿងពាក់ពន្ធ័ទាំងអស់ ហើយតាមគោលការណ៍ "បំពេញបន្ថែម" តុលាការ ICC អាចធ្វើសកម្មភាពបានតែ នៅពេលណាដែលតុលាការជាតិ មិនមានលទ្ធភាព ឬមិនមានឆន្ទៈធ្វើការចោទប្រកាន់ប៉ុណ្ណោះ។

*តុលាការ ICC និង តុលាការយុត្តិធម៌អន្តរជាតិ (ICJ)* : ICJ ដោះស្រាយតែទំនាស់រវាងរដ្ឋ និង រដ្ឋ ដែលមិនមែនជាបទឧក្រិដ្ឋ ដែលប្រព្រឹត្តឡើងដោយបុគ្គលឡើយ។

តុលាការ *ICC និងសាលាក្តីអន្តរជាតិពិសេសចំពោះកិច្ច (ICTY និង ICTR)*: សាលាក្តីពិសេស ត្រូវដាក់ឱ្យស្ថិតក្រោមដែនកំណត់ពេលវេលា និងទីកន្លែង "យុត្តិធម៌តាមជំរើស" រីឯតុលាការអចិន្ត្រៃយ៍វិញ ដូចជា តុលាការ ICC អាចប្រតិបត្តិការបានជាប់លាប់ច្រើនជាង។

### កិច្ចព្រមព្រៀងស្ដីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តុលាការ

ក្រោមមាត្រា ៤៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម តុលាការត្រូវ "ទទួលបាននូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនានា នៅក្នុងដែនដីនៃរដ្ឋភាគីនីមួយៗ ដែលចាំបាច់សម្រាប់បំពេញភារកិច្ចតាមគោលបំណងរបស់តុលាការ"។ កិច្ចព្រមព្រៀងមួយ ស្ដីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ ICC ត្រូវបានសំរេចឡើងស្របពេលជាមួយនឹងការអនុម័តលក្ខន្តិកៈនេះ បានផ្ដល់នូវកិច្ចការពារ និងការធានាសមស្រប ហើយជាពិសេស សម្រាប់កិច្ចការពារ បុគ្គលិករបស់ ICC មេធាវីការពារក្ដី ជនរងគ្រោះ និងសាក្សីក្នុងអំឡុងពេលនៃការស៊ើបអង្កេត។ ទោះបីថា តាមរយៈការផ្ដល់សច្ចាប័នលើលក្ខន្តិកៈនេះ រដ្ឋភាគីមានកាតព្វកិច្ចគោរពបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ បុគ្គលិក ICC និងឯកសារនានារបស់ ICC ក៏ដោយ មានតែរដ្ឋចំនួន ១៦ ប៉ុណ្ណោះ ដែលបានផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ គិតត្រឹមថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤។

ប្រអប់ ៣៣

## បញ្ហាប្រឈមនានារបស់ ICC

បរាជ័យក្នុងការយល់ព្រមជាឯកច្ឆ័ន្ទមួយនៅទីក្រុងរ៉ូម និងវិធានការនានារបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីឱ្យសំរេចបាននូវកិច្ចព្រមព្រៀងទ្វេភាគីជាមួយរដ្ឋភាគីនានា ដើម្បីលើកលែងប្រជាជនរបស់សហរដ្ឋអាមេរិកពី យុត្តាធិការការរបស់ ICC។

ឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់ មានវត្តមាននៅលើទឹកដីនៃរដ្ឋនានា ដែលមិនទាន់បានផ្ដល់សច្ចាប័នលើលក្ខន្តិកៈរបស់ ICC ឬ ដែលបដិសេធមិនព្រមសហការជាមួយ ICC។

និយមន័យចង្អៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងពេលមានសន្តិភាព។

តួនាទីរបស់ក្រុមប្រឹក្សាសន្តិសុខ។

ភាពទន់ខ្សោយនៅក្នុងគោលការណ៍នៃភាពបង្គ្រប់ ៈ តើ ICC ត្រូវកំណត់ដោយរបៀបណាដើម្បីឱ្យដឹងថា តុលាការជាតិមិនមានឆន្ទៈ ឬ គ្មានលទ្ធភាពចាត់បណ្ដឹងអាជ្ញា?

## កាតព្វកិច្ចរបស់រដ្ឋនៅក្រោមលក្ខន្តិកៈទីក្រុងរ៉ូមនៃ ICC

ដោយទទួលយកការផ្តល់សច្ចាប័នលើលក្ខន្តិកៈនេះ រដ្ឋនានាមានកាតព្វកិច្ចជា មូលដ្ឋានចំនួនបី ដែលក្នុងនោះ សភាររបស់រដ្ឋនោះ ដើរតួនាទីសំខាន់ ដូចខាងក្រោមៈ[១៣]

*១. កាតព្វកិច្ចមួយ ដែលចេញពីភាពបំពេញបន្ថែមរបស់ ICC:* ដោយសារថា ICC អាចចាត់វិធានការ នៅពេលណាដែលរដ្ឋមិនមានលទ្ធភាព ឬមិនមានឆន្ទៈចាត់ការតែប៉ុណ្ណោះនោះ រដ្ឋទាំងនោះមានភារកិច្ច ជាបឋម ដោយនាំយកជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាក្រោមច្បាប់អន្តរជាតិទៅកាត់ទោស។ ដូច្នេះ រដ្ឋទាំងនោះត្រូវតែអនុម័ត និងដាក់ឱ្យអនុវត្តនូវច្បាប់ជាតិដោយធានាថា ឧក្រិដ្ឋកម្មទាំងនោះ ក៏ជាបទឧក្រិដ្ឋនៅក្រោមច្បាប់ជាតិរបស់គេដែរ-ដោយមិនគិតពីទីកន្លែងដែលបទឧក្រិដ្ឋទាំងនោះ ត្រូវបានប្រព្រឹត្ត អ្នកណាជាអ្នកប្រព្រឹត្ត ហើយអ្នកណាជាជនរងគ្រោះឡើយ។

២. *កាតព្វកិច្ចត្រូវសហការឱ្យបានពេញលេញ:* ក្រោមមាត្រា ៨៦នៃលក្ខន្តិកៈ រដ្ឋភាគីត្រូវ "សហការយ៉ាងពេញលេញជាមួយតុលាការ នៅក្នុងការស៊ើបអង្កេតរបស់ខ្លួន និង ក្នុងការចាត់បណ្តឹងអាជ្ញាលើឧក្រិដ្ឋកម្ម នៅក្នុងរង្វង់យុត្តាធិការរបស់តុលាការ "។ ដូច្នេះហើយ រដ្ឋត្រូវតែបង្កលទ្ធភាពដល់ព្រះរាជអាជ្ញា និង ស្មាក្តី ធ្វើការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព នៅក្នុងដែនយុត្តាធិការរបស់ខ្លួន ហើយត្រូវធានាថា តុលាការនិងអាជ្ញាធរផ្សេងទៀតរបស់ប្រទេសទាំងនោះ សហការឱ្យបានពេញលេញក្នុងផ្នែកនានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារ បើកការស្រាវជ្រាវរកសាក្សីឱ្យឃើញ និងការការពារសាក្សី និងចាប់ខ្លួន និងប្រគល់ខ្លួនបុគ្គលដែលត្រូវបានចោទប្រកាន់ដោយ ICC។ រដ្ឋនានា ត្រូវសហការជាមួយ

[១៣] ប្រភពៈ អង្គការលើកលែងទោសអន្តរជាតិ *តុលាការឧក្រិដ្ឋកម្មអន្តរជាតិ: តារាងបញ្ជីសំរាប់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព* (AI Index: IOR 40/011/2000)។

ICC លើការអនុវត្តន៍ទោស និងក្នុងការបង្កើត និងអនុវត្តកម្មវិធីផ្តល់ព័ត៌មានសាធារណៈ និងកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីនានា អំពីការអនុវត្តន៍លក្ខន្តិកៈនេះ។

៣. *កាតព្វកិច្ចត្រូវផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ* ដើម្បីបង្កលក្ខណៈ ឱ្យ ICC មានលទ្ធភាពបំពេញមុខងាររបស់ខ្លួន ដោយឯករាជ្យ និងដោយគ្មានលក្ខខណ្ឌ។

នៅក្នុងបទសិក្សាមួយស្តីវិធានការចាត់ឡើងដោយរដ្ឋភាគីនានា ក្នុងការអនុម័តច្បាប់[១៤] សម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាព អង្គការលើកលែងទោសអន្តរជាតិ បានរកឃើញភាពចន្លោះប្រហោង ដែលតែងតែមានច្រើនបំផុតនៅក្នុងពង្រាងច្បាប់ជាតិ ដូចតទៅនេះ ៖

ក. និយមន័យទន់ខ្សោយលើឧក្រិដ្ឋកម្មនានា

ខ. គោលការណ៍ទទួលខុសត្រូវឧក្រិដ្ឋកម្ម និងគោលការណ៍ការពារក្តីលើបទឧក្រិដ្ឋមិនមាន លក្ខណៈគ្រប់គ្រាន់

គ. ខកខានមិនបានផ្តល់យុត្តាធិការសកល ឱ្យបានពេញលេញ ដូចដែលច្បាប់អន្តរជាតិបានអនុញ្ញាតឱ្យមាន

ឃ. មានការត្រួតត្រាផ្នែកនយោបាយលើការផ្តើមចាត់បណ្តឹងអាជ្ញា

ង. ខកខានមិនបានផ្តល់នីតិវិធីសងជំងឺចិត្ត ឱ្យបានលឿនបំផុត និងមានប្រសិទ្ធភាពបំផុត ជូនជនរងគ្រោះ

ច. ការដាក់បញ្ចូលនូវបញ្ញត្តិនានា ដែលទប់ស្កាត់ ឬមានសក្តានុពលអាចទប់ស្កាត់

---

[១៤] AI Index: IOR 40/019/2004.

កិច្ចសហការជាមួយ ICC

ឆ. ខកខានមិនបានផ្តល់ឱ្យបុគ្គលដែលត្រូវបានផ្តន្ទាទោសដោយ ICC នៅទទួលទោសរបស់ខ្លួនក្នុងពន្ធនាគារ ជាតិ

ជ. ខកខានមិនបានបង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់អាជ្ញាធរជាតិនានា អំពីការអនុវត្តន៍លក្ខន្តិកៈទីក្រុងរ៉ូម ប្រកបដោយប្រសិទ្ធភាព។

## កម្រងគោលការណ៍សម្រាប់ការពារ និង លើកស្ទួយសិទ្ធិមនុស្ស តាមរយៈវិធានការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព

តាំងពីឆ្នាំ ១៩៩១ មក អង្គការសហប្រជាជាតិ បានសម្រេចនូវសមិទ្ធិផលជាដុំកំភួន លើការងារប្រយុទ្ធប្រឆាំង នឹងនិទណ្ឌភាពជាចំបង តាមរយៈគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងអនុគណៈកម្មការលើកស្ទួយ និងការពារសិទ្ធិមនុស្ស។ ច្បាប់លើកលែងទោស ដែលនៅក្នុងទសវត្សឆ្នាំ១៩៧០ ត្រូវបានគេប្រើដើម្បីដោះលែងអ្នកទោសនយោបាយ និងជានិមិត្តរូបដល់សេរីភាពនោះ ពេលក្រោយមកត្រូវបានគេប្រើសម្រាប់ធានានិទណ្ឌភាពឱ្យជន ដែលប្រព្រឹត្តរំលោភសិទ្ធិមនុស្សវិញ។ ដោយដឹងអំពីបញ្ហានេះ សន្និសីទពិភពលោកនាទីក្រុងវីយែន(១៩៩៣) នៅក្នុងសេចក្តីថ្លែងការណ៍និងកម្មវិធីសកម្មភាពរបស់ខ្លួន បានគាំទ្រកិច្ចប្រឹងប្រែងរបស់គណៈកម្មការ និងអនុគណៈកម្មការក្នុងការពិនិត្យលើគ្រប់ទិដ្ឋភាពនៃបញ្ហានេះ។ អាស្រ័យហេតុនេះ អនុគណៈកម្មការ បានស្នើសមាជិកម្នាក់ក្នុងចំណោមសមាជិករបស់ខ្លួន គឺលោក Louis Joinet ឱ្យរៀបចំគោលការណ៍មួយឈុត សំរាប់បំរើក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស តាមរយៈវិធានការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព។ អ្នកជំនាញការរូបនេះ បានដាក់ជូនរបាយការណ៍របស់គាត់ និងគោលការណ៍ មួយឈុតនោះ ទៅអនុគណៈកម្មការ នៅឆ្នាំ ១៩៩៧។[១៥] ក្រោមគោលការណ៍

[១៥] E/CN.4/Sub.2/1997/20/Rev.1.

ទាំងនោះ ជនរងគ្រោះមានសិទ្ធិដូចតទៅ :

*សិទ្ធិដឹងឮ* : នេះមិនគ្រាន់តែជាសិទ្ធិរបស់ជនរងគ្រោះណាមួយ ឬរបស់បុគ្គល ដែលជាប់សាច់ញាតិជិតដិត នឹងជនរងគ្រោះនោះ ដែលត្រូវដឹងឮអំពីអ្វីដែលបានកើតឡើង ពោលគឺសិទ្ធិទទួលបានការពិតតែប៉ុណ្ណោះ ។ វាក៏ ជាសិទ្ធិរួមមួយផងដែរ ដើម្បីចារឹកជាប្រវត្តិសាស្ត្រ សម្រាប់ទប់ស្កាត់ការកើតឡើងជាថ្មី ទៀតនៃអំពើហឹង្សានោះ ។ លទ្ធផលនោះ គឺជា "ករណីយកិច្ចរបស់រដ្ឋ ដែលត្រូវចងចាំ" (កថាខ័ណ្ឌទី១៧ នៃរបាយការណ៍នោះ) ។

*សិទ្ធិទទួលបានយុត្តិធម៌:* សិទ្ធិនេះ មានន័យថា ជនរងព្រេះទាំងអស់ត្រូវមានឱកាសទាមទារនូវសិទ្ធិរបស់ពួកគេ ហើយទទួលបានការដោះស្រាយសំណងមួយប្រកបដោយយុត្តិធម៌ និងមានប្រសិទ្ធភាព ដោយធានាថា អ្នកជិះជាន់គេត្រូវទទួលការកាត់ទោស ហើយធានាថា ជនរងគ្រោះអាចទទួលបានសំណងជួសជុលការខូច ខាត ។

*សិទ្ធិទទួលបានសំណងជួសជុលការខូចខាត* : សិទ្ធិនេះ តំរូវឱ្យចាត់វិធានការបុគ្គលម្នាក់ៗ និងរួមទូទៅ ។ សេចក្តីពិស្តារមានចែងនៅក្នុងឯកសារមួយ ដែលមានចំណងជើងថា *គោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពី សិទ្ធិទទួលបានសំណងជួសជុលការខូចខាត សម្រាប់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងច្បាប់ មនុស្សធម៌* ដែលរៀបរៀងឡើងដោយលោក Theo Van Boven សម្រាប់អនុគណៈកម្មការនៅឆ្នាំ១៩៩៦ ហើយនិងត្រូវបានអភិវឌ្ឍន៏បន្ថែមទៀត ដោយលោក Cherif Bassiouni នៅឆ្នាំ២000 តាមសំណើរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "។[១៦] គោលការណ៏ និងសេចក្តីណែនាំ ទាំងនេះ កំពុងរង់ចាំការអនុម័តដោយគណៈកម្មការ ។

[១៦] E/CN.4/Sub.2/1996/17 និង E/CN.4/2000/62, ដោយឡែកពីគ្នា ។

ប្រអប់ ៣៤

## ICC ក្នុងកិច្ចប្រតិបត្តិការ : ឧទាហរណ៍ផ្សេងៗ

នៅខែធ្នូ ឆ្នាំ២០០៣ រដ្ឋាភិបាលនៃប្រទេសយូហ្គាន់ដា បានបញ្ជូនទៅជូនព្រះរាជអាជ្ញារបស់ ICC នូវស្ថានការណ៍ទាក់ទិននឹងកងកំលាំងតស៊ូប្រឆាំងរបស់លោកម្ចាស់ (Lord's Resistance Army) ដែលប្រតិបត្តិការនៅ ប្រទេសយូហ្គាន់ដាភាគខាងជើង។ នៅខែកក្កដា ឆ្នាំ២០០៤ ព្រះរាជអាជ្ញា បានកំណត់ថា មានមូលដ្ឋានគ្រប់គ្រាន់ដើម្បី ផ្តើមស៊ើបអង្កេតលើស្ថានការណ៍នោះ។

នៅខែមីនា ឆ្នាំ ២០០៤ រដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ បានបញ្ជូនទៅជូនព្រះរាជអាជ្ញា នូវស្ថានការណ៍ឧក្រិដ្ឋកម្មក្រោមយុត្តាធិការ ICC ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងប្រទេសនេះ ចាប់តាំងពីការចូលជាធរមាននៃលក្ខន្តិកៈទីក្រុងរ៉ូម។ ដោយផ្អែកលើការស្នើសុំនេះ និងដោយផ្អែកលើព័ត៌មានដែលបញ្ជូនមកតុលាការកាលពីលើកមុនដោយអង្គការក្រៅរដ្ឋាភិបាលនានា ព្រះរាជអាជ្ញាបានសម្រេច នៅក្នុងខែមិថុនា ឆ្នាំ ២០០៤ បើកការស៊ើបអង្កេតមួយលើស្ថានការណ៍នេះ ដែលមានពាក់ព័ន្ធដល់ការធ្វើឃាដទ្រង់ទ្រាយធំ ការសម្លាប់ភ្លាមៗក្រៅប្រព័ន្ធតុលាការ និងការរំលោភសេពសន្ថវៈតាមបែបផែនទារុណកម្ម ការផ្លាស់ទីដោយបង្ខំ និងការប្រើ-ទាហានកុមារ ដោយខុសច្បាប់។

នៅខែមករា ឆ្នាំ២០០៥ រដ្ឋាភិបាលនៃសាធារណៈរដ្ឋអាហ្វ្រិកកណ្តាល (CAR) បានបញ្ជូនទៅជូនព្រះរាជអាជ្ញានូវស្ថានភាពឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តឡើងនៅកន្លែងណាមួយលើទឹកដីរបស់ខ្លួន ចាប់តាំងពីការចូលជាធរ មានរបស់លក្ខន្តិកៈទីក្រុងរ៉ូមមក។

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៥ ក្រុមប្រឹក្សាសន្តិសុខ បានបញ្ជូនទៅព្រះរាជអាជ្ញានូវសំណុំឯកសាររបស់គណៈកម្មការអន្តរជាតិស៊ើបសួរនៅតំបន់ដាហ្វួ។ បន្ថែមលើនេះ ការិយាល័យព្រះរាជអាជ្ញា បានស្នើសុំព័ត៌មានពីប្រភពផ្សេងៗ ដែលនាំដល់ការទទួលបានកម្រងឯកសាររាប់ពាន់។ បន្ទាប់ពីការវិភាគហ្មត់ចត់មកព្រះរាជអាជ្ញា បានសរុបសេចក្តីថា លក្ខខណ្ឌផ្លូវច្បាប់សម្រាប់ផ្តើមការស៊ើបអង្កេត មានគ្រប់គ្រាន់ល្មមហើយ។

ទោះបីជាគោលការណ៍មួយឈុតខាងលើនេះ មិនទាន់ត្រូវបានអនុម័តដោយគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងមហាសន្និបាតអង្គការសហប្រជាជាតិក៏ដោយ ក៏របាយការណ៍មួយដែលធ្វើឡើងនៅឆ្នាំ២០០៤ តាមការស្នើសុំរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិស្តីពីការអនុវត្តន៍ប្រសើរបំផុត និងអនុសាសន៍ផ្សេងៗ ដើម្បីជួយជ្រោមជ្រែងរដ្ឋនានា ក្នុងការពង្រឹងសមត្ថភាពតាមប្រទេសរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងរាល់ទិដ្ឋភាពនៃនិទណ្ឌភាពនោះ[១៧] បង្ហាញឱ្យឃើញថា គោលការណ៍ដែលបានលើកឡើងទាំងនេះ បានផ្តល់ផលប្រយោជន៍យ៉ាងធំធេងរួចទៅហើយ ទៅលើការខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និងត្រូវបានប្រើជាឯកសារយោងយ៉ាងសំខាន់ ដោយស្ថាប័នត្រួតពិនិត្យថ្នាក់តំបន់ និង-ថ្នាក់អន្តរជាតិ និងដោយអាជ្ញាធរជាតិនានា។

[១៧] E/CN.4/2004/88.

## ផ្នែកទី ២

# ជំពូកទី ១១
# តួនាទីរបស់សមាជិកសភា
# ក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស

## គោលការណ៍មូលដ្ឋាន

សភា និងសមាជិកសភា គឺជាតួអង្គសំខាន់ បើនិយាយអំពីការលើកស្ទួយ និងការការពារ-សិទ្ធិមនុស្ស៖ សកម្មភាពរបស់សភាទាំងមូល ដូចជាការធ្វើច្បាប់ ការអនុម័តកញ្ចប់ថវិកាជាតិ និងការត្រួតពិនិត្យលើសកម្មភាពរបស់អំណាចនីតិប្រតិបត្តិ បានគ្របដណ្តប់លើវិសាលភាពទាំងមូលនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលមានអនុភាពផ្ទាល់ចំពោះការទទួលបាននូវសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋ។ ក្នុងនាមជាស្ថាប័នរដ្ឋមួយ ដែលតំណាងឱ្យប្រជាពលរដ្ឋ និងដែលតាមរយៈស្ថាប័ននេះ ប្រជាពលរដ្ឋបានរួមចំណែក ក្នុងការគ្រប់គ្រង កិច្ចការសាធារណៈ សភាពិតជាស្ថាប័នមួយដែលលើកស្ទួយសិទ្ធិមនុស្ស។ សភាត្រូវដឹងយ៉ាង ច្បាស់អំពីតួនាទីនេះគ្រប់កាលៈទេសៈព្រោះថា ប្រទេសមានសុខសន្តិភាព ភាពសុខដុម-រមនា និងការអភិវឌ្ឍន៍សង្គមប្រកបដោយចិរភាព គឺត្រូវពឹងផ្អែកទាំងស្រុង ទៅលើការ-បញ្ច្រៀបសិទ្ធិ មនុស្សនៅក្នុងគ្រប់សកម្មភាពទាំងអស់របស់សភា។

ដើម្បីឱ្យសភាបានបំពេញតួនាទី និងភារៈកិច្ចប្រកបដោយប្រសិទ្ធភាព ជាអ្នកការពារ-សិទ្ធិមនុស្ស វិធានការការពារ និងលក្ខណ្ឌវិនិច្ឆ័យជាក់លាក់មួយចំនួន ត្រូវតែបានបង្កើតឡើង។

**ការធានាភាពជាតំណាងរបស់សភា**

អំណាចរបស់សភា កើតចេញមកពីសមត្ថកិច្ចរបស់ខ្លួនយ៉ាងទូលំទូលាយ ដែលឆ្លុះបញ្ចាំងនូវភាពចម្រុះគ្នាពីគ្រប់ផ្នែកនៃសង្គម ។ ភាពចម្រុះគ្នានេះ រួមមាន បុរស និង ស្ត្រី ទស្សនៈនយោបាយផ្សេងៗ ក្រុមជាតិពន្ធុ និងបណ្ដាជនជាតិដើមភាគតិច ។ ដើម្បីអោយសម្រេចទិសដៅនេះ សមាជិកសភា ត្រូវបានជ្រើសរើសដោយប្រជាពលរដ្ឋ ដែលមានអធិបតេយ្យភាព តាមរយៈការបោះឆ្នោតដោយសេរី យុត្តិធម៌ ជាសកល ដោយសំងាត់ និងស្មើភាព ស្របតាមគោលការណ៍ដែលមានចែងក្នុងមាត្រា២១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា២៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

**ការធានាអធិបតេយ្យភាពរបស់សភា តាមរយៈកិច្ចការការពារសេរីភាពក្នុងការបញ្ចេញមតិរបស់សមាជិកសភា**

សភាអាចបំពេញតួនាទីរបស់ខ្លួនបាន លុះត្រាតែសមាជិកសភាអាចប្រើប្រាស់នូវសេរីភាពក្នុងការបញ្ចេញមតិ តាមសេចក្តីត្រូវការចាំបាច់ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការបញ្ចេញមតិ ក្នុងនាមជាអ្នកតំណាងរបស់ប្រជាពលរដ្ឋ ។ សមាជិកសភាត្រូវមានសេរីភាព ក្នុងការស្វែងរកការទទួលបានការផ្សព្វផ្សាយព័ត៌មាន និងគំនិតផ្សេងៗដោយគ្មានការភ័យខ្លាចមានផលប៉ះពាល់អវិជ្ជមាន និងសកម្មភាពសងសឹក ។ អាស្រ័យហេតុនេះ ពួកគេទទួលបាននូវឋានៈពិសេសមួយ ក្នុងគោលដៅធ្វើឱ្យពួកគេមានឯករាជ្យភាពដែលចាំបាច់ៈ ពួកគេត្រូវមានបុព្វសិទ្ធិសភា ឬអភ័យឯកសិទ្ធិសភា ។

អភ័យឯកសិទ្ធិសភា ធានាឯករាជ្យភាព និងកិត្តិយសអ្នកតំណាងជាតិ ដោយការពារពួកគេពីការគំរាមកំហែង ការបំភិតបំភ័យ ឬការចាត់វិធានការតាមទំនើងចិត្តមកលើពួកគេ ដោយមន្ត្រីសាធារណៈ ឬប្រជាពលរដ្ឋផ្សេងទៀត ។ ដូច្នោះ ពួកគេអាចធានាស្វ័យភាព និងឯករាជ្យភាពរបស់ស្ថាប័នសភា ។វិសាលភាពនៃអភ័យឯកសិទ្ធិមានជាច្រើនផ្សេងៗពីគ្នា ។ការធានាជាអប្បបរិមាអនុវត្តចំពោះសមាជិកសភាទាំងអស់ គឺ *ការមិនអាចចាប់បង្ខំឱ្យទទួលខុសត្រូវ* ។

ក្រោមកិច្ចធានានេះ សមាជិកសភាក្នុងខណៈពេលបំពេញការងារ តាមមុខនាទីរបស់ខ្លួន អាច-បញ្ចេញមតិតាមដែលពួកគេពេញចិត្តដោយមិនបារម្ភចំពោះការដាក់វិន័យឡើយ ក្រៅតែពីការបារម្ភខ្លាចក្រែងពលរដ្ឋម្ចាស់បោះឆ្នោតឈប់គាំទ្រពួកគេនិងមិនអាចទទួលបានការបោះឆ្នោតគាំទ្រដើម្បីបន្តអាណត្តិទៀត។ នៅបណ្តាប្រទេសជាច្រើន សមាជិកសភា ទទួលបានសិទ្ធិស្តីពី*ភាពមិនអាចរំលោភបំពានបាន* ពោលគឺទាល់តែមានការព្រមព្រៀងពីសភា ទើបពួកគេអាចប្រឈមមុខនឹងការចាប់ខ្លួន ការឃុំខ្លួន និងដំណើរការក្តីក្នុងបណ្តឹងរឿងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ ភាពមិនអាចរំលោភបំពានបាន មិនមានន័យស្មើទៅនឹងនិទណ្ឌភាពទេ។ នេះគ្រាន់តែផ្តល់សិទ្ធិជូនសភាធ្វើការត្រួតពិនិត្យជាមុនថា ការយកសមាជិកខ្លួនទៅតុលាការនោះមាន-ភាពត្រឹមត្រូវតាមបទដ្ឋានច្បាប់ជាមុនតែប៉ុណ្ណោះ។

*“ កិច្ចការពារសិទ្ធិមនុស្សរបស់សមាជិកសភាគឺជាលក្ខខណ្ឌចាំបាច់ ដើម្បីធ្វើឱ្យពួកគេអាចការពារនិងលើកស្ទួយសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅក្នុងប្រទេសរបស់ពួកគេរៀងៗខ្លួន។ បន្ថែមលើនេះ ភាពជាតំណាងរបស់សភា គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើការគោរព សិទ្ធិរបស់សមាជិកសភានោះ”*

*ក្រុមប្រឹក្សាអន្តរសភា សេចក្តីសម្រេច បង្កើតនីតិវិធីសម្រាប់ពិនិត្យ*
*និងដោះស្រាយលើពាក្យបណ្តឹងស្តីពីការរំលោភសិទ្ធិរបស់សមាជិកសភា ទីក្រុងម៉ិចស៊ិចកូ*
*ខែមេសា ឆ្នាំ១៩៧៦ ។*

ប្រអប់ ៣៥

## ការការពារសិទ្ធិមនុស្សរបស់សមាជិកសភា ៖
## គណៈកម្មាធិការសហភាពអន្តរសភា (IPU) ទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាជិកសភា

- ប្រសិនបើសមាជិកសភាមានភារកិច្ចការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋ ដែលពួកគេតំណាងឱ្យពួកគេផ្ទាល់ ត្រូវតែមានលទ្ធភាពអនុវត្តសិទ្ធិមនុស្សរបស់ពួកគេ ជាពិសេសសិទ្ធិបញ្ចេញមតិដោយសេរី។

ដោយកត់សំគាល់ថា លក្ខខណ្ឌនេះ ជារឿយៗមិនត្រូវបានគេគោរពនោះ នៅឆ្នាំ១៩៧៦ IPU បានអនុម័ត នីតិវិធីមួយដើម្បីត្រួតពិនិត្យ និងដោះស្រាយចំពោះការចោទប្រកាន់ពីអំពើរំលោភសិទ្ធិមនុស្ស ទៅលើសមាជិកសភា។

- IPU បានប្រគល់ភារកិច្ចដល់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាជិកសភា ដើម្បីធ្វើការត្រួតពិនិត្យរាល់ពាក្យបណ្តឹង ដែលពាក់ព័ន្ធជាមួយសមាជិកសភា "សមាជិកសភា ដែលធ្លាប់បានរងគ្រោះ ឬកំពុងតែត្រូវរងគ្រោះដោយសារតែការចាត់វិធានការតាមទំនើងចិត្តចំពោះពួកគេ ក្នុងអំឡុងពេលដែលពួកគេបំពេញកិច្ចការតាមអាណត្តិរបស់ខ្លួន ទោះបីជាសមាជិកសភានោះ កំពុងតែបំពេញកិច្ចការ ឬកំពុងសម្រាក ឬត្រូវបានបញ្ឈប់ ដោយសារតែវិធានការមិនស្របតាមរដ្ឋធម្មនុញ្ញ ឬដោយវិធានការក្រៅច្បាប់ណាមួយក៏ដោយ"។ នីតិវិធីនេះ អនុវត្តចំពោះសមាជិកសភាជាតិគ្រប់ប្រទេសទាំងអស់។
- គណៈកម្មាធិការ មានសមាជិកពេញសិទ្ធិប្រាំនាក់ និងសមាជិកបម្រុងប្រាំនាក់ ពួកគេម្នាក់ៗត្រូវបានជ្រើសរើសជាលក្ខណៈបុគ្គល ដើម្បីតំណាងឱ្យតំបន់ភូមិសាស្ត្រជាក់លាក់មួយ សម្រាប់រយៈពេលប្រាំឆ្នាំ។ គណៈកម្មាធិការ ជួបប្រជុំជាអសាធារណៈចំនួនបួនដងក្នុងមួយឆ្នាំ។
- ខណៈដែលគណៈកម្មាធិការរកឃើញថា បណ្តឹងណាមួយបានបំពេញគ្រប់លក្ខខណ្ឌ គណៈកម្មាធិការពិនិត្យករណីនេះ យោងតាមច្បាប់សិទ្ធិមនុស្សថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ នីតិវិធីនេះគឺពឹងផ្អែកខ្លាំងលើការផ្ទៀងផ្ទាត់ ដោយប្រៀបធៀបទៅលើព័ត៌មានទាំងអស់ ដែលបញ្ជូនមកគណៈកម្មាធិការ ដោយអាជ្ញាធរនានារបស់ប្រទេសដែលពាក់ព័ន្ធ ជាពិសេសពីសភា និងសាមីដើមបណ្តឹង។ រាល់ភស្តុតាងបង្ហាញនៅចំពោះមុខគណៈកម្មាធិការ នឹងត្រូវរក្សាការសម្ងាត់។
- គណៈកម្មាធិការរៀបចំសវនាការជាមួយភាគីពាក់ព័ន្ធ និងអាចចុះបំពេញបេសកកម្មដល់កន្លែងកើតហេតុ។ សវនាការអាចប្រព្រឹត្តទៅបាន អាស្រ័យលើការព្រមព្រៀងពីរដ្ឋសាមី និងត្រូវអនុលោមតាមលក្ខខណ្ឌអប្បបរិមាជាក់លាក់មួយចំនួន។
- គណៈកម្មាធិការ អាចលើកយកករណីណាមួយទៅដាក់ជូនសមាជិក IPU ទាំងមូល តាមរយៈការចេញផ្សាយរបាយការណ៍ជាសាធារណៈ។ ធ្វើដូច្នោះ ដើម្បីសំរួលឱ្យសភា និងសមាជិកសភាអាចធ្វើសកម្មភាពជួយដល់សហការីដែលកំពុងមានបញ្ហា។
- គណៈកម្មាធិការ នឹងបន្តធ្វើការលើករណីទាំងឡាយណាដែលពួកគេយល់ថា ការពិនិត្យពិច័យរបស់ពួកគេ អាចជួយស្វែងរកដំណោះស្រាយដែលមានការគោរពសិទ្ធិមនុស្ស។ កាលណា

ដំណោះស្រាយបែបនេះ គ្មានលទ្ធភាពអនុវត្តបាន គណៈកម្មាធិការអាចបិទសំណុំរឿង ហើយផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាគ្រប់គ្រងរបស់ IPU ដើម្បីធ្វើការថ្កោលទោសចំពោះអាជ្ញាធរពាក់ព័ន្ធ។

## ការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់ជាពិសេសនីតិវិធីសភា

ជាការសំខាន់ណាស់ដែលសមាជិកសភាស្គាល់ច្បាស់ពីរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចរបស់រដ្ឋចំពោះសិទ្ធិមនុស្ស ដំណើរការរបស់រដ្ឋាភិបាល និងកិច្ចការរដ្ឋបាលសាធារណៈ ជាពិសេសនីតិវិធីសភា។ សភាមួយចំនួន ដូចជាសភាប្រទេសអាហ្វ្រិកខាងត្បូង តែងតែរៀបចំសិក្ខាសាលាជាច្រើនវគ្គ សម្រាប់សមាជិកសភាដែលទើបជាប់ឆ្នោតថ្មី ដើម្បីជួយសម្រួលឱ្យពួកគេបានយល់ច្បាស់លើក្របខ័ណ្ឌច្បាប់នៃការងាររបស់ខ្លួន និងនីតិវិធីរបស់សភា។

ដើម្បីបំពេញមុខនាទីរបស់ពួកគេ សមាជិកសភាទាំងអស់ត្រូវតែទទួលបាននូវធនធានគ្រប់គ្រាន់។

ជំនួយការផ្នែកបច្ចេកទេស អាចជួយពង្រឹងចំណេះដឹងរបស់សមាជិកសភា លើវិស័យសិទ្ធិមនុស្ស និងជួយដោះស្រាយបញ្ហាធនធានដែលមានមិនគ្រប់គ្រាន់ (មើលផ្នែកទី I ប្រអប់២៩)។

## ការកំណត់តួនាទីរបស់សភាក្នុងពេលមានភាពអាសន្ន

ពេលដែលរដ្ឋប្រកាសភាពអាសន្ន ជាទូទៅជនរងគ្រោះដំបូងគេគឺសភា : អំណាចរបស់សភាអាចត្រូវបានកាត់បន្ថយយ៉ាងគំហុក ឬសភាអាចត្រូវរំលាយចោលតែម្តង។ ដើម្បីជៀសវាងហេតុការណ៍ជាយថាហេតុ សភាគួរតែធានាថា :

- ការដាក់រដ្ឋក្នុងភាពអាសន្ន មិនបានផ្តល់ឱកាសឱ្យរដ្ឋាភិបាលអនុវត្តវិធានការ ដែលមិនស្របច្បាប់តាមទំនើងចិត្តនោះទេ
- សភា ជាស្ថាប័នដែលទទួលខុសត្រូវ ក្នុងការប្រកាសដាក់រដ្ឋក្នុងភាពអាសន្ន និង

ប្រកាសលើកចេញពីភាពអាសន្ន ដោយអនុលោមតាមគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ រួមទាំងគោរពតាមបទដ្ឋានដែលកំណត់មកថា សិទ្ធិជាក់លាក់មួយចំនួនមិនអាចត្រូវបានដកហូតឡើយ (មើលផ្នែកទី ៤)

- ការរំលាយ ឬការព្យួរសភា ក្នុងខណៈដែលរដ្ឋស្ថិតក្នុងភាពអាសន្ន ត្រូវបានហាមឃាត់ ដោយច្បាប់
- ក្នុងខណៈដែលរដ្ឋស្ថិតក្នុងភាពអាសន្ន សភាត្រូវឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ រាល់សកម្មភាពរបស់អាជ្ញាធរ ជាពិសេសរាល់ភ្នាក់ងារអនុវត្តច្បាប់ ដែលកំពុងកាន់កាប់អំណាចពិសេសនេះ
- រដ្ឋស្ថិតក្នុងភាពអាសន្នត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់នានា ដែលមានធម្មនុញ្ញភាព ដើម្បីការពារច្បាប់ទាំងនេះពីការធ្វើកំណែទម្រង់ ដើម្បីកេងយកផលប្រយោជន៍។

## វិធានការសភាក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស

### ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស

ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្ស គឺជាមធ្យោបាយសំខាន់មួយ ក្នុងការបង្ហាញដល់សហគមន៍អន្តរជាតិ និងសាធារណៈមតិក្នុងស្រុក ពីការប្តេជ្ញារបស់រដ្ឋចំពោះសិទ្ធិមនុស្ស។ ការផ្តល់សច្ចាប័ន គឺជាការបង្ហាញនូវការអនុវត្តន៍កាតព្វកិច្ចរបស់រដ្ឋ ដែលមានចែងនៅក្នុងសន្ធិសញ្ញា និងអនុញ្ញាតឱ្យមានការត្រួតពិនិត្យជាលក្ខណៈអន្តរជាតិ ទៅលើភាពជឿនលឿនរបស់រដ្ឋ ក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស។

សន្ធិសញ្ញាសិទ្ធិមនុស្សត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័នដោយតំណាងស្ថាប័ននីតិប្រតិបត្តិ ជាទូទៅ គឺជាប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។ ទោះជាយ៉ាងនេះក្តី នៅក្នុងបណ្តារដ្ឋជាច្រើន សេចក្តីសម្រេចចុងក្រោយថាគួរ ឬមិនគួរផ្តល់សច្ចាប័នលើសន្ធិសញ្ញាណាមួយនោះ គឺស្ថិតនៅលើសភាដែលជាស្ថាប័នត្រូវអនុម័ត

លើការផ្តល់សច្ចាប័ននោះ។ ការផ្តល់សច្ចាប័ន ធ្វើឱ្យបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានចែងក្នុងសន្ធិសញ្ញា មានអនុភាពផ្លូវច្បាប់នៅក្នុងរដ្ឋដែលផ្តល់សច្ចាប័ននោះ ហើយរដ្ឋមានកាតព្វកិច្ចធ្វើរបាយការណ៍ជូនសហគមន៍អន្តរជាតិ អំពីវិធានការនានាដែលបានបង្កើតឡើងដើម្បីតម្រង់ទិសដៅធ្វើច្បាប់របស់ខ្លួន អោយស្របទៅតាមបទដ្ឋាននៃសន្ធិសញ្ញាទាំងនោះ។

ប្រអប់ ៣៦

## ការរួមចំណែករបស់សភាក្នុងការចរចា និងការធ្វើសេចក្តីព្រាងសន្ធិសញ្ញា

សមាជិកសភាជាតិ ជាទូទៅ មិនចូលរួមដោយផ្ទាល់ក្នុងការធ្វើសេចក្តីព្រាងសន្ធិសញ្ញាអន្តរជាតិ ឬសន្ធិសញ្ញាថ្នាក់តំបន់ ឬក្នុងដំណើរការធ្វើសេចក្តីសម្រេចផ្នែកនយោបាយទាំងនោះទេ។ មានតែក្រុមប្រឹក្សាសភាអឺរ៉ុប ដែលជាសភាថ្នាក់តំបន់បង្កើតឡើងនៅឆ្នាំ១៩៤៩ បានដើរតួនាទីកាន់តែសំខាន់ឡើង១ ក្នុងកិច្ចឃ្លាំមើលសិទ្ធិមនុស្ស និងការធ្វើសេចក្តីព្រាងលិខិតុបករណ៍ថ្មី១។ គណៈកម្មាធិការសភាដែលទទួលបន្ទុកការងារផ្នែកច្បាប់ និងសិទ្ធិមនុស្ស ធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគណៈរដ្ឋមន្ត្រី (រួមមានរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសរបស់រដ្ឋសមាជិក ដែលបច្ចុប្បន្នមានសមាជិកចំនួន ៤៦ប្រទេស) និងជាមួយគណៈកម្មាធិការនាយកទទួលបន្ទុកសិទ្ធិមនុស្ស នៅពេលមានការតាក់តែងលិខិតុបករណ៍ថ្មី១ ឬពេលណាមានបញ្ហាសិទ្ធិមនុស្សកើតឡើង។ ឧទាហរណ៍ គណៈរដ្ឋមន្ត្រី បានកោះអញ្ជើញសភាឱ្យជួយខ្លួនក្នុងការដោះស្រាយបញ្ហា ដែលកើតឡើងដោយសារតែមានការដាក់ពាក្យបណ្តឹងកាន់តែច្រើនឡើងទៅតុលាការសិទ្ធិមនុស្សអឺរ៉ុប។

**IPU** បានអំពាវនាវជាប្រចាំ ស្នើឱ្យមានការរួមចំណែកពីសមាជិកសភា ក្នុងកិច្ចចរចាពាក់ព័ន្ធនឹងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនានា ដោយសំអាងថា នៅពេលក្រោយសភានឹងត្រូវចងក្រងច្បាប់ដែលពាក់ព័ន្ធនឹងលិខិតុបករណ៍ និងធានាការអនុវត្តន៍ច្បាប់នោះ សភាគួរតែចូលធ្វើអន្តរាគមន៍មុនដំណាក់កាលផ្តល់សច្ចាប័នជាមួយតំណាងរដ្ឋាភិបាល ក្នុងការតាក់តែងលិខិតុបករណ៍ថ្មី១ ក្នុងអង្គពិភាក្សាអន្តរជាតិ។

# តើអ្នកអាចធ្វើអ្វីខ្លះក្នុងឋានៈជាសមាជិកសភា

☐ ពិនិត្យមើលថា តើរដ្ឋាភិបាលអ្នកបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសំខាន់ៗ (យ៉ាងហោចណាស់) សន្ធិសញ្ញាសំខាន់ៗចំនួនប្រាំពីរ (មើលផ្នែកទី១ ជំពូកទី៣ និងទី៥) និងសន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់ហើយឬនៅ។

☐ បើមិនទាន់ទេ អាចពិនិត្យថាតើ រដ្ឋាភិបាលមានឆន្ទៈក្នុងការចុះហត្ថលេខាលើលិខិតុបករណ៍ទាំងនោះដែរឬទេ។ ប្រសិនបើគ្មាន គប្បីប្រើនីតិវិធីសភា ដើម្បីកំណត់មូលហេតុដែលនាំឱ្យរដ្ឋាភិបាល អសកម្មភាពបែបនេះ នឹងត្រូវជំរុញរដ្ឋាភិបាលឱ្យចាប់ផ្តើមដំណើរការចុះហត្ថលេខា និងផ្តល់សច្ចាប័ន ដោយមិនអូសបន្លាយពេលវេលា ។

☐ ប្រសិនបើនីតិវិធីនៃការចុះហត្ថលេខាកំពុងតែដំណើរការ ត្រូវពិនិត្យថាតើរដ្ឋាភិបាល មានបំណងដាក់លក្ខខណ្ឌណាមួយចំពោះសន្ធិសញ្ញានោះដែរឬទេ។ បើមាន ត្រូវស្វែងយល់ឱ្យច្បាស់ថាតើការដាក់លក្ខខណ្ឌនោះគឺជាការចាំបាច់ និងស្របតាមខ្លឹមសារ និងគោលបំណងនៃសន្ធិសញ្ញា ដែរឬយ៉ាងណា(មើលជំពូកទី៤)។ ប្រសិនបើរកឃើញថា ការដាក់លក្ខខណ្ឌនោះ គ្មានមូលដ្ឋានច្បាស់លាស់ទេ ត្រូវចាត់វិធានការឱ្យរដ្ឋាភិបាលផ្លាស់ប្តូរជំហររបស់ខ្លួនវិញ។

☐ ពិនិត្យមើលថាតើ ការដាក់លក្ខខណ្ឌណាមួយដោយរដ្ឋរបស់យើង ចំពោះសន្ធិសញ្ញាទាំងឡាយដែលចូលជាធរមាន នៅតែជាការចាំបាច់ខានមិនបានដែរឬទេ។ ប្រសិនបើរកឃើញថា ការដាក់លក្ខខណ្ឌទាំងនោះ គ្មានការចាំបាច់ទៀតទេ ត្រូវចាត់វិធានការដើម្បីដកយកខលក្ខខណ្ឌទាំងនោះចេញវិញ។

☐ ពិនិត្យមើលថាតើ រដ្ឋាភិបាលអ្នកបានធ្វើសេចក្តីប្រកាសចាំបាច់នានា ឬផ្តល់សច្ចាប័នលើពិធីសារបន្ថែមដែរឬទេ? (មើលផ្នែកទី I ជំពូកទី៥) ក្នុងទស្សនៈដើម្បី ៖

(ក) ទទួលស្គាល់សមត្ថកិច្ចរបស់ស្ថាប័នសន្ធិសញ្ញា ក្នុងការទទួលពាក្យបណ្តឹងរបស់បុគ្គល (អនុលោមតាម **CCPR, CEDAW, CERD, CAT** និងអនុសញ្ញាពលករអន្តោប្រវេសន៍)

(ខ) ទទួលស្គាល់សមត្ថកិច្ចរបស់ស្ថាប័នឃ្លាំមើលការអនុវត្តសន្ធិសញ្ញា (**CAT** និង **CEDAW**)

ដើម្បីរៀបចំបង្កើតនីតិវិធីស៊ើបសួរមួយ

(គ) ផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមរបស់ CAT (ពិធីសារបន្ថែមបង្កើតអោយមានការចុះទស្សនកិច្ចទៀងទាត់ទៅកាន់មន្ទីរឃុំឃាំងនានា)។

☐ ប្រសិនបើមិនបានធ្វើកិច្ចការទាំងនេះទេ ត្រូវចាត់វិធានការ ដើម្បីធានាថា សេចក្តីប្រកាសនានា ឬពិធីសារបន្ថែមទាំងនោះ នឹងត្រូវបានផ្តល់សច្ចាប័ន។

☐ ធានាថាអាជ្ញាធរសាធារណៈ ភ្នាក់ងាររដ្ឋ និងសាធារណជន បានដឹងអំពីសន្ធិសញ្ញាសិទ្ធិមនុស្សដែលបានផ្តល់សច្ចាប័នរួចហើយ ព្រមទាំងយល់ច្បាស់ អំពីខបញ្ញត្តិនានានៃសន្ធិសញ្ញាទាំងនោះ។

☐ ករណីប្រទេសរបស់អ្នក មិនទាន់បានចុះហត្ថលេខា និងផ្តល់សច្ចាប័នទៅលើលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICC ត្រូវចាត់វិធានការដើម្បីថាប្រទេសរបស់អ្នកនឹងចាត់វិធានការអនុម័ត នឹងធានាថា ប្រទេសរបស់អ្នក នឹងធ្វើអនុបវាទ ទៅលើកិច្ចព្រមព្រៀងទាំងឡាយណា ដែលកាត់បន្ថយអំណាចលក្ខន្តិកៈនេះ នឹងធ្វើឱ្យអន្តរាយដល់អំណាចរបស់តុលាការនេះ។

ប្រអប់ ៣៧

### វិធានការសភាដើម្បីរក្សានូវបូរណភាព នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICC

ក្នុងការបញ្ចេញប្រតិកម្មតបទៅនឹងសំណើ ដែលលើកឡើងដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលស្នើឱ្យមានកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីលើកលែងជនជាតិរបស់សហរដ្ឋអាមេរិក ឱ្យរួចផុតពីយុត្តាធិការរបស់ ICC នោះ មានសភាជាច្រើន (ដូចជាសភារបស់ប្រទេសអ៊ីរូហ្គាយ និងប្រទេសស្វីស) បានបញ្ជូនសារទៅកាន់រដ្ឋាភិបាលរបស់ខ្លួន ដោយជំរុញឱ្យបដិសេធទៅនឹងសំណើនោះ ហើយប្រកាន់ជំហរអនុបវាទទៅលើកិច្ចព្រមព្រៀងទាំងឡាយណាដែលធ្វើឱ្យឃ្លាតឆ្ងាយពីលក្ខន្តិកៈ។ សភាប្រទេសផ្សេងទៀតបានបដិសេធមិនព្រមផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរបៀបនោះទេ។

*ក្រុមប្រឹក្សាអន្តរសភា “ អំពាវនាវទៅកាន់គ្រប់សភា និងសមាជិកទាំងអស់របស់ខ្លួន ឱ្យចាត់វិធានការនៅថ្នាក់ជាតិ ដើម្បីធានាថា សន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់ និង ថ្នាក់អន្តរជាតិត្រូវបានផ្តល់សច្ចាប័ន ឬត្រូវបានចូលជាសមាជិកភ្លាម១ ដោយប្រទេសរបស់ពួកគេ ហើយក្នុងករណីដែលប្រទេសរបស់ពួកគេមិនបានធ្វើដូច្នេះទេ ត្រូវធានាថា ការដាក់លក្ខខណ្ឌណាមួយ នឹងត្រូវបានដកចេញ នៅពេលណាដែលវាមានទំនាស់ទៅនឹងកម្មវត្ថុ និងគោលបំណងរបស់សន្ធិសញ្ញានោះ ”*

*សេចក្តីសម្រេចដែលបានអនុម័ត នាឱកាសខួបទី៥០*
*នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សទីក្រុង*
Cairo *ខែកញ្ញា ឆ្នាំ១៩៩៧ វាក្យខ័ណ្ឌទី៣* (i)

## ការធានាឱ្យមានការអនុវត្តន៍ថ្នាក់ជាតិ

### *ការអនុម័តថវិកា*

ការធានាឱ្យមនុស្សគ្រប់គ្នាទទួលបានសិទ្ធិមនុស្ស មិនមែនបានមកដោយគ្មានការចំណាយអ្វីសោះនោះទេ។ វិធានការប្រកបដោយប្រសិទ្ធភាព សម្រាប់ការពារសិទ្ធិមនុស្ស ជាពិសេស សម្រាប់ទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស តម្រូវឱ្យមានមូលនិធិច្រើន។ ក្នុងការអនុម័តថវិកាជាតិដែលនឹងមានការចាត់ជាអាទិភាព សម្រាប់ជាតិ សភាត្រូវធានាឱ្យមានមូលនិធិគ្រប់គ្រាន់សម្រាប់ការអនុវត្តន៍សិទ្ធិមនុស្ស។ បន្ទាប់មក តាមឃ្លាំមើលការចំណាយរបស់រដ្ឋាភិបាល ប្រសិនបើចាំបាច់ សភាអាចដាក់ឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការបំពេញការងាររបស់ខ្លួន ដែលមានលក្ខណៈខ្វះខាត ក្នុងវិស័យសិទ្ធិមនុស្ស។

## ការត្រួតពិនិត្យលើអង្គនីតិប្រតិបត្តិ

តាមរយៈមុខនាទីត្រួតពិនិត្យរបស់ពួកគេ ក្នុងការដាក់គោលនយោបាយ និង សកម្មភាពរបស់អង្គនីតិប្រតិបត្តិ ឱ្យនៅក្រោមការតាមដានត្រួតពិនិត្យជាប្រចាំនោះ សភា និងសមាជិកសភា អាចធានា និងត្រូវតែធានាថា ច្បាប់ទាំងឡាយត្រូវបានអនុវត្តយ៉ាង ពិតប្រាកដ ដោយរដ្ឋាភិបាល និងដោយស្ថាប័នពាក់ព័ន្ធដទៃទៀត។ អនុលោមតាមនីតិវិធី របស់សភា មធ្យោបាយដែលមានសម្រាប់សមាជិកសភា ធ្វើការត្រួតពិនិត្យតាមដានសកម្មភាពរបស់រដ្ឋាភិបាល មានដូចជា :

- សំណួរជាលាយលក្ខណ៍អក្សរ និងសំណួរផ្ទាល់មាត់ទៅកាន់រដ្ឋមន្ត្រី មន្ត្រីរាជការ និង មន្ត្រី នៃអង្គនីតិប្រតិបត្តិទាំងឡាយ
- ការជជែកដេញដោល
- គណៈកម្មាធិការ ឬគណៈកម្មការស្វែងរកការពិត ឬស៊ើបអង្កេត
- បោះឆ្នោតដកសេចក្តីទុកចិត្ត ប្រសិនបើការព្យាយាមខាងលើនេះ មិនបានទទួល ជោគជ័យ

## ការបន្តពិនិត្យតាមដានលើអនុសាសន៍ និងសេចក្តីសម្រេចផ្សេងៗ

អនុសាសន៍ដែលធ្វើឡើងដោយស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញា និងដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ និងដោយស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាថ្នាក់តំបន់ និងថ្នាក់អន្តរជាតិផ្សេងទៀត (មើលផ្នែកទី I ជំពូកទី៥, ៦ និងទី៩) អាចត្រូវបានយកមកប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពដោយសមាជិកសភា ដើម្បីពិនិត្យពិច័យលើសកម្មភាពរបស់អង្គនីតិប្រតិបត្តិ ក្នុងការអនុវត្តន៍តាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ។

*សន្និសីទអន្តរសភាលើកទី១០០“ អំពាវនាវដល់សភាទាំងឡាយឱ្យធ្វើការយ៉ាងសកម្មដើម្បីធានាថា រដ្ឋាភិបាលជាតិបំពេញតួនាទីធ្វើរបាយការណ៍របស់ខ្លួន ចំពោះស្ថាប័នទទួលបន្ទុកសិទ្ធិមនុស្ស ឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ហើយធានាឱ្យភ្នាក់ងារមានសមត្ថកិច្ចរបស់រដ្ឋាភិបាល ធ្វើសហប្រតិបត្តិការយ៉ាងពេញលេញជាមួយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីឱ្យពួកគេមានការគាំទ្រដែលពួកគេត្រូវការចាំបាច់ សម្រាប់អនុវត្តការងារប្រកបដោយប្រសិទ្ធភាព” ។*

*សេចក្តីសម្រេចស្តីពី “វិធានការចម្បង៧ដោយសភាជាតិ នាឱកាសខួបទី៥០*
*នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដើម្បីធានាការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស*
*នៅក្នុងសតវត្សទី២១ ” នាទីក្រុងមូស្គូ ខែកញ្ញា ឆ្នាំ១៩៩៨ វាក្យខ័ណ្ឌទី ៤ (ii)*

**ប្រអប់ ៣៨**

## ការអនុវត្តន៏អនុសាសន៏របស់ស្ថាប័នសន្ធិសញ្ញាថ្នាក់តំបន់ : ឧទាហរណ៏

សភា ជាពិសេសគណៈកម្មាធិការសិទ្ធិមនុស្ស អាចជាឧបករណ៏ដ៏សំខាន់ក្នុងការធានាការអនុវត្តន៏សេចក្តីសម្រេច ឬអនុសាសន៏នានារបស់ស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ និងថ្នាក់តំបន់។ ឧទាហរណ៏ គណៈកម្មាធិការសិទ្ធិមនុស្សរបស់សភាតំណាងរាស្ត្រនៃប្រទេសប្រេស៊ីល ដើរតួនាទីសំខាន់ក្នុងការអនុវត្តន៏សេចក្តីសម្រេច ដំបូងរបស់គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិកាំងក្នុងរឿងក្តីមួយប្រឆាំងនឹងប្រទេសប្រេស៊ីលៈ លោក Joâo Canuto ជាប្រធានសហជីពការងារជនបទនៃ Rio Maria រដ្ឋ Pará ដែលត្រូវគេធ្វើឃាតនៅឆ្នាំ១៩៨៥។ នៅឆ្នាំ ១៩៩៨ គណៈកម្មាធិការនេះបានសរុបសេចក្តីថា ប្រទេសប្រេស៊ីលបានរំលោភលើកតិកាសញ្ញាអាមេរិកាំងស្តីពីសិទ្ធិមនុស្ស ដោយមិនបានផ្តល់ការការពារគ្រប់គ្រាន់ដល់លោក Canuto នៅពេលដែលគាត់បានរាយការណ៏ថាគាត់បានទទួលការគំរាមសំលាប់ និងដោយខកខានមិនបានធ្វើការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងដោយខកខានក្នុងការផ្តួចផ្តើមនីតិវិធីតាមប្រព័ន្ធតុលាការទាក់ទងនឹងអំពើឃាតកម្មលើរូបគាត់។ គណៈកម្មាធិការបានផ្តល់អនុសាសន៏ថា ប្រទេសប្រេស៊ីលគួរតែពង្រឹងនីតិវិធីព្រហ្មទណ្ឌរបស់ខ្លួន

និងបង់ប្រាក់សំណងជំងឺចិត្តដល់គ្រួសារជនរងគ្រោះចំពោះការបាត់បង់រូបកាយ និងផ្លូវចិត្ត។ នៅឆ្នាំ១៩៩៩ គណៈកម្មាធិការសិទ្ធិមនុស្សរបស់សភា តំណាងរាស្ត្របានរៀបចំយុទ្ធនាការថ្នាក់ជាតិមួយដើម្បីធ្វើឱ្យអាជ្ញាធរនានាបានដឹងអំពីសេចក្តីសម្រេចនេះ និងដឹងអំពីសារៈសំខាន់ក្នុងការអនុវត្តន៍សេចក្តីសម្រេចនេះ។ ក្រោយមក សេចក្តីសម្រេចនេះត្រូវបានគេយកទៅអនុវត្ត។

## ការបង្កើតស្ថានប័នសិទ្ធិមនុស្សរបស់សភា

សិទ្ធិមនុស្ស គួរត្រូវបានបញ្ជ្រាបចូលយ៉ាងស៊ីជម្រៅទៅក្នុងសកម្មភាពរបស់សភា។ នៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការសភានីមួយៗ គួរធ្វើការពិចារណាស៊ីសង្វាក់គ្នាលើវិស័យសិទ្ធិមនុស្ស និងធ្វើការវាយតម្លៃពីផលប៉ះពាល់របស់សេចក្តីស្នើច្បាប់ និងបទដ្ឋានគតិយុត្តិដទៃទៀត ពាក់ព័ន្ធនឹងការទទួលបានសិទ្ធិមនុស្ស ដោយប្រជាពលរដ្ឋ។ ដើម្បីធានាថា សិទ្ធិមនុស្សត្រូវបានដាក់បញ្ចូលក្នុងការងាររបស់សភា មានសភាកាន់តែច្រើនឡើង បានបង្កើតអង្គភាពជំនាញខាងសិទ្ធិមនុស្ស ឬប្រគល់ភារកិច្ចពាក់ព័ន្ធវិស័យសិទ្ធិមនុស្ស ឱ្យគណៈកម្មការដែលមានស្រាប់។ សភាជាច្រើន ក៏បានបង្កើតគណៈកម្មការសិទ្ធិមនុស្សតាម ប្រភេទផ្សេងៗគ្នា ដូចជាសមភាពយេនឌ័រ និងសិទ្ធិជនជាតិដើមភាគតិច។ បន្ថែមលើនេះក្រុមការងារក្រៅផ្លូវការរបស់សមាជិកសភាជាច្រើនបានធ្វើការយ៉ាងសកម្មក្នុងវិស័យសិទ្ធិមនុស្ស។

អង្គភាពសិទ្ធិមនុស្សរបស់សភាបានទទួលភារកិច្ចជាច្រើនផ្សេងៗគ្នា ដូចជាការវាយតម្លៃលើភាពសមស្របនៃសេចក្តីស្នើច្បាប់ ឬច្បាប់ដែលមានកាតព្វកិច្ចសិទ្ធិមនុស្ស។ ឯករណីខ្លះ អង្គភាពទាំងនេះ មានសមត្ថកិច្ចទទួលពាក្យបណ្តឹងរបស់បុគ្គល។

## ការអនុម័តច្បាប់សម្រាប់សម្រួលដល់ការអនុវត្តន៍

ប្រសិនបើកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ មិនត្រូវបានយកទៅអនុវត្តនៅក្នុងកំរិតជាតិទេ សន្ធិសញ្ញាទាំងឡាយ នឹងក្លាយជាលិខិតគ្មានន័យ។ សភា និងសមាជិកសភា មានតួនាទី

សំខាន់ នៅពេលអនុម័តច្បាប់ដែលចាំបាច់ សម្រាប់អនុវត្តក្នុងវិស័យណាមួយ (ដូចជា រដ្ឋប្បវេណី ព្រហ្មទណ្ឌ រដ្ឋបាល ឬច្បាប់ការងារ អប់រំ គាំពារសុខភាព ឬច្បាប់សន្តិសុខសង្គម)។

នីតិវិធីសំរាប់បកស្រាយសន្ធិសញ្ញាអន្តរជាតិ បញ្ចូលទៅក្នុងច្បាប់ជាតិ ជាទូទៅ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនានា ដែលកំណត់អំពីលទ្ធភាពដែលបុគ្គលម្នាក់ៗ អាចយកបញ្ញត្តិនៅក្នុងសន្ធិសញ្ញា មកធ្វើជាសំអាងនៅចំពោះមុខតុលាការជាតិបាន។ មធ្យោបាយ ជាមូលដ្ឋានមានពីររបៀបគឺ :

(ក) ប្រព័ន្ធបញ្ចូលដោយស្វ័យប្រវត្តិ មានន័យថា រាល់សន្ធិសញ្ញានានា បន្ទាប់ពីត្រូវបានឱ្យសច្ចាប័ន ឬរួមសច្ចាប័នហើយ ក្លាយជាផ្នែកមួយនៃច្បាប់ជាតិដែលបុគ្គលគ្រប់រូប អាចយកធ្វើជាសំអាងបាន។ ក្នុងករណីខ្លះ មានការតម្រូវឱ្យបោះពុម្ពផ្សាយសន្ធិសញ្ញានៅក្នុងរាជកិច្ចផ្លូវការ ឬធ្វើច្បាប់ជាតិ សម្រាប់អនុវត្តជាមុនសិន ទើបសន្ធិសញ្ញាទាំងនោះ មានអានុភាពផ្លូវច្បាប់ ដើម្បីអនុវត្តនៅក្នុងប្រទេស ទើបបុគ្គលគ្រប់រូប អាចយកបញ្ញត្តិទាំងនោះ ធ្វើជាសំអាងនៅចំពោះមុខតុលាការបាន។

(ខ) តាមប្រព័ន្ធទ្វិកនិយម សន្ធិសញ្ញាអាចក្លាយជាផ្នែកមួយនៃប្រព័ន្ធច្បាប់ជាតិបាន លុះត្រាតែមានការអនុម័តជាផ្លូវការ។ តាមប្រព័ន្ធនេះ បុគ្គលម្នាក់ៗមិនអាចយកបញ្ញត្តិរបស់សន្ធិសញ្ញាដែលមិនមែនជាផ្នែកនៃច្បាប់ជាតិ ទៅប្រើបានទេ។ បញ្ញត្តិទាំងនោះ គ្មានអនុភាពគតិយុត្តិលើច្បាប់ជាតិដែលផ្ទុយគ្នាឡើយ។

នៅបណ្តាប្រទេសដែលប្រើប្រព័ន្ធច្បាប់ស៊ីវិល ចាំបាច់តម្រូវឱ្យមានចែងអំពីសិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញ ព្រោះថា រដ្ឋធម្មនុញ្ញបានកំណត់និយាមក្នុងការបង្កើតក្របខ័ណ្ឌច្បាប់ជាតិឯទៀត ដែលត្រូវតែស្របគ្នាជាមួយស្មារតី និងគោលការណ៍របស់រដ្ឋធម្មនុញ្ញ។

## តើអ្នកអាចធ្វើអ្វីបានខ្លះក្នុងឋានៈជាសមាជិកសភា

សភាគួររួមចំណែក និងឃ្លាំមើលឱ្យបានទៀងទាត់លើការប្រតិបត្តិរបស់ស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញា។ ក្នុងស្មារតីនេះ អ្នកត្រូវ :

☐ ផ្ទៀងផ្ទាត់ស្ថានភាពនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋរបស់អ្នក និងស្ថាប័នសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ និងជាមួយយន្តការតាមឃ្លាំមើលជាអន្តរជាតិ និងថ្នាក់តំបន់ឯទៀតៗ (មើលផ្នែកទី I ជំពូកទី៥, ៦ និងទី៩) ដោយស្នើសុំព័ត៌មានពីរដ្ឋាភិបាលរបស់អ្នក។ អ្នកអាចដាក់សំណួរទៅកាន់រដ្ឋាភិបាលរបស់អ្នក អំពីបញ្ហានេះ

☐ ធានាថា សភាទទួលបានដំណឹងទាន់កាលៈទេសៈ អំពីការងាររបស់ស្ថាប័នសន្ធិសញ្ញា និងយន្តការពាក់ព័ន្ធផ្សេងៗ ហើយព័ត៌មានដែលពាក់ព័ន្ធនានា ត្រូវបានផ្ដល់ជូនសភាឱ្យបាន ទៀងទាត់ដោយសេវាគាំទ្ររបស់សភា

☐ ចាត់វិធានការបន្ថែមលើអនុសាសន៍ និងលើសេចក្ដីសន្និដ្ឋាននានា ព្រមទាំងមតិយោបល់ផ្សេង ទៀត ដែលស្ថាប័នសន្ធិសញ្ញាបានរៀបចំឡើង ពាក់ព័ន្ធនឹងប្រទេសរបស់អ្នក

☐ សិក្សាលើអនុសាសន៍ ដែលរៀបចំឡើងដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ជាពិសេស គឺអនុសាសន៍ដែលនិយាយអំពីស្ថានភាពនៅក្នុងប្រទេសរបស់អ្នក ប្រសិនបើមាន

☐ ពិនិត្យមើលថាតើ មានការចាត់វិធានការណាមួយដើម្បីអនុវត្តអនុសាសន៍ទាំងនេះដែរឬទេ? ករណីដែលគ្មាន ត្រូវប្រើនីតិវិធីរបស់សភា ដើម្បីរកមូលហេតុឱ្យឃើញ និងផ្ដួចផ្ដើមវិធានការបន្ត

☐ ធ្វើឱ្យប្រាកដថា អ្នករាយការណ៍ពិសេសបំពេញបេសកកម្មដល់ទីកន្លែងទៅធ្វើ

ទស្សនកិច្ចនៅសភារបស់អ្នក ឬនៅគណៈកម្មការសភាដែលមានសមត្ថកិច្ច ហើយធានាឱ្យប្រាកដថា សភានឹងទទួលបានរបាយការណ៍មួយច្បាប់ ។

☐ សូមធ្វើឱ្យប្រាកដថាអាណត្តិរបស់អ្នករាយការណ៍ពិសេសនឹងត្រូវបន្តនៅក្នុងប្រទេសរបស់អ្នក

☐ ប្រើអំណាចរបស់អ្នក ដើម្បីធ្វើទស្សនៈកិច្ចផ្ទាល់ដល់សាលារៀន មន្ទីរពេទ្យ ពន្ធនាគារ និងមន្ទីរឃុំឃាំងផ្សេងទៀត ការិយាល័យប៉ូលីស និងក្រុមហ៊ុនឯកជន ដើម្បីកំណត់ឱ្យច្បាស់ដោយខ្លួនឯងថាតើសិទ្ធិមនុស្សត្រូវបានគេគោរពដែរឬទេ ។

ដើម្បីតាមឃ្លាំមើលថាតើ រដ្ឋរបស់អ្នកបានបំពេញតាមកាតព្វកិច្ចក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សឬទេ អ្នកអាចធ្វើឱ្យប្រាកដថាៈ

☐ របាយការណ៍ជាតិដែលតម្រូវឱ្យធ្វើ ត្រូវដាក់ជូនឱ្យបានទៀងទាត់ ដោយធ្វើការសាកសួរក្រោយពីដល់ពេលកំណត់ ដែលប្រទេសអ្នកត្រូវរាយការណ៍ និងធានាថា រដ្ឋាភិបាលគោរពតាមពេលវេលាទាំងនោះ ។ ពេលដែលរបាយការណ៍ត្រូវបានពន្យាពេល អ្នកអាចស្នើឱ្យមានការពន្យល់ករណីចាំបាច់ត្រូវប្រើនីតិវិធីសភាដើម្បីជំរុញរដ្ឋាភិបាលឱ្យអនុវត្តកាតព្វកិច្ច ។

☐ របាយការណ៍ពេលលេញត្រូវបានដាក់ជូន ដើម្បីបានសម្រេចកិច្ចការនេះសូមធ្វើការធានាថាៈ

☐ សភា (តាមរយៈគណៈកម្មការមានសមត្ថកិច្ច) បានចូលរួមក្នុងការរៀបចំរបាយការណ៍ជាតិផ្តល់ព័ត៌មាន និងធានាថា សកម្មភាពរបស់សភាត្រូវបានដាក់បញ្ចូលល្អត្រឹមត្រូវទៅក្នុងរបាយការណ៍ ហើយក្នុងករណីណាក៏ដោយ សភាត្រូវតែបានដឹងឮអំពីខ្លឹមសារនៃរបាយការណ៍នោះ ។

☐ របាយការណ៍ត្រូវគោរពតាមគោលការណ៍ណែនាំស្តីពីនីតិវិធីធ្វើរបាយការណ៍

(មើលផ្នែកទីI ជំពូកទី៥) និងត្រូវយកចិត្តទុកដាក់លើអនុសាសន៍ទូទៅ និងសេចក្តីសង្កេតសន្និដ្ឋានលើរបាយការណ៍មុនៗ ដែលស្ថាប័នសន្ធិសញ្ញាបានធ្វើ ដោយពាក់ព័ន្ធករណីពីមុនៗ

☐ សមាជិកសភាម្នាក់ត្រូវមានវត្តមាន នៅពេលរបាយការណ៍នោះត្រូវបានដាក់បង្ហាញជូនស្ថាប័នសន្ធិសញ្ញាពាក់ព័ន្ធ។ ប្រសិនបើមិនអាចធ្វើដូចនេះបានទេត្រូវផ្តល់អនុសាសន៍ដល់ស្ថានបេសកកម្មអចិន្ត្រៃយ៍របស់ប្រទេសអ្នកប្រចាំនៅអង្គការសហប្រជាជាតិ (នៅ ទីក្រុងញូយ៉ក ឬទីក្រុងហ្សឺណែវ អាស្រ័យលើទីកន្លែង ដែលស្ថាប័នសន្ធិសញ្ញាជួបប្រជុំ) ឱ្យតាមដានការងាររបស់ស្ថាប័នសន្ធិសញ្ញា ដើម្បីធានាថារបាយការណ៍របស់ស្ថាប័នសន្ធិសញ្ញានេះត្រូវបានផ្ញើទៅជូនសភារបស់អ្នក។

**ប្រអប់ ៣៩**

## សមត្ថកិច្ចត្រឹមត្រូវនៃគណៈកម្មាធិការសិទ្ធិមនុស្សរបស់សភា

ដើម្បីឱ្យមានប្រសិទ្ធភាពពេញលេញ គណៈកម្មការសិទ្ធិមនុស្សរបស់សភា គួរ ៖

- មានអាណត្តិការងារទូលំទូលាយលើបញ្ហាសិទ្ធិមនុស្ស ដែលគ្របដណ្តប់លើការងារធ្វើច្បាប់ និងការងារត្រួតពិនិត្យ
- មានសមត្ថកិច្ចធ្វើការដោះស្រាយលើបញ្ហាសិទ្ធិមនុស្សដែលយល់ថាមានសារៈសំខាន់បង្កើតគំនិតផ្តើមធ្វើច្បាប់ និងគំនិតផ្តួចផ្តើមផ្សេងទៀតក្នុងវិស័យសិទ្ធិមនុស្ស និងដោះស្រាយបញ្ហាសិទ្ធិមនុស្សដែលបានលើកឡើងពាក់ព័ន្ធនឹងតតិយជន
- មានសមត្ថកិច្ចផ្តល់ប្រឹក្សាយោបល់ដល់គណៈកម្មការផ្សេងៗរបស់សភាអំពីវិស័យសិទ្ធិមនុស្ស
- មានអំណាចកោះហៅមនុស្ស និងស្នើឯកសារ និងធ្វើបេសកកម្មដល់ទីកន្លែង

## តើអ្នកអាចធ្វើអ្វីបានខ្លះក្នុងឋានៈជាសមាជិកសភា

ក្នុងឋានៈជាសមាជិកសភាអ្នកអាចៈ

- ☐ ធានាថា បញ្ញត្តិសិទ្ធិមនុស្សអន្តរជាតិទាំងឡាយត្រូវបានដាក់បញ្ចូលក្នុងច្បាប់ជាតិ ហើយប្រសិនជាអាចធ្វើបានផ្តល់ធម្មនុញ្ញភាពលើបញ្ញត្តិទាំងនោះ ដើម្បីឱ្យបញ្ញត្តិទាំងនោះ ទទួលបានការការពារជាអតិបរមានៅក្រោមច្បាប់ជាតិ
- ☐ ធានាថា សេចក្តីស្នើច្បាប់ដែលដាក់ជូនសភា និងបញ្ជូនមកគណៈកម្មការទទួលបន្ទុកវិស័យច្បាប់នោះត្រូវស៊ីសង្វាក់គ្នាជាមួយកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសអ្នក ហើយអ្នកអាចពិនិត្យឡើងវិញលើច្បាប់ដែលមានស្រាប់ ដើម្បីកំណត់ថាតើច្បាប់ទាំងនោះស្របជាមួយនឹងកាតព្វកិច្ចទាំងនោះដែរឬទេ
- ☐ ដើម្បីសម្រេចតាមគោលបំណងនេះ អ្នកគួរព្យាយាមយល់ដឹងអំពីការងាររបស់ស្ថាប័នសន្ធិសញ្ញានានា យល់ដឹងអំពីអនុសាសន៍នានាដែលរៀបចំធ្វើឡើងដោយស្ថាប័នសន្ធិសញ្ញាទាំងនោះ និងដោយយន្តការឃ្លាំមើលថ្នាក់តំបន់ និងអន្តរជាតិនានា (សូមមើលផ្នែកទី I ជំពូកទី ៥, ៦ និងទី៩) ហើយគួរយល់ដឹងអំពីការងាររបស់អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលធ្វើការលើវិស័យសិទ្ធិមនុស្ស និងការងាររបស់ស្ថាប័នជាតិសិទ្ធិមនុស្ស។ ប្រសិនបើរកឃើញថាមានភាពមិនស្របគ្នា ត្រូវចាត់វិធានការដើម្បីកែតម្រូវស្ថានភាពនោះ ដោយការធ្វើវិសោធនកម្ម ឬសេចក្តីព្រាងច្បាប់ថ្មី ឬធ្វើញត្តិប្តឹងទៅតុលាការធម្មនុញ្ញ ឬស្ថាប័នតុលាការស្រដៀងគ្នានេះនៅក្នុងប្រទេសរបស់អ្នក។
- ☐ ធានាថា ក្រឹត្យនានាដែលរដ្ឋាភិបាលបានដាក់ចេញ ត្រូវអនុលោមតាមច្បាប់ដែលកំពុងអនុវត្តមិនផ្ទុយនឹងស្មារតីច្បាប់ និងការធានាសិទ្ធិមនុស្ស ដែលក្រឹត្យទាំងនោះមានបំណងផ្តល់ជូន។
- ☐ ធានាថា មន្ត្រីសាធារណៈ ជាពិសេសភ្នាក់ងារអនុវត្តច្បាប់នានាមានការយល់ដឹងអំពី

ភារកិច្ចរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្ស និងទទួលបានការបណ្តុះបណ្តាលសមស្រប ។

- ☐ ដោយយល់ឃើញអំពីសារៈសំខាន់នៃការយល់ដឹងរបស់សាធារណជនលើសិទ្ធិមនុស្ស ត្រូវធានាថា ការអប់រំអំពីសិទ្ធិមនុស្សនឹងត្រូវដាក់បញ្ចូលជាផ្នែកមួយនៃកម្មវិធីសិក្សា នៅក្នុងសាលារៀនក្នុងប្រទេស ។
- ☐ ធានាថា កាតព្វកិច្ចសិទ្ធិមនុស្សក្រោមរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិត្រូវបានអនុវត្ត ដោយបើកចំហប្រកបដោយន័យស្ថាបនា ភាពច្នៃប្រឌិត និងសកម្ម ។

ប្រអប់ ៤០

## វិធានការរបស់សភា ដើម្បីលើកស្ទួយការធ្វើយុត្តិកម្មនៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក្នុងរដ្ឋជាច្រើន បុគ្គលគ្រប់រូបមិនអាចទាមទារសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ពួកគេនៅចំពោះមុខតុលាការបានទេ។ សភាអាចដោះស្រាយស្ថានភាពនេះ ដោយអនុម័តច្បាប់ជាតិដែលផ្តល់អំណាចឱ្យតុលាការជំនុំជម្រះបណ្តឹងទាក់ទងនឹងសិទ្ធិទាំងនេះ។ ការអនុវត្តន៍ជាក់ស្តែងកិច្ចការនេះមិនទាមទារឱ្យមានការកែទម្រង់ជាដុំកំភួនទេ។ ឧទាហរណ៍ បណ្តាប្រទេសជាច្រើនមានតុលាការការងារដែលមានសមត្ថកិច្ចជំនុំជម្រះក្តីទាក់ទងនឹងការបណ្តេញបុគ្គលិកចេញពីការងារតាមទំនើងចិត្ត ការរើសអើងក្នុងការជ្រើសរើសបុគ្គលិក ឬលក្ខខណ្ឌការងារមិនមានសុវត្ថិភាព។ ក្នុងបរិបទនេះ ភាពខុសគ្នាជាចម្បងគឺនៅត្រង់ថា មានច្បាប់តិចតួចណាស់ ដែលមានចែងច្បាស់អំពីសិទ្ធិការងារ និងសិទ្ធិទទួលបានលក្ខខណ្ឌការងារគួរជាទីពេញចិត្ត ដូចមានចែងក្នុងមាត្រា៦ និង៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ CESCR និងមានចៅក្រមតិចតួចណាស់ដែលបានដឹងថា ពួកគេកំពុងតែអនុវត្ត និងពង្រឹងការអនុវត្តសិទ្ធិសេដ្ឋកិច្ចជាមូលដ្ឋាននោះ។ ប្រហាក់ប្រហែលគ្នានេះដែរ បណ្តារដ្ឋជាច្រើនអនុវត្តច្បាប់ធានាឱ្យមានការអប់រំថ្នាក់មូលដ្ឋានដោយមិនបង់ប្រាក់ ក្នុងករណីនេះឪពុកម្តាយដែលមានកូនត្រូវបានគេបដិសេដមិនឱ្យចូលរៀន ដោយផ្អែកលើមូលដ្ឋានលំអៀង និងរើសអើង

ផ្សេងៗ មានលទ្ធភាពប្តឹងទៅស្ថាប័នរដ្ឋបាល និងតុលាការជាតិបាន។ មិនជាការពិបាកក្នុងការផ្សាភ្ជាប់ការទាមទារ និងដំណោះស្រាយករណីនេះទៅនឹងសិទ្ធិទទួលបានការអប់រំ ដូច្នេះសិទ្ធិនេះមានការធានាតាមផ្លូវច្បាប់ (ឬមានប្រសិទ្ធភាពដូចច្បាប់)។

*ក្រុមប្រឹក្សាអន្តរសភា "អំពាវនាវដល់គ្រប់សភា និងសមាជិកសភាទាំងអស់ឱ្យចាត់វិធានការថ្នាក់ជាតិ ដើម្បីធានាថា ច្បាប់ផ្តល់នីតិសម្បទា ត្រូវបានអនុម័ត និងធានាថា បញ្ញត្តិ និងបទបញ្ជាអនុវត្តច្បាប់ទាំងឡាយរបស់ជាតិ មានភាពស៊ីសង្វាក់គ្នាជាមួយទម្រង់ និងស្តង់ដា ដែលមាននៅក្នុងលិខិតុបករណ៍ (អន្តរជាតិ) ទាំងនេះ ក្នុងទស្សនៈឆ្ពោះទៅរកការអនុវត្តដោយពេញលេញ "។*

*សេចក្តីសម្រេចដែលបានអនុម័តនាឱកាសខួបទី៥០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នាទីក្រុង Cairo ខែកញ្ញា ឆ្នាំ១៩៩៧ កថាខ័ណ្ឌទី៣ (ii)*

## ប្រអប់ ៤១

### ដំណើរការធ្វើច្បាប់ និងស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ : ឧទាហរណ៍

ដំណើរការធ្វើច្បាប់នៅប្រទេសហ្វាំងឡង់ ជាពិសេសការងាររបស់គណៈកម្មការសភាទទួលបន្ទុកច្បាប់រដ្ឋធម្មនុញ្ញ បង្ហាញជាញឹកញាប់ ពីការប្រើប្រាស់ស្តង់ដាអន្តរជាតិ (ដោយរួមទាំងលទ្ធផលរបស់ស្ថាប័នសន្ធិសញ្ញា) ក្នុងដំណើការព្រាងច្បាប់ និងត្រួតពិនិត្យសេចក្តីស្នើច្បាប់។ ក្របខ័ណ្ឌសម្រាប់ការប្រើប្រាស់របៀបនេះ មានចែងក្នុងផ្នែកទី ២២ នៃរដ្ឋធម្មនុញ្ញ (ឆ្នាំ២០០០) ដែលបានចែងថា "អាជ្ញាធរសាធារណៈ ត្រូវតែធានាការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋាន និងសិទ្ធិមនុស្សអន្តរជាតិ "និងផ្នែកទី៧៤ ចែងថា "គណៈកម្មាធិការទទួលបន្ទុកច្បាប់រដ្ឋធម្មនុញ្ញត្រូវចេញសេចក្តីថ្លែងការណ៍ស្តីអំពី

ធម្មនុញ្ញភាពរបស់សេចក្តីស្នើច្បាប់ និងករណីផ្សេងទៀត ដែលបានបញ្ជូនមកឱ្យគណៈកម្មការធ្វើការពិចារណា ព្រមទាំងអំពីទំនាក់ទំនងនៃសេចក្តីស្នើច្បាប់នោះទៅនឹងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ”។ អាណត្តិការងាររបស់គណៈកម្មការទទួលបន្ទុកច្បាប់រដ្ឋធម្មនុញ្ញ គឺពិនិត្យលើភាពស៊ីសង្វាក់គ្នានៃសេចក្តីស្នើច្បាប់និងរដ្ឋធម្មនុញ្ញ និងស្តង់ដាសិទ្ធិមនុស្ស និងត្រូវផ្តល់ទស្សនៈពាក់ព័ន្ធនានាជូនសភា និងស្ថាប័នដទៃទៀត។ គណៈកម្មាធិការពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនាញបណ្ឌិតសភាពីប្រភពខាងក្រៅ។

ប្រភេទនៃលទ្ធផលរបស់ស្ថាប័នសន្ធិសញ្ញា ជាពិសេសលទ្ធផលរបស់គណៈកម្មាធិការសិទ្ធិមនុស្សដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងដំណើរការនីតិកម្មរបស់ប្រទេសហ្វាំងឡង់ ដោយដំបូងបំផុតដាក់បញ្ចូលសេចក្តីសម្រេចស្តីពីរឿងក្តីជាឯកត្តបុគ្គល និងសេចក្តីអធិប្បាយទូទៅ ក៏ប៉ុន្តែមិនបានដាក់បញ្ចូលសេចក្តីសង្កេតសន្និដ្ឋាន គោលការណ៍ណែនាំសម្រាប់ធ្វើរបាយការណ៍ និងសំភារៈផ្សេងទៀតនោះទេ។ សំភារៈជាក់លាក់សំរាប់ប្រទេស រួមមានឯកសារយោងនានា មិនគ្រាន់តែយោងទៅលើប្រទេសហ្វាំងឡង់ប៉ុណ្ណោះទេ ថែមទាំងយោងទៅលើឯកសាររបស់ប្រទេសផ្សេងៗទៀតផងដែរ។ ក្នុងករណីខ្លះ ការយោងលើប្រភពនៃស្ថាប័នសន្ធិសញ្ញាបណ្តាលមកពីការអនុវត្តផ្ទាល់តាមកាតព្វកិច្ចផ្លូវច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ។ កិច្ចការនេះអាចធ្វើបានដើម្បីឆ្លើយតបទៅនឹងលទ្ធផលជាក់លាក់ណាមួយ ដែលស្ថាប័នសន្ធិសញ្ញាបានរកឃើញថាការរំលោភបំពានបានកើតឡើង ឬអាចបណ្តាលមកពីលក្ខខណ្ឌតម្រូវជាទូទៅរបស់រដ្ឋធម្មនុញ្ញ ដើម្បីធានាឱ្យមានការគោរពតាមបញ្ញត្តិសិទ្ធិមនុស្ស។[១៨]

---

[១៨] សមាគមច្បាប់អន្តរជាតិ (ILA) របាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការទទួលបន្ទុកការអនុវត្តន៍ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិរបស់សមាគមច្បាប់អន្តរជាតិស្តីពីផលប៉ះពាល់របស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលបង្ហាញការរកឃើញនានាអំពីការងាររបស់តុលាការ និងសាលាក្តីជាតិ។ សន្និសីទ ILA ធ្វើរៀងរាល់ពីរឆ្នាំម្តង នៅទីក្រុង ប៊ែរឡាំង ខែសីហា ឆ្នាំ ២០០៤ ទំព័រ ៣៦-៣៨។

ប្រអប់ ៤២

**គោលការណ៍ទីក្រុងប៉ារីស**

នៅឆ្នាំ១៩៩៣ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តគោលការណ៍អនុវត្ត ដើម្បីបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស (មើលទំព័របន្ទាប់)។ គោលការណ៍នេះ ត្រូវបានគេស្គាល់ថាជា "គោលការណ៍ទីក្រុងប៉ារីស" គោលការណ៍នេះ ត្រូវបានទទួលយកជាបទដ្ឋានអន្តរជាតិ ដែលកំណត់ស្តង់ដាអប្បបរិមាសំខាន់ៗ សម្រាប់តួនាទី និងការប្រព្រឹត្តទៅ នៃស្ថាប័នទាំងនេះ។ យោងតាមគោលការណ៍នេះ ស្ថាប័នជាតិសិទ្ធិមនុស្ស ត្រូវ ៖

- មានឯករាជ្យភាព ភាពឯករាជ្យរបស់ស្ថាប័ន គួរត្រូវបានធានាដោយច្បាប់លក្ខន្តិកៈ ឬដោយបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ
- មានលក្ខណៈពហុនិយម នៅក្នុងតួនាទី និងសមាជិកភាពរបស់ខ្លួន
- មានអាណត្តិទូលំទូលាយ តាមដែលអាចធ្វើបាន
- មានអំណាចស៊ើបអង្កេតគ្រប់គ្រាន់
- ត្រូវមានមុខងារទៀងទាត់ និងមានប្រសិទ្ធភាព
- មានមូលនិធិគ្រប់គ្រាន់
- ត្រូវបើកចំហចំពោះសាធារណៈជនទូទៅ

## ការបង្កើត និងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

### *ស្ថាប័នសិទ្ធិមនុស្សជាតិ (NHRIs)*

អំឡុងពេល២០ឆ្នាំកន្លងមកនេះមានការយល់ដឹងកាន់តែច្រើនឡើងអំពីសេចក្តីត្រូវការដើម្បីពង្រឹងសកម្មភាពព្រមៗគ្នានៅថ្នាក់ជាតិ ក្នុងគោលបំណងអនុវត្ត និងធានាដល់ការគោរពតាមស្តង់ដាសិទ្ធិមនុស្ស។ មធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយជាច្រើន គឺការបង្កើត

ស្ថាប័នជាតិសិទ្ធិមនុស្ស (NHRIs) ។ ខណៈដែលពាក្យស្ថាប័នជាតិសិទ្ធិមនុស្ស មានន័យគ្រប ដណ្តប់លើអង្គភាពជាច្រើនដែលមានស្ថានភាពផ្លូវច្បាប់ សមាសភាព រចនាសម្ព័ន្ធ មុខងារ និង អាណត្តិការងារផ្សេងពីគ្នា អង្គភាពទាំងនេះត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល ដើម្បីប្រតិបត្តិការ ដោយឯករាជ្យ ដូចជាតុលាការដែរ ក្នុងទស្សនៈលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។

NHRIs ជាទូទៅត្រូវបានហៅថា គណៈកម្មការសិទ្ធិមនុស្ស គួរមានសមត្ថភាព និងអំណាច ដើម្បីៈ

- ដាក់អនុសាសន៍ សេចក្តីស្នើ និងរបាយការណ៍ជូនរដ្ឋាភិបាល ឬជូនសភាអំពីបញ្ហាទាំងឡាយណា ដែលពាក់ព័ន្ធ នឹងសិទ្ធិមនុស្ស
- ជំរុញច្បាប់ជាតិ និងការអនុវត្តនៅថ្នាក់ជាតិ ឱ្យមានភាពស្របគ្នាទៅនឹងស្តង់ដាអន្តរជាតិ
- ទទួល និងចាត់វិធានការលើរាល់បណ្តឹងជាបុគ្គល ឬជាក្រុម ស្តីពីការរំលោភសិទ្ធិមនុស្ស
- លើកទឹកចិត្តឱ្យមានការផ្តល់សច្ចាប័ន និងការអនុវត្តតាមស្តង់ដាសន្ធិសញ្ញាសិទ្ធិមនុស្ស អន្តរជាតិ និងរួមចំណែកទៅក្នុងនីតិវិធីធ្វើរបាយការណ៍ ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្ស អន្តរជាតិ
- លើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស តាមរយៈព័ត៌មាន ការអប់រំ និងធ្វើការស្រាវ ជ្រាវនៅក្នុងវិស័យសិទ្ធិមនុស្ស
- សហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ ស្ថាប័ននៅក្នុងតំបន់ ស្ថាប័នជាតិនៃ ប្រទេសឯទៀត១ និងអង្គការក្រៅរដ្ឋាភិបាល

ទំនាក់ទំនងរវាង NHRIs ជាមួយរដ្ឋសភា មានសក្តានុពលធំធេងណាស់ ដើម្បីការពារ និង លើកស្ទួយសិទ្ធិមនុស្សនៅថ្នាក់ជាតិ ។ កិច្ចទំនាក់ទំនងនេះ ត្រូវបានលើកមកពិភាក្សានៅក្នុងសិក្ខាសាលា អន្តរជាតិមួយ ដែលមានចំណងជើងថា *ស្ថាប័នជាតិសិទ្ធិមនុស្ស និងនីតិបញ្ញត្តិ : ការកសាងទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាព* ដែលបានរៀបចំនៅទីក្រុង Abuja ប្រទេសនីហ្សេរីយ៉ា ពីថ្ងៃទី២២

ដល់២៥ មីនា ឆ្នាំ២០០៤ ។[១៩]

គោលការណ៍ណែនាំមួយចំនួន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងNHRIs និងសភា ដែលត្រូវបានគេស្គាល់ថា ជាគោលការណ៍ណែនាំ Abuja ត្រូវបានរៀបចំឡើងក្នុងអំឡុងពេលនៃសិក្ខាសាលាខាងលើ ។

**ប្រអប់ ៤៣**

## បណ្តាប្រទេសដែលបានបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស

**បណ្តាប្រទេសដែលបានបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដែលបានទទួលស្គាល់ដោយគណៈកម្មាធិការសម្របសម្រួលអន្តរជាតិនៃស្ថាប័នជាតិ ដើម្បីការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស:**

| | |
|---|---|
| *អាស៊ី និងប៉ាស៊ីហ្វិក:* | អូស្ត្រាលី ហ្វីជី ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ម៉ុងហ្គោលី នេប៉ាល់ នូវែលសេឡង់ ហ្វីលីពីន សាធារណៈរដ្ឋកូរ៉េ ស្រីលង្កា ថៃឡង់ |
| *អាហ្វ្រិក:* | អាល់ហ្សេរី កាមេរូន ហ្គាណា ម៉ាឡាវី ម៉ូរីទីស ម៉ូរ៉ុក នីហ្សេ នីហ្សេរីយ៉ា រវ៉ាន់ដា សេណេហ្គាល់ អាហ្វ្រិកខាងត្បូង តូហ្គូ យូហ្គាន់ដា |
| *អាមេរិក:* | អាហ្សង់ទីន បូលីវី កាណាដា កូឡុំប៊ី កូស្តារីកា អេក្វាឌ័រ ហ្គាតេម៉ាឡា ហុងឌុយរ៉ាស់ មិចស៊ិច ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉េរូ វ៉េណេហ្ស៊ុយអេឡា |
| *អឺរ៉ុប* | អាលបានី បូស្នីនិងហឺហ្សេហ្គូវីណា ដាណឺម៉ាក បារាំង អាល្លឺម៉ង់ ក្រិច អៀកឡង់ លុចសំបួរ ប៉ូឡូញ ប័ទុយហ្គាល់ អេស្ប៉ាញ ស៊ុយអែត |

[១៩] សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងដោយគណៈកម្មការជាតិសិទ្ធិមនុស្ស ប្រទេសនីហ្សេរីយ៉ា គណៈកម្មការសិទ្ធិមនុស្សរបស់សភាតំណាងរាស្ត្រប្រទេសនីហ្សេរីយ៉ា សហគមន៍ធនធានច្បាប់របស់ប្រទេសនីហ្សេរីយ៉ា និងក្រុមប្រឹក្សាចក្រភពអង់គ្លេស ហើយត្រូវបានគាំទ្រដោយការិយាល័យកិច្ចការបរទេស និង កំមិនវែលរបស់ចក្រភពអង់គ្លេស ។

ផ្សេងៗទៀត៖

| | |
|---|---|
| *អាស៊ី និងប៉ាស៊ីហ្វិក:* | ហុងកុង តំបន់រដ្ឋបាលពិសេសរបស់ប្រទេសចិន សាធារណៈរដ្ឋឥស្លាមអ៊ីរ៉ង់ |
| *អាហ្វ្រិក:* | បឺណាំង បឺគីណាហ្វាសូ ឆាត មាដាហ្គាស្កា ណាមីប៊ី សាធារណៈរដ្ឋតង់ហ្សានី និងហ្សំប៊ី |
| *អាមេរិក:* | អង់ទីហ្គានិងបាប៊ុយដា បាបាដូស |
| *អ៊ឺរ៉ុប* | អូទ្រីស ប៊ែលហ្សិក ហុល្លង់ ណ័រវ៉ែស សហព័ន្ធរុស្ស៊ី ស្លូវ៉ាគី ស្លូវ៉ានី និងចក្រភពអង់គ្លេស |

## ប្រអប់ ៤៤

### អនុសាសន៍សម្រាប់សមាជិកសភាអំពីគោលការណ៍ណែនាំ Abuja

- សភា គួរបង្កើតក្របខ័ណ្ឌគតិយុត្តមួយសមស្របដើម្បីបង្កើត NHRIs ដោយអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីស ។
- សភា និង NHRIs គួរបង្កើតនូវទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពមួយដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្សឱ្យកាន់តែប្រសើរ ។
- សភា គួរធានាថា ធនធាន និងមធ្យោបាយគ្រប់គ្រាន់ត្រូវបានផ្តល់ឱ្យ NHRIs ដើម្បីបង្កលក្ខណៈឱ្យNHRIs អាចបំពេញការងារប្រកបដោយប្រសិទ្ធភាព ។ សភា គួរធានាបន្ថែមថា ធនធានទាំងនោះ ប្រាកដជាត្រូវបានរក្សាទុកសម្រាប់ NHRIs ប្រើប្រាស់តាមតម្រូវការ ។
- របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ដទៃទៀតរបស់ NHRIs-ការឆ្លើយតបរបស់រដ្ឋាភិបាល គួរត្រូវលើកយកមកពិភាក្សានៅក្នុងសភាឱ្យបានលឿនបំផុត ។
- គណៈកម្មាធិការសភាមួយដែលមានសមាសភាពពីគ្រប់គណៈបក្សទាំងអស់ គួរមានតួនាទីជាក់លាក់ដើម្បីពិនិត្យ និងគាំទ្រការងាររបស់ NHRIs ។ នៅក្នុងប្រទេសតូចៗ កិច្ចការនេះ អាចត្រូវ

អនុវត្តដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់សភា។

- សមាជិករបស់ NHRIs គួរត្រូវបានអញ្ជើញមកកាន់គណៈកម្មការសភាឱ្យបានទៀងទាត់ ដើម្បីពិភាក្សាលើរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ផ្សេងទៀតរបស់ស្ថាប័ន។
- សមាជិកសភា គួរអញ្ជើញសមាជិករបស់ NHRIs ជួបពិភាក្សាគ្នាជាទៀងទាត់លើករណីដែលជាប្រយោជន៍រួម
- សមាជិកសភា គួរធានាឱ្យមានពេលគ្រប់គ្រាន់ សម្រាប់ធ្វើការពិចារណាលើការងាររបស់ NHRIs
- សមាជិកសភា គួរធានាថា ពលរដ្ឋនៅក្នុងមណ្ឌលដែលខ្លួនតំណាង បានយល់ដឹងអំពីកិច្ចការរបស់ NHRIs
- សមាជិកសភា គួរពិនិត្យដោយប្រុងប្រយ័ត្នទៅលើសេចក្តីស្នើណាមួយរបស់រដ្ឋាភិបាល ដែលអាចមានផលប៉ះពាល់ ផ្ទុយទៅនឹងកិច្ចការរបស់ NHRIs និងគប្បីស្វះស្វែងពិគ្រោះយោបល់ជាមួយសមាជិក NHRIs អំពីសំណើនោះ
- សមាជិកសភា គួរធានាថា អនុសាសន៍របស់ NHRIs សម្រាប់វិធានការអ្វីមួយ ត្រូវបានយកទៅអនុវត្ត និងពិនិត្យតាមដាន។

## ***ការិយាល័យទទួលដោះស្រាយបណ្តឹង*** (Ombudsman)

ការិយាល័យទទួលដោះស្រាយបណ្តឹង ជាស្ថាប័នជាតិមួយ ដែលមានបង្កើតនៅក្នុងបណ្តាប្រទេសជាច្រើន។ មានសកម្មភាពត្រួតស៊ីគ្នាខ្លះ រវាងការិយាល័យទទួលដោះស្រាយបណ្តឹង និងគណៈកម្មការជាតិសិទ្ធិមនុស្ស ប៉ុន្តែជាទូទៅ តួនាទីរបស់ការិយាល័យទទួលដោះស្រាយបណ្តឹង មានភាពចង្អៀតជាង គឺមានតួនាទីក្នុងការធានាឱ្យមានភាពត្រឹមត្រូវ និងភាពស្របតាមច្បាប់ នៅក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ ជាទូទៅ ការិយាល័យទទួលដោះស្រាយបណ្តឹង ត្រូវ រាយការណ៍ជូនសភា។ មានតែការិយាល័យទទួលដោះស្រាយបណ្តឹងផ្នែកសិទ្ធិមនុស្សជាក់លាក់ប៉ុណ្ណោះ ដែលអាចចាត់ទុកថាជាស្ថាប័នជាតិសិទ្ធិមនុស្ស។

## *ផែនការសកម្មភាពសិទ្ធិមនុស្សថ្នាក់ជាតិ*

គ្មានរដ្ឋណាមួយនៅលើពិភពលោកនេះ មានប្រវត្តិសិទ្ធិមនុស្សល្អឥតខ្ចោះនោះទេ។ លើសពីនេះទៀត ដោយសារតែប្រទេសនីមួយៗ ត្រូវអភិវឌ្ឍគោលនយោបាយសិទ្ធិមនុស្សរបស់ខ្លួន តាមស្ថានភាពជាក់ស្តែងផ្នែកនយោបាយ វប្បធម៌ ប្រវត្តិសាស្ត្រ និងកាលៈទេសៈច្បាប់នោះ ករណីនេះបង្ហាញថា គ្មានរបៀបដោះស្រាយបញ្ហាសិទ្ធិមនុស្សជាគំរូតែមួយសម្រាប់បណ្តាប្រទេសទាំងអស់លើពិភពលោកទេ។ យោងតាមសន្និសីទពិភពលោកឆ្នាំ ២០០៣ នៅទីក្រុងវីយ៉ែនស្តីពីសិទ្ធិមនុស្ស បានលើកទឹកចិត្តរដ្ឋនានា ឱ្យរៀបចំផែនការសកម្មភាពស្តីពីសិទ្ធិមនុស្ស ដើម្បីចងក្រងយុទ្ធសាស្ត្រសិទ្ធិមនុស្ស ស្របទៅនឹងស្ថានភាពរបស់ប្រទេសខ្លួន។ ការសម្រេចក្នុងការធ្វើផែនការសកម្មភាពជាតិ គឺជាសេចក្តីប្រឹងប្រែងសម្រាប់ជាតិទាំងមូល ដោយមិនប្រកាន់និន្នាការនយោបាយ និងបក្សពួកទេ។ ផែនការសកម្មភាពជាតិនេះ ត្រូវមានការគាំទ្រពីរដ្ឋាភិបាល និងមានការចូលរួមពីគ្រប់ផ្នែកទាំងអស់ក្នុងសង្គម ព្រោះថា ការសម្រេចបានជោគជ័យនូវផែនការទាំងនេះ គឺអាស្រ័យទាំងស្រុង ថាតើ ប្រជាពលរដ្ឋមានភាពជាម្ចាស់លើផែនការសកម្មភាពនោះបានប៉ុណ្ណា។

មុខនាទីចំបងនៃផែនការនេះ គឺដើម្បីធ្វើឱ្យប្រសើរឡើងដល់ការលើកកំពស់ និងកិច្ចការពារសិទ្ធិមនុស្ស។ ដើម្បីសម្រេចបានទិសដៅនេះ ផែនការធ្វើឱ្យសិទ្ធិមនុស្សប្រសើរឡើងនេះ ត្រូវតែទុកជាវត្ថុបំណងជាក់លាក់របស់គោលនយោបាយសាធារណៈ ដែលត្រូវធ្វើតាមរយៈការអនុវត្តកម្មវិធីច្បាស់លាស់ ការចូលរួមរបស់ផ្នែកពាក់ព័ន្ធផ្សេងៗរបស់រដ្ឋាភិបាល និងសង្គម និងការផ្តល់ធនធនឱ្យបានគ្រប់គ្រាន់។ ផែនការនេះ គួរផ្អែកលើការវាយតម្លៃជាក់លាក់អំពីសេចក្តីត្រូវការសិទ្ធិមនុស្សក្នុងប្រទេស។ ផែនការនេះ គួរផ្តល់គោលការណ៍ណែនាំស្តីពីកិច្ចការដែលត្រូវធ្វើក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សជូនមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ក្រុមវិជ្ជាជីវៈ អ្នកអប់រំនិងក្រុមតស៊ូមតិ និងសមាជិកនៃអង្គការសង្គមស៊ីវិល

ដទៃទៀត។ ផែនការនេះ គួរជំរុញឱ្យផ្តល់សច្ចាប័នលើលិខិតុបករណ៍សិទ្ធិមនុស្ស និងលើកកំពស់កម្រិតយល់ដឹងអំពីបទដ្ឋានសិទ្ធិមនុស្ស ដោយផ្តោតការយកចិត្តទុកដាក់ ជាពិសេសលើស្ថានភាពសិទ្ធិមនុស្សរបស់ក្រុមជនដែលងាយរងគ្រោះ។ ព័ត៌មានពិស្តារអំពីផែនការសកម្មភាពជាតិស្តីពីសិទ្ធិមនុស្ស និងរបៀបរៀបចំធ្វើផែនការសកម្មភាពទាំងនោះ អាចរកបាននៅក្នុង*សៀវភៅរបស់OHCHR ស្តីពីផែនការសកម្មភាពសិទ្ធិមនុស្ស ថ្នាក់ជាតិ* កម្រងសៀវភៅសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈលេខ១០ ដែលអាចរកបានតាមគេហទំព័រ ដែលមានអាស័យដ្ឋានតទៅនេះ: http://www.ohchr.org/english/about/publications/training.htm ។

ផែនការសកម្មភាពជាតិ ទាមទារឱ្យមានកិច្ចប្រឹងប្រែងជាច្រើនពីសំណាក់អង្គការរដ្ឋ។ កត្តាមួយចំនួន ដែលផ្តល់ផលជាវិជ្ជមានដោយផ្ទាល់ ទៅលើប្រសិទ្ធភាពរបស់ផែនការ នេះមានជាអាទិ៍:

- កិច្ចគាំពារជាប្រចាំពីផ្នែកនយោបាយ
- ការធ្វើផែនការប្រកបដោយតម្លាភាព និងមានការចូលរួមពីច្រើនផ្នែក
- ការវាយតម្លៃយ៉ាងពិស្តារអំពីស្ថានភាពសិទ្ធិមនុស្ស
- ធ្វើចំណាក់ថ្នាក់អាទិភាពបែបប្រាកដនិយមចំពោះបញ្ហាដែលត្រូវដោះស្រាយ និងវិធីដោះស្រាយតាមទិសដៅសកម្មភាព
- លក្ខណៈវិនិច្ឆ័យច្បាស់លាស់លើការបំពេញការងារ និងមានយន្តការចូលរួមយ៉ាងសកម្មក្នុងការឃ្លាំមើល និងវាយតម្លៃ
- ការប្តេជាចិត្តខ្ពស់ក្នុងការផ្តល់ធនធានបានគ្រប់គ្រាន់

ប្រអប់ ៤៥

## ការរៀបចំផែនការសកម្មភាពជាតិស្តីពីសិទ្ធិមនុស្ស : ឧទាហរណ៍

នៅប្រទេសលីទុយអានី (Lithuania) សភា គណៈកម្មាធិការសភាទទួលបន្ទុក សិទ្ធិមនុស្ស និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានរួមគ្នាចងក្រងផែនការសកម្មភាពសិទ្ធិមនុស្សថ្នាក់ជាតិ។ ដំណើរការរៀបចំមានបីដំណាក់កាល។ ដំណាក់កាលទីមួយ ធ្វើចំណាត់ថ្នាក់អាទិភាពនៃបញ្ហា តាមរយៈដំណើរដែលមានការចូលរួមពីផ្នែកផ្សេងៗ និងអ្នកជំនាញការរៀបចំនូវការសិក្សាមូលដ្ឋានមួយ ពីបញ្ហាសិទ្ធិមនុស្សនៅប្រទេសលីទុយអានី។ ដំណាក់កាលទីពីរ ការសិក្សាត្រូវបានផ្តល់សុពលភាពនៅក្នុងសន្និសីទថ្នាក់ជាតិ និងក្នុងសិក្ខាសាលាថ្នាក់តំបន់។ ដំណាក់កាលចុង ក្រោយធ្វើការលើកផែនការដោយផ្អែកលើមូលដ្ឋាននៃការសិក្សា និងការប្រឹក្សាយោបល់ដ៏ទូលំទូលាយ។ ផែនការនោះត្រូវបានពិភាក្សានៅក្នុងគណៈកម្មាធិការសភា និងត្រូវបានអនុម័តយល់ព្រមដោយសភា នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០២។ ការវិភាគជាបន្ត បន្ទាប់នៃដំណើរការនេះ បានបង្ហាញថា តួនាទីដឹកនាំដោយគណៈកម្មាធិការសភាទទួលបន្ទុកសិទ្ធិមនុស្ស មានសារៈសំខាន់ដូចគ្នាទៅនឹងសារៈសំខាន់ ដែលគណៈកម្មាធិការនេះបានធ្វើឱ្យសាធារណៈជន ចូលរួមយ៉ាងទូលំទូលាយក្នុងការរៀបចំដែរ។

## តើអ្នកអាចធ្វើអ្វីបានខ្លះក្នុងឋានៈអ្នកជាសមាជិកសភា

ដោយយល់ពីសារៈសំខាន់របស់យន្តការលើកតំកើង និងការពារសិទ្ធិមនុស្សរបស់ សភា និងយន្តការផ្សេងទៀត ដែលមិនមែនជារបស់សភា និងដើម្បីលើកកំពស់ការយល់ដឹងរបស់សាធារណៈជន អ្នកត្រូវ :

☐ ជម្រុញឱ្យបង្កើតគណៈកម្មាធិការសភាដែលមានជំនាញផ្នែកសិទ្ធិមនុស្សនៅក្នុងសភារបស់អ្នក

☐ ជម្រុញឱ្យបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ នៅក្នុងប្រទេសរបស់អ្នក ស្របតាមគោលការណ៍ទីក្រុងប៉ារីស ចាត់វិធានការដើម្បីអនុវត្តគោលការណ៍ណែនាំ Abuja (មើលប្រអប់ ៤២ និង ៤៤)

☐ ដាក់សំណើសុំឱ្យមានការរៀបចំផែនការសកម្មភាពសិទ្ធិមនុស្សថ្នាក់ជាតិ ប្រសិនបើមានការរៀបចំផែនការនេះ សូមធានាថា សភានឹងបានចូលរួមក្នុងគ្រប់ដំណាក់កាល ទាំងអស់នៃការរៀបចំតាក់តែង និងការអនុវត្ត។

## ការកៀងគរសាធារណៈមតិ

សភាអាចរួមចំណែកបានយ៉ាងធំធេងក្នុងការលើកកំពស់ការយល់ដឹងរបស់សាធារណៈជនអំពីសិទ្ធិមនុស្ស និងការកៀងគរមតិសាធារណៈអំពីបញ្ហាពាក់ព័ន្ធនេះ ឱ្យបានកាន់តែច្រើន ដោយសារ ថាការពិភាក្សាផ្នែកនយោបាយតែងតែផ្តោតលើបញ្ហា ដូចជាការរើសអើងប្រឆាំងក្រុមផ្សេងៗ សមភាពយេនឌ័រ សិទ្ធិជនជាតិដើមភាគតិច ឬបញ្ហាសង្គមនានា។ នៅគ្រប់ពេលទាំងអស់ សមាជិកសភាគួរតែមានស្មារតីប្រុងប្រយ័ត្នអំពីផលប៉ះពាល់នៃសេចក្តីថ្លែងការណ៍ជាសាធារណៈចំពោះបញ្ហាសិទ្ធិមនុស្ស ដែលអាចមានផលប៉ះពាល់ទៅលើការយល់ឃើញរបស់សាធារណជន។

ដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្សជាទូទៅនៅក្នុងប្រទេសរបស់ពួកគេ សមាជិកសភា គួរធ្វើការជាមួយតួអង្គផ្សេងៗទៀតរបស់ជាតិនៅក្នុងប្រទេស ដែលធ្វើការលើបញ្ហាសិទ្ធិមនុស្ស បូករួមទាំងអង្គការក្រៅរដ្ឋាភិបាល។

*“ អង្គការក្រៅរដ្ឋាភិបាលមានដូចជាសហជីពកម្មករ សមាគមឯកជន និងអង្គការសិទ្ធិមនុស្ស គឺជាប្រភពព័ត៌មាន និងជំនាញដែលមិនអាចកាត់ថ្លៃបានសម្រាប់សមាជិកសភា នៅតាមបណ្តាប្រទេសជាច្រើន ដែលខ្វះខាតនូវធនធាន និងជំនួយដែលត្រូវការចាំបាច់ដើម្បីឱ្យពួកគេមានប្រសិទ្ធភាព*

*ក្នុងការតាមឃ្លាំមើលលើគោលនយោបាយ និងការអនុវត្តរបស់រដ្ឋាភិបាលនៅក្នុងវិស័យសិទ្ធិមនុស្ស"*

*សន្និសីទ IPU អំពី "សភា : អ្នកថែរក្សាសិទ្ធិមនុស្ស"*
*ការពិភាក្សានៅទីក្រុងប៊ុយដាប៉េស ខែឧសភា ឆ្នាំ១៩៩៣*

**តើអ្នកអាចធ្វើអ្វីបានខ្លះក្នុងឋានៈអ្នកជាសមាជិកសភា**

អ្នកអាច ៖

- ☐ ជម្រុញឱ្យសភាធ្វើការពិភាក្សាបញ្ហាសិទ្ធិមនុស្សជាពិសេសបញ្ហាដែលសាធារណៈមតិផ្តោតការយកចិត្តទុកដាក់
- ☐ ជម្រុញឱ្យមានការពិភាក្សា នៅក្នុងរង្វង់គណៈបក្សនយោបាយរបស់អ្នក លើវិស័យសិទ្ធិមនុស្ស និងលើកាតព្វកិច្ចជាអន្តរជាតិរបស់រដ្ឋ ក្នុងវិស័យនេះ
- ☐ រៀបចំយុទ្ធនាការនៅមូលដ្ឋានថ្នាក់តំបន់ ឬថ្នាក់ជាតិ ដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស
- ☐ ចូលរួមក្នុងកិច្ចពិភាក្សាតាមទូរទស្សន៍ ឬតាមវិទ្យុ ឬនៅក្នុងកិច្ចប្រជុំនានា ឬផ្តល់កិច្ចសម្ភាសន៍អំពីបញ្ហាសិទ្ធិមនុស្ស
- ☐ សរសេរអត្ថបទអំពីសិទ្ធិមនុស្ស នៅក្នុងកាសែត និងទស្សនាវដ្តីនានា
- ☐ ភ្ជាប់ទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល និងតួអង្គដែលធ្វើការផ្នែកសិទ្ធិមនុស្ស និងគណៈបក្សនយោបាយដទៃទៀតនៅថ្នាក់ជាតិ ដើម្បីប្រមូលមតិសាធារណៈ និងដើម្បីរៀបចំយុទ្ធសាស្ត្រសម្រាប់ផ្តល់ព័ត៌មានអំពីបញ្ហាសិទ្ធិមនុស្ស នៅពេលសមស្រប ។
- ☐ រៀបចំ និងរួមចំណែកក្នុងសិក្ខាសាលា សន្និសីទ កិច្ចប្រជុំ និងព្រឹត្តិការណ៍ផ្សេងទៀត

នៅតាម មណ្ឌលបោះឆ្នោតរបស់អ្នក ដើម្បីជាប្រយោជន៍ដល់សិទ្ធិមនុស្ស

☐ គាំទ្រយុទ្ធនាការសិទ្ធិមនុស្សនានា នៅតាមមូលដ្ឋាន

☐ ប្រើប្រាស់ទិវាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រារព្ធធ្វើនៅថ្ងៃទី១០ ធ្នូ ដើម្បីទាក់ទាញការចាប់អារម្មណ៍របស់សាធារណៈជន ចំពោះបញ្ហាសិទ្ធិមនុស្ស។

## ការចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ

សភា និងសមាជិកសភា អាចរួមចំណែកបានយ៉ាងធំធេងទៅលើកិច្ចប្រឹងប្រែងក្នុងកិច្ចការពារ និងការលើកកំពស់សិទ្ធិមនុស្សអន្តរជាតិ។ ដូចបានពិភាក្សាខាងលើការគោរពសិទ្ធិមនុស្ស គឺជាការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវតាមច្បាប់របស់សហគមន៍អន្តរជាតិ ក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ រដ្ឋនានាដែលជាភាគីទៅនឹងសន្ធិសញ្ញាសិទ្ធិមនុស្ស មានប្រយោជន៍ផ្លូវច្បាប់ចំពោះរដ្ឋជាភាគីដទៃទៀត ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន។ ដោយអនុលោមតាមនីតិវិធីបណ្ដឹងរវាងរដ្ឋនិងរដ្ឋ ដែលមានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ (មើលជំពូកទី ៥) រដ្ឋមួយអាចអំពាវនាវឱ្យចាត់វិធានការទៅលើរដ្ឋមួយផ្សេងទៀត ដែលរំលោភលើសន្ធិសញ្ញាណាមួយ។ សភាតាមរយៈគណៈកម្មការសិទ្ធិមនុស្សរបស់ខ្លួនអាចលើកយកបញ្ហាសិទ្ធិមនុស្សដែលអាចមានការរំលោភបំពាន និងតាមរយៈនោះ ជម្រុញឱ្យមានការប្រតិបត្តិតាមលំនាំនៃសិទ្ធិមនុស្សអន្តរជាតិ។

សភា និងសមាជិកសភា អាចគាំទ្រទៅដល់អង្គការសិទ្ធិមនុស្សអន្តរជាតិនានា តាមរយៈការធានាឱ្យមានមូលនិធិដែលអង្គការទាំងនោះត្រូវការ។ សភា និងសមាជិកសភាគួរចូលរួមយ៉ាងសកម្ម ក្នុងការងាររបស់គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និង-ការតាក់តែងលិខិតុបករណ៍សិទ្ធិ មនុស្សអន្តរជាតិថ្មីៗ ដែលទៅអនាគត ពួកគេនឹងត្រូវស្នើឱ្យផ្ដល់សច្ចាប័ន។

នៅក្នុងពិភពលោក ដែលត្រូវបានធ្វើសកលភាវូបនីយកម្ម កាន់តែខ្លាំងឡើងៗ សេចក្តីសម្រេចនានា ក្នុងកម្រិតអន្តរជាតិ មានផលប៉ះពាល់កាន់តែខ្លាំងជាងពេលណាទាំងអស់ ទៅលើនយោបាយថ្នាក់ជាតិ និងការកំណត់វិសាលភាពនៃការធ្វើសេចក្តីសម្រេច។ កាន់តែញឹកញាប់ថែមទៀត សេចក្តីសម្រេចផ្នែកសេដ្ឋកិច្ចចំបងៗ ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ត្រូវបានធ្វើឡើងនៅខាងក្រៅប្រទេសរបស់ពួកគេ ដោយស្ថាប័នអន្តរជាតិ ដែលគ្មាន គណនេយ្យភាព ប៉ុន្តែកិច្ចការនោះ មានឥទ្ធិពលទៅលើលទ្ធភាពរបស់រដ្ឋក្នុងការធានាអនុវត្តសិទ្ធិមនុស្ស ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ហេតុដូច្នេះបានជាតម្រូវឱ្យស្ថាប័នទាំងនេះ "មានប្រជាធិបតេយ្យ" ប្រសិនបើប្រទេសនីមួយៗរក្សា សមត្ថកិច្ចរបស់គេក្នុងការធានាសិទ្ធិមនុស្ស ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ដូច្នេះ សភា និងសមាជិកសភា ត្រូវចូលរួមឱ្យកាន់តែសកម្មឡើងនៅក្នុងការពិភាក្សារបស់ស្ថាប័នទាំងនេះ ដើម្បីឱ្យសម្លេងរបស់ពួកគេបានឮ។

**ប្រអប់ ៤៦**

## កិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ សិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋ

តាមការស្នើរបស់គណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស OHCHR បានចេញរបាយការណ៍ជាច្រើន ស្តីពីសិទ្ធិមនុស្ស និងពាណិជ្ជកម្ម ជាពិសេស គឺបញ្ហាសិទ្ធិមនុស្សដែលមានពាក់ព័ន្ធនៅក្នុងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ស្តីពីទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញាទាក់ទិននឹងពាណិជ្ជកម្មដែលត្រូវបានគេស្គាល់ថាជាកិច្ចព្រមព្រៀងទ្រីប(TRIPs)[២០] កិច្ចព្រមព្រៀងកសិកម្មរបស់WTO[២១] និង

[២០] E/CN.4/Sub.2/2001/13.

[២១] E/CN.4/2002/54.

កិច្ចព្រមព្រៀងទូទៅលើពាណិជ្ជកម្មផ្នែកសេវាកម្មរបស់ WTO ឬហៅថា GATs[២២] ។ របាយការណ៍បានចង្អុលបង្ហាញថា គ្រប់សមាជិករបស់ WTO បានផ្តល់សច្ចាប័នយ៉ាងហោចណាស់ លើលិខិតូបករណ៍សិទ្ធិមនុស្សចំនួនមួយ ហើយសមាជិកភាគច្រើន បានផ្តល់សច្ចាប័នទៅលើកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ CESCR ហើយប្រទេសទាំងអស់ លើកលែងតែប្រទេសមួយចេញបានផ្តល់ សច្ចាប័នទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារ CRC ។ របាយការណ៍ទាំងនោះថែមទាំងបញ្ជាក់ថា ដូច្នេះ សមាជិករបស់ WTO គួរធានាថា វិធានអន្តរជាតិស្តីពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម មិនផ្ទុយទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន នៅក្រោមសន្ធិសញ្ញាទាំងនោះ ។ ដូច្នេះ ច្បាប់ពាណិជ្ជកម្ម និងគោលនយោបាយពាណិជ្ជកម្ម គួរមិនត្រឹមតែផ្តោតទៅលើកំណើនសេដ្ឋកិច្ចទីផ្សារ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប៉ុណ្ណោះទេ ត្រូវផ្តោតសំខាន់លើប្រព័ន្ធសុខាភិបាល ការអប់រំ ការផ្គត់ផ្គង់ទឹកស្អាត សន្តិសុខស្បៀង ការងារ និងដំណើរការនយោបាយ ។ល។" រដ្ឋមានភារកិច្ចធានាថា ការបាត់បង់ស្វ័យភាពរបស់ពួកគេ នៅពេលចូលទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា " មិនបន្ថយសមត្ថភាពពួកគេ ដោយវិសមាមាត្រក្នុងការកំណត់ និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិទេ "។ កិច្ចការទាំងនេះ ទាមទារឱ្យមាន "ការពិនិត្យមើលជាប្រចាំទៅលើច្បាប់ពាណិជ្ជកម្ម និងគោលនយោបាយពាណិជ្ជកម្ម ព្រោះវាមានការប៉ះពាល់ទៅដល់ការប្រើប្រាស់សិទ្ធិមនុស្ស ។ ការវាយតម្លៃលើសក្តានុពលនៃផលប៉ះពាល់ និងផលប៉ះពាល់ពិតប្រាកដរបស់គោលនយោបាយពាណិជ្ជកម្ម និងច្បាប់ពាណិជ្ជកម្ម ទៅលើការប្រើប្រាស់សិទ្ធិមនុស្ស គឺប្រហែលជាមធ្យោបាយ ដ៏ចំបងក្នុងការជៀសវាងពីការអនុវត្តវិធានការដើរថយក្រោយ ដែលកាត់បន្ថយនូវការទទួលបានសិទ្ធិមនុស្ស" ។[២៣]

[២២] E/CN.4/Sub.2/2002/9.

[២៣] E/CN.4/Sub.2/2002/9, paragraphs 7, 9 and 12

នៅក្នុងករណីស្រដៀងគ្នានេះដែរ សេចក្ដីពន្យល់រួមលេខ១៤ របស់CESCR អំពីសិទ្ធិទទួលបានសេវាសុខភាព ចែងថា រដ្ឋភាគីគួរធានាថា សិទ្ធិទទួលបានសេវាសុខភាពត្រូវបានយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ នៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ហើយត្រូវចាត់វិធានការ ដើម្បីធានាថា លិខិតុបករណ៍ទាំងនេះ មិនមានផលអាក្រក់ទៅលើសិទ្ធិទទួលបានសេវាសុខាភិបាលឡើយ។ ស្រដៀងគ្នានេះដែរ រដ្ឋភាគីមានកាតព្វកិច្ច ធានាថា វិធានការរបស់ពួកគេ ក្នុងឋានៈជាសមាជិករបស់អង្គការអន្តរជាតិ ត្រូវតែយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ ទៅលើសិទ្ធិទទួលបានសេវាសុខាភិបាល...” (កថាខ័ណ្ឌទី ៣៩)។

ក្នុងបរិបទនេះ IPU បានប្រតិបត្តិដំណើរការជួយនាំសភាឱ្យបានទៅជិតស្ថាប័ននានា ដូចជាអង្គការពាណិជ្ជកម្មពិភពលោក (WTO) ជាដើម។

*សន្និសីទអន្តរសភាលើកទី១០៧ “អំពាវនាវទៅដល់សភាទាំងឡាយឱ្យដើរតួនាទីដ៏សកម្ម នៅក្នុងការតាមឃ្លាំមើលលើសេចក្ដីសម្រេច និងសកម្មភាពនានា ដែលធ្វើឡើងដោយស្ថាប័នពហុជាតិទាំងឡាយ ជាពិសេស ស្ថាប័នដែលធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍របស់ប្រទេសនានា ក្នុងការនាំយកស្ថាប័នពហុជាតិដែលទាក់ទិនទៅនឹងពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ឱ្យទៅជិតប្រជាពលរដ្ឋដែលពួកគេត្រូវផ្ដល់សេវាជូន និងក្នុងការធ្វើឱ្យស្ថាប័នពហុជាតិទាំងនោះ មានប្រជាធិប្បតេយ្យ មានតម្លាភាព និងមានសមធម៌”*

*សេចក្ដីសម្រេចស្ដីពី “តួនាទីរបស់សភាក្នុងការអភិវឌ្ឍគោលនយោបាយសាធារណៈ នៅក្នុងយុគសម័យសកលភាវូបនីយកម្ម ស្ថាប័នពហុជាតិ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ” ទីក្រុងម៉ារ៉ាកេស ខែមីនា ឆ្នាំ២០០២ កថាខ័ណ្ឌ ៩។*

## តើអ្នកអាចធ្វើអ្វីបានខ្លះក្នុងឋានៈអ្នកជាសមាជិកសភា

សភា និងសមាជិកសភា គួររួមចំណែកដល់ការលើកកំពស់ និងកិច្ចការពារសិទ្ធិមនុស្ស នៅកម្រិតអន្តរជាតិ និងធ្វើឱ្យសំឡេងរបស់ពួកគេបានឮ។ ដើម្បីសម្រេចបានគោលបំណងនេះ អ្នកត្រូវ៖

☐ បង្កើតទំនាក់ទំនងជាមួយសមាជិកសភា នៅក្នុងប្រទេសផ្សេងៗទៀត ដើម្បី

(ក) ចែករំលែកបទពិសោធន៍ កិច្ចការដែលបានជោគជ័យ និងមេរៀនដែលទទួលបាន

(ខ) ពិភាក្សារកលទ្ធភាព ដើម្បីធ្វើកិច្ចសហការទ្វេភាគី ឬពហុភាគី ជាពិសេស បញ្ហារំលោភសិទ្ធិមនុស្ស ដែលតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការឆ្លងដែន (ដូចជា បញ្ហាជួញដូរមនុស្ស អន្តោរប្រវេសន៍ និងសុខភាព)

☐ ធានាថា សភារបស់អ្នកចូលរួម (តាមរយៈគណៈកម្មាធិការមានសមត្ថកិច្ច) ក្នុងការងាររបស់គណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ ឬយ៉ាងហោចណាស់ សភាត្រូវទទួលបានដំណឹងអំពីរាល់គោលជំហររបស់រដ្ឋាភិបាលរបស់អ្នកលើករណីផ្សេងៗដែលត្រូវបានពិភាក្សានៅក្នុងគណៈកម្មការ។ នៅពេលសមស្របអ្នកអាចដាក់សំណួរទៅកាន់រដ្ឋាភិបាលរបស់អ្នកពាក់ព័ន្ធទៅនឹងមូលដ្ឋាននៃគោលជំហរគេ។

☐ ធានាថា សភារបស់អ្នក ត្រូវបានគេជូនដំណឹងអំពីការចរចារដែលកំពុងតែកើតមានឡើងស្ដីពីសន្ធិសញ្ញាសិទ្ធិមនុស្សថ្មីៗ ហើយធានាថា សភា មានឱកាសរួមចំណែកក្នុងកិច្ចចរចារនោះ

☐ ធានាថា សភារបស់អ្នក (តាមរយៈគណៈកម្មាធិការមានសមត្ថកិច្ច) ទាក់ទាញការយកចិត្តទុកដាក់ទៅលើការរំលោភសន្ធិសញ្ញាសិទ្ធិមនុស្សនៅប្រទេសផ្សេងៗទៀត ក្នុងពេល

សមស្រប ជម្រុញរដ្ឋាភិបាលរបស់អ្នកឱ្យដាក់ពាក្យបណ្ដឹងអន្តររដ្ឋមួយ (មើលផ្នែកទី I ជំពូកទី ៥) ។

☐ ចូលរួមក្នុងបេសកកម្មឃ្លាំមើលការបោះឆ្នោត និងបេសកកម្មសិទ្ធិមនុស្សអន្តរជាតិដទៃទៀត

☐ ធានាថា សភារបស់អ្នកត្រូវបានគេជូនដំណឹងអំពីការចរចាអន្តរជាតិនានាដែលលទ្ធផលរបស់វាអាចមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលទ្ធភាពរបស់ប្រទេសអ្នកក្នុងការប្រតិបត្តិតាមកាតព្វកិច្ចសិទ្ធិមនុស្ស នៅពេលសមស្របដាក់សំណួរទៅកាន់រដ្ឋាភិបាលអ្នក ពីគោលជំហររបស់រដ្ឋាភិបាល ក្នុងការរក្សាការពារការគោរពតាមកាតព្វកិច្ចនោះ តាមរបៀបណា។

# ជំពូកទី ១២
# អ្វីដែលសមាជិកសភាគួរយល់ដឹងអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែល-មាននៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)

## សិទ្ធិរស់រានមានជីវិត

មាត្រា៣ នៃ UDHR

*" មនុស្សគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន"*

មាត្រា ៦ (១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ICCPR

*" ជនគ្រប់រូបមានសិទ្ធិមានជីវិតជាប់ពីកំណើត ។ សិទ្ធិនេះ ត្រូវការពារដោយច្បាប់ ។ គ្មានជនណាម្នាក់ត្រូវគេប្រហារជីវិតតាមអំពើចិត្តបានឡើយ"*

សិទ្ធិរស់រានមានជីវិត គឺជាសិទ្ធិមនុស្សមូលដ្ឋានសំខាន់ជាងគេ ហើយមិនអាចត្រូវបានដកហូតបានទេ បើទោះបីជាក្នុងពេលមានសង្គ្រាម ឬក៏នៅគ្រាមានភាពអាសន្នក៏ដោយ។ ទោះជាយ៉ាងនេះក៏ដោយ មិនដូចគ្នាទៅនឹងការហាមប្រាមការធ្វើទារុណកម្ម ឬទាសកម្មទេ សិទ្ធិរស់រានមានជីវិត មិនមែនជាសិទ្ធិដាច់ខាតមួយទេ។ ការស្លាប់របស់អ្នកប្រយុទ្ធម្នាក់ដែលជាលទ្ធផលនៃ "សកម្មភាពសង្គ្រាមស្របច្បាប់ " ដែលស្ថិតនៅក្នុងរង្វង់នៃអត្ថន័យរបស់ច្បាប់មនុស្សធម៌អន្តរជាតិ មិនបង្កើតឱ្យមានការរំលោភទៅលើសិទ្ធិរស់រានមានជីវិតទេ។ ស្រដៀងគ្នានេះផងដែរ ប្រសិនបើភ្នាក់ងារអនុវត្តច្បាប់បានផ្តាច់ជីវិតបុគ្គលម្នាក់

សកម្មភាពនេះអាចមិនមែនជាការរំលោភទៅលើសិទ្ធិរស់រានមានជីវិតនេះក៏ទេដែរ។ ខ. ប្រសិនបើការស្លាប់នោះ មកពីការប្រើប្រាស់កម្លាំង ដែលពិតជាចាំបាច់សម្រាប់គោលបំណងស្របច្បាប់ក្នុងការការពារខ្លួន ឬដើម្បីការពារជនទីបីណាម្នាក់ ឬកើតពីការចាប់ខ្លួនដោយស្របច្បាប់ ឬពីវិធានការនានាដែលធ្វើឡើង ដើម្បីទប់ស្កាត់ការរត់គេចខ្លួនរបស់ជនមួយដែលត្រូវឃុំខ្លួនតាមច្បាប់ ឬក៏ដើម្បីបង្ក្រាបទៅលើកុប្បកម្ម ឬការបះបោរមួយ។ ភាពចាំបាច់ដ៏ច្បាស់លាស់បែបនេះ អាចត្រូវបានកំណត់ដោយតុលាការមានសមត្ថកិច្ចប៉ុណ្ណោះ ដោយផ្អែកលើករណីនីមួយៗ ដោយពិចារណាទៅលើគោលការណ៍សមាមាត្រហើយជាជម្រើសចុងក្រោយដោយត្រូវពិចារណាដោយស្ថាប័នសន្និសញ្ញា។ បន្ថែមពីលើនេះ សិទ្ធិរស់រានមានជីវិតមិនអាចត្រូវបានគិតថា ត្រូវតែមាននោះទេ នៅក្នុងប្រព័ន្ធច្បាប់ណាដែលអនុញ្ញាតឱ្យមានទោសប្រហារជីវិត (សូមមើលខាងក្រោម)។

**ប្រអប់ ៤៧**

## សិទ្ធិរស់រានមានជីវិត និងយុត្តិសាស្ត្រពហុប្រទេស

នៅឆ្នាំ១៩៩៥ ការបើកសវនាការនៃរឿងក្តីរបស់លោក *McCann និងអ្នកផ្សេងទៀតប្រឆាំងទៅនឹងចក្រភពអង់គ្លេស* តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុបបានរកឃើញថា ប្រតិបត្តិការយោធាដែលក្នុងនោះមានជនសង្ស័យជាភេរវករចំនួនបីរូប ដែលទាហានរបស់ចក្រភពអង់គ្លេសអះអាងថា ពួកគេព្យាយាមធ្វើការចាប់ខ្លួន ហើយត្រូវបានគេបាញ់សម្លាប់នោះពុំបានរៀបចំផែនការឱ្យបានត្រឹមត្រូវ ហើយដូច្នេះវាជាការរំលោភទៅលើសិទ្ធិរស់រានមានជីវិត។

នៅក្នុងករណីជាច្រើន តុលាការអឺរ៉ុប និងតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង និងគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានចេញសេចក្តីសម្រេចថា តាមនិយមន័យការសម្លាប់ មិនតាមនីតិវិធី និងដោយទំនើងចិត្ត គឺជាការរំលោភបំពានទៅលើសិទ្ធិរស់រានមានជីវិត។

បន្ថែមពីលើនេះ តាំងពីមានសាលក្រមប្រវត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិក នៅឆ្នាំ១៩៨៨ ទៅលើរឿងរបស់ *Velasquez Rodriguez ប្រឆាំងទៅនឹងប្រទេសហុងឌុយរ៉ាស់* មក វាក៏បានកំណត់ថា ការអនុវត្តឱ្យមានការបាត់ខ្លួនដោយបង្ខំ បង្កើតបានជាការរំលោភទៅលើសិទ្ធិរស់រានមានជីវិត ឬក៏យ៉ាងហោចណាស់ ជាការគំរាមកំហែងធ្ងន់ធ្ងរមួយទៅលើសិទ្ធិរស់រានមានជីវិត ។

## សិទ្ធិរស់រានមានជីវិត និងកាតព្វកិច្ចរបស់រដ្ឋ

ដូចគ្នាទៅនឹងសិទ្ធិមនុស្សផ្សេងទៀតដែរ សិទ្ធិរស់រានមានជីវិត មិនគ្រាន់តែការពារបុគ្គលទល់ទៅនឹងការជ្រៀតជ្រែកដោយបំពាន ដោយភ្នាក់ងាររដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងដាក់កាតព្វកិច្ចឱ្យរដ្ឋចាត់វិធានការវិជ្ជមាន ដើម្បីផ្តល់ការការពារពីការសម្លាប់ដោយបំពាន ការបាត់ខ្លួនដោយបង្ខំ និងសកម្មភាពហឹង្សាស្រដៀងគ្នានេះ ដែលធ្វើឡើងដោយកងកម្លាំងយោធា ឧក្រិដ្ឋកម្មដែលមានការចាត់តាំង ឬពីបុគ្គលឯកជនណាមួយ ។ ដូច្នោះហើយ រដ្ឋត្រូវតែដាក់សកម្មភាពរបៀប នោះថាជាបទឧក្រិដ្ឋក្រៅច្បាប់ ហើយត្រូវតែអនុវត្តច្បាប់ឱ្យបានសមរម្យ ។

**ប្រអប់ ៤៨**

### ករណីរបស់ Osman ប្រឆាំងនឹងចក្រភពអង់គ្លេស ( ឆ្នាំ១៩៩៨)

តុលាការសិទ្ធិមនុស្សអឺរ៉ុបបានបើកសវនាការទៅលើការទាមទារមួយ ដែលប្តឹងដោយសាច់ញាតិរបស់ **Ahmed Osman** ដែលត្រូវបានបាញ់សម្លាប់ដោយគ្រូបង្រៀនរបស់កូនគាត់ ដោយចោទថាមានការរំលោភលើសិទ្ធិរស់រានមានជីវិតរបស់បុរសនោះ ។ តុលាការបានពិចារណាថា លក្ខខណ្ឌពីរខាងក្រោម ដែលត្រូវតែមាន ដើម្បីធ្វើជាបន្ទុកសម្រាប់ការចោទប្រកាន់ដែលផ្អែកលើមូលដ្ឋានដែលថា អាជ្ញាធរបានរំលោភទៅលើ

កាតព្វកិច្ចវិជ្ជមាន ក្នុងការការពារសិទ្ធិរស់រាន មានជីវិតរបស់ជនរងគ្រោះ ដោយខកខានក្នុងការចាត់វិធានការនានា ដើម្បីការពារបុគ្គលម្នាក់ ដែលជីវិតរបស់គេ ស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ដោយសកម្មភាពឧក្រិដ្ឋកម្មរបស់ជនមួយទៀត :

(ក) អាជ្ញាធរបានដឹង ឬត្រូវបានដឹងជាមុនថា វាមានហានិភ័យពិតប្រាកដ និងជាបន្ទាន់ ទៅលើជីវិតរបស់ជនរងគ្រោះ ពីសកម្មភាពឧក្រិដ្ឋកម្មរបស់ជនទីបី និង

(ខ) អាជ្ញាធរបានខកខានក្នុងការចាត់វិធានការដែលស្ថិតក្នុងវង្វង់នៃអំណាចរបស់ខ្លួន ហើយអាចត្រូវបានរំពឹងទុកដោយសមហេតុផលថា អាជ្ញាធរអាចបញ្ចៀសហានិភ័យនោះបាន ។

តុលាការបានរកឃើញថានៅក្នុងករណីនេះពុំមានការរំលោភបំពានទៅលើសិទ្ធិរស់រានមានជីវិតទេ ដោយសារថា អ្នកប្តឹងពុំបានបង្ហាញថា ប៉ូលីសបានដឹង ឬត្រូវបានដឹងថា ជីវិតរបស់គ្រួសារ **Osman** ស្ថិតនៅក្នុងគ្រោះថ្នាក់ដោយពិតប្រាកដ និងជាបន្ទាន់ពីគ្រូបង្រៀននោះទេ ឬថាវិធានការនានាដែលប៉ូលីសអាចធ្វើបាន នឹងមុខជាមានលទ្ធផលពិតប្រាកដនោះក៏ទេដែរ ។

ស្របគ្នានេះ រដ្ឋមានករណីយកិច្ច ក្នុងការធានាថា:

- ការវាយប្រហារសម្លាប់ទៅលើបុគ្គលម្នាក់ដោយបុគ្គលម្នាក់ទៀត គឺជាបទល្មើសមួយដែលមានទោស សមល្មម នៅក្រោមច្បាប់ព្រហ្មទណ្ឌក្នុងស្រុក
- បទឧក្រិដ្ឋហឹង្សាណាមួយ ត្រូវតែធ្វើការស៊ើបអង្កេតដោយល្អិតល្អន់ ដើម្បីកំណត់រកអ្នកប្រព្រឹត្តល្មើស និងនាំពួកគេ មកកាត់ទោសតាមច្បាប់
- វិធានការនានា ត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់ និងដាក់ទោសទណ្ឌទៅលើការសម្លាប់ ដោយបំពាន ដោយមន្ត្រីអនុវត្តច្បាប់
- នីតិវិធីមានប្រសិទ្ធភាពនានា ត្រូវបានចែងដោយច្បាប់ ដើម្បីធ្វើការស៊ើបអង្កេតករណីនានារបស់បុគ្គល ដែលត្រូវរងនូវការបាត់ខ្លួនដោយបង្ខំមួយ

គណៈកម្មាធិការសិទ្ធិមនុស្ស បានកំណត់ថា រដ្ឋនានា តែងតែបកស្រាយសិទ្ធិរស់រាន មានជីវិត ដោយចង្អៀតពេក ហើយថា កាតព្វកិច្ចរបស់រដ្ឋទាំងនោះក្នុងការការពារ និងបំពេញសិទ្ធិ នោះមានទំហំទូលាយជាង ដោយចាត់ទុកជាបទឧក្រិដ្ឋតែទៅលើការធ្វើឃាត ការលបសម្លាប់ និងការវាយប្រហារដល់ជីវិតប៉ុណ្ណោះ។ នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ៦ គណៈកម្មាធិការបានបញ្ជាក់ ថា រដ្ឋនានា គួរ "ចាត់វិធានការដែលមានទាំងអស់ ដើម្បីកាត់បន្ថយការស្លាប់របស់កូនក្មេង និងដើម្បីបង្កើនអាយុរបស់មនុស្ស ជាពិសេស ក្នុងការជ្រើសយកវិធានការនានា ដើម្បីបំបាត់ ចោលនូវភាពខ្វះជីវជាតិ និងជំងឺរាតត្បាត " ដែលបង្កប់ន័យថា រដ្ឋមានភារកិច្ច ដើម្បីចាត់ វិធានការដែលមានទាំងអស់ក្នុងការធានានូវស្តង់ដារស់នៅសមរម្យ ហើយថារដ្ឋមាន" តួនាទីជាចំបង ដើម្បីទប់ស្កាត់កុំឱ្យមានសង្គ្រាម សកម្មភាពឧក្រិដ្ឋ និងសកម្មភាពផ្សេងទៀត នៃអំពើហឹង្សាសំលាប់រង្គាល ដែលបណ្តាលឱ្យមានការបាត់បង់ជីវិតដោយបំពាន"។

ស្រដៀងគ្នានេះដែរ សមាជិកសភា អាចចូលរួមចំណែកបាន ទៅដល់ការធ្វើឱ្យសិទ្ធិរស់រាន មានជីវិតក្លាយជាការពិត ដោយធានាថាៈ

- វិធានការនានា ត្រូវបានធ្វើឡើង ដើម្បីធ្វើឱ្យមានភាពប្រសើរឡើង ទាក់ទិនទៅនឹង សិទ្ធិទទួលបានចំណីអាហារ សុខភាព សន្តិភាព និងស្តង់ដារស់នៅបានសមរម្យ ដែល សិទ្ធិទាំងអស់នេះ ចូលរួមចំណែកដល់ការការពារសិទ្ធិរស់រានមានជីវិត។
- រដ្ឋាភិបាល ជ្រើសយក និងអនុវត្តគោលនយោបាយនានា ដើម្បីផ្តល់ឱ្យបុគ្គលិកនានា ដូចជាមន្ត្រីប៉ូលីស និងសន្តិសុខពន្ធនាគារនូវការបណ្តុះបណ្តាល ដើម្បីកាត់បន្ថយភាព ដែលអាចកើតមានការរំលោភលើសិទ្ធិរស់រានមានជីវិត
- វិធានការនានា ត្រូវធ្វើឡើងដើម្បីកាត់បន្ថយការស្លាប់របស់ក្មេង និងដើម្បីបង្កើន អាយុរបស់មនុស្ស ជាពិសេស ដើម្បីបំបាត់ចោលនូវភាពខ្វះជីវជាតិ និងជំងឺរាតត្បាត។

## បញ្ហាចម្រូងចម្រាស ដែលទាក់ទិនទៅនឹងសិទ្ធិរស់រានមានជីវិត

### *ទោសប្រហារជីវិត*

បញ្ហានៃទោសប្រហារជីវិត គឺជាបញ្ហាស្នូល នៅក្នុងសិទ្ធិរស់រានមានជីវិត។ ប្រវត្តិសាស្ត្រច្បាប់នៃបញ្ហានេះ និងការពិភាក្សាដែលពាក់ព័ន្ធនានា មានចំណុចស្រដៀងគ្នាជាច្រើនទៅនឹងប្រវត្តិសាស្ត្រ និងការពិភាក្សាទៅលើការអនុវត្តពីរផ្សេងគ្នា : ទាសភាព និងការធ្វើទារុណកម្ម។ ទាសភាព ដែលបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងពិភពលោក នៅពេញប្រវត្តិសាស្ត្រ ត្រូវបានបំបាត់ចោលដោយច្បាប់ នៅក្នុងសតវត្សទី១៩ ហើយការធ្វើទារុណកម្ម ត្រូវបានគេទទួលយកជាប្រចាំថា ជាផ្នែកមួយនៃនីតិវិធីព្រហ្មទណ្ឌរហូតដល់សម័យរុងរឿងនេះ។ ខណៈពេលដែលការអនុវត្តទាំងពីរ ត្រូវបានហាមឃាត់យ៉ាងដាច់ខាត នាពេលឥឡូវនេះ នៅក្រោមច្បាប់ប្រពៃណី និងច្បាប់អន្តរជាតិ ដែលមានមូលដ្ឋានលើសន្ធិសញ្ញានោះ ការលុបបំបាត់ចោលឱ្យអស់តែម្តង នូវទោសប្រហារជីវិត នៅមានការយឺតយ៉ាវនៅឡើយ។

នៅឆ្នាំ១៩៨៤ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ បានអនុម័ត ហើយមហាសន្និបាតអង្គការសហប្រជាជាតិបានគាំទ្រឱ្យមានវនាំងការពារ[២៤] ដែលធានានូវការការពារសិទ្ធិមនុស្ស ទៅដល់អ្នកទាំងឡាយដែលប្រឈមមុខនឹងទោសប្រហារជីវិត (ពេលខ្លះត្រូវបានហៅថាជា "វនាំងការពារ ECOSOC")។ ទោះបីជាវនាំងការពារទាំងនេះ ដែលភាគច្រើនបង្ហាញឱ្យឃើញពីបញ្ញត្តិរបស់ CCPR ជាស្តង់ដាអប្បបរិមាក៏ដោយ ក៏វានៅតែត្រូវបានគេរំលោភបំពានលើដែរ។ មាន ការពិចារណាសមហេតុផលខ្លះ ត្រូវបានគូសបញ្ជាក់ខាងក្រោម។

[២៤] សេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៣៩/១១៨ ថ្ងៃទី ១៤ ធ្នូ ឆ្នាំ ១៩៨៤

ប្រអប់ ៤៩

**ទឡ្ហីករណ៍ និង បដិទឡ្ហីករណ៍ជុំវិញបញ្ហាទោសប្រហារជីវិត**

| ទឡ្ហីករណ៍ និងយុត្តិកម្មសំរាប់ឱ្យមានទោសប្រហារជីវិត | បដិទឡ្ហីករណ៍ |
|---|---|
| ការកម្លា | អនុភាពកម្លានៃទោសប្រហារជីវិតមិនមានភស្តុតាងគាំទ្រទេ |
| ការសងសឹក និងយុត្តិធ-មិសម្រាប់ជនរងគ្រោះ | ស្តង់ដាយុត្តិធមិបែបទំនើប ចង់ឱ្យមានការកសាងខ្លួនឡើងវិញ និងបញ្ចូលជនល្មើសចូលទៅក្នុងសង្គមវិញ |
| ការកម្រិតព្រំដែននៃការប្តឹងឧទ្ធរណ៍ និងកំណែទម្រង់ប្រព័ន្ធច្បាប់ ដែលតម្រូវឱ្យមានដីកានាំខ្លួនជនសង្ស័យ មកកាន់តុលាការដើម្បីពិនិត្យនីត្យានុកូលភាពនៃការឃុំខ្លួន (habeas corpus) | ការធ្វើបែបនេះ គឺបង្កើនហានិភ័យនៃភាពខុសឆ្គងនៃការវិនិច្ឆ័យ និងការសម្លាប់ជនទាំងឡាយដែលគ្មានទោស |
| ច្បាប់អន្តរជាតិ បើកឱ្យមានសិទ្ធិរស់រានមានជីវិត | នេះនឹងឱ្យមានទម្រង់ទណ្ឌកម្មមួយ ដែលឃោរឃៅអមនុស្សធមិ និងបន្ថោកបន្ទាប។ |

ប្រភេទនៃអ្នកប្រព្រឹត្តល្មើសជាក់លាក់នានា ត្រូវឬគួរត្រូវតែលើកលែងពីទោសប្រហារជីវិត។ អ្នកទាំងនោះមាន៖

- *អនីតិជន* : CCPR និងCRC ចែងយ៉ាងច្បាស់ថា បុគ្គលក្រោមអាយុ១៨ឆ្នាំ នៅពេលដែលគាត់ប្រព្រឹត្តបទល្មើស មិនគួរត្រូវបានគេកាត់ទោសប្រហារជីវិតទេ។ ក្បួនវិន័យនេះ បានក្លាយជាផ្នែកមួយនៃច្បាប់អន្តរជាតិទៅហើយ។

- *ជនចាស់ជរា*: ទាំងCCPR ទាំងរនាំងការពារ មិនបានផ្តល់ការលើកលែងរបៀបនេះទេ បើទោះបីជា នៅក្នុងឆ្នាំ១៩៨៨ គណៈកម្មាធិការទទួលបន្ទុកទប់ស្កាត់ និងត្រួតពិនិត្យឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិ បានឱ្យអនុសាសន៍ទៅដល់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមថា រដ្ឋជាសមាជិកនានា គួរត្រូវបានប្រឹក្សាយោបល់ ឱ្យបង្កើតឱ្យមានអាយុអតិបរមាសម្រាប់កាត់ទោស ឬប្រហារជីវិត។ មាត្រា៤(៥) នៃ ACHR ចែងថា ទោសប្រហារជីវិត មិនត្រូវអនុវត្តទៅលើជនទាំងឡាយណា ដែលមានអាយុលើសពី ៧០ឆ្នាំ នៅពេលឧក្រិដ្ឋកម្ម ត្រូវបានធ្វើឡើងនោះឡើយ។
- *ស្ត្រីមានផ្ទៃពោះ* : រនាំងការពារ បានរារាំងកុំឱ្យមានការប្រហារជីវិត ទៅលើស្ត្រីមានផ្ទៃពោះ ធ្វើដូច្នោះដើម្បីការពារទារកដែលមិនទាន់ប្រសូត្រ (ដោយស្របជាមួយមាត្រា ៦ នៃ CCPR)។
- *បុគ្គលដែលមានវិបត្តិផ្លូវចិត្ត*: គោលការណ៍ដែលថា បុគ្គលដែលមានចិត្តអារម្មណ៍មិនល្អ មិនគួរត្រូវបានគេកាត់ទោស និងប្រហារជីវិតទេនោះ ត្រូវបានបញ្ចូលទៅក្នុងរនាំងការពារ ដែលធានាការការពារសិទ្ធិ អ្នកដែលប្រឈមមុខនឹងទោសប្រហារជីវិត។ គោលការណ៍នេះ មិនមានចែងនៅក្នុង CCPR និងសន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់នានាទេ។

បន្ថែមលើនេះ ច្បាប់អន្តរជាតិ បានផ្តល់នូវលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនានា ដែលអាចអនុវត្តបានចំពោះករណីប្រហារជីវិតទាំងអស់ : ការធានាឱ្យមានការកាត់ទោសដោយត្រឹមត្រូវ ដោយផ្តល់លទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍ទៅកាន់តុលាការជាន់ខ្ពស់ និងការអនុគ្រោះទោស។ នៅក្រោមមាត្រា៦(៤) នៃ CCPR ការលើកលែងទោសជាសាធារណៈ ការលើកលែងទោស ឬការសម្រាលទោសដល់ទោសប្រហារជីវិត អាចត្រូវផ្តល់ឱ្យបាននៅគ្រប់ពេលទាំងអស់។ ជាឧទាហរណ៍ ការអនុគ្រោះទោសអាចពន្យារ ឬព្យួរការប្រហារជីវិតដោយសម្រាលទោសមកនៅត្រឹមជាប់ពន្ធនាគារមួយជីវិតវិញ ហើយអាចត្រូវបានគេប្រើប្រាស់ ដើម្បីសង

ជួសនូវកំហុសនានា ដើម្បីបន្ថយការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ឬដើម្បីទូទាត់គ្នានឹងបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ដែលមិនអនុញ្ញាតិឱ្យមានការពិចារណាលើកត្តាផ្សេងៗទៀត។ សិទ្ធិពិរុទ្ធជនដែលត្រូវប្រហារជីវិតក្នុងការស្វែងរកការបន្ធូរបន្ថយទោស ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

នៅកន្លែងណាដែលមិនទាន់បានលុបចោលទោសប្រហារជីវិតគួរបង្កើតឱ្យមានការដាក់ទោសទណ្ឌជាពិសេស ដែលជានិច្ចកាលតែងតែធ្វើស្របជាមួយគោលការណ៍សមាមាត្រ។ មាត្រា៦នៃCCPR សំដៅលើ "ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត" និងនៅក្រោមរនាំងការពារ និយមន័យរបស់ "ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត " ដែលអាចដាក់ទោសទណ្ឌដល់ស្លាប់គឺ "មិនគួរឱ្យហួសពីបទល្មើសដោយចេតនា ដោយមានផលវិបាកជាការប្រល័យជីវិត ឬផលវិបាកធ្ងន់ធ្ងរជាទីបំផុតដទៃទៀត "នោះទេ។ ការដាក់កំហិតរបៀបនេះគឺស្របទៅតាមគោលបំណងដែលចង់ឱ្យមានការលុបចោលទាំងស្រុងនូវទោសប្រហារជីវិត។ ដូចដែលមហាសន្និបាតអង្គការសហប្រជាជាតិបានបញ្ជាក់នៅក្នុងឆ្នាំ១៩៧១ សិទ្ធិរស់រានមានជីវិត អាចត្រូវបានធានាពេញលេញបាន ដរាបណាចំនួនបទល្មើសដែលមានទោសទណ្ឌដល់ប្រហារជីវិតអាចត្រូវបានដាក់កំហិតបន្តិចម្តងៗ "ដោយមានទស្សនៈចង់ឱ្យមានការលុបចោលទាំងស្រុងនៅគ្រប់ប្រទេស ទាំងអស់"។[២៥]

## *ចលនាឆ្ពោះទៅរកការលុបចោលទោសប្រហារជីវិត*

នៅពេលចុងបញ្ចប់នៃសង្គ្រាមលោកលើកទី២ នៅពេលដែលស្តង់ដាសិទ្ធិមនុស្សអន្តរជាតិកំពុងត្រូវបានតាក់តែងឡើង ទោសប្រហារជីវិតនៅតែត្រូវបានគេអនុវត្តនៅតាមរដ្ឋជាច្រើន។ ជាបន្តបន្ទាប់ក្រោយមក មាត្រា២ នៃ ECHR មាត្រា៦ នៃ CCPR និងមាត្រា៤ នៃ ACHR ផ្តល់ឱ្យមានការលើកលែងមួយទៅលើគោលការណ៍នៃសិទ្ធិរស់រានមានជីវិតនៅក្នុង

[២៥] សេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ២៨៥៧ (XXVI) ថ្ងៃទី២០ ធ្នូ ឆ្នាំ១៩៧១។

ករណីនៃទោសប្រហារជីវិត។ ទោះជាយ៉ាងនេះក៏ដោយ តាំងពីពេលនោះមក និន្នាការដ៏ច្បាស់លាស់មួយសម្រាប់លុបចោល និងហាមប្រាមការកាត់ទោសប្រហារជីវិតបានកើតមានឡើងភាគច្រើននៅបណ្ដាប្រទេសអឺរ៉ុប និងអាមេរិក ឡាទីន។

## *ការលុបទោសប្រហារជីវិតនៅអឺរ៉ុប*

ពិធីសារបន្ថែមទី៦ទៅលើ ECHR បានអនុម័តនៅក្នុងឆ្នាំ១៩៨៣ ហើយត្រូវបានផ្ដល់សច្ចាប័នដោយរដ្ឋទាំងអស់នៃក្រុមប្រឹក្សាអឺរ៉ុប លើកលែងតែប្រទេសម៉ូណាកូ និងសហព័ន្ធរុស្ស៊ី បានហាមប្រាមការដាក់ទោសប្រហារជីវិត នៅក្នុងពេលមានសន្តិភាព ហើយពិធីសារបន្ថែមទី១៣ ទៅលើអនុសញ្ញាអឺរ៉ុប ដែលបានអនុម័តនៅក្នុងឆ្នាំ២០០២ បានចែងអំពីការហាមប្រាមការដាក់ទោសប្រហារជីវិតជាដាច់ខាតនៅអឺរ៉ុប (ទោះបីជាក្នុងពេលមានសង្គ្រាមក៏ដោយ)។ ចាប់តាំងពីការលុបចោលទោសប្រហារជីវិត ត្រូវបានអនុម័តជាផ្នែកមួយ ដែលមិនអាចផ្ដាច់ចេញបានរបស់សហភាពអឺរ៉ុប និងគោលនយោបាយរបស់ក្រុមប្រឹក្សាអឺរ៉ុបមក (ហើយក៏ជាលក្ខខណ្ឌតម្រូវមួយសម្រាប់ការចូលជាសមាជិកសំរាប់រដ្ឋសមាជិកថ្មី។) អឺរ៉ុបអាចត្រូវបានគេចាត់ទុកថាជាតំបន់គ្មានទោសប្រហារជីវិត នាពេលបច្ចុប្បន្ននេះ។

## *កិច្ចប្រឹងប្រែងដើម្បីលុបចោលទោសប្រហារជីវិត នៅទ្វីបអាមេរិក និងនៅជុំវិញពិភពលោក*

ការអភិវឌ្ឍន៍ស្រដៀងគ្នាមួយ ត្រូវបានគេឃើញកើតមាននៅតាមបណ្ដារដ្ឋនៃទ្វីបអាមេរិក និងជាកម្រិតថ្នាក់ពិភពលោក។ នៅក្នុងឆ្នាំ១៩៩០ អង្គការសម្រាប់រដ្ឋនៅអាមេរិក (OAS) បានអនុម័តពិធីសារមួយ ទៅលើអនុសញ្ញាអាមេរិក សម្រាប់សិទ្ធិមនុស្សដោយលុបចោលទោសប្រហារជីវិត ក៏ប៉ុន្តែរហូតមកដល់ពេលនេះមានប្រទេសតែ៨ ប៉ុណ្ណោះ (ប្រេស៊ីល កូស្តារីការ អេក្វាទ័រ នីការ៉ាហ្គ័រ ប៉ាណាម៉ា ប៉ារ៉ាហ្គាយ អ៊ុយរ៉ាហ្គាយ និង វេណេហ្ស៊ុយអេឡា) ដែលបានផ្ដល់សច្ចាប័នទៅលើពិធីសារនោះ។ ស្រដៀងគ្នានេះដែរ ពិធី

សារបន្ថែមទី២ ទៅលើ CCPR (ឆ្នាំ១៩៨៩) ដែលមានបំណងលុបបំបាត់ចោលជាសាកល នូវទោសប្រហារជីវិត ត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួន ៩៤ តែប៉ុណ្ណោះ ដែលភាគច្រើនលើសលុប មកពីរដ្ឋនានារបស់អឺរ៉ុប និងអាមេរិកឡាទីន។ ទោះជាយ៉ាងនេះក៏ដោយ ប្រទេសដែលជាមហាអំណាចផ្សេងទៀត ដូចជា សហរដ្ឋអាមេរិក និងប្រទេសចិន និងរដ្ឋអ៊ីស្លាមជាច្រើនទៀត មិនគ្រាន់តែនៅបន្តអនុវត្តទោសប្រហារជីវិតប៉ុណ្ណោះទេ ថែមទាំងធ្វើការជំទាស់យ៉ាងខ្លាំងទៅលើការលុបចោលទោសនេះ នៅក្រោមច្បាប់អន្តរជាតិទៀតផង។

**ប្រអប់ ៥០**

### និន្នាការនៅក្នុងយុត្តិសាស្ត្រ ក្នុងការគាំទ្រដល់ការមិនឱ្យធ្វើបត្យាប័ន និងការលុបចោលទោសប្រហារជីវិត

- នៅឆ្នាំ១៩៨៩ សវនាការទៅលើរឿងរបស់ *Soering ប្រឆាំងទៅនឹងចក្រភពអង់គ្លេស* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ការធ្វើបត្យាប័នដោយចក្រភពអង់គ្លេសនូវជនជាតិអាល្លឺម៉ង់ម្នាក់ទៅកាន់សហរដ្ឋអាមេរិក ដែលគាត់នឹងនៅក្នុងជួររង់ចាំការប្រហារជីវិតអស់រយៈពេលជាច្រើនឆ្នាំ ដែលការធ្វើនេះបង្កើតឱ្យមានការប្រព្រឹត្តធ្វើដោយអមនុស្សធម៌ នៅក្រោមមាត្រា៣ នៃ ECHR។

- នៅឆ្នាំ១៩៩៣ នៅក្នុងរឿងរបស់ *Ng v. Canada* ទាក់ទងនឹងករណីនៃការធ្វើបត្យាប័នមួយទៀតពាក់ព័ន្ធនឹងសហរដ្ឋអាមេរិកនោះ គណៈកម្មាធិការសិទ្ធិមនុស្សបានសម្រេចថា ការសម្លាប់ដោយប្រើឧស្ម័នឱ្យថប់ដង្ហើមរហូតដល់ស្លាប់ ដូចដែលប្រព្រឹត្តធ្វើនៅរដ្ឋកាលីហ្វ័រញ៉ានោះ បង្កើតឱ្យមានការដាក់ទោសទណ្ឌដោយអមនុស្សធម៌ នៅក្រោមមាត្រា៧ នៃ CCPR។

- នៅក្នុងសាលក្រមជាប្រវត្តិសាស្ត្រ ឆ្នាំ១៩៩៥ តុលាការធម្មនុញ្ញរបស់ប្រទេសអាហ្វ្រិកខាងត្បូង បានសរុបសេចក្តីថា ទោសប្រហារជីវិត ដោយមិនខ្វល់គិតពីវិធីនៃការសម្លាប់ ឬកាលៈទេសៈផ្សេងទៀត គឺមានលក្ខណៈអមនុស្សធម៌ និងបានរំលោភលើការហាមឃាត់ នៃការដាក់ទោសទណ្ឌ ដោយអមនុស្សធម៌ នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង។

- នៅឆ្នាំ២០០៣ សវនាការទៅលើរឿង របស់ *Judge v. Canada* គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានពិចារណាថា "ក្នុងនាមជារដ្ឋភាគីមួយ ដែលបានលុបទោសប្រហារជីវិតរួចហើយ ដោយមិនគិតថា ប្រទេសនេះ មិនទាន់បានផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាសំដៅលុបបំបាត់ទោសប្រហារជីវិតនោះទេ ប្រទេសកាណាដាបានរំលោភសិទ្ធិរស់រានមានជីវិតរបស់អ្នកនិពន្ធរូបនេះ នៅក្រោមមាត្រា៦ កថាខ័ណ្ឌទី១ ដោយធ្វើការបញ្ជូនរូបគាត់ទៅសហរដ្ឋអាមេរិក ជាទីកន្លែងដែលលោកស្ថិតនៅក្រោមទោសប្រហារជីវិត ហើយដោយគ្មានបានធ្វើការធានាកុំឱ្យទោសប្រហារជីវិតនោះ ធ្វើឡើងទៅលើរូបគាត់ទេ"។

- នៅក្នុងរឿងរបស់ *Ocalan v. Turkey ប្រឆាំងទៅនឹង ប្រទេសទួគី* (ឆ្នាំ ២០០៣) តុលាការសិទ្ធិមនុស្សអឺរ៉ុបបានតំកល់សេចក្តីសម្រេចថា ការដាក់ឱ្យមានទោសប្រហារជីវិត បន្ទាប់ពីមានការកាត់ក្តីមិនត្រឹមត្រូវ វាបង្កើតឱ្យបានជាការដាក់ទោសដោយអមនុស្សធម៌ និងបានរំលោភ មាត្រា៣ នៃ ECHR ។

- នៅថ្ងៃទី១ មីនា ឆ្នាំ២០០៥ តុលាការកំពូលសហរដ្ឋអាមេរិក បានចេញសេចក្តីសម្រេចថា ទោសប្រហារជីវិតរបស់បុគ្គលទាំងឡាយ ដែលត្រូវបានជាប់ចោទពីបទឧក្រិដ្ឋ ដែលធ្វើឡើងនៅពេលដែលពួកគេជាអនីតិជនផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ។ តុលាការបានលើកយក "ទស្សនៈអន្តរជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ ប្រឆាំងទៅនឹងការដាក់ទោសប្រហារជីវិតទៅលើអនីតិជន" ជាមូលដ្ឋាន"សម្រាប់ជាការអះអាងយ៉ាងធំធេង" ទៅលើការសម្រេចចិត្តរបស់ខ្លួន ដោយបានថ្លែងថា "វា មិនធ្វើឱ្យអន់ថយទៅដល់សេចក្តីស្មោះត្រង់ទៅលើរដ្ឋធម្មនុញ្ញ ឬមោទនភាពនៅក្នុងភាពដើមរបស់ខ្លួននោះទេ ដើម្បីទទួលស្គាល់នូវការពិតទៅលើសិទ្ធិជាមូលដ្ឋានមួយចំនួនដោយជាតិ និងប្រជាជននៃប្រទេសផ្សេងៗ បានគូសបញ្ជាក់ឱ្យច្បាស់នូវចំណុចស្នូលនៃសិទ្ធិដូចគ្នាទាំងនោះ នៅក្នុងវង្វង់មរតកផ្ទាល់ខ្លួននៃសេរីភាពរបស់យើង"។

## ***ការរំលូតកូន***

នៅពេលដែលមាត្រា៤ នៃ ACHR ជាទូទៅការពារសិទ្ធិរស់រានមានជីវិត ចាប់ពីពេលបង្កកំណើតមកនោះ មាត្រា៦ នៃ CCPR និងមាត្រា២ នៃ ECHR មិនបានកំណត់ឱ្យបានច្បាស់លាស់ទៅលើចំណុចចាប់ផ្តើមពីពេលណាមកទៅលើការការពារអាយុជីវិតនោះទេ។ ការប្តឹងឱ្យមានការកាត់សេចក្តីមួយនៅឆ្នាំ១៩៧៣ នៅតុលាការកំពូលសហរដ្ឋអាមេរិកទៅលើរឿងរបស់ *Roe ប្រឆាំងទល់នឹង Wade* តុលាការក្នុងស្រុកនានា នៅតាមប្រទេសជាច្រើន និងអ្នកប្រាជ្ញច្បាប់ទាំងឡាយ បានអះអាងការពារថា ការការពារតាមផ្លូវច្បាប់ ទៅលើសិទ្ធិរស់រានមានជីវិត ចាប់ផ្តើមតាំងពីពេលទារក មានលទ្ធភាពរស់ដោយខ្លួនគេបានមកម៉្លេះ។ នៅក្រោមការបកស្រាយនេះ បុគ្គលទាំងឡាយណា ដែលធ្វើការរំលូតកូន ក្នុងអំឡុងមុនចុងត្រីមាសដំបូងនៃការមានគតិអាចត្រូវបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌពីអំពើរបស់ខ្លួន។ ដូចនេះ ច្បាប់មួយដែលលើកលែងការធ្វើរបៀបនេះ គឺមានភាពស៊ីសង្វាក់ទៅនឹងកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋ ក្នុងការការពារសិទ្ធិរស់រានមានជីវិតរបស់ទារក ប្រឆាំងទៅនឹងការជ្រៀតជ្រែកពីឪពុកម្តាយ និងពីគ្រូពេទ្យ ដោយសារថា សិទ្ធិរស់រានមានជីវិតរបស់ទារក នឹងកើតមានឡើងបាន លុះត្រាតែវាអាចមានលទ្ធភាពរស់បាន ដោយមិនចាំបាច់ពឹងលើម្តាយរបស់វា។ ទោះជាយ៉ាងនេះក៏ដោយ បន្ទាប់ពីត្រីមាសដំបូងមក កាតព្វកិច្ចវិជ្ជមានរបស់រដ្ឋនឹងកើតមានឡើង ហើយសិទ្ធិរស់រានមានជីវិតរបស់ទារក ដែលមិនទាន់ប្រសូត្រ ត្រូវតែធ្វើឱ្យមានតុល្យភាពទៅនឹងសិទ្ធិមនុស្សផ្សេងទៀត ជាពិសេស ទៅនឹងសិទ្ធិរស់រានមានជីវិតរបស់ម្តាយ ហើយប្រហែលជាសិទ្ធិរបស់គាត់ទៅលើបញ្ហាសុខភាព និងសិទ្ធិឯកជនរបស់គាត់ផងដែរ។

ប្រអប់ ៥១

## ស្ថានការណ៍នៅជុំវិញពិភពលោក ទាក់ទិនទៅនឹងទោសប្រហារជីវិត

ដោយយោងទៅលើអង្គការលើកលែងទោសអន្តរជាតិ នៅក្នុងឆ្នាំ២០០៤ មានមនុស្សយ៉ាងហោចណាស់ចំនួន៣៧៩៧ នាក់ ដែលត្រូវបានប្រហារជីវិត នៅក្នុងប្រទេសចំនួន២៥ ហើយយ៉ាងហោចណាស់មនុស្ស ចំនួន៧៣៩៥ នាក់ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារមួយជីវិតនៅក្នុងប្រទេសចំនួន៦៤។ តួលេខទាំងនេះ រួមមានតែករណីដែលត្រូវបានដឹងដោយអង្គការលើកលែងទោសអន្តរជាតិតែប៉ុណ្ណោះ ដូចនេះ តួលេខពិតប្រាកដអាចមានច្រើនជាងនេះ។[២៦]

### ប្រទេសដែលលុបចោលទាំងស្រុង និងប្រទេសដែលរក្សាទុកទាំងស្រុង

ប្រទេសដែលលុបចោលទាំងស្រុងនូវឧក្រិដ្ឋកម្មគ្រប់ប្រភេទ : ៨៥

ប្រទេសដែលលុបចោលទាំងស្រុង ប៉ុន្តែលើកលែងចំពោះឧក្រិដ្ឋកម្មមួយចំនួន
ដូចជាឧក្រិដ្ឋកម្មនាពេលសង្គ្រាម : ១១

ប្រទេសដែលលុបចោលទាំងស្រុងក្នុងការអនុវត្ត : ២៤

ចំនួនប្រទេសសរុប ដែលលុបចោលទាំងស្រុងតាមច្បាប់ ឬតាមការអនុវត្ត : ១២០

ប្រទេសដែលរក្សាទុកទាំងស្រុង (ប្រទេស និងដែនដី): ៧៦

### ១. ប្រទេសដែលលុបចោលទាំងស្រុងសម្រាប់ឧក្រិដ្ឋកម្មគ្រប់ប្រភេទ

ប្រទេស និងដែនដីនានា ដែលច្បាប់របស់គេ មិនអនុញ្ញាតឱ្យមានទោសប្រហារជីវិត ចំពោះឧក្រិដ្ឋកម្មគ្រប់ប្រភេទទាំងអស់: អង់ដូរ៉ា អង់ហ្គោឡា អាម៉ឺនី អូស្ត្រាលី អូទ្រីស បែលហ្សិក ប៊ូតាន អាហ្សែបៃហ្សាន់ បូស្នីនិងហឺហ្សេហ្គូវីណា ប៊ុលហ្គារី កម្ពុជា កាណាដា ខេបវែដ កូឡំប៊ី កូស្តារីកា កូឌីវ័រ ក្រូអាត ស៊ីប្រឹស ដាណឺម៉ាក ដ្ស៊ីប៊ូទី សាធារណៈរដ្ឋដូមីនីកាំង អេក្វាដ័រ អេស្តូនី ហ្វាំងឡង់ បារាំង ក្រិច សាធារណៈរដ្ឋឆែក ហ្សកហ្ស៊ី អាល្លឺម៉ង់ ហ្គីនីប៊ីសូ ហៃទី ហូលីស៊ី

---

[២៦] ព័ត៌មានពិស្តារអាចរកបាននៅលើគេហទំព័ររបស់អង្គការលើកលែងទោសអន្តរជាតិ http://web.amnesty.org/pages/deathpenalty-facts-eng

ហុងដុយរ៉ាស់ ហុងហ្គារី អ៊ីស្លង់ ស៊្វីស អៀកឡង់ អ៊ីតាលី គីរីបាទី លីឆតិនស្ដែន លីទុយអានី លុចសំបួរ ម៉ាល់តា កោះម៉ាសល កោះម៉ូរីស មិចស៊ិច (រដ្ឋសហព័ន្ធ)មីក្រូណេស៊ី ម៉ូណាកូ ម៉ូហ្សំប៊ិច ណាមីប៊ី នេប៉ាល់ ហុល្លង់ នូវ៉ែលស្សេឡង់ នុយ នីការ៉ាហ្គ័រ ណ័រវ៉ែស ប៉ាឡូ ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉ូឡូញ ប៉័ទុយហ្គាល សាធារណៈរដ្ឋម៉ូលដូវ៉ា រ៉ូម៉ានី សាម៉ៅ សង់មារីណូ សៅតូម៉េនិងប្រាំងស៊ីប សេណេហ្គាល់ ស៊ីឆែល សែបនិងម៉ុងតេណេក្រូ ស្លូវ៉ាគី ស្លូវ៉ានី កោះសូឡូម៉ុង អាហ្វ្រិកខាងត្បូង អេស្ប៉ាញ អតីតៈសាធារណៈរដ្ឋយូហ្គោស្លាវីម៉ាសេដូនី ទូគីស៊ុយអែត ទីម័រខាងកើត ទូមីនីស្ដង់ ទុយវ៉ាលុយ អ៊ុយក្រែន ចក្រភពអង់គ្លេស អ៊ុយរ៉ាហ្គាយ វ៉ានូទុយ និងវេណេហ្សុយអេឡា។

## ២. ប្រទេសដែលលុបចោលទាំងស្រុង ចំពោះតែឧក្រិដ្ឋកម្មធម្មតាប៉ុណ្ណោះ

ប្រទេសនានា ដែលច្បាប់អនុញ្ញាតឱ្យមានទោសប្រហារជីវិតតែលើឧក្រិដ្ឋកម្មទាំងឡាយណាដែលអាច ត្រូវបានប្រព្រឹត្តធ្វើឡើងនៅក្រោមច្បាប់យោធា ឬក៏នៅក្រោមកាលៈទេសៈពិសេសផ្សេងៗទៀតៈ អាល់បានីអាហ្សង់ទីន អាមេនី បូឡាវី ប្រេស៊ីល ឈីលី កោះឃុក អែលសាវ៉ាដ័រ ហ្វីជី ក្រិច អីស្រាអែល ឡាតវី មិចស៊ិច ប៉េរូ និងទួរគី។

## ៣. ប្រទេសដែលលុបចោលទាំងស្រុងនៅក្នុងការអនុវត្ត

ប្រទេសទាំងឡាយដែលរក្សាទុកទោសប្រហារជីវិត សម្រាប់ឧក្រិដ្ឋកម្មធម្មតា ដូចជាការធ្វើឃាតក៏ប៉ុន្តែដែលអាចត្រូវបានចាត់ទុកថាជាប្រទេសដែលលុបចោលទាំងស្រុងនៅក្នុងការអនុវត្ត ដោយសារថាប្រទេសទាំងនោះ មិនដែលបានប្រហារជីវិតជនណាម្នាក់ក្នុងអំឡុងពេល១០ឆ្នាំកន្លងមក ហើយត្រូវបានគេជឿថា ប្រទេសនោះមានគោលនយោបាយមួយ ឬមានការអនុវត្តចាក់ឫសមួយ ដោយមិនឱ្យមានការអនុវត្តការប្រហារជីវិត ហើយប្រទេសទាំងនេះបានបង្ហាញការតាំងចិត្តជាអន្តរជាតិ មិនប្រើប្រាស់ទោសប្រហារជីវិតទេ :

ប្រទេសអាល់ហ្សេរី ប៉េណាំង ប្រុយណេដារុយសាឡាម បឺរគីណាហ្វាសូ សាធារណៈរដ្ឋអាហ្វ្រិចកណ្ដាល កុងហ្គោ ហ្គាមប្បៀ គ្រែនណាដា កែនយ៉ា ម៉ាដាហ្គាស្កា ម៉ាល់ឌីវ ម៉ាលី ម៉ូរីតានីនូរុយ នីហ្សេ ប៉ាពួញូវហ្គីនី សហព័ន្ធរុស្ស៊ី ស្រីលង្កា ស៊ូរីណាម តូហ្គោ តុងហ្គា និងទុយនីស៊ី។

### ៤. ប្រទេសដែលរក្សាទុកទាំងស្រុង

ប្រទេស និងដែនដីនានា ដែលរក្សាទុកនូវទោសប្រហារជីវិតចំពោះបទឧក្រិដ្ឋធម្មតា: អាហ្គានីស្ថាន អង់ទីហ្គានិងបាប៊ុយដា បាហាម៉ា បារ៉ែន បង់ក្លាដែស បាបាដូ បែលឡារុស ប៊ែលីស បូតស្វាណា ប៊ូរុនឌី កាម៉េរូន ឆាត ចិន កូម៉ូរុស គុយបា សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដូមីនីកា អេហ្ស៊ីប អេក្វាទ័រ ហ្គីនី អេរីទ្រា អេត្យូពី ហ្គាបុង ហ្គាណា ហ្គាតេម៉ាឡា ហ្គីនី ហ្គុយយ៉ាណា ឥណ្ឌា ឥណ្ឌូនេស៊ី សាធារណៈរដ្ឋឥស្លាមអ៊ីរ៉ង់ អ៊ីរ៉ាក់ ចាម៉ៃកា ជប៉ុន ហ្សកដង់ កាហ្សាក់ស្ថាន គុយវ៉ែត គីជីស្ថាន សាធារណៈរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ លីបង់ លេសូតូ លីបេរីយ៉ា លីប៊ីអារ៉ាប់ចាម៉ាហ៊ីរីយ៉ា ម៉ាឡាវី ម៉ាឡេស៊ី ម៉ុងហ្គោលី ម៉ូរ៉ុកកូ នីហ្សេរីយ៉ា ភូមា អូម៉ង់ ប៉ាគីស្ថាន ប៉ាឡេស្ទីន ហ្វីលីពីន កាតា សាធារណៈរដ្ឋកូរ៉េ រវ៉ាន់ដា សាំងឃីតនិងណេវីស សាំងលូស៊ី សាំងវ៉ាំងសង់និងហ្គ្រេណាឌីន អារ៉ាប៊ីសាអូឌី សេរ៉ាឡេអូន សឹង្ហបុរី សូម៉ាលី ស្វាស៊ីឡង់ ថៃ ស៊ូដង់ សាធារណៈរដ្ឋអារ៉ាប់ស៊ីរី តាជីគីស្តង់ ទ្រីនីដាតនិងតូបាហ្គោ យូហ្គាន់ដា អារ៉ាប់រួមអេមីរ៉ែត ហ្សំប៊ី សហសាធារណៈរដ្ឋ តង់ហ្សានី សហរដ្ឋអាមេរិច អ៊ូបេគីស្តង់ វៀតណាម យេមែន និងហ្ស៊ីមបាវ៉េ។

## *ការកែប្រែហ្សែន* (Genetic Engineering)

ក្រុមប្រឹក្សាអឺរ៉ុប ដើរតួនាទីត្រួសត្រាយផ្លូវទៅលើផ្នែក ដែលមានភាពចម្រូងចម្រាសនេះ ដែលស្ថិតនៅលើព្រំដែនរវាងបញ្ហាសីលធម៌ សិទ្ធិមនុស្ស និងការអភិវឌ្ឍសម័យទំនើប នៅក្នុងផ្នែកជីវសាស្ត្រវិទ្យា។ នៅឆ្នាំ១៩៩៧ គណៈកម្មាធិការនៃរដ្ឋមន្ត្រី បានអនុម័ត *អនុសញ្ញាដើម្បីការពារសិទ្ធិមនុស្ស និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស* ដោយទាក់ទងទៅនឹងការប្រើប្រាស់ជីវៈវិទ្យា និងឱសថ (អនុសញ្ញាស្ដីពីសិទ្ធិមនុស្ស និងជីវៈឱសថ)។ អនុសញ្ញា បានបញ្ជាក់នូវគោលការណ៍នៃការយល់ព្រមដោយសេរី និងដោយបានយល់ទៅលើរាល់កិច្ចអន្តរាគមន៍ នៅក្នុងវិស័យសុខាភិបាលទាំងអស់ (មាត្រា ៥) ដោយបានចែងថា កិច្ចអន្តរាគមន៍

មួយ ដែលស្វែងរកឱ្យមានការកែប្រែហ្សែនរបស់មនុស្ស អាចត្រូវធ្វើទៅបាន លុះត្រាតែសម្រាប់គោលបំណងបង្ការ ធ្វើរោគវិនិច្ឆ័យ ឬវិធីព្យាបាលរោគតែប៉ុណ្ណោះ ហើយប្រសិនបើគោលបំណងរបស់វា មិននាំឱ្យមានការកែប្រែហ្សែនរបស់បច្ឆាជនឡើយ (មាត្រា១៣) ហើយចែងថា រាង្គកាយ និងសរីរាង្គរបស់មនុស្ស មិនត្រូវបានធ្វើជាការទទួលបានផ្នែកហិរញ្ញវត្ថុ ឡើយ(មាត្រា ២១)។ ពិធីសារបន្ថែមទី១ទៅលើអនុសញ្ញានោះ ដែលត្រូវបានអនុម័តកាលពីឆ្នាំកន្លងទៅ សំដៅឱ្យមានការហាមប្រាមការធ្វើសរីរះចំលង(clone)ទៅលើមនុស្សឡើយ ហើយពិធីសារបន្ថែមទី២ ដែលត្រូវបានអនុម័តនៅឆ្នាំ២០០២ ពាក់ព័ន្ធទៅនឹងការផ្សាំបង្កាត់សរីរាង្គ និងជាលិកានៃធាតុដើមរបស់មនុស្ស។

## ***ការសុំឱ្យគេសម្លាប់*** (Euthanasia)

មិនមានការងឿងឆ្ងល់នោះទេ កាតព្វកិច្ចរបស់រដ្ឋ ក្នុងការការពារសិទ្ធិរស់រានមានជីវិតបានអនុវត្តលើអ្នកដែលមានជំងឺមិនអាចព្យាបាលបាន ទៅលើអ្នកមានពិការភាព និងប្រជាពលរដ្ឋផ្សេងទៀត ដែលងាយរងគ្រោះយ៉ាងខ្លាំង ទៅលើវិធានការនានាដែលដាក់បង្ខំដល់ការសុំឱ្យគេសម្លាប់នេះ។ ក៏ប៉ុន្តែនៅក្នុងករណីដែលថា បុគ្គលមានជំងឺ រង់ចាំតែស្លាប់ដែលបានបង្ហាញបំណងចង់ស្លាប់យ៉ាងច្បាស់លាស់ និងហ្មត់ចត់ កាតព្វកិច្ចដើម្បីការពារសិទ្ធិរស់រានមានជីវិត ត្រូវតែធ្វើសេចក្តីថ្លឹងថ្លែងជាមួយនឹងសិទ្ធិផ្សេងៗទៀត ដែលបុគ្គលអ្នកជំងឺនោះ ត្រូវទទួលបានជាពិសេស គឺសិទ្ធិមានជីវភាពឯកជន និងសេចក្តីថ្លៃថ្នូរ។ ច្បាប់ក្នុងស្រុកនានាស្តីពីការសុំឱ្យគេសម្លាប់ដោយសកម្ម និងអកម្ម (ដូចជាច្បាប់ពាក់ព័ន្ធនានានៅប្រទេសហូល្លង់) ដែលកម្រិតការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយផ្តល់នូវការពិចារណា ដោយប្រយ័ត្នប្រយែងទៅលើសិទ្ធិដែលពាក់ព័ន្ធទាំងអស់ ហើយធ្វើការប្រុងប្រយ័ត្ន ដោយសមរម្យប្រឆាំងទៅនឹងការរំលោភបំពានធ្ងន់ធ្ងរ ដែលស៊ីសង្វាក់ជាមួយកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋក្នុងការការពារសិទ្ធិរស់រានមានជីវិត។ ក៏ប៉ុន្តែ ដោយប្រឈមមុខទៅនឹងសំណួរដ៏លំបាកជាច្រើន

អំពីព្រំដែនរវាងសីលធម៌ និងឱសថសាស្ត្រនោះ រដ្ឋអាចសម្រេចធ្វើការហាមប្រាមការសុំឱ្យគេសម្លាប់តែម្តង ដូចដែលការសម្រេចក្តីរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប នៅក្នុងរឿងក្តីរបស់ Pretty *ប្រឆាំងទៅនឹងចក្រភពអង់គ្លេស* (ឆ្នាំ២០០២) បានបង្ហាញឱ្យឃើញស្រាប់។ (សូមមើលប្រអប់ ៥២)។

**ប្រអប់ ៥២**

### រឿងក្តីរបស់ Pretty ប្រឆាំងនឹងចក្រភពអង់គ្លេស (ឆ្នាំ ២០០២)

Dianne Pretty មានជំងឺធ្ងន់ធ្ងររង់ចាំតែថ្ងៃស្លាប់ ហើយមិនអាចធ្វើចលនាចាប់ពី ករហូតដល់ក្រោម ដោយទទួលរងជំងឺស៊ីខួរឆ្អឹង (motor neurone)។ ទោះជាកើតជំងឺនេះក៏ដោយ ក៏សមត្ថភាពខាងប្រាជ្ញា និងខាងការធ្វើសេចក្តីសម្រេចមិនមានការប៉ះពាល់ឡើយ ហើយគាត់មានបំណងធ្វើអត្តឃាត ក៏ប៉ុន្តែស្ថានភាពរបស់គាត់មិនអាចឱ្យគាត់ធ្វើកិច្ចការនេះបានតែម្នាក់ឯងនោះទេ។ ដូចនេះហើយគាត់បានស្វះស្វែងរកការធានាពីប្រធានអយ្យការសាធារណៈថា ប្តីរបស់គាត់នឹងមិនត្រូវជាប់មានទោសទេ ប្រសិនបើគាត់ជួយនាងក្នុងការបញ្ចប់ជីវិតរបស់នាង។ សំណើសុំរបស់នាង ត្រូវបានបដិសេធដោយយោងទៅតាមខបញ្ញត្តិពាក់ព័ន្ធនានារបស់ច្បាប់អង់គ្លេស ដែលហាមប្រាមការជួយជ្រោមជ្រែងនៅក្នុងការធ្វើអត្តឃាត ហើយសេចក្តីសម្រេចនេះ ត្រូវបានតំកល់នៅតុលាការចុងក្រោយនៅថ្នាក់ជាតិ។ នៅក្នុងការសម្រេចចិត្តទៅលើពាក្យស្នើសុំរបស់នាង ដែលបានលើកឡើងថា សេចក្តីវិនិច្ឆ័យនេះបានរំលោភទៅលើសិទ្ធិរស់រានមានជីវិតរបស់នាង តុលាការអឺរ៉ុបបានតំកល់ថា សិទ្ធិរស់រានមានជីវិតដែលត្រូវបានធានាក្រោមមាត្រា ២នៃ ECHR មិនអាចត្រូវបានគេបកស្រាយថាជាការឱ្យសិទ្ធិផ្ទុយបញ្ច្រាស់មកវិញនោះទេ មានន័យថាជាសិទ្ធិក្នុងការស្លាប់ ទោះបីជាធ្វើឡើងដោយបុគ្គលដទៃ ឬដោយមានការជួយជ្រោមជ្រែងពីអាជ្ញាធរសាធារណៈក៏ដោយ។ ជាលទ្ធផលនៃសេចក្តីវិនិច្ឆ័យនេះ កម្រងច្បាប់ស្តីពីសមាជិកឯកជន (ត្រូវបានគេស្គាល់ថា

ជាកម្រងច្បាប់ជួយអ្នកជំងឺឱ្យស្លាប់) ត្រូវបានដាក់ជូនទៅសភារបស់ចក្រភពអង់គ្លេស ដោយមានបំណងធ្វើឱ្យស្របច្បាប់ចំពោះការជួយជ្រោមជ្រែងរបស់គ្រូពេទ្យ ឱ្យបុគ្គលម្នាក់ស្លាប់នៅក្រោមលក្ខខណ្ឌ និងកាលៈទេសៈតឹងរ៉ឹង និងមានការកំណត់ច្បាស់លាស់។ អ្នកនិពន្ធច្បាប់នោះ ដែលកំពុងតែនៅធ្វើការពិភាក្សានៅឡើយ បានពិចារណាថា សិទ្ធិក្នុងការជួយអ្នកណាឱ្យបានស្លាប់មានប្រភពចេញពីមាត្រា៨(១) នៃ ECHR ជាមាត្រាមួយដែលចែងថា ជនគ្រប់រូបមានសិទ្ធិទទួលបានការគោរពចំពោះជីវិតឯកជន និងជីវិតគ្រួសាររបស់ខ្លួន។ នៅក្នុងទស្សនៈយល់ឃើញនេះ វាមិនមានវិសមិតភាពជាមួយនឹងកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋក្នុងការការពារជីវិតនោះទេ។

## ហាមប្រាមការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប : សិទ្ធិទទួលបានបូរណភាព និងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន

មាត្រា៥ នៃ UDHR

*“គ្មានជនណាម្នាក់ ត្រូវរងទទួលទារុណកម្ម ឬទណ្ឌកម្ម ឬការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ ”*

មាត្រា៧ នៃ CCPR

*“គ្មានជនណាម្នាក់ ត្រូវរងទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើជាការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រម ដោយសេរីពីសាមីខ្លួនឡើយ ។*

ទារុណកម្ម គឺជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតមួយ ដោយសារថាវាបង្កើត

ឱ្យមានការវាយប្រហារដោយផ្ទាល់ទៅលើភាពជាបុគ្គល និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ បំរាមការធ្វើទារុណកម្ម និងទម្រង់ផ្សេងៗទៀតនៃការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ លើរូបកាយ និងផ្លូវចិត្ត ដូចជាសិទ្ធិទទួលបានបូរណភាព និងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន *គឺជាសិទ្ធិមនុស្សដាច់ខាត* ហើយដូចនេះមិនអាចត្រូវបានគេធ្វើការដកហូត ទោះនៅក្រោមកាលៈទេសៈណាក៏ដោយ ។ នេះមានន័យផងដែរថា គ្មានជនណាម្នាក់អាចយកបញ្ជាពីថ្នាក់លើរបស់ខ្លួនមកធ្វើយុត្តិកម្មនៃការធ្វើទារុណកម្មនោះឡើយ ។

ប្រអប់ ៥៣

## ការធ្វើច្បាប់បំរាមការធ្វើទារុណកម្ម

ការហាមប្រាមការធ្វើទារុណកម្មត្រូវបានធ្វើជាច្បាប់ នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា ៥) CCPR(មាត្រា ៧) និងអនុសញ្ញាប្រឆាំងទារុណកម្ម (CAT) ហើយក៏មាននៅក្នុងសន្ធិសញ្ញាថ្នាក់តំបន់នានា ដូចជា ECHR(មាត្រា ៣) អនុសញ្ញាអឺរ៉ុបស្តីពីការបង្ការទារុណកម្ម និងទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប (មាត្រា ៥) អនុសញ្ញាអន្តរអាមេរិកាំងស្តីពីការបង្ការ និងការផ្តន្ទាទោសអំពើទារុណកម្ម និងធម្មនុញ្ញរបស់អាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ(មាត្រា ៥) និងនៅក្នុងលិខិតុបករណ៍មួយចំនួនដែលមិនជាប់កាតព្វកិច្ចផ្លូវច្បាប់ ប៉ុន្តែមានអំណាចខាងសីលធម៌ ដោយមានរួមទាំងបញ្ញត្តិជាបទដ្ឋានអប្បបរិមាសម្រាប់គ្រប់គ្រងអ្នកទោស គោលការណ៍មូលដ្ឋានសម្រាប់គ្រប់គ្រងអ្នកទោស អង្គនៃគោលការណ៍សម្រាប់ការពារគ្រប់បុគ្គលទាំងអស់ដែលស្ថិតនៅក្រោមរាល់ទម្រង់នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ វិធានរបស់អង្គការសហប្រជាជាតិដើម្បីការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព និងគោលការណ៍ស្តីពីការស៊ើបអង្កេតដោយប្រសិទ្ធភាពនិងការប្រមូលផ្តុំឯកសារស្តីពីការប្រឆាំងទារុណកម្ម និងទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប

ផ្សេងទៀត។ ទារុណកម្មត្រូវបានហាមប្រាមដាច់ខាតដោយបញ្ញត្តិនានានៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ជាពិសេសមាត្រា៣ រួមគ្នារបស់វា។ បន្ថែមលើនេះទៅទៀត លក្ខន្តិកៈទីក្រុងរ៉ូម បានឱ្យនិយមន័យទៅលើការធ្វើទារុណកម្មថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៅពេលដែលអំពើនោះត្រូវបានធ្វើឡើងដោយដឹងជាមុន ហើយជាផ្នែកមួយនៃការវាយប្រហារទ្រង់ទ្រាយធំ ឬដោយប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ។

## *អ្វីទៅហៅថា ទារុណកម្ម ?*

មាត្រា១នៃ CAT បានឱ្យនិយមន័យទៅលើការធ្វើទារុណកម្មថាជាសកម្មភាពណាមួយដែលប្រព្រឹត្តធ្វើដោយមន្ត្រីសាធារណៈម្នាក់ ឬដោយជនដទៃទៀតដែលបំពេញតួនាទីផ្លូវការ ឬដោយការញុះញង់ ឬដោយមានការយល់ព្រមពីមន្ត្រីនោះ ហើយក្នុងបំណងបណ្តាលឱ្យមានការឈឺចាប់ផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដ៏ធ្ងន់ធ្ងរ ឬការឈឺចាប់នោះ ត្រូវបានធ្វើឡើងដោយចេតនាលើបុគ្គលម្នាក់ ក្នុងគោលបំណងជាក់លាក់មួយ ដូចជា ការកំហែងសួររកព័ត៌មាន ឬឱ្យសារភាព ការដាក់ឱ្យមានទោស ការសំឡុតបំភ័យ និងការរើសអើងជាដើម។

អំពើទាំងឡាយ ដែលខ្វះនូវធាតុសំខាន់ណាមួយ ក្នុងចំណោមធាតុសំខាន់ជាច្រើននៃទារុណកម្ម ដូចជា ការប្រព្រឹត្តដោយមន្ត្រីសាធារណៈ ឬដោយមានការយល់ព្រមពីមន្ត្រីសាធារណៈ ដោយមានចេតនា ឬមានឆន្ទៈជាក់លាក់ និងកម្លាំងនៃការឈឺចាប់ ដោយអាស្រ័យទៅលើទម្រង់ គោលបំណង ស្ថានភាពទំងន់នៃការឈឺចាប់ ត្រូវបានគេចាត់ទុកថា ជាការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ ដោយសារទណ្ឌកម្មទាំងអស់នោះបណ្តាលឱ្យមានការឈឺចាប់ និងមានសារធាតុធ្វើឱ្យមានការអាប់អោន ធាតុបន្ថែមមួយទៀតត្រូវតែមាន ដើម្បីធ្វើឱ្យទណ្ឌកម្មនោះ មានសភាពស្មើទៅនឹងការដាក់ទោសទណ្ឌដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

*" ទារុណកម្ម គឺមានចេតនាប្រមាថមើលងាយធ្វើឱ្យអាក់អន់ស្រពោនចិត្ត និងធ្វើឱ្យថោកទាប*

*ទៅលើមនុស្សម្នាក់ ហើយធ្វើឱ្យជននោះក្លាយទៅជាវត្ថុ ”*

*Antonio Cassese អតីតៈប្រធានគណៈកម្មាធិការដើម្បីទប់ស្កាត់ការធ្វើទារុណកម្មរបស់ក្រុមប្រឹក្សាអឺរ៉ុប*

ដកស្រង់ពីសៀវភៅស្ថានភាពអមនុស្សធម៌ ៖ ការដាក់ពន្ធនាគារ ការឃុំខ្លួន និងទារុណកម្ម នៅអឺរ៉ុបនាពេលបច្ចុប្បន្ន បោះពុម្ពផ្សាយដោយ Cambridge Polity Press ឆ្នាំ១៩៩៦ ទំព័រ៤៧ ។

*“ មូលដ្ឋានច្បាប់ និងមូលដ្ឋានសីលធម៌សម្រាប់ហាមប្រាមការធ្វើទារុណកម្ម និងការប្រព្រឹត្ត និងទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប គឺមានលក្ខណៈដាច់ខាត និងជាអាជ្ញាបញ្ជា ហើយទោះជាក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវបន្ទន់ទៅតាម ឬដាក់ឱ្យនៅក្រោមឥទ្ធិពលនៃគោលនយោបាយ និងការអនុវត្តផ្សេងទៀតឡើយ ។”*

*Theo van Boven អ្នករាយការណ៍ពិសេសរបស់គណៈកម្មការសិទ្ធិមនុស្សស្តីពីទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។*

## តើរដ្ឋមានកាតព្វកិច្ចអ្វីខ្លះ ក្នុងការហាមប្រាមទារុណកម្ម ?

រដ្ឋាភិបាលមិនត្រូវដាក់កម្រិតព្រំដែន ឬអនុញ្ញាតឱ្យមានការព្យួសិទ្ធិទទួលបានបូរណភាព និងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនឡើយ ទោះបីជាក្នុងពេលមានសង្គ្រាម និងមានភាពអាសន្នក៏ដោយ ។ គណៈកម្មាធិការ CAT បានសម្រេចថា ទោះបីជា នៅពេលជនសង្ស័យណាម្នាក់ត្រូវបានគេជឿថា មានព័ត៌មានអំពីការវាយប្រហារ ដែលនឹងអាចធ្វើឱ្យគ្រោះថ្នាក់ដល់ជីវិតរបស់ជនស៊ីវិលជាច្រើន ហើយរដ្ឋដែលស្ថិតក្រោម ការគំរាមកំហែងនេះក៏មិនត្រូវប្រើវិធីសួរចម្លើយដែលរំលោភទៅលើការហាមប្រាមការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ដូចជាបង្ខាំងមនុស្សក្នុងស្ថានភាពឈឺចាប់ ឃ្លុំមុខ ដាក់ឱ្យស្តាប់ភ្លេងខ្លាំងៗ ក្នុងរយៈពេលយូរ ឬធ្វើមិនឱ្យដេកបានគំរាមកំហែង ចាប់អង្រួនដោយ

តំហុក ឬប្រើខ្សែលួសត្រជាក់ ដើម្បីឱ្យអ្នកជាប់ឃុំឃាំង រងាញាក់ញ័រជាដើម។ ការហាមប្រាម ការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ជាដាច់ខាតនេះត្រូវបានគេរកឃើញថា ប្រសិនបើអនុញ្ញាតឱ្យមានការលើកលែងតែបន្តិចបន្តួចក៏ដោយ បទពិសោធន៍បានបង្ហាញថា ការប្រើទារុណកម្មទំនងនឹងរីកដុះដាល ដូចជាជំងឺមហារីកអញ្ចឹង។

**ប្រអប់ ៥៤**

### ការធានាការពារតាមនីតិវិធីច្បាប់នៅអំឡុងពេលឃាត់ខ្លួន

ការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា កើតឡើងភាគច្រើននៅអំឡុងពេលនៅក្រោមការឃុំខ្លួនរបស់ប៉ូលិស។ វិធីសាស្ត្រការពារដូចខាងក្រោមនេះ អាចជួយការពារជនដែលត្រូវបានចាប់ខ្លួន ទប់ទល់នឹងហានិភ័យនោះ ៖

- ការប្រាប់ឱ្យដំណឹងពីការឃុំខ្លួន៖ សិទ្ធិរបស់ជនដែលត្រូវគេចាប់ខ្លួនក្នុងការបានដឹងពីអង្គហេតុនៃការឃុំខ្លួនរបស់ពួកគេ ត្រូវបានគេជូនដំណឹងទៅភាគីទី៣ តាមជម្រើសរបស់ពួកគេ (ដូចជាសមាជិកគ្រួសារ មិត្តភ័ក្ក ឬស្ថានកុងស៊ុល)
- សិទ្ធិរកមេធាវីរបស់ជនដែលត្រូវគេឃុំខ្លួន
- សិទ្ធិរបស់ជនដែលត្រូវគេឃុំខ្លួន ក្នុងការស្នើឱ្យមានការពិនិត្យ ដោយគ្រូពេទ្យម្នាក់តាមការជ្រើសរើសរបស់ពួកគេ (បន្ថែមពីលើការពិនិត្យដោយគ្រូពេទ្យដែលត្រូវបានរៀបចំដោយអាជ្ញាធរប៉ូលិស)
- ការបង្កើតឱ្យមានបញ្ជីមួយ សម្រាប់ចុះឈ្មោះអ្នកត្រូវឃុំខ្លួនទាំងអស់ និងទីកន្លែងឃុំខ្លួន
- ការផាត់ចោល ឬមិនទទួលយកភស្តុតាងណា ដែលប្រមូលបានពីការធ្វើទារុណកម្ម ឬតាមទម្រង់បង្ខំ ផ្សេងទៀត
- ការថតសម្លេង និងថតវីដេអូ រាល់ការសួរចម្លើយរបស់ប៉ូលិសទាំងអស់

លក្ខណៈដាច់ខាតនៃការហាមប្រាមទារុណកម្មនេះ ត្រូវតែបានធានា។ ដូច្នេះរដ្ឋត្រូវបានហាមការដកហូតសិទ្ធិនោះទេ ព្រោះថាប្រសិនបើសិទ្ធិនោះត្រូវបានព្យួរនោះនឹងនាំឱ្យមានការធ្វើទារុណកម្ម ដូចជាសិទ្ធិក្នុងការមិនឱ្យគេឃុំខ្លួន សម្រាប់រយៈពេលយូរ ដោយមិនឱ្យជួប និងនិយាយជាមួយអ្នកដទៃ និងសិទ្ធិរបស់ជនដែលត្រូវគេចាប់ខ្លួនក្នុងការទទួលបាននូវសវនាការនៅតុលាការឱ្យបានឆាប់។ រដ្ឋមានកាតព្វកិច្ច ដើម្បីទប់ស្កាត់ ស៊ើបអង្កេត កាត់ទោស និងដាក់ទោស ទៅលើសកម្មភាពធ្វើទារុណកម្មទាំងអស់។ រដ្ឋត្រូវតែសងការខូចខាតដល់ជនរងគ្រោះ ដោយរួមទាំងការកសាងនីតិសម្បទាផ្នែកពេទ្យ និង ផ្នែកចិត្តសាស្ត្រ និងសងជម្ងឺចិត្តចំពោះការខូចខាតសំភារៈ និងការខូចខាតផ្លូវចិត្តនានា (សូមមើលប្រអប់៥៥)។

**ប្រអប់ ៥៥**

## កាតព្វកិច្ចរបស់រដ្ឋ នៅក្រោម CAT

**រដ្ឋជាភាគីនៃអនុសញ្ញានេះ មានករណីយកិច្ច ត្រូវ :**

- អនុម័តច្បាប់សម្រាប់ដាក់ទោសដល់ការធ្វើទារុណកម្ម ផ្តល់អំណាចទៅឱ្យអាជ្ញាធរដើម្បីធ្វើបណ្តឹងអាជ្ញា និងដាក់ទោសដល់ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ទោះជាទារុណកម្មនោះ ធ្វើនៅទីណាក៏ដោយ ហើយទោះជាអ្នកប្រព្រឹត្ត ឬជនរងគ្រោះនោះជាជាតិសាសន៍ណាក៏ដោយ ហើយត្រូវទប់ស្កាត់អំពើទាំងនេះ (គោលការណ៍របស់យុត្តាធិការសកល)
- ធានាថា ការអប់រំ និងព័ត៌មានទាក់ទិនទៅនឹងការហាមប្រាមទារុណកម្មនេះ ត្រូវបានបញ្ចូលដោយពេញលេញ ទៅក្នុងការបណ្តុះបណ្តាលបុគ្គលិកអនុវត្តច្បាប់ ទាំងស៊ីវិល និងយោធា មន្ត្រីសុខាភិបាល មន្ត្រីសាធារណៈ និងបុគ្គលផ្សេងទៀតដែលអាចមានការពាក់ព័ន្ធនៅក្នុងការឃុំខ្លួន ការសួរចម្លើយ ឬការទុកដាក់អ្នក ដែលត្រូវចាប់ខ្លួនបុគ្គលទាំងឡាយ ដែលត្រូវឃុំខ្លួន ឬដាក់ពន្ធនាគារ។
- ធានាថា វិធាន សេចក្តីណែនាំ វិធី និងការអនុវត្តក្នុងការសួរចម្លើយ និងការរៀបចំសម្រាប់ឃុំខ្លួន និងគ្រប់គ្រងលើបុគ្គលដែលត្រូវចាប់ខ្លួន ឃុំខ្លួន ឬដាក់ពន្ធនាគារក្នុងទម្រង់ណាមួយ ត្រូវតែធ្វើការ

ពិនិត្យឡើងវិញ ក្នុងលក្ខណៈជាប្រព័ន្ធ ដោយស្ថាប័នឯករាជ្យនានា។

- ធានាថា ពាក្យបណ្តឹងពីការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ត្រូវបានស៊ើបអង្កេតឱ្យបានហ្មត់ចត់ ដោយអាជ្ញាធរមានសមត្ថកិច្ចនានា ហើយធានាថា អ្នកដែលប្រព្រឹត្តអំពើទារុណកម្ម ត្រូវតែនាំយកទៅកាត់ទោស ហើយធានាថា សំណងដ៏មានប្រសិទ្ធភាពត្រូវតែផ្តល់ឱ្យជនរងគ្រោះ ហើយធានាថា ច្បាប់នានា ត្រូវបានចែងឡើង ដើម្បីអនុវត្តវិធានការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ក្នុងអំឡុងពេលនៃការឃុំខ្លួន។
- ទប់ស្កាត់កុំឱ្យមានការបណ្តេញចេញ និងការបញ្ជូនត្រឡប់វិញ (refoulement) ឬធ្វើបត្យាប័នបុគ្គលណាម្នាក់ ទៅប្រទេសមួយទៀត ជាទីកន្លែងដែលជននោះទំនងជានឹងត្រូវប្រឈមមុខនឹងទារុណកម្ម (គោលការណ៍ "មិនបញ្ជូនត្រឡប់វិញ" ឬ " មិនធ្វើមាតុភូមិនិវត្តន៍ ")។
- ដាក់ជូនរបាយការណ៍ឱ្យបានទៀងទាត់ទៅកាន់គណៈកម្មាធិការ CAT អំពីវិធានការនានា ដែលបានធ្វើឡើង ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពទៅដល់អនុសញ្ញា ឬរបាយការណ៍ផ្សេងទៀតដែលគណៈកម្មាធិការស្នើសុំ
- បង្កើតគណៈកម្មការជាតិឯករាជ្យនានា (រួមមានសមាជិករបស់តុលាការ មន្ត្រីអនុវត្តច្បាប់ មេធាវី គ្រូពេទ្យ អ្នកជំនាញឯករាជ្យ និងតំណាងសង្គមស៊ីវិលនានា) ដើម្បីធ្វើទស្សនកិច្ចសម្រាប់ទប់ស្កាត់ទារុណកម្មនៅគ្រប់ទីឃុំឃាំងទាំងអស់ (ពិធីសារបន្ថែមទៅលើ CAT ដែលបានអនុម័ត នៅឆ្នាំ ២០០២)។

**ប្រអប់ ៥៦**

## ស្តង់ដាអប្បបរិមារបស់អង្គការសហប្រជាជាតិសម្រាប់ការឃុំខ្លួន និងរបៀបនៃការអនុវត្តច្បាប់

- រនាំងការពារដែលធានានូវការការពារសិទ្ធិរបស់អ្នកដែលត្រូវមានទោសប្រហារជីវិត ឆ្នាំ១៩៨៤
- ស្តង់ដានៃវិធានអប្បបរិមាសម្រាប់គ្រប់គ្រងអ្នកទោស ឆ្នាំ១៩៥៥
- ក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់ ឆ្នាំ១៩៧៩

- គោលការណ៍នៃក្រមសីលធម៌វិជ្ជាសាស្ត្រពាក់ព័ន្ធទៅនឹងតួនាទីរបស់បុគ្គលិកសុខាភិបាល ជាពិសេស គ្រូពេទ្យ ក្នុងការការពារអ្នកទោស និងអ្នកត្រូវគេឃុំខ្លួន ប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន និងទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឆ្នាំ១៩៨២
- វិធានការពារដែលធានានូវការការពារសិទ្ធិរបស់អ្នកដែលប្រឈមមុខទោសប្រហារជីវិត ឆ្នាំ១៩៨៤
- ស្តង់ដានៃវិធានអប្បបរិមាអង្គការសហប្រជាជាតិ សម្រាប់ការគ្រប់គ្រងយុត្តិធម៌អនីតិជន (“វិធានទីក្រុងប៉េកាំង”) ឆ្នាំ១៩៨៥
- គោលការណ៍មួយចំនួន ដើម្បីការពារបុគ្គលទាំងអស់ ក្រោមទម្រង់នៃការឃុំឃាំង ឬការដាក់ពន្ធនាគារណាមួយ ឆ្នាំ ១៩៨៨
- គោលការណ៍មូលដ្ឋាន ស្តីពីការប្រើកម្លាំង និងអាវុធ ដោយមន្ត្រីអនុវត្តច្បាប់ ឆ្នាំ១៩៩០
- គោលការណ៍មូលដ្ឋាន សម្រាប់គ្រប់គ្រងអ្នកទោស ឆ្នាំ១៩៩០
- គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ សម្រាប់ការទប់ស្កាត់អាកប្បកិរិយាមិនល្អរបស់អនីតិជន (“គោលការណ៍ណែនាំទីក្រុងរីយ៉ាដ”) ឆ្នាំ១៩៩០
- បទដ្ឋាននៃវិធានអប្បបរិមាអង្គការសហប្រជាជាតិ សម្រាប់វិធានការមិនឱ្យមានការឃុំខ្លួន (វិធាន ទីក្រុងតូក្យូ) ឆ្នាំ១៩៩០
- វិធានរបស់អង្គការសហប្រជាជាតិ សម្រាប់ការពារអនីតិជន ដែលត្រូវបានគេបដិសេធសេរីភាពរបស់ខ្លួន ឆ្នាំ១៩៩០។

## ការហាមប្រាមទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប

ដោយសារថា ការធ្វើទោសទណ្ឌណាមួយ ក៏បណ្តាលឱ្យមានការឈឺចាប់ និងការអាប់អោនដែរនោះ ធាតុបន្ថែមមួយទៀតត្រូវតែមានដើម្បីឱ្យការធ្វើទណ្ឌកម្មនោះមានសភាពស្មើទៅនឹងការដាក់ទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ ស្តង់ដាអប្បបរិមានានា នៅក្នុងវិស័យនេះ មានភាពខុសគ្នា ពីប្រទេសមួយ ទៅប្រទេសមួយទៀត។ នៅអឺរ៉ុប

ទោសប្រហារជីវិត និងរាល់ទម្រង់នៃទណ្ឌកម្មលើរាងកាយ បច្ចុប្បន្ននេះ ត្រូវបានចាត់ទុកជាទណ្ឌកម្មដែលមានភាពអមនុស្សធម៌ និងបន្ថោកបន្ទាប ដូច្នេះហើយ ទោសនេះត្រូវបានហាមឃាត់ ហើយនៅប្រទេសជាច្រើន ការដាក់ទោសជាប់ពន្ធនាគារមួយជីវិត ត្រូវបានគេចាត់ទុកក្នុងផ្លូវដូចគ្នានេះដែរ។ គណៈកម្មាធិការសិទ្ធិមនុស្ស បានពិចារណាទៅលើទណ្ឌកម្មលើរាងកាយ ដូចជា ការធ្វើទោសទណ្ឌលើអ្នកទោសនៅប្រទេសចាម៉ៃកា និងប្រទេសទ្រីនីដាត និងតូបាហ្គូ ថាជាការដាក់ទោសដែលមានលក្ខណៈបន្ថោកបន្ទាបនៅក្រោមមាត្រា៧នៃCCPR។ បន្ថែមលើនេះទៅទៀត គណៈកម្មាធិការ បានរក្សាជំហរថា វិធីធ្វើទារុណកម្មមួយចំនួន ដូចជាការប្រើឧស្ម័នឱ្យថប់ដង្ហើម ជាការធ្វើទណ្ឌកម្មដោយអមនុស្សធម៌ ហើយដូច្នេះ វារំលោភលើច្បាប់អន្តរជាតិ។

## សិទ្ធិរបស់ជនត្រូវគេឃុំខ្លួន និងអ្នកទោស ក្នុងការទទួលបាននូវការប្រព្រឹត្តដោយមនុស្សធម៌មកលើខ្លួន

មាត្រា១០ នៃ CCPR បានធានានូវសិទ្ធិរបស់ជនគ្រប់រូបដែលត្រូវបានគេដកហូតសេរីភាពរបស់ពួកគេ ដើម្បីទទួលបាននូវការប្រព្រឹត្តមកលើខ្លួនប្រកបដោយមនុស្សធម៌ និងប្រកបដោយការគោរពទៅលើសេចក្ដីថ្លៃថ្នូរ ដែលពួកគេមានជាប់ពីកំណើតមក។ ផ្អែកលើគណៈកម្មាធិការសិទ្ធិមនុស្ស អ្នកដែលត្រូវបានគេដកហូតសេរីភាព មិនត្រូវបានគេ "ដាក់ទៅក្នុងភាពលំបាក ឬការកម្រិតផ្សេងៗ ជាជាងអ្វីដែលជាលទ្ធផលពីការដកហូតសេរីភាពរបស់ពួកគេឡើយ"។

មានឧបករណ៍ច្បាប់ធម្មជាតិមួយចំនួន បានបញ្ជាក់ពីស្តង់ដាអប្បបរិមា ដែលអាចអនុវត្តបានទៅលើការឃុំខ្លួន។

## ប្រអប់ ៥៧

### សិទ្ធិមនុស្ស និងការធ្វើឯកជនភាវូបនីយកម្មពន្ធនាគារ

ការចូលរួមពាក់ព័ន្ធរបស់វិស័យឯកជន ក្នុងកិច្ចប្រតិបត្តិការពន្ធនាគារ - ដូចជា ការសាងសង់ពន្ធនាគារ ការដឹកជញ្ជូនអ្នកទោស លទ្ធកម្មលើការផ្គត់ផ្គង់ និងថែមទាំងការគ្រប់គ្រងពេញលេញទៅលើមណ្ឌលឃុំខ្លួនផង - មានការកើនឡើងជាលំដាប់ តាំងពីទសវត្សទី៨០ មក នៅពេលដែលគេដាក់ឱ្យមានឡើងវិញដំបូងគេ នៅសហរដ្ឋអាមេរិក (ដែលគំនិតនេះ ត្រូវគេបោះបង់អស់កន្លះសតវត្សកន្លងមកហើយ)។ ការធ្វើឯកជនភាវូបនីយកម្មពន្ធនាគារបានកាត់បន្ថយលទ្ធភាពរបស់រដ្ឋក្នុងការធានាឱ្យមានការគោរពសិទ្ធិអ្នកទោស។ នៅក្នុងការសិក្សាមួយ ដែលធ្វើឡើងសម្រាប់អនុគណៈកម្មាធិការទទួលបន្ទុកការលើកស្ទួយ និងការពារសិទ្ធិមនុស្ស[២៧] លោកស្រី Claire Palley ជាអ្នកជំនាញការបានលើកឡើងនូវអំណះអំណាងគោលនយោបាយ ជាគោលការណ៍ចំនួន ៥ ដូចខាងក្រោមនេះ ប្រឆាំងទៅនឹងការឱ្យការគ្រប់គ្រងពន្ធនាគារទៅឯកជនៈ

(ក) មានតែរដ្ឋទេដែលគួរឱ្យមានអំណាចដើម្បីគ្រប់គ្រងវិស័យយុត្តិធម៌នេះនិងដាក់ឱ្យអនុវត្តដោយបង្ខំ ព្រោះថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ ភាពស្របច្បាប់នៃអំណាចរដ្ឋាភិបាលដែលមានពីកំណើត ដែលអំណាចនេះ ប្រជាជនបានប្រគល់ទៅឱ្យរដ្ឋ ដោយ-អាស្រ័យទៅលើការអនុវត្តរបស់រដ្ឋ

(ខ) អំណាច និងមុខការផ្សេងៗ ក្នុងការដាក់ទោសវិន័យ គួរតែទុកឱ្យរដ្ឋធ្វើតែប៉ុណ្ណោះ ដោយ-សារថា មុខការ បែបនេះ អាចបណ្តាលឱ្យមានការកាត់បន្ថយសេរីភាពដែលនៅសេសសល់ ឬក៏ធ្វើការពន្យា ពេលការឃុំខ្លួន

(គ) កម្លាំងក្នុងការបង្ខំងអ្នកទោស គួរតែត្រូវបានប្រើដោយរដ្ឋតែប៉ុណ្ណោះ ដែលជាស្ថាប័នតែមួយ ដែលមានធម្មានុភាពក្នុងការចាត់ចែងលើវិស័យយុត្តិធម៌ និងដាក់វាឱ្យអនុវត្តដោយបង្ខំបាន

(ឃ) ការទទួលខុសត្រូវទៅលើការរំលោភលើសិទ្ធិមនុស្ស ត្រូវតែជាបន្ទុករបស់រដ្ឋ

(ង) រដ្ឋត្រូវតែធានាឱ្យប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌមានភាពទទួលខុសត្រូវ និងមានការដឹងឮពីសាធារណៈជន ហើយនឹងធានាឱ្យសាធារណៈជនទទួលបាននូវព័ត៌មានផ្សេងៗ។

---

[២៧] E/CN.4/Sub.2/1993/21

ការសិក្សានេះក៏បានលើកឡើងនូវបញ្ហានៃការបង្កើតឱ្យមានមូលនិធិសម្រាប់ពន្ធនាគារដ៏ធំ ដែលបង្កើតឡើងដោយសហគ្រាសសាងសង់ និងក្រុមហ៊ុនការពារសន្តិសុខ ហើយនឹងលើកឡើងអំពីផលប្រយោជន៍ ដែលមូលនិធិនេះអាចសម្លឹងឃើញក្នុងការជះឥទ្ធិពលទៅលើគោលនយោបាយផ្នែកព្រហ្មទណ្ឌជាទូទៅ។ អ្នកខ្លះទៀតបានលើកឡើងនូវសំណួរថាតើការធ្វើឯកជនភាវូបនីយកម្មពន្ធនាគារនេះប្រហែលជាអាចមិនដូចគ្នាទៅនឹងការធ្វើឯកជនភាវូបនីយកម្មអ្នកទោសដែរទេឬ។[២៨]

## សិទ្ធិទទួលបានសេរីភាពផ្ទាល់ខ្លួន

មាត្រា៣ នៃ UDHR

*" ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន "*

មាត្រា៩ នៃ UDHR

*" គ្មានជនណាម្នាក់ ត្រូវប្រឈមមុខទៅនឹងការចាប់ចង ការឃុំខ្លួន និងនិរទេស ដោយបំពានឡើយ "*

មាត្រា៩(១) នៃ ICCPR

*" ជនគ្រប់រូបមានសិទ្ធិ មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ ។ គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពរបស់ខ្លួនបាន ឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធី ដែលមានចែងនៅក្នុងច្បាប់ ។ "*

សិទ្ធិក្នុងការទទួលបានសេរីភាពផ្ទាល់ខ្លួន មានទិសដៅផ្តល់ឱ្យមានការការពារប្រឆាំងនឹងការចាប់ចង និងឃុំខ្លួន ដោយបំពាន និងដោយខុសច្បាប់។ ការធានាជាមូលដ្ឋាន

[២៨] សូមមើល ដូចជា *CorpWatch* " សាកលភាវូបនីយកម្មពន្ធនាគារៈ កត្តាជាមូលដ្ឋាន" ២១ សីហា ឆ្នាំ ១៩៩៩

នេះ ត្រូវឱ្យមានប្រសិទ្ធភាពលើមនុស្សគ្រប់រូប ដោយរួមទាំងបុគ្គលដែលត្រូវបានគេចោទពីបទល្មើសព្រហ្មទណ្ឌ ឬក្នុងមូលហេតុនានា ដូចជាការត្រួតត្រាលើជំងឺសតិបញ្ញា ភាពអាវ៉ាសែ និងវិស័យអន្តោប្រវេសន៍ជាដើម ។ ការដាក់កំហិត ក្នុងការដើរហើរផ្សេងទៀត ដូចជា ការបំបរបង់ចោលទៅលើកោះមួយឬទៅក្នុងតំបន់ណាមួយ ការដាក់បំរាមគោចរណ៍ ការបណ្តេញចេញពីប្រទេស ឬការហាមមិនឱ្យចេញពីប្រទេសជាដើម មិនមែនជាការជ្រៀតជ្រែកទៅលើសេរីភាពផ្ទាល់ខ្លួនឡើយ បើទោះបីជាថាវាអាចរំលោភទៅលើសិទ្ធិផ្សេងទៀត ដូចជាសេរីភាពក្នុងការដើរហើរ និងផ្ទះសំបែងជាដើមក្តី (មាត្រា១៤ នៃ UDHR) ។

**ប្រអប់ ៥៨**

### មាត្រា៥ នៃអនុសញ្ញាអឺរ៉ុប ស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន : មូលដ្ឋានដែលអាចអនុញ្ញាតឱ្យធ្វើទៅបានដើម្បីចាប់ខ្លួន និងឃុំខ្លួន

- ការដាក់ជនម្នាក់ឱ្យជាប់ពន្ធនាគារ ក្រោយពីបានត្រូវកាត់ទោសពីបទល្មើសព្រហ្មទណ្ឌ
- ការឃុំខ្លួនដោយប៉ូលីស និងការឃុំខ្លួនត្រៀមចាំសវនាការ ទៅលើជនសង្ស័យពីបទឧក្រិដ្ឋ ដើម្បីរារាំងកុំឱ្យមានការរត់គេចខ្លួន ការរំខានដល់ការរកភស្តុតាង ឬការប្រព្រឹត្តល្មើសបន្ថែមទៀត
- ការឃុំខ្លួននៅក្នុងបរិបទនៃរឿងរដ្ឋប្បវេណី ដើម្បីធានាឱ្យសាក្សីមកបង្ហាញខ្លួននៅតុលាការ ឬដើម្បីធ្វើតេស្តក្នុងការរកបិតុភាព
- ការឃុំខ្លួនជនបរទេសដែលទាក់ទិនទៅនឹងការធ្វើអន្តោប្រវេសន៍ សិទ្ធិជ្រកកោន ការបណ្តេញចេញ និងការធ្វើបត្យាប័ន
- ការឃុំខ្លួនអនីតិជន ដើម្បីគោលបំណងត្រួតពិនិត្យលើការសិក្សាអប់រំ
- ការឃុំខ្លួនមនុស្ស ដែលអសមត្ថភាពខាងសតិបញ្ញា នៅក្នុងមន្ទីរពេទ្យចិត្តសាស្ត្រមួយ

- ការឃុំគ្រងជនដែលមានជំងឺ ឱ្យនៅមួយកន្លែង ដើម្បីទប់ស្កាត់ជំងឺឆ្លង
- ការឃុំខ្លួនជនដែលស្រវឹងស្រា ជនញៀនថ្នាំ និងជនអាវ៉ាសែ

## តើនៅពេលណាដែលការចាប់ខ្លួន និងការឃុំខ្លួនមានភាពស្របច្បាប់?

បុគ្គលម្នាក់ អាចត្រូវបានគេដកហូតសេរីភាពរបស់ខ្លួន តែនៅក្នុងករណីដែលមានមូលដ្ឋានច្បាប់ និងនៅក្រោមនីតិវិធីនានា ដែលបានបង្កើតឡើងដោយច្បាប់តែប៉ុណ្ណោះ។ នីតិវិធីនោះ មិនគ្រាន់ត្រូវតែស្របទៅនឹងច្បាប់ក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងត្រូវស្របទៅនឹងស្តង់ដារអន្តរជាតិថែមទៀតផង។ ច្បាប់ក្នុងស្រុកពាក់ព័ន្ធនានា មិនត្រូវមានធ្វើតាមតែអំពើចិត្ត ដូចជា មិនត្រូវប្រឡាក់ប្រឡូកជាមួយនឹងភាពមិនសមរម្យ ភាពអយុត្តិធម៌ ឬភាពមិនអាចទាយទុកជាមុនបាននោះទេ។ លើសនេះទៅទៀត ការអនុវត្តច្បាប់ នៅក្នុងករណីណាមួយក៏ដោយ មិនត្រូវធ្វើតាមតែអំពើចិត្ត ឬភាពរើសអើងនោះទេ ក៏ប៉ុន្តែ គួរតែមានសមាមាត្រ ទៅនឹងកាលៈទេសៈទាំងអស់ដែលមាននៅជុំវិញករណីនោះ។

ឧទាហរណ៍ដ៏សាមញ្ញនានាស្តីពី *មូលដ្ឋានដែលអាចអនុញ្ញាតិឱ្យចាប់ខ្លួន និងឃុំខ្លួនបាន* មានចែងនៅក្នុងមាត្រា៥ នៃECHR ដែលត្រូវបានគេយល់ថា ដើម្បីផ្តល់បញ្ជីមួយយ៉ាងវែងលើករណីនៃការដកហូតសេរីភាព ដោយស្របច្បាប់នៅអឺរ៉ុប (សូមមើលប្រអប់៥៨) ហើយអាចប្រើជាមូលដ្ឋានមួយសម្រាប់ការបកស្រាយលើពាក្យ "ការដកហូតសេរីភាពដោយបំពាន" នៅក្នុងមាត្រា៩ នៃ ICCPR។ ការដាក់ពន្ធនាគារ ដោយគ្រាន់តែផ្អែកលើមូលដ្ឋាននៃភាពមិនអាចបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ដូចជាការសងសំណងទៅលើប្រាក់ជំពាក់ជាដើម ត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់ ដោយមាត្រា១១ នៃ ICCPR, មាត្រា៧(៧) នៃ ACHR និងមាត្រា១ នៃពិធីសារបន្ថែមទី៤ ទៅលើ ECHR។

**ប្រអប់ ៥៩**

## យុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្ស ស្ដីពីការឃុំខ្លួនមុនពេលសវនាការ

យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស ការឃុំខ្លួនមុនពេលសវនាការមិនគ្រាន់តែត្រូវធ្វើតាមច្បាប់ប៉ុណ្ណោះទេ ថែមទាំងត្រូវតែមានភាពចាំបាច់ និងសមហេតុផលតាមកាលៈទេសៈនីមួយៗទៀតផង។ គណៈកម្មាធិការសិទ្ធិមនុស្សបានទទួលស្គាល់ថា ICCPR អនុញ្ញាតិឱ្យអាជ្ញាធរឃុំខ្លួនបុគ្គលណាម្នាក់ ក្នុងវិធានការពិសេសបំផុតមួយ ប្រសិនបើវាមានភាពចាំបាច់ដើម្បីធានានូវការបង្ហាញខ្លួនរបស់បុគ្គលនោះនៅតុលាការ ក៏ប៉ុន្តែបានបកស្រាយលក្ខខណ្ឌនៃ "ភាពចាំបាច់" នេះយ៉ាងចង្អៀតបំផុតថា: ការសង្ស័យថាបុគ្គលម្នាក់ បានប្រព្រឹត្តបទល្មើសមួយមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឃុំខ្លួន ដើម្បីរង់ចាំការស៊ើបអង្កេត និងការចោទពីតុលាការឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ គណៈកម្មាធិការសិទ្ធិមនុស្សក៏បានសម្រេចថាការឃុំខ្លួនអាចត្រូវធ្វើជាចាំបាច់ ដើម្បីទប់ស្កាត់ការរត់គេចខ្លួន បញ្ចៀសការជ្រៀតជ្រែកទៅលើសាក្សី និងភស្តុតាងផ្សេងទៀត ឬទប់ស្កាត់ការប្រព្រឹត្តបទល្មើសបន្ថែមទៀត។

## ក្នុងពេលឃាត់ខ្លួន តើបុគ្គលម្នាក់មានសិទ្ធិអ្វីខ្លះ ?

- ជនទាំងឡាយដែលត្រូវបានចាប់ខ្លួន *មានសិទ្ធិឱ្យគេជូនដំណឹង* ជាបន្ទាន់ អំពីមូលហេតុនៃការចាប់ខ្លួន និងឃុំខ្លួនពួកគេ ហើយមានសិទ្ធិដើម្បីរកអ្នកប្រឹក្សាយោបល់។ ពួកគេត្រូវតែបានដឹងជាបន្ទាន់អំពីការចោទប្រកាន់នានា ដែលត្រូវបានធ្វើឡើងប្រឆាំងរូបគេ ដើម្បីឱ្យពួកគេមានលទ្ធភាពធ្វើការតវ៉ាទល់នឹងភាពស្របច្បាប់នៃការចាប់ខ្លួន និងការឃុំខ្លួនរបស់ពួកគេ ហើយដើម្បីរៀបចំការពារខ្លួន ប្រសិនបើពួកគេត្រូវបានចោទដោយតុលាការ។
- បុគ្គលទាំងឡាយ ដែលប្រឈមមុខទៅនឹងការចោទពីបទល្មើសណាមួយ មាន*សិទ្ធិរកជំនួយពីមេធាវីម្នាក់* តាមជម្រើសរបស់ពួកគេ។ ប្រសិនបើពួកគេ គ្មានលទ្ធភាពរក

មេធាវីទេ ពួកគេគួរត្រូវបានគេផ្តល់ឱ្យនូវអ្នកប្រឹក្សាយោបល់មួយ ដែលមានគុណភាព និងមានប្រសិទ្ធភាព។ ត្រូវផ្តល់ពេលវេលា និងឧបករណ៍គ្រប់គ្រាន់ ដើម្បីទាក់ទងជាមួយអ្នកប្រឹក្សាយោបល់របស់ពួកគេ។ គួរតែផ្តល់អ្នកប្រឹក្សាយោបល់ឱ្យពួកគេជាបន្ទាន់។

- បុគ្គលទាំងឡាយដែលនៅជាប់ឃុំខ្លួន មាន*សិទ្ធិធ្វើទំនាក់ទំនងជាមួយអ្នកខាងក្រៅ* ហើយជាពិសេស ប្រាស្រ័យទាក់ទងជាមួយគ្រួសារ មេធាវី គ្រូពេទ្យ មន្ត្រីតុលាការ ហើយប្រសិនបើអ្នកជាប់ឃុំនេះ ជាជនបរទេស គេអាចប្រាស្រ័យទាក់ទងជាមួយបុគ្គលិកកុងស៊ុល ឬអង្គការអន្តរជាតិមានសមត្ថកិច្ច។ ការទាក់ទងទៅខាងក្រៅ គឺជារនាំងការពារដ៏សំខាន់មួយប្រឆាំងទៅនឹងការរំលោភសិទ្ធិមនុស្ស ដូចជា "ការបាត់ខ្លួន" ការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ផ្សេងៗ ហើយគឺជាកត្តាចាំបាច់សម្រាប់ឱ្យមានការកាត់ក្តីត្រឹមត្រូវ។

- ជនដែលត្រូវបានចាប់ខ្លួនដោយការសង្ស័យពីបទល្មើសព្រហ្មទណ្ឌ *មានសិទ្ធិឱ្យគេបញ្ជូនយ៉ាងរហ័សទៅចៅក្រម* ឬមន្ត្រីយុត្តិធម៌ផ្សេងទៀតដែលត្រូវ (ក) ធ្វើការវាយតម្លៃថាតើមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ដើម្បីឱ្យមានការចាប់ខ្លួនដែរឬអត់ (ខ) ធ្វើការវាយតម្លៃថាតើការឃុំខ្លួនមុនសវនាការ ជាការចាំបាច់ដែរឬទេ (គ) ការពារសុខមាលភាពរបស់អ្នក ត្រូវឃុំខ្លួន និង (ឃ) ទប់ស្កាត់មិនឱ្យមានការរំលោភសិទ្ធិជាមូលដ្ឋានរបស់ជនដែលត្រូវឃុំឃាំង

- ជនទាំងឡាយនៅក្នុងការឃុំឃាំងមុនសវនាការ មាន*សិទ្ធិទទួលបានការកាត់ទោសក្នុងអំឡុងពេលសមរម្យ បើមិនដូច្នោះទេ ត្រូវទទួលការដោះលែង*។ ដោយអនុលោមតាម *ការសន្និដ្ឋានថាគ្មានទោស* ជនដែលកំពុងរង់ចាំការកាត់ទោសពីបទឧក្រិដ្ឋនានា មិនគួរត្រូវបានរក្សាទុកនៅក្នុងការឃុំឃាំងទេ នេះគឺជានិយាមទូទៅមួយ។

- បុគ្គលដែលត្រូវបានគេដកហូតសេរីភាព ទោះដោយឈរលើមូលដ្ឋានណាក៏ដោយ *មានសិទ្ធិទទួលបានការដែលតម្រូវឱ្យមានដីកានាំខ្លួន ជនសង្ស័យមកកាន់តុលាការ ដើម្បីពិនិត្យនីត្យានុកូលភាពនៃការឃុំខ្លួន* (habeas corpus) ដូចជា ពួកគេអាចចោទសួរពីភាពត្រឹមត្រូវតាមច្បាប់លើការឃុំខ្លួនរបស់ពួកគេនៅមុខតុលាការ ហើយឱ្យមានការពិនិត្យឡើងវិញដោយទៀងទាត់ លើការឃុំខ្លួនរបស់ពួកគេ។ តុលាការត្រូវធ្វើសេចក្តីសម្រេចភ្លាម ដោយឥតពន្យាពេល ក្នុងរយៈពេលជាធម្មតា បួនប្រាំថ្ងៃ ឬពីរបីអាទិត្យទៅលើភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួន និងបញ្ជាឱ្យដោះលែងជាបន្ទាន់ ប្រសិនបើការឃុំខ្លួននោះ មានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់។ ប្រសិនបើមានការឃុំខ្លួនដោយគ្មានរយៈពេលកំណត់ (ឧទាហរណ៍ នៅក្នុងមន្ទីរពេទ្យចិត្តសាស្ត្រជាដើម) ជនដែលត្រូវគេឃុំខ្លួន មានសិទ្ធិទទួលបាននូវការពិនិត្យមើលតាមកាលកំណត់ទៀងទាត់ជាធម្មតា រៀងរាល់ពីរបីខែម្តង។ ជាចុងក្រោយ ជនរងគ្រោះណាដែលត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ មានសិទ្ធិដែលអាចអនុវត្តបានក្នុងការ*ទទួលបាននូវការសងជំងឺចិត្ត*។

## ការគ្រប់គ្រងវិស័យយុត្តិធម៌ : សិទ្ធិទទួលបានការកាត់ទោសដោយត្រឹមត្រូវ

មាត្រា៦ នៃ UDHR

*"មនុស្សរាល់រូប មានសិទ្ធិមានការទទួលស្គាល់នៅគ្រប់ទីកន្លែង ថាជាមនុស្សម្នាក់ នៅចំពោះមុខច្បាប់ "។*

មាត្រា៧ នៃ UDHR

*" មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។"*

មាត្រា៨ នៃ UDHR

*" មនុស្សគ្រប់រូប មានសិទ្ធិរកដំណោះស្រាយជាក់ស្តែងមួយ នៅចំពោះមុខសាលាជំរះក្តីជាតិ ដែលមានសមត្ថកិច្ច ចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់ ។"*

មាត្រា១០ នៃ UDHR

*" មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យ និងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ ។"*

មាត្រា១១ នៃ UDHR

*១. ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មត់ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញ នៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីការពារសិទ្ធិជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ។*

*២. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើណាដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងច្បាប់ជាតិ ឬអន្តរជាតិ នៅពេលដែលអំពើនេះត្រូវបានប្រព្រឹត្ត ។ ហើយក៏មិនត្រូវផ្តន្ទាទោសធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្ត ក្នុងអំឡុងពេលដែលបទល្មើសបានកើតឡើង ។*

មាត្រា១៤ ១៥ និង១៦ របស់ ICCPR ក៏បានចែងពីសិទ្ធិទទួលបានការកាត់ទោសដោយត្រឹមត្រូវដែរ ។

មាត្រា៦ ទៅមាត្រា១១ នៃ UDHR អាចត្រូវដាក់បញ្ចូលជាក្រុម នៅក្រោមចំណងជើងរួមមួយៈ ការគ្រប់គ្រងវិស័យយុត្តិធម៌ ។ សិទ្ធិទទួលបានការកាត់ទោសដោយត្រឹមត្រូវ ក៏បាន

ធានាផងដែរនៅក្រោម ICCPR និងសន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់នានាគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ហើយទាមទារឱ្យមានការធានាតាមនីតិវិធី។

## សមភាពចំពោះមុខច្បាប់ និងចំពោះមុខតុលាការ

ការកាត់ក្តីដោយត្រឹមត្រូវ ធានាឱ្យបានដឹងជាមុននូវសមភាពចំពោះមុខច្បាប់ និងចំពោះមុខតុលាការ។ សិទ្ធិទទួលបានសមភាពចំពោះមុខច្បាប់ មានន័យថាច្បាប់មិនត្រូវមានភាពរើសអើង និងថា ចៅក្រម និងមន្ត្រីនានា មិនអនុវត្តច្បាប់ ដោយមានការរើសអើង។ សិទ្ធិទទួលបានសមភាពចំពោះមុខតុលាការ មានន័យថា គ្រប់បុគ្គលទាំងអស់ មាសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាពីតុលាការ ហើយមានសិទ្ធិទទួលបានការយកចិត្តទុកដាក់ស្មើគ្នា ពីតុលាការ។

## ធាតុចំបងនានា នៃសិទ្ធិទទួលបានការកាត់ក្តីដោយត្រឹមត្រូវ

- នៅក្នុងនីតិវិធីកាត់ក្តីព្រហ្មទណ្ឌ រដ្ឋប្បវេណី និងក្នុងនីតិវិធីផ្សេងៗទៀត ធាតុជាមូលដ្ឋាននៃសិទ្ធិទទួលបានការកាត់ក្តីដោយត្រឹមត្រូវ ជាគោលការណ៍នៃ "*កម្លាំងតទល់ស្មើភាពគ្នា*" រវាងភាគី និងភាគី និងលក្ខខណ្ឌតម្រូវឱ្យមានសវនាការត្រឹមត្រូវ និងជាសាធារណៈនៅចំពោះមុខអង្គជម្រះក្តីមួយដែលឯករាជ្យ និងឥតលំអៀង។

- "*កម្លាំងតទល់ស្មើភាពគ្នា*" មានន័យថា ភាគីទាំងពីរ-គឺអយ្យការ និងជនជាប់ចោទ នៅក្នុងដំណើរការកាត់ក្តីព្រហ្មទណ្ឌ ឬដើមបណ្តឹង និងចុងចោទនៅក្នុងដំណើរការរឿងស៊ីវិលមានសិទ្ធិ និងមានឱកាសស្មើគ្នាដើម្បីមានវត្តមាននៅក្នុងដំណាក់កាលនានានៃដំណើរការកាត់ក្តី ដើម្បីដឹងឮអំពីអង្គហេតុ និងអំណះអំណាងទាំងឡាយរបស់ភាគីម្ខាងទៀត និងដើម្បីខ្លួនអាចសំដែងអំណះអំណាងរបស់ខ្លួន ជូនដល់តុលាការវិញដែរ។ ដូច្នេះ គោល-ការណ៍នៃ "*កម្លាំងតទល់ស្មើភាពគ្នា*" ទាមទារឱ្យមានការកាត់ក្តី ដោយមានការតតាំងដាក់គ្នា។

- សវនាការ និងសេចក្ដីសម្រេចរបស់តុលាការ ជាទូទៅ ត្រូវធ្វើឡើងជាសាធារណៈ ៖ មិនគ្រាន់តែសម្រាប់ភាគីដែលពាក់ព័ន្ធទៅនឹងសំណុំរឿងប៉ុណ្ណោះទេ តែសម្រាប់សាធារណជនទូទៅផងដែរ ដែលត្រូវតែមានសិទ្ធិមានវត្តមាននៅក្នុងសវនាការនោះ។ គោលបំណងរបស់គោលការណ៍ *សវនាការសាធារណៈ*នេះ គឺតម្លាភាព និងការត្រួតពិនិត្យពីសាធារណជន ដែលជាល័ក្ខខ័ណ្ឌគន្លឹះមួយ សម្រាប់ការគ្រប់គ្រងវិស័យយុត្តិធម៌នៅក្នុងសង្គមប្រជាធិបតេយ្យ។ "*យុត្តិធម៌មិនគ្រាន់តែត្រូវបានសម្រេចប៉ុណ្ណោះទេ គឺថែមទាំងត្រូវធ្វើឱ្យគេឃើញថា បានសម្រេចទៀតផង*"។ ជាគោលការណ៍ទូទៅ ការកាត់ក្ដីមិនត្រូវធ្វើឡើងដោយនីតិវិធីលាយល័ក្ខណ៍អក្សរនៅក្នុងបន្ទប់ស្ងាត់នោះទេ ក៏ប៉ុន្តែដោយមានសវនាការផ្ទាល់មាត់ដែលសាធារណជនមានលទ្ធភាពចូលទៅស្ដាប់បាន។ មិនមែននៅគ្រប់ដំណាក់កាលទាំងអស់ទេ ដែលទាមទារឱ្យមានការស្ដាប់ពី សាធារណជននោះ ជាពិសេសនៅសាលាឧទ្ធរណ៍ ដែលសាធារណៈជន រួមទាំងបណ្ដាញព័ត៌មានផងអាចត្រូវបានគេមិនឱ្យចូលរួម ដោយសារមូលហេតុសីលធម៌ សណ្ដាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ផលប្រយោជន៍ឯកជន និងក្នុងករណីពិសេសនានា គឺដើម្បីមូលហេតុនៃផលប្រយោជន៍យុត្តិធម៌។ ទោះជាយ៉ាងនេះក៏ដោយសេចក្ដីសម្រេចទាំងអស់របស់តុលាការ ត្រូវតែធ្វើឡើងនៅចំពោះមុខសាធារណៈជន ជាសេចក្ដីថ្លែងផ្ទាល់មាត់ ឬដោយការប្រកាសជាលាយល័ក្ខណ៍អក្សរ។

**ប្រអប់ ៦០**

### អង្គជំនុំជម្រះដែលឯករាជ្យ និងមិនលំអៀង: ឯករាជ្យភាពនៃអង្គចៅក្រម

អង្គជំនុំជម្រះ (តុលាការ) ត្រូវតែបានបង្កើតឡើងក្នុងរបៀបមួយ ដែលធានាឱ្យមានឯករាជ្យភាព និងភាពឥតលំអៀង។ ឯករាជភាព តម្រូវឱ្យមានរនាំងការពារនានាទាក់ទិនទៅនឹងរបៀបនៃការតែងតាំងចៅក្រម រយៈពេលសម្រាប់ពួកគេនៅក្នុងតំណែង និងការផ្ដល់កិច្ចធានានូវរនាំងការពារប្រឆាំងនឹងការគៀបសង្កត់ពីខាងក្រៅ។ ភាពឥតលំអៀង

មានន័យថា ក្នុងការជម្រះរឿងក្តីមួយនៅចំពោះមុខខ្លួន ចៅក្រមមិនត្រូវមានភាពលំអៀង ឬត្រូវបានដឹកនាំដោយផលប្រយោជន៍ផ្ទាល់ខ្លួនឬដោយមូលហេតុនយោបាយឡើយ ។ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជភាពនៃអង្គចៅក្រម ផ្តល់នូវគោលការណ៍ណែនាំច្បាស់លាស់ក្នុងផ្នែកនោះ ។

ល័ក្ខខ័ណ្ឌតម្រូវជាមុន សម្រាប់បញ្ញត្តិច្បាប់ ដែលធានានូវឯករាជភាព និងភាពឥតលំអៀងរបស់តុលាការ មានដូចតទៅ:

- ទីមួយ និងមុនគេបំផុត ឯករាជភាពនៃអង្គចៅក្រម គួរត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬនៅក្នុងច្បាប់ជាតិ
- វិធីជ្រើសរើសមន្ត្រីយុត្តិធម៌ គួរត្រូវបានកំណត់អោយមានតុល្យភាពរវាងស្ថាប័ននីតិប្រតិបត្តិ និង អង្គស្ថាប័នឥតលំអៀងដែលភាគច្រើននៃសមាជិកទាំងនោះ គួរត្រូវបានតែងតាំងដោយអង្គការវិជ្ជាជីវៈនានា ដូចជាសហគមន៍អ្នកច្បាប់ជាដើម ។
- ការកាន់មុខតំណែងរបស់ចៅក្រម គួរត្រូវបានធានាឱ្យដល់ពេលចូលនិវត្តតាមការកំណត់ ឬរហូតដល់ពេលចប់អាណត្តិការងាររបស់ខ្លួន
- សេចក្តីសម្រេចលើវិធានការដាក់វិន័យ ការព្យួរ និងការដកចេញចំពោះចៅក្រមណាម្នាក់ គួរត្រូវបានបើកឱ្យមានការពិនិត្យមើលជាថ្មី ដោយស្ថាប័នឯករាជ្យ ។

## សិទ្ធិរបស់ជនជាប់ចោទ នៅក្នុងអង្គជំនុំជម្រះក្តីព្រហ្មទណ្ឌ

បន្ថែមទៅលើសិទ្ធិឱ្យមាន "*កម្លាំងតទល់ស្មើភាពគ្នា*" និងសិទ្ធិឱ្យមានសវនាការជាសាធារណៈ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ បានផ្តល់សិទ្ធិជាក់លាក់មួយចំនួន ដែលបុគ្គលទាំងឡាយ ដែលត្រូវបានគេចោទពីបទឧក្រិដ្ឋ គួរទទួលបាន:

- សិទ្ធិត្រូវបានគេសន្មត់ថាគ្មានទោស ។ អយ្យការត្រូវតែបង្ហាញឱ្យឃើញពីភាពមានទោសរបស់ជននោះ ហើយករណីមានវិមតិសង្ស័យ ជនជាប់ចោទមិនគួរត្រូវបានគេរកឃើញថាមានទោសនោះទេ ហើយត្រូវតែឱ្យរួចខ្លួនពីការចោទប្រកាន់ ។

- សិទ្ធិមិនត្រូវបានបង្ខំឱ្យទទួលឬសារភាពទោស។ ការហាមឃាត់នេះគឺស្របទៅនឹងការសន្មត់ថាគ្មានទោសដែលដាក់បន្ទុកទៅលើអយ្យការ ក្នុងការរកភស្តុតាង ហើយដោយហាមប្រាមការធ្វើទារុណកម្មនិងការធ្វើទុក្ខបុកម្នេញ។ ភស្តុតាងដែលប្រមូលបានពីការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ អាចមិនត្រូវបានយកទៅប្រើក្នុងតុលាការទេ។
- សិទ្ធិការពារខ្លួនឯងដោយផ្ទាល់ ឬតាមរយៈអ្នកប្រឹក្សាយោបល់ ដែលខ្លួនជ្រើសរើស និងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ដោយឥតបង់ប្រាក់
- សិទ្ធិមានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ សម្រាប់ការពារខ្លួនឯង និងសិទ្ធិទាក់ទងជាមួយអ្នកប្រឹក្សាយោបល់របស់ខ្លួន
- សិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យាពេលព្រោះថា "យុត្តិធម៌ដែលត្រូវបានពន្យាពេល គឺជាយុត្តិធម៌ដែលត្រូវបានបដិសេធ"។ ជាគោលការណ៍ ដំណើរការកាត់ក្តីបទព្រហ្មទណ្ឌត្រូវតែធ្វើឱ្យបានលឿនជាងដំណើរការផ្សេងទៀត ជាពិសេសប្រសិនបើជនជាប់ចោទ កំពុងស្ថិតនៅក្នុងការឃុំឃាំង
- សិទ្ធិមានវត្តមាននៅពេលកាត់ក្តី
- សិទ្ធិកោះហៅ និងសាកសួរសាក្សី
- សិទ្ធិទទួលបានការបកប្រែភាសា ដោយឥតគិតថ្លៃ ប្រសិនបើ ជនជាប់ចោទ មិនអាចស្តាប់បាន ឬនិយាយភាសាដែលប្រើនៅក្នុងតុលាការបាន
- សិទ្ធិប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះថ្នាក់ខ្ពស់
- សិទ្ធិមិនត្រូវបានគេកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (បំរាមកាត់ក្តីពីរដង ឬគោលការណ៍ ne bis in idem)
- សិទ្ធិទទួលបានការសងជំងឺចិត្ត នៅក្នុងព្រឹត្តការណ៍នៃភាពខុសឆ្គងនៃយុត្តិធម៌

- គោលការណ៍ nullum crimen sine lege and nulla poena sine lege ហាមឃាត់មិនឱ្យមានប្រតិសកម្មទៅលើច្បាប់ព្រហ្មទណ្ឌ ហើយធានាថា ជនជាប់ចោទ ទទួលផលប្រយោជន៍ពីការដាក់ទោសស្រាលជាង ប្រសិនបើច្បាប់ទាំងនោះចូលជាធរមានក្រោយការប្រព្រឹត្តបទល្មើសនោះ ។

## តុលាការពិសេស និងតុលាការយោធា

តុលាការពិសេស តុលាការវិសាមញ្ញ ឬតុលាការយោធា ត្រូវបានបង្កើតឡើង នៅតាមប្រទេសជាច្រើន ដើម្បីជំនុំជម្រះទៅលើបទល្មើសប្រភេទជាក់លាក់ជាច្រើន ឬដើម្បីជំនុំជម្រះទៅលើជនដែលមានស្ថានភាពផ្លូវច្បាប់ពិសេស ។ ជារឿយៗ តុលាការរបៀបនេះផ្តល់ការធានាតិចជាងតុលាការធម្មតា ក្នុងការកាត់ក្តីដោយត្រឹមត្រូវ ហើយដូចដែលបានគូសបញ្ជាក់ដោយគណៈកម្មាធិការសិទ្ធិមនុស្ស "ជារឿយៗ មូលហេតុដែលនាំឱ្យបង្កើតតុលាការរបៀបនោះ គឺដើម្បីបើកលទ្ធភាពឱ្យអនុវត្តនីតិវិធីពិសេសនានា ដោយមិនធ្វើតាមស្តង់ដារយុត្តិធម៌ធម្មតា" ។ [២៩]

ស្តង់ដារអន្តរជាតិភាគច្រើន មិនហាមឃាត់ នូវការបង្កើតឡើងតុលាការពិសេសនេះទេ ក៏ប៉ុន្តែទាមទារថាតុលាការទាំងនោះត្រូវតែមានសមត្ថភាពឯករាជ្យ និងឥតលំអៀង ហើយថាតុលាការទាំងនោះត្រូវតែមានរនាំងការពារផ្នែកតុលាការ ដែលធានាដល់ដំណើរការកាត់សេចក្តីដោយត្រឹមត្រូវ ។

[២៩] HRC សេចក្តីពន្យល់ទូទៅលេខ ១៣ ឃ្លា ៤

ប្រអប់ ៦១

### ការកាត់ក្តីលើមន្ត្រីយោធា នៅក្នុងតុលាការយោធា ចំពោះបទល្មើសសាមញ្ញ

ការកាត់ក្តីលើមន្ត្រីយោធា នៅក្នុងតុលាការយោធា ចំពោះបទល្មើសសាមញ្ញ និងការរំលោភសិទ្ធិ មនុស្សតែងតែនាំឱ្យជនល្មើសរួចផុតពីការដាក់ទោសទណ្ឌ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកលើការសម្លាប់ក្រៅប្រព័ន្ធតុលាការ ការសម្លាប់មិនតាមនីតិវិធី និងតាមទំនើងចិត្ត បានសំដែងនូវការព្រួយបារម្ភទៅលើរបាយការណ៍នានាស្តីពី "ការកាត់ទោសសមាជិកនៃកងកម្លាំងសន្តិសុខនៅតុលាការយោធា ដែលជាទីកន្លែងដែលត្រូវបានចោទថា ពួកអ្នកទាំងនេះ បានរួចពីការដាក់ទោសទណ្ឌ ដោយសារគេមានស្មារតីរួមក្រុម ដែលជាទូទៅឈានទៅដល់និទណ្ឌភាព"។[៣០] គណៈកម្មការសិទ្ធិមនុស្សអន្តរអាមេរិកាំង បានពិចារណាថា ការពង្រីកយុត្តាធិការរបស់តុលាការយោធាទៅលើបទល្មើសសាមញ្ញៗ ដោយផ្អែកលើមូលដ្ឋានតែមួយថាវាត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលិកយោធានោះ មិនផ្តល់នូវការធានាឱ្យមានតុលាការមួយដែលឯករាជ និងឥតលំអៀងដូចមានចែងនៅក្នុងមាត្រា៨ (១) នៃ ACHRឡើយ។[៣១]

## សិទ្ធិទទួលបានការកាត់ទោសដោយត្រឹមត្រូវក្នុងគ្រាមានអាសន្ន និងនៅក្នុងជម្លោះប្រដាប់អាវុធ

ដូចបាននិយាយនៅក្នុងផ្នែក I សិទ្ធិខ្លះមិនអាចត្រូវបានព្យួរឡើយ ទោះនៅក្រោមកាលៈទេសៈណាក៏ដោយ។ សិទ្ធិទាំងនេះ រួមមានសិទ្ធិទទួលបានការការពារប្រឆាំងនឹងទារុណកម្ម និងប្រឆាំងនឹងការធ្វើប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដែលជាផ្នែកមួយនៃការធានាឱ្យមានការកាត់ក្តីត្រឹមត្រូវ។ បន្ថែមពីលើនេះទៀត មានការស្របមតិគ្នា ជាអន្តរជាតិកាន់តែច្រើនឡើងៗថា

[៣០] ឯកសារអង្គការសហប្រជាជាតិ .A/51/457, para 2.125 ខែតុលា ឆ្នាំ១៩៩៦

[៣១] ដំណោះស្រាយគណៈកម្មការ ១៩៩៤/៣២

ការដកហូតសិទ្ធិទទួលបានការតម្រូវឱ្យមានដីកានាំខ្លួនជនសង្ស័យទៅកាន់តុលាការ ដើម្បីពិនិត្យនីត្យានុកូលភាពនៃការឃុំខ្លួន (habeas corpus) ក៏មិនគួរឱ្យធ្វើទៅបានដែរ។ គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអំពាវនាវដល់គ្រប់រដ្ឋទាំងអស់ឱ្យ "បង្កើតនីតិវិធីមួយ ដូចជា (habeas corpus) ឬក៏នីតិវិធីស្រដៀងគ្នានេះ ទុកជាសិទ្ធិរបស់បុគ្គល ដែលមិនអាចឱ្យដកហូតបាន រួមទាំងក្នុងពេលមានភាពអាសន្ន"។[៣២]

ជាការច្បាស់ណាស់ថា នៅពេលណាមានភាពអាសន្នថ្នាក់ជាតិ រដ្ឋនានាទំនងជានឹងធ្វើការរំលោភទៅលើសិទ្ធិមនុស្ស។ *សភាគួរប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីធានាថា ការធានាឱ្យមានការកាត់ក្ដីត្រឹមត្រូវ និងឯករាជភាពនៃអង្គចៅក្រម ដែលជាអាយុជីវិតដល់ការការពារសិទ្ធិមនុស្ស ត្រូវតែមានផងដែរ នាពេលមានភាពអាសន្នថ្នាក់ជាតិ។*

ច្បាប់មនុស្សធម៌អន្តរជាតិ គ្រប់គ្រងលើការប្រតិបត្តិ នាអំឡុងពេលមានជម្លោះប្រដាប់អាវុធ។ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ បានចែងនូវការធានាឱ្យមានការកាត់ក្ដីត្រឹមត្រូវចំពោះពលរដ្ឋដែលត្រូវបានចោទពីបទឧក្រិដ្ឋ។

## សិទ្ធិទទួលបានភាពឯកជន និងការការពារជីវិតគ្រួសារ

មាត្រា១២ នៃ UDHR

*" គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្ត ទៅក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ។ ជនគ្រប់រូប មានសិទ្ធិទទួលបានការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងនេះ។"*

[៣២] ដំណោះស្រាយគណៈកម្មការ ១៩៩៤/៣២

មាត្រា១៦ នៃ UDHR

*១.បុរស និងស្ត្រីពេញវ័យ មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារ ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ ។ ពួកគេមានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយអាពាហ៍ពិពាហ៍ ។*

*២.អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តី ប្រពន្ធ ។*

*៣.គ្រួសារជាធាតុធម្មជាតិ និងជាធាតុមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ”*

មាត្រា១៧ នៃ ICCPR

*“ ១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។*

*២. ជនគ្រប់រូបមានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ ។ ”*

មាត្រា២៣ នៃ ICCPR

*“ ១. គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ។*

*២. សិទ្ធិរបស់មនុស្សប្រុសស្រីពេញវ័យក្នុងការរៀបអាពាហ៍ពិពាហ៍ និងក្នុងការកសាងគ្រួសារ ត្រូវតែបានទទួលស្គាល់ ។*

*៣. គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រមដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធឡើយ ។*

*រដ្ឋភាគីនៃកតិកាសញ្ញានេះ ត្រូវចាត់វិធានការសមស្រប ដើម្បីធានាសមភាព ខាងសិទ្ធិ និងការទទួលខុសត្រូវរបស់ប្តីប្រពន្ធ ចំពោះការរៀបអាពាហ៍ពិពាហ៍ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។ ក្នុងគ្រាដែលមានការរំលាយអាពាហ៍ពិពាហ៍ ត្រូវមានបទបញ្ញត្តិ សម្រាប់ការការពារជាចំបាច់ចំពោះកូន ។"*

សិទ្ធិទទួលបានភាពឯកជន គឺជាស្នូលចំពោះសញ្ញាណនៃសេរីភាព និងស្វ័យភាពរបស់បុគ្គល ។ បញ្ហាចម្រូងចម្រាស់ជាច្រើនបានកើតឡើង នៅក្នុងបរិបទនៃវិវាទទាក់ទិននឹងភាពឯកជនរបស់មនុស្ស ដូចជាការជ្រៀតជ្រែករបស់រដ្ឋទៅលើប្រតិព័ទ្ធរវាងមនុស្សដែលមានភេទដូចគ្នា ប្រតិព័ទ្ធរវាងមនុស្សប្តូរភេទ ពេស្យាកម្ម ការរំលូតកូន ការធ្វើអត្តឃាត (ដែលមានអ្នកជួយ) របៀបស្លៀកពាក់ និងក្រមសីលធម៌ស្រដៀងគ្នា ការប្រាស្រ័យទាក់ទងគ្នាជាឯកជន អាពាហ៍ពិពាហ៍ និងការលែងលះ សិទ្ធិលើការបន្តពូជ ការផ្លាស់ប្តូររបៀបរៀន ការចម្លងសរីរៈ និងការបំបែកកូនពីឪពុកម្តាយដោយបង្ខំ បានប៉ះពាល់ទៅលើមូលដ្ឋាននៃបញ្ហាគុណតម្លៃផ្លូវចិត្ត និងភាពត្រឹមត្រូវតាមសីលធម៌ដែលត្រូវបានគេមើលឃើញខុសពីគ្នានៅក្នុងសង្គមទីទៃៗពីគ្នា ។ បន្ថែមលើនេះទៅទៀត គោលគំនិតសេរីនៃភាពជាឯកជនមានមូលដ្ឋានលើការបែកចេញជាពីរផ្សេងគ្នារវាងផ្នែកឯកជន និងផ្នែកសាធារណៈ ហើយផ្អែកលើទស្សនៈវិជ្ជាដែលថា រដ្ឋាភិបាល មិនគួរជ្រៀតជ្រែកទៅក្នុងស្ថានភាពឯកជនដ៏ចាំបាច់ និងបញ្ហាគ្រួសារឡើយ ។ ទោះជាយ៉ាងនេះក៏ដោយ វាជាការពិតណាស់ដែលថា ភាពបែកជាពីរផ្សេងគ្នានេះត្រូវបានតបតវិញដោយផ្ទាល់ដែលភាគច្រើនលើសលុបដោយទ្រឹស្តីស្ត្រីនិយមបែបទំនើប និងត្រូវបានស្តីបន្ទោសចំពោះការរំលោភបំពានធំៗទៅលើសិទ្ធិមនុស្សរបស់ស្ត្រី និងកុមារ ដោយរួមទាំងអំពើហឹង្សានៅក្នុងគ្រួសារ និងការកាត់ព្រហ្មចារីស្ត្រី (FGM) ផងដែរ ។

## សិទ្ធិទទួលបាននូវភាពឯកជន ៖ ជាសិទ្ធិមនុស្សដ៏ស្មុគស្មាញ និងដែលមានច្រើនប្រភេទ

សិទ្ធិនេះធានានូវ៖

- ការគោរពចំពោះការកកើតឡើងនៃមនុស្សជាតិនីមួយៗ ដូចជា សារជាតិដោយឡែករបស់ស្ត្រី ឬបុរស លក្ខណៈពិសេស អាការខាងក្រៅ កិត្តិយស និងកេរ្តិ៍ឈ្មោះជាដើម ។
- ការការពារស្វ័យភាពរបស់បុគ្គល និងផ្តល់អំណាចជូនបុគ្គលទាំងឡាយ ក្នុងការផ្តាច់ចេញខ្លួនពួកគេពីមនុស្សផ្សេងទៀត និងដកខ្លួនចេញពីជីវិតសាធារណៈ ចូលទៅក្នុងកន្លែងឯកជនផ្ទាល់ខ្លួន ដើម្បីកំណត់ជោគវាសនាជីវិតរបស់ខ្លួនពួកគេផ្ទាល់ ស្របទៅតាមសេចក្តីប្រាថ្នា និងសេចក្តីរំពឹងទុករបស់ពួកគេ ។ ការធានាជាស្ថាប័នមួយចំនួន ដូចជា ការការពារទៅលើ*លំនៅដ្ឋាន គ្រួសារ អាពាហ៍ពិពាហ៍* និង*ភាពសម្ងាត់ក្នុងការទាក់ទងគ្នា* គាំទ្រទៅលើទិដ្ឋភាពនៃសិទ្ធិឯកជន ។
- សិទ្ធិនេះ រួមបញ្ចូលនូវសិទ្ធិក្នុងការធ្វើឱ្យខ្លួនខុសប្លែកពីគេ និងក្នុងការបង្ហាញភាពខុសពីគេរបស់ខ្លួននៅចំពោះមុខសាធារណជន ដោយអាកប្បកិរិយាដែលបញ្ច្រាសទៅនឹងផ្នត់គំនិតដែលត្រូវបានគេទទួលស្គាល់រួចហើយ នៅក្នុងសង្គម និងបរិយាកាសណាមួយ ។ ដូច្នេះហើយ អាជ្ញាធរនានារបស់រដ្ឋាភិបាល និងអង្គការសិទ្ធិមនុស្សអន្តរជាតិ ប្រឈមមុខទៅនឹងភារកិច្ចដែលពិបាកនឹងដោះស្រាយ ក្នុងការ*ធ្វើឱ្យមានតុល្យភាព* រវាងសិទ្ធិឯកជន និងផលប្រយោជន៍សាធារណៈដែលត្រឹមត្រូវតាមច្បាប់ ដូចជា ការការពារសណ្តាប់ធ្នាប់សាធារណៈ សុខភាព សីលធម៌ និងសិទ្ធិ និងសេរីភាពរបស់អ្នកឯទៀត ។

កថាខ័ណ្ឌខាងក្រោមនេះ ផ្តោតទៅលើតែទិដ្ឋភាព ដែលលេចធ្លោខ្លះៗ នៃសិទ្ធិឯកជន ក្នុងចំណោមទិដ្ឋភាពសំខាន់ៗ តែប៉ុណ្ណោះ ។ ដោយយល់ទៅលើភាពចម្រូងចម្រាស់ នៃរឿងភាគច្រើន ដែលពាក់ព័ន្ធការផ្តល់ចម្លើយឱ្យបានជាក់ច្បាស់ តែងតែមិនអាចធ្វើទៅបាន

ដោយហេតុថា ចម្លើយទាំងនោះ អាស្រ័យទៅលើការថ្លឹងថ្លែង ដោយប្រុងប្រយ័ត្ន លើផលប្រយោជន៍ទាំងឡាយ នៅតាមករណីនីមួយៗដោយមានការពិចារណាលើកាលៈទេសៈពិសេសនានា ដែលមាននៅក្នុងសង្គមនីមួយៗ។

## ទិដ្ឋភាពចំបងៗនៃសិទ្ធិទទួលបានភាពឯកជន

### *រក្សាការពារអត្តសញ្ញាណ និងភាពស្និទស្នាល*

ភាពជាឯកជន ផ្ដើមចេញពីការគោរពអត្តសញ្ញាណជាក់លាក់ របស់បុគ្គលម្នាក់ៗ ដែលរួមមានឈ្មោះ អាការខាងក្រៅ សំលៀកបំពាក់ ម៉ូតសក់ យ៉េនឌ័រ អារម្មណ៍ ការរិះគិត និងការគោរពបូជា ទៅលើសាសនា និងលើអ្វីៗផ្សេងទៀត។ ការដាក់វិន័យជាកំហិត លើសំលៀកបំពាក់ ឬលើម៉ូតសក់ ការកែប្រែដោយបង្ខំ ឬការមិនទទួលស្គាល់ទៅលើការប្ដូរឈ្មោះ សាសនា ឬយ៉េនឌ័រ (ឧទាហរណ៍ ការបដិសេធរបស់រដ្ឋ ក្នុងការកែប្រែការចុះបញ្ជីកំណើតរបស់ជនដែលប្ដូរភេទ) ឬរាល់ទម្រង់នៃការបញ្ចូលមនោគមវិជ្ជា ("ការលាងខួរក្បាល") ឬការកែប្រែរាងកាយដោយបង្ខំ ជាការជ្រៀតជ្រែកលើសិទ្ធិឯកជន។ ភាពស្និទ្ធស្នាលរបស់បុគ្គល ត្រូវតែបានការពារ ដោយគោរពចំពោះកាតព្វកិច្ចក្នុងការរក្សាភាពអាថិកំបាំង ដែលមានការទទួលស្គាល់ជាទូទៅ(ដូចជាករណីទាក់ទិនដល់គ្រូពេទ្យ និងបុព្វជិតជាដើម) និងការធានាដល់ការលាក់អាថិកំបាំង (ដូចជា ក្នុងអំឡុងពេលធ្វើការបោះឆ្នោត) ហើយដោយធ្វើច្បាប់ការពារទិន្នន័យឱ្យបានសមរម្យជាមួយសិទ្ធិដែលអាចអនុវត្តបាន ក្នុងការទទួលព័ត៌មានការកែតម្រូវ និងការលុបចេញទិន្នន័យផ្ទាល់ខ្លួន។

*ការការពារស្វ័យភាពបុគ្គល*

ទំហំបរិវេណនៃស្វ័យភាព ដែលត្រូវការពារដោយសិទ្ធិឯកជន គឺជាបញ្ហាដ៏ចម្រូងចម្រាសមួយ។ ស្វ័យភាពបុគ្គល ដូចជា ក្នុងវិស័យនៃជីវិតឯកជន ដែលក្នុងនោះ មនុស្សជាតិ

ខិតខំព្យាយាមដើម្បីឱ្យសម្រេចបាននូវអ្វីៗដែលខ្លួនចង់ធ្វើដោយខ្លួនឯង តាមរយៈ *អំពើ* ដែលមិនជ្រៀតជ្រែកដល់សិទ្ធិអ្នកដទៃ – គឺជាស្នូលទៅនឹងគំនិតសេរីនៃភាពជាឯកជន ។ ជាគោលការណ៍ស្វ័យភាព បណ្តាលឱ្យមានសិទ្ធិក្នុងការគ្រប់គ្រងលើរាងកាយខ្លួនឯង ដែលមានផងដែរនូវសិទ្ធិមួយ ក្នុងការធ្វើអំពើ ក្នុងលក្ខណៈបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពខ្លួនឯង ដោយរួមទាំងការធ្វើអត្តឃាតផង ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ សង្គមមនុស្សមានទស្សនៈដោយឥតប្រែប្រួលថា ការប្រព្រឹត្តបែបនេះ មានគ្រោះថ្នាក់ដល់ផលប្រយោជន៍រួម និងសីលធម៌ ហើយតែងតែហាមឃាត់ និងដាក់ទោសចំពោះការប្រព្រឹត្តរបៀបនេះ (ឧទាហរណ៍ ការធ្វើអត្តឃាតដោយមានការជួយ និងការសេពគ្រឿងញៀន គ្រឿងស្រវឹង និងសេពជាតិនីកូទីនជាដើម) ។ សួរថាតើសិទ្ធិរបស់ស្ត្រីទៅលើរាងកាយរបស់គាត់ អាចនាំឱ្យមានសិទ្ធិលើការរំលូតកូនគាត់ដែរឬទេ គឺជាសំណួរដែលមានការប្រកែកប្រណាំងគ្នា ដែលសំណួរនេះ ទទួលបានចម្លើយផ្សេងៗគ្នា ពីតុលាការកំពូល និងតុលាការធម្មនុញ្ញផ្សេងគ្នា ។ សិទ្ធិមានភាពជាឯកជន ក៏មានន័យជាប់ទៅនឹងសិទ្ធិរបស់បុគ្គលណាម្នាក់ ក្នុងការទាក់ទងជាមួយអ្នកដទៃទៀតផងដែរ ដោយរួមទាំងសិទ្ធិបង្កើតចំណងទាក់ទងខាងផ្លូវអារម្មណ៍ជាដើម ។ សិទ្ធិទទួលបានស្វ័យភាពផ្លូវភេទ និងទំនាក់ទំនងផ្លូវភេទ មានសារៈសំខាន់បំផុត ហើយរដ្ឋាភិបាល ត្រូវតែប្រុងប្រយ័ត្ន ជាពិសេស នៅពេលដែលធ្វើការជ្រៀតជ្រែកទៅក្នុងរឿងផ្លូវភេទ ។

ប្រអប់ ៦២

### តើ “*គ្រួសារ*” មានន័យដូចម្តេចខ្លះ នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

បន្ថែមទៅលើការគាំទ្រ នៅក្រោមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ស្ថាប័នរបស់គ្រួសារ ដូចជា “ក្រុមនៃផ្នែកសង្គមដែលមានលក្ខណៈជាធម្មជាតិ និងជាមូលដ្ឋាន” ទទួលបានការការពារជាពិសេសនៅក្រោមមាត្រា២៣នៃ ICCPR មាត្រា១០នៃ ICESCR មាត្រា១៦នៃធម្មនុញ្ញអឺរ៉ុបផ្នែកសង្គមកិច្ច មាត្រា៨នៃ ECHR មាត្រា១៧នៃACHR និងមាត្រា

១៨នៃធម្មនុញ្ញអាហ្វ្រិកសម្រាប់សិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ។ លំដាប់ឈ្មោះដ៏ច្រើននេះចង្អុលបង្ហាញថា អត្ថន័យរបស់ពាក្យ " គ្រួសារ " បានទៅហួសគោលគំនិតនៃគ្រួសារដែលមានឪពុក-ម្ដាយ និងកូន ដែលមានជាទូទៅ នៅក្នុងប្រទេសឧស្សាហកម្មជឿនលឿននានា ហើយបានផ្ដោតជុំវិញគ្រួសារធំៗ ដែលចែកចេញជាផ្នែកច្រើនជាង ដូចជាគ្រួសារ ដែលមានឪពុកម្ដាយជីដូនជីតា និងកូនចៅរស់នៅជុំគ្នាក្រោមដំបូលតែមួយ ឧទាហរណ៍ ដូចជាគ្រួសារនៅក្នុងសង្គមអាហ្វ្រិកជាដើម។ បន្ថែមទៅលើចំណងទាក់ទងសាច់ឈាម និងទំនាក់ទំនងតាមផ្លូវច្បាប់ (ដូចជាអាពាហ៍ពិពាហ៍ ការយកកូនមកចិញ្ចឹម ការចុះបញ្ជីលើក្រុមប្រតិព័ទ្ធភេទដូចគ្នា។ល។) ការរួមរស់ជាមួយគ្នា ទំនាក់ទំនងផ្នែកសេដ្ឋកិច្ច និងគុណតម្លៃសង្គម និងវប្បធម៌ ជាក់លាក់នៅក្នុងសង្គមណាមួយ ជាលក្ខណៈវិនិច្ឆ័យគន្លឹះ ដែលបានប្រើប្រាស់ដើម្បីកំណត់ថាតើ ក្រុមដែលមានប្រភេទទំនាក់ទំនងណាមួយរវាងមនុស្ស និងមនុស្សបង្កើតបានជាគ្រួសារមួយដែរឬទេ។

## *ការការពារគ្រួសារ*

ការការពារគ្រួសារមានសារៈសំខាន់ចំពោះសិទ្ធិទទួលបានភាពឯកជន។ ការធានារបស់ស្ថាប័នចំពោះគ្រួសារ (ដូចជា ការទទួលស្គាល់តាមផ្លូវច្បាប់ និងអត្ថប្រយោជន៍ជាក់លាក់ដែលកើតចេញពីស្ថានភាពនោះ ហើយនិងបទដ្ឋាននៃទំនាក់ទំនងផ្លូវច្បាប់រវាងប្ដីប្រពន្ធដៃគូ ឪពុក-ម្ដាយ និងកូន។ល។) គឺមានបំណងដើម្បីការពារសណ្ដាប់ធ្នាប់សង្គមពីនិន្នាការដែលឆ្ពោះទៅរកការបែកបាក់គ្នា និងដើម្បីថែរក្សាមុខនាទីជាក់លាក់របស់គ្រួសារ (ដូចជាការបន្តពូជ និងការបីបាច់ថែរក្សាកូន) - ដែលជាកត្តា ដែលមិនអាចខ្វះបានចំពោះការរស់រានមានជីវិតរបស់សង្គម ជាជាងបណ្ដោយឱ្យមានការផ្ទេរតួនាទីនេះ ទៅឱ្យស្ថាប័នសង្គមផ្សេងទៀត ឬក៏ទៅរដ្ឋ។ សិទ្ធិមនុស្សក្នុងការរៀបអាពាហ៍ពិពាហ៍ និងបង្កបង្កើតជាគ្រួសារមួយ រួមទាំងសិទ្ធិបន្តពូជ សិទ្ធិទទួលភាពស្មើភាពគ្នារវាងប្ដីប្រពន្ធ សិទ្ធិទទួលបានការការពារមាតុភាព និងសិទ្ធិពិសេសរបស់កូនៗ ដូចមានចែងនៅក្នុង CRC ត្រូវបានភ្ជាប់ផ្ទាល់ ទៅនឹងការធានា

ស្ថាប័នរបស់គ្រួសារ។ សិទ្ធិរបស់កូនក្នុងការមិនអាចបំបែកបានពីឪពុក-ម្តាយគេ ការទទួលខុសត្រូវរួមរបស់ឪពុកម្តាយ ដើម្បីចិញ្ចឹមកូន និងការអភិវឌ្ឍរបស់កូន និងសិទ្ធិ ក្នុងការជួបជុំគ្រួសារ សិទ្ធិឱ្យកូនទៅគេចិញ្ចឹម និងសិទ្ធិយកកូនគេមកចិញ្ចឹម មានសារៈសំខាន់ជាទីបំផុត។

សិទ្ធិទទួលបានភាពឯកជន នាំមកនូវការការពារលើជីវិតគ្រួសារ ប្រឆាំងនឹងការជ្រៀតជ្រែក ដោយបំពាន និងមិនត្រូវតាមច្បាប់ ជាពិសេស ដោយអាជ្ញាធររបស់រដ្ឋ ។ ការជ្រៀតជ្រែកជាតួយ៉ាងមួយ គឺការតម្រូវឱ្យបំបែកកូនចេញពីឪពុកម្តាយរបស់ពួកគេ ដោយមូលហេតុថា ឪពុកម្តាយ មិនយកចិត្តទុកដាក់លើភារកិច្ចខ្លួនដែលជាឪពុកម្តាយ និងដាក់កូនទាំងនោះឱ្យនៅក្រោមការថែទាំរបស់រដ្ឋ។ ក្រោយពីបានពិនិត្យសំណុំរឿងមួយចំនួនមក តុលាការសិទ្ធិមនុស្សអឺរ៉ុប បានបង្កើតនូវយន្តការធានាអប្បបរិមាមួយចំនួន សម្រាប់ឪពុក-ម្តាយ និងកូន១ ដែលពាក់ព័ន្ធ ដូចជា ការចូលរួមនៅក្នុងដំណើរការរដ្ឋបាល ពាក់ព័ន្ធការពិនិត្យមើលរបស់តុលាការ និងការទាក់ទងគ្នាជាទៀងទាត់រវាងឪពុកម្តាយនិងកូននៅអំឡុងពេលនៃការដាក់ពួកគេនៅកន្លែងថែទាំ ដើម្បីអនុញ្ញាតឱ្យមានការជួបជុំគ្រួសារឡើងវិញ។ ដូចគ្នានេះដែរ បន្ទាប់ពីការលែងលះគ្នា ប្តីប្រពន្ធទាំងពីរនាក់ រក្សាសិទ្ធិក្នុងការទៅជួបកូនរបស់ពួកគេ។

## ***ការការពារលំនៅដ្ឋាន***

ការការពារលំនៅដ្ឋាន ជាទិដ្ឋភាពដ៏សំខាន់មួយទៀតនៃភាពជាឯកជន ដោយសារថាលំនៅដ្ឋាន មានជាប់នូវអារម្មណ៍មួយនៃភាពស្និទ្ធស្នាល ទីជម្រក និងសន្តិសុខ ដូច្នេះ វាជានិមិត្តរូប នៃកន្លែងជ្រកកោនមួយ សម្រាប់គេចចេញពីជីវិតជាសាធារណៈ ដែលគេអាចរៀបចំជីវិតរបស់គេ តាមសេចក្តីប្រាថ្នារបស់ខ្លួនដោយពុំភ័យខ្លាចដល់ការរំខាន។ ក្នុងការអនុវត្តជាក់ស្តែង “លំនៅដ្ឋាន” មិនគ្រាន់តែសំដៅទៅលើទីអាស្រ័យនៅជាក់ស្តែងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំដៅទៅលើផ្ទះ ឬអាគារផ្ទះល្វែងនានា ដោយមិនគិតពីកម្មសិទ្ធិតាមផ្លូវច្បាប់( ម្ចាស់កម្មសិទ្ធិ ការជួល ការកាន់កាប់និងថែមទាំងការប្រើប្រាស់

ដោយខុសច្បាប់) ឬមិនគិតពីរបៀបនៃការប្រើប្រាស់ (កន្លែងរស់នៅជាចំបង ផ្ទះសម្រាកចុងសប្តាហ៍ ឬជាកន្លែងប្រកបអាជីវកម្ម)។ ការចូលលុកលុយទៅក្នុងកន្លែងទាំងនោះ - ដែលពណ៌នានៅក្រោមពាក្យថា "លំនៅដ្ឋាន" - ដែលកើតឡើងដោយមិនមានការយល់ព្រមពីបុគ្គល ដែលពាក់ព័ន្ធ គឺជាការជ្រៀតជ្រែកមួយ។ ទម្រង់ធម្មតានៃការជ្រៀតជ្រែក គឺការឆែកឆេររបស់ប៉ូលីស ដើម្បីរុករក និងចាប់ខ្លួនជនណាមួយ ឬក៏រកភស្តុតាង ដើម្បីយកទៅប្រើនៅក្នុងដំណើរការជម្រះក្តីរឿងព្រហ្មទណ្ឌ។ ប៉ុន្តែ នេះមិនមែនជាប្រភេទតែមួយនៃការជ្រៀតជ្រែកនោះទេ។ ការបំផ្លាញផ្ទះដោយកម្លាំងសន្តិសុខ ការបណ្តេញចេញដោយបង្ខំ ការប្រើកាមេរ៉ា ឬប្រដាប់ស្តាប់ដោយលាក់មិនឱ្យគេឃើញ ការអនុវត្ត ការតាមដានមើលដោយប្រព័ន្ធអេឡិចត្រូនិក ឬទម្រង់ដ៏អាក្រក់នៃការបំពុលបរិស្ថាន (ដូចជាសម្លេងថ្លង់ ឬផ្សែងពុលជាដើម) អាចបង្កើតជាការជ្រៀតជ្រែករំខាន ទៅលើសិទ្ធិទទួលបានការការពារលំនៅដ្ឋាន។ ការជ្រៀតជ្រែកប្រភេទនេះ អាចអនុញ្ញាតិឱ្យធ្វើបាន ប្រសិនបើអនុវត្តតាមច្បាប់ក្នុងស្រុក ហើយដោយមិនធ្វើតាមតែអំពើចិត្ត ដូចជា ប្រសិនបើវាកើតឡើងក្នុងគោលបំណងជាក់លាក់ និងដោយស្របជាមួយគោលការណ៍សមាមាត្រ។ ការឆែកឆេររបស់ប៉ូលីស ការរឹបអូស និងការតាមដានមើលជាធម្មតា ត្រូវបានអនុញ្ញាតិឱ្យធ្វើទៅបាន តែដោយផ្អែកលើមូលដ្ឋាននៃដីកាជាលាយល័ក្ខណ៍អក្សរ ដែលចេញឱ្យដោយតុលាការតែប៉ុណ្ណោះ ហើយមិនត្រូវប្រើដោយមិនត្រឹមត្រូវ ឬបង្កើតឱ្យមានការរំខាន ហួសពីការបំពេញគោលបំណងជាក់លាក់មួយ ដូចជាការរក្សាឱ្យបាននូវភស្តុតាងជាដើម។

**ប្រអប់ ៦៣**

## កម្រិតព្រំដែនលើការជ្រៀតជ្រែករបស់រដ្ឋ ទៅលើជីវិតគ្រួសារ ទាក់ទិនទៅនឹងច្បាប់ និង គោលនយោបាយស្តីពីអន្តោប្រវេសន៍ ការបណ្តេញចេញ និរទេស និងបត្យាប័ន

ទោះបីជាពុំមានសិទ្ធិជាទូទៅរបស់ជនបរទេសក្នុងការចូល និងស្នាក់នៅក្នុងប្រទេសមួយក៏ដោយគោលនយោបាយអន្តោប្រវេសន៍ដែលធ្វើតាមតែអំពើចិត្ត និងដោយរើសអើង គឺរំលោភទៅលើសិទ្ធិនៃការទទួលបានការការពារ និងជួបជុំគ្រួសារ។ កាលណាជនបរទេសម្នាក់បានរស់នៅក្នុងប្រទេសបានកាន់តែយូរ ជាពិសេសបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ និងបានបង្កើតបានជាគ្រួសារនោះ រដ្ឋាភិបាលត្រូវតែមានអំណះអំណាងកាន់តែច្រើនខ្លាំងឡើង ដើម្បីបង្ហាញភាពសមហេតុផលលើការបណ្តេញចេញ និងនិរទេសចេញពីប្រទេសទៅលើជននោះ។ ជាឧទាហរណ៍ នៅក្នុងករណីរបស់ *Berrehab ទល់ជាមួយនឹងប្រទេសហុល្លង់* (១៩៨៨) ក្រុមប្រឹក្សាសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា ហេតុការណ៍លែងលះពីប្រពន្ធជនជាតិហូឡង់របស់គាត់មិនអាចជាអំណះអំណាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ភាពសមហេតុផលទៅលើការបណ្តេញចេញបុរសជនជាតិម៉ូរ៉ុកម្នាក់នេះដែលគាត់បានរក្សាទំនាក់ទំនងជាមួយកូនស្រីគាត់នៅក្នុងប្រទេសហូឡង់។ ម្យ៉ាងវិញទៀត ប្រសិនបើសិទ្ធិទទួលបាននូវជីវិតគ្រួសារនៃជនបរទេសម្នាក់ត្រូវបានយកទៅថ្លឹងថ្លែងជាមួយនឹងផលប្រយោជន៍ធម្មានុភាពរបស់រដ្ឋ ដូចជាការទប់ស្កាត់ សណ្តាប់ធ្នាប់មិនល្អ ឬឧក្រិដ្ឋកម្មនោះ អំពើឧក្រិដ្ឋធ្ងន់ធ្ងររបស់បុគ្គលដែលជាជនសង្ស័យនោះ ជាធម្មតានឹងត្រូវយកជាមូលហេតុគ្រប់គ្រាន់ដើម្បីបញ្ជាក់ភាពសមហេតុផលដល់ការបំបែកគ្រួសារនោះ ទោះបីជាមានការស្នាក់នៅក្នុងប្រទេសយូរហើយក៏ដោយ។ ទាល់តែមានករណីពិសេសមែនទែន ដែលជនអន្តោប្រវេស្តន៍ជំនាន់ទីពីរ ដោយពិតជាពុំមានជាប់ជំពាក់នឹងប្រទេសដើមកំណើតរបស់ខ្លួន ឬក្នុងករណីបុគ្គលមានពិការភាព និងជំងឺធ្ងន់ធ្ងរប៉ុណ្ណោះ ទើបតុលាការអឺរ៉ុបរកឃើញថា មានការរំលោភលើសិទ្ធិនៃជីវិតគ្រួសារ។ បើនិយាយឱ្យចំទៅ រដ្ឋមានឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការអនុវត្តគោលនយោបាយទាក់ទិនទៅនឹងជនបរទេស ក៏ប៉ុន្តែរដ្ឋទាំងនោះត្រូវថ្លឹងថ្លែងរកតុល្យភាពរវាង

ផលប្រយោជន៍សាធារណៈជាធម្មានុភាព និងល័ក្ខខ័ណ្ឌតម្រូវដើម្បីការពារជីវិតគ្រួសារ និង កាលៈទេសៈឯកជនផ្សេងទៀត ដូចជាការកាន់កាប់ជាទៀងទាត់ ឬទ្រព្យសម្បត្តិ ឬភាពជាម្ចាស់លើលំនៅដ្ឋាន នៅក្នុងប្រទេសដែលខ្លួនកំពុងរស់នៅ។

## *កិច្ចការពារចំពោះការឆ្លើយឆ្លងជាឯកជន*

ទោះបីជាពាក្យ "ឆ្លើយឆ្លង" កាលពីដំបូងឡើង ត្រូវបានគេប្រើប្រាស់តែទៅលើសំបុត្រជាលាយល័ក្ខអក្សរក៏ដោយ ក៏នាពេលបច្ចុប្បន្ននេះ វាគ្របដណ្តប់ទៅលើគ្រប់ទម្រង់ទាំងអស់នៃទំនាក់ទំនងដែលមានចម្ងាយពីគ្នាៈ ដោយទូរស័ព្ទ ខ្សែកាប តេឡិច ហ្វាក់ សំបុត្រផ្ញើតាមអេឡិចត្រូនិច ឬមធ្យោបាយមេកានិច ឬអេឡិចត្រូនិចទាំងអស់។ ការការពារការឆ្លើយឆ្លង មានន័យថាការគោរពលើភាពសម្ងាត់របស់ការទាក់ទងឆ្លើយឆ្លងបែបហ្នឹង។ ការដកហូតទុក ការចាប់ពិរុទ្ធ ការត្រួតពិនិត្យ ការស្កាត់ចាប់សម្លេង ឬការបោះពុម្ពអ្វីៗដែលជាការឆ្លើយឆ្លងឯកជន គឺជាការជ្រៀតជ្រែក។ ទម្រង់សាមញ្ញបំផុតនៃការជ្រៀតជ្រែករបៀបនេះ គឺវិធានការតាមដានមើលដោយសម្ងាត់ដែលធ្វើឡើងដោយភ្នាក់ងាររបស់រដ្ឋ(ដូចជា ការបើកសំបុត្រ ការតាមដានការ សន្ទនាតាមទូរស័ព្ទ និងការស្កាត់ចាប់ការផ្ញើលិខិត តាមហ្វាក់ និងអ៊ីមែល។ល។) សម្រាប់គោលបំណងគ្រប់គ្រងយុត្តិធម៌និងទប់ស្កាត់ឧក្រិដ្ឋកម្ម (ឧទាហរណ៍ តាមរយៈការឆែកមើល ការឆ្លើយឆ្លងរបស់អ្នកទោស) ឬការប្រយុទ្ធប្រឆាំងភេរវកម្ម។ ដូចករណីឆែកឆេរផ្ទះដែរ ការជ្រៀតជ្រែកទៅលើការឆ្លើយឆ្លង ត្រូវតែអនុលោមទៅតាមច្បាប់ក្នុងស្រុក (គឺថា តាមច្បាប់វាទាមទារឱ្យមានបញ្ជាពីតុលាការ) និងអនុលោមតាមគោលការណ៍សមមាត្រ។

ប្រអប់ ៦៤

## សិទ្ធិទទួលបានភាពឯកជន និងការប្រយុទ្ធប្រឆាំងភេរវកម្ម

សិទ្ធិទទួលបានភាពឯកជនត្រូវបានទទួលការប៉ះពាល់យ៉ាងដំណំដោយសារច្បាប់នានា ដែលត្រូវបានធ្វើឡើងនាពេលថ្មីៗនេះនៅប្រទេសជាច្រើនដើម្បីពង្រីកអំណាចប៉ូលីសនិងអំណាចសេវាស៊ើបការណ៍ដើម្បីប្រយុទ្ធប្រឆាំងភេរវកម្ម។ ជាបន្ថែមទៅលើការពង្រីកទំហំមុខនាទីជាប្រពៃណីរបស់ប៉ូលីស ដូចជាការឆែកឆេរ ការរឹបអូស និងការតាមដានពិនិត្យ (តែងតែធ្វើឡើយដោយពុំមានការអនុញ្ញាតពីតុលាការ) ឧទាហរណ៍ជាក់ស្តែង រួមមានការតាមដានពិនិត្យដោយដាក់គ្រឿងអេឡិចត្រូនិចសម្រាប់ឃ្លាំមើល "កន្លែងដេកពួន" និងភេរវជនដ៏មានសក្តានុពលឯទៀតៗ តាមមធ្យោបាយពិនិត្យជ្រើសរើសការឆ្លុះ ពិនិត្យ ការវិភាគ ការចាប់បញ្ចូលគ្នា ការដាក់ផ្ទួរផ្គងគ្នា ការផ្ទុក និងតាមដានលើទិន្នន័យឯកជនដ៏ច្រើនសន្ធឹកសន្ធាប់ ហើយនិងប្រើវិធីស្វ័យប្រវត្តិសម្រាប់ចាប់យកស្នាមក្រយៅដៃ និងយកឈាម និងDNA ពីក្រុមគោលដៅ ដែលតែងតែត្រូវបានជ្រើសរើសតាមរយៈសាវតានៃជាតិសាសន៍។

នៅក្នុងវិស័យនេះ(ក៏ដូចជាក្នុងវិស័យសិទ្ធិមនុស្សផ្សេងទៀត ដូចជា សិទ្ធិមានសេរីភាពផ្ទាល់ខ្លួន និងសិទ្ធិទទួលបានការកាត់ទោសត្រឹមត្រូវ) *សមាជិកសភាមានតួនាទីស្នូលមួយ*: គឺត្រូវតែធានាថាការពង្រីកអំណាចប៉ូលីស និងអំណាចអ្នកស៊ើបការណ៍សម្ងាត់ ប្រសិនជាការចាំបាច់ណាស់ត្រូវធ្វើឡើងដោយ:

១. មានតម្លាភាព និងប្រជាធិបតេយ្យភាព
២. មានការគោរពយ៉ាងត្រឹមត្រូវដល់ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ
៣. មិនធ្វើឱ្យអន់ថយដល់គុណតម្លៃដ៏ថ្លៃថ្លារបស់សង្គមសេរី និងប្រជាធិបតេយ្យ : គឺសេរីភាពរបស់បុគ្គលម្នាក់ៗ និងនីតិរដ្ឋ។

## សេរីភាពក្នុងការធ្វើដំណើរ

មាត្រា១៣ នៃ UDHR

*“ ១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ ។*

*២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ” ។*

មាត្រា១២ នៃ ICCPR

*“ ១. ជនណាដែលរស់នៅត្រឹមត្រូវតាមលក្ខណៈច្បាប់ ក្នុងប្រទេសណាមួយ មានសិទ្ធិធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួនដោយសេរី ។*

*២. ជនគ្រប់រូប មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង ។*

*៣. សិទ្ធិដែលបានចែងខាងលើនេះ មិនត្រូវមានការរិតត្បិតឡើយ លើកលែងតែការរិតត្បិតនេះ មានចែងក្នុងច្បាប់ចាំបាច់ ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពអ្នកដទៃ ហើយមិនទំនាស់ជាមួយសិទ្ធិដទៃទៀត ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ។*

*គ្មានជនណាម្នាក់ ត្រូវបានដកសិទ្ធិតាមអំពើចិត្ត មិនឱ្យចូលក្នុងប្រទេសរបស់ខ្លួន ឡើយ ។”*

មាត្រា១៣ នៃ ICCPR

*“ ជនបរទេសឋិតនៅស្របច្បាប់លើដែនដីរដ្ឋភាគីនៃកតិកាសញ្ញានេះ អាចនឹងត្រូវបានបណ្តេញចេញពីរដ្ឋនោះបាន លុះត្រាតែធ្វើឡើងដោយអនុលោមតាមសេចក្តីសម្រេចស្របច្បាប់ ហើយបើការបណ្តេញចេញនេះ មិនមានហេតុផលសម្រាប់រក្សាសន្តិសុខជាតិ*

*ដែលតម្រូវឱ្យបណ្តេញទេ ជនបរទេសនេះ ត្រូវបានអនុញ្ញាតឱ្យដាក់អំណះអំណាងជំទាស់នឹងការបណ្តេញនេះ និងសុំឱ្យមានតំណាងដើម្បីគោលបំណងនេះ និងដើម្បីសុំឱ្យពិនិត្យឡើងវិញលើរឿងរបស់ខ្លួន ដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយមនុស្សម្នាក់ ឬច្រើននាក់ដែលអាជ្ញាធរមានសមត្ថកិច្ចបានតែងតាំងជាពិសេស ។"*

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ការពារសិទ្ធិជនគ្រប់រូបដែលស្នាក់នៅជាបណ្តោះអាសន្នដោយស្របច្បាប់នៅក្នុងប្រទេសមួយ ក្នុងការមានសិទ្ធិធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួនដោយសេរី នៅទីណាក៏បាន ក្នុងទឹកដីរបស់ប្រទេសនោះ។ សិទ្ធិនេះ ត្រូវបានការពារពីការជ្រៀតជ្រែកទាំងផ្នែកសាធារណៈ និងផ្នែកឯកជន។

## សេរីភាពនៃការធ្វើដំណើររបស់ជនបរទេសនៅក្នុងដែនដីនៃរដ្ឋមួយ

ដោយសារសិទ្ធិនេះ ទាក់ទិនទៅលើតែបុគ្គលទាំងឡាយណា ដែលស្ថិតនៅក្នុងទឹកដីរបស់រដ្ឋមួយ ដោយស្របច្បាប់ រដ្ឋាភិបាល អាចដាក់ការរឹតត្បិតលើជនបរទេស ដែលចូលមកក្នុងប្រទេស ដោយពិនិត្យមើលយ៉ាងល្អិតល្អន់ លើជនទាំងឡាយ ដែលស្វែងរកការចូលមកក្នុងប្រទេស។ តើជនបរទេសម្នាក់ដែល "ស្របច្បាប់" នៅក្នុងទឹកដីនៃរដ្ឋមួយ គួរត្រូវបានកំណត់តាមច្បាប់ក្នុងស្រុក ដែលអាចមានការរឹតត្បិតមិនឱ្យចូលក្នុងប្រទេស ឬយ៉ាងណានោះ លុះត្រាតែ ការរឹតត្បិតនោះ ឆ្លើយតបទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋ។

ជនបរទេស ដែលចូលមកក្នុងប្រទេសមួយដោយខុសច្បាប់ ក៏ប៉ុន្តែ ក្រោយមកស្ថានភាពរបស់ពួកគេ ត្រូវបានធ្វើឱ្យមានភាពធម្មតាវិញ ត្រូវបានចាត់ទុកថាបានស្ថិតនៅក្នុងទឹកដីនោះ ដោយស្របច្បាប់។ ប្រសិនបើបុគ្គលម្នាក់ ស្ថិតនៅក្នុងប្រទេសមួយ ដោយស្របច្បាប់ ការរឹតត្បិតណាមួយដែលដាក់ទៅលើបុគ្គលនោះ ឬការប្រព្រឹត្តណាមួយ ទៅលើបុគ្គល

នោះ មានភាពខុសផ្លែកពីការប្រព្រឹត្តចំពោះជនជាតិរបស់ខ្លួននោះ ត្រូវតែមានការបញ្ជាក់ថា សមហេតុផល នៅក្រោមមាត្រា១២(៣) នៃ ICCPR ។

ឧទាហរណ៍ដ៏ល្អមួយនៃការរឹតត្បិត ដែលដាក់ទៅលើជនបរទេស ហើយត្រូវបាន អនុញ្ញាតិឱ្យធ្វើទៅបាន នៅក្រោមមាត្រានេះ មាននៅក្នុងករណីរបស់ *Celepli ទល់នឹង ប្រទេសស៊ុយអែត* នៅគណៈកម្មាធិការសិទ្ធិមនុស្ស (១៩៩៤) ។ លោកCelepli ជាជនជាតិ ទួគីម្នាក់មានដើមកំណើតជាជនជាតិឃឺត(Kurdish) រស់នៅក្នុងប្រទេសស៊ុយអែតត្រូវបាន បញ្ជាឱ្យចាកចេញពីប្រទេស ដោយមូលដ្ឋាននៃការសង្ស័យថាបានពាក់ព័ន្ធទៅក្នុងសកម្មភាព ភេរវកម្ម ។ បទបញ្ជានោះ មិនត្រូវបានអនុវត្តទេ ហើយគាត់ក៏ត្រូវបានគេអនុញ្ញាតិឱ្យរស់នៅ ក្នុងក្រុងមួយ ជាបន្តទៅទៀត ដែលជាទីកន្លែង ដែលគាត់ត្រូវតែទៅបង្ហាញខ្លួនឱ្យបានទៀង ទាត់នៅមុខប៉ូលីស ។ គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញថា ការរឹតត្បិតនេះ មានភាព ស្របជាមួយខបញ្ញត្តិនៃមាត្រា១២(៣) របស់ ICCPR ដូច្នេះហើយ វាមានលក្ខណៈស្រប ច្បាប់ ។

## សេរីភាពចាកចេញពីប្រទេសមួយ

មាត្រា១២(២) នៃ ICCPR ចែងថា ជនគ្រប់រូប (ប្រជាជន និងជនបរទេស និង ថែមទាំងជនរស់នៅជាបណ្តោះអាសន្ននៅក្នុងប្រទេសដោយខុសច្បាប់) មានសេរីភាព ចាក ចេញពីទឹកដីនៃប្រទេសណាមួយ ។ សិទ្ធិនេះ អនុវត្តលើទស្សនៈកិច្ចរយៈពេលខ្លី និងវែង នៅ ក្រៅប្រទេស ហើយនិងទៅធ្វើអន្តោប្រវេសន៍ (ជាអចិន្ត្រៃយ៍ និងពាក់កណ្តាលអចិន្ត្រៃយ៍) ។ ការទទួលបាននូវសិទ្ធិនេះ មិនអាស្រ័យទៅលើគោលបំណង ឬរយៈពេលនៃការធ្វើដំណើរទៅ ក្រៅប្រទេសនោះទេ ។

សិទ្ធិនេះ បានដាក់កាតព្វកិច្ចទាំងទៅលើរដ្ឋដែលជានិវេសនដ្ឋាន និងរដ្ឋដែលផ្តល់

សញ្ជាតិ។ ឧទាហរណ៍ រដ្ឋដែលផ្តល់សញ្ជាតិ ត្រូវតែចេញឯកសារធ្វើដំណើរ ឬលិខិតឆ្លងដែនឱ្យពលរដ្ឋគ្រប់រូបទាំងអស់ ទាំងនៅក្នុង និងនៅក្រៅដែនដីនៃប្រទេស។ ប្រសិនណារដ្ឋមួយធ្វើការជំទាស់មិនព្រមចេញលិខិតឆ្លងដែន ឬតម្រូវឱ្យប្រជាជនរបស់ខ្លួន សុំទិដ្ឋាការដើម្បីចេញពីប្រទេស នោះគឺជាការជ្រៀតជ្រែក ដែលលំបាកនឹងលើកអំណះអំណាងមកបង្ហាញថាសមហេតុផល។ បន្ថែមលើនេះទៅទៀត គណៈកម្មាធិការសិទ្ធិមនុស្សបានថ្កោលទោសលើច្បាប់ជាតិណាដែលដាក់ការរឹតត្បិតលើសិទ្ធិរបស់ស្ត្រី ក្នុងការចាកចេញពីប្រទេសដោយទាមទារឱ្យមានការយល់ព្រមពីប្តីរបស់គាត់។

**ប្រអប់ ៦៥**

## ឧបសគ្គនានាដល់សេរីភាពនៃការធ្វើដំណើរៈ ឧទាហរណ៍

សេរីភាពក្នុងការធ្វើដំណើរ តែងតែត្រូវបានភ្ជាប់ទៅនឹងឧបសគ្គដែលមិនចាំបាច់នានា ដូចមានរាយបញ្ជីខាងក្រោម ដែលធ្វើឱ្យការធ្វើដំណើរក្នុងប្រទេស និងរវាងប្រទេសនានា មានការលំបាក ឬមិនអាចធ្វើទៅបាន។ សមាជិកសភាអាចប្រាថ្នាចង់ធ្វើការជំទាស់ទៅនឹងវិធានការបែបហ្នឹង។

### ការធ្វើដំណើរនៅក្នុងប្រទេស

- កាតព្វកិច្ចសុំការអនុញ្ញាតិ សម្រាប់ការធ្វើដំណើរក្នុងប្រទេស
- កាតព្វកិច្ចសុំការអនុញ្ញាត ពេលផ្លាស់ប្តូរកន្លែងរស់នៅ
- កាតព្វកិច្ចសុំការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន នៃកន្លែងគោលដៅ
- រដ្ឋបាលអូសបន្លាយ ក្នុងការពិនិត្យពាក្យសុំជាលាយល័ក្ខណ៍អក្សរ

### ការធ្វើដំណើរទៅប្រទេសមួយផ្សេងទៀត

- ខ្វះមធ្យោបាយទៅរកអាជ្ញាធរ ឬទទួលបានព័ត៌មាន ទាក់ទិនទៅនឹងល័ក្ខខ័ណ្ឌផ្សេងៗ
- ល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ពាក្យសុំ ទម្រង់ពិសេស ដើម្បីទទួលបានទម្រង់ពាក្យសុំពិតប្រាកដមួយ

សម្រាប់ចេញលិខិតឆ្លងដែនមួយ

- ល័ក្ខខ័ណ្ឌតម្រូវឱ្យមានសេចក្តីប្រកាសគាំទ្រពីនិយោជក ឬសាច់ញាតិ
- ល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ជូននូវការពណ៌នាចំៗមួយ អំពីផ្លូវដែលត្រូវធ្វើដំណើរ
- តម្លៃនៃការចេញលិខិតឆ្លងដែន មានកម្រិតខ្ពស់
- ការអូសបន្លាយដោយមិនសមហេតុផល ក្នុងការចេញឯកសារធ្វើដំណើរ
- ការរឹតត្បិត លើសមាជិកគ្រួសារដែលធ្វើដំណើរជាមួយគ្នា
- ល័ក្ខខ័ណ្ឌតម្រូវឱ្យបង់ប្រាក់កក់សម្រាប់ធានានូវការត្រឡប់មកវិញ ឬឱ្យមានសំបុត្រធ្វើដំណើរត្រឡប់មកវិញ
- ល័ក្ខខ័ណ្ឌតម្រូវឱ្យមានលិខិតអញ្ជើញពីរដ្ឋដែលត្រូវធ្វើដំណើរទៅ
- ការបៀតបៀនលើអ្នកដាក់ពាក្យសុំ

## ការកម្រិតព្រំដែននានា

សេរីភាពក្នុងការធ្វើដំណើរមិនត្រូវមានការរិតត្បិតឡើយ លើកលែងតែការរិតត្បិតនេះត្រូវបានចែងដោយច្បាប់ និងក្នុងករណីណាដែលមានភាពចាំបាច់លើមូលដ្ឋាននៃសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពអ្នកដទៃ (មាត្រា១២(៣) នៃ ICCPR ។

យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស ល័ក្ខខ័ណ្ឌតម្រូវទាំងនេះ នឹងមិនអាចធ្វើបានទេក្នុងករណី ដូចជា "ប្រសិនបើបុគ្គលម្នាក់ ត្រូវបានគេហាមឃាត់ មិនឱ្យចាកចេញពីប្រទេសដោយគ្រាន់តែផ្អែកលើមូលដ្ឋានថា គាត់មាន "កិច្ចការសម្ងាត់របស់រដ្ឋ" ឬប្រសិនបើ បុគ្គលម្នាក់ ត្រូវបានគេហាមឃាត់ មិនឱ្យធ្វើដំណើរនៅក្នុងផ្ទៃប្រទេស ដោយពុំមានការអនុញ្ញាតជាក់លាក់មួយ" ។ ដូចគ្នានេះដែរ ការហាមមិនឱ្យស្ត្រី ធ្វើដំណើរដោយសេរី ឬចាកចេញពីប្រទេសដោយគ្មានការយល់ព្រម ឬការអមដំណើរដោយបុគ្គលជាបុរសម្នាក់នោះ គឺជាការ

រំលោភលើមាត្រា១២ នៃ ICCPR ។ ប៉ុន្តែផ្ទុយទៅវិញ ការរឹតត្បិតមិនឱ្យចូលទៅកាន់តំបន់យោធា ដោយផ្អែកលើមូលដ្ឋានសន្តិសុខជាតិ ឬការកម្រិតព្រំដែនលើសេរីភាពក្នុងការតាំងទីលំនៅ ក្នុងតំបន់ដែលជាកន្លែងរស់នៅរបស់ជនជាតិដើម ឬសហគមន៍ជនជាតិភាគតិចនោះ គឺជាការរឹតត្បិតដែលអាចអនុញ្ញាតិឱ្យធ្វើបាន ។

ប្រអប់ ៦៦

## ការដាក់កម្រិតព្រំដែន និងការពិនិត្យមើលលើការអនុវត្តរបស់វា

### ការតាក់តែងច្បាប់

ក្នុងការអនុម័តច្បាប់ដែលផ្តល់ឱ្យមានការរឹតត្បិត នៅក្រោមមាត្រា១២(៣) នៃ ICCPR ជានិច្ចកាល សភាគួរតែប្រតិបត្តិតាមគោលការណ៍ដែលថា ការរឹតត្បិតនានាមិនត្រូវធ្វើឱ្យបរាជ័យដល់គោលបំណងនៃសិទ្ធិនោះទេ ។ ច្បាប់ត្រូវចែងអំពីលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ដាក់ការរឹតត្បិតទាំងនេះ ដែលគួរយកទៅអនុវត្តត្រឹមត្រូវតាមទិសដៅ និងគោរពគោលការណ៍ ដើម្បីសមាមាត្រ ហើយការរឹតត្បិត គួរធ្វើឡើងឱ្យបានសមរម្យ មានការបំពានយ៉ាងតិចបំផុត តាមដែល-អាចធ្វើទៅបាន និងគួរមានសមាមាត្រទៅនឹងផលប្រយោជន៍ ដែលត្រូវការពារ ។

### ការអនុវត្ត

ប្រសិនបើរដ្ឋសម្រេចដាក់ឱ្យមានការរឹតត្បិតនោះ ការរឹតត្បិតទាំងនេះត្រូវមានចែងនៅក្នុងច្បាប់ ។ ការរឹតត្បិតដែលមិនបានចែងនៅក្នុងច្បាប់ ហើយមិនស្របនឹងមាត្រា ១២ (៣) នៃ ICCPR ទេ នោះគឺជាការរំលោភដោយផ្ទាល់ ទៅលើសេរីភាពនៃការធ្វើដំណើរ ។ ការអនុវត្តជាក់ស្តែងលើការ រឹតត្បិតណាមួយគួរតែឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌនៃភាពចាំបាច់ និងភាពសមាមាត្រដូចបានពន្យល់ខាងលើ ។ បន្ថែមលើនេះទៀត ការរឹតត្បិតទាំងឡាយ ត្រូវតែស៊ីសង្វាក់ជាមួយសិទ្ធិផ្សេងទៀត ដែលចែងនៅក្រោម ICCPR ហើយស៊ីសង្វាក់ជាមួយគោលការណ៍សមភាព និងគោលការណ៍មិនរើសអើង ។

## សិទ្ធិចូលទៅកាន់ប្រទេសរបស់ខ្លួនវិញ

មាត្រា១២(៤) នៃ ICCPR បង្កប់ន័យថា ជនម្នាក់មានសិទ្ធិ ស្ថិតនៅក្នុងប្រទេសរបស់ខ្លួនផ្ទាល់ និងមានសិទ្ធិវិលត្រឡប់ទៅកាន់ប្រទេសនោះវិញបន្ទាប់ពីខ្លួនបានចាកចេញ ហើយវាអាចផ្ដល់សិទ្ធិឱ្យជនម្នាក់ អាចចូលទៅកាន់ប្រទេសមួយជាលើកដំបូង (ប្រសិនបើគាត់មានសញ្ជាតិរបស់ប្រទេសនោះ ប៉ុន្តែគាត់កើតនៅប្រទេសក្រៅ)។ សិទ្ធិក្នុងការត្រឡប់មកវិញ មានសារៈសំខាន់ ជាពិសេស សម្រាប់ជនភៀសខ្លួន ដែលមានបំណងធ្វើមាតុភូមិនិវត្តន៍ ដោយស្ម័គ្រចិត្ត។

ពាក្យថា "ប្រទេសផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់" សំដៅជាបឋម ទៅលើពលរដ្ឋនៃប្រទេសនោះ។ ក្នុងករណីដោយឡែក បុគ្គលដែលបានស្នាក់នៅក្នុងប្រទេសមួយអស់រយៈពេលជាយូរមកហើយ ក្នុងឋានៈជាជនបរទេស ឬដែលបានកើតនៅទីនោះ ក្នុងឋានៈជាជនអន្តោប្រវេសន៍ជំនាន់ទីពីរ អាចចាត់ទុកប្រទេសដែលខ្លួនបានស្នាក់នៅនោះថា ជាប្រទេស "ផ្ទាល់" របស់ខ្លួន។

## សេរីភាពខាងការគិត ខាងសម្បជញ្ញៈ និងខាងសាសនា

មាត្រា១៨ នៃ UDHR

*"មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សេរីភាពខាងសម្បជញ្ញៈ និងខាងសាសនា។ សិទ្ធិនេះ រាប់បញ្ចូលទាំង សេរីភាពក្នុងការផ្លាស់ប្ដូរសាសនា ឬជំនឿរបស់ខ្លួន ព្រមទាំងសេរីភាពសម្ដែងសាសនា ឬជំនឿរបស់ខ្លួន តែម្នាក់ឯង ឬជារួម ជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការប្រតិបត្តិ ការគោរពបូជា ព្រមទាំងតាមការប្រារព្ធពិធីសក្ការៈផ្សេងៗ ។"*

មាត្រា១៨ នៃ ICCPR

*"១. ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការគិត សេរីភាពខាងសម្បជញ្ញៈ និងខាងសាសនា ។*

*សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការកាន់ ឬគោរពសាសនា ឬជំនឿណាមួយតាមការជ្រើសរើសរបស់ខ្លួន និងសេរីភាពក្នុងការសម្តែងសាសនា ឬជំនឿរបស់ខ្លួន ដោយម្នាក់ៗឯង ឬដោយរួមជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជន តាមការគោរពបូជា ការប្រតិបត្តិតាម ការអនុវត្ត និងការបង្ហាត់បង្រៀន ។*

*២. គ្មានជនណាម្នាក់ ត្រូវរងការបង្ខិតបង្ខំឱ្យកាន់ ឬគោរពសាសនា ដែលធ្វើឱ្យខូចដល់សេរីភាព នៃការកាន់ ឬការគោរពសាសនា ឬជំនឿ តាមការជ្រើសរើសរបស់ខ្លួនឡើយ ។*

*៣. សេរីភាពសម្តែងការគោរពសាសនា ឬជំនឿរបស់ខ្លួន នឹងអាចដាក់កម្រិតព្រំដែនបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដល់ការការពារសន្តិសុខសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាព មូលដ្ឋានរបស់អ្នកដទៃ ។*

*៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាល ស្របច្បាប់ ប្រសិនជាមិនមានឪពុកម្តាយ ក្នុងការធានាដល់ការអប់រំខាងសាសនា និងសីលធម៌ ចំពោះ បុត្រធីតារបស់គេ ស្របតាមជំនឿរបស់គេ ។"*

សិទ្ធិមានសេរីភាពខាងការគិត សេរីភាពខាងសម្បជញ្ញៈ និងខាងសាសនា មានសារៈសំខាន់ណាស់ ដែលវាមិនអាចត្រូវរងនូវការដកហូតឡើយ ទោះជាក្នុងអំឡុងពេលដែលរដ្ឋមានអាសន្នក៏ដោយ ។ អ្វីដែលត្រូវបានគេស្គាល់ថាជា forum internum ដូចជា សិទ្ធិដើម្បីបង្កើតការគិត ទស្សនៈយល់ឃើញ សម្បជញ្ញៈ ការគោរពបូជា និងជំនឿផ្ទាល់របស់ខ្លួន គឺជាសិទ្ធិដាច់ខាតមួយ ដែលការពារប្រឆាំងទៅនឹងទម្រង់ណាមួយនៃការជ្រៀតជ្រែករបស់រដ្ឋ ដូចជាការអប់រំមនោគមវិជ្ជា ( "លាងខួរក្បាល" ) ជាដើម ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ការសំដែងជាសាធារណៈអំពីសាសនា ឬជំនឿ អាចត្រូវគេរឹតត្បិតបាន បើមានមូលដ្ឋាន ច្បាប់ត្រឹមត្រូវ ។

ពាក្យ "សាសនា " និង "ជំនឿ "គួរធ្វើការបកស្រាយឱ្យទូលំទូលាយដើម្បីរួមបញ្ចូល ទាំងជំនឿ និងសាសនា ដែលជាប្រពៃណី ព្រមទាំងមិនប្រពៃណីផងដែរ ទោះបីវាជាវេទនិយម មិនមែនវេទនិយម ឬមិនជឿលើការមានព្រះក៏ដោយ។ សេរីភាពក្នុងការមាន ឬជ្រើសរើសសាសនា និងជំនឿមួយ រួមមានទាំងសេរីភាព ដើម្បីធ្វើការជ្រើសរើស ដែលអាចនាំទៅដល់ការផ្លាស់ចេញពីសាសនា ឬជំនឿដែលធ្លាប់ជឿពីមុន ទៅជឿលើសាសនា ឬជំនឿផ្សេងមួយទៀត ឬដើម្បីជ្រើសរើសនូវទស្សនៈយល់ឃើញនានា ដែលមិនជឿថាមានព្រះ ឬក៏ដើម្បីរក្សាទុកនូវសាសនា ឬជំនឿរបស់ខ្លួន។

## ការហាមមិនឱ្យមានការបង្ខិតបង្ខំ

គ្មានកាលៈទេសៈណាមួយ ដែលបុគ្គលណាម្នាក់អាចត្រូវបានគេបង្ខំដោយការប្រើកម្លាំងកាយ ឬការគំរាមប្រើកម្លាំងកាយ ឬការដាក់ទោសទណ្ឌព្រហ្មទណ្ឌ ដើម្បីឱ្យជ្រើសយក ប្រកាន់ខ្ជាប់ ឬ ឈប់ជឿនូវសាសនា និងជំនឿជាក់លាក់ណាមួយបានទេ។ ការហាមប្រាមនេះក៏អនុវត្តផងដែរទៅលើគោលនយោបាយ និងវិធានការនានា ដែលមានឥទ្ធិពលស្រដៀងគ្នានេះ។ ជាឧទាហរណ៍ សមាជិកភាពនៅក្នុងក្រុមសាសនាមួយមិនអាចធ្វើឱ្យបុគ្គលម្នាក់បាត់បង់គុណវុឌ្ឍិ ពីតួនាទីសាធារណៈរបស់ខ្លួនបានទេ។

## ការសម្តែងនូវសាសនា និង ជំនឿ

ពាក្យ"សំដែង"នេះមានអត្ថន័យទូលំទូលាយណាស់។ វាមានន័យគ្របដណ្តប់ទៅលើៈ

- ការគោរពបូជា : ការប្រារព្ធពិធីសែនព្រេន និងជាពិធីបុណ្យផ្សេងៗ ការកសាងទីសក្ការបូជា ការប្រើរូបមន្ត និងអណ្តាប់អណ្តាសម្រាប់ប្រារព្ធពិធី ការដាក់បង្ហាញនិមិត្តសញ្ញា និងការប្រតិបត្តិតាមថ្ងៃបុណ្យ និងថ្ងៃឈប់សម្រាក
- ការប្រតិបត្តិតាម : ការប្រារព្ធពិធីបុណ្យ ដោយអនុវត្តតាមក្បួនវិន័យម្ហូបអាហារ ការស្លៀកពាក់

សំលៀកបំពាក់ ឬឈ្នួតក្បាលខុសពីគេ និងប្រើភាសាជាក់លាក់មួយ

- ការអនុវត្ត និងការបង្ហាត់បង្រៀន : ការជ្រើសរើសមេដឹកនាំសាសនា បុព្វជិត និងគ្រូបង្រៀន រៀបចំសិក្ខាសាលា និងសាលាបង្រៀនសាសនា និងបង្កើត ឬចែកចាយអត្ថបទសាសនា ឬការបោះពុម្ពផ្សាយនានា។

ដោយហេតុថា ការសំដែងសាសនា និងជំនឿរបស់ជនមួយរូបមានភាពសកម្ម ជាចាំបាច់នោះ វាអាចប៉ះពាល់ទៅលើសិទ្ធិខ្លះរបស់អ្នកផ្សេងទៀត ហើយធ្ងន់ធ្ងរជាងនេះទៀតវា ថែមទាំងអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សង្គមទៀតផង។ ហេតុដូច្នេះ នៅក្រោមមាត្រា ១៨(៣) នៃ ICCPR ការសំដែងទាំងនេះអាចជាកម្មវត្ថុនៃការដាក់កំហិតជាក់លាក់ខ្លះ។

## ការកម្រិតព្រំដែនលើការសម្តែងសាសនា និងជំនឿរបស់បុគ្គលម្នាក់ៗ

ការកម្រិតព្រំដែនលើសេរីភាពប្រារព្ធពិធីតាមសាសនា និងជំនឿរបស់បុគ្គលម្នាក់ៗ ត្រូវភ្ជាប់ទៅនឹងល័ក្ខខ័ណ្ឌយ៉ាងតឹងតែង ហើយអនុញ្ញាតិឱ្យធ្វើបាន ប្រសិនបើ :

- ត្រូវបានចែងដោយច្បាប់
- ចាំបាច់ដើម្បីការពារសុវត្ថិភាព សណ្តាប់ធ្នាប់ សុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃ

ឧទាហរណ៍មួយស្តីពីមូលដ្ឋាននៃការអនុញ្ញាតិឱ្យដាក់កម្រិតព្រំដែនលើសេរីភាពប្រារព្ធពិធីតាមសាសនា និងជំនឿរបស់បុគ្គលម្នាក់ៗ គឺនៅពេលការប្រារព្ធពិធីនោះ ក្លាយជាធ្វើការឃោសនាឱ្យមានសង្គ្រាម ឬការតស៊ូមតិ ឱ្យមានការស្អប់ខ្ពើមសញ្ជាតិ ពូជសាសន៍ ឬសាសនាដែលបង្កើតជាការអុចអាលឱ្យមានការរើសអើង អរិភាព ឬហឹង្សា។ ជារឿយៗ ភាពមិនអត់អោនផ្នែកសាសនាទាំងអស់ គឺជាប្រភពនៃវិវាទប្រកបដោយអំពើហឹង្សា រវាងក្រុមជាតិសាសន៍ និងក្រុមសាសនា។

**ប្រអប់ ៦៧**

## ការហាមប្រាមលើនិមិត្តសញ្ញាសាសនាជាចំហរ នៅក្នុងសាលារៀននៃប្រទេសបារាំង

ភាពប្រទាញប្រទង់គ្នាលើច្បាប់បារាំងមួយ ដែលបានអនុម័តនៅឆ្នាំ២០០៤ បង្ហាញឱ្យឃើញនូវទំហំនៃភាពរសើបនៃបញ្ហាដាក់កម្រិតព្រំដែន លើការប្រារព្ធតាមសាសនា ឬជំនឿ។ ច្បាប់មួយត្រូវបានអនុម័តដោយសម្លេងភាគច្រើនលើសលុប នៃសមាជិកសភា ហាមមិនឱ្យប្រើសញ្ញាសាសនាជាចំហនៅក្នុងសាលារៀនរបស់រដ្ឋ។ ច្បាប់នោះត្រូវបានគេមើលឃើញច្បាស់ថា សំដៅទៅលើក្រណាត់គ្របក្បាល និងមុខរបស់សាសនិកអ៊ីស្លាម ថ្វីដ្បិតតែថាការហាមនោះរួមបញ្ចូលទាំងមួកកន្ទិបរបស់ពួកជ្វីប និងឈើឆ្កាងដ៏ធំរបស់សាសនាគ្រឹះក៏ដោយ។

នៅពេលដែលសភា និងរដ្ឋាភិបាលបារាំង ផ្តល់យុត្តិកម្មលើច្បាប់នេះ ដោយលើកឡើងពីគោលការណ៍នៃអាណាចក្រ (ការបែងចែកដាច់ពីគ្នារវាងរដ្ឋនិងសាសនា) និងសេចក្តីត្រូវការដើម្បីការពារក្មេងស្រីមូស្លីមពីការរើសអើងដាក់លាក់ផ្នែកយេនឌ័រក៏ដោយ ក៏ក្រុមសិទ្ធិមនុស្សជាច្រើន បានផ្តល់អំណះអំណាងថា បំរាមនោះ រំលោភលើសិទ្ធិក្នុងការទទួលបានសេរីភាពខាងសាសនា ឬខាងជំនឿ ហើយថា បំរាមនោះគឺពិតជា ការបង្ខិតបង្ខំមួយ ដែលមាត្រា១៨ នៃ CCPR បានហាមឃាត់តែម្តង។

## ការអប់រំសាសនា និងអប់រំសីលធម៌

មាត្រា១៨(៤) នៃ CCPR តម្រូវឱ្យរដ្ឋនានាគោរពសេរីភាពរបស់ឪពុកម្តាយ និងអាណាព្យាបាលស្របច្បាប់ក្នុងការចិញ្ចឹមបីបាច់កូនរបស់ពួកគេ ដោយស្របទៅតាមជំនឿសាសនា និងសីលធម៌របស់ពួកគេផ្ទាល់។

ការអប់រំសាសនា និងអប់រំសីលធម៌ដែលខានមិនបាន នៅតាមសាលារៀនសាធារណៈនានា មិនផ្ទុយទៅនឹងខបញ្ញត្តិនេះទេ ប្រសិនបើសាសនានោះ ត្រូវបានបង្រៀនតាមទិសដៅ និងមានលក្ខណៈពហុនិយម (ឧទាហរណ៍ បង្រៀនជាផ្នែកមួយនៃមេរៀនស្តីពីប្រវត្តិសាស្ត្រទូទៅរបស់សាសនា និងចរិយាធម៌ជាដើម)។ ប្រសិនបើសាសនាមួយ ត្រូវបានបង្រៀននៅក្នុង

សាលាសាធារណៈ នោះគួរមានឧបញ្ញត្តិដោយឥតរើសអើង ដើម្បីឱ្យមានការលើកលែង ឬមានជម្រើសសម្រាប់ឆ្លើយតបតាមសេចក្តីប្រាថ្នារបស់ឪពុកម្តាយ និងអាណាព្យាបាល ស្របច្បាប់ទាំងអស់ ។

## សេរីភាពនៃគំនិត និងការសម្តែងមតិ

មាត្រា១៩ នៃ UDHR

*" មនុស្សគ្រប់រូប មានសិទ្ធិក្នុងការមានមតិ និងសម្តែងមតិដោយសេរី ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់យកមតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ទទួលយក និងផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ទោះតាមរយៈមធ្យោបាយផ្សព្វផ្សាយព័ត៌មានណាមួយក៏បាន និងដោយឥតគិតអំពីព្រំដែន ។"*

មាត្រា១៩ នៃ ICCPR

*" ១. មនុស្សគ្រប់រូប មានសិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក ។*

*២. មនុស្សគ្រប់រូបមានសិទ្ធិសំដែងមតិដោយសេរី ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវរក ទទួលយក និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ទោះដោយផ្ទាល់មាត់ ដោយសរសេរ ឬដោយការបោះពុម្ពក្តី តាមទម្រង់សិល្បៈ ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ។*

*៣. ការប្រើសិទ្ធិដែលចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស ។ ដូច្នេះ ការប្រើសិទ្ធិនេះ អាចមានការរឹតត្បិតមួយចំនួន ប៉ុន្តែការរឹតត្បិតទាំងនេះ ត្រូវមានចែងដោយច្បាប់ និងមានការចាំបាច់ដើម្បី :*

*(ក). គោរពសិទ្ធិ និងកិត្តិនាមរបស់អ្នកដទៃ*

*(ខ). ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ។"*

ខបញ្ញត្តិខាងលើនេះ សំគាល់បានតាមធាតុផ្សំសំខាន់ចំនួនពីរៈ

- សេរីភាពនៃគំនិត និង
- សេរីភាពក្នុងការសម្តែងមតិ

## សេរីភាពនៃគំនិត

សិទ្ធិក្នុងការប្រកាន់យកទស្សនៈ គឺមានលក្ខណៈអកម្មជាធម្មជាតិ ហើយបង្កើតបានជាទម្រង់នៃសេរីភាពដាច់ខាតមួយ។ ICCPR មិនអនុញ្ញាតិឱ្យមានការលើកលែង ឬការរឹតត្បិតណាមួយទៅលើសេរីភាពនេះឡើយ ដោយសារតែសារជាតិដាច់ខាតរបស់វា នឹងរលាយបាត់ទៅវិញ នៅពេលណាអ្នកដែលមានមតិនោះ សំដែងឱ្យគេឃើញនូវគំនិតយោបល់របស់ខ្លួន ដែលទិដ្ឋភាពនេះទាក់ទិនទៅនឹងសេរីភាពក្នុងការសំដែងមតិ។ ដូចដែលយើងនឹងឃើញសេរីភាពក្នុងការសំដែងមតិនេះអាចមានការរឹតត្បិត ហើយថែមទាំងត្រូវតែបានគេរឹតត្បិត នៅក្រោមកាលៈទេសៈមួយចំនួន។

## សេរីភាពក្នុងការបញ្ចេញមតិ

សេរីភាពក្នុងការសម្តែងមតិ ព្រមជាមួយសេរីភាពក្នុងការរួមប្រជុំ និងសេរីភាពចូលរួមក្នុងសមាគម គឺជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ ប្រជាធិបតេយ្យ មិនអាចសម្រេចជោគជ័យទេ ប្រសិនបើគ្មានលំហូរនៃគំនិត និងព័ត៌មានដោយសេរីនិងលទ្ធភាពដើម្បីឱ្យពលរដ្ឋប្រមូលផ្តុំគ្នា ដើម្បីពិភាក្សា និងបន្លឺឱ្យគេដឹងពីគំនិតមតិរិះគន់ និងការទាមទារនានាក្នុងការការពារផលប្រយោជន៍ និងសិទ្ធិរបស់ពួកគេ និងក្នុងការបង្កើតអង្គការនានាដើម្បីបំរើគោលបំណងទាំងនោះ ដូចជា សហជីព និងគណៈបក្សនយោបាយជាដើម។ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសេរីភាពក្នុងការសំដែងមតិ បានពិពណ៌នាថា សិទ្ធិនេះ ជា "សិទ្ធិសម្រាប់ធ្វើតេស្តមួយយ៉ាងសំខាន់ ការទទួលបាននូវសិទ្ធិនេះបង្ហាញឱ្យឃើញនូវ

កម្រិតនៃការទទួលបាននូវសិទ្ធិទាំងអស់ ដែលមានចែងនៅក្នុង ធម្មនុញ្ញអន្តរជាតិ ស្តីពីសិទ្ធិមនុស្ស ហើយថាការគោរពសិទ្ធិនេះ ឆ្លុះបញ្ចាំងដល់ស្តង់ដាររបស់ប្រទេសមួយ ដែលមានការប្រព្រឹត្តដោយត្រឹមត្រូវ ដោយយុត្តិធម៌ និងមានសុចរិតភាព។[៣៣]

គ្រប់អង្គភាពដែលធ្វើការត្រួតពិនិត្យតាមដានថ្នាក់តំបន់និងអន្តរជាតិទាំងអស់ បានគូសបញ្ជាក់នូវសារៈសំខាន់ដ៏ឧត្តុងឧត្តមនៃសិទ្ធិនេះ ទៅលើលទ្ធិប្រជាធិបតេយ្យ។ គណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្សនិងសិទ្ធិប្រជាពលរដ្ឋ បានធ្វើតាមគោលការណ៍នេះ ដោយអនុម័តសេចក្តីប្រកាសពីគោលការណ៍នៃការសំដែងមតិ នៅអាហ្វ្រិក ក្នុងខែតុលា ឆ្នាំ២០០២។

សិទ្ធិក្នុងការសំដែងមតិ មិនគ្រាន់តែរួមបញ្ចូលនូវសិទ្ធិរបស់បុគ្គលម្នាក់ៗ ក្នុងការសំដែងឱ្យឃើញនូវការគិតឃើញរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងសិទ្ធិក្នុងការស្វែងរក ទទួលយក និងផ្សព្វផ្សាយពីព័ត៌មាននិងគំនិតគ្រប់ប្រភេទទាំងអស់ទៀតផង។ ដូច្នេះ សិទ្ធិនេះមានវិសាលភាពសម្រាប់បុគ្គល និងសម្រាប់សង្គមៈ ពោលគឺ វាជាសិទ្ធិមួយ ដែលជាកម្មសិទ្ធិរបស់បុគ្គលទាំងឡាយ ហើយក៏បង្កប់នូវសិទ្ធិរួមគ្នា ក្នុងការទទួលបានព័ត៌មានប្រភេទណាក៏ដោយ និងដើម្បីទទួលបានគំនិតផ្សេងៗ ដែលសម្តែងឡើងដោយអ្នកដទៃផ្សេងទៀត។

---

[៣៣] គណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិ *របាយការណ៍របស់អ្នករាយការណ៍ពិសេសទៅលើការលើកស្ទួយ និងការការពារសិទ្ធិទទួលបានសេរីភាពក្នុងការមានទស្សនៈយោបល់ និងការសំដែងមតិ* (E/CN.4/2002/75) ខែមករា ឆ្នាំ២០០២។

ប្រអប់ ៦៨

## សេរីភាពក្នុងការបញ្ចេញមតិ - សិទ្ធិដ៏ទូលំទូលាយមួយ

នៅក្នុងសំណុំរឿងរបស់ *Handyside ទល់នឹងចក្រភពអង់គ្លេស* (១៩៧៦) ជាក្រុមហ៊ុនបោះពុម្ពមួយដែលចេញផ្សាយ "កូនសៀវភៅក្រហម" ដែលមានបំណងនឹងលក់ទៅឱ្យ កូនសិស្សសាលា ដែលមានអាយុ ១២ឆ្នាំ ឬច្រើនជាង។ សៀវភៅនោះ មានផ្នែកខ្លះផ្តោតទៅលើរឿងភេទ និងអាស័យដ្ឋាននានា សម្រាប់ការរកជំនួយ និងដំបូន្មានទៅលើរឿងដែលពាក់ព័ន្ធទៅនឹងផ្លូវភេទ។ ជាលទ្ធផលនៃបណ្តឹងមួយចំនួន ដែលទទួលបានដោយអាជ្ញាធរ ទីកន្លែងរបស់ក្រុមហ៊ុនត្រូវបានឆែកឆេរ សៀវភៅមួយចំនួនត្រូវបានរឹបអូស ហើយក្រុមហ៊ុនត្រូវបានរកឃើញថាមានទោសក្នុងការមានសៀវភៅអាសអាភាសសម្រាប់បោះពុម្ពផ្សាយ ដើម្បីទទួលបានការចំណេញ។ គាត់ត្រូវបាន គេផាកពិន័យ ហើយត្រូវបានបញ្ជាឱ្យបង់តំលៃទាំងនោះ។ ការចោទនេះត្រូវបានតំកល់ទុក នៅពេលប្តឹងឧទ្ធរណ៍ ហើយសៀវភៅដែលត្រូវបានរឹបអូសទាំងនោះត្រូវបានបំផ្លាញចោល។ ការបោះពុម្ពផ្សាយកែប្រែឡើងវិញត្រូវបានចេញនាពេលបន្ទាប់មក។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថាពុំមានការរំលោភបំពានទៅលើសិទ្ធិទទួលបានសេរីភាពខាងការបញ្ចេញមតិនោះទេ ដោយសារអាជ្ញាធរបានដាក់កម្រិតទៅលើពួកគេទៅនឹងអ្វីដែលមានភាពចាំបាច់បំផុត នៅក្នុងសង្គមប្រជាធិបតេយ្យមួយ។ ទោះជាយ៉ាងនេះក៏ដោយ វាបានសង្កត់ធ្ងន់ថាចំណាប់អារម្មណ៍ខ្ពស់បំផុតគួរត្រូវបានធ្វើឡើងលើគោលការណ៍នានា ដែលកំណត់ចរិតលក្ខណៈរបស់សង្គមប្រជាធិបតេយ្យ។ តុលាការបានយល់ឃើញថា សេរីភាពក្នុងការបញ្ចេញមតិបានបង្កើតឱ្យមានមូលដ្ឋានគ្រឹះដ៏សំខាន់មួយក្នុងចំណោមមូលដ្ឋានគ្រឹះនានារបស់សង្គមមួយ ហើយវាជាលក្ខខណ្ឌមូលដ្ឋានមួយ សម្រាប់ការរីកចំរើនរបស់សង្គម និងការអភិវឌ្ឍន៍របស់បុគ្គលម្នាក់ៗ។ ដោយភ្ជាប់ទៅនឹងការិតត្បិតជាធម្មានុភាព ការិតត្បិតមានប្រសិទ្ធភាព"មិនគ្រាន់តែទៅលើព័ត៌មាន ឬគំនិតនានា ដែលត្រូវបានទទួលដោយពេញចិត្ត ឬត្រូវបានគេយល់ថា មានលក្ខណៈមិនប្រមាថមើលងាយ ឬជារឿងដែលមិនមានភាពខុសពីគេប៉ុណ្ណោះទេ ថែមទាំងមានប្រសិទ្ធភាពទៅលើព័ត៌មាន ឬគំនិតដែលប្រមាថ ធ្វើឱ្យភ័យស្លន់ស្លោ

ឬរំខានទៅដល់រដ្ឋ ឬទៅដល់ផ្នែកណាមួយរបស់ប្រជាពលរដ្ឋ។ បើគ្មានសេចក្តីត្រូវការទៅលើលទ្ធិពហុនិយម ការអត់អោន និងការយោគយល់ដ៏ទូលំទូលាយទាំងអស់នេះទេ នោះក៏គ្មានសង្គមប្រជាធិបតេយ្យដែរ”។

នៅក្នុងសំណុំរឿងរបស់*Feldek ទល់នឹងប្រទេសស្លូវ៉ាគី* (២០០១) ដែលក្នុងនោះអ្នកដាក់ពាក្យបណ្តឹង ត្រូវបានរកឃើញថា មានទោសបរិហាកេរ្តិ៍ចំពោះការចោទទៅលើរដ្ឋមន្ត្រី ដែលទើបនឹងត្រូវបានតែងតាំងថ្មីៗ ថាមានប្រវត្តិជាមួយក្រុមហ្វាស៊ីសនោះ តុលាការអឺរ៉ុប បានបញ្ជាក់ជាថ្មី ថាសេរីភាពក្នុងការបញ្ចេញមតិ មានសារៈប្រយោជន៍ខ្ពស់បំផុត នៅក្នុងបរិបទនៃការពិភាក្សាផ្នែកនយោបាយ ហើយបានពិចារណាថា ហេតុផលយ៉ាងដុំកំភួនត្រូវតែធ្វើឡើងដើម្បីបញ្ជាក់ទៅលើការរិត ត្បិតទាំងឡាយនោះ នៅក្នុងការថ្លែងការណ៍នយោបាយ។ តុលាការបានយល់ថាការថ្លែងរបស់អ្នកដាក់ពាក្យបណ្តឹងនេះ ជាការវិនិច្ឆ័យដែលមានគុណតំលៃមួយ ដែលភាពពិតប្រាកដនៃការវិនិច្ឆ័យនេះមិនរងគ្រោះទៅដល់ភស្តុតាងនោះទេ ហើយបានថ្លែងថា ”លក្ខខណ្ឌតម្រូវដើម្បីបង្ហាញការពិតនៃការវិនិច្ឆ័យប្រកបដោយគុណតំលៃមួយមិនអាចធ្វើទៅបានដើម្បីបំពេញនិងរំលោភទៅលើសេរីភាពនៃការមានមតិយោបល់នោះទេ ”។ ការបរិយាយទៅលើថាតើការវិនិច្ឆ័យប្រកបដោយគុណតំលៃមានទំហំប៉ុណ្ណា ដែលផ្សារភ្ជាប់ទៅនឹងការពិតនានា តុលាការបានសន្និដ្ឋានថា សេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកប្តឹងនេះត្រូវបានគេរំលោភ ពីព្រោះថាតុលាការក្នុងស្រុកបានខកខានក្នុងការបង្ហាញឱ្យឃើញពីសេចក្តីត្រូវការផ្នែកសង្គមដែលចាំបាច់ ដើម្បីធ្វើជាមូលហេតុក្នុងការការពារទៅលើសិទ្ធិបុគ្គលរបស់រដ្ឋមន្ត្រីនោះ ដែលត្រូវបង្ហាញឱ្យឃើញថាតើការការពារទៅលើរដ្ឋមន្ត្រីនោះ អាចមានចំណុចសំខាន់ខ្លាំង ជាងសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកប្តឹងរូបនេះ ហើយនិងសំខាន់ខ្លាំងជាងផលប្រយោជន៍ទូទៅ ក្នុងការលើកស្ទួយសេរីភាពស្តីពីបញ្ហានៃផលប្រយោជន៍សាធារណៈ ទៅទៀតដែរឬអត់។

នៅក្នុងរឿងរបស់ *Jersild*(១៩៩៤) អ្នកសារព័តិមានម្នាក់ត្រូវបានគេកាត់ទោសពីបទញុះញង់ឱ្យមានការរើសអើង បន្ទាប់ពីគាត់បានធ្វើបទសម្ភាសន៍មួយជាមួយពួកអ្នកលេង ដែលអ្នកទាំងនោះបានថ្លែងពីអំណះអំណាងជាតិសាសន៍និយមជ្រុលហួសហេតុ និងប្រឆាំងជនបរទេស។ តុលាការ

អ៊ីរ៉ុបបានរកឃើញថា ការកាត់ទោសនោះបានរំលោភលើសេរីភាពក្នុងការបញ្ចេញមតិ ជាពិសេស ដោយសារថា កម្មវិធីនោះជាទូទៅមានការរិះគន់ទៅលើក្រុមពួកអ្នកលេង និងមនោគមវិជ្ជារបស់ពួកគេហេតុដូច្នេះហើយមិនអាចបង្កើតឱ្យបានជាការញុះញង់ឱ្យមានការរើសអើងនោះទេ។

*“សេរីភាពក្នុងការបញ្ចេញមតិ គឺជាសសរគ្រឹះមួយ ដែលការរស់រានមានជីវិតរបស់សង្គមប្រជាធិបតេយ្យ ត្រូវពឹងផ្អែកទៅលើសសរគ្រឹះមួយនេះ។ វាជាការដែលមិនអាចខ្វះបាន ដើម្បីបង្កើតឱ្យបានជាទស្សនៈគំនិតជាសាធារណៈ។ វាក៏ជាលក្ខខណ្ឌដែលមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍន៍ឱ្យមានគណបក្សនយោបាយ សហជីព សង្គមវិទ្យាសាស្ត្រនិងវប្បធម៌ និងជាទូទៅ ចំពោះជនទាំងឡាយដែល មានបំណងជះឥទ្ធិពលរបស់ខ្លួន ទៅកាន់សាធារណៈជន។ និយាយដោយខ្លី វាតំណាងឱ្យមធ្យោបាយនានា ដែលផ្តល់លទ្ធភាពទៅឱ្យសហគមន៍ នៅពេលដែលធ្វើប្រតិបត្តិការទៅលើជំរើសរបស់ខ្លួន មានព័ត៌មានយ៉ាងគ្រប់គ្រាន់។ ជាលទ្ធផល វាអាចត្រូវបានគេនិយាយថា សង្គមមួយដែលមិនមានព័ត៌មានគ្រប់គ្រាន់ទេនោះ សង្គមនោះពុំមានសេរីភាពពិតប្រាកដនោះទេ ”។*

*តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង*

*ទស្សនៈផ្តល់ជាការប្រឹក្សាយោបល់ OC-5/85 ឃ្លាប្រយោគ ៧០។*

## សេរីភាពក្នុងការផ្សព្វផ្សាយព័ត៌មាន និងគំនិត

ទិដ្ឋភាពនៃសេរីភាពក្នុងការបញ្ចេញមតិនេះ មានសារៈសំខាន់ជាពិសេស ចំពោះសមាជិកសភា ដោយសារថា វានាំមកនូវសេរីភាពក្នុងការបញ្ចេញមតិផ្ទាល់របស់ពួកគេ នៅក្នុងផ្នែកនយោបាយ។ នៅក្នុងករណីនៃ *Kivenmaa ទល់នឹងប្រទេសហ្វាំងឡង់* (១៩៩៤) ពាក់ព័ន្ធទៅនឹងការធ្វើបាតុកម្មមួយ ដើម្បីថ្កោលទោសទៅលើប្រវត្តិសិទ្ធិមនុស្សរបស់ប្រមុខរដ្ឋបរទេសម្នាក់ ដែលកំពុងធ្វើដំណើរទស្សនៈកិច្ចផ្លូវការមកកាន់ប្រទេស

ហ្វាំងឡង់នោះ គណៈកម្មាធិការសិទ្ធិមនុស្ស បានរកឃើញថា "សិទ្ធិរបស់បុគ្គលម្នាក់ ក្នុងការបញ្ចេញនូវទស្សនៈយល់ឃើញផ្នែកនយោបាយ ដោយរួមមានទាំងទស្សនៈយល់ឃើញរបស់គាត់ ទៅលើរឿងសិទ្ធិមនុស្សយ៉ាងជាក់ច្បាស់នោះ បង្កើតបានជាផ្នែកមួយនៃសេរីភាពក្នុងការបញ្ចេញមតិ ដែលត្រូវបានធានាដោយ មាត្រា១៩ នៃកតិកាសញ្ញានេះ"។ ដូចដែលតុលាការសិទ្ធិមនុស្សអឺរ៉ុប បានថ្លែងដោយស៊ីសង្វាក់គ្នាថា "វាមិនគ្រាន់តែអនុវត្តទៅលើព័ត៌មាន ឬគំនិតនានាដែលត្រូវបានទទួលដោយពេញចិត្ត ឬត្រូវបានគេយល់ថាមានលក្ខណៈមិនប្រមាថមើលងាយ ឬជារឿងដែលមិនមានភាពខុសពីគេប៉ុណ្ណោះទេ ថែមទាំងអនុវត្តទៅលើព័ត៌មាន ឬគំនិតដែលប្រមាថ ធ្វើឱ្យភ័យស្លន់ស្លោ ឬរំខានថែមទៀតផង" (សូមមើលប្រអប់ ៦៨)។

## *សេរីភាពក្នុងការស្វែងរក និង ទទួលព័ត៌មាន*

*"ស្ថាប័នសាធារណៈនានា មានផ្ទុកព័ត៌មានទាំងឡាយ មិនមែនសម្រាប់តែខ្លួនពួកគេនោះទេ ប៉ុន្តែក៏ជាអ្នកមើលថែទាំសុខមាលភាពសាធារណៈ ហើយបុគ្គលរាល់រូបមានសិទ្ធិក្នុងការទទួលបាននូវព័ត៌មានទាំងនោះ ដោយយោងទៅតាមបទដ្ឋានដែលត្រូវបានចែងយ៉ាងច្បាស់លាស់ និងដែលត្រូវបង្កើតឡើងដោយច្បាប់"។*

*សេចក្តីប្រកាសនៃគោលការណ៍ពីសេរីភាពក្នុងការបញ្ចេញមតិនៅអាហ្វ្រិក អត្ថបទលេខ IV ។*

បើពុំមានសេរីភាពក្នុងការស្វែងរក និងទទួលបានព័ត៌មានទេនោះ ប្រព័ន្ធផ្សព្វផ្សាយ សមាជិក-សភា និងអ្នកផ្សេងទៀត នឹងមិនមានលទ្ធភាពក្នុងការបើកកកាយករណីនានា ដែលទាក់ទិនទៅនឹងអំពើពុករលួយ ការគ្រប់គ្រងមិនត្រឹមត្រូវ ឬអប្រសិទ្ធភាពនានា និងធានាឱ្យមានរដ្ឋាភិបាលដែលមានតម្លាភាព និងគណនេយ្យភាពនោះទេ។ នៅក្នុងរបាយការណ៍ឆ្នាំ១៩៩៥ របស់លោកទៅកាន់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អ្នករាយការណ៍ពិសេសរបស់សហប្រជាជាតិ ទទួលបន្ទុកលើសេរីភាពនៃគំនិត និងការបញ្ចេញមតិ បានសង្កត់ធ្ងន់ថា

"សេរីភាពនឹងគ្មានប្រសិទ្ធភាពអ្វីទាំងអស់ ប្រសិនបើ ប្រជាជន ពុំមានសិទ្ធិក្នុងការទទួលបាន ព័ត៌មានទេនោះ ។ សិទ្ធិទទួលបានព័ត៌មាន គឺជាមូលដ្ឋាន ចំពោះរបៀបរស់នៅ ប្រកបដោយប្រជាធិបតេយ្យ ។ ដូច្នេះហើយ និន្នាការនាំឱ្យមានការលាក់ទុកព័ត៌មានពីប្រជាជនទូទៅ គឺត្រូវតែលើកយកមកពិនិត្យឱ្យបាន យ៉ាងយកចិត្តទុកដាក់ " ។[៣៤]

## ប្រអប់ ៦៩

### ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន

ប្រទេសជាច្រើនបានអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ។ ច្បាប់ប្រភេទនោះបានក្លាយជាលិខិតុបករណ៍មួយដ៏សំខាន់ក្នុងការធ្វើឱ្យការរំលោភសិទ្ធិមនុស្ស និងការប្រយុទ្ធទៅនឹងនិទណ្ឌភាពលេចចេញឡើង ។ នៅក្នុងការសិក្សាទៅលើនិទណ្ឌភាព ដែលរៀបចំធ្វើឡើងសម្រាប់គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០០៤ អ្នកជំនាញការឯករាជ្យ (ដើម្បីប្រមូលព័ត៌មានថ្មីៗទៅលើគោលការណ៍មួយចំនួនសម្រាប់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស តាមរយៈវិធានការប្រឆាំងនឹងនិទណ្ឌភាព) បានផ្តល់នូវឧទាហរណ៍មួយចំនួនដែលក្នុងនោះ មានដូចជា ច្បាប់នានាដែលផ្តល់លទ្ធភាពឱ្យជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សបានដឹងពីការពិត ។ ជាឧទាហរណ៍ កន្លែងទុកដាក់ឯកសារប្រវត្តិសាស្ត្រអាហ្វ្រិកខាងត្បូងរបស់សាកលវិទ្យាល័យ Witwatersrand បានប្រើប្រាស់ច្បាប់ស្តីពីការលើកស្ទួយសិទ្ធិទទួលបានព័ត៌មានរបស់អាហ្វ្រិកខាងត្បូង ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០០ ដើម្បីបន្តរកឯកសារដែល "បាត់ " ហើយធ្វើការបង្ហាញឱ្យដឹងអំពីទំហំដែលឯកសារខ្លះ ត្រូវបានគេលាក់មិនឱ្យគណៈកម្មការស្វែងរកការពិតរបស់ប្រទេសបានដឹងឡើយ ។ អ្នកជំនាញរូបនេះបានផ្តល់អនុសាសន៍ថា "ដោយយល់ទៅលើសក្តានុពលរបស់ឯកសារទាំងនោះ ទៅលើការលើកកំពស់សិទ្ធិ

[៣៤] E/CN.4/1995/32 ឃ្លាប្រយោគ ៣៥ ។

ក្នុងការទទួលបានការពិតរបស់ប្រជាពលរដ្ឋ ទាក់ទិនទៅនឹងការរំលោភសិទ្ធិមនុស្សរដ្ឋទាំងឡាយ ដែលមិនទាន់បានអនុម័តច្បាប់ ដែលផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋនូវសិទ្ធិទទួលបានឯកសាររបស់រដ្ឋាភិបាល រួមបញ្ចូលទាំងព័ត៌មាន ដែលត្រូវបិទបាំងនានាពាក់ព័ន្ធទៅលើរឿងសិទ្ធិមនុស្សផងដែរ"។ គាត់បាននិយាយទៅដល់គំរូនេះ ទាក់ទិនទៅនឹងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានរបស់រដ្ឋាភិបាលសហព័ន្ធម៉ិចស៊ិចកូ (Ley Federal de Acceso a la Informacion) ដែលបានអនុម័តនៅឆ្នាំ២០០២ " ដែលហាមឃាត់ដល់ការបដិសេធមិនឱ្យលាក់ទុកឯកសារដែលរៀបរាប់អំពី "ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ" នោះទេ។[៣៥]

## សេរីភាពរបស់សារព័ត៌មាន

ទិដ្ឋភាពដ៏សំខាន់មួយនៃសេរីភាពក្នុងការសំដែងមតិ គឺជាសេរីភាពនៃការបោះពុម្ពនិងសារព័ត៌មាន។ គណៈកម្មាធិការសិទ្ធិមនុស្ស បានគូសបញ្ជាក់នៅក្នុងសេចក្តីពន្យល់ទូទៅរបស់ខ្លួនលេខ១០ ថា "....ដោយសារតែការអភិវឌ្ឍន៍នៃប្រព័ន្ធសារព័ត៌មាននាសម័យទំនើប វិធានការមានប្រសិទ្ធភាពនានា ត្រូវតែធ្វើឡើង ដើម្បីទប់ស្កាត់ការត្រួតត្រាទៅលើសារព័ត៌មាន ដែលធ្វើដូចនេះអាចនឹងមានផលប៉ះពាល់ទៅលើសិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបាននូវសេរីភាពនៃការបញ្ចេញមតិ នៅក្នុងរបៀបមួយ ដែលមិនត្រូវបានចែងឡើង..."។

## ការរិតត្បិត

មាត្រា១៩(៣) នៃCCPR ធ្វើការសង្កត់ធ្ងន់ថា ការអនុវត្តសិទ្ធិទទួលបានសេរីភាព ក្នុងការបញ្ចេញមតិ នាំមកជាមួយនូវករណីយកិច្ច និងការទទួលខុសត្រូវពិសេសនានា ហើយថាករណីយកិច្ច និងការទទួលខុសត្រូវនេះបញ្ជាក់ពីការរិតត្បិតនានា ទៅលើសិទ្ធិនោះដែរ។

---

[៣៥] E/CN.4/2004/88 ឃ្លាប្រយោគ ២០។

ការរិតត្បិតណាមួយ ទៅលើសិទ្ធិទទួលបានសេរីភាព ក្នុងការបញ្ចេញមតិ ត្រូវតែឆ្លើយតបទៅនឹងការធ្វើតេស្តបញ្ជាក់ដោយតឹងតែង ដូចខាងក្រោម៖

- ការរិតត្បិត ត្រូវតែមាន*ចែងឡើងដោយច្បាប់* (ច្បាប់ដែលអនុម័តដោយសភា ច្បាប់រួមគ្នាដែលចេញមកពីតុលាការឬវិធានវិជ្ជាជីវៈនានា)។ ការរិតត្បិត ត្រូវតែមានភាពជាក់លាក់ និងឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃភាពច្បាស់លាស់ និងអាចព្យាករណ៍បានតាមផ្នែកច្បាប់៖ វាអាចត្រូវបានគេផ្តល់ទៅឱ្យបុគ្គលដែលពាក់ព័ន្ធ ហើយលទ្ធផលរបស់វា ទៅលើបុគ្គលនោះ ត្រូវតែជាអ្វីដែលអាចមើលឃើញជាមុនបាន។ ច្បាប់នានា ដែលមានន័យស្រពិចស្រពិល ឬអនុញ្ញាតិឱ្យមានឆន្ទានុសិទ្ធិជ្រុលពេក នៅក្នុងការអនុវត្តរបស់វានោះ មានការខកខានក្នុងការការពារបុគ្គលទាំងឡាយនោះប្រឆាំងទៅនឹងការជ្រៀតជ្រែកដោយបំពាន ហើយមិនបង្កើតបានជាការការពារគ្រប់គ្រាន់ ប្រឆាំងទៅនឹងការរំលោភបំពាននោះទេ។
- ការរិតត្បិត ត្រូវតែមានការចាំបាច់ សម្រាប់៖

  (ក) ការគោរពសិទ្ធិ ឬកេរ្តិ៍ ឈ្មោះរបស់អ្នកដទៃ

  (ខ) ការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

លក្ខណៈវិនិច្ឆ័យខាងក្រោយនេះ អាចធ្វើទៅបាន លុះត្រាតែ ក្នុងករណីដែលការិតត្បិតនោះឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្នែកសង្គមដែលបន្ទាន់មួយ ហើយវាមានចំនួនសមាមាត្រទៅនឹងគោលបំណងស្របច្បាប់ ដែលត្រូវបន្តធ្វើដូច្នេះ ទើបការខូចខាតទៅលើសេរីភាពក្នុងការបញ្ចេញមតិ មិនមានទម្ងន់ធ្ងន់ជាងផលប្រយោជន៍នានា។

ប្រអប់ ៧០

## ការការពារសេរីភាពសារព័ត៌មាន

សភាអាចចាត់ជំហានមួយចំនួន ដែលអាចចូលរួមចំណែក ក្នុងការធានាឱ្យសារព័ត៌មានមានលក្ខណៈសេរី និងឯករាជ:

- ពិនិត្យឡើងវិញច្បាប់សារព័ត៌មាននិងធ្វើវិសោធនកម្មលើច្បាប់ទាំងនោះ ហើយប្រសិនបើចាំបាច់ កែប្រែច្បាប់ទាំងនោះ ដើម្បីធ្វើឱ្យមានភាពស្របគ្នាទៅនឹងមាត្រា១៩ នៃ ICCPR ជាពិសេស ដូចទៅនឹងការផ្តល់អនុសាសន៍ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសេរីភាពនៃគំនិត និងការបញ្ចេញមតិ។ លុបចោលច្បាប់ទាំងឡាយណា ដែលដាក់ទណ្ឌកម្ម ទៅលើបទល្មើសផ្នែកព័ត៌មាន ដោយដាក់ពន្ធនាគារ លើកលែងតែក្នុងករណីពាក់ព័ន្ធទៅនឹង ការឱ្យមតិយោបល់ ប្រកាន់ជាតិសាសន៍ ឬរើសអើង ឬការអំពាវនាវឱ្យមានអំពើហឹង្សា ហើយធ្វើការធានាថា ការផាកពិន័យ សម្រាប់បទល្មើស ដូចជា ការបង្ខូចកេរ្តិ៍ឈ្មោះ ការបរិហារកេរ្តិ៍ និង ការជេរប្រមាថ ។ល។ មិនត្រូវលើសពីសមាមាត្រទៅនឹងការខូចខាតដែលរងទទួល ដោយជនរងគ្រោះនោះទេ។
- លើកស្ទួយឱ្យមានភាពពហុនិយម និងឯករាជ្យភាពរបស់សារព័ត៌មាន
- ធានាថា អ្នកប្រកាសផ្សព្វផ្សាយ ត្រូវបានការពារប្រឆាំងទៅនឹងឥទ្ធិពលនយោបាយ និង ពាណិជ្ជកម្ម ដោយរួមទាំងតាមរយៈការតែងតាំងនូវគណៈគ្រប់គ្រងឯករាជ្យមួយ ហើយមាន ការគោរពចំពោះឯករាជ្យភាពផ្នែកវិចារណកថា។
- ធានាថា អាជ្ញាធរផ្សព្វផ្សាយឯករាជ្យមួយ ត្រូវបានបង្កើតឡើង
- បង្កើតលក្ខណៈវិនិច្ឆ័យច្បាស់លាស់ សម្រាប់ការទូទាត់ប្រាក់ និងការដកការឧបត្ថម្ភទុនរបស់រដ្ឋាភិបាល ចេញពីសារព័ត៌មាន ដើម្បីជៀសវាងនូវការប្រើប្រាស់ប្រាក់ឧបត្ថម្ភទុនសម្រាប់បំបិទមាត់ កុំឱ្យមានការរិះគន់ទៅលើអាជ្ញាធរ។
- ជៀសវាងការប្រមូលផ្តុំនៃការត្រួតពិនិត្យសារព័ត៌មានដោយហួសហេតុ អនុវត្តវិធានការនានាដោយធានានូវការបែងចែកធនធាននានា ដោយពុំមានភាពលំអៀង និងធានានូវការ

ដែលអាចរកបាននៃសារព័ត៌មាន ហើយអនុម័តច្បាប់ទប់ស្កាត់ការដាក់តំលៃមិនត្រឹមត្រូវទាក់ទិនទៅនឹង សារព័ត៌មាន។

- លើកស្ទួយការទទួលបានជាសកល នូវប្រព័ន្ធអ៊ីនធឺណែត។

## ការរិតត្បិត ដោយផ្អែកលើមូលដ្ឋាននៃសន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ

នៅក្នុងករណីរបស់ *Mukong ទល់នឹងប្រទេសកាមេរូន* (១៩៩៤) អ្នកកាសែតម្នាក់ បានទាមទារថា សិទ្ធិសេរីភាពរបស់គាត់ក្នុងការបញ្ចេញមតិ និងទស្សនៈគំនិត ត្រូវបានគេរំលោភ ហើយថា គាត់ត្រូវបានគេចាប់ខ្លួនជាច្រើនដង ហើយសៀវភៅគាត់ខ្លះ ត្រូវបានហាមប្រាមដោយរដ្ឋ ដោយសារតែសកម្មភាពរបស់គាត់ ជាអ្នកតស៊ូមតិនៃលទ្ធិប្រជាធិបតេយ្យពហុបក្ស។ រដ្ឋនោះ បានប្រើប្រាស់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ នៅក្រោមមាត្រា១៩(៣) នៃ ICCPR ដើម្បីគាំទ្រជំហររបស់ខ្លួន។ គណៈកម្មាធិការសិទ្ធិមនុស្ស បានសន្និដ្ឋានថា វិធានការដែលធ្វើឡើងដោយរដ្ឋនោះមិនមានភាពចាំបាច់ទេ ហើយបានពិចារណាថា "វត្ថុបំណងត្រឹមត្រូវនៃការការពារ និងការពង្រឹងឯកភាពជាតិ នៅក្រោមកាលៈទេសៈនយោបាយដ៏លំបាកនោះ មិនអាចត្រូវបានធ្វើឱ្យសម្រេច តាមរយៈការព្យាយាមបំបិទកុំឱ្យមានការតស៊ូមតិ ទៅលើប្រជាធិបតេយ្យពហុបក្ស គោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សឡើយ "។

## ការរិតត្បិត ដោយផ្អែកលើមូលដ្ឋានសីលធម៌សាធារណៈ

នៅក្នុងករណីរបស់ *Open Door Counselling and Dublin Woman Well Centre and Others ទល់ជាមួយប្រទេសអៀកឡង់* (១៩៩២) អ្នកដាក់ពាក្យប្តឹងដែលជាសាជីវកម្មទាំងពីរ បានពាក់ព័ន្ធទៅក្នុងការប្រឹក្សាយោបល់ ដែលមិនមានលក្ខណៈជាបញ្ហាទៅលើស្ត្រីមានផ្ទៃពោះ ក្នុងប្រទេសអៀកឡង់ ដោយទាក់ទិនទៅនឹងលទ្ធភាព ក្នុងការទទួលបានការ

រំលូតកូននៅក្នុងគ្លីនិកនានា នៅក្នុងចក្រភពអង់គ្លេស ។ ដីកាបញ្ឈប់ជាបន្ទាន់ស្ថាពរមួយ ត្រូវបានធ្វើឡើងដើម្បីឃាត់ស្កាត់ពួកគេពីសកម្មភាពនោះ ដោយឈរលើមូលដ្ឋានថា ការរំលូតកូនជាការខុសច្បាប់ នៅក្រោមរដ្ឋធម្មនុញ្ញរបស់ប្រទេសអៀរឡង់។ តុលាការសិទ្ធិមនុស្សអឺរ៉ុប ខណៈពេលដែលធ្វើការថ្លែងថា ឆន្ទានុសិទ្ធិរបស់រដ្ឋ នៅក្នុងវិស័យនៃការការពារសីលធម៌មិនត្រូវបានធ្វើដោយសេរី និងដោយគ្មានការពិនិត្យមើលឡើងវិញនោះទេ តុលាការនេះបានថ្លែងសង្កត់ធ្ងន់ថា អាជ្ញាធរជាតិនានាទទួលបាននូវការពេញចិត្ត ដែលមានទំហំធំទៅលើរឿងសីលធម៌ និងបានបញ្ជាក់ឡើងវិញពីគោលជំហររបស់ខ្លួនថា វាជាការមិនអាចធ្វើទៅកើតទេ ក្នុងការរកឱ្យឃើញ នូវគោលគំនិតផ្នែកសីលធម៌របស់អឺរ៉ុប ដែលមានលក្ខណៈឯកភាពដូចៗគ្នា នៅក្នុងចំណោមរបៀបរបបតាមផ្លូវច្បាប់ និងសង្គមរបស់រដ្ឋជាភាគីនោះ ។ ទោះជាយ៉ាងនេះក៏ដោយ តុលាការបានពិចារណាថា ដីកាបញ្ឈប់ដែលធ្វើឡើងនោះ មានលក្ខណៈទូលំទូលាយពេក ហើយពុំមានសមាមាត្រឡើយ ។ ដូច្នេះហើយតុលាការបានសម្រេចថា វាបានបង្កើតឱ្យមានការរំលោភមួយ ទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យបណ្ដឹង ទាំងក្នុងការផ្សព្វផ្សាយព័ត៌មាន និងទាំងក្នុងការទទួលព័ត៌មានរបៀបនោះ ។

## ការរិតត្បិត ដោយផ្អែកលើមូលដ្ឋាននៃការគោរពទៅលើសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ

នៅក្នុងសំណុំរឿងរបស់ *Krone Verlag GmbH និង Co.KG ទល់នឹងប្រទេសអូទ្រីស* (២០០២) ទាក់ទិនទៅនឹងការទប់ស្កាត់កាសែតមួយ មិនឱ្យធ្វើការបោះពុម្ពផ្សាយរូបភាពរបស់អ្នកនយោបាយមួយរូប ព្រមជាមួយនឹងការចោទប្រកាន់នានា អំពីស្ថានភាពហិរញ្ញវត្ថុរបស់គាត់នោះ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានរកឃើញថា ការជ្រៀតជ្រែកដោយអាជ្ញាធរត្រូវបានចែងឡើងដោយច្បាប់ ហើយធ្វើទៅតាមគោលបំណងធម្មានុភាពក្នុងការការពារភាពឯកជនរបស់បុគ្គលម្នាក់ ក៏ប៉ុន្តែមិនបានឆ្លើយតបទៅនឹងការធ្វើតេស្តទៅលើភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យមួយទេ។ តុលាការបានរកឃើញថាបញ្ហាដែលបានលើក

ឡើងនេះ មានការចាប់អារម្មណ៍ពីសាធារណៈដែលថាវាជាប់ពាក់ព័ន្ធទៅនឹងមន្ត្រីសាធារណៈម្នាក់ ហើយថា ការបោះពុម្ពរូបភាពនោះតែម្តង មិនបានបង្ហាញឱ្យឃើញព័ត៌មានពិស្តារណាទៀត ពីជីវិតឯកជនរបស់អ្នកនយោបាយនោះទេ។ ជាលទ្ធផល ការជ្រៀតជ្រែកនេះ មិនបានដោះស្រាយតម្រូវការសង្គម ដែលចាំបាច់ ហើយបែរជាបង្កើតបានជាការរំលោភមួយ ទៅលើសេរីភាពក្នុងការបញ្ចេញមតិទៅវិញ។

**ប្រអប់ ៧១**

## សេរីភាពក្នុងការបញ្ចេញមតិ និងសមាជិកសភា: ការពិនិត្យយ៉ាងជិតដល់ពីការជ្រៀតជ្រែកណាមួយ ទៅលើសេរីភាពនៃការបញ្ចេញមតិ ប៉ុន្តែដោយការអត់ធ្មត់ធំធេងទៅលើមតិរិះគន់

សេរីភាពក្នុងការបញ្ចេញមតិ គឺជាឧបករណ៍ធ្វើការងារដ៏ចំបងរបស់សមាជិកសភា។ គណៈកម្មាធិការរបស់ IPU ទទួលបន្ទុកសិទ្ធិមនុស្សរបស់សភា បានសង្កត់ធ្ងន់ដោយស៊ីសង្វាក់ថា ដោយយោងទៅលើអាណត្តិតំណាងរបស់ពួកគេ សមាជិកសភាត្រូវតែមានលទ្ធភាពក្នុងការបញ្ចេញមតិរបស់ខ្លួនដោយសេរី ក្នុងឋានៈជាអ្នកការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលបោះឆ្នោតឱ្យពួកគេ។

នៅក្នុងករណីដ៏សំខាន់របស់ *Castells ទល់នឹងប្រទេសអេស្ប៉ាញ* (១៩៩២) ដែលពាក់ព័ន្ធទៅនឹងសមាជិកសភាម្នាក់ ដែលត្រូវបានជាប់ទោស ដោយសារការបោះពុម្ពផ្សាយអត្ថបទមួយដោយចោទប្រកាន់រដ្ឋាភិបាលបានចូលរួមផ្សំគំនិតទៅលើការវាយប្រហារនិងឃាតកម្មជាច្រើននោះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានថ្លែងថា "នៅពេលសេរីភាពនៃការបញ្ចេញមតិមានសារៈសំខាន់ចំពោះមនុស្សគ្រប់ រូបនោះ វាកាន់តែសំខាន់ថែមទៀតចំពោះអ្នកតំណាងប្រជាពលរដ្ឋដែលត្រូវបានគេបោះឆ្នោតឱ្យ។ គាត់តំណាងឱ្យមណ្ឌលបោះឆ្នោតរបស់គាត់ គាត់ធ្វើឱ្យមានការចាប់អារម្មណ៍ទៅលើការបារម្ភរបស់ពួកគេ ហើយធ្វើការការពារផលប្រយោជន៍របស់ពួកគេ។ ស្របគ្នានេះ ការជ្រៀតជ្រែកទៅលើសិទ្ធិក្នុងការបញ្ចេញមតិរបស់សមាជិកសភាមកពីគណបក្សប្រឆាំង

..ទាមទារឱ្យមានការពិនិត្យពិច័យពីសំណាក់តុលាការ..."។ តុលាការក៏បានបញ្ជាក់ផងដែរថា "កម្រិតនៃមតិរិះគន់ ដែលអាចអនុញ្ញាតិឱ្យធ្វើទៅបានចំពោះការរិះគន់ទាំងឡាយណាទៅលើរដ្ឋាភិបាលមានលក្ខណៈធំទូលាយជាងការរិះគន់ទៅលើប្រជាជនឯកជន ឬក៏អ្នកនយោបាយម្នាក់។ នៅក្នុងប្រព័ន្ធប្រជាធិបតេយ្យមួយ អំពើសកម្ម ឬអំពើអកម្មរបស់រដ្ឋាភិបាល ត្រូវតែទទួលនូវការត្រួតពិនិត្យយ៉ាងដិតដល់ មិនត្រឹមតែពីសំណាក់អាជ្ញាធរសភា និងតុលាការនោះតែប៉ុណ្ណោះទេថែមទាំងទទួលការត្រួតពិនិត្យពីសំណាក់សារព័ត៌មាន និងទស្សនៈរបស់សាធារណៈផងដែរ។ បន្ថែមលើនេះទៀត តួនាទីដែលមានចរឹតត្រួតត្រាគ្របដណ្តប់លើគេរបស់រដ្ឋាភិបាល ធ្វើឱ្យមានភាពចាំបាច់ សម្រាប់ឱ្យរដ្ឋាភិបាលធ្វើការជៀសវាងក្នុងការបន្តប្តឹងផ្នែកព្រហ្មទណ្ឌនានា ជាពិសេសនៅកន្លែងណា ដែលមានមធ្យោបាយដទៃផ្សេងទៀត សម្រាប់ធ្វើការឆ្លើយតបទៅនឹងការវាយប្រហារ និងការរិះគន់មិនត្រឹមត្រូវពីគូបដិបក្សរបស់ខ្លួន ឬ ពីសំណាក់សារព័ត៌មាន..."។ នៅក្នុងករណីជាច្រើន តុលាការអឺរ៉ុប បានសម្រេចថា ដើម្បីការពារសេរីភាពក្នុងការបញ្ចេញមតិ ប្រជាពលរដ្ឋគួរត្រូវបានគេអនុញ្ញាតិឱ្យធ្វើការ រិះគន់ទៅលើអ្នកនយោបាយឱ្យបានខ្លាំងក្លា ជាងទៅលើបុគ្គលទាំងឡាយ ដែលមិនត្រូវបានជ្រើសរើសឱ្យធ្វើជាមន្ត្រីសាធារណៈ (សូមមើលករណីជាក់ស្តែងរបស់ *Lingens ទល់នឹងប្រទេស អូទ្រីស* (១៩៨៦) និង *Dichand និងអ្នកផ្សេងទៀត ទល់នឹងប្រទេសអូទ្រីស* (២០០២)។

## ការដាក់កំហិតជាចាំបាច់ ទៅលើសេរីភាពនៃការបញ្ចេញមតិ

មាត្រា២០ នៃ ICCPR ចេញបញ្ជីនៃការដាក់កំហិតជាចាំបាច់ ទៅលើមាត្រា១៩ ដែលទាក់ទិនទៅនឹងការឃោសនាឱ្យមានសង្គ្រាម និងការតស៊ូមតិឱ្យមានការស្អប់ខ្ពើមទៅលើសញ្ជាតិ ប្រកាន់ជាតិសាសន៍ ឬសាសនា ដែលបង្កើតបានជាការញុះញង់ឱ្យមានការរើសអើង ភាពប្រទុស្តរ៉ាយ ឬអំពើហឹង្សា។ គណៈកម្មាធិការសិទ្ធិមនុស្ស បានថ្លែងថា "ដើម្បីឱ្យមាត្រា២០ មានប្រសិទ្ធភាពពេញលេញ វា

ត្រូវតែមានច្បាប់មួយដែលធ្វើឱ្យកាន់តែច្បាស់ថា ការឃោសនា និងការតស៊ូមតិ ដូចបានពណ៌នាខាងលើ មានភាពផ្ទុយទៅនឹងគោលនយោបាយសាធារណៈ ហើយផ្ដល់ឱ្យមានការដាក់ទណ្ឌកម្មសមរម្យ ក្នុងករណីមានការរំលោភ" (សេចក្ដីពន្យល់ទូទៅ លេខ១១)។

គណៈកម្មាធិការសិទ្ធិមនុស្ស បានជំរុញឱ្យរដ្ឋាភិបាល ចាត់វិធានការតាមផ្លូវច្បាប់នានា ដើម្បីដាក់ការរិតត្បិតទៅលើការបោះពុម្ពផ្សាយ ឬការចែកចាយនូវឯកសារអាសគ្រាម និងអាសអាភាស ដោយមានបង្ហាញនូវស្ត្រី និងក្មេងស្រី ជាកម្មវត្ថុនៃអំពើហឹង្សា ឬការប្រព្រឹត្តិដោយបន្ថោកបន្ទាប និងអមនុស្សធម៌ (សេចក្ដីពន្យល់ទូទៅ លេខ២៨)។

**ប្រអប់ ៧២**

### *សំណុំរឿងរបស់ Faurisson ទល់នឹងប្រទេសបារាំង*
### (គណៈកម្មាធិការសិទ្ធិមនុស្ស ឆ្នាំ១៩៩៦)

លោក Faurisson ជាសាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រម្នាក់នៅសកលវិទ្យាល័យ Sorbonne នៅក្នុងក្រុងប៉ារីសរហូតដល់ឆ្នាំ១៩៧៣ និងនៅសកលវិទ្យាល័យ Lyons រហូតដល់ឆ្នាំ១៩៩១ នៅពេលដែលគាត់ ត្រូវបានគេបណ្ដេញចេញពីតួនាទីរបស់គាត់ ដោយសារតែគាត់បានចោទសួរពីអត្ថិភាព នៃការសម្លាប់ជាក្រុមដោយប្រើឧស្ម័នពុល នៅក្នុងជំរុំប្រមូលផ្ដុំរបស់ពួកណាហ្ស៊ី។ នៅឆ្នាំ១៩៩០ សភាបារាំង

បានអនុម័តច្បាប់ Gayssot ដែលកែប្រែទៅលើច្បាប់ឆ្នាំ១៨៨១ ស្ដីពីសេរីភាពរបស់សារព័ត៌មានដោយបានធ្វើឱ្យក្លាយជាបទល្មើសមួយ ក្នុងការប្រឆាំងទៅនឹងអត្ថិភាពនៃប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលកំនត់និយមន័យនៅក្នុងធម្មនុញ្ញទីក្រុងឡុង កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ដោយផ្អែកលើមូលដ្ឋាននោះ មេដឹកនាំណាហ្ស៊ី ត្រូវបានគេកាត់ទោស និងរកឃើញថា ជាប់ទោសដោយសាលាក្ដី Nuremberg ក្នុងឆ្នាំ១៩៤៥-១៩៤៦។ ក្នុងឆ្នាំ១៩៩១ អ្នកនិពន្ធរូបនេះ ត្រូវបានជាប់ទោសពីបទនិយាយឡើងវិញនូវទស្សនៈដដែលនៅក្នុងកិច្ចសម្ភាសន៍ ដែលមានការបោះពុម្ពផ្សាយមួយ។

អ្នកនិពន្ធនេះបានដាក់ពាក្យបណ្ដឹងរបស់គាត់ទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្ស ដោយធ្វើការជំទាស់ថា ច្បាប់ Gayssot បានរំលោភទៅលើសិទ្ធិរបស់គាត់ក្នុងការទទួលបានសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការអប់រំថ្នាក់ឧត្ដម។ គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញថា ការរិតត្បិតទៅលើសេរីភាពនៃការបញ្ចេញមតិរបស់លោក Faurisson ត្រូវបានអនុញ្ញាតិឱ្យធ្វើទៅបាននៅក្រោមមាត្រា១៩(៣)នៃ *ICCPR* ពីព្រោះថាការរិតត្បិតនោះបានបំរើនូវសចក្ដីប្រាថ្នាទៅកាន់សហគមន៍ជនជាតិជ្វីបឱ្យរស់នៅដោយសេរីផុតពីការភ័យខ្លាចពីបរិយាកាសដែលប្រឆាំងទៅនឹងជនជាតិជ្វីប។ គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញថា ការរិតត្បិតនេះ មានសារៈសំខាន់ ណាស់ក្នុងការទាមទារប្រឆាំងការប្រកាន់ពូជសាសន៍ និងប្រឆាំងការនិយមភាសា។

## សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម

### មាត្រា២០ នៃ UDHR

*"១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការបង្កើតសមាគមដោយសន្តិវិធី។*

*២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ។"*

### មាត្រា២១ នៃ ICCPR

*" សិទ្ធិប្រជុំដោយសន្តិវិធី ត្រូវតែទទួលស្គាល់ ។ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍ នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្ដាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។ "*

### មាត្រា២២(១) និង(២) នៃ ICCPR

*" ១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។*

*២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និង ដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាព សាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។ មាត្រានេះ មិនរារាំងដល់ការរិតត្បិត ខាងផ្លូវច្បាប់លើសមាជិកយោធា និងនគរបាលក្នុងការប្រើប្រាស់សិទ្ធិនេះទេ ។ "*

សេរីភាពក្នុងការប្រជុំ និងការបង្កើតសមាគមដោយសន្តិវិធី ជាមួយគ្នានឹងសេរីភាពក្នុងការបញ្ចេញមតិ គឺជាសិទ្ធិគន្លឹះនៅក្នុងសង្គមប្រជាធិបតេយ្យមួយ ដោយសារថា សិទ្ធិទាំងនេះអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ ។ ដូចនៅក្នុងករណីនៃសេរីភាពក្នុង-ការបញ្ចេញមតិដែរ សិទ្ធិទាំងនេះ ក៏ត្រូវមានកម្រិតជាក់លាក់នានាផងដែរ ។

## សេរីភាពក្នុងការជួបប្រជុំ

### *វិសាលភាព*

ការការពារសេរីភាពក្នុងការប្រជុំធានានូវសិទ្ធិក្នុងការរៀបចំការប្រជុំនានា ដែលមានគោលបំណង ដើម្បីពិភាក្សាព័ត៌មាន ឬគំនិតជាសាធារណៈ ឬដោយធ្វើការចែកចាយព័ត៌មានទាំងនោះ ។ ទោះជាយ៉ាងនេះក៏ដោយ ការជួបប្រជុំនានាត្រូវបានគេការពារ លុះត្រាតែវាត្រូវបានធ្វើឡើង "ដោយសន្តិវិធី " ជាពាក្យមួយដែលត្រូវតែធ្វើការបកស្រាយឱ្យបានទូលំទូលាយ ។ ជាឧទាហរណ៍ រដ្ឋភាគីត្រូវតែទប់ស្កាត់កុំឱ្យការជួបប្រជុំដោយសន្តិវិធីប្រែក្លាយទៅជាកុប្បកម្មមួយ ដោយសារមានការបង្កហេតុ ឬដោយប្រើកម្លាំង ដោយកម្លាំងសន្តិសុខ ឬភាគីឯកជននានា ដូចជាបាតុករប្រឆាំងបាតុករដូចគ្នា ឬដោយភ្នាក់ងារបង្កហេតុនានាជាដើម ។

រដ្ឋនានា ស្ថិតនៅក្រោមកាតព្វកិច្ចមួយ ដើម្បីចាត់វិធានការជាវិជ្ជមានទាំងឡាយ

ដើម្បីធានានូវសិទ្ធិនេះ ហើយធ្វើការការពារប្រឆាំងទៅនឹងការជ្រៀតជ្រែកដោយភ្នាក់ងាររដ្ឋ និងភាគីឯកជនផងដែរ។ ដើម្បីទទួលបានគោលបំណងនេះ អាជ្ញាធរ ត្រូវតែចាត់វិធានការធានាឱ្យមានដំណើរការប្រព្រឹត្តទៅដោយរលូន នៃការប្រមូលផ្តុំ និងការធ្វើបាតុកម្មនានា។ ស្របជាមួយគ្នានេះដែរ ពួកគេគួរត្រូវតែបានគេឱ្យដំណឹងអំពីទីកន្លែង និងពេលវេលានៃការជួបប្រជុំនោះ ដោយមានការជូនដំណឹងជាមុនឱ្យបានគ្រប់គ្រាន់ ហើយគួរត្រូវបានគេអនុញ្ញាតឱ្យចូលទៅកន្លែងជួបប្រជុំនោះបាន។

## *ការដាក់កំហិតផ្សេងៗ*

សិទ្ធិក្នុងការប្រជុំដោយសន្តិវិធី ត្រូវរងនូវការរិតត្បិតជាច្រើន ដែលត្រូវតែ:

- ស្របទៅតាមច្បាប់: ការជ្រៀតជ្រែក ទៅលើសេរីភាពក្នុងការប្រជុំ អាចត្រូវបានធ្វើឡើងយ៉ាងឯករាជ្យដោយអាជ្ញាធររដ្ឋបាលនានា ជាពិសេស ដោយប៉ូលីស ដោយផ្អែកលើមូលដ្ឋាននៃការអនុញ្ញាតិដែលមានចែងនៅក្នុងច្បាប់ទូទៅមួយ
- មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យមួយ: ឧទាហរណ៍ វាមានសមាមាត្រនិងស្របគ្នាជាមួយ នឹងគុណតំលៃប្រជាធិបតេយ្យជាមូលដ្ឋាន នៃពហុនិយម ភាពអត់អោន ការយោគយល់ទូលំទូលាយ និងអធិបតេយ្យភាពរបស់មនុស្ស ហើយស្របតាមនេះដែរការបំបែកការជួបប្រជុំដោយកម្លាំងបង្ខំ អាចអនុញ្ញាតឱ្យធ្វើទៅបាន លុះត្រាតែគ្រប់មធ្យោបាយសមល្មមនានា បានទទួលបរាជ័យមក។
- មានបំណងទៅលើគោលបំណងជាធម្មានុភាព ដូចជា សន្តិសុខជាតិ សុវត្ថិភាពសាធារណៈ (ការជួបប្រជុំអាចត្រូវបានគេធ្វើការបំបែកបាន ប្រសិនបើវានាំឱ្យមានការគំរាមកំហែងជាក់លាក់ណាមួយ ទៅលើបុគ្គល និងអ្នកធ្វើដំណើរ កាត់កន្លែងប្រជុំនោះ) សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ និងសីលធម៌សាធារណៈ និងសិទ្ធិ និងសេរីភាពរបស់អ្នកដទៃផ្សេងទៀត។

## សេរីភាពខាងសមាគម

### *វិសាលភាព*

ការការពារសេរីភាពក្នុងការបង្កើតសមាគម ធានានូវសិទ្ធិរបស់ជនគ្រប់រូប ក្នុងការបង្កើតសមាគមមួយ ជាមួយបុគ្គលដែលមានការយល់ឃើញស្រដៀងគ្នា ឬដើម្បីចូលរួមទៅក្នុងសមាគមដែលមានស្រាប់មួយ ។ ដូច្នេះហើយ ប្រព័ន្ធបក្សតែមួយដ៏តឹងរឹងដែលច្រានចោល មិនឱ្យមានការបង្កើត និងសកម្មភាពនានារបស់គណៈបក្សនយោបាយផ្សេងៗ រំលោភទៅលើសេរីភាពក្នុងការបង្កើតសមាគម ។ ការបង្កើតសមាគម នឹងក្លាយជាសមាជិកភាព នៅក្នុងសមាគមត្រូវតែមានលក្ខណៈស្ម័គ្រចិត្ត គ្មានជនណាម្នាក់អាចត្រូវគេបង្ខំដោយផ្ទាល់ និងដោយប្រយោល ដោយរដ្ឋ ឬដោយភាគីឯកជននានា ឱ្យចូលរួមទៅក្នុងគណៈបក្សនយោបាយមួយ សង្គមសាសនាមួយ ក្រុមពាណិជ្ជកម្ម ឬក្នុងក្លឹបកីឡាមួយបានឡើយ ។ រដ្ឋទាំងឡាយស្ថិតនៅក្រោមកាតព្វកិច្ចមួយ ដើម្បីផ្តល់ក្របខ័ណ្ឌច្បាប់ សម្រាប់ការបង្កើតសមាគម និងដើម្បីការពារសិទ្ធិនេះ ប្រឆាំងទៅនឹងការជ្រៀតជ្រែកដោយភាគីឯកជននានា ។

សេរីភាពក្នុងការបង្កើតសមាគម រួមបញ្ចូលនូវសិទ្ធិក្នុងការបង្កើត និងចូលរួមទៅក្នុងសហជីពនានាដើម្បីការពារផលប្រយោជន៍របស់បុគ្គលមួយ ។ សិទ្ធិរបស់សហជីពត្រូវបានលើកឡើងយ៉ាងពិសេស នៅក្នុងមាត្រា៨ នៃ **ICESCR** ។

**ប្រអប់ ៧៣**

***ករណីរបស់គណៈបក្សសង្គមនិយមនៃប្រទេសទួគី (STP) និងអ្នកផ្សេង ទល់នឹងប្រទេសទួគី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប)**

គណៈបក្សសង្គមនិយមនៃប្រទេសទួគី(STP) ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ១៩៩២ ក៏ប៉ុន្តែ នៅថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៩៣ តុលាការធម្មនុញ្ញប្រទេសទួគីបានបញ្ជា

ឱ្យរំលាយគណៈបក្សចោល ដែលផ្អែកលើមូលដ្ឋានថា កម្មវិធីរបស់គណៈបក្សនោះអាចនឹងធ្វើឱ្យខូចខាតទៅលើបូរណភាពដែនដីរបស់ប្រទេស និងឯកភាពជាតិ។ តុលាការបានរកឃើញថា STP បានអំពាវនាវឱ្យមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចជោគវាសនាដោយខ្លួនឯង សម្រាប់ក្រុមពួក Kurds ហើយបានគាំទ្រ សិទ្ធិក្នុងការ "ធ្វើសង្គ្រាមដើម្បីទាមទារឯករាជ្យភាព" ហើយបាន ប្រដូចទស្សនៈយល់ឃើញរបស់ខ្លួនទៅនឹងក្រុមភេរវករ។ អ្នកដាក់ពាក្យប្តឹងក្នុងចំណោមការចោទប្រកាន់ជាច្រើននោះបានចោទថា ការរំលាយគណៈបក្សចោលនោះបានរំលោភសិទ្ធិរបស់ពួកគេដែលត្រូវបានធានានៅក្រោមមាត្រា១១នៃECHR ស្តីពីសិទ្ធិក្នុងការបង្កើតសមាគម។

តុលាការសិទ្ធិមនុស្សអឺរ៉ុប បានរកឃើញថា ការរំលាយ STP បានបង្កើតឱ្យមានការជ្រៀតជ្រែកមួយទៅលើសិទ្ធិក្នុងការទទួលបានសេរីភាពក្នុងការបង្កើតសមាគមរបស់អ្នកប្តឹងពិតមែន។ វាពុំមានសេចក្តីបញ្ជាក់ណាសម្រាប់ធ្វើឱ្យរាំងស្ទះទៅដល់គណៈបក្សនយោបាយមួយ ដោយគ្រាន់តែគណៈបក្សនយោបាយនោះស្វះស្វែងរកការពិភាក្សាជាសាធារណៈអំពីស្ថានភាពមួយផ្នែករបស់ប្រជាជនទាំងមូលរបស់រដ្ឋ ហើយស្វះស្វែងចូលរួមទៅក្នុងជីវិតនយោបាយរបស់ប្រទេស ដើម្បីធ្វើការស្វែងរកដំណោះស្រាយនានា ដោយប្រើមធ្យោបាយមានលក្ខណៈប្រជាធិបតេយ្យ ដែលមានលទ្ធភាពក្នុងការធ្វើឱ្យក្រុមពាក់ព័ន្ធនានាមានការពេញចិត្ត។ បន្ថែមលើនេះទៅទៀត ដោយសារតែតុលាការធម្មនុញ្ញ បានធ្វើសេចក្តីសម្រេចនេះ ទាំងមុនពេលដែល STP បានចាប់ផ្តើមសកម្មភាព របស់ខ្លួនទៅទៀត ដូច្នេះតុលាការអឺរ៉ុប បានរកឃើញថា ពុំមានភស្តុតាងនៅចំពោះមុខ ដើម្បីគាំទ្រទៅ នឹងការចោទប្រកាន់ថា STP អំពីទំនួលខុសត្រូវណាមួយទៅលើបញ្ហានានា ដែលបង្កឡើងដោយភេរវកម្មនៅក្នុងប្រទេសទួគីនោះទេ។ ដូច្នេះហើយ ផ្អែកទៅលើតុលាការអឺរ៉ុប ការរំលាយនោះគឺមិនមានសមាមាត្រ និងមិនមានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យមួយឡើយ។

## ការកម្រិតព្រំដែននានា

សេរីភាពក្នុងការបង្កើតសមាគម ត្រូវទទួលរងនូវការរឹតត្បិតដូចគ្នាទៅនឹងសេរីភាពក្នុងការជួបប្រជុំដែរៈ ការរឹតត្បិតណាមួយ ត្រូវតែមានចែងនៅក្នុងច្បាប់ មានភាពចាំបាច់នៅក្នុង

សង្គមប្រជាធិបតេយ្យ និងបំរើគោលបំណងមួយ ក្នុងចំណោមគោលបំណងជាច្រើន ដោយធ្វើការបញ្ជាក់នូវហេតុផលឱ្យបានសមរម្យនៃការជ្រៀតជ្រែក ដូចជាការការពារសន្តិសុខជាតិ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ហើយនិងផលប្រយោជន៍ និងសេរីភាពរបស់អ្នកដទៃ។ ការបង្កើតសមាគម ដែលចង់បានឱ្យមានការស្អប់ខ្ពើមទៅលើសញ្ជាតិ ជាតិសាសន៍និងសាសនា គួរត្រូវបានហាមឃាត់ដើម្បីជាផលប្រយោជន៍របស់អ្នកដទៃផ្សេងទៀត ទៅតាមមាត្រា២០(២) នៃ ICCPR ដែលហាមឃាត់ការតស៊ូមតិណា ដែលនាំឱ្យមានការស្អប់ខ្ពើមទៅលើសញ្ជាតិ ជាតិសាសន៍ និងសាសនា។

## សិទ្ធិក្នុងការចូលរួមនៅក្នុងរដ្ឋាភិបាល

មាត្រា២១ នៃ UDHR

*" ១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួន ដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី ។*

*២. មនុស្សគ្រប់រូប មានសិទ្ធិចូលបម្រើមុខងារសាធារណៈនៃប្រទេសរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌសមភាព ។*

*៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ ។ ឆន្ទៈនេះត្រូវសម្តែងចេញតាមរយៈការបោះឆ្នោតយ៉ាងទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដ មានលក្ខណៈសកល ស្មើភាព និងបោះឆ្នោតដោយសម្ងាត់ ឬតាមនីតិវិធីសមមូល ដែលធានាសេរីភាពនៃការបោះឆ្នោត ។ "*

មាត្រា២៥ នៃ ICCPR

*" ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានឱកាស :*

*(ក). រួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាង ដែល*

*ខ្លួនជ្រើសរើសដោយសេរី ។*

*(ខ). បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ទៀងទាត់ ជាសកល ស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត ។*

*(គ).ចូលបម្រើមុខងារសាធារណៈក្នុងប្រទេសរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌទូទៅដោយសមភាព ។*

សិទ្ធិក្នុងការចូលរួមនៅក្នុងរដ្ឋាភិបាល គឺជាសសរទ្រូងមួយរបស់ប្រជាធិបតេយ្យសម័យទំនើប ដូច្នេះហើយ វាមានសារៈសំខាន់ណាស់សម្រាប់សភា។ ការអនុវត្តសិទ្ធិនេះបានត្រឹមត្រូវមានផលប៉ះពាល់ដោយផ្ទាល់ទៅដល់ចរិតប្រជាធិបតេយ្យរបស់សភា ហើយជាពិសេសទៅដល់រដ្ឋាភិបាល និងគោលនយោបាយនានារបស់ខ្លួន។

តាមពិតទៅ សិទ្ធិនេះមានបីផ្នែក ដែលត្រូវបានពន្យល់ដូចខាងក្រោមៈ

- សិទ្ធិទូទៅក្នុងការចូលរួមជាសាធារណៈ
- សិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត
- សិទ្ធិទទួលបានសេវាកម្មសាធារណៈស្មើគ្នា

## សិទ្ធិទូទៅក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ

សិទ្ធិក្នុងការចូលរួមជាសាធារណៈ រួមមាន :

(ក).ការចូលរួមដោយប្រយោលទៅក្នុងកិច្ចការសាធារណៈ តាមរយៈអ្នកតំណាងជាប់ឆ្នោត

(ខ).ការចូលរួមដោយផ្ទាល់ទៅក្នុងកិច្ចការសាធារណៈ ។

## *ការចូលរួមដោយប្រយោល*

ការចូលរួមដោយប្រយោល ត្រូវបានធ្វើឡើងភាគច្រើន តាមរយៈការបោះឆ្នោត និងការបង្កើតនូវ

ស្ថាប័នតំណាងនានា ជាពិសេស សភាជាតិ ដែលប្រជាពលរដ្ឋចូលរួមនៅក្នុងកិច្ចការសាធារណៈ បញ្ចេញឆន្ទៈរបស់ពួកគេ និងដាក់ឱ្យរដ្ឋាភិបាល មានគណនេយ្យភាពចំពោះពួកគេ ។ គណៈកម្មាធិការសិទ្ធិមនុស្ស បានថ្លែងថា អំណាចរបស់ស្ថាប័នតំណាង គួរត្រូវបានពង្រឹងតាមផ្លូវច្បាប់ និងមិនគួរត្រូវបានគេកម្រិតនៅត្រឹមតែជាមុខនាទីជាអ្នកឱ្យយោបល់នោះទេ ហើយថា អ្នកតំណាងនោះ គួរតែអនុវត្តនូវអំណាចទាំងឡាយណា ដែលត្រូវបានប្រគល់មកឱ្យខ្លួនតែប៉ុណ្ណោះ ឱ្យបានស្របទៅតាមខបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញ (សេចក្តីពន្យល់ទូទៅ លេខ២៥) ។

ដើម្បីឱ្យសភាធ្វើការឆ្លុះបញ្ចាំងឱ្យបានពិតប្រាកដពីឆន្ទៈរបស់ប្រជាពលរដ្ឋ ការបោះឆ្នោតត្រូវតែមានភាពពិតប្រាកដ សេរី និងត្រឹមត្រូវ ហើយត្រូវបានរៀបចំធ្វើឡើងមិនឱ្យមានចន្លោះពេលយូរមិនតាមកាលកំណត់នោះទេ។ នៅឆ្នាំ១៩៩៤ IPU បានអនុម័តសេចក្តីថ្លែងការណ៍ស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវដែលបានបញ្ជាក់ច្បាស់អំពីលក្ខណៈ វិនិច្ឆ័យទៅលើសិទ្ធិក្នុងការបោះឆ្នោត ការឈរឈ្មោះជាបេក្ខជនសិទ្ធិ និងការទទួលខុសត្រូវរបស់គណៈបក្ស និងការឃោសនា ហើយនិងសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋ។ អង្គការសហប្រជាជាតិជាផ្នែកមួយនៃការជួយជ្រោមជ្រែង ទៅលើការបោះឆ្នោត និងសកម្មភាព ពិនិត្យមើលទៅលើការបោះឆ្នោត ក៏បានបង្កើតលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់កំណត់អ្វីដែលគួរជាធាតុទូទៅនានារបស់ច្បាប់ និងនីតិវិធីបោះឆ្នោតផ្សេងៗ។

## *ការចូលរួមដោយផ្ទាល់*

ការចូលរួមដោយផ្ទាល់មានន័យថា មិនគ្រាន់តែអ្នកតំណាងជាប់ឆ្នោតប៉ុណ្ណោះទេ ថែមទាំងប្រជាជនផងដែរ ដែលមានលទ្ធភាពចូលរួមដោយផ្ទាល់ទៅក្នុងកិច្ចការសាធារណៈ តាមរយៈការពិភាក្សា និងការជជែកវែកញែកជាសាធារណៈ ជាមួយអ្នកតំណាងជាប់ឆ្នោត ការធ្វើប្រជាមតិ និងគំនិតផ្តួចផ្តើមពេញនិយមនានា ឬតាមរយៈការរៀបចំអង្គការដោយខ្លួនឯង

ដែលបានធានាដោយសេរីភាពក្នុងការបញ្ចេញមតិ ការប្រជុំនិងបង្កើតសមាគម។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងករណីរឿង Marshall *ទល់នឹងកាណាដា* (១៩៩១) គណៈកម្មាធិការសិទ្ធិមនុស្ស បានទទួលស្គាល់នូវទំហំដ៏ទូលំទូលាយនៃឆន្ទានុសិទ្ធិរបស់រដ្ឋទាក់ទិនទៅនឹងការផ្តល់សិទ្ធិក្នុងការចូលរួមនយោបាយដោយផ្ទាល់៖

"វាពុំមានអ្វីដែលជាទំនាស់ទេ ដែលថា ការចូលរួមទៅក្នុងកិច្ចការសាធារណៈ នៅក្នុងរដ្ឋប្រកាន់លទ្ធិប្រជាធិបតេយ្យនោះ គឺជាភារកិច្ចរបស់អ្នកតំណាងឱ្យប្រជាពលរដ្ឋដែលត្រូវបានគេបោះឆ្នោតឡើងសម្រាប់គោលបំណងនោះ ហើយមន្ត្រីសាធារណៈនានាត្រូវបានគេតែងតាំងឡើងដោយស្របទៅតាមច្បាប់។ ដោយមិនខុសប្លែកពីគ្នា ការប្រព្រឹត្តទៅរបស់កិច្ចការសាធារណៈ ប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ ប្រជាពលរដ្ឋមួយផ្នែកធំ ឬក៏ប៉ះពាល់ទៅដល់ប្រជាពលរដ្ឋទាំងមូលតែម្តង ខណៈពេលដែលក្នុងករណីខ្លះទៀត វាប៉ះពាល់ដោយផ្ទាល់ទៅលើផលប្រយោជន៍របស់ក្រុមជាក់លាក់ណាមួយនៅក្នុងសង្គមទៀតផង។ ទោះបីជាការពិគ្រោះយោបល់ជាមុន ដូចជាសវនាការ ឬការពិគ្រោះយោបល់សាធារណៈ ជាមួយក្រុមមានផលប្រយោជន៍សំខាន់ជាងគេ តែងតែអាចត្រូវបានអនុញ្ញាតដោយច្បាប់ ឬត្រូវបានវិវត្តទៅជាគោលនយោបាយសាធារណៈនៅក្នុងការប្រព្រិត្តិនានា នៃកិច្ចការសាធារណៈក៏ដោយ ក៏ មាត្រា២៥(ក) នៃកតិកាសញ្ញានេះ មិនអាចត្រូវបានគេយល់ក្នុងន័យថា ក្រុមដែលមានការប៉ះពាល់ដោយផ្ទាល់ណាមួយទំហំធំ ឬតូច មានសិទ្ធិដោយគ្មានលក្ខខណ្ឌ ដើម្បីជ្រើសរើសរបៀបចូលរួមទៅក្នុងការប្រព្រិត្តិនៃកិច្ចការសាធារណៈនោះទេ។ តាមពិតទៅ វាជាការប្រមើមើលទៅលើសិទ្ធិនៃការចូលរួមដោយផ្ទាល់របស់ប្រជាជន ដែលមានច្រើនលើសពីវិសាលភាពនៃមាត្រា ២៥(ក) ទៅទៀត"។

ប្រអប់ ៧៤

## សេចក្តីប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវរបស់ IPU (១៩៩៤)

អំណាចរបស់សភាភាគច្រើនកើតចេញពីសមត្ថភាពរបស់ពួកគេក្នុងការឆ្លុះបញ្ចាំងដោយស្មោះត្រង់ទៅលើភាពចំរុះនៃគ្រប់ផ្នែកទាំងអស់របស់សង្គម ហើយដើម្បីធ្វើដូចនេះបាន វាអាស្រ័យទៅលើរបៀបដែលការបោះឆ្នោតត្រូវបានគេរៀបចំឡើង។ ដូច្នេះហើយ IPU បានធ្វើការប្រឹងប្រែងជាដុំកំភួន ទៅលើការបង្កើតឡើងនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោត។ លទ្ធផលសំខាន់មួយពីការងារនោះ គឺសេចក្តីថ្លែងការណ៍ស្តីពីលក្ខណៈវិនិច្ឆ័យ សម្រាប់ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៩៤។ ភាគច្រើន សេចក្តីថ្លែងការណ៍នេះផ្អែកទៅលើការសិក្សាមួយទៅលើអត្ថន័យ និងវិធានរបស់ច្បាប់អន្តរជាតិ និងការអនុវត្តជាក់ស្តែងរបស់រដ្ឋដែលទាក់ទិនទៅនឹងការបោះឆ្នោត ដោយគ្របដណ្តប់ដំណើរ ការបោះឆ្នោតទាំងមូលតែម្តង មានតាំងពីច្បាប់បោះឆ្នោត ការរៀបចំសន្លឹកឆ្នោត ការត្រួតពិនិត្យមើលលើកន្លែងបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រកាសលទ្ធផល ការពិនិត្យទៅលើបណ្តឹង និងដោះស្រាយ ទំនាស់នានា។ សេចក្តីប្រកាសនេះក៏បានលើកឡើងនូវបញ្ហានានា នៃសិទ្ធិក្នុងការបោះឆ្នោត ការឈរឈ្មោះជា បេក្ខជន សិទ្ធិ និងការទទួលខុសត្រូវរបស់គណៈបក្ស និងការឃោសនា ហើយនិងសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋ។ ដោយសារវាជាឯកសារលើកដំបូងក្នុងការបញ្ចេញនូវការយល់ព្រមជាឯកច្ឆ័នផ្នែកនយោបាយជុំវិញពិភពលោកទៅលើប្រធានបទនេះ នោះសេចក្តីថ្លែងការណ៍នេះត្រូវបានគេយកទៅប្រើប្រាស់ជាគោលការណ៍ណែនាំមួយសម្រាប់ការបោះឆ្នោតនៅតាមប្រទេសជាច្រើន។

## សិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត

សិទ្ធិបោះឆ្នោត និងសិទ្ធិក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោត គឺសំខាន់ណាស់សម្រាប់សភាក្នុងឋានៈជាស្ថាប័នប្រជាធិបតេយ្យមួយសម្រាប់សមាជិកសភា និងសម្រាប់លទ្ធិប្រជាធិបតេយ្យ

ទាំងមូល។ ការអនុវត្តដោយត្រឹមត្រូវ និងការធ្វើឱ្យបានសម្រេចរបស់វា មានផលប៉ះពាល់ដោយផ្ទាល់មួយទៅលើរបៀបដែលអ្នកបោះឆ្នោត មានការគិតមកលើអ្នកតំណាងជាប់ឆ្នោតរបស់ពួកគេ មានផលប៉ះពាល់ ទៅលើធម្មានុភាពនៃការធ្វើច្បាប់ ដែលសភាធ្វើការអនុម័ត ហើយទៅលើការធ្វើសេចក្តីសម្រេចចិត្តនានារបស់ខ្លួន។ ដូច្នេះហើយ វាមានការជាប់ទាក់ទិនដោយផ្ទាល់ ទៅនឹងខ្លឹមតំលៃរបស់សភា និងគំនិតនៃការគ្រប់គ្រងដោយមានការពេញចិត្ត ពីប្រជាពលរដ្ឋ តាមរយៈភាពជាតំណាង។ ការរំលោភណាមួយ ទៅលើសិទ្ធិនេះ ជះឥទ្ធិពលដោយផ្ទាល់ទៅលើធម្មានុភាពរបស់សភា ហើយក្នុងករណីធ្ងន់ធ្ងរ ថែមទាំងមានផលប៉ះពាល់ទៅលើច្បាប់ និងបទបញ្ជា និងទៅលើស្ថិរភាពក្នុងប្រទេសមួយថែមទៀតផង។ បន្ថែមពីលើនេះទៅទៀត សមាជិកសភា គឺជាអ្នកការពារឱ្យមានការអនុវត្តឱ្យបានត្រឹមត្រូវ ទៅលើសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត។

ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី និងត្រឹមត្រូវ ការបោះឆ្នោតត្រូវធ្វើឡើងនៅក្រោមបរិយាកាស គ្មានការគំរាមកំហែង និងមានការគោរពទៅលើសិទ្ធិមនុស្សជាមូលដ្ឋាន ជាពិសេស ការគោរពទៅលើសេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគមដោយមាននីតិវិធីតុលាការប្រកបដោយឯករាជ្យភាព និងមានការការពារកុំឱ្យមានការរើសអើង។ ការបោះឆ្នោត ត្រូវបានគេរៀបចំធ្វើឡើងនៅក្នុងវិធីមួយ ដែលធានាថា ឆន្ទៈរបស់ប្រជាពលរដ្ឋ ត្រូវបានសម្តែងឡើងដោយសេរី និងដោយមានប្រសិទ្ធភាព ហើយអ្នកបោះឆ្នោតត្រូវបានគេផ្តល់ជំរើសពិតប្រាកដមួយ។

សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត គួរត្រូវបានបង្កើតឡើងដោយច្បាប់ ដែលឈរលើមូលដ្ឋានគ្មានការរើសអើង និងសិទ្ធិស្មើគ្នាសម្រាប់គ្រប់បុគ្គលទាំងអស់នៅក្នុងដំណើរការបោះឆ្នោត។ ទោះបីជាការចូលរួមនៅក្នុងការបោះឆ្នោតអាចត្រូវបានគេកម្រិតឱ្យតែប្រជាជនរបស់រដ្ឋមួយនោះក៏ដោយ ក៏គ្មានការរិតត្បិតដែលផ្អែកលើមូលដ្ឋានមិនសមហេតុ

ផលណាមួយ ដូចជា ពិការភាពផ្នែករាងកាយ អវិជ្ជា ប្រវត្តិនៃការអប់រំ សមាជិកភាពគណបក្ស ឬលក្ខខណ្ឌតម្រូវឱ្យមានទ្រព្យសម្បត្តិ អាចត្រូវបានឱ្យធ្វើឡើងឡើយ ។

## *សិទ្ធិក្នុងការបោះឆ្នោត*

បុគ្គលទាំងឡាយ ដែលមានសិទ្ធិបោះឆ្នោត គួរមានលទ្ធភាពក្នុងការចុះឈ្មោះ ហើយការកែបន្លំទៅលើការចុះឈ្មោះ និងការបោះឆ្នោត ដូចជា ការគំរាមកំហែង ឬការបង្ខិតបង្ខំ គួរត្រូវបានហាមឃាត់ដោយច្បាប់ ។ ការបោះឆ្នោតទាំងឡាយគួរត្រូវមានមូលដ្ឋានផ្អែកលើគោលការណ៍ "មនុស្សម្នាក់ សន្លឹកឆ្នោតមួយ " ។ ការគូសកំណត់ព្រំដែនមណ្ឌលបោះឆ្នោត និងវិធីនានានៃការបោះឆ្នោត មិនគួរធ្វើឱ្យខូចដល់ការបែងចែកអ្នកបោះឆ្នោត ឬរើសអើងប្រឆាំងក្រុមណាមួយឡើយ ។

វិធានការវិជ្ជមាននានា គួរត្រូវធ្វើឡើង ដើម្បីដោះស្រាយការលំបាកនានា ដូចជាភាពមិនចេះអក្សរ ឧបសគ្គនៃការប្រើភាសា (ព័ត៌មានគួរតែផលិតឡើង ជាភាសារបស់ជនជាតិភាគតិចផងដែរ) ភាពក្រីក្រ ឬឧបសគ្គនានា ទៅលើសេរីភាពក្នុងការធ្វើដំណើរ ។

ប្រជាពលរដ្ឋ គួរត្រូវបានគេការពារពីការបង្ខិតបង្ខំឬពីការប៉ុនប៉ងនានាដើម្បីបង្ខាប់ឱ្យពួកគេបង្ហាញពីគោលបំណង ឬជំរើសពេញចិត្តនៃការបោះឆ្នោតរបស់ពួកគេ ហើយគោលការណ៍នៃការបោះឆ្នោតដោយសម្ងាត់ត្រូវតែរក្សាទុក ។

## *សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត*

សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត អាចរងនូវការរិតត្បិតខ្លះ ដូចជាអាយុអប្បបរមាជាដើម ក៏ប៉ុន្តែការរិតត្បិតនេះត្រូវតែមានមូលហេតុនិងហេតុផលច្បាស់លាស់ ។ ដូចដែលបានលើកឡើងពិការភាពរាងកាយ អវិជ្ជា ប្រវត្តិនៃការអប់រំ សមាជិកភាពគណៈបក្ស ឬលក្ខខណ្ឌតម្រូវឱ្យមានទ្រព្យសម្បត្តិមិនគួរយកមកធ្វើជាលក្ខខណ្ឌនៃការរិតត្បិតទេ ។

បន្ថែមលើនេះទៅទៀត លក្ខខណ្ឌនានា ដែលទាក់ទិនទៅនឹងកាលបរិច្ឆេទ កម្រៃ ឬប្រាក់កក់នានា សម្រាប់ការតែងតាំងបេក្ខជន គួរត្រូវធ្វើឡើយដោយសមហេតុផល និងដោយមិនរើសអើង។ គណៈកម្មាធិការសិទ្ធិមនុស្ស បានសំដែងការព្រួយបារម្ភ ទៅលើការចំណាយហិរញ្ញវត្ថុ ដែលពាក់ព័ន្ធទៅនឹងការស្វែងរកការបោះឆ្នោតចូលកាន់ការិយាល័យសាធារណៈ នៅសហរដ្ឋអាមេរិក ហើយបានពិចារណាថា ការធ្វើរបៀបនេះបានប៉ះពាល់អវិជ្ជមានទៅលើសិទ្ធិក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោត។

***នីតិវិធីបោះឆ្នោត***

ការបោះឆ្នោតគួរត្រូវធ្វើឡើយដោយសេរី ត្រឹមត្រូវ និងទៀងទាត់។ អ្នកបោះឆ្នោតគួរតែមានសេរីភាពក្នុងការគាំទ្រ ឬប្រឆាំងរដ្ឋាភិបាល ហើយបង្កើតជាទស្សនៈដោយឯករាជ។ ការបោះឆ្នោតត្រូវតែធ្វើឡើងដោយសម្ងាត់ ដោយធានាថាឆន្ទៈរបស់អ្នកបោះ ឆ្នោតត្រូវបានសម្តែងឡើងដោយសេរី។

វិធានការនានា គួរត្រូវបានធ្វើឡើង ដើម្បីធានាឱ្យមានការបោះឆ្នោតពិតប្រាកដ សេរី ត្រឹមត្រូវ និងទៀងទាត់ ហើយច្បាប់ និងនីតិវិធីនានា ត្រូវតែធ្វើឡើង ដោយធានាថា សិទ្ធិក្នុងការបោះឆ្នោត អាចត្រូវបានគេអនុវត្តដោយសេរី ដោយប្រជាពលរដ្ឋទាំងអស់យ៉ាងពិតប្រាកដ។

វិធានការដ៏សំខាន់មួយ គឺការបង្កើតឡើងនូវអាជ្ញាធរឯករាជ្យមួយ ដើម្បីត្រួតពិនិត្យលើដំណើរការបោះឆ្នោត។ វាជាការសំខាន់ដើម្បីធានាឱ្យមានសន្តិសុខដល់ប្រអប់ឆ្នោត ក្នុងអំឡុងពេលនៃការបោះឆ្នោត។ បន្ទាប់ពីការបោះឆ្នោត សន្លឹកឆ្នោត គួរត្រូវបានគេរាប់ នៅចំពោះវត្តមានរបស់អ្នកសង្កេតការណ៍ (អន្តរជាតិ) បេក្ខជន ឬភ្នាក់ងាររបស់ពួកគេ។

## សិទ្ធិទទួលបានសេវាកម្មសាធារណៈស្មើគ្នា

ក្នុងឋានៈតួនាទីជាអ្នកបំរើសេវាសាធារណៈ គោលការណ៍មូលដ្ឋាននៃសមភាពត្រូវតែគ្រប់គ្រងលើលក្ខណៈវិនិច្ឆ័យ និងដំណើរការសម្រាប់ការតែងតាំង ការតំលើងតួនាទី ការព្យួរ និងការបណ្តេញចេញ ដែលគួរធ្វើឡើងដោយមិនលំអៀង និងសមហេតុផល ។

នៅក្នុងមុខនាទីត្រួតពិនិត្យរបស់ខ្លួន សមាជិកសភា គួរយកចិត្តទុកដាក់ជាពិសេសទៅលើលក្ខខណ្ឌនានា ទៅលើការទទួលបានការរិតត្បិតដែលកំពុងតែអនុវត្ត ដំណើរការតែងតាំង ការតំលើងតួនាទី ការព្យួរ និងការបណ្តេញចេញ ឬផ្លាស់ចេញពីការងារ ហើយយកចិត្តទុកដាក់ទៅលើយន្តការពិនិត្យមើលឡើងវិញ របស់តុលាការ និងរបស់ស្ថាប័នផ្សេងទៀត ដែលអាចរកបាន ទាក់ទិនទៅនឹងដំណើរការទាំងនេះ ។

## សារព័ត៌មាន និង គណៈបក្សនយោបាយ

ជាចុងក្រោយ វាជាការសំខាន់ដែលប្រជាពលរដ្ឋ បេក្ខជននិងអ្នកតំណាងដែលជាប់ឆ្នោតទាំងឡាយ មានលទ្ធភាពដើម្បីធ្វើការពិភាក្សា និងទំនាក់ទំនងនូវព័ត៌មាន និងគំនិតពីកិច្ចការនយោបាយបានដោយសេរី ដើម្បីរៀបចំធ្វើបាតុកម្ម និងការជួបប្រជុំ ធ្វើការបោះពុម្ពផ្សាយឯកសារនយោបាយ និងការរៀបចំយុទ្ធនាការសម្រាប់ការបោះឆ្នោត ។ ការបោះពុម្ពកាសែតឯករាជ្យ និងសារព័ត៌មានសេរី ដែលជាធាតុគន្លឹះនៃបរិស្ថានរបៀបនេះ និងការគោរពទៅលើសេរីភាពក្នុងការបង្កើតសមាគម ការធានានូវលទ្ធភាពក្នុងការបង្កើត និងចូលរួមក្នុងគណៈបក្សនយោបាយនានា គឺមានសារៈសំខាន់ណាស់ សម្រាប់ប្រជាធិបតេយ្យមួយ ដែលកំពុងប្រព្រឹត្តទៅយ៉ាងល្អ ។

# ជំពូកទី ១៣

# អ្វីដែលសមាជិកសភាគួរយល់ដឹងអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

ការរំលោភបំពានធ្ងន់ធ្ងរបំផុត លើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នាពេលបច្ចុប្បន្ននេះ កើតចេញពីភាពក្រីក្រ។ ដោយសារហេតុនេះ ការដោះស្រាយបញ្ហាភាពក្រីក្រគឺជាចំណុចគន្លឹះ សំរាប់ទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស និងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។ ដូច្នេះហើយ ការពិភាក្សាវែកញែកអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌សំខាន់ៗ គួរត្រូវធ្វើ ក្រោយការពិនិត្យទៅលើនិន្នាការសង្គម និងសេដ្ឋកិច្ចទាំងឡាយ ដែលមានផលប៉ះពាល់ទៅលើការទទួលសិទ្ធិទាំងនេះ ដោយប្រជាពលរដ្ឋគ្រប់រូបនាពេលបច្ចុប្បន្ន។

## និន្នាការសង្គម និងសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍

ការធ្វើសកលភាវូបនីយកម្មលឿនពេកធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សគួរឱ្យបារម្ភ។ ទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៅក្នុងផ្នែកនេះ ត្រូវបានគេយល់ដឹងយ៉ាងច្បាស់លាស់។ នៅឯជំនួបប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍន៍សង្គមដែលបានប្រព្រឹត្តទៅនៅទីក្រុង Copenhagen នៅឆ្នាំ១៩៩៥ បញ្ហានេះ ត្រូវបានគេសង្កត់ធ្ងន់ថា ខណៈពេលនៃការបំលាស់ទី និងការប្រាស្រ័យទាក់ទងកាន់តែប្រសើរឡើងនោះ ការកើនឡើងផ្នែកពាណិជ្ជកម្ម និង

លំហូរមូលធន និងការរីកចំរើន ផ្នែកបច្ចេកវិទ្យាដែលបង្កឡើងដោយភាវូបនីយកម្មបាន បើកឱ្យមានកាលានុវត្តភាពថ្មីៗ ដើម្បីទទួលបានការចំរើន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកប ដោយចិរភាព នៅជុំវិញពិភពលោក និងការចែករំលែកប្រកបដោយភាពថ្លៃប្រឱតនូវបទពិសោធន៍ ឧត្តមគតិ គុណតំលៃ និងការប្រាថ្នាចង់ បាននានា សកលភាវូបនីយកម្មក៏ត្រូវបាន "អមមកជាមួយនូវភាពក្រីក្រ ភាពអត់មានការ ងារធ្វើ និងការបែកបាក់សង្គមកាន់តែខ្លាំងឡើងផងដែរ"។ [៣៦]

នៅតាមប្រទេសជាច្រើន ការបន្ធូរច្បាប់សេរីភាវូបនីយកម្ម ឯកជនភាវូបនីយកម្ម និងនិន្នាការស្រដៀងគ្នានេះ ក្នុងគោលបំណងកាត់បន្ថយតួនាទីរបស់រដ្ឋ និងការផ្ទេរមុខនាទីនានារបស់រដ្ឋាភិបាល ដែលធ្លាប់មានពីមុន ទៅឱ្យកម្លាំងផ្នែកទីផ្សារ បានជះផលប៉ះពាល់ជាអវិជ្ជមាន ដល់សិទ្ធិក្នុងការទទួលបានការអប់រំ ការថែទាំសុខភាព ទឹក និងសិទ្ធិការងារនានា ជាពិសេស ទៅលើក្រុមដែលងាយរងគ្រោះទាំងឡាយ។ នៅផ្នែកខាងក្រោមនេះដែលបញ្ជាក់អំពីស្តង់ដាអន្តរជាតិទាំងឡាយ ក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច បង្ហាញថា មានគំលាតដែលអាចកើតមានកាន់តែធំឡើងៗ រវាងកាតព្វកិច្ច និងលទ្ធភាពរបស់រដ្ឋ ឬឆន្ទៈរបស់រដ្ឋ ក្នុងការបំពេញកាតព្វកិច្ចទាំងនោះ។ បន្ថែមលើនេះទៅទៀត សកលភាវូបនីយកម្ម បាននាំឱ្យមាន "ការធ្វើឯកជនភាវូបនីយកម្មនៃការរំលោភសិទ្ធិមនុស្ស"។ នៅតាមប្រទេសជាច្រើន (មិនមែនត្រឹមតែប្រទេសដែលគេហៅថា "រដ្ឋបរាជ័យ" ប៉ុណ្ណោះទេ) ស្ថាប័នមិនមែនជារបស់រដ្ឋនានា ដូចជា អង្គការអន្តររដ្ឋាភិបាល សាជីវកម្មឆ្លងដែន ក្រុមហ៊ុនសន្តិសុខឯកជន កងកម្លាំងយោធា

---

[៣៦] ជំនួបកំពូលពិភពលោកស្តីពីការអភិវឌ្ឍន៍សង្គម *សេចក្តីប្រកាសទីក្រុង* Copenhagen *ស្តីពីការអភិវឌ្ឍន៍សង្គម* ឃ្លាប្រយោគទី១៤

និងទ័ពព្រៃ ក្រុមឧក្រិដ្ឋជន និងភេរវជនដែលមានការចងក្រង មានទំនួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស កាន់តែធ្ងន់ធ្ងរ និងកាន់តែរីករាលដាលជាងរដ្ឋាភិបាលទៅទៀត (សូមមើលប្រអប់៥៧ ស្តីពីការធ្វើឯកជនភាវូបនីយកម្មពន្ធនាគារ)។

**ប្រអប់ ៧៥**

## សកលភាវូបនីយកម្ម និងបញ្ហាសិទ្ធិមនុស្ស

នៅក្នុងឆ្នាំ២០០០ គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានតែងតាំងអ្នករាយការណ៍ពិសេសចំនួនពីររូប ដើម្បីសិក្សាលើសកលភាវូបនីយកម្ម និងផលប៉ះពាល់របស់វាលើការទទួលបានសិទ្ធិមនុស្សពេញលេញ។ របាយការណ៍បន្តឆ្នាំ២០០១ របស់ពួកគេមានសេចក្តីថ្លែងការណ៍ដូចខាងក្រោម ៖

"នៅក្នុងការពិនិត្យសារឡើងវិញ លើទំនាក់ទំនងជាសកល និងការរីកចំរើនផ្នែកបច្ចេកវិទ្យា ដែលបានប្រកាសដោយអ្នក ដែលអាចមើលឃើញតែផលវិជ្ជមាននៃសកលភាវូបនីយកម្ម វាមានសារៈសំខាន់ណាស់ ដែលយើងត្រូវទទួលស្គាល់ការពិតដែលថា កត្តាទាំងនោះកើតឡើងនៅក្នុងលក្ខខណ្ឌ ដែលគ្រាន់តែអាចពិពណ៌នាថា ជាការខុសគ្នាយ៉ាងសម្បើមតែប៉ុណ្ណោះ"។ ការនៅតែកើតមានឡើង (ការរីកដុះដាល) នៃបញ្ហាជំងឺដែលបណ្តាលឱ្យបាត់បង់ជីវិត ភាពអត់ឃ្លាន កង្វះខាតសំលៀកបំពាក់ ភាពមិនមាន ជម្រកគ្រប់គ្រាន់ បំលាស់ប្តូរពលកម្ម និងកង្វះខាតម្ហូបអាហារនៅក្នុងកន្លែងជាច្រើននៅលើពិភពលោក គឺជាកត្តាគួរឱ្យព្រួយបារម្ភ ដែលកាន់តែកើតមានច្រើនឡើង។ ការកើនឡើងនៃការប្រកួតប្រជែងនឹងការ ធ្វើអាជីវកម្មរុករកធនធានរ៉ែក៏ដូចជាទៅលើធនធានធម្មជាតិផ្សេងៗទៀត កំពុងតែបន្ថែមនូវភាពតានតឹង និងជំលោះនានា ....

វាជារឿងគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងដែលថា ដំណើរការសកលភាវូបនីយកម្មកំពុងតែកើតមានឡើង ក្នុងបរិបទមួយ ដែលមានភាពតានតឹងនៅក្នុងសង្គម ក៏ដូចជាភាពមិនស៊ីសង្វាក់ផ្នែកនយោបាយ .... យោងតាមទស្សនៈសិទ្ធិមនុស្ស ការរៀបចំ និងការប្រព្រឹត្តទៅនៃចលនាប្រឆាំងនឹងសកលភាវូបនីយកម្ម ហើយនិងការសងសឹកចំពោះចលនាទាំងនោះបានលេចចេញនូវសំនួរយ៉ាងច្រើន

ទាក់ទងទៅនឹងសិទ្ធិក្នុងការបញ្ចេញមតិ ដោយសេរី ការជួបប្រជុំ និងការបង្កើតសមាគម។ ទីបំផុត ពួកគេក៏លើកឡើង នូវសំណួរនានាអំពីការចូលរួម ការផាត់ចេញ និងការរើសអើង ដែលជាលក្ខណៈពិសេសនៃរបបសិទ្ធិមនុស្ស ដែលផ្អែកទៅលើជាស្នូលនៃ ឧបករណ៍ជាច្រើន ដែលផ្សំផ្គុំឡើងទៅជាបណ្តុំនៃសិទ្ធិមនុស្ស...។ ហេតុដូច្នេះហើយ សកលភាវូបនីយកម្ម មិនគ្រាន់តែជាបញ្ហាសេដ្ឋកិច្ចប៉ុណ្ណោះទេ ក៏ប៉ុន្តែជាបាតុភូតនយោបាយមួយផងដែរ...។ ដូច្នេះហើយ ការពិចារណាដោយហ្មត់ចត់ទៅលើនយោបាយនៃបញ្ហាសកលភាវូបនីយកម្មគឺជាលក្ខខណ្ឌដ៏សំខាន់មួយ ដើម្បីតាក់តែង នូវរចនាសម្ព័ន្ធសេដ្ឋកិច្ច និងអភិបាលកិច្ចអន្តរជាតិមួយទៀតជាជំនួស”។

នៅក្នុងទស្សនៈរបស់អ្នករាយការណ៍ពិសេសទាំង២រូប “សកលភាវូបនីយកម្ម មិនមែនត្រូវបានកំណត់ដោយអាទិទេពទេ” ប៉ុន្តែ “វាជាផលិតផលរបស់មនុស្សជាតិ”។ “ហេតុដូចនេះវាត្រូវបានជំរុញដោយមនោគមវិជ្ជា ផលប្រយោជន៍ ហើយនិងដោយស្ថាប័ននានា។ យើងត្រូវតែសួរខ្លួនឯងថាតើ សកលភាវូបនីយកម្ម បង្ហាញនូវលទ្ធភាព និងការដាក់កំហិតយ៉ាងណាខ្លះ ហើយថាតើយើងអាចចូលរួមពាក់ព័ន្ធដោយសកម្មប្រកបដោយយុទ្ធសាស្ត្រ និងភាពច្នៃប្រឌិតបានយ៉ាងណា។ ជាពិសេសទៅទៀតនោះ តើយើងអាចធានាបានយ៉ាងដូចម្តេចថា នៅក្នុងការពិភាក្សាវែកញែកអំពីសកលភាវូបនីយកម្ម និងផលប៉ះពាល់ របស់វាដល់សិទ្ធិមនុស្ស តើយើងអាចប្រកាន់ខ្ជាប់នូវគោលការណ៍ នៃការចូលរួមប្រកបដោយអត្ថន័យ និងការមិនរើសអើងនៅក្នុងដំណើរការនៃការសម្រេចចិត្តបានដោយរបៀបណា?”។[៣៧]

គំលាតរវាងប្រទេសមាន និងប្រទេសក្រីក្រ ហើយនិងគំលាតរវាងអ្នកមាននិងអ្នកក្រនៅក្នុងសង្គមតែមួយកាន់តែបន្តរីកធំទៅៗ។ ប្រជាជនប្រហែលជា១កោដិនាក់ កំពុងរស់នៅក្នុងស្ថានភាពក្រីក្រជាទីបំផុត ពាសពេញពិភពលោក ដោយខ្វះអាហារ ទីជំរក ការអប់រំ និង

---

[៣៧] J. Olaka–Onyango និង Deepika Udagama បេសកកម្មពិសេសរបស់អនុគណៈកម្មការលើកស្ទួយនិងការពារសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *របាយការណ៍រីកចំរើន ស្តីពីសកលភាវូបនីយកម្ម និងផលប៉ះពាល់របស់វាទៅលើការទទួលបានសិទ្ធិមនុស្ស E/CN4/ ផ្នែក ២/២០០១/១០ ឃ្លាទី ៧ ១០ ១១ និងទី១២*

ការថែទាំសុខភាព។ នៅពេលជាមួយគ្នានេះដែរ សកលភាវូបនីយកម្ម ជួយផ្ដល់នូវព័ត៌មាន ដោយសុក្រិតអំពីស្ថានភាពរស់នៅ នៅក្នុងផ្នែកណាមួយនៃពិភពលោក ដើម្បីធ្វើឱ្យសង្គមអ្នកមាន និងអ្នកក្រ កាន់តែមានការពឹងពាក់គ្នាទៅវិញទៅមក ហើយដើម្បីបង្កើតនូវមធ្យោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដ៏ទំនើប ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ហេតុដូច្នេះហើយ នៅក្នុង " ភូមិសកល " របស់យើងនោះ គេ មិនគួរអនុញ្ញាតឱ្យមនុស្សជាតិមួយផ្នែកធំ រស់នៅក្នុងភាពទុគ៌តទេ។

## ការលុបបំបាត់ភាពក្រីក្រ

*"ការលុបបំបាត់ភាពក្រីក្រត្រូវតែជាគោលដៅចំបងទីមួយរបស់យើងនៅក្នុងសហវត្សថ្មីនេះ។ រដ្ឋាភិបាល បានធ្វើការប្ដេជ្ញាចិត្ត ដើម្បីចាត់វិធានការតាមរយៈយុទ្ធសាស្ត្រនានា និងកម្មវិធីផ្សេងៗ ក្នុងគោលបំណងដើម្បីកាត់បន្ថយភាពក្រីក្រ និងបំបាត់ភាពទុគ៌ត។ ការបដិសេធនូវសិទ្ធិមនុស្សនៅអន្ទោលតាមភាពក្រីក្រ។"*

Mary Robinson *អតីតឧត្ដមស្នងការអង្គការសហប្រជាជាតិ អារម្ភកថានៅក្នុងគោលការណ៍ណែនាំព្រាងៈ យុទ្ធសាស្ត្រផ្អែកសិទ្ធិមនុស្សឆ្ពោះទៅកាន់យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ*
OHCHR *ហ្សឺណែវ ខែកញ្ញា ឆ្នាំ២០០២*

តាមរយៈការពិចារណាពីពេលមុនៗ នាទសវត្សកន្លងមកនេះ ការលុបបំបាត់ភាពក្រីក្រ ត្រូវបានលេចចេញជាគោលដៅខ្ពស់ជាងគេមួយនៃការអភិវឌ្ឍន៍។ ក្នុងពេលជាមួយគ្នានេះដែរ និយមន័យនៃភាពក្រីក្រ ត្រូវបានធ្វើឱ្យទូលំទូលាយជាបណ្ដើរៗ។ អស់រយៈពេលជាយូរមកហើយ ដែលប្រជាជនក្រីក្រ ត្រូវបានគេពិពណ៌នាតែនៅក្នុងន័យសម្ភារៈ : (ដូចជា "ជនដែលរស់នៅអាស្រ័យទៅលើប្រាក់តិចជាង ១ដុល្លារ ក្នុង១ថ្ងៃ " ជាដើម) តាមពិតទៅ អ្វីដែលធ្វើឱ្យតក់ស្លុតនោះ គឺទំហំនៃភាពក្រីក្រ ដែលមិនផ្អែកទៅលើអត្ថន័យតាមសំភារៈនោះទេ។ លក្ខណៈ

វិនិច្ឆ័យទាំងនោះ ត្រូវបានប្រើនៅក្នុងស្ថិតិកាន់តែច្រើនឡើងៗ ដើម្បីពិពណ៌នានូវបាតុភាពនៃភាពក្រីក្រ។ នៅពាសពេញពិភពលោក ប្រជាជនប្រហែលជា ១កោដិនាក់ មានការខ្វះខាតទីជំរក ម្ហូបអាហារគ្រប់គ្រាន់ ភាពចេះអក្សរ លទ្ធភាពប្រើប្រាស់ទឹកស្អាត ហើយនិងសេវាថែទាំសុខភាពជាមូលដ្ឋាន។ ជារៀងរាល់ថ្ងៃ កុមារចំនួន៣៤ 000នាក់ដែលមានអាយុក្រោម៥ឆ្នាំ ត្រូវបានបាត់បង់ជីវិត ដោយសារភាពអត់ឃ្លាន និងជំងឺ ដែលអាចការពារបាន។ ការពិតទាំងនេះ មិនមែនជារឿងដែលថ្មីនោះទេ ហើយបើតាមការបញ្ជាក់ពីខាងលើ គំលាតរវាងអ្នកមាន និងអ្នកក្រ គឺមានទំហំកាន់តែធំឡើងៗ ដែលធ្វើឱ្យភាពបរាជ័យ នៃការប្រយុទ្ធទៅនឹងបញ្ហា នៃភាពក្រីក្រនៅក្នុងកំឡុងពេលដែលសកលភាវូបនីយកម្ម កើតឡើងយ៉ាងឆាប់រហ័សនោះ កាន់តែមិនអាចការពារបានកាន់តែខ្លាំងឡើងៗ។ នៅក្នុងបរិបទនោះ នៅខែកញ្ញា ឆ្នាំ២000 មហាសន្និបាតអង្គការសហប្រជាជាតិ បានបង្កើតគោលដៅអភិវឌ្ឍន៏សហសវត្សរ៍ ដោយរួមមាន គោលដៅដើម្បីកាត់បន្ថយឱ្យបានពាក់កណ្ដាលនូវចំនួនប្រជាជន ដែលកំពុងរស់នៅក្នុងភាពក្រីក្រជាទីបំផុតត្រឹមឆ្នាំ២០១៥ ហើយក្នុងឆ្នាំជាមួយគ្នានោះដែរ គឺនឹងសម្រេចឱ្យបាននូវគោលដៅធំៗមួយចំនួនទៀត ដូចជា ការអប់រំកំរិតបឋមសិក្សាជាសកល ការកាត់បន្ថយអាត្រាស្លាប់របស់កុមារ ដែលមានអាយុក្រោម៥ឆ្នាំ ឱ្យបានត្រឹម ២ភាគ៣ និងអាត្រាមរណៈរបស់ម្ដាយ ឱ្យបាន ៣ភាគ៤ ហើយនិងកាត់បន្ថយឱ្យបានពាក់កណ្ដាលនូវសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន និងកង្វះលទ្ធភាពប្រើប្រាស់ទឹកស្អាត។

ដោយហេតុថា ភាពក្រីក្រ ជាផ្នែកមួយនៃការមិនទទួលបាននូវសិទ្ធិមនុស្សជាច្រើននោះ មាគ៌ាយកសិទ្ធិមនុស្សជាគោលគឺជាការចាំបាច់ដើម្បីពង្រឹងយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ។ ក្នុងការឆ្លើយតបទៅនឹងសំណើ ដែលធ្វើឡើងដោយ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ នៅក្នុងខែកក្កដា ឆ្នាំ២០០១ ក្រោមការជួយពីអ្នកជំនាញ៣រូប លោកស្រីRobinson ឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនាពេលនោះបាន

បង្កើតឡើងនូវគោលការណ៍ណែនាំព្រាង ៖ មាគ៌ាយកសិទ្ធិមនុស្សជាគោល ដើម្បីធ្វើជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (ដែលបានបោះពុម្ពផ្សាយ នៅក្នុងខែកញ្ញា ឆ្នាំ២០០២)។ ក្នុងការឱ្យនិយមន័យលើភាពក្រីក្រ ពួកគេបានជ្រើសយកនូវទស្សនៈ ដែលត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយមួយ ដែលត្រូវបានលើកឡើងដំបូងគេ ដោយអ្នកតស៊ូមតិ គឺលោក Amartya Sen ដែលឱ្យនិយមន័យថា ជនក្រីក្រម្នាក់ គឺជាជនដែលត្រូវបានគេបំបាត់ចោល នូវលទ្ធភាពជាមូលដ្ឋាននានា ដូចជាលទ្ធភាពក្នុងការរួចផុតពីការអត់ឃ្លាន លទ្ធភាពក្នុងការរស់នៅប្រកបដោយសុខភាពល្អ និងអាចចេះអាន និងសរសេរ។ ឧទាហរណ៍នានា អំពីសិទ្ធិ មនុស្ស ដែលមានការពាក់ព័ន្ធសំខាន់នឹងភាពក្រីក្រ មានដូចជា សិទ្ធិទទួលបានចំណីអាហារ ទីជំរក សុខភាព និងការអប់រំ។ សិទ្ធិមនុស្ស ផ្សេងទៀត មានការទាក់ទងសំខាន់ទៅនឹងភាពក្រីក្រ គឺថាការទទួលបានសិទ្ធិទាំងនោះ នឹងជួយឱ្យបានទទួលនូវសិទ្ធិពាក់ព័ន្ធសំខាន់ៗដទៃទៀតដែរ។ ឧទាហរណ៍ ការទទួលបានសិទ្ធិធ្វើការ និងធ្វើឱ្យមានការទទួលបាននូវសិទ្ធិមនុស្សផ្សេងទៀតដែរ ដូចជាសិទ្ធិទទួលបានចំណីអាហារ សុខភាព និងទីលំនៅ។ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចជាសិទ្ធិមានសុវត្ថិភាពផ្ទាល់ខ្លួន សិទ្ធិទទួលបានយុត្តិធម៌ដោយស្មើភាពគ្នា និងសិទ្ធិសេរីភាពផ្នែកនយោបាយក៏មានទំនាក់ទំនងសំខាន់និងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រដែរ។

**ប្រអប់ ៧៦**

### គោលដៅអភិវឌ្ឍន៍សហសវត្សរបស់អង្គការសហប្រជាជាតិ

១. **លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានហួសហេតុ**

*ទិសដៅសម្រាប់ឆ្នាំ ២០១៥: កាត់បន្ថយពាក់កណ្តាលនៃចំនួនមនុស្ស ដែលកំពុងរស់នៅជាមួយចំណូលតិចជាង ១ដុល្លារ ក្នុងមួយថ្ងៃ ហើយនិងប្រជាជនដែលរងគ្រោះពីភាពអត់ឃ្លាន*

២. **សម្រេចឱ្យបាននូវការអប់រំកំរិតបឋមសិក្សាជាសកល**

*ទិសដៅសម្រាប់ឆ្នាំ២០១៥: ធានាថា ក្មេងប្រុស និងក្មេងស្រី បញ្ចប់ការអប់រំកំរិតបឋមសិក្សា*

៣. **លើកស្ទួយសមភាពយេនឌ័រ និងពង្រឹងអំណាចស្ត្រី**

*ទិសដៅសម្រាប់ឆ្នាំ២០០៥ និង២០១៥ : លុបបំបាត់ចោលភាពខុសគ្នាផ្នែកយេនឌ័រនៅក្នុងការអប់រំកំរិតបឋមសិក្សា និងមធ្យមសិក្សា ចង់បានបំផុតនៅឆ្នាំ២០០៥ នឹងនៅតាមគ្រប់កំរិតទាំងអស់នៅឆ្នាំ២០១៥*

៤. **កាត់បន្ថយអត្រាមរណៈរបស់កុមារ**

*ទិសដៅសម្រាប់ឆ្នាំ២០១៥:កាត់បន្ថយចំនួនពីរភាគបីនៃអត្រាមរណៈរបស់កុមារក្រោមអាយុ៥ឆ្នាំ*

៥. **ធ្វើឱ្យសុខភាពម្តាយមានភាពប្រសើរឡើង**

*ទិសដៅសម្រាប់ឆ្នាំ២០១៥ : កាត់បន្ថយចំនួនបីភាគបួននៃអត្រាមរណៈរបស់ស្ត្រី ដែលស្លាប់ពេលសំរាលកូន*

៦. **ប្រយុទ្ធប្រឆាំងនឹងជំងឺហ៊ីវ/អេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗ**

*ទិសដៅសម្រាប់ឆ្នាំ២០១៥ : បញ្ឈប់ និងចាប់ផ្តើមធ្វើការទប់ស្កាត់ការរីករាលដាលនៃជំងឺហ៊ីវ/អេដស៍ និងការផ្ទុះឡើងនូវជំងឺគ្រុនចាញ់ និងជំងឺកាចសាហាវផ្សេងៗទៀត*

៧. **ធានានិរន្តរភាពបរិស្ថាន**

*ដាក់បញ្ចូលគោលនយោបាយនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ប្រទេស ហើយធ្វើការទប់ស្កាត់នូវការបាត់បង់នៃធនធានបរិស្ថាន ។*

*នៅឆ្នាំ២០១៥ : កាត់បន្ថយចំនួនពាក់កណ្តាលនូវសមាមាត្រនៃចំនួនប្រជាជន ដែលគ្មានលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ទទួលទាន*

*នៅឆ្នាំ២០២០ : ធ្វើឱ្យសម្រេចបានភាពប្រសើរឡើងជាដុំកំភួន លើជីវិតរបស់មនុស្ស យ៉ាងហោចណាស់ ចំនួន ១០០លាននាក់ ដែលកំពុងរស់នៅក្នុងតំបន់អនាធិបតេយ្យ*

៨. **អភិវឌ្ឍន៍នូវភាពដៃគូជាសកល សម្រាប់ការអភិវឌ្ឍន៍ ដោយមានការកំនត់គោលដៅសម្រាប់ជំនួយពាណិជ្ជកម្ម និងការរំលោះបំណុល**

*អភិវឌ្ឍន៍ថែមទៀតទៅលើប្រព័ន្ធពាណិជ្ជកម្ម និងហិរញ្ញវត្ថុបើកទូលាយមួយ ដោយរួមបញ្ចូលនូវការតាំងចិត្តមួយ ទៅលើអភិបាលកិច្ចល្អ ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ នៅថ្នាក់ជាតិ និងអន្តរជាតិ ។*

*ឆ្លើយតបទៅនឹងសេចក្តីត្រូវការពិសេសរបស់ប្រទេសមានការអភិវឌ្ឍន៍តិចបំផុត និងសេចក្តីត្រូវការពិសេសរបស់ប្រទេសដែលពុំនៅជាប់សមុទ្រ និងរដ្ឋកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗនានា ។ ដោះស្រាយដោយទូលំទូលាយទៅនឹងបញ្ហាបំណុលរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។ អភិវឌ្ឍន៍ការងារសម្រាប់យុវជនដែលប្រកបដោយភាពថ្លៃថ្នូរ និងមានផលិតភាព ។ ដោយមានកិច្ចសហការជាមួយក្រុមហ៊ុនផលិតឱសថនានា ផ្តល់លទ្ធភាពឱ្យទទួលបាននូវឱសថដែលអាចទិញបានក្នុងតំលៃថោក និងដែលត្រូវការចាំបាច់នានា ទៅឱ្យប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ។ ដោយមានកិច្ចសហការជាមួយផ្នែកឯកជន ធ្វើឱ្យមានអត្ថប្រយោជន៍នានាពីបច្ចេកវិទ្យាថ្មី ជាពិសេសលើបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ។*

## ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ

ចាប់តាំងពីឆ្នាំ១៩៩៦ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ បានចាប់ផ្តើមទទួលស្គាល់នូវសារៈសំខាន់នៃការកាត់បន្ថយភាពក្រីក្រ។ ក្នុងកម្មវិធីអភិវឌ្ឍន៍ទូលំទូលាយរបស់ពួកគេ ក្រុមធនាគារពិភពលោក និងស្ថាប័នរូបិយវត្ថុអន្តរជាតិដែលត្រូវបានគេស្គាល់ថាជាស្ថាប័នBretton Woods នោះបានសន្មត់យកការកាត់បន្ថយភាពក្រីក្រ ជាមូលដ្ឋាននៃយុទ្ធសាស្ត្រថ្មីក្នុងការរំលោះបំណុល និងកិច្ចសហការនៃការអភិវឌ្ឍន៍។ ប្រទេសដែលជំពាក់បំណុលច្រើន និងប្រទេសក្រីក្រផ្សេងទៀតត្រូវបានជំរុញឱ្យបង្កើតនូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSPs) តាមរយៈដំណើរការដែលមានការចូលរួម។ យុទ្ធសាស្ត្រនោះ ត្រូវបញ្ជាក់ឱ្យបានច្បាស់ អំពីការកាត់បន្ថយ និង

គោលដៅដើម្បីលុបបំបាត់ឱ្យបានទាំងស្រុងនូវភាពក្រីក្រ ព្រមទាំងបង្កើតនូវទិសដៅនិងស្តង់ដាសម្រាប់វាស់វែងនៅក្នុងផ្នែកផ្សេងៗ ដូចជាការផលិតស្បៀង សុខភាព ការអប់រំ ពលកម្ម ភាពយុត្តិធម៌ អភិបាលកិច្ចល្អ និងការធ្វើឱ្យបានលទ្ធិប្រជាធិបតេយ្យ។ ទោះជាយ៉ាងនេះក៏ដោយក៏កម្មវិធីបែបនេះត្រូវបានទទួលរងនូវការរិះគន់ជាច្រើន រួមទាំងពីសំណាក់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិដែលទទួលបន្ទុកវិស័យសកលភាវូបនីយកម្ម និងសិទ្ធិមនុស្សផងដែរ (សូមមើលប្រអប់៧៥) ក្នុងការទទូចឱ្យគិតតែពីម៉ាក្រូសេដ្ឋកិច្ច ហើយដែលធ្វើឱ្យបាត់បង់នូវភាពជាម្ចាស់ការ និងការចូលរួមរបស់ប្រជាជនក្នុងស្រុក។[៣៨] ការស្ទាបស្ទង់មតិដែលធ្វើឡើងដោយមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) បានធ្វើការសិក្សាទៅលើវិសាលភាពដែល PRSPs បានគ្របដណ្តប់ផ្នែកទាំង៧ នៃចំនួនប្រជាជន និងបញ្ហាការអភិវឌ្ឍន៍ រួមទាំង សិទ្ធិមនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ចំនួន៤៤ រហូតដល់ឆ្នាំ២០០១។ ការសិក្សាបានលាតត្រដាងឱ្យឃើញថា បញ្ហាសិទ្ធិមនុស្សដែលមានទំនាក់ទំនងយ៉ាងជាក់ច្បាស់ទៅនឹងសន្ធិសញ្ញាអន្តរជាតិ គឺជាប្រធានបទដែលត្រូវបានគេលើកមកនិយាយ ដោយតិចតួចបំផុត ហើយថាប្រទេសភាគច្រើន មិននិយាយអំពីសិទ្ធិមនុស្សទាល់តែសោះ។[៣៩]

ទោះបីជាសិទ្ធិមនុស្ស មិនទាន់បានដើរតួជាចំបងនៅក្នុងការបង្កើត និងការអនុវត្តន៍ទៅលើ PRSPs ក៏ដោយ ក៏គោលនយោបាយទូទៅស្តីពីការរួមបញ្ចូលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នឹងនាំឱ្យមានមាគ៌ាយកសិទ្ធិមនុស្សជាគោល ដើម្បីបង្កើតលើយុទ្ធសាស្ត្រនានានៃការកាត់

[៣៨] Oloka-Onyango និង Udagama op. cit, ឃ្លាទី ៥៣

[៣៩] ការផ្តោតទៅលើប្រជាជន និងប្រធានបទផ្នែកអភិវឌ្ឍន៍ នៅក្នុងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ការប្រឈមមុខ និងកាលានុវត្តភាពសំរាប់ UNFPA ថ្ងៃទី១១ ខែមិនា ឆ្នាំ២០០២

បន្ថយភាពក្រីក្រ នៅក្នុងសកម្មភាពនានា របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្នុងស្ថាប័ន Bretton Woods និងទីភ្នាក់ងារម្ចាស់ជំនួយផ្សេងៗទៀត។

ផ្នែកដែលនៅសល់ទាំងប៉ុន្មានក្នុងជំពូកនេះ ដែលភាគច្រើន ផ្អែកទៅលើយោបល់ជាទូទៅរបស់គណៈកម្មាធិការ CESCR ផ្តោតទៅលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលត្រូវបានធានានៅក្រោមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ហើយនិង CESCR។ ផ្នែកនោះ ក៏លើកឡើងនូវគោលចំណុចសំខាន់ៗ ទាក់ទងនឹងបញ្ហាផ្សេងៗដែលពាក់ព័ន្ធ។

**ប្រអប់ ៧៧**

## តំលៃបន្ថែមនៃដំណោះស្រាយដោយផ្អែកលើសិទ្ធិមនុស្ស

ឆ្លើយតបទៅនឹងសំនួរស្តីពីតំលៃបន្ថែមទៅលើដំណោះស្រាយដោយផ្អែកលើសិទ្ធិមនុស្ស ចំពោះការកាត់បន្ថយភាពក្រីក្រ និងទៅកាន់ការអភិវឌ្ឍន៍ទូទៅ សេចក្តីណែនាំព្រាងផ្តល់នូវចំលើយដ៏គួរឱ្យជឿមួយគឺ : ការផ្តល់អំណាច ឬការធ្វើឱ្យមានភាពម្ចាស់ការ។

មាគាទទួលបានសិទ្ធិមនុស្សជាគោលផ្តល់នូវគំរោងបទដ្ឋានដ៏ជាក់ច្បាស់ និងគួរឱ្យជឿទុកចិត្តសម្រាប់ការបង្កើតនូវបទដ្ឋានគតិយុត្ត សំរាប់ជារូបមន្តកាត់បន្ថយភាពក្រីក្រ ពីព្រោះថា ការកាត់បន្ថយភាពក្រីក្រដោយមានប្រសិទ្ធភាពមិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការផ្តល់អំណាចដល់ប្រជាជនក្រីក្រ។ បទដ្ឋាន និងតំលៃរបស់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ មានសក្តានុពលភាព នឹងសម្រេចនូវការផ្តល់អំណាច នេះ។ នៅពេលដែលវិធីសាស្រ្តបែបនេះ ត្រូវបានគេប្រកាន់យកការកាត់បន្ថយភាពក្រីក្រលែងមានន័យថាគ្រាន់តែជាការបំពេញនូវតម្រូវការរបស់ប្រជាជនក្រីក្រទៀតហើយ។ វាក៏មានន័យថា ជាការទទួលស្គាល់ថាប្រជាជនក្រីក្រមានសិទ្ធិរបស់ខ្លួន ហើយស្របពេលជាមួយគ្នានោះ ក៏មានការបំពេញនូវកាតព្វកិច្ចតាមផ្លូវច្បាប់សម្រាប់អ្នកផ្សេងទៀត។ ហេតុនេះហើយ ការកាត់បន្ថយភាពក្រីក្របានក្លាយទៅជាអ្វី ដែលលើសពីការផ្តល់សប្បុរសធម៌ និងលើសពីការ

បំពេញកាតព្វកិច្ចបែបសីលធម៌ គឺវាក្លាយទៅជាការបំពេញកាតព្វកិច្ចទៅតាមផ្លូវច្បាប់ ដែលបង្កប់ន័យថា នីតិបុគ្គលដែលមានករណីកិច្ចក្នុងការបំពេញនូវតួនាទីនេះ រួមមានរដ្ឋ ស្ថាប័នអន្តររដ្ឋាភិបាល និងស្ថាប័នសកលទាំងឡាយ គួរតែត្រូវមានគណនេយ្យភាព ចំពោះកិច្ចការនេះ។

បន្ថែមទៅនឹងគំនិត ដែលសំដៅទៅដល់ភាពស្របច្បាប់ គណនេយ្យភាព និងការពង្រឹងអំណាចនោះ ទម្រង់សំខាន់នៃមាគ៌ាទទួលបានសិទ្ធិមនុស្សជាគោល រួមមានគោលការណ៍នៃលក្ខណៈសកល ភាពមិនរើសអើង និងភាពស្មើគ្នា មានការចូលរួម និងមានការទទួលស្គាល់នូវទំនាក់ទំនងរវាង គ្នាទៅវិញទៅមកនៃសិទ្ធិមនុស្សទាំងអស់។

កម្មវិធី និងស្ថាប័នរបស់អង្គការសហប្រជាជាតិជាច្រើន ជាពិសេស UNDP និង OHCHR បានអនុម័តយកនូវមាគ៌ាយកសិទ្ធិមនុស្សជាគោល ដើម្បីការអភិវឌ្ឍន៍មនុស្សជាតិ ដោយធ្វើការកំណត់ នូវវត្ថុបំណង នៃការអភិវឌ្ឍន៍ ក្នុងន័យដែលសិទ្ធិ ដែលអាចអនុវត្តបានទៅតាមផ្លូវច្បាប់។ មាគ៌ាទទួលបានសិទ្ធិ មនុស្សជាគោលនេះ មានគោលបំណង ដើម្បីពង្រឹងកម្រិតគណនេយ្យភាពនៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ តាមរយៈការកំណត់នូវអ្នកត្រូវទទួលបានសិទ្ធិ (និងសិទ្ធិដែលពួកគេត្រូវទទួលបាន) ហើយនិងអ្នកដែលត្រូវបំពេញករណីយកិច្ច (និងកាតព្វកិច្ចរបស់ពួកគេ) ហើយនិងតាមរយៈការបំលែងស្តង់ដារជាសកលទៅជាគោលដៅ ដែលកំណត់ឡើងនៅក្នុងស្រុក ដើម្បីសម្រាប់ធ្វើការវាស់វែងទៅលើភាពរីកចំរើន។

## សិទ្ធិទទួលបានសន្តិសុខសង្គម

មាត្រា២២ នៃ UDHR

*"ក្នុងឋានៈជាសមាជិកនៃសង្គម មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសន្តិសុខសង្គម និងត្រូវទទួលបានការសម្រេចនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូរ និងការរីកចំរើន ដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈ*

*ការខិតខំរបស់ជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ស្របតាមការរៀបចំ និងតាមធនធានរបស់ប្រទេសនីមួយៗ ។ ”*

មាត្រា២៥ នៃ UDHR

*“ ១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួន និងគ្រួសារ រួមមាន ចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត ។ មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការគាំពារ នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្តាលមកពីកាលៈទេសៈ ផុតពីឆន្ទៈរបស់ខ្លួន ។*
*២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស ។ កុមារគ្រប់រូប ទោះកើតពីឪពុកម្តាយមានខាន់ស្លា ឬឥតមានខាន់ស្លាក្តី ត្រូវបានទទួលការការពារខាងសង្គមកិច្ចដូចគ្នា ។ ”*

មាត្រា៩ នៃ CESCR

*“ រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូបទទួលបានសិទ្ធិសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គមផង ។ ”*

## តើអ្វីទៅជាប្រព័ន្ធសន្តិសុខសង្គម?

តាមពិតទៅ ប្រព័ន្ធសន្តិសុខសង្គម គួរតែមានគោលដៅ ដើម្បីផ្តល់នូវការគ្របដណ្តប់ដ៏ទូលំទូលាយសម្រាប់ស្ថានការណ៍គ្រប់ប្រភេទដែលអាចនឹងធ្វើការគំរាមកំហែងដល់សមត្ថភាពបុគ្គលណាម្នាក់ ក្នុងការរកប្រាក់កំរៃ និងដើម្បីធានានូវស្តង់ដានៃការរស់នៅឱ្យបានគ្រប់គ្រាន់។ ចំណុចទាក់ទងនឹងសុវត្ថិភាពសង្គម ត្រូវបានសង្ខេប នៅក្នុងអនុសញ្ញាស្តីពីសន្តិសុខ

សង្គម (ស្តង់ដាជាអប្បបរមា) នៅឆ្នាំ១៩៥២ (លេខ១០២) ។ ចំណុចទាំងនោះ មានដូចជា:

- ការថែទាំវេជ្ជសាស្ត្រ
- អត្ថប្រយោជន៍សម្រាប់ពេលមានជំងឺ
- អត្ថប្រយោជន៍នៅពេលគ្មានការងារធ្វើ
- អត្ថប្រយោជន៍សម្រាប់ចាស់ជរា
- អត្ថប្រយោជន៍សម្រាប់បុគ្គលិកនៅពេលរងរបួស
- អត្ថប្រយោជន៍សម្រាប់គ្រួសារ និងមាតុភាព
- អត្ថប្រយោជន៍ពេលអសុពលភាព
- អត្ថប្រយោជន៍សម្រាប់អ្នកនៅរស់បន្ត

នៅក្នុងប្រព័ន្ធសន្តិសុខសង្គម មានការបែងចែកខុសគ្នា រវាងកម្មវិធីធានារ៉ាប់រងសង្គមកិច្ច ដែលផ្តល់នូវប្រាក់ឧបត្ថម្ភ ក្នុងករណីមានការបង្អាក់ដល់ការរកចំណូលពីមុខរបរ និងកម្មវិធីជំនួយឧបត្ថម្ភសង្គមកិច្ចដែលផ្តល់នូវប្រាក់ឧបត្ថម្ភបន្ថែមទៅលើប្រាក់ចំណូលតិចតួចរបស់សមាជិកក្រុមដែលងាយរងគ្រោះ ។ កម្មវិធីទាំងពីរប្រភេទនេះ មានគោលបំណងដើម្បីធានានូវលក្ខខណ្ឌសំភារៈ ដែលត្រូវការសម្រាប់ការរស់នៅក្នុងកម្រិតបទដ្ឋានគ្រប់គ្រាន់ ហើយនិងផ្តល់ការការពារពីផលប៉ះពាល់ដែលបណ្តាលមកពីភាពក្រីក្រ និងអសន្តិសុខនៃផ្នែកសំភារៈ ។

ទាក់ទងទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ ការអង្កេតទៅលើសន្តិសុខសង្គម ត្រូវបានដាក់ជាលំដាប់លំដោយដូចខាងក្រោម:

- ប្រទេសចំនួនតិចតួចណាស់ ដែលបានបង្កើតផែនការសន្តិសុខសង្គម ដ៏ទូលំទូលាយ ដោយផ្តល់នូវការគ្របដណ្តប់ជាសកល
- ផែនការសន្តិសុខសង្គម ទំនងជាធ្វើឡើង ដើម្បីផ្តោតទៅលើក្រុមពិសេសនានា (ដូចជា កុមារ ឬស្ត្រីមានផ្ទៃពោះ)

- ផែនការសន្តិសុខសង្គមភាគច្រើន ជាកម្មវិធីជួយសង្គ្រោះបន្ទាន់ ដោយផ្តល់នូវការជួយឧបត្ថម្ភ នៅពេលមានគ្រោះមហន្តរាយ ។

ឧបសគ្គតែងតែកើតមានឡើងចំពោះប្រទេសកំពុងអភិវឌ្ឍន៍ នៅពេលដែលពួកគេព្យាយាមបង្កើតនូវប្រព័ន្ធសន្តិសុខសង្គម។ ឧបសគ្គនោះ រួមមាន ភាពក្រីក្រ អសមត្ថភាពផ្នែករដ្ឋបាល បំណុល និងគោលនយោបាយសំរបសំរួលរចនាសម្ព័ន្ធ ដែលដាក់កំហិតដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។

**កត្តាសំខាន់ៗ ដែលត្រូវយកមកពិចារណា ទាក់ទងទៅនឹងសិទ្ធិទទួលបានសន្តិសុខសង្គម**

នៅក្នុងកិច្ចប្រឹងប្រែង ដើម្បីធានាឱ្យបាននូវការអនុវត្តសិទ្ធិទទួលនូវសន្តិសុខសង្គម ស្ថាប័នរដ្ឋ ជាពិសេស សភា គួរតែចងចាំនូវអនុសាសន៍ដូចខាងក្រោមៈ

- ផែនការសកម្មភាពថ្នាក់ជាតិមួយ ដែលរួមមាន គោលដៅ សូចនករសម្រាប់វាស់វែងនូវភាពរីកចំរើន និងពេលវេលាកំណត់ច្បាស់លាស់ ។ ផែនការនេះ គួរតែត្រូវបានតាក់តែងឡើង ហើយយន្តការ គួរតែត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យការរីកចំរើនទៅលើការសម្រេចបាននូវសិទ្ធិនេះ ។
- វិធានការនីតិបញ្ញត្តិដែលទាក់ទងទាំងឡាយ គួរតែជំរុញឱ្យបាននូវការរីកចំរើនទៅលើការទទួលបាននូវសិទ្ធិនេះ ហើយត្រូវតែពុំមានភាពរើសអើងឡើយ
- ក្នុងកំឡុងពេលនៃការរីកចំរើន ទៅលើការទទួលបាននូវសិទ្ធិកម្រិតអប្បបរមា នៃសន្តិសុខសង្គម គួរតែត្រូវបានធានាឱ្យមានចំពោះក្រុមសង្គមដែលងាយរងគ្រោះជាទីបំផុត( ដូចជាចាស់ជរា កុមារដែលមកពីគ្រួសារក្រីក្រ បុគ្គលដែលមានជំងឺ ព្រមទាំងជនពិការ)
- ការអនុវត្តនវិធានការសន្តិសុខសង្គមគួរតែត្រូវទទួលការពិនិត្យ ហើយចំណែកឯវិធាន

ការកាត់បន្ថយ (ការកាត់បន្ថយគុណប្រយោជន៍នៃសុវត្ថិភាពសង្គម ឬទំហំនៃការគ្របដណ្តប់) គួរតែត្រូវជៀសវាង

- នីតិវិធីរដ្ឋបាល និងប្រព័ន្ធតុលាការ គួរតែត្រូវបង្កើតឱ្យមាន ដើម្បីជំរុញលទ្ធភាពឱ្យអ្នកដែលត្រូវទទួលផលប្រយោជន៍ អាចរិះរកនូវសំណងខូចខាតរបស់ខ្លួន
- ការជួយជ្រោមជ្រែង គួរតែបង្កើតឡើង ដើម្បីអនុវត្តវិធានការទាំងនេះ ដើម្បីជៀសវាងអំពើពុករលួយ និងការបន្លំ ទាក់ទងទៅនឹងគុណប្រយោជន៍នៃសន្តិសុខសង្គម ។

**ប្រអប់ ៧៨**

**សន្តិសុខសង្គមសម្រាប់ចាស់ជរា : សេចក្តីពន្យល់ទូទៅរបស់ CESCR លេខ៦**

"កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពុំបានចែងច្បាស់អំពីសិទ្ធិរបស់មនុស្សចាស់ជរាទេ ក៏ប៉ុន្តែនៅក្នុងមាត្រា១៦ មានចែងអំពី "សិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការទទួលបានសន្តិសុខសង្គម ដែលរួមមានការធានារ៉ាប់រងសង្គមកិច្ច"។ មាត្រានោះទទួលស្គាល់នូវសិទ្ធិទទួលប្រាក់ឧបត្ថម្ភរបស់ចាស់ជរា។ ទោះបីជាយ៉ាងណាក៏ដោយ ការពិតដែលថា សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញាសំដៅសម្រាប់គ្រប់សមាជិកទាំងអស់នៅក្នុងសង្គម វាច្បាស់ណាស់ដែលថាប្រជាជនចាស់ជរាក៏ត្រូវទទួលបាននូវសិទ្ធិពេញលេញ ដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញានោះដែរ ។"

## សិទ្ធិធ្វើការងារ និងសិទ្ធិនៅកន្លែងធ្វើការ

មាត្រា២៣ (១) នៃ UDHR

*" ១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ ជ្រើសរើសការងារដោយសេរី និងធ្វើការងារក្នុងលក្ខខណ្ឌត្រឹមត្រូវ និងពេញចិត្ត ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ ។ "*

## មាត្រា៦ នៃ CESCR

*" ១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិធ្វើការងារ រួមមាន សិទ្ធិរបស់មនុស្សគ្រប់រូប មានលទ្ធភាពចិញ្ចឹមជីវិតដោយការងារដែលជ្រើសរើស ឬព្រមទទួលយកដោយសេរី និងចាត់វិធានការសមស្រប ដើម្បីការពារសិទ្ធិនេះ ។*

*២. វិធានការដែលរដ្ឋភាគីនៃកតិកាសញ្ញានេះប្រកាន់យក ដើម្បីធានាការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះត្រូវរួមបញ្ចូលការតម្រង់ទិសខាងបច្ចេកទេស និងវិជ្ជាជីវៈ និងកម្មវិធីបណ្តុះបណ្តាលគោលនយោបាយ និងបច្ចេកទេស ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍ថេរខាងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការងារពេញលេញដែលមានផលប្រយោជន៍ក្នុងលក្ខខណ្ឌការពារ សេរីភាពមូលដ្ឋានខាងនយោបាយ និងសេដ្ឋកិច្ចចំពោះបុគ្គលគ្រប់រូប ។"*

## មាត្រា៧ នៃ CESCR

*" រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប ដើម្បីទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងប្រកបដោយអំណោយផល ដែលធានាជាពិសេសនូវ :*

*(ក) ប្រាក់កម្រៃដែលផ្តល់ជាអប្បបរមាឱ្យអ្នកធ្វើការនូវ :*

*១. បៀវត្សរ៍ប្រកបដោយសមរម្យ និងប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលមានតំលៃស្មើគ្នា ដោយមិនមានការបែងចែកណាមួយ ជាពិសេស ស្ត្រីត្រូវតែមានការធានានូវលក្ខខណ្ឌការងារដែលផ្តល់ឱ្យពួកគេមិនតិចជាងលក្ខខណ្ឌដែលបុរសទទួល ដោយត្រូវបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា ។*

*២. ជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនគេផ្ទាល់ និងគ្រួសារ ស្របតាមបញ្ញត្តិនៃកតិកាសញ្ញានេះ ។*

*(ខ) លក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព និងអនាម័យ ។*

*(គ) ឱកាសដូចគ្នាសម្រាប់បុគ្គលគ្រប់រូប ដើម្បីបានឡើងឋានៈក្នុងការងារទៅកម្រិតខ្ពស់*

*សមស្រប ដោយមិនពិចារណាទៅលើអ្វីផ្សេងពីអតីតភាពការងារ និងសមត្ថភាព ។*

*(ឃ) ការសម្រាក ការលំហែ ការកម្រិតម៉ោងធ្វើការសមរម្យ និងការឈប់សម្រាកតាមកាលកំណត់ទៀងទាត់ ដោយមានប្រាក់បៀវត្សរ៍ និងប្រាក់កម្រៃសម្រាប់ថ្ងៃបុណ្យជាតិ ។ "*

## សិទ្ធិធ្វើការងារ

ជាគោលសំខាន់ សិទ្ធិធ្វើការងារ ការពារបុគ្គលគ្រប់រូបប្រឆាំងទៅនឹងការផាត់ចេញពីសេដ្ឋកិច្ចក៏ដូចជាការពារបុគ្គលដែលគ្មានការងារធ្វើទល់នឹងការដាក់ឱ្យឯកោពីសង្គម ។

ជំរើសដោយសេរី ដែលមានចែងនៅក្នុងមាត្រា៦(១) នៃCESCR បានសង្កត់ធ្ងន់ថា : មុខរបរ និងការទទួលបាននូវធនធាន គួរតែត្រូវបានបែងចែក នៅក្នុងមធ្យោបាយណាមួយដែលធានាបានថាបុគ្គលគ្រប់ៗរូបដែលមានបំណងនឹងប្រកបមុខរបរណាមួយអាចធ្វើទៅបាន ហើយអាចជ្រើសរើស ឬទទួលនូវរបរនោះដោយសេរី ក្នុងគោលបំណងច្រើនផ្សេងៗដែលក្នុងនោះ គឺដើម្បីធ្វើការចិញ្ចឹមជីវិត តាមរយៈមុខរបរនោះ ។

នៅក្នុងបរិបទសិទ្ធិមនុស្ស "ការងារ" មានន័យទូលំទូលាយជាជាងត្រឹមតែជាពាក្យ "ប្រាក់ឈ្នួលកម្លាំងពលកម្ម" ។ ប៉ុន្តែ សំណួរថាតើ ការងារត្រូវបានរួមបញ្ចូលច្រើន ទៅក្នុងសកម្មភាពផ្សេងៗទៀតនៅក្នុងទិដ្ឋភាពនៃជីវិត (ឧទាហរណ៍ នៅក្នុងចំណោមជនជាតិភាគតិច) ឬតិចជាងនេះក៏ដោយ(ឧទាហរណ៍នៅក្នុងករណីអ្នកលក់កម្លាំងពលកម្ម) ការងារ មានន័យជានិច្ចថា ជាការអនុវត្តសកម្មភាព ដែលបំពេញនូវសេចក្តីត្រូវការ និងផ្តល់នូវសេវា ទៅដល់ក្រុមមនុស្ស ឬសង្គម ហេតុដូច្នេះហើយ ការងារ ត្រូវតែបានគេទទួលស្គាល់ ហើយទទួលបានជារង្វាន់មកវិញ ។

**ប្រអប់ ៧៩**

## ករណីយកិច្ចរបស់រដ្ឋទាក់ទងទៅនឹងមុខរបរការងារ ក្រោមមាត្រា១ នៃធម្មនុញ្ញសង្គមកិច្ចរបស់អឺរ៉ុប

- ដើម្បីទទួលយកជាវត្ថុបំណង និងការទទួលខុសត្រូវជាបឋមមួយក្នុងចំណោមវត្ថុបំណង និងការទទួលខុសត្រូវជាបឋមជាច្រើននូវការសម្រេចបាននិងការរក្សាបាននូវភាពមានការងារ ធ្វើក្នុងកម្រិតខ្ពស់និងមានលំនឹងតាមដែលអាចធ្វើទៅបានដោយមានការរំពៃគិតឃើញទៅដល់ការទទួលបានការងារធ្វើទាំងអស់គ្នា
- ដើម្បីការពារប្រកបដោយប្រសិទ្ធភាព នូវសិទ្ធិរបស់កម្មករនិយោជិក ក្នុងការរកកំរៃចិញ្ចឹមជីវិតរបស់ពួកគេ នៅក្នុងមុខរបរមួយ ដែលពួកគេជ្រើសរើសដោយសេរី ។
- ដើម្បីបង្កើត និងរក្សានូវការផ្តល់សេវារកការងារធ្វើ ដោយឥតគិតថ្លៃ ទៅដល់កម្មករនិយោជិកទាំងអស់ ។
- ដើម្បីផ្តល់ ឬលើកស្ទួយការណែនាំវគ្គហ្វឹកហ្វឺនសមរម្យ ក៏ដូចជាការបណ្តុះបណ្តាល និងការស្តារនីតិសម្បទា

នៅពេលដែលការតែងច្បាប់កំពុងត្រូវបានព្រាងស្តីពីសិទ្ធិធ្វើការងារ និងការអនុវត្តរបស់ច្បាប់នេះតាមរយៈគោលនយោបាយ ឬកម្មវិធីផ្សេងៗ ចំណាប់អារម្មណ៍ជាពិសេស គួរត្រូវបានផ្តោតទៅលើការទប់ស្កាត់ការរើសអើងទាក់ទងទៅនឹងការទទួលបាននូវការងារធ្វើ ។ ការតាក់តែងច្បាប់ គួរតែសំដៅទៅលើការសំរបសំរួល នូវការរាប់បញ្ចូលរបស់ជនមួយក្រុមៗ ដូចជា ក្រុមស្ត្រី ចាស់ជរា និងជនពិការទៅក្នុងពលកម្មទីផ្សារ ហើយជាទូទៅ គួរតែសំដៅទៅលើការការពារ និងការលើកស្ទួយសិទ្ធិរបស់និយោជិក ក្នុងការចិញ្ចឹមជីវិតរបស់ពួកគេ តាមរយៈការជ្រើសរើសនូវមុខរបរដោយសេរី ។

គោលដៅចំបងនៃគោលនយោបាយការងារ គួរតែជាការសម្រេចបាននូវការមានការងារធ្វើពេញលេញឱ្យបានលឿនបំផុតដែលអាចធ្វើទៅបាន ដោយស្របទៅនឹងធនធានជាតិ។ លើសពីផលប្រយោជន៍សង្គមកិច្ច គោលនយោបាយទាំងនោះ គួរតែលើកពីការព្រួយបារម្ភទាក់ទងនឹងភាពអត់មានការងារធ្វើ ដែលមានរយៈពេលយូរអង្វែង និងអ្នកដែលមានប្រាក់ចំណូលតិចតួច តាមរយៈការបង្កើតកម្មវិធីការងារសាធារណៈ។

រដ្ឋគួរតែធានាឱ្យបានថា ការបណ្តុះបណ្តាល និងការណែនាំបច្ចេកទេស ដែលអាចទទួលបានជាទូទៅ ដោយឥតគិតថ្លៃ ឬដោយតំលៃសមរម្យ ត្រូវបានបង្កើតឡើង ហើយថាការផ្តល់សេវារកការងារធ្វើ ដោយឥតគិតថ្លៃ សម្រាប់កម្មករនិយោជិក ត្រូវបានផ្តល់ឱ្យនៅកន្លែងធ្វើការ។

## សិទ្ធិនៅកន្លែងធ្វើការ

មាត្រា៧ នៃ CESCR ធានានូវសិទ្ធិរបស់បុគ្គលគ្រប់ៗរូប ដើម្បីទទួលបាននូវលក្ខខណ្ឌការងារដែលយុត្តិធម៌ និងសមស្រប។ លក្ខខណ្ឌទាំងនេះរួមមានៈ

- កំរៃការងារ ដែលផ្តល់ដល់និយោជិកទាំងអស់ជាអប្បបរមា នូវៈ
  - បៀវត្សរ៍ប្រកបដោយសមធម៌ និងប្រាក់កំរៃស្មើគ្នា ចំពោះការងារដែលស្មើគ្នាសម្រាប់ការងារដែលមានតំលៃស្មើគ្នា ដោយមិនមានការរើសអើង (ជាពិសេស ចំពោះស្ត្រី)
  - ការរស់នៅដោយសមរម្យ សម្រាប់កម្មករនិយោជិត និងគ្រួសាររបស់ពួកគេ
- លក្ខខណ្ឌធ្វើការដែលមានសុវត្ថិភាព និងមានសុខុមាលភាព
- ឱកាសស្មើៗគ្នា សម្រាប់ការឡើងឋានៈ ដោយផ្អែកទៅលើរយៈពេល ដែលបានធ្វើការ និងសមត្ថភាព

- រយៈពេលម៉ោងធ្វើការងារសមហេតុផល ការសំរាក ការលំហែ ពេលវេលាឈប់សំរាក និងការឈប់សំរាកសាធារណៈ ដែលទទួលបានប្រាក់កំរៃ ។

ហេតុដូច្នេះហើយ សមាជិកសភា គួរតែធានាឱ្យបានថា ចំណុចគន្លឹះដូចខាងក្រោមនេះត្រូវបានសង្កត់បញ្ជាក់នៅក្នុងការតាក់តែងច្បាប់ ហើយត្រូវបានអនុវត្តជាក់ស្តែងៈ

- ប្រាក់ឈ្នួលជាអប្បបរមា ដែលគ្រប់គ្រាន់ សម្រាប់លក្ខខណ្ឌរស់នៅដ៏សមរម្យ សម្រាប់កម្មករនិយោជិក និងគ្រួសាររបស់ពួកគេ ហើយនិងការហាមឃាត់នូវការធ្វើការងារដោយបង្ខំ
- បទដ្ឋានមានសុវត្ថិភាព សុខមាលភាព និងការត្រួតពិនិត្យលក្ខខណ្ឌការងារតាមលក្ខណៈជាប្រព័ន្ធ
- សិទ្ធិបង្កើត និងចូលរួមសហជីពកម្មករ ដែលសហជីពនោះ គួរតែអាចដំណើរការដោយស្វ័យភាព នៅក្នុងលំដាប់ជាតិ និងអន្តរជាតិ ។
- ភាពមិនមានការរើសអើង នៅកន្លែងធ្វើការ (ដែលក្នុងនោះ ប្រឆាំងនឹងស្ត្រី ជនជាតិភាគតិច ជនពិការ និងក្រុមសាសនា) ទាក់ទងទៅនឹងៈ
  - ប្រាក់ឈ្នួលៈ តំលៃប្រាក់ឈ្នួលត្រូវតែមានភាពស្មើគ្នា សម្រាប់ការងារដូចគ្នា
  - ឱកាសសម្រាប់ការឡើងតួនាទីៈ ទាំងនេះគួរតែមានភាពស្មើគ្នា ហើយផ្អែកទៅលើចំនួនឆ្នាំដែលបានធ្វើការ និងការអនុវត្តការងារ

## សិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ

មាត្រា២៥ នៃ UDHR

*" ១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួន និងគ្រួសារ រួមមាន ចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គមចាំបាច់ផ្សេងៗទៀត ។ មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការគាំពារ*

នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយផ្សេងៗដើម្បីជីវភាព ដែលបណ្តាលមកពីកាលៈទេសៈដែលគេមិនអាចត្រួតត្រាបាន ។

២.មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស ។ កុមារគ្រប់រូប ទោះកើតពីឪពុកម្តាយមានខាន់ស្លា ឬឥតមានខាន់ស្លាក្តី ត្រូវបានទទួលការការពារខាងសង្គមកិច្ចដូចគ្នា ។ ”

មាត្រា១១ នៃ CESCR

“ ១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមាន ចំណីអាហារ សំលៀកបំពាក់ និងលំនៅដ្ឋានសមរម្យ ព្រមទាំង ការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ ។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យសម្រេចបាននូវសិទ្ធិនេះ និងទទួលស្គាល់សារៈសំខាន់ចាំបាច់នៃសហប្រតិបត្តិការអន្តរជាតិ តាមការយល់ព្រមគ្នា ដោយសេរី ។

២. ដោយទទួលស្គាល់សិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូប រួចចាកផុតពីសេចក្តីស្រេកឃ្លាន រដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយម្នាក់ៗឯង និងតាមរយៈសហការអន្តរជាតិ ត្រូវចាត់វិធានការ រួមមាន កម្មវិធីពិសេសៗជាក់លាក់ ដែលចាំបាច់ដូចតទៅ ៖

(ក) ដើម្បីធ្វើឱ្យប្រសើរដល់វិធីនៃការផលិត ការរក្សាទុក និងការចែកចាយម្ហូបអាហារ ដោយការប្រើប្រាស់ពេញលេញនូវចំណេះដឹងខាងបច្ចេកទេស និងវិទ្យាសាស្ត្រ ដោយការផ្សព្វផ្សាយគោលការណ៍នៃការអប់រំស្តីពីអាហារូបត្ថម្ភ និងដោយការអភិវឌ្ឍន៍ ឬការកែទម្រង់របបដីធ្លី ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ។

*(ខ) ដើម្បីធានាការបែងចែកដោយសមធម៌នូវធនធានស្បៀងអាហារពិភពលោក ទៅតាមសេចក្តីត្រូវការ ដោយគិតទៅដល់បញ្ហាទាំងឡាយដែលចោទឡើងចំពោះប្រទេសនាំចូល ក៏ដូចជាប្រទេសនាំចេញស្បៀងអាហារ ។*

មាត្រា១២ នៃ CESCR

*១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាពទាំងខាងរាងកាយ និងខាងស្មារតី ខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ។*

*២. វិធានការនានា ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះចាត់ដើម្បីធានាការប្រើសិទ្ធិនេះឱ្យបានពេញលេញ ត្រូវរាប់បញ្ចូលនូវវិធានការដែលចាំបាច់ ដើម្បីធានា :*

*(ក) វិធានការសម្រាប់ការកាត់បន្ថយអត្រាមរណៈភាពនៃទារកក្នុងពោះម្តាយ និងមរណៈភាពកុមារ និងសម្រាប់ការរីកលូតលាស់ ប្រកបដោយសុខភាពល្អរបស់កុមារ ។*

*(ខ) ការធ្វើឱ្យប្រសើរគ្រប់ទិដ្ឋភាពនៃអនាម័យខាងផ្នែកបរិស្ថាន និងឧស្សាហកម្ម ។*

*(គ) វិធីបង្ការ ការព្យាបាល និងការត្រួតពិនិត្យជំងឺឆ្លង ជំងឺរាតត្បាត ជំងឺបណ្តាលមកពីវិជ្ជាជីវៈ និងជំងឺដទៃទៀត ព្រមទាំង ប្រយុទ្ធប្រឆាំងនឹងជំងឺទាំងនេះផង ។*

*(ឃ) ការបង្កើតលក្ខខណ្ឌសម្រាប់ធានាដល់ជនគ្រប់រូបនូវសេវាសុខាភិបាលគ្រប់ផ្នែក និងជំនួយផ្នែកសុខាភិបាលក្នុងពេលមានជំងឺ ។*

មាត្រា២៥ នៃ UDHR ធានាសិទ្ធិសង្គមកិច្ចដែលថា ក្នុងកម្រិតណាមួយនោះគឺជាមែកធាងនៃសិទ្ធិដែលទទួលយកបាន : សិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ ។

បន្ថែមទៅនឹងសិទ្ធិទទួលបានសន្តិសុខសង្គម ដែលទាក់ទងទៅនឹងចំណុចខាងលើ សិទ្ធិនេះក៏រាប់បញ្ចូលនូវសិទ្ធិដូចខាងក្រោមនេះដែរ:

- សិទ្ធិទទួលបានម្ហូបអាហារគ្រប់គ្រាន់
- សិទ្ធិទទួលបានសំលៀកបំពាក់សមរម្យ
- សិទ្ធិទទួលបានលំនៅដ្ឋាន
- សិទ្ធិសុខភាព

មាត្រា១១ នៃ CESCR ចែងអំពី សិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ (ម្ហូបអាហារ សំលៀកបំពាក់ និងលំនៅដ្ឋាន) ហើយទទួលស្គាល់នូវសិទ្ធិទទួលបានលក្ខខណ្ឌរស់នៅប្រកបដោយការរីកចំរើនជាលំដាប់។ ភាគីរដ្ឋជាផ្នែកមួយនៃសន្ធិសញ្ញានេះ បានប្តេជ្ញាចិត្ត "នឹងចាត់វិធានការសមស្រប ដើម្បីធានាការទទួលបានសិទ្ធិនេះ ដោយទទួលស្គាល់នូវសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលមានមូលដ្ឋានទៅលើការយល់ព្រម ដោយសេរី។" នៅក្នុងមាត្រា១១ នៃ CESCR គណៈកម្មាធិការ CESCR ក៏បានដាក់ចេញមកនូវសិទ្ធិទទួលបានទឹកប្រើប្រាស់ផងដែរ។

ភាពអត់ឃ្លាន និងភាពក្រីក្រនៅលើពិភពលោក ផ្ទុយទៅនឹងសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ។ ហេតុដូច្នេះហើយ សិទ្ធិនេះ គួរតែបង្កើតជាមូលដ្ឋាននៃផែនការ និងយុទ្ធ-សាស្ត្រកាត់បន្ថយភាពអត់ឃ្លាន និងភាពក្រីក្រ ទាំងថ្នាក់ជាតិ និអន្តរជាតិ។

## សិទ្ធិទទួលបានចំណីអាហារ

ទោះបីជាសហគមន៍អន្តរជាតិ តែងតែធ្វើអំណះអំណាងជារឿយៗ អំពីសារៈសំខាន់ នៃការគោរពដោយពេញទំហឹង នូវសិទ្ធិទទួលបានចំណីអាហារគ្រប់គ្រាន់ក៏ដោយ ក៏នៅតែមានគំលាតដ៏ធំធេងនៅក្នុងវិស័យនេះ រវាងបទដ្ឋានច្បាប់អន្តរជាតិ និងស្ថានការណ៍ពិតៗ ដែលតែងតែកើតមានឡើង នៅលើកន្លែងជាច្រើនក្នុងពិភពលោកនេះ។ ប្រជាជនជាង ៨៤០លាននាក់ នៅពាសពេញពិភពលោក ប្រឈមមុខនឹងភាពអត់ឃ្លានហួសហេតុ ហើយប្រជាជនរាប់

លាននាក់ទទួលរងនូវគ្រោះអត់ឃ្លាន ដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ ជំលោះស៊ីវិល សង្គ្រាមនិងយកអាហារធ្វើជាអាវុធនយោបាយ។ ជាងនេះទៅទៀត គណៈកម្មាធិការ CESCRបានធ្វើការសង្កេតថា "ការខ្វះជីវជាតិ និងកង្វះអាហាររូបត្ថម្ភ និងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបាននូវអាហារគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេរីភាព ពីភាពអត់ឃ្លាន ក៏មានកើតឡើងនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍន៏ជាទីបំផុតដែរ "។[៤០] ហេតុដូច្នេះហើយ បញ្ហានេះគឺជាបញ្ហាសកល ហើយទាមទារនូវការយកចិត្តទុកដាក់យ៉ាងពេញទំហឹងពីសហគមន៍អន្តរជាតិ។

នៅក្នុងឆ្នាំ១៩៩៦ ជំនួបកំពូលស្តីពីស្បៀងអាហារពិភពលោក បានដាក់ចេញនូវគោលដៅ សំដៅទៅដល់ការកាត់បន្ថយ ឱ្យបានពាក់កណ្តាល នូវអត្រាប្រជាជនដែលពុំបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ ត្រឹមឆ្នាំ២០១៥។ ចំណែកឯគោលដៅអភិវឌ្ឍន៏សហវត្សទី១ ក៏មានដាក់ចេញនូវការកាត់បន្ថយឱ្យបានពាក់កណ្តាល នូវសមាមាត្រប្រជាជន ដែលពឹងផ្អែកទៅលើប្រាក់តិចជាង ១ ដុល្លារ ក្នុង១ថ្ងៃ ហើយនិងប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន ក្នុងឆ្នាំជាមួយគ្នា។

ខណៈដែលប្រទេសកំពុងអភិវឌ្ឍន៏បានទទួលជោគជ័យក្នុងការកាត់បន្ថយភាពអត់ឃ្លានបានយ៉ាងលឿន រូបភាពទូទៅនៃបញ្ហានេះ នៅតែជារឿងក្រៀមក្រំ។ យោងទៅតាមការវាយតំលៃរបស់ FAO ទោះបីជា ចំនួនប្រជាជនដែលទទួលរងនូវកង្វះអាហារូបត្ថម្ភយ៉ាងធ្ងន់ធ្ងរ បន្ធ្លាក់ចុះបន្តិចម្តងៗ រវាងឆ្នាំ១៩៩៥-១៩៩៧ និងឆ្នាំ២០០០-២០០២ ក៏ដោយ ក៏ការពិតទៅចំនួនប្រជាជន ដែលទទួលរងនូវកង្វះអាហារូបត្ថម្ភ បានកើនឡើងដល់ទៅ ១៨លាននាក់។ នៅកំឡុងឆ្នាំ២០០០-២០០២ ប្រជាជនប្រហែល ៨៥២លាននាក់ ពាសពេញពិភពលោក

[៤០] CESCR សេចក្តីពន្យល់ទូទៅ លេខ១២ (១៩៩៩)

ត្រូវបានវាយតំលៃថាខ្វះអាហារូបត្ថម្ភ( ៩លាននាក់រស់នៅក្នុងប្រទេសឧស្សាហកម្ម ២៨លាននាក់នៅក្នុងប្រទេសដែលស្ថិតនៅក្នុងកាពអន្តរកាល និង៨១៥លាននាក់ ស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏) ។ [៤១]

នៅក្នុងបណ្តាប្រទេសដែលទទួលបានជោគជ័យ នៅក្នុងការកាត់បន្ថយភាពអត់ឃ្លាន GDP បានកើនឡើងលឿនលើសពី ៥ដង (នៅក្នុងអាត្រា ២.៦% ក្នុង១ឆ្នាំ) ជាងនៅក្នុងបណ្តាប្រទេសដែលបញ្ហាកង្វះអាហារូបត្ថម្ភកើនឡើង (នៅក្នុងអាត្រា 0.៥% ក្នុង១ឆ្នាំ) ។ ប្រទេសដែលទទួលជោគជ័យបំផុត ក៏បានបង្ហាញនូវការរីកលូតលាស់លឿនជាងមុន ខាងផ្នែកវិស័យកសិកម្ម អាត្រាទាបជាងមុន នៃការរីករាលដាលនៃមេរោគអេដស៏ និងការកើនឡើងយឺតនៃចំនួនប្រជាជន ។ [៤២]

## តើសិទ្ធិទទួលបានចំណីអាហារ អាចធ្វើឱ្យសម្រេចបានដោយវិធីណា?

*"ភាពអត់ឃ្លាន និងកង្វះជីវជាតិ មិនមែនបង្កឡើងដោយព្រេងវាសនា ឬជាការដាក់ទំនាយរបស់ធម្មជាតិឡើយ បញ្ហានេះ គឺបង្កឡើងដោយមនុស្សផ្ទាល់ ។"*

*Jean Ziegler, អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិទទួលបានចំណីអាហារ: របាយការណ៍ស្តីពីសិទ្ធិទទួលបានចំណីអាហារ (E/CN.4/2001/53) ឆ្នាំ២០០៦ ឃ្លាទី៦*

សិទ្ធិទទួលបានចំណីអាហារគ្រប់គ្រាន់ គឺមិនអាចផ្តាច់ចេញពីភាពថ្លៃថ្នូរដែលមាននៅក្នុងបុគ្គលម្នាក់ៗ ហើយវាពាក់ព័ន្ធនឹងមានសារៈសំខាន់ជាទីបំផុត ជាមួយនឹងការទទួលបានសិទ្ធិមនុស្សដទៃទៀត ។

---

[៤១] អង្គការស្បៀងអាហារ និងកសិកម្មអង្គការសហប្រជាជាតិ: ភាពពុំច្បាស់លាស់នៃសន្តិសុខស្បៀង នៅលើពិភពលោក ឆ្នាំ២០០៤ ទីក្រុងរ៉ូម ឆ្នាំ២០០៤

[៤២] Ibid.

ប្រអប់ ៨០

## ក្របខ័ណ្ឌច្បាប់ស្តីពីស្បៀងអាហារ

ខណៈដែលរដ្ឋនានានៅក្រោមកតិកាសញ្ញា CESCR មានកាតព្វកិច្ចមួយក្នុងការធានាការអនុវត្ត សិទ្ធិទទួលបានចំណីអាហារ ហើយត្រូវតែដាក់សិទ្ធិនេះនៅក្នុងច្បាប់នោះក៏ដោយ ក៏ប្រជាពលរដ្ឋ ដែលរងនូវភាពអត់ឃ្លានអាចស្វែងរកការដោះស្រាយទៅលើបញ្ហានេះបាន លុះត្រាតែក្នុងករណី កតិកាសញ្ញានេះត្រូវបានគេលើកយកមកពិភាក្សានៅចំពោះមុខតុលាការ ដែលករណីនេះ ជាការកម្រនឹងកើតឡើង ឬក៏វាត្រូវបានគេបញ្ចូលទៅក្នុងច្បាប់ជាតិនានា។ ហេតុដូច្នេះហើយ គណៈ កម្មាធិការ ដែលត្រួតពិនិត្យការអនុវត្តសន្ធិសញ្ញានេះបានទទូចឱ្យប្រទេសទាំងអស់ គួរតែចេញច្បាប់ ដើម្បីការពារសិទ្ធិទទួលបានចំណីអាហារ ហើយបានផ្តល់អនុសាសន៍ជាពិសេសដល់រដ្ឋនានា ដើម្បី ឱ្យពួកគេពិចារណាទៅលើ*ការអនុវត្តគំរោងច្បាប់ ដែលនៅក្នុងនោះធានាថា* ដំណោះស្រាយនានាត្រូវបាន យកចិត្តទុកដាក់ នៅក្នុងករណីមានការកេងប្រវ័ញ្ចលើសិទ្ធិទទួលបានចំណីអាហារ។

សេក្តីពន្យល់ទូទៅលេខ១២ របស់ CESCR បញ្ជាក់ថា “ គំរោងច្បាប់គួរតែរាប់បញ្ចូលនូវគោល បំណង ទិសដៅ ឬគោលដៅ ដែលត្រូវសម្រេច និងពេលវេលាកំណត់ សម្រាប់ការសម្រេចបាន ទិសដៅទាំងនោះ។ គំរោងច្បាប់នោះ ក៏គួររាប់បញ្ចូលវិធីសាស្ត្រដែលនាំឱ្យគោលបំណងទាំងនោះ អាច ត្រូវសម្រេចបាន នៅក្នុងន័យទូលំទូលាយមួយ ជាពិសេស ការប៉ុនប៉ងធ្វើកិច្ចសហប្រតិបតិការ ជាមួយសង្គមស៊ីវិល និងវិស័យឯកជន ព្រមទាំងជាមួយអង្គការអន្តរជាតិ ស្ថាប័ននានា ដែល ទទួលខុសត្រូវ ចំពោះដំណើរការនៃច្បាប់នេះ និងយន្តការថ្នាក់ជាតិ សម្រាប់ការត្រួតពិនិត្យ ក៏ដូចជា នីតិវិធីសម្រាប់ជំរើសផ្សេងទៀត បើអាចទៅរួច។ នៅក្នុងការបង្កើតនូវរង្វាស់ប្រវែង និងការ តាក់តែងច្បាប់ ភាគីរដ្ឋគួរតែធ្វើការទំនាក់ទំនង ដោយសកម្មជាមួយអង្គការសង្គមស៊ីវិលនានា។ ”

សិទ្ធិទទួលបានចំណីអាហារអាចទទួលបាន នៅពេលដែលស្ត្រី បុរសនិងកុមារគ្រប់ៗ រូប តែឯង ឬនៅក្នុងការសហការជាមួយអ្នកផ្សេងទៀត មានលទ្ធភាពគ្រប់ពេលវេលា ខាងផ្នែក សេដ្ឋកិច្ច ក៏ដូចជាផ្នែករាងកាយ ក្នុងការទទួលបានចំណីអាហារគ្រប់គ្រាន់ ឬទទួលបាននូវ មធ្យោបាយក្នុងការទិញចំណីអាហារ។ នេះមិនមែនមានន័យថា រដ្ឋាភិបាល ត្រូវតែផ្តល់នូវ

ម្ហូបអាហារ ដោយឥតគិតថ្លៃ គ្រប់ពេលវេលា ទៅគ្រប់គ្នានោះទេ ប៉ុន្តែ វាទាក់ទងទៅនឹងករណីយកិច្ចរបស់រដ្ឋាភិបាល ក្នុងការគោរព ការការពារ ការបំពេញកាតព្វកិច្ច និងក្រោមកាលៈទេសៈណាមួយនោះ ត្រូវតែផ្តល់នូវសិទ្ធិនោះ។

ជាបន្ទាប់ទៅនេះ គឺជាឧទាហរណ៍ជាក់លាក់មួយចំនួន នៃការចាត់វិធានការនានា និងសកម្មភាពនានា ដែលត្រូវអនុវត្ត។

ក្របខ័ណ្ឌច្បាប់ គួរតែត្រូវបង្កើតឡើងជាឧបករណ៍គន្លឹះ សម្រាប់ការបង្កើត និងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីស្បៀង និងសន្តិសុខស្បៀង សម្រាប់ទាំងអស់គ្នា។

នៅក្នុងការពិនិត្យឡើងវិញទៅលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ ហើយនិងការផ្សារភ្ជាប់ចំណុចទាំងអស់នេះ ជាមួយនឹងច្បាប់សិទ្ធិមនុស្សស្តីពីសិទ្ធិទទួលបានចំណីអាហារ ចំណាប់អារម្មណ៍ជាពិសេស គួរតែត្រូវផ្តោតទៅលើតម្រូវការដើម្បីរារាំងកុំឱ្យមានការរើសអើងទាក់ទងទៅនឹងការទទួលបានស្បៀង ឬធនធានដែលពាក់ព័ន្ធ។ វិធានការខាងក្រោមនេះត្រូវបានអំពាវនាវឱ្យមាន ៖

១. *ធានាឱ្យបាននូវការទទួលយកបាននូវស្បៀងអាហារ* ទាំងផ្នែកសេដ្ឋកិច្ច និងរូបរាងកាយ ទៅដល់សមាជិកគ្រប់ក្រុមទាំងអស់ រួមទាំងប្រជាជនក្រីក្រ និងផ្នែកផ្សេងទៀតនៃសង្គមដែលងាយរងគ្រោះ ឬក៏ទទួលរងនូវការរើសអើង។ គ្មានសកម្មភាពណាមួយអាចបង្អាក់នូវការទទួលយកបានអាហារគ្រប់គ្រាន់ (ឧទាហរណ៍ៈ ការដកហូតប្រជាជនចេញពីដីរបស់ពួកគេ ដោយពុំត្រឹមត្រូវតាមផ្លូវច្បាប់ ការដាក់នូវសារធាតុមានជាតិពុលទៅក្នុងម្ហូបអាហារដោយចេតនា ឬក៏នៅក្នុងពេលមានជំលោះអាវុធ មានការបណ្តាលឱ្យមានការបំផ្លាញដល់ធនធាន ផលិតផល ហើយនិងការរារាំងដល់ការផ្តល់ជំនួយសង្គ្រោះ ទៅកាន់ប្រជាជនស៊ីវិល ជាដើម)។

វិធានការនានា គួរតែត្រូវបានអនុវត្ត ដើម្បីការពារសហគ្រាស ឬបុគ្គលណាម្នាក់ ពីការធ្វើឱ្យបាត់បង់នូវការទទួលយកបានចំណីអាហារគ្រប់គ្រាន់។ កាតព្វកិច្ច ដើម្បីការពារសំដៅទៅលើការជំរុញឱ្យមានច្បាប់ ការពារអ្នកប្រើប្រាស់ និងការអនុវត្តច្បាប់នេះ ឧទាហរណ៍ នៅក្នុងករណីក្រុមហ៊ុនណាមួយ ធ្វើឱ្យកខ្វក់ដល់ទឹកសម្រាប់ប្រើប្រាស់ ឬប្រសិនបើក្រុមហ៊ុនផ្គាច់មុខនានា ធ្វើឱ្យខូចទីផ្សារស្បៀង ឬការផ្តល់នូវគ្រាប់ពូជ។

២. ធានាឱ្យបានថា គ្រប់គ្នាទាំងអស់ ជាពិសេស ស្ត្រី ទទួលបាននូវសិទ្ធិពេញលេញ និងស្មើគ្នា *ក្នុងការទទួលយកនូវធនធានសេដ្ឋកិច្ច* រួមមាន សិទ្ធិស្នងមរតក និងធ្វើជាម្ចាស់ដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត និងការទទួលយកបាននូវឥណទាន ធនធានធម្មជាតិ និងបច្ចេកវិទ្យាផ្សេងៗ ទៅតាមការគួរ។

ដើម្បីធានានិងពង្រឹងដល់ប្រជាជនក្នុងការទទួលបាន និងការប្រើប្រាស់ធនធានផ្សេងៗ និងមធ្យោបាយចិញ្ចឹមជីវិត វិធានការមួយចំនួន គួរតែត្រូវបានដាក់ចេញ ដើម្បីធានាឱ្យបានថា ៖

- ប្រជាពលរដ្ឋទទួលបានប្រាក់ឈ្នួលគ្រប់គ្រាន់ ឬការទទួលបាននូវដីធ្លី ការទិញ និងផលិតស្បៀង

- ក្រុមដែលងាយរងគ្រោះ ត្រូវបានកំណត់ ហើយគោលនយោបាយ ត្រូវបានអនុវត្ត ដើម្បីផ្តល់ឱ្យពួកគេ ទទួលបាននូវស្បៀងអាហារគ្រប់គ្រាន់ តាមរយៈការពង្រឹងសមត្ថភាព ដើម្បឱ្យពួកគេអាចចិញ្ចឹមជីវិតដោយខ្លួនឯង(ឧទាហរណ៍ៈ តាមរយៈលទ្ធភាពនៃការមានការងារធ្វើដែលប្រសើរ កម្មវិធីផ្លាស់ប្តូរទម្រង់កសិកម្មសំរាប់អ្នកដែលអត់មានដីធ្លី ឬការផ្តល់ទឹកដោះគោដោយឥតគិតថ្លៃនៅក្នុងសាលាដើម្បីធ្វើឱ្យប្រសើរឡើង ដល់អាហារូបត្ថម្ភសម្រាប់កុមារ)។

៣. វិធានការមួយចំនួន គួរតែត្រូវបានដាក់ចេញ ដើម្បីគោរព និងការពារការប្រកបរបរផ្ទាល់ខ្លួន និងការងារដែលទទួលបានប្រាក់កំរៃ អាចនឹងធានានូវលក្ខខណ្ឌរស់នៅដោយសមរម្យ សម្រាប់និយោជិកនិងគ្រួសាររបស់ពួកគេ និងដើម្បីរារាំងមិនឱ្យកើតមានការរុញច្រានចោលការទទួលបាននូវការងារធ្វើ ស្ថិតលើមូលដ្ឋាន ភេទ ជាតិសាសន៍ ឬការរើសអើងផ្សេងទៀត ពីព្រោះការរើសអើងនេះអាចប៉ះពាល់ដល់សមត្ថភាពធ្វើការងាររបស់និយោជិក ក្នុងការចិញ្ចឹមជីវិតរបស់ពួកគេ។

៤. ការរក្សានូវការចុះបញ្ជីដីធ្លី

រដ្ឋាភិបាល គួរតែមានគំនិតបង្កើតនូវកម្មវិធី ជួយជ្រោមជ្រែងដល់កសិករឱ្យបានគ្រប់គ្រាន់ ដោយផ្តោតជាសំខាន់ ទៅលើអ្នកដែលត្រូវការបំផុត ឧទាហរណ៍ដូចជា តាមរយៈការធានានូវសិទ្ធិរបស់ជនជាតិដើម ក្នុងការទទួលបាននូវដីធ្លីដែលតពីដូនតារបស់ពួកគេ ការផ្តល់អំណាចដល់ស្ត្រី និងជួយជ្រោមជ្រែងអ្នកផលិតទ្រង់ទ្រាយខ្នាតតូច និងកសិករ ដែលស្ថិតនៅតំបន់ដាច់ស្រយាល (ដូចជានៅតាមតំបន់ភ្នំ ឬតំបន់ទីរហោស្ថាន)។

ស្បៀងគួរតែត្រូវបានផ្តល់ឱ្យ នៅពេលដែលបុគ្គលណាម្នាក់ ឬក្រុមណាមួយ មិនអាចចិញ្ចឹមជីវិតរបស់ពួកគេបាន ដោយសារមូលហេតុ ពួកគេមិនអាចគ្រប់គ្រងស្ថានភាពបាន រួមមាន គ្រោះធម្មជាតិ និងគ្រោះផ្សេងៗទៀត (ប្រភេទនៃការឧបត្ថម្ភ អាចរួមមាន ការចែកចាយស្បៀងដោយផ្ទាល់ ការផ្ទេរប្រាក់ ឬក៏តាមរយៈកម្មវិធីការងារ ដើម្បីស្បៀង)។

## តើត្រូវតែចាត់វិធានការភ្លាមៗឬ?

ដូចគ្នាទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ផងដែរ កាតព្វកិច្ចរបស់រដ្ឋក្នុងការបំពេញនិងការពារសិទ្ធិទទួលបានស្បៀងគ្រប់គ្រាន់ គឺជាកម្មវត្ថុដែលត្រូវធ្វើអោយទទួលបានជាបណ្តើរៗ ដែលនេះមានន័យថា គឺគេមិនបានតម្រូវឱ្យរដ្ឋ ធ្វើអោយបានសម្រេចការទទួលបាននេះ

ទាំងស្រុងភ្លាមៗនោះទេ ប៉ុន្តែ ត្រូវចាត់វិធានការ ដើម្បីសម្រេចឱ្យបានជាបណ្តើរៗ តាមរយៈ *ការប្រើប្រាស់ធនធានដែលមានឱ្យអស់ពីលទ្ធភាព*។ តែទោះជាយ៉ាងណាក៏ដោយ កាតព្វកិច្ចខាងក្រោមនេះ គឺមិនមែនជាកម្មវត្ថុដែលត្រូវធ្វើ អោយទទួលបានជាបណ្តើរៗទេ គឺរដ្ឋមានតួនាទី ត្រូវចាត់វិធានការជាបន្ទាន់ទាក់ទងទៅនឹងចំណុចទាំងនេះ:

- បញ្ចៀសពីការរើសអើងណាមួយ ទាក់ទងទៅនឹងការទទួលបានស្បៀង និងការទទួលបានមធ្យោបាយ និងសិទ្ធិ សម្រាប់ការទិញស្បៀងនោះ
- ផល់ជាអប្បបរមា នូវការចិញ្ចឹមជីវិតជាមូលដ្ឋាន (ដើម្បីធានានូវការរួចផុតពីការអត់ឃ្លាន)
- ជៀសវាងគោលការណ៍កាត់បន្ថយ

## សិទ្ធិខាងសំលៀកបំពាក់

សិទ្ធិក្នុងការមានសំលៀកបំពាក់គ្រប់គ្រាន់ គឺជាសមាសភាពទី៣ដែលបានបញ្ជាក់យ៉ាងច្បាស់ក្នុងសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ (បន្ទាប់ពីសិទ្ធិទទួលបាននូវសន្តិសុខសង្គម និងសិទ្ធិទទួលបានចំណីអាហារ)។ រដ្ឋាភិបាល ត្រូវតែគោរពនូវរបៀបស្លៀកពាក់ ជាពិសេស របស់សមាជិកជនជាតិភាគតិចនិងជនជាតិដើម គោរពសំលៀកបំពាក់របស់ពួកគេហើយត្រូវការពារពួកគេប្រឆាំងនឹងច្បាប់ស្លៀកពាក់ ដោយមានការរើងអើងមិនត្រឹមត្រូវតាមច្បាប់ ការបៀតបៀន និងការជ្រៀតជ្រែកស្រដៀងគ្នា ពីសំណាក់សមាជិករដ្ឋ និងមិនមែនរដ្ឋ។ លើសពីនេះទៅទៀត រដ្ឋាភិបាល ត្រូវតែបង្កើតឱ្យមានគ្រប់គ្រាន់នូវសំលៀកបំពាក់ សម្រាប់ប្រជាជនដែលក្រីក្រជាទីបំផុត រួមមាន ប្រជាជនក្រីក្រ ជនដែលត្រូវបានគេឃុំឃាំង ជនភៀសខ្លួន និងជនភៀសសឹក។ ប្រភេទសំលៀកបំពាក់ អាស្រ័យទៅលើលក្ខខណ្ឌវប្បធម៌ សង្គម និងអាកាសធាតុ។ យ៉ាងហោចណាស់ ប្រជាជនក្រីក្រ គួរទទួលបាននូវ សំលៀកបំពាក់ដែលជំរុញឱ្យពួកគេអាចចេញមុខនៅទីសាធារណៈ ដោយពុំមានការខ្មាសអៀន។

## សិទ្ធិមានលំនៅដ្ឋាន

សិទ្ធិមានលំនៅដ្ឋានសមរម្យ មិនគួរត្រូវបានយល់ដោយចង្អៀតចង្អល់ ថាជាសិទ្ធិទទួលបាននូវដំបូលជ្រកនោះឡើយ ក៏ប៉ុន្តែ វាគួរតែត្រូវបានមើលឃើញថាជាសិទ្ធិក្នុងការរស់នៅកន្លែងណាមួយ ដោយសុវត្ថិភាព សន្តិភាព និងប្រកបដោយភាពថ្លៃថ្នូរ។

ភាពអត់មានទីជំរក គឺជាទម្រង់ហួសប្រមាណ នៃការមិនទទួលស្គាល់ នូវសិទ្ធិក្នុងការមានទីជំរក ហើយជាកត្តាមួយដែលបណ្តាលឱ្យមានភាពក្រីក្រ។ ប៉ុន្តែ ស្ថានការណ៍ ដែលមិនប្រាកដប្រជារបស់អ្នកដែលរស់នៅតាមតំបន់ដាច់ស្រយាល និងអ្នករស់នៅក្នុងសំណង់អនាធិបតេយ្យ ជាច្រើនលាននាក់ ដែលប្រឈមមុខនឹងភាពចង្អៀតណែនហួសប្រមាណ កង្វះប្រព័ន្ធថែទាំ កាកសំណល់ ការបំពុល ការប្រឈមមុខតាមរដូវកាល ក្នុងលក្ខខណ្ឌអាកាសធាតុអាក្រក់បំផុត និងកង្វះទឹកស្អាត និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ដែលនាំអោយបាត់បង់ធ្ងន់ធ្ងរ នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។ គោលដៅអភិវឌ្ឍន៏សហសវត្ស រាប់បញ្ចូលគោលដៅជាក់លាក់ នៅក្នុងវិស័យនេះ : "នឹងសម្រេចឱ្យបាននូវភាពរីកចំរើនដ៏គួរឱ្យកត់សំគាល់ នៃជីវិតរស់នៅរបស់អ្នករស់នៅសំណង់អាណាធិបតេយ្យនានា យ៉ាងហោចណាស់ចំនួន ១០០ លាននាក់ ត្រឹមឆ្នាំ២០២០។"

## *សិទ្ធិលំនៅដ្ឋាន : ការទទួលបាននូវធាតុផ្សំរបស់វា*

សេចក្តីពន្យល់ទូទៅលេខ៤របស់CESCR ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ កំណត់ថា សិទ្ធិដូចដែលមានការពាក់ព័ន្ធជាក់លាក់ មានដូចខាងក្រោមនេះ:

### ក. ការកាន់កាប់ដោយមានសន្តិសុខតាមផ្លូវច្បាប់

ជនគ្រប់រូប គួរតែមានកម្រិតសន្តិសុខ នៃការកាន់កាប់លំនៅដ្ឋានរបស់ខ្លួន ដែលធានាការពារដោយច្បាប់ប្រឆាំងនឹងការបណ្តេញដោយបង្ខំ ការយាយី និងការគំរាមកំហែង

ផ្សេងទៀត។ ជាលទ្ធផល រដ្ឋាភិបាល គួរតែចាត់វិធានការភ្លាមជាបន្ទាន់ក្នុងគោលបំណងផ្តល់នូវសន្តិសុខផ្លូវច្បាប់ ដល់គ្រួសារណាដែលពុំទាន់មានឯកសាររបៀបនោះ។ វិធានការទាំងនេះ គួរតែត្រូវបានធ្វើឡើង តាមរយៈការពិគ្រោះយោបល់ជាមួយបុគ្គល និងក្រុមដែលប៉ះពាល់នានា។

## ខ. ភាពអាចរកបាននៃសេវាកម្ម សំភារៈ និងហេដ្ឋារចនាសម្ព័ន្ធ

រាល់អ្នកដែលត្រូវទទួលបានផលពីសិទ្ធិមានលំនៅដ្ឋានសមរម្យ គួរតែទទួលបានជានិរន្តរភាពនូវធនធានធម្មជាតិ និងធនធានរួម : ទឹកស្អាតសម្រាប់បរិភោគ ថាមពលសម្រាប់ការចំអិន កំដៅ និងភ្លើង អនាម័យស្អាត និងឧបករណ៍សម្រាប់ដុះលាង ឧបករណ៍សម្រាប់ផ្ទុកម្ហូបអាហារ ប្រព័ន្ធចោលកាកសំណល់ ប្រព័ន្ធចម្រោះ ព្រមទាំងសេវាសង្គ្រោះបន្ទាន់។

## គ. លំនៅដ្ឋានដែលមានតំលៃសមរម្យអាចទិញបាន

ចំណាយផ្ទាល់ខ្លួន ឬចំណាយគ្រួសារទាំងមូល ដែលទាក់ទងទៅនឹងផ្ទះសម្បែង គួរតែមិនត្រូវបានធ្វើឱ្យមានការផ្លាស់ប្តូរ ឬរងការគំរាមគំហែងទៅលើការទទួលយកបាននូវតម្រូវការ ជាមូលដ្ឋានដទៃទៀតទេ។ ការឧបត្ថមក្នុងការទិញផ្ទះ គួរតែត្រូវបង្កើតឱ្យមានសម្រាប់ជនដែលមិនមានលទ្ធភាពទិញផ្ទះក្នុងតំលៃសមរម្យ ចំណែកអ្នកជួលផ្ទះគេនៅ ក៏គួរតែត្រូវបានគេការពារ ពីការតំលើងថ្លៃឈ្នួលផ្ទះមិនសមហេតុផលផងដែរ។ ផែនការសកម្មភាព គួរតែត្រូវបានបង្កើតឡើង ដោយរួមបញ្ចូលកម្មវិធីចំណាយសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប និងការផ្តល់ប្រាក់ឧបត្ថម្ភទុន សម្រាប់ទិញផ្ទះ ដោយផ្តល់អាទិភាពដល់ជន ដែលងាយរងគ្រោះបំផុត ដូចជាជនពិការ ជនចាស់ជរា ជនជាតិភាគតិច ជនជាតិដើមភាគតិច ជនភៀសខ្លួន និងជនភៀសសឹក។

នៅក្នុងសង្គមជាច្រើន ដែលសម្ភារៈសំខាន់សម្រាប់ការសាងសង់ផ្ទះ មានលក្ខណៈធម្មជាតិ វិធានការនានា គួរត្រូវធ្វើឡើងដោយអាជ្ញាធរ ដើម្បីធានានូវភាពដែលអាចរកបាននូវសម្ភារៈទាំងអស់នោះ។

**ឃ. លំនៅដ្ឋានដែលអាចរស់នៅបាន**

ដើម្បីធ្វើឱ្យមានភាពសមរម្យ លំនៅដ្ឋាន ត្រូវផ្តល់ឱ្យអ្នករស់នៅ នូវទីលំហរគ្រប់គ្រាន់ និងការពារពួកគេ ពីអាកាសធាតុត្រជាក់ សើម ក្តៅ ភ្លៀង ខ្យល់ ឬការគំរាមកំហែងផ្សេងទៀត ចំពោះសុខភាព គ្រោះថ្នាក់ និងជំងឺ។ សុវត្ថិភាពផ្នែករាងកាយរបស់អ្នករស់នៅ ត្រូវបានធានា។

**ង. លំនៅដ្ឋានដែលអាចចេញចូលបាន**

ដើម្បីឱ្យមានភាពសមរម្យ លំនៅដ្ឋាន ត្រូវតែមានភាពអាចទទួលបាន ដោយអ្នកដែលមានសិទ្ធិទទួលបានលំនៅដ្ឋាននោះ។ ក្រុមដែលបាត់បង់ផលប្រយោជន៍ ត្រូវបានគេផ្តល់ឱ្យនូវសិទ្ធិពេញលេញ និងប្រកបដោយនិរន្តរភាព ចំពោះធនធានលំនៅដ្ឋាន។ ស្របជាមួយគ្នានេះ ក្រុមនានា ដូចជាជនចាស់ជរា កុមារ មនុស្សពិការ អ្នកមានជំងឺធ្ងន់ធ្ងរ អ្នកផ្ទុកមេរោគហ៊ីវ បុគ្គលដែលមានបញ្ហាសុខភាពជាប្រចាំ ជនមានជំងឺផ្លូវចិត្ត ជនរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ និងប្រជាជនដែលកំពុងរស់នៅ នៅក្នុងតំបន់ងាយរងគ្រោះ ដោយមហន្តរាយ គួរទទួលបាននូវអាទិភាព ទៅលើលំនៅដ្ឋាន។ ច្បាប់ និងគោលនយោបាយស្តីពីលំនៅដ្ឋាន គួរយកចិត្តទុកដាក់ទៅលើសេចក្តីត្រូវការលំនៅដ្ឋានជាពិសេសរបស់ក្រុមទាំងនេះ និងក្រុមងាយរងគ្រោះផ្សេងទៀត។

**ច. ទីតាំងសមរម្យ**

ដើម្បីឱ្យមានភាពសមរម្យ លំនៅដ្ឋាន ត្រូវមានទីតាំងកន្លែងណាដែលងាយរកការងារធ្វើ សេវាកម្មថែទាំសុខភាព សាលារៀន កន្លែងមើលកូនក្មេង និងសេវាសង្គមកិច្ចផ្សេង

ទៀត។ លំនៅដ្ឋាន មិនគួរត្រូវបានគេសាងសង់នៅលើកន្លែងដែលមានការបំពុល ឬសង់នៅទីជិតទៅនឹងប្រភពពុលនោះទេ ដែលនេះគឺជាការរំលោភទៅលើសិទ្ធិសុខភាពរបស់អ្នករស់នៅក្នុងលំនៅដ្ឋាននោះ។

## ឆ. លំនៅដ្ឋានមានភាពសមរម្យផ្នែកវប្បធម៌

ការសាងសង់លំនៅដ្ឋាន សម្ភារៈសាងសង់ដែលប្រើប្រាស់ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ត្រូវតែរក្សាការពារអត្តសញ្ញាណនិងភាពចំរុះផ្នែកវប្បធម៌។ កត្តាវប្បធម៌នៃលំនៅដ្ឋាន មិនគួរត្រូវគេយកទៅដោះដូរ ដើម្បីធ្វើការសំរបសំរួលការអភិវឌ្ឍន៍លំនៅដ្ឋាន និងគំរោងធ្វើឱ្យទាន់សម័យនានាឡើយ។

សិទ្ធិទូលំទូលាយដែលរៀបរាប់នេះ បានគូសបង្ហាញឱ្យឃើញ នូវភាពស្មុគស្មាញខ្លះដែលមានជាមួយសិទ្ធិមានលំនៅដ្ឋានសមរម្យ ហើយបង្ហាញថា ផ្នែកជាច្រើនដែលរដ្ឋមួយ ត្រូវតែធ្វើការពិចារណាក្នុងការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់របស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ។ ជនទាំងឡាយ គ្រួសារ ផ្ទះសម្បែង ក្រុម និងសហគមន៍នានា ដែលកំពុងរស់នៅក្នុងលក្ខខណ្ឌ ដែលមានលក្ខណៈទាបជាងកម្រិតនៃសិទ្ធិទាំងនេះ អាចធ្វើការទាមទារដោយសមហេតុផលថា ពួកគេមិនបានទទួលសិទ្ធិក្នុងការទទួលបានលំនៅដ្ឋានសមរម្យដូចមានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិនេះទេ។

បន្ថែមលើនេះទៅទៀត វាជាការចាំបាច់ ដើម្បី :

- ធ្វើការធានាថា សិទ្ធិនេះ ត្រូវបានគេការពារអោយរួចផុតពី :
  - ការឈូសបំផ្លាញដោយបំពាន
  - ការបណ្តេញចេញដោយបំពាន និងដោយបង្ខំ
  - ការបំបែក និងផ្លាស់ទីក្រុមជាតិសាសន៍ ឬក្រុមកាន់សាសនា

- ការរើសអើង
- ការបៀតបៀន និងការជ្រៀតជ្រែកស្រដៀងគ្នានោះ

- ចាត់វិធានការជាវិជ្ជមាន ដើម្បីកាត់បន្ថយចំនួនប្រជាជនដែលគ្មានទីជម្រក និង ដើម្បីផ្តល់ឱ្យពួកគេ នូវកន្លែងរស់នៅសមរម្យមួយ ដោយការពារពីអាកាសធាតុ អាក្រក់ និងការគ្រោះថ្នាក់ដល់សុខភាព

- បង្កើតយន្តការតុលាការ ពាក់កណ្តាលតុលាការ រដ្ឋបាល ឬយន្តការអនុវត្ត នយោបាយ ដែលមានលទ្ធភាពក្នុងការផ្តល់នូវសំណងទៅដល់ជនរងគ្រោះទាំងឡាយ ពីការរំលោភបំពាន ដែលត្រូវគេចោទប្រកាន់ទៅលើសិទ្ធិមានលំនៅដ្ឋានសមរម្យ។

**ប្រអប់ ៨១**

**ករណីរបស់ Villa la Dulce៖**
**រាប់ទាំងប្រជាជនដែលត្រូវគេផាត់ចេញពីផែនការលំនៅដ្ឋានសង្គមកិច្ច តាមមធ្យោបាយនៃវិធានការតុលាការ**[៤៣]

នៅខែតុលា ឆ្នាំ២០០០ ក្រុមគ្រួសារមួយចំនួនដែលបានកំពុងរស់នៅក្នុងលំនៅដ្ឋាន ដែលមានលក្ខណៈទ្រុឌទ្រោមបានកាន់កាប់អាគារមួយឈ្មោះថា Villa la Dulce នៅក្នុងទីក្រុង Buenos Aires ដែលត្រូវបានទុកទំនេរច្រើនជាង ១០ឆ្នាំ មកហើយ។ នៅខែកក្កដា ឆ្នាំ២០០១ ចៅក្រមម្នាក់បានបញ្ជាឱ្យមានការបណ្តេញចេញជាបន្ទាន់នូវប្រជាជនចំនួន១៨០នាក់ ដែលកំពុងរស់នៅក្នុងផ្ទះនោះ។ ប្រជាជនទាំងនោះបានគោរពតាមបញ្ជាតុលាការនោះ ក៏ប៉ុន្តែដោយសារតែពួកគេគ្មានកន្លែងណាដែលត្រូវទៅរស់នៅ ពួកគេក៏បានសង់ខ្ទមនៅលើច្រកដើរ និងផ្លូវនានាជុំវិញ

[៤៣] សូមមើល *លំនៅដ្ឋាន និង ច្បាប់ស្តីពីសិទ្ធិ ESC ប្រចាំត្រីមាស* Vol.1 លេខ ១ ទំព័រ ១-៤

អាគារនោះ។ ដោយមានការគាំទ្រពីមន្ត្រីមួយចំនួន ការចរចាជាច្រើនលើកត្រូវបានធ្វើឡើងជាមួយអាជ្ញាធរមូលដ្ឋាន ហើយកិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខា នៅខែវិច្ឆិកា ឆ្នាំ២០០១ ដែលនៅក្នុងកិច្ចព្រមព្រៀងនោះ រដ្ឋាភិបាលនឹងផ្តល់ឱ្យប្រជាជន ដែលត្រូវបណ្តេញចេញទាំងនោះនូវជម្រកក្នុងរយៈពេល ៦០ថ្ងៃ។ ការផ្តល់ជម្រកនេះ មិនបានកើតមានឡើងទេ។

ដោយមានការជួយគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលមួយ ប្រជាជនដែលត្រូវគេបណ្តេញចេញ បានដាក់ពាក្យប្តឹង ដើម្បីទាមទារឱ្យអនុវត្តសិទ្ធិរបស់ពួកគេ ក្នុងការមានលំនៅដ្ឋានសមរម្យ ដែលត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសអាហ្សង់ទីន។ បន្ទាប់ពីមានការចុះពិនិត្យទៅដល់ទីកន្លែង ចៅក្រមដែលបើកសវនាការលើករណីនេះ បានចេញបញ្ជាបណ្តោះអាសន្នមួយឱ្យដាក់ប្រាក់ចំនួន៥០០០០ដុល្លារពីមូលនិធិថវិការបស់ក្រុង សម្រាប់ការសាងសង់លំនៅដ្ឋានសមរម្យ។ ដើម្បីដោះស្រាយបញ្ហាលំនៅដ្ឋាន ដែលមានជាបន្ទាន់ ចៅក្រមរូបនោះក៏បានធ្វើការចរចានូវកិច្ចព្រមព្រៀងតុលាការមួយ ដើម្បីផ្លាស់គ្រួសារទាំងនោះ ទៅកាន់សណ្ឋាគារនានារបស់ក្រុង។ ដោយជំពាក់ទៅនឹងបញ្ហានានាទាក់ទិនការសាងសង់ផ្ទះទាំងនោះ រដ្ឋាភិបាលបានធ្វើការចរចាឡើងវិញជាមួយគ្រួសារ ដែលត្រូវគេបណ្តេញចេញ ហើយកិច្ចព្រមព្រៀងចុងក្រោយមួយ ដែលបញ្ចូលនូវស្តង់ដារអន្តរជាតិ ដែលអាចអនុវត្តបានទៅលើសិទ្ធិមានលំនៅដ្ឋានសមរម្យ ត្រូវបានចុះហត្ថលេខា នៅខែធ្នូ ឆ្នាំ២០០៣។ កិច្ចព្រមព្រៀងនេះបានផ្តល់ឱ្យមានការសាងសង់ផ្ទះចំនួន៩១។ វាបានផ្តល់អត្ថិភាពទៅឱ្យក្រុមហ៊ុនសាងសង់ណា ដែលមានជួលកម្មករជាអ្នកគ្មានផ្ទះនៅ ដែលតំណាងឱ្យ២០ភាគរយយ៉ាងតិចនៃចំនួនបុគ្គលិកសរុបរបស់ខ្លួន ហើយដោយមានការជួលដោយផ្តល់ជា ជំរើសក្នុងការទិញដែលអាចធ្វើទៅបាន ហើយមូលនិធិពិសេសត្រូវបានបង្កើតឡើង ដើម្បីអនុញ្ញាតឱ្យ អ្នកទទួលផលមានកម្មសិទ្ធិទៅលើផ្ទះរបស់ខ្លួន។

ករណីនេះបង្ហាញថា ការប្រើប្រាស់យុទ្ធសាស្ត្រ និងការដាក់ពាក្យប្តឹងតាមផ្លូវតុលាការ ដើម្បីអនុវត្តសិទ្ធិសង្គមកិច្ច ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ អាចជះឥទ្ធិពលទៅលើសេចក្តីសម្រេចគោលនយោបាយនានា។

# សិទ្ធិសុខភាព

មាត្រា២៥(១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលផ្តល់នូវការធានាទៅលើសុខភាព និងសុខុមាលភាព បង្កើតបានជាមូលដ្ឋានសម្រាប់ក្របខ័ណ្ឌច្បាប់អន្តរជាតិធានាដល់សិទ្ធិទទួលបានសេវាសុខាភិបាល។ មាត្រា១២ នៃ CESCR បានបរិយាយបន្ថែមទៅលើសិទ្ធិនេះ ហើយគូសបញ្ជាក់អំពីកាតព្វកិច្ចនានារបស់រដ្ឋ។

យោងទៅតាមអង្គការសុខភាពពិភពលោក(WHO) សុខភាព គឺជា "ស្ថានភាពនៃសុខុមាលភាពពេញលេញផ្នែករាងកាយ ចិត្ត និងសង្គម ហើយមិនគ្រាន់តែជាការគ្មានជំងឺ ឬពិការភាពប៉ុណ្ណោះនោះទេ"។[៤៤] ដូច្នេះហើយ សិទ្ធិសុខភាពគឺជាសិទ្ធិ រួមបញ្ចូលទាំងអស់ដែលមិនគ្រាន់តែទាក់ទិនទៅនឹងសុខភាពផ្នែករាងកាយរបស់បុគ្គលមួយប៉ុណ្ណោះទេ ថែមទាំងពាក់ព័ន្ធទៅលើសិទ្ធិមនុស្សជាច្រើនផ្សេងទៀត និងបញ្ហាសិទ្ធិមនុស្សដទៃទៀតផងដែរ។ នៅឆ្នាំ១៩៩៧ រដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជននានា ដែលបានចូលរួមនៅក្នុងសន្និសីទអន្តរជាតិលើកទី ៤ ស្តីពីការលើកកំពស់សុខភាពបានអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងហ្សាការតាស្តីពីការដឹកនាំឱ្យមានការលើកកំពស់សុខភាព ឆ្ពោះទៅកាន់សតវត្សទី២១។ សេចក្តីថ្លែងការណ៍នេះ ឆ្លុះបញ្ចាំងពីចារិកលក្ខណៈរួមបញ្ចូលគ្នានៃសិទ្ធិសុខភាព ហើយបានកំណត់លក្ខខណ្ឌតម្រូវនានាសម្រាប់គោលនយោបាយដែលមានបំណងឱ្យទទួលបាននូវសិទ្ធិនេះ: "សន្តិភាព ទីជម្រក ការអប់រំ សន្តិសុខសង្គម ទំនាក់ទំនងសង្គម ចំណីអាហារ ចំណូល ការផ្តល់អំណាចទៅឱ្យស្ត្រី ប្រព័ន្ធអេកូប្រកបដោយស្ថិរភាព ការប្រើប្រាស់ធនធានប្រកបដោយចិរភាព យុត្តិធម៌សង្គម ការគោរពសិទ្ធិមនុស្ស និងសមធម៌។ លើសពីនេះទៅទៀត ភាពក្រីក្រ គឺជាការគំរាមកំហែង ដ៏ធំធេងជាងគេទៅលើសុខភាព។"

[៤៤] ធម្មនុញ្ញរបស់អង្គការសុខភាពពិភពលោក គោលការណ៍ ១៩៤៦។

ផ្នែកនេះ មិនបានលើកឡើងពីអត្ថន័យទូលំទូលាយនៃសិទ្ធិសុខភាព និងពីទំនាក់ទំនងរវាងសុខភាព និងសិទ្ធិទទួលបានចំណីអាហារ លំនៅដ្ឋាន និងជីវិតដែលត្រូវបានពិភាក្សានៅផ្នែកផ្សេងនៅក្នុងសៀវភៅនេះ នោះទេ។

## និយមន័យចង្អៀតនៃសិទ្ធិសុខភាព

ដោយផ្តោតអោយចំទៅ គេអាចបំបែកសិទ្ធិសុខភាព ទៅតាមការអនុវត្តរបស់វា ជាបួនផ្នែកដាច់ដោយឡែកពីគ្នា ៖

១. សុខភាពម្តាយ កុមារ និងសុខភាពបន្តពូជ
២. កន្លែងធ្វើការប្រកបដោយសុខភាព និងបរិស្ថានធម្មជាតិ
៣. ការការពារ ការព្យាបាល និងការត្រួតពិនិត្យជំងឺ ដោយរួមបញ្ចូលការអាចរកបាន នូវឱសថសារ័ន្ត និងសេវាកម្មពេទ្យចាំបាច់នានា
៤. សិទ្ធិទទួលបានទឹកផឹកដែលមានសុវត្ថិភាព

ប្រអប់ ៨២

### សុខភាព និងភាពក្រីក្រ

នៅតាមប្រទេសកំពុងអភិវឌ្ឍន៍ និងនៅក្នុងប្រទេសលោកខាងលិចមានការជាប់ទាក់ទងគ្នាមួយត្រូវបានគេប្រកាសឱ្យដឹងរវាងបញ្ហាសុខភាព និងភាពក្រីក្រ។ ប្រជាពលរដ្ឋក្រីក្រ ដែលមានលទ្ធភាពតិចតួច ក្នុងការទទួលបានការថែទាំសុខភាព និងការការពារសង្គមកិច្ច ជាទូទៅមិនសូវមានសុខភាពល្អឆាប់ស្លាប់ ហើយមានអត្រាមរណៈកុមារនិងមាតាខ្ពស់។ នៅពេលជាមួយគ្នានេះ ការមានជំងឺបានធ្វើឱ្យភាពក្រីក្រ កាន់តែធ្ងន់ធ្ងរឡើងតាមរយៈការបាត់បង់ប្រាក់ចំណូល និងការចំណាយទៅលើការថែទាំសុខភាពហើយ បានប្រែក្លាយរង្វង់នៃភាពក្រីក្រផុងចុះកាន់តែជ្រៅ។ ដូច្នេះហើយ ការធ្វើឱ្យសុខភាពកាន់តែប្រសើរឡើងរបស់ជនក្រីក្រគឺមានវត្ថុបំណងនៃការអភិវឌ្ឍន៍ ដែលមានភាពចាំបាច់បំផុត។

នៅក្នុងគោលដៅទី៨នៃការអភិវឌ្ឍន៍សហសវត្ស មានការអំពាវនាវចំនួនបី សម្រាប់ការលើកកំពស់សុខភាពជាក់លាក់ នៅត្រឹមឆ្នាំ២០១៥ : កាត់បន្ថយអត្រាមរណៈកុមារ និងមាតា និងពិនិត្យមើលលើការរីកដាល នៃជំងឺហ៊ីវ/អេដស៍ ជំងឺគ្រុនចាញ់និងជំងឺរបេង។ សុខភាពគឺជាកត្តាគន្លឹះមួយផងដែរទាក់ទិនទៅនឹងគោលដៅទី១ នៃការអភិវឌ្ឍន៍សហសវត្ស (ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន)។

សុខភាពល្អចូលរួមចំណែកទៅលើការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ តាមវិធីច្រើនយ៉ាង។ វាបង្កើនផលិតភាពការងារ ដូច្នោះជំរុញឱ្យមានការវិនិយោគទុនក្នុងស្រុក និងបរទេស បង្កើនធនធានមនុស្ស និងបង្កើនអត្រាសន្សំប្រាក់របស់ជាតិ។ ដូច្នេះហើយ ការវិនិយោគទុនទៅលើវិស័យសុខភាព គឺជាវិធានការដ៏មានចិរភាពមួយ ដែលធានាឱ្យមានអត្ថប្រយោជន៍ខាងក្រៅជាវិជ្ជមានជាច្រើន។

វិធានការផ្សេងៗមួយចំនួន អាចត្រូវបានធ្វើឡើង ដើម្បីធានាថា សិទ្ធិសុខភាពត្រូវបានអនុវត្ត។ ដោយនាំយកមុខនាទីនិងអំណាចរបស់ខ្លួនផ្ទាល់មកប្រើនោះ សភាអាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការនោះ។

និយាយជាទូទៅ ការសម្រេចបាននូវសិទ្ធិសុខភាព មានន័យទៅដល់ការថែទាំសុខភាពបឋមសម្រាប់មនុស្សគ្រប់គ្នា ដោយគ្មានការរើសអើង ទៅដល់យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃសុខភាពសាធារណៈជាតិ និងការបង្កើតឡើងនូវសូចនាករ យន្តការសម្រាប់វាស់វែង និងយន្តការត្រួតពិនិត្យតាមដានសុខភាពថ្នាក់ជាតិ។

យន្តការធានារ៉ាប់រងសុខភាព និងកម្មវិធីអប់រំអំពីបញ្ហា និងការការពារសុខភាពគឺជាការសំខាន់ ហើយសមាជិកសភា គួរធ្វើការធានាថា មានមូលនិធិគ្រប់គ្រាន់សម្រាប់កិច្ចប្រឹងប្រែងទាំងនោះ និងសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងសុខភាព។

## *ក្រុមនានា ដែលត្រូវការការយកចិត្តទុកដាក់ជាពិសេស*

បញ្ហាសុខភាពនានាដែលមានជាក់លាក់ទៅនឹងក្រុមណាមួយ ដូចជា ជនដែលអសមត្ថភាពផ្នែករាងកាយនិងផ្លូវចិត្ត ជនក្រីក្រ ស្ត្រី កុមារ និងអ្នកកំពុងមានផ្ទុកជំងឺហ៊ីវ/អេដស៍ ទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស។ គោលនយោបាយ ដែលមានទិសដៅច្បាស់លាស់ និងថវិកាផ្នែកសុខភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅតាមសេចក្តីត្រូវការនៃក្រុមទាំងនេះ គឺជាការចាំបាច់។

ទាក់ទិនជាមួយជនក្រីក្រ បញ្ហាសុខភាពជាគន្លឹះនានា រួមមាន ការលើកកំពស់ ការទទួលបានសេវាសុខាភិបាល ការដាក់ចេញនូវកម្មវិធីចាក់វ៉ាក់សាំងបានសមរម្យ និងការអនុវត្តទៅលើវិធានការបរិស្ថានជាមូលដ្ឋាននានា (ជាពិសេស បញ្ហាការបោះចោលកាកសំណល់)។ សមាជិកសភាអាចជាធនធានដ៏សំខាន់ជាទីបំផុត ក្នុងការតាក់តែងច្បាប់ពាក់ព័ន្ធនានា ដោយធ្វើការធានានូវការអនុវត្តច្បាប់ទាំងនោះ និងលើកកំពស់ការយល់ដឹងជាសាធារណៈ អំពីស្ថានភាពរបស់អ្នកក្រីក្រ។

ការទទួលបានសេវាសុខភាព ការថែទាំផ្នែកពេទ្យ និងសេវាកម្មពន្យាកំណើតរបស់ ស្ត្រី ទាមទារឱ្យមានការយកចិត្តទុកដាក់។ សមាជិកសភា គួរធានាឱ្យមានការអនុម័តច្បាប់ដែលហាមឃាត់ និងបំបាត់ចោលការកាត់សន្ទះព្រហ្មចារីរបស់ក្មេងស្រី។[៤៥]

---

[៤៥] នៅខែកញ្ញា ឆ្នាំ២០០១ IPU បានបើកយុទ្ធនាការសភាមួយដើម្បីបញ្ឈប់អំពើហឹង្សាប្រឆាំងស្ត្រី ដោយផ្តោតទៅលើការលុបបំបាត់នូវ FGM។ ព័ត៌មានបន្ថែមអាចរកបានពី http://www.ipu.org/wmn-e/fgm.htm

ច្បាប់នានាដែលធានាឱ្យមានការផ្តល់ទៅឱ្យកុមារទាំងអស់នូវជំនួយផ្នែកពេទ្យ និងការថែទាំសុខភាពដែលចាំបាច់នានា គួរត្រូវបានអនុម័ត និងអនុវត្ត។ វាជាការសំខាន់ ដើម្បីដាក់ចុះនូវកម្មវិធីនានាដែលរៀបចំឡើង ដើម្បីកាត់បន្ថយអត្រាមរណៈទារក និងកុមារ និងដើម្បីរៀបចំផលិតកម្មវិធីព័ត៌មានស្តីពីសុខភាព និងចំណីអាហាររបស់កុមារ អត្ថប្រយោជន៍នៃការចិញ្ចឹមកូនដោយទឹកដោះ សារៈសំខាន់នៃអនាម័យ និងបរិស្ថានល្អស្អាត និងការការពារកុំឱ្យមានគ្រោះថ្នាក់។

កុមារពិការ គួរមានលទ្ធភាព និងទទួលបានការអប់រំ ការបណ្តុះបណ្តាល និងសេវាថែទាំសុខភាព ហើយគួរទទួលអត្ថប្រយោជន៍ពីសេវាយុវនីតិសម្បទា ការរៀបចំខ្លួនសម្រាប់ការងារ និងកាលានុវត្តភាព ទទួលភាពសប្បាយរីករាយ ក្នុងបំណង ដើម្បីធានាឱ្យមានការបញ្ចូលទៅក្នុងសង្គម និងការអភិវឌ្ឍន៍ផ្ទាល់ខ្លួនជាអតិបរមា។

ចុងក្រោយ គឺបុគ្គលទាំងឡាយដែលកំពុងមានផ្ទុកជំងឺហ៊ីវ/អេដស៍ ដែលនៅខែធ្នូ ឆ្នាំ២០០៤ មានចំនួនជិតទៅដល់ ៤០លាននាក់[៤៦] នៅទូទាំងពិភពលោក គួរត្រូវបានគេការពារប្រឆាំងទៅនឹងការរើសអើងគ្រប់ទម្រង់ទាំងអស់។ ការចំណាយលើការពិនិត្យពេទ្យរបស់ពួកគេ គួរត្រូវបានគេចេញឱ្យ ហើយថ្នាំគួរត្រូវបានផ្តល់ទៅឱ្យពួកគេ ដោយផ្អែកលើមូលដ្ឋានទៀងទាត់។[៤៧]

---

[៤៦] បណ្ឌិត Peter Piot នាយកប្រតិបត្តិនៃ UNAIDS. សារផ្ញើរជូនទិវាជំងឺអេដស៍ពិភពលោក ថ្ងៃទី១ ខែធ្នូ ឆ្នាំ ២០០៤។

[៤៧] សំរាប់ព័ត៌មានបន្ថែមលើប្រធានបទនេះ សូមមើលសៀវភៅសំរាប់សមាជិកសភា អំពីជំងឺហ៊ីវ/អេដស៍ ច្បាប់ និង សិទ្ធិមនុស្ស UNAIDS/IPU ទីក្រុងហ្សឺណែវ ឆ្នាំ១៩៩៩។

## សិទ្ធិទទួលបានទឹក

បន្ថែមលើសិទ្ធិទទួលបានចំណីអាហារ លំនៅដ្ឋាន និងសំលៀកបំពាក់ (ដែលមានចែងយ៉ាងច្បាស់ក្នុងមាត្រា២៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១១ នៃ CESCR) សិទ្ធិមានកិរិតជីវភាពរស់នៅសមរម្យ អាចនាំឱ្យមានសេចក្តីត្រូវការជាមូលដ្ឋានផ្សេងទៀត។ សេចក្តីពន្យល់ទូទៅលេខ១៥ របស់គណៈកម្មាធិការ CESCR ដែលបានអនុម័តនៅខែវិច្ឆិកា ឆ្នាំ២០០២ បានកំណត់ "សិទ្ធិមនុស្សក្នុងការទទួលបានទឹក" ថាជាផ្នែកមួយដ៏សំខាន់នៃចង្កោមសិទ្ធិទាំងមូល ដោយបានថ្លែងថា សិទ្ធិទទួលបានទឹក "ស្ថិតនៅក្នុងរង្វង់នៃការធានាដែលចាំបាច់ សម្រាប់ធ្វើឱ្យមានកិរិតជីវភាព រស់នៅសមរម្យ ជាពិសេស ដោយសារវាជាលក្ខខណ្ឌមូលដ្ឋានមួយ ដ៏សំខាន់បំផុត ក្នុងចំណោមលក្ខខណ្ឌមូលដ្ឋានជាច្រើនសម្រាប់ការរស់រានមានជីវិត"។ សិទ្ធិទទួលបានទឹក ត្រូវបានលើកមកនិយាយផងដែរ នៅក្នុងមាត្រា១៤(២) នៃ CEDAW និង មាត្រា២៤(២) នៃ CRC ។

### *តើអ្វីទៅជាសិទ្ធិទទួលបានទឹក?*

សិទ្ធិទទួលបានទឹក ផ្តល់ទៅដល់គ្រប់មនុស្សទាំងអស់នូវទឹកគ្រប់គ្រាន់ មានសុវត្ថិភាព អាចទទួលយកបាន អាចទៅរកបាន និងអាចមានលទ្ធភាពទិញបាន សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននិងនៅក្នុងផ្ទះ។ សិទ្ធិទទួលបានទឹកមានសារៈសំខាន់ណាស់សម្រាប់ការសម្រេចបាននូវសិទ្ធិផ្សេងទៀត ដូចជាសិទ្ធិរស់រានមានជីវិត សុខភាពនិងចំណីអាហារ។ ទោះបីជាថាអ្វីដែលបង្កើតបានជាភាពគ្រប់គ្រាន់នៃទឹក មានការប្រែប្រួលទៅតាមលក្ខខណ្ឌជាច្រើនក៏ដោយ ក៏កត្តាខាងក្រោម អនុវត្តនៅគ្រប់កាលៈទេសៈទាំងអស់ :

**ភាពអាចរកបាន** : ការផ្គត់ផ្គង់ទឹកដោយទៀងទាត់ ត្រូវតែធ្វើឱ្យបានដល់ជនគ្រប់រូបក្នុងចំនួនមួយគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងការប្រើប្រាស់ក្នុងផ្ទះ។ ការប្រើប្រាស់ទាំងនេះ ជាធម្មតា រួមមាន បរិភោគ អនាម័យផ្ទាល់ខ្លួន បោកគក់សំលៀកបំពាក់

ការរៀបចំចំណីអាហារ អនាម័យ និងភាពស្អាតបាតរបស់គ្រួសារ ។ ចំណុះទឹក ដែលមានសម្រាប់បុគ្គលម្នាក់ៗ គួរធ្វើទៅតាមគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក ។ បុគ្គល និងក្រុមខ្លះអាចត្រូវការទឹកបន្ថែមលើសនេះទៅទៀត ដោយសារតែលក្ខខណ្ឌសុខភាព អាកាសធាតុ និងការងារជាក់លាក់ណាមួយ ។

**គុណភាព :** ទឹកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងការប្រើប្រាស់ក្នុងផ្ទះ ត្រូវតែមានសុវត្ថិភាព ដូចជា គ្មានអតិសុខុមប្រាណ សារធាតុគីមី និងវិទ្យុសកម្ម ដែលគ្រោះថ្នាក់យ៉ាងអាក្រក់ដល់សុខភាព ។ ពណ៌ ក្លិន និងរសជាតិរបស់ទឹក គួរមានភាពសមស្របសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងការប្រើប្រាស់ក្នុងផ្ទះ ។

**ភាពអាចទទួលបាន :** ទឹក និងសំភារៈ និងសេវាកម្មទឹក ត្រូវតែផ្តល់ទៅឱ្យជនគ្រប់គ្នាទាំងអស់ ដែលកំពុងរស់នៅក្នុងដែនដីរបស់រដ្ឋ ដោយគ្មានការរើសអើងឡើយ ។ ភាពអាចទៅរកបាន មានកត្តាចំនួនបួនដែលជាន់ត្រួតគ្នា :

**ការចូលទៅដល់ទីកន្លែងមានទឹក :** សម្រាប់ក្រុមប្រជាជនទាំងអស់ ទឹក និងសំភារៈ និងសេវាកម្មទឹកគ្រប់គ្រាន់ ត្រូវតែស្ថិតនៅក្នុងចម្ងាយមួយ ដែលអាចទៅរកបានដោយសុវត្ថិភាព ។ មានទឹកគ្រប់គ្រាន់ សុវត្ថិភាព និងអាចទទួលយកបាន ត្រូវតែផ្តល់ទៅឱ្យគ្រប់គ្រួសារ ស្ថាប័នអប់រំ អាគារថែទាំសុខភាព និងកន្លែងធ្វើការ ឬកន្លែងនៅជិតនោះ ។ គុណភាពរបស់សំភារៈ និងសេវាកម្មទឹកទាំងអស់ ត្រូវតែមានលក្ខណៈល្អគ្រប់គ្រាន់ និងសមរម្យផ្នែកវប្បធម៌ ហើយត្រូវតែឆ្លើយតបទៅនឹងលក្ខខណ្ឌយេនឌ័រ វដ្តសង្សារ និងភាពឯកជននានា ។ សន្តិសុខរូបកាយរបស់ជន ដែលទទួលបានការប្រើប្រាស់ និងសេវាកម្មទឹក ត្រូវតែបានធានា ។

**ការទទួលបានផ្នែកសេដ្ឋកិច្ច :** ទឹក និងសំភារៈ និងសេវាកម្មទឹក ត្រូវតែមានលក្ខណៈដែលអាចការទិញបានជាទូទៅ ។ តំលៃ និងការបង់កំរៃដោយផ្ទាល់ និងប្រយោល

ដែលមានជាប់ទៅនឹងការទទួលបានទឹកសុវត្ថិភាព ត្រូវតែមានចំនួនសមហេតុផល និងមិនកែប្រែ ឬគំរាមកំហែងទៅលើការទទួលបាននូវសិទ្ធិផ្សេងៗទៀត ដែលត្រូវបានធានាក្រោម CESCR ។

**ការទទួលបានដោយមិនរើសអើង** : តាមច្បាប់ និងតាមការអនុវត្តជាក់ស្តែង ទឹកនិងសំភារៈ និងសេវាកម្មទឹក ត្រូវតែផ្តល់ទៅដល់គ្រប់គ្នា ដោយរួមទាំង ក្រុមប្រជាជនដែលងាយរងគ្រោះបំផុត និងដែលត្រូវបានគេផាត់ចេញ ដោយគ្មាន ការរើសអើងផ្អែកលើមូលដ្ឋានណាមួយឡើយ ។

**ការទទួលបានព័ត៌មាន** : ការទទួលបាននេះ រួមបញ្ចូលនូវសិទ្ធិក្នុងការរកទទួល និងផ្សព្វផ្សាយព័ត៌មានទាំងឡាយ ដែលទាក់ទិនទៅនឹងបញ្ហាទឹក ។

ប្រអប់ ៨៣

### ទឹក និងសិទ្ធិក្នុងការរស់រានមានជីវិត

- រៀងរាល់ឆ្នាំ ប្រជាជនចំនួន ២.២ លាននាក់ ស្លាប់ដោយសារជំងឺរាគរូស
- មនុស្សជាច្រើនលាននាក់ថែមទៀតទទួលរងនូវការបាត់បង់ខាងចំណីអាហារ ការអប់រំ និងសេដ្ឋកិច្ច តាមរយៈជំងឺរាគរូស ដែលអាចបង្ការបានតាមរយៈការធ្វើឱ្យប្រសើឡើងក្នុងការផ្គត់ផ្គង់ទឹក និងអនាម័យ
- ប្រជាជនចំនួនជិត ៣.៤លាននាក់ ស្លាប់រៀងរាល់ឆ្នាំ ពីជំងឺនានា ដែលពាក់ព័ន្ធនឹងទឹក
- នៅពេលណាមួយ ប្រជាជនចំនួន ១.៥កោដ មានប្រជាជនម្នាក់ក្នុងចំណោមបួននាក់នៅក្នុងពិភពលោក រងនូវការឆ្លងដង្កូវបារ៉ាស៊ីត ដែលកើតចេញពីកាកសំណល់របស់មនុស្ស និងកាកសំណល់រឹងនៅក្នុងបរិស្ថាន ។[៤៨]

[៤៨] ការវាយតំលៃពីការផ្គត់ផ្គង់ទឹក និងអនាម័យពិភពលោក របាយការណ៍ឆ្នាំ២០០០ សេចក្តីសង្ខេបរបាយការណ៍

ប្រអប់ ៨៤

## ប្រភេទនៃការរំលោភបំពាននានាទៅលើសិទ្ធិទទួលបានទឹក

**ការរំលោភបំពាននានាទៅលើកាតព្វកិច្ច ក្នុងការគោរពសិទ្ធិទទួលបានទឹក :**

- ការកាត់ផ្តាច់ឬការដាក់ឱ្យនៅក្រៅពីសេវាកម្ម ឬការប្រើប្រាស់ទឹកដោយបំពាន និងមិនមានការបញ្ជាក់ហេតុផលត្រឹមត្រូវ
- ការបង្កើនតំលៃទឹក ដោយមានភាពរើសអើង ឬមានតំលៃថ្លៃពេក
- ការបំពុល និងការកាត់បន្ថយប្រភពធនធានទឹក ដោយធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់មនុស្ស

**ការរំលោភបំពាននានាទៅលើកាតព្វកិច្ច ក្នុងការការពារសិទ្ធិទទួលបានទឹក**

- ខកខានមិនបានអនុម័ត និងអនុវត្តច្បាប់នានា ដើម្បីទប់ស្កាត់ការបំពុល និងការទាញយកទឹកដោយអសមភាពរបស់វា
- ខកខានក្នុងការដាក់ឱ្យនៅក្រោមការគ្រប់គ្រងដ៏មានប្រសិទ្ធភាព និងខកខានធ្វើការត្រួតពិនិត្យទៅលើអ្នកផ្តល់សេវាទឹករបស់ឯកជន
- ខកខានក្នុងការការពារប្រព័ន្ធបែងចែកទឹក (ឧ. បណ្តាញបំពង់ទុយោ និងអណ្តូង) ពីការជ្រៀតជ្រែក ការធ្វើឱ្យខូចខាត និងការបំផ្លិចបំផ្លាញ

**ការរំលោភបំពាននានាទៅលើកាតព្វកិច្ច ក្នុងការបំពេញសិទ្ធិទទួលបានទឹក**

- ខកខានក្នុងការអនុម័ត ឬអនុវត្តទៅលើគោលនយោបាយជាតិ សម្រាប់គ្រប់គ្រងទឹក ដែលត្រូវបានរៀបចំឡើង ដើម្បីធានាសិទ្ធិទទួលបានទឹក សម្រាប់មនុស្សគ្រប់រូប
- ការចំណាយមិនគ្រប់គ្រាន់ ឬការបែកចែកធនធានសាធារណៈ នាំឱ្យមានការមិនអាចសម្រេចបាននូវសិទ្ធិទទួលបានទឹក ដោយបុគ្គល និងក្រុមជនទាំងឡាយ ជាពិសេសក្រុមដែលងាយរងគ្រោះ និងក្រុមដែលត្រូវបានគេផាត់ចេញ ។
- ខកខានក្នុងការធ្វើការពិនិត្យតាមដាន នូវការទទួលបានសិទ្ធិទទួលបានទឹកនៅថ្នាក់ជាតិក្នុងចំណោមនោះ ដោយប្រើប្រាស់សូចនាករ និងស្តង់ដារសម្រាប់វាស់ទៅលើសិទ្ធិទទួលបានទឹក

- ខកខានក្នុងការចាត់វិធានការនានា ដើម្បីកាត់បន្ថយការបែងចែកសម្បទា និងសេវាកម្មទឹក ដោយមិនស្មើភាពគ្នា
- ខកខានក្នុងការអនុម័តយន្តការនានា សម្រាប់ការជួយសង្គ្រោះបន្ទាន់
- ខកខានក្នុងការធានាថា មនុស្សគ្រប់រូបទទួលបានសិទ្ធិនេះ នៅកម្រិតអប្បបរមាដែលចាំបាច់
- ការខកខានរបស់រដ្ឋ ក្នុងការយកចិត្តទុកដាក់ទៅលើកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ ទាក់ទិន ទៅនឹងសិទ្ធិទទួលបានទឹក នៅពេលចុះកិច្ចព្រមព្រៀងជាមួយរដ្ឋដទៃ ឬជាមួយអង្គការអន្តរជាតិនានា។

## ***តើសកម្មភាពអ្វីខ្លះ អាចចូលរួមចំណែក ក្នុងការធានានូវការទទួលបានសិទ្ធិទទួលបានទឹក?***

ទីមួយ រដ្ឋាភិបាលទាំងឡាយគួរផ្តល់ឱ្យមានទឹក ដែលអាចមានគុណភាពសមរម្យ និងអាចទទួលយកបាន ដូចដែលគូសបញ្ជាក់ខាងលើ។ ការអនុវត្តជាបណ្តើរៗ នូវវិធានការទាំងនោះ ដូចបានរៀបរាប់ខាងលើ វាអាចនឹងឈានទៅរកការសម្រេចបានយ៉ាងពេញលេញ នូវសិទ្ធិទទួលបានទឹក។ សភាអាចធ្វើការតាមដានពិនិត្យមើល និងពង្រឹងវិធានការជាក់លាក់របស់រដ្ឋាភិបាល ដូចខាងក្រោម ៖

- ប្រសិនបើមានភាពចាំបាច់ រដ្ឋាភិបាលគួរអនុម័តយុទ្ធសាស្ត្រនិងផែនការសកម្មភាពទៅលើទឹកថ្នាក់ជាតិ ដើម្បីធានាឱ្យមានប្រព័ន្ធផ្គង់ផ្គង់ និងគ្រប់គ្រងទឹកមួយ ដែលផ្តល់ឱ្យប្រជាជនទាំងអស់ នូវទឹកស្អាត និងមានសុវត្ថិភាព ក្នុងបរិមាណគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងនៅក្នុងផ្ទះ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនោះ គួររួមបញ្ចូលនូវឧបករណ៍នានា ដូចជា សូចនាករ និងស្តង់ដារសម្រាប់វាស់វែងទៅលើសិទ្ធិទទួលបានទឹកសម្រាប់តាមដានពិនិត្យ ការវិវត្តឱ្យបានជិតដល់ ហើយគួរកំណត់ទិសដៅជាពិសេស

ទៅដល់ក្រុមនានា ដែលពុំទទួលបានប្រយោជន៍ និងក្រុមដែលគេផាត់ចេញពីសង្គម ។

- រដ្ឋាភិបាល គួរចាត់វិធានការនានាប្រកបដោយប្រសិទ្ធភាព ដើម្បីការពារកុំឱ្យភាគីទីបីដោយរួមទាំង សាជីវកម្មឆ្លងប្រទេស កុំឱ្យបង្កើតឧបសគ្គចំពោះការទទួលបាន ដោយស្មើភាពគ្នា ទៅលើទឹកស្អាត និងការពារកុំឱ្យមានការបំពុល និងចូលរួមទៅក្នុងទំលាប់នៃការទាញយកទឹក ដោយហួសពីសមត្ថភាពរបស់វា
- រដ្ឋាភិបាល គួរចាត់វិធានការនានា ដើម្បីទប់ស្កាត់ ពិនិត្យមើល និងត្រួតមើលទៅលើជំងឺនានា ដែលពាក់ព័ន្ធនឹងទឹក ហើយជាពិសេស ធានាការទទួលបានអនាម័យគ្រប់គ្រាន់ ។

## សិទ្ធិទទួលបានការអប់រំ

មាត្រា២៦(១) នៃ UDHR

*"មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ ។ ការអប់រំ ត្រូវតែឥតបង់ថ្លៃ យ៉ាងហោចណាស់ សម្រាប់ការអប់រំបឋម និងការអប់រំមូលដ្ឋាន ។ ការអប់រំបឋមសិក្សា គឺជាកាតព្វកិច្ច ។ ការអប់រំខាងបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ ។ ការអប់រំថ្នាក់ឧត្តមសិក្សា ត្រូវបើកឱ្យចូលរៀនស្មើភាពគ្នា ដោយឈរលើមូលដ្ឋានសមត្ថភាព ។*

មាត្រា១៣ នៃ CESCR

*រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិបុគ្គលគ្រប់រូប ដើម្បីទទួលបានការអប់រំ ។*

*(....)*

*រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា ដើម្បីសម្រេចបានការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ ៖*

(ក) ការអប់រំកម្រិតបឋមសិក្សា ត្រូវតែជាកាតព្វកិច្ច ហើយឥតគិតថ្លៃសម្រាប់ទាំងអស់គ្នា ។

(ខ) ការអប់រំកម្រិតមធ្យមសិក្សាតាមទ្រង់ទ្រាយផ្សេងៗ រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យម ត្រូវតែបើក ឱ្យមានជាទូទៅ និងឱ្យមនុស្សគ្រប់គ្នាអាចចូលរៀនបាន តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យ មានជាលំដាប់នូវការសិក្សាដោយឥតបង់ថ្លៃ ។

(គ) ការអប់រំកម្រិតឧត្តមសិក្សា ត្រូវតែបើកចំហដល់មនុស្សគ្រប់រូបដោយស្មើភាព តាមសមត្ថភាពរបស់មនុស្សម្នាក់ៗ តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យមានជាលំដាប់នូវការសិក្សា ដោយឥតបង់ថ្លៃ ។

(ឃ) ការអប់រំមូលដ្ឋាន ត្រូវតែជំរុញ ឬពង្រឹងតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន សម្រាប់អ្នកដែលមិនបានទទួល ឬមិនបានបញ្ចប់កម្រិតបឋមសិក្សារបស់ខ្លួន ។

(ង) ត្រូវតែបន្តយ៉ាងសកម្ម លើការអភិវឌ្ឍន៍បណ្តាញសិក្សាធិការគ្រប់លំដាប់ បង្កើតប្រព័ន្ធអាហារូបករណ៍ឱ្យបានគ្រប់គ្រាន់ និងបង្កើនជាលំដាប់នូវលក្ខខណ្ឌសម្ភារៈរបស់បុគ្គលិកសិក្សា ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់មាតាបិតា និងអាណាព្យាបាលស្របច្បាប់ បើសមស្រប ដើម្បីជ្រើសរើសសាលារៀន ក្រៅពីសាលារៀនសាធារណៈ ឱ្យកូនរបស់ខ្លួន ប៉ុន្តែត្រូវស្របតាមវិធានអប្បបរមាដែលរដ្ឋអាចកំណត់ ឬអនុម័ត ក្នុងវិស័យអប់រំ និងរ៉ាប់រងការអប់រំសាសនា និងសីលធម៌របស់កូន ស្របតាមជំនឿផ្ទាល់របស់ពួកគេ

៤. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ត្រូវយកមកបកស្រាយថាប៉ះពាល់ដល់សេរីភាពនៃរូបវ័ន្តបុគ្គល និងនីតិបុគ្គល ក្នុងការបង្កើត និងដឹកនាំគ្រឹះស្ថានសិក្សា លើកលែងតែគោលការណ៍ដែលបានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវបានគោរព និងឱ្យតែការ

*អប់រំដែលផ្តល់ឱ្យនៅក្នុងគ្រឹះស្ថានទាំងនោះ ស្របទៅនឹងបទដ្ឋានអប្បបរមា ដែលអាចកំណត់ដោយរដ្ឋ ។*

មាត្រា១៤ នៃ CESCR

*" នៅពេលក្លាយជាភាគីនៃកតិកាសញ្ញានេះ រដ្ឋភាគីដែលមិនទាន់អាចធានាការអប់រំកម្រិតបឋម ជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃ នៅក្នុងដែនដីចំណុះនៃប្រទេសខ្លួន ឬដែនដីដែលស្ថិតនៅក្រោម ដែនសមត្ថកិច្ចរបស់ខ្លួន សន្យាបង្កើត និងអនុម័តក្នុងរយៈពេល ២ឆ្នាំ នូវផែនការលំអិតនៃវិធាន ការចាំបាច់ ដើម្បីធ្វើឱ្យបានសម្រេចជាលំដាប់ តាមចំនួនឆ្នាំសមរម្យដែលកំណត់ក្នុងផែនការនេះ នូវការអនុវត្តពេញលេញនៃគោលការណ៍អប់រំកម្រិតបឋមជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃសម្រាប់ទាំងអស់គ្នា ។ "*

បន្ថែមទៅលើការចែង និងគូសបញ្ជាក់នៅក្នុងច្បាប់អន្តរជាតិ និងសន្ធិសញ្ញាសំខាន់ៗ ដែលបានបង្ហាញខាងលើ សិទ្ធិទទួលបានការអប់រំ ក៏ត្រូវបានគេលើកឡើងផងដែរនៅក្នុងមាត្រា២៨ និង២៩ នៃ CRC និងនៅក្នុងគោលដៅទី២ និងទី៣នៃការអភិវឌ្ឍន៏សហសវត្ស ដែលបានដាក់ចេញនូវស្តង់ដារ និងគោលបំណងសំខាន់ៗ ទាក់ទិនទៅនឹងការទទួលបានសិទ្ធិនេះ។ សិទ្ធិនេះ ត្រូវបានផ្សារភ្ជាប់ ដោយមិនអាចកាត់ផ្តាច់បាន ទៅនឹងសេចក្តីថ្លៃថ្នូរបស់មនុស្ស និងការសម្រេចបាននូវសិទ្ធិនេះ គឺមានសារៈសំខាន់ណាស់ ចំពោះការអភិវឌ្ឍន៏របស់បុគ្គលម្នាក់ៗ និងរបស់សង្គមទាំងមូល។ សិទ្ធិទទួលបានការអប់រំ ផ្តល់អំណាចទៅដល់ប្រជាជន ដែលត្រូវបានគេផាត់ចេញផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច ហើយវាមានសារៈសំខាន់ណាស់នៅក្នុងការ *ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ* វាការពារកុមារពីការកេងប្រវ័ញ្ច និងវាមានឥទ្ធិពលធ្វើការកំណត់ទៅលើការកើនឡើងនូវចំនួនប្រជាជន។ ដូច្នេះហើយ សិទ្ធិនេះគឺជាគន្លឹះក្នុងការសម្រេចបាននូវសិទ្ធិមនុស្សជាច្រើនផ្សេងទៀត។

*“ ដូច្នេះ ស្ថានភាពប្រជាធិបតេយ្យដែលមានចិរភាពមួយ តម្រូវឱ្យមានបរិយាកាស និងវប្បធម៌ប្រជាធិបតេយ្យដែលត្រូវបានបណ្ដុះឡើង និងពង្រឹងជាបន្តបន្ទាប់ ដោយការអប់រំ និងមធ្យោបាយនៃវប្បធម៌ និងព័ត៌មានផ្សេងទៀត ។ ដូច្នេះ សង្គមប្រជាធិបតេយ្យមួយ ត្រូវតែមានការប្ដេជ្ញាខ្ពស់ទៅលើការអប់រំ ឱ្យបានទូលំទូលាយជាទីបំផុត ហើយជាពិសេសទៅទៀតនោះ គឺការអបរំទៅលើប្រជាពលរដ្ឋ និងការតម្រង់ទិស ដើម្បីសម្រេចបាននូវប្រជាជនដែលប្រកបដោយទំនួលខុសត្រូវមួយ ។ ”*

*សហជីពអន្តរសភា សេចក្ដីប្រកាសជាសាកលស្ដីពីប្រជាធិបតេយ្យ*
*ទីក្រុងគែរ ខែសីហា ឆ្នាំ១៩៩៧ ឃ្លាប្រយោគ១៩*

បញ្ញត្តិខាងលើនៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និង CESCR បានចែងនូវគោលបំណងយ៉ាងច្បាស់លាស់ថា រដ្ឋជាភាគីទាំងឡាយ គួរមានបំណង ដើម្បីធ្វើការឆ្លើយតបទៅនឹងខបញ្ញត្តិទាំងនេះ ដើម្បីធានានូវការទទួលបានសិទ្ធិមនុស្សក្នុងការទទួលបានការអប់រំ ។ ក៏ប៉ុន្តែ អ្វីទៅដែលជាការពាក់ព័ន្ធនានា ដែលអាចអនុវត្តបានពិតប្រាកដ ទៅលើបញ្ញត្តិទាំងនោះសម្រាប់រដ្ឋ និងជាពិសេសសម្រាប់សភា? ដើម្បីផ្ដល់ជាចំលើយ សិទ្ធិទទួលបានការអប់រំអាចត្រូវបានបំបែកចេញទៅជាពីរផ្នែក ដូចតទៅ:

១. ការលើកកំពស់ឱ្យមានការទទួលបានការអប់រំ

២ . សេរីភាពក្នុងការជ្រើសរើសប្រភេទ និងខ្លឹមសារនៃការអប់រំ

ប្រអប់ ៨៥

## ភាពក្រីក្រ និងការអប់រំ [៤៩]

នៅទូទាំងពិភពលោក កុមារចំនួន១១៣លាននាក់មិនបានចូលរៀន ដែលពីរភាគបីនៃចំនួននេះជាក្មេងស្រី។ បន្ថែមលើនេះ ការបង្កើនគុណភាពអប់រំ ការពង្រីកការអប់រំជាមូលដ្ឋានឆ្ពោះទៅទិសដៅអប់រំបឋមជាសកលកម្រិតអន្តរជាតិ និងការកាត់បន្ថយភាពលំអៀងក្នុងការទទួលបាន និងវិសាលភាព បង្ហាញនូវការលំបាកយ៉ាងខ្លាំង។ មានកិច្ចព្រមព្រៀងអន្តរជាតិយូរអង្វែងមួយ ដែលថាការអប់រំបឋម គួរមានលក្ខណៈជាសកល នៅដើមសតវត្សទី២១។ គំលាតជាច្រើននៃវត្តមានការចូលរៀន និងការរក្សាឱ្យកុមារនៅរៀន ស្ថិតទៅតាមទ្រព្យសម្បត្តិ ដែលបានបង្ហាញថា អ្នកក្រីក្រគឺស្ថិតនៅឆ្ងាយណាស់ ពីការសម្រេចឱ្យបាននូវគោលបំណងនេះ ជាងអ្នកផ្សេងៗទៀត។ ក៏ប៉ុន្តែហេតុអ្វីបានជាអត្រាចុះឈ្មោះចូលរៀនទាប និងលទ្ធផលនៃការអប់រំមានគុណភាពអន់ក្នុងចំណោមអ្នកក្រ?

### ការផ្គត់ផ្គង់

ទីមួយ វាជាការលំបាកសម្រាប់កុមារក្រីក្រ ដើម្បីទៅកាន់សាលារៀន។ សាលារៀនទំនងជាប្រមូលផ្តុំគ្នានៅតាមទីក្រុង និងតំបន់ដែលមានអ្នកមានរស់នៅច្រើន។ នៅប្រទេសគីនី (Guinea) ជាឧទាហរណ៍ ពេលវេលាធ្វើដំណើរជាមធ្យមទៅកាន់សាលារៀនបឋមសិក្សាដែលនៅជិតបំផុត គឺមានចំនួន ៤៧ នាទី នៅតាមតំបន់ជនបទ និងមានតែ ១៩នាទីប៉ុណ្ណោះនៅតំបន់ប្រជុំជននានា។

ទោះជាយ៉ាងណាក៏ដោយ នៅតាមប្រទេសជាច្រើន ការទៅកាន់សាលារៀនមិនមែនជាបញ្ហាស្នូលទេ។ ការចំណាយលើការអប់រំ មានការកើនឡើងនៅតាមប្រទេសជាច្រើនក្នុងអំឡុង

[៤៩] ទិន្នន័យផ្អែកលើ "ប្រជាជន ភាពក្រីក្រ និងលទ្ធភាព" ស្ថានភាពនៃប្រជាជនពិភពលោក ឆ្នាំ២០០២. មូលនិធិសហប្រជាជាតិសំរាប់ប្រជាជន។

ប៉ុន្មានទសវត្សកន្លងមកនេះ ក៏ប៉ុន្តែកំណើនទៅលើការចំណាយដែលធ្វើឡើងមិនព្រមគ្នាជាមួយនឹងការយកចិត្តទុកដាក់ជាពិសេសទៅលើសេចក្តីត្រូវការរបស់អ្នកក្រ អាចធ្វើឱ្យភាពខុសគ្នាដែលពាក់ព័ន្ធជាមួយទ្រព្យសម្បត្តិ មានកាន់តែខ្លាំងឡើងទៅវិញ ជាជាងធ្វើការកាត់បន្ថយ។

ភស្តុតាងពីប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានបង្ហាញថា សកម្មភាពរបស់រដ្ឋាភិបាល ដែលផ្តល់ផលប្រយោជន៍ទៅដល់អ្នកមានទ្រព្យសម្បត្តិ បានស្រូបយកចំណែកដ៏ធំមួយនៃការចំណាយសាធារណៈសម្រាប់ការអប់រំ។ នៅអាមេរិកឡាទីន ភាពខុសគ្នាទៅលើសមិទ្ធផលរៀនសូត្រ បាននាំឱ្យមាននូវភាពគ្មានប្រសិទ្ធភាពនៃសាលារៀនរបស់រដ្ឋ ដែលភាគច្រើនជាសាលារៀនរបស់អ្នកក្រ ហើយការអប់រំបឋមសិក្សា និងមធ្យមសិក្សា ដែលជាកម្រិតនៃការរៀនសូត្រមួយ ដែលមានអត្ថប្រយោជន៍ច្រើនបំផុតទៅដល់អ្នកក្រ ទទួលបានចំណែកតិចតួចនៃការចំណាយផ្នែកអប់រំសរុប។ ទោះបីជានៅពេលណាដែលរដ្ឋាភិបាល ធ្វើការបែងចែកធនធានគ្រប់គ្រាន់ក្នុងគោលបំណង ដើម្បីពង្រឹងការទទួលបាន និងពង្រីកគុណភាពអប់រំឱ្យទៅដល់អ្នកក្រក៏ដោយក៏សមត្ថភាពផ្នែករដ្ឋបាល ក្នុងការផ្តល់សេវាទាំងនោះ នៅតែមិនគ្រប់គ្រាន់នៅឡើយ។

គុណភាពអប់រំ រួមមានកម្មវិធីសិក្សា ឯកសារសៀវភៅ វិធីសាស្រ្តបង្រៀន ការបណ្តុះបណ្តាលទៅដល់គ្រូបង្រៀន អាត្រាធៀបរវាងសិស្សនិងគ្រូ និងការចូលរួមរបស់ឪពុកម្តាយសិស្សធ្វើការកំណត់ទៅលើលទ្ធផលនៃការអប់រំ (ដូចជាអត្រាសិស្សនៅរក្សាចូលរៀនក្នុងសាលា កម្រិតនៃការបញ្ចប់ការសិក្សា និងពិន្ទុតេស្ត)។

## សេចក្តីត្រូវការ

សេចក្តីត្រូវការសម្រាប់ការអប់រំអាស្រ័យទៅលើការទទួលបានប្រយោជន៍មកវិញចំពោះ គ្រួសារ។ ប្រយោជន៍នេះ រួមមានចំណូល ដែលត្រូវបានរំពឹងទុក ប៉ុន្តែក៏ពាក់ព័ន្ធទៅដល់បញ្ហាសុខភាពដែលមានភាពប្រសើរឡើង និងអត្រាមានកូនតិចជាងមុន។ យោងទៅតាមការសិក្សាមួយការរកប្រាក់បានជាមធ្យមអាចកើន ១០ភាគរយ សម្រាប់ការរៀនបានកម្រិតបន្ថែមមួយថ្នាក់

ប្រសិនបើមានកាលានុវត្តភាពការងារ សម្រាប់កម្មករដែលបានទទួលការរៀនសូត្រទាំងនោះ។

នៅប្រទេសខ្លះ សេចក្តីត្រូវការសម្រាប់ការអប់រំ មានចំនួនតិចជាង ដោយសារតែផលប្រយោជន៍ដែលគេរំពឹងទុកនានាពីការអប់រំ មានចំនួនថយ ដែលក្នុងចំណោមនោះ ដោយសារការចំណាយទៅលើការអប់រំ គុណភាពទាបតាមសាលាសាធារណៈ និងការរើសអើងប្រឆាំងក្រុមជនជាតិភាគតិច ឬក្រុមមានភាសាផ្សេង និងការរើសអើងប្រឆាំងនឹងស្ត្រី នៅក្នុងទីផ្សារការងារ។

### ថ្លៃបង់សាលា

ការស្រាវជ្រាវថ្មីៗ រួមទាំងការស្រាវជ្រាវ ដែលផ្អែកលើរបាយការណ៍របស់រដ្ឋផងដែរ ត្រូវបានដាក់ជូនទៅគណៈកម្មាធិការ CRC និងCESCR បង្ហាញថាការអប់រំជាមូលដ្ឋាន (ទោះបីជាកាតព្វកិច្ចក៏ដោយ) គឺមិនមែនតែងតែមិនបង់ប្រាក់នោះទេ។ ថ្លៃបង់សាលាមានផលប៉ះពាល់ដោយផ្ទាល់ទៅលើការចូលរួមទៅក្នុងប្រព័ន្ធអប់រំ ហើយបានជំរុញឱ្យអ្នកក្រទទួលបាន នូវការខាតបង់មួយ។

ផ្នែកទាំងពីរ អាចត្រូវបានបំបែកចេញទៅជា ៤វិស័យនៃកាតព្វកិច្ចថែមទៀត ៖ ការដែលអាចរកបាន ការទៅទទួលបាន ការទទួលយកបាន និងការដែលអាចសម្របទៅតាមបាន ដូចមានចែងក្នុងសេចក្តីពន្យល់ទូទៅលេខ១៣ នៃគណៈកម្មាធិការ CESCR។ គោលគំនិតទាំងនេះ រួមមាននូវវិធានការអនុវត្តដូចតទៅ:

### ភាពដែលអាចរកបាននូវស្ថាប័ន និងកម្មវិធីអប់រំដែលមានដំណើរការ

- ការអប់រំបឋមគឺជាកាតព្វកិច្ច និងមិនបង់ថ្លៃសម្រាប់ទាំងអស់គ្នា (ដើម្បីការពារកុមារពីការធ្វើការងារ ពេលដែលពួកគេនៅក្មេងនៅឡើយ)
- កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន
- លក្ខខណ្ឌការងារសមរម្យសម្រាប់គ្រូបង្រៀន ដោយរួមទាំងសិទ្ធិក្នុងការបង្កើតសមាគម និងការចរចាជារួម

### ភាពអាចទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា

- ការអប់រំមធ្យមសិក្សា និងឧត្តមសិក្សា ដែលអាចមានលទ្ធភាពទទួលបានផ្នែកសេដ្ឋកិច្ច
- ការទទួលបាននូវការអប់រំ ដោយមិនមានការរើសអើង
- ប្រព័ន្ធផ្តល់ប្រាក់ឧបត្ថម្ភសមរម្យ សម្រាប់ការអប់រំ ទៅដល់ក្រុមដែលបាត់បង់អត្ថប្រយោជន៏នានា
- ការផ្តល់មូលនីធិគ្រប់គ្រាន់ សម្រាប់ការអប់រំនៅតំបន់ជនបទនានា
- យន្តការនានា សម្រាប់ត្រួតពិនិត្យតាមដានទៅលើគោលនយោបាយ គ្រឹះស្ថាននានា កម្មវិធី របៀបនៃការចំណាយ និងការអនុវត្តផ្សេងទៀត នៅក្នុងវិស័យអប់រំ ។

### ភាពអាចទទួលយកបាននូវទម្រង់ និងខ្លឹមសារ

- ធ្វើច្បាប់ដោយធានានូវគុណភាពរបស់កម្មវិធីសិក្សា និងវិធីសាស្ត្រក្នុងការបង្រៀន
- ស្តង់ដារអប់រំជាអប្បបរមា (លើការអនុញ្ញាតឱ្យចូលរៀន កម្មវិធីសិក្សា ការទទួលស្គាល់វិញ្ញាបនប័ត្រ ។ល ។ និងយន្តការតាមដានត្រួតពិនិត្យពាក់ព័ន្ធនានា
- ការធានាឱ្យមានសិទ្ធិក្នុងការបង្កើតគ្រឹះស្ថានឯកជន

### ភាពដែលអាចសម្របទៅតាមបានរបស់កម្មវិធីសិក្សា

- ការរៀបចំកម្មវិធីសិក្សា និងការផ្តល់មូលនិធិអប់រំ ឱ្យស្របទៅនឹងសេចក្តីត្រូវការពិតប្រាកដរបស់សិស្ស និងនិស្សិតទាំងឡាយ ។

## *ផែនការសកម្មភាព*

ការកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ ដើម្បីសម្រេចបាននូវសិទ្ធិទទួលបានការអប់រំ គួរមានលក្ខណៈឈានឡើងជាបណ្តើរៗ ។ កិច្ចប្រឹងប្រែងទាំងនោះ គួរមានប្រសិទ្ធភាព និងមិនបង្អែរបង្អង់នៅក្នុងកម្រិតសមរម្យមួយ ។ កាតព្វកិច្ចរបស់រដ្ឋមិនស្ថិតនៅក្នុងស្ថានភាព

ប្រញាប់ប្រញាល់ទៅលើគ្រប់ផ្នែក( ការអប់រំជាមូលដ្ឋាន បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា) នោះទេ ៖ រដ្ឋាភិបាលនានាត្រូវបានគេរំពឹងទុកឱ្យផ្តល់អាទិភាពក្នុងការដាក់ឱ្យមានការអប់រំកម្រិតបឋម ដែលជាកាតព្វកិច្ច និងដោយមិនបង់ថ្លៃ ខណៈពេលទន្ទឹមគ្នានេះ ចាត់វិធានការជាជំហានៗ សម្រាប់ធ្វើឱ្យបានសម្រេចសិទ្ធិទទួលបានការអប់រំ នៅតាមកម្រិតផ្សេងទៀត ។

រដ្ឋនានា នៅពេលកំពុងក្លាយជាភាគីមួយរបស់ CESCR មិនទាន់មានលទ្ធភាព អនុវត្តការអប់រំកម្រិតបឋម ដែលជាកាតព្វកិច្ច និងដោយមិនបង់ប្រាក់ គួរធ្វើការអនុម័ត និងអនុវត្តផែនការអប់រំថ្នាក់ជាតិមួយ ដូចមានចែងក្នុងមាត្រា១៤ នៃកតិកាសញ្ញានេះ ។ ផែនការនោះ គួរត្រូវបានគូសវាសឡើង ហើយអនុម័តក្នុងរង្វង់រយៈពេល ២ឆ្នាំ សម្រាប់ការ អនុវត្តជាបណ្តើរៗ នៅក្នុងរង្វង់ចំនួនឆ្នាំសមហេតុផល ដែលត្រូវធ្វើឡើងនៅក្នុងផែនការនោះ នូវគោលការណ៍នៃការអប់រំជាកាតព្វកិច្ច ដែលមិនបង់ប្រាក់សម្រាប់ទាំងអស់គ្នា ។ ការចែងជាក់លាក់ នូវរយៈពេល ២ឆ្នាំ មិនមែនទុកឱ្យរដ្ឋភាគីរួចខ្លួនពីកាតព្វកិច្ចនេះទេ ក្នុងករណី ដែលរដ្ឋនោះ ខកខានក្នុងការធ្វើសកម្មភាពនេះក្នុងអំឡុងពេលនោះ ។

*សន្និសីទអន្តរសភាលើកទី១០៥ "ពោលអះអាងថា ការអប់រំ គឺជាលក្ខខណ្ឌមួយ សម្រាប់ការលើកកំពស់ឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចិរភាព ធ្វើការធានានូវបរិស្ថាន ប្រកបដោយសុខុមាលភាព ធានានូវសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ និងទទួលបាននូវវត្ថុ បំណងនៃការប្រយុទ្ធនឹងភាពក្រីក្រ ធ្វើឱ្យកំណើនប្រជាជនមានការថយចុះ និងបង្កើតឱ្យមាន សមភាពរវាងភេទនានា ហើយវប្បធម៌ គឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការអភិវឌ្ឍន៍នេះ ។"*

*ដំណោះស្រាយស្តីពី "ការអប់រំ និងវប្បធម៌ ជាកត្តា សំខាន់ក្នុងការលើកកំពស់ការចូលរួមរបស់បុរស និងស្ត្រី នៅក្នុងវិស័យនយោបាយ និងជាលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍន៍មនុស្ស" ទីក្រុងហាវ៉ាណា ខែមេសា ឆ្នាំ២០០១ ឃ្លាប្រយោគ ១*

# សេចក្តីសន្និដ្ឋានចុងក្រោយ

សិទ្ធិមនុស្សគឺជាគោលគំនិតដែលមានការវិវត្តន៍។ ការវិវត្តន៍របស់វាគឺជាដំណើរការមួយដែលក្នុងនោះ សមាជិកសភា និងអង្គស្ថាប័នសភាអាចដើរតួនាទីឈានមុខមួយ។ តួនាទីនេះអាចជាឧបករណ៍យ៉ាងសំខាន់ នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការ ៖ ផ្តួចផ្តើមគំនិត និងជំរុញឱ្យមានការពិភាក្សាវែកញែកនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ធ្វើការគាំទ្រដល់អង្គស្ថាប័ន បង្កើតបទដ្ឋាន ធ្វើការចូលរួមក្នុងការគូសវាសឡើងនូវឧបករណ៍ច្បាប់ ធ្វើការធានាឱ្យមានការអនុម័ត និងផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាអន្តរជាតិនានា ធ្វើការតាមដានទៅលើសន្ធិសញ្ញាទាំងនោះ និងធ្វើការតាមដានពិនិត្យមើលលើការអនុវត្តរបស់វា។ ធ្វើបែបនេះ សមាជិកសភាអាចជាដៃគូដ៏សំខាន់ក្នុងការកែប្រែប្រព័ន្ធពិភពលោក ដោយឈរលើមូលដ្ឋាននៃភាពត្រឹមត្រូវ សមភាព និងសិទ្ធិមនុស្ស។

# បញ្ជីអក្សរបំព្រួញ

| | |
|---|---|
| ACHR | American Convention on Human Rights, also known as «Pact of San José, Costa Rica» |
| AU | African Union |
| CAT | Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment |
| CCPR | International Covenant on Civil and Political Rights |
| CEDAW | Convention on the Elimination of All Forms of Discrimination against Women |
| CERD | International Convention on the Elimination of All Forms of Racial Discrimination |
| CESCR | International Covenant on Economic, Social and Cultural Rights |
| CMW | International Convention on the Protection of the Rights of All Migrant Workers and Members of Their Families |
| CRC | Convention on the Rights of the Child |
| DAW | Division for the Advancement of Women |
| DESA | United Nations Department of Economic and Social Affairs |
| ECHR | European Convention for the Protection of Human Rights and Fundamental Freedoms |
| ECOSOC | Economic and Social Council |
| FAO | Food and Agriculture Organization of the United Nations |
| FGM | Female genital mutilation |
| GATS | General Agreement on Trade in Services |
| IACHR | Inter-American Commission on Human Rights |
| ICC | International Criminal Court |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| ILO | International Labour Organization |
| IMF | International Monetary Fund |
| INSTRAW | United Nations International Research and Training Institute for the Advancement of Women |
| IPU | Inter-Parliamentary Union |
| NGO | Non-governmental organization |

| | |
|---|---|
| NHRI | National human rights institution |
| OAS | Organization of American States |
| OHCHR | Office of the United Nations High Commissioner for Human Rights |
| OP | Optional Protocol |
| PRSP | Poverty reduction strategy paper |
| TRIPS | Agreement on Trade-Related Aspects of Intellectual Property Rights |
| UDHR | Universal Declaration of Human Rights |
| UNDP | United Nations Development Programme |
| UNESCO | United Nations Educational, Scientific and Cultural Organization |
| UNFPA | United Nations Population Fund |
| UN-HABITAT | United Nations Human Settlement Programme |
| UNHCR | United Nations High Commissioner for Refugees |
| UNICEF | United Nations Children's Fund |
| UNIFEM | United Nations Development Fund for Women |
| UNITAR | United Nations Institute for Training and Research |
| UNRISD | United Nations Research Institute for Social Development |
| UNRWA | United Nations Relief and Works Agency for Palestine Refugees in the Near East |
| UNU | United Nations University |
| WFP | World Food Programme |
| WHO | World Health Organization |
| WTO | World Trade Organization |

# ឧបសម្ព័ន្ធ ១

## សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

### បុព្វកថា

*ដោយយល់ឃើញថា* ការទទួលស្គាល់សេចក្ដីថ្លៃថ្នូរជាប់ពីកំណើតរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ហើយនិងការទទួលស្គាល់សិទ្ធិស្មើភាពគ្នានិងសិទ្ធិមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបាន ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក។

*ដោយយល់ឃើញថា* ការមិនទទួលស្គាល់និងការប្រមាថមើលងាយសិទ្ធិមនុស្ស បាននាំទៅកាន់អំពើព្រៃផ្សៃសាហាវយង់ឃ្នង ធ្វើឱ្យក្ដៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ និង *ដោយយល់ឃើញថា* ការកើតឡើងនូវពិភពលោកមួយ ដែលមនុស្សជាតិត្រូវមានសេរីភាព-ក្នុងការនិយាយស្ដី និងជំនឿរួចផុតពីភាពភ័យខ្លាចនិងទុគ៌តភាព ត្រូវបានប្រកាសថាជាសេចក្ដីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលសិទ្ធិមនុស្សត្រូវតែបានការពារដោយនីតិរដ្ឋ ដើម្បីជៀសវាង កុំឱ្យមនុស្សបង្ខំចិត្តជាចុងក្រោយបង្អស់ បះបោរប្រឆាំងទល់នឹងអំណាចផ្ដាច់ការ និងការគាបសង្កត់។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលត្រូវលើកស្ទួយការពង្រីកទំនាក់ទំនងជាមិត្តភាពរវាងប្រជាជាតិនានា។

*ដោយយល់ឃើញថា* ប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិនូវជំនឿរបស់ខ្លួនទៅលើសិទ្ធិមូលដ្ឋាននៃមនុស្ស លើសេចក្តីថ្លៃថ្នូរលើតម្លៃរបស់មនុស្សនិងលើសមភាពនៃសិទ្ធិរវាងបុរសនិងស្ត្រី ហើយប្តេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គមនិងកម្រិតជីវភាព រស់នៅឱ្យកាន់តែប្រសើរឡើងក្នុងសេរីភាព កាន់តែទូលំទូលាយ ។

*ដោយយល់ឃើញថា* ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់សន្យា និងធានាគោរពសិទ្ធិសកល និងសេរីភាពមូលដ្ឋានឱ្យបានសម្រេច ។

*ដោយយល់ឃើញថា* ទស្សនៈរួមមួយស្តីអំពីសិទ្ធិនិងសេរីភាពទាំងនេះ មានសារសំខាន់បំផុតដើម្បីបំពេញនូវការសន្យាខាងលើ

*អាស្រ័យហេតុនេះមហាសន្និបាតប្រកាសថា :*

*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះ* ជាឧត្តមគតិរួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់ៗរូបនិងអង្គការសង្គមទាំងអស់ ដោយរក្សាខ្ជាប់ជានិច្ចក្នុងស្មារតីរបស់ខ្លួននូវសេចក្តីប្រកាសនេះ ខិតខំប្រឹងប្រែងបណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះតាមរយៈការបង្រៀននិងការអប់រំ ហើយនិងខំប្រឹងប្រែងធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសកលជាក់ស្តែងនូវសិទ្ធិនិងសេរីភាព ដោយ-វិធានការជាតិនិងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិកទាំងក្នុងចំណោមប្រជាពលរដ្ឋដែនដី ដែលស្ថិតនៅក្រោមអំណាចនៃរដ្ឋទាំងនោះផង ។

មាត្រា ១

មនុស្សទាំងអស់កើតមកមានសេរីភាពនិងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាតរភាពជាបងប្អូន ។

មាត្រា ២

មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិនិងសេរីភាពទាំងអស់ ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬមតិផ្សេងៗទៀត ដើមកំណើតជាតិឬសង្គម ព្រទ្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

លើសពីនេះ មិនត្រូវធ្វើការប្រកាន់បែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងយុត្តាធិការឬខាងអន្តរជាតិរបស់ប្រទេសឬដែនដីដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្តី ស្ថិតក្រោមអាណាព្យាបាលក្តី ឬ គ្មានស្វ័យគ្រប់គ្រងក្តី ឬស្ថិតក្រោមការដាក់កម្រិតផ្សេង ទៀតណាមួយនៃអធិបតេយ្យភាពក្តី ។

មាត្រា ៣

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

មាត្រា ៤

គ្មានជនណាម្នាក់ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ ។ ទាសភាព និងទាសពាណិជ្ជកម្មត្រូវហាមឃាត់ ទោះតាមទម្រង់ណាក៏ដោយ ។

មាត្រា ៥

គ្មានជនណាម្នាក់ ត្រូវទទួលរងទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មបែបឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។

មាត្រា ៦

មនុស្សម្នាក់ៗ មានសិទ្ធិឱ្យទទួលស្គាល់ពីបុគ្គលិកលក្ខណៈគតិយុត្តរបស់ខ្លួន នៅគ្រប់ទីកន្លែង។

មាត្រា ៧

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូប មានសិទ្ធិទទួលការការពារស្មើៗគ្នាប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង។

មាត្រា ៨

មនុស្សគ្រប់រូប មានសិទ្ធិរកដំណោះស្រាយជាក់ស្តែងមួយនៅចំពោះមុខសាលាជម្រះក្តីជាតិដែលមានសមត្ថកិច្ច ចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។

មាត្រា ៩

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន ដោយបំពានឡើយ។

មាត្រា ១០

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យ និងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈនិងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ ។

មាត្រា ១១

១. ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោស រហូតដល់ពិរុទ្ធភាព ត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីការពារសិទ្ធិជនជាប់ចោទ ពីបទល្មើសព្រហ្មទណ្ឌ ។

២. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ដោយបានប្រព្រឹត្ត ឬភ្លាំងភ្លាត់ប្រព្រឹត្ត ដែលអំពើនេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ ។ មិនត្រូវផ្តន្ទាទោសឱ្យធ្ងន់ជាងទោស ដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេល បទល្មើសបានកើតឡើងឡើយ ។

មាត្រា ១២

គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបាន ឡើយ ។ ជនគ្រប់រូប មានសិទ្ធិទទួលការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬ ការប៉ះពាល់ទាំងនេះ ។

មាត្រា ១៣

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ ។

២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ ។

មាត្រា ១៤

១. មនុស្សគ្រប់រូប មានសិទ្ធិស្វែងរកនិងទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុក្ខបុកម្នេញមកលើខ្លួន ។

២. សិទ្ធិសុំជ្រកកោននេះមិនអាចលើកមកសំអាងបានទេ ក្នុងករណីមានការចោទប្រកាន់ពីបទល្មើសនៃនីតិរួម ឬពីការប្រព្រឹត្តណាដែលផ្ទុយពីគោលបំណង និងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិ ។

មាត្រា ១៥

១. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ ។

២. គ្មានជនណាម្នាក់អាចត្រូវដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួន ដោយរំលោភបានឡើយ ។

មាត្រា ១៦

១. បុរសនិងស្ត្រី មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារ ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ។ បុរសនិងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយអាពាហ៍ពិពាហ៍។

២. អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញ ពីអនាគតប្តីប្រពន្ធ។

៣. គ្រួសារជាធាតុធម្មជាតិ និងជាធាតុមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ។

មាត្រា ១៧

១. មនុស្សគ្រប់រូប ទោះជាបុគ្គលក្តី សមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។

២. គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ ។

មាត្រា ១៨

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែងសាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬ ជារួម ជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តជាទម្លាប់ ការគោរពបូជា ព្រមទាំង តាមការប្រារព្ធពិធីសក្ការៈផ្សេងៗ។

## មាត្រា ១៩

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្ដែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំង សេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុង-ការស្វែងរក ការទទួល និងការផ្សព្វ ផ្សាយពតិមាននិងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្ដែងមតិណាមួយក៏ដោយ។

## មាត្រា ២០

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការបង្កើតសមាគម ដោយសន្តិវិធី។

២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ។

## មាត្រា ២១

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី។

២. មនុស្សគ្រប់រូប មានសិទ្ធិចូលបម្រើមុខងារសាធារណៈនៃប្រទេសរបស់ខ្លួនក្នុងល័ក្ខខ័ណ្ឌសមភាព។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ។ ឆន្ទៈនេះ ត្រូវសម្ដែងចេញតាមរយៈការបោះឆ្នោតយ៉ាងទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដ មានលក្ខណៈសកល ស្មើភាព និងបោះឆ្នោតដោយសម្ងាត់ ឬតាមនីតិវិធីសមមូល ដែលធានាសេរីភាពនៃការបោះឆ្នោត។

មាត្រា ២២

ក្នុងឋានៈជាសមាជិកនៃសង្គម មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសន្តិសុខសង្គម និង-មានបុព្វសិទ្ធិទទួលបានសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូរ និងការរីកចំរើនដោយ សេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈការខិតខំរបស់ជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ស្របតាមការរៀបចំ និងតាមធនធានរបស់ប្រទេសនីមួយៗ ។

មាត្រា ២៣

១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ ជ្រើសរើសការងារដោយសេរី និងធ្វើការងារក្នុងល័ក្ខខ័ណ្ឌ ត្រឹមត្រូវនិងពេញចិត្ត ព្រមទាំងក ារប្រឆាំងនឹងភាពអត់ការងារធ្វើ ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង ។

៣. អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភការដោយសមធម៌និងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួននិងគ្រួស ឱ្យសមស្របនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀត តាមមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គម ប្រសិនបើចាំបាច់ ។

៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និងចូលរួមសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

មាត្រា ២៤

មនុស្សគ្រប់រូប មានសិទ្ធិឈប់សម្រាកនិងលំហែកំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផល និងការឈប់សម្រាកដោយបានប្រាក់បៀវត្សតាមពេលកំណត់ ។

មាត្រា ២៥

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួននិងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការគាំពារនៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬ នៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្ដាលមកពីកាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន។

២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស។ កុមារ គ្រប់រូប ទោះកើតពីឪពុកម្ដាយមានខាន់ស្លា ឬឥតខាន់ស្លាក្ដី ត្រូវបានទទួលការពារខាងសង្គមកិច្ចដូចគ្នា។

មាត្រា ២៦

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ។ ការអប់រំត្រូវឥតបង់ថ្លៃយ៉ាងហោចណាស់ សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន។ ការអប់រំបឋមសិក្សា គឺជាកាតព្វកិច្ច។ ការអប់រំខាងបច្ចេក ទេសនិងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ។ ការអប់រំឧត្ដមសិក្សា ត្រូវបើកឱ្យចូលរៀនស្មើភាពគ្នាដោយឈរលើមូលដ្ឋានសមត្ថភាព។

២. ការអប់រំ ត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។ ការអប់រំនេះ ត្រូវលើកកំពស់ការយល់ដឹងការអត់ឱន អធ្យាស្រ័យគ្នានិងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់សហប្រជាជាតិ ក្នុងការ

ថែរក្សាសន្តិភាព។

៣. មាតាបិតា មានសិទ្ធិជាអាទិភាពក្នុងការជ្រើសរើសប្រភេទនៃការអប់រំសម្រាប់បុត្រធីតារបស់ខ្លួន។

មាត្រា ២៧

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌របស់សហគមន៍ រីករាយនឹង សិល្បៈ និងចូលរួមចំណែកក្នុងវឌ្ឍនភាពវិទ្យាសាស្ត្រ និងបានទទួលផលប្រយោជន៍ពីលទ្ធផលវឌ្ឍនភាពនេះ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការការពារផលប្រយោជន៍ខាងសីលធម៌ និងសម្ភារៈ ដែលដែលបានមកពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈស្នាដៃរបស់ខ្លួន។

មាត្រា ២៨

មនុស្សគ្រប់រូប មានសិទ្ធិចូលរួមគ្រប់គ្រងសណ្តាប់ធ្នាប់សង្គមនិងអន្តរជាតិ ដែលសិទ្ធិនិងសេរីភាពចែងក្នុងសេចក្តីប្រកាសនេះ អាចត្រូវសម្រេចឱ្យបានដោយពេញលេញ។

មាត្រា ២៩

១. មនុស្សគ្រប់រូប មានករណីយកិច្ចចំពោះសហគមន៍ដែលជាកន្លែងតែមួយគត់ អាចបង្កើតបានការរីកចម្រើនដោយសេរីនិងពេញបរិបូរណ៍នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។

២. ក្នុងការប្រើសិទ្ធិនិងសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូប ត្រូវស្ថិតនៅត្រឹមកម្រិត-ដែលច្បាប់បានកំណត់តែប៉ុណ្ណោះ ក្នុងគោលបំណងធានាការទទួលស្គាល់ និងការគោរពសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ និង ដើម្បីបំពេញសេចក្តីត្រូវការយ៉ាងត្រឹមត្រូវខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ ។

៣. គ្មានករណីណាមួយ ដែលសិទ្ធិនិងសេរីភាពទាំងនេះ អាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិឡើយ ។

មាត្រា ៣០

គ្មានបទបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ អាចត្រូវបានបកស្រាយ ដែលបណ្តាលឱ្យរដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយដើម្បីធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយ សំដៅបំផ្លិចបំផ្លាញនូវសិទ្ធិនិងសេរីភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះឡើយ ។

# ឧបសម្ព័ន្ធ ២

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

### បុព្វកថា

*រដ្ឋភាគីនៃកតិកាសញ្ញានេះ*

*យល់ឃើញថា* ស្របតាមគោលការណ៍នានា ដែលបានប្រកាសនៅក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត សិទ្ធិស្មើភាពគ្នា និងសិទ្ធិដែលមិនអាចលក់ដូរផ្ទេរ ដកហូតបាន របស់សមាជិកគ្រួសារមនុស្ស គឺជាគ្រឹះ នៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ទទួលស្គាល់ថា* សិទ្ធិទាំងនេះ កើតមកពីសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស ។

*ទទួលស្គាល់ថា* ស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឧត្តមគតិរបស់មនុស្សសេរី ដែលអាស្រ័យផលសេរីភាពពលរដ្ឋ និងនយោបាយ និងភាពរួចផុតពីការភ័យខ្លាច និង-ទុគ៌តភាព អាចសម្រេចជោគជ័យទៅបាន លុះត្រាតែបង្កើតបានលក្ខខណ្ឌ ដែលឱ្យមនុស្សម្នាក់ៗ អាចប្រើប្រាស់បាននូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួន ។

*យល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិ តម្រូវឱ្យរដ្ឋនូវកាតព្វកិច្ចជំរុញឱ្យមានការគោរពជាសកល និងការអនុវត្តន៍នូវសិទ្ធិ និងសេរីភាពរបស់មនុស្ស ។

*យល់ឃើញថា* បុគ្គលគ្រប់រូប មានករណីយកិច្ចចំពោះអ្នកដទៃ និងចំពោះសហគមន៍

ដែលខ្លួនរស់នៅ ហើយត្រូវខិតខំលើកស្ទួយ និងគោរពសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

*ព្រមព្រៀងលើមាត្រាទាំងឡាយដូចតទៅ :*

## ផ្នែកទី ១

### មាត្រា ១

១. ប្រជាជាតិទាំងអស់ មានសិទ្ធិស្វ័យសម្រេច ។ អាស្រ័យដោយសិទ្ធិនេះ ប្រជាជាតិទាំងនេះ សម្រេចដោយសេរីនូវឋានៈនយោបាយ និងខិតខំអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី ។

២. ដើម្បីសម្រេចគោលដៅរបស់ខ្លួន ប្រជាជាតិទាំងអស់ អាចចាត់ចែង ដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួន ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ច ដែលចេញមកពីសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដែលផ្អែកលើគោលការណ៍នៃផលប្រយោជន៍ទៅវិញទៅមក និងគោលការណ៍នៃច្បាប់អន្តរជាតិ ។ តែទោះយ៉ាងណាក៏ដោយ ប្រជាជាតិនីមួយៗ មិនត្រូវបានដកហូតមធ្យោបាយចិញ្ចឹមជីវិតផ្ទាល់ខ្លួនឡើយ ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ រួមទាំងរដ្ឋនានាដែលមានការទទួលខុសត្រូវគ្រប់គ្រងទឹកដីអស្វយ័ត និងទឹកដីអាណាព្យាបាល ត្រូវលើកស្ទួយធ្វើឱ្យបានសម្រេចនូវសិទ្ធិស្វ័យសម្រេច និងត្រូវគោរពសិទ្ធិនេះ ស្របតាមបទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ ។

# ផ្នែកទី ២

## មាត្រា ២

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូប ដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួននូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

២. បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះ ដោយសម្រួលដល់ការអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវសិទ្ធិទាំងឡាយដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ។

៣. រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យា ៖

(ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះ មានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះ បានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ ។

(ខ) ធានាថា ជនណាដែលប្តឹងឱ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឱ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត សម្រេចឱ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង ។

(គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តឱ្យបាននូវដំណោះស្រាយ ដែលបានសម្រេចហើយ ។

## មាត្រា ៣

រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុងកតិកាសញ្ញានេះ ។

## មាត្រា ៤

១. ក្នុងករណីមានភាពអាសន្នសាធារណៈពិសេស ដែលគំរាមកំហែងដល់អត្ថិភាពជាតិ និងដែលត្រូវបានប្រកាសជាផ្លូវការ រដ្ឋភាគីនៃកតិកាសញ្ញានេះ អាចចាត់វិធានការបដិប្បញ្ញត្តិនឹងកាតព្វកិច្ចដែលមានចែងក្នុងកតិកាសញ្ញានេះ ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ កុំឱ្យតែវិធានការទាំងនេះ មានវិសមិតភាពទៅនឹងកាតព្វកិច្ចដទៃទៀត ដែលច្បាប់អន្តរជាតិតម្រូវ ហើយមិនពាក់ព័ន្ធនឹងការរើសអើងដែលផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬដើមកំណើតសង្គម ។

២. បទបញ្ញត្តិខាងលើនេះ មិនអនុញ្ញាតឱ្យមាន បដិប្បញ្ញត្តិនឹង មាត្រា៦ មាត្រា៧ មាត្រា៨ (កថាខណ្ឌ១ និង២) មាត្រា១១ មាត្រា១៥ មាត្រា១៦ និង មាត្រា១៨ ។

៣. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះដែលប្រើប្រាស់សិទ្ធិបដិប្បញ្ញត្តិ ត្រូវផ្តល់ព័ត៌មានដល់រដ្ឋភាគីឯទៀតជាបន្ទាន់ តាមរយៈអន្តរការីនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវបទបញ្ញត្តិ និងមូលហេតុដែលខ្លួនបានធ្វើបដិប្បញ្ញត្តិនេះ។ ការផ្តល់ព័ត៌មានបន្ថែមស្តីពីកាលបរិច្ឆេទ នៃការបញ្ចប់បដិប្បញ្ញត្តិរបស់ខ្លួន ត្រូវធ្វើឡើងតាមរយៈអន្តរការីនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៥

១. គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ អាចត្រូវបានបកស្រាយតម្រូវថា រដ្ឋមួយ ក្រុមមួយ បុគ្គលម្នាក់ មានសិទ្ធិធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយដែលសំដៅទៅបំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាព ដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ឬសំដៅទៅដាក់កម្រិត ដែលមានវិសាលភាពធំជាងកម្រិត ដែលបានចែងនៅក្នុងកតិកាសញ្ញានេះ ។

២. មិនត្រូវធ្វើការរិតត្បិត ឬធ្វើបដិប្បញ្ញត្តិណាមួយឡើយ ទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្ស ដែលត្រូវបានទទួលស្គាល់ ឬដែលនៅជាធរមាន ក្នុងរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ អនុសញ្ញា បទបញ្ជា ឬទំនៀមទំលាប់ ដោយយកលេសថា កតិកាសញ្ញានេះ មិនទទួលស្គាល់សិទ្ធិទាំងនោះ ឬទទួលស្គាល់សិទ្ធិទាំងនោះ ក្នុងកម្រិតតិចជាង ។

# ផ្នែកទី ៣

## មាត្រា ៦

១. ជនគ្រប់រូប មានសិទ្ធិមានជីវិតជាប់ពីកំណើត ។ សិទ្ធិនេះ ត្រូវការពារដោយច្បាប់ ។ គ្មានជនណាម្នាក់ ត្រូវគេប្រហារជីវិតតាមអំពើចិត្តបានឡើយ ។

២. ក្នុងប្រទេសទាំងឡាយណា ដែលមិនទាន់បានលប់ចោលទោសប្រហារជីវិត សាលក្រមកាត់ទោសប្រហារជីវិត អាចប្រកាសបានចំពោះតែបទឧក្រិដ្ឋណា ដែលធ្ងន់ធ្ងរបំផុតស្របតាមច្បាប់ជាធរមាន ក្នុងពេលដែលបទឧក្រិដ្ឋនោះកើតឡើង ហើយមិនផ្ទុយ នឹងបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងអនុសញ្ញាស្តីពី-

ការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ ទណ្ឌកម្មនេះ អាចអនុវត្តបាន ដោយអនុលោមតែតាមសាលក្រមស្ថាពរ ដែលចេញដោយតុលាការ-មានសមត្ថកិច្ចប៉ុណ្ណោះ ។

៣. នៅពេលដែលការប្រហារជីវិតជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវយល់ថាគ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ដែលអនុញ្ញាតឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះធ្វើបដិប្បញ្ញត្តិ តាមបែបណាមួយពីកាតព្វកិច្ចណាដែលបានសន្មត់ ស្របតាមបទបញ្ញត្តិនៃអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះបានឡើយ ។

៤. ជនដែលទទួលទោសប្រហារជីវិត មានសិទ្ធិសុំអភ័យទោស ឬបន្ធូរបន្ថយទោស។ ការលើកលែងទោស ការអភ័យទោស ឬការបន្ធូរបន្ថយទោសប្រហារជីវិត អាចផ្តល់ឱ្យបានគ្រប់ករណីទាំងអស់ ។

៥. ទោសប្រហារជីវិត មិនត្រូវអនុវត្តចំពោះបទឧក្រិដ្ឋទាំងឡាយណាដែលប្រព្រឹត្តដោយជនមានអាយុក្រោម ១៨ឆ្នាំ និងមិនត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃពោះឡើយ ។

៦. គ្មានបទបញ្ញត្តិណាមួយក្នុងមាត្រានេះ អាចយកមកសំអាង ដើម្បីធ្វើឱ្យយឺតយ៉ាវ ឬរារាំងដល់ការលុបចោលទោសប្រហារជីវិតដោយរដ្ឋភាគីនៃកតិកាសញ្ញានេះឡើយ ។

## មាត្រា ៧

គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យថោកទាបឡើយ ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ ។

## មាត្រា ៨

១. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងទាសភាពឡើយ ។ ទាសភាព និងទាសពាណិជ្ជកម្ម តាមគ្រប់ទម្រង់ទាំងអស់ ត្រូវហាមឃាត់ ។

២. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងភាពជាខ្ញុំបម្រើដាច់ថ្លៃឡើយ ។

៣. (ក) គ្មានជនណាម្នាក់ តម្រូវឱ្យធ្វើការដោយបង្ខំ ឬខានមិនបានឡើយ ។

(ខ) កថាខណ្ឌ៣.(ក) មិនត្រូវយកមកបកស្រាយថា ហាមឃាត់ការអនុវត្តនីទោសឱ្យធ្វើការដោយបង្ខំ ស្របតាមការវិនិច្ឆ័យទោស ដោយតុលាការមានសមត្ថកិច្ចក្នុងប្រទេសដែលបទឧក្រិដ្ឋខ្លះ អាចមានទោសជាប់គុកឱ្យធ្វើការដោយបង្ខំ ។

(គ) បំណងនៃកថាខណ្ឌនេះ ពាក្យថា "ការងារដោយបង្ខំ ឬដោយខានមិនបាន" មិនត្រូវរាប់បញ្ចូល ៖

(i) ការងារ ឬសេវាដែលគ្មានចែងក្នុងអនុកថាខណ្ឌ(ខ) និងដែលតម្រូវជាធម្មតា ចំពោះជនជាប់ឃុំ តាមបទបញ្ជាស្របច្បាប់របស់តុលាការ ឬចំពោះជនដែលតុលាការ សម្រេចដោះលែងឱ្យមានសេរីភាព ដោយមានលក្ខខណ្ឌ ។

(ii) សេវាដែលមានលក្ខណៈយោធា និងកិច្ចការបំរើជាតិដែលតម្រូវតាមច្បាប់សម្រាប់អ្នកប្រឆាំងសង្គ្រាម នៅក្នុងប្រទេសដែលទទួលស្គាល់សិទ្ធិប្រឆាំងសង្គ្រាម ។

(iii) សេវាដែលតម្រូវក្នុងករណីមានអាសន្ន ឬគ្រោះមហន្តរាយ ដែលគំរាមកំហែងដល់អាយុជីវិត និងសុខមាលភាពសហគមន៍ ។

(iv) ការងារ ឬសេវាដែលជាផ្នែកនៃកាតព្វកិច្ចធម្មតារបស់ប្រជាពលរដ្ឋ ។

## មាត្រា ៩

១. ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ។

២. ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឱ្យគេ ប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីការចោទប្រកាន់ ។

៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង ។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជំរះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ ដំណាក់ការដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តន៍សាលក្រម ។

៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងការបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់ ។

៥. ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួនឬឃុំខ្លួនដោយខុសច្បាប់ មាន-សិទ្ធិទាមទារសំណង ។

## មាត្រា ១០

១. ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមនុស្សធម៌និងការគោរពចំពោះសេចក្ដីថ្លៃថ្នូរពីកំណើតរបស់មនុស្ស ។

២. (ក) ជនជាប់ចោទ ត្រូវដាក់ឱ្យនៅផ្សេងពីទណ្ឌិត លើកលែងតែក្នុងកាលៈទេសៈពិសេស ។ ជនជាប់ចោទ ត្រូវស្ថិតនៅក្រោមរបបដាច់ដោយឡែកដែល សមស្របទៅតាមលក្ខខណ្ឌរបស់ជនពុំទាន់មានទោស ។

(ខ) ជនជាប់ចោទជាអនីតិជន ត្រូវដាក់ផ្សេងពីនីតិជន ហើយត្រូវទទួលការជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើបាន ។

៣. ប្រព័ន្ធគ្រប់គ្រងពន្ធនាគារ ត្រូវមានការប្រព្រឹត្តទៅលើទណ្ឌិត ដែលមានគោលបំណងជាសារវ័ន្ត ដើម្បីស្តារនីតិសម្បទា និងបញ្ចូលពួកគេទៅក្នុងសង្គមវិញ ។ ទណ្ឌិតជាអនីតិជន ត្រូវបំបែកចេញពីនីតិជន ហើយត្រូវស្ថិតនៅក្នុងការប្រព្រឹត្តទៅលើពួកគេ សមស្របតាមអាយុ និងស្ថានភាពនីត្យានុកូលភាពរបស់គេ ។

## មាត្រា ១១

គ្មានជនណាម្នាក់ ត្រូវជាប់ពន្ធនាគារ ដោយសារតែខ្លួនពុំអាចបំពេញតាមកាតព្វកិច្ចនៃកិច្ចសន្យានោះឡើយ ។

## មាត្រា ១២

១. ជនណាដែលរស់នៅត្រឹមត្រូវ តាមលក្ខណៈច្បាប់ ក្នុងប្រទេសណាមួយ មានសិទ្ធិធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួនដោយសេរី ។

២. ជនគ្រប់រូប មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួន ផង ។

៣. សិទ្ធិដែលមានចែងខាងលើនេះ មិនត្រូវមានការរិតត្បិតឡើយ លើកលែងតែការរិតត្បិតនេះ មានចែងក្នុងច្បាប់ ចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពអ្នកដទៃ ហើយមិនទំនាស់ជាមួយសិទ្ធិដទៃទៀត ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ។

៤. គ្មានជនណាម្នាក់ ត្រូវបានដកសិទ្ធិតាមអំពើចិត្ត មិនឱ្យចូលក្នុងប្រទេស របស់ខ្លួនឡើយ ។

## មាត្រា ១៣

ជនបរទេស ឋិតនៅដោយស្របច្បាប់ លើដែនដីរដ្ឋភាគីនៃកតិកាសញ្ញានេះ នឹងអាចត្រូវបានបណ្តេញចេញពីរដ្ឋនោះបាន លុះត្រាតែធ្វើឡើង ដោយអនុលោមតាមសេចក្តីសម្រេចស្របតាមច្បាប់ លើកលែងតែការបណ្តេញចេញដោយហេតុផលបង្ខំ សម្រាប់រក្សាសន្តិសុខជាតិ ហើយជនបរទេសនេះ ត្រូវបានអនុញ្ញាតឱ្យដាក់ហេតុផលជំទាស់នឹងការបណ្តេញចេញនេះ និងសុំឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬមនុស្សម្នាក់ ឬច្រើននាក់ ដែលអាជ្ញាធរបានតែងតាំងជាពិសេស ពិនិត្យករណីរបស់ខ្លួនឡើងវិញ រួមទាំងឱ្យមានអ្នកការពារសិទ្ធិផងដែរ ។

## មាត្រា ១៤

១. ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី ។ ជនគ្រប់រូប ត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជំរះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី។ សារព័ត៌មាន និងសាធារណៈជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ សម្រាប់ផលប្រយោជន៍នៃទំនៀមទំលាប់ល្អ សណ្តាប់

ធ្លាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់បំផុតតាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេសដែលថា ការធ្វើជាសាធារណៈ នឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌ ។ ប៉ុន្តែ ការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ ។

២. ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មត់ជាមុនថា ជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់ ។

៣. ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូប មានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម ៖

(ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ ។

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង ។

(គ) ត្រូវបានជំនុំជំរះដោយឥតពន្យារពេលយូរហួសហេតុ ។

(ឃ) ត្រូវបានជំនុំជំរះដោយមានវត្តមានរបស់ខ្លួននិងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ ។

(ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នា នឹងសាក្សីដាក់បន្ទុក ។

(ច) ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទ មិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ ។

(ឆ) មិនត្រូវបានបង្ខិតបង្ខំ ឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថា មានពិរុទ្ធ ។

៤. នីតិវិធីអនុវត្តចំពោះយុវជន-យុវនារី ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ ។

៥. ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ ស្របតាមច្បាប់ ។

៦. នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមក ការប្រកាសឱ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោសដោយហេតុថា អង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់តុលាការ ជនដែលទទួលរងគ្រោះ ដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់បង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំង នៃការពិតទាន់ពេល បណ្តាលមកពីជននោះទាំងស្រុង ឬមួយផ្នែក ។

៧. គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ ។

## មាត្រា ១៥

១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោស ដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ ។ ប្រសិនបើ ក្រោយពីការប្រព្រឹត្តបទល្មើស ហើយច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ ។

២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជំរះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ ចំពោះអំពើ ឬការខកខានណាមួយដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ ។

## មាត្រា ១៦

ជនគ្រប់រូប មានសិទ្ធិឱ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តិរបស់ខ្លួននៅគ្រប់ទីកន្លែង ។

## មាត្រា ១៧

១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។

២. ជនគ្រប់រូប មានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ បែបនេះ ។

## មាត្រា ១៨

១. ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការកាន់ ឬគោរពសាសនា ឬជំនឿណាមួយ តាមការជ្រើសរើសរបស់ខ្លួន និងសេរីភាពក្នុងការសម្តែងសាសនា ឬជំនឿរបស់ខ្លួនដោយម្នាក់ៗឯង ឬដោយរួមជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជន តាមការគោរពបូជា ការប្រតិបត្តិតាមការអនុវត្តន៍ និងការបង្ហាត់បង្រៀន ។

២. គ្មានជនណាម្នាក់ ត្រូវរងការបង្ខិតបង្ខំឱ្យកាន់ ឬគោរពសាសនា ដែលបំពារបំពានធ្វើឱ្យខូចខាត ដល់សេរីភាពនៃការកាន់ ឬកាគោរពសាសនា ឬជំនឿ តាមការជ្រើសរើសរបស់ខ្លួនឡើយ ។

៣. សេរីភាពសម្តែងការគោរពសាសនា ឬជំនឿរបស់ខ្លួន នឹងអាចដាក់កម្រិតព្រំដែនបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដល់ការការពារ សន្តិសុខ-សាធារណៈ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់ ប្រសិនជាមានក្នុងការធានាដល់ការអប់រំខាងសាសនា និងសីលធម៌ដល់បុត្រធីតារបស់គេ ស្របតាមជំនឿរបស់គេ ។

## មាត្រា ១៩

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។

២. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិត សព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាម ទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ។

៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ច និង-ការទទួលខុសត្រូវពិសេស ។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី ៖

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ ។

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ។

## មាត្រា ២០

១. ការឃោសនាណាជាគុណប្រយោជន៍ដល់សង្គ្រាម ត្រូវហាមឃាត់ដោយច្បាប់ ។

២. ការអំពាវនាវណាឱ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនាដែល ជាការញុះញង់នាំឱ្យកើតមានការរើសអើង ការប្រទូស្តរាយ ឬអំពើហិង្សា ត្រូវហាមឃាត់ដោយច្បាប់ ។

## មាត្រា ២១

សិទ្ធិប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់ ។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារ-សុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និង សេរីភាពរបស់អ្នកដទៃ ។

## មាត្រា ២២

១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ

និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។ មាត្រានេះ មិនរារាំងដល់ការរឹតត្បិតខាងផ្លូវច្បាប់លើសមាជិកយោធា និងនគរបាលក្នុងការប្រើប្រាស់សិទ្ធិនេះទេ ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ អនុញ្ញាតឱ្យរដ្ឋភាគីនៃអនុសញ្ញា ឆ្នាំ១៩៤៨ របស់អង្គការពលកម្មអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារ-សិទ្ធិខាងសហជីព ចាត់វិធានការខាងផ្លូវច្បាប់ ឬអនុវត្តច្បាប់ តាមរបៀបដែលធ្វើឱ្យប៉ះពាល់ដល់ការធានា ដែលមានចែងក្នុងអនុសញ្ញានោះឡើយ ។

## មាត្រា ២៣

១. គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ។

២. សិទ្ធិរបស់មនុស្សប្រុស-ស្រីពេញវ័យ ក្នុងការរៀបអាពាហ៍ពិពាហ៍ និង ក្នុងការកសាងគ្រួសារ ត្រូវតែទទួលស្គាល់ ។

៣. គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រមដោយសេរី និង ពេញលេញពីអនាគតប្តី-ប្រពន្ធឡើយ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ ត្រូវចាត់វិធានការសមស្រប ដើម្បីធានាសមភាពខាងសិទ្ធិ និងការទទួលខុសត្រូវរបស់ប្តីប្រពន្ធ ចំពោះការរៀបអាពាហ៍ពិពាហ៍ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។ ក្នុងគ្រាដែលមានការរំលាយអាពាហ៍ពិពាហ៍ ត្រូវមានបទបញ្ញត្តិសម្រាប់ការការពារជាចាំបាច់ចំពោះ កូន ។

## មាត្រា ២៤

១. កុមារគ្រប់រូប មានសិទ្ធិទទួលបានវិធានការការពារ តម្រូវនឹងស្ថានភាពរបស់ខ្លួនជាអនីតិជន ពីសំណាក់គ្រួសាររបស់ខ្លួន សង្គម និងរដ្ឋ ដោយគ្មានការរើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ឬកំណើតឡើយ ។

២. កុមារគ្រប់រូប ត្រូវបានចុះឈ្មោះក្នុងបញ្ជីជាបន្ទាន់ បន្ទាប់ពីពេលកើត និង ត្រូវមានឈ្មោះ ។

៣. កុមារគ្រប់រូប មានសិទ្ធិបានសញ្ជាតិមួយ ។

មាត្រា ២៥

ដោយគ្មានការបែងចែក ដូចដែលបានចែងក្នុងមាត្រា២ និងដោយគ្មានការរិតត្បិតដែលមិនសមហេតុផល ប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិ និងមានឱកាស ៖

(ក) រួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរី ។

(ខ) បោះឆ្នោត និងឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ទៀងទាត់ ជាសកល ស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិ ដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត ។

(គ) ចូលបម្រើមុខងារសាធារណៈក្នុងប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌទូទៅដោយសមភាព ។

## មាត្រា ២៦

ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិការពារពីច្បាប់ស្មើគ្នា

ដោយឥតរើសអើង ។ ក្នុងប្រការនេះ ច្បាប់ត្រូវហាមការរើសអើង និងត្រូវធានាឱ្យជនគ្រប់រូបនូវការការពារស័ក្តិសិទ្ធិស្មើគ្នាប្រឆាំងការរើសអើងទាំងឡាយ មានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត ។

**មាត្រា ២៧**

ក្នុងរដ្ឋដែលមានក្រុមជនភាគតិចខាងជាតិពន្ធុ សាសនា ឬភាសា ជនដែលជាសមាជិកជនភាគតិចទាំងនេះ ដោយរួមនឹងសមាជិកដទៃទៀតនៃក្រុមរបស់ខ្លួន មិនត្រូវទទួលរងការរារាំង សិទ្ធិអាស្រ័យផលវប្បធម៌របស់ពួកគេ សិទ្ធិកាន់ និងប្រតិបត្តិ សាសនាតាមទម្លាប់ពួកគេ ឬសិទ្ធិប្រើប្រាស់ភាសារបស់ពួកគេឡើយ ។

## ផ្នែកទី ៤

**មាត្រា ២៨**

១. គណៈកម្មាធិការសិទ្ធិមនុស្សមួយ (បន្ទាប់ពីនេះទៅហៅថា គណៈកម្មាធិការ) ត្រូវបង្កើតឡើង ។ គណៈកម្មាធិការ មានសមាជិក ១៨រូប និងបំពេញមុខងារតាម-ការកំណត់ខាងក្រោម ។

២. គណៈកម្មាធិការ ត្រូវមានសមាជិកជាប្រជាពលរដ្ឋនៃរដ្ឋសមាជិកកតិកាសញ្ញានេះ ដែលជាមនុស្សមានអត្តចរិកសីលធម៌ខ្ពស់ និងសមត្ថភាព ដែលគេទទួលស្គាល់ក្នុងវិស័យសិទ្ធិមនុស្ស ដោយការគិតដល់ប្រយោជន៍ដែលបានមកពីការចូលរួមពីមនុស្សមួយចំនួន ដែលមានបទពិសោធន៍ខាងវិស័យច្បាប់ ។

៣. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត ហើយត្រូវធ្វើការក្នុងឋានៈជាបុគ្គល ។

## មាត្រា ២៩

១. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតជាសម្ងាត់ ពីបញ្ជីឈ្មោះបេក្ខជន ដែលមានគុណសម្បត្តិ តាមលក្ខខណ្ឌបញ្ញត្តិក្នុងមាត្រា ២៨ ហើយដែលជ្រើសតាំង ដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ។

២. រដ្ឋភាគីនីមួយៗ នៃកតិកាសញ្ញានេះ អាចជ្រើសតាំងបេក្ខជន ២ រូប យ៉ាងច្រើន ។ បេក្ខជនទាំងនេះ ត្រូវតែជាជនជាតិនៃរដ្ឋដែលជ្រើសតាំងបេក្ខជន ។

៣. បេក្ខជនដដែល អាចមានសិទ្ធិជ្រើសតាំងជាថ្មីទៀតបាន ។

## មាត្រា ៣០

១. ការបោះឆ្នោតលើកដំបូង ត្រូវធ្វើយ៉ាងយូរបំផុត ៦ខែ ក្រោយពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកតិកាសញ្ញានេះ ។

២. យ៉ាងតិច៤ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសសមាជិក សម្រាប់គណៈកម្មាធិការ ក្រៅពីការជ្រើសរើស ឱ្យបំពេញមុខងារទំនេរ ស្របតាមមាត្រា ៣៤ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ បញ្ជូនបញ្ជីបេក្ខជនរបស់ខ្លួន ក្នុងរយៈពេល៣ខែ សម្រាប់ធ្វើជាសមាជិកគណៈកម្មាធិការ ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវធ្វើបញ្ជីឈ្មោះបេក្ខជនទាំងអស់តាមឈ្មោះលំដាប់អក្ខរៈក្រម ដោយបញ្ជាក់ឈ្មោះរដ្ឋភាគីដែលបានជ្រើសតាំងបេក្ខជន

ហើយផ្ញើបញ្ជីនេះ ទៅរដ្ឋភាគីទាំងអស់នៃកតិកាសញ្ញានេះ យ៉ាងហោច ១ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ ។

៤. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើក្នុងពេលប្រជុំរដ្ឋភាគីនៃកតិកាសញ្ញានេះ ដែលកោះអញ្ជើញដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅទីស្នាក់ការនៃអង្គការនេះ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគីនៃកតិកាសញ្ញានេះ។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែ ជាបេក្ខជនដែលទទួលបាន សម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

## មាត្រា ៣១

១. គណៈកម្មាធិការ មិនអាចមានសមាជិកលើសពី ១រូប ដែលជាជនជាតិនៃរដ្ឋដដែលឡើយ ។

២. ក្នុងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើការពិចារណាបែងចែកសមាជិកភាព ទៅតាមភូមិសាស្ត្រដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង ។

## មាត្រា ៣២

១. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត សម្រាប់រយៈពេល ៤ឆ្នាំ ។ សមាជិកគណៈកម្មាធិការ អាចមានសិទ្ធិឈរឈ្មោះបោះឆ្នោតឡើងវិញ ប្រសិនបើមានការជ្រើសតាំងជាថ្មី ។ ប៉ុន្តែអាណត្តិសមាជិក៩រូប ដែលជាប់ឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយក្រោយពីការបោះឆ្នោតលើកទី១

ឈ្មោះសមាជិកទាំង ៩រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសជាបន្ទាន់ ដោយប្រធានអង្គប្រជុំ ដែលមានចែងក្នុង កថាខណ្ឌ៤ នៃមាត្រា៣០ ។

២. ពេលផុតអាណត្តិការងារ ការបោះឆ្នោត ត្រូវធ្វើឡើងឱ្យស្របតាមបទបញ្ញត្តិនៃ មាត្រាមុន៧ នៅក្នុងផ្នែកទី៤ នៃកតិកាសញ្ញានេះ ។

## មាត្រា ៣៣

១. ប្រសិនបើមានសមាជិកណាមួយនៃគណៈកម្មាធិការបានឈប់ធ្វើការងាររបស់ខ្លួន ក្រៅពីមូលហេតុអវត្តមានជាលក្ខណៈបណ្តោះអាសន្ន ប្រធានគណៈកម្មាធិការ តាមមតិឯកច្ឆ័ន្ទពីសមាជិកឯទៀត ត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជា-ជាតិ ហើយអគ្គលេខាធិការត្រូវប្រកាសពីអាសនៈទំនេររបស់សមាជិកនោះ ។

២. ក្នុងគ្រាមានមរណភាព ឬការលាឈប់ពីតំណែង របស់សមាជិកណាម្នាក់ ប្រធានគណៈកម្មាធិការ ត្រូវជូនដំណឹងភ្លាមទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវប្រកាសពីអាសនៈទំនេរ ចាប់ពីកាលបរិច្ឆេទ មរណភាព ឬការសុំលាលែងមានអានុភាព ។

## មាត្រា ៣៤

១. នៅពេលអាសនៈទំនេរ ត្រូវបានប្រកាសស្របតាមមាត្រា ៣៣ និងបើអាណត្តិ របស់សមាជិកដែលត្រូវដាក់ជំនួស មិនទាន់ផុតកំណត់ក្នុងរយៈពេល ៦ខែ បន្តពី-កាលបរិច្ឆេទនៃការប្រកាសអាសនៈទំនេរ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងឱ្យរដ្ឋភាគីទាំងអស់នៃកតិកាសញ្ញានេះ ក្នុងរយៈពេល២ខែ ឱ្យជ្រើស តាំងបេក្ខជន ស្របតាម បទបញ្ញត្តិនៃមាត្រា២៩ ដើម្បីបំពេញអាសនៈទំនេរនេះ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនជ្រើសតាំងតាមលំដាប់អក្ខរក្រម ហើយត្រូវផ្ញើបញ្ជីនេះ ទៅរដ្ឋភាគីនៃកតិកាសញ្ញានេះ ។ ការបោះឆ្នោតបំពេញអាសនៈទំនេរ ត្រូវធ្វើស្របតាមបទបញ្ញត្តិពាក់ព័ន្ធនៃផ្នែកទី៤ នៃកតិកាសញ្ញានេះ ។

៣. សមាជិកគណៈកម្មាធិការដែលជាប់ឆ្នោតបំពេញអាសនៈទំនេរ ដូចបានប្រកាសស្របតាមមាត្រា៣៣ ត្រូវបំពេញភារកិច្ចរហូតដល់ចប់អាណត្តិរបស់សមាជិកដែលទុកអាសនៈឱ្យទំនេរនៅក្នុងគណៈកម្មាធិការ ស្របតាមបទបញ្ញត្តិនៃមាត្រានោះ។

**មាត្រា ៣៥**

សមាជិកគណៈកម្មាធិការទទួលបរិលាភពីធនធានរបស់អង្គការសហប្រជាជាតិ តាម-ការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងលក្ខខណ្ឌកំណត់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ទៅតាមសារសំខាន់នៃមុខងាររបស់គណៈកម្មាធិការ ។

**មាត្រា ៣៦**

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងសម្ភារៈរូបវ័ន្តចាំបាច់ ដើម្បីឱ្យគណៈកម្មាធិការ បំពេញមុខងារឱ្យបានស័ក្តិសិទ្ធិ ស្របតាមកតិកាសញ្ញានេះ ។

**មាត្រា ៣៧**

១. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះសមាជិកគណៈកម្មាធិការឱ្យមកប្រជុំជាលើកទី១ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

២. ក្រោយពីកិច្ចប្រជុំលើកទី១ គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំគ្រប់ពេលដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៣. តាមធម្មតា គណៈកម្មាធិការ ត្រូវប្រជុំនៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬ នៅការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ។

**មាត្រា ៣៨**

មុននឹងទទួលតំណែង សមាជិកគណៈកម្មាធិការទាំងអស់ត្រូវប្រកាសជាឧឡារិក នៅចំពោះមុខអង្គប្រជុំថា នឹងបំពេញមុខងាររបស់ខ្លួន ដោយគ្មានលំអៀង និងដោយសតិសម្បជញ្ញៈ ។

**មាត្រា ៣៩**

១. គណៈកម្មាធិការ ត្រូវបោះឆ្នោតជ្រើសរើស មន្ត្រីការិយាល័យរបស់ខ្លួន សម្រាប់រយៈពេល២ឆ្នាំ ។ មន្ត្រីការិយាល័យទាំងអស់ អាចត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មីទៀតបាន ។

២. គណៈកម្មាធិការត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ ប៉ុន្តែ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវមានបទបញ្ញត្តិដូចខាងក្រោមនេះ បន្ថែមលើបទបញ្ញត្តិដទៃទៀត ៖

(ក) កូរ៉ុម ត្រូវមានសមាជិក ១២នាក់ ។

(ខ) សេចក្តីសម្រេចរបស់គណៈកម្មាធិការ ត្រូវធ្វើឡើងដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

**មាត្រា ៤០**

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាបង្ហាញរបាយការណ៍ ស្តីពីវិធានការ ដែលបានអនុម័ត អនុវត្តសិទ្ធិដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ និងរបាយការណ៍ស្តីពីការរីកចម្រើន ដែលសម្រេចបាន ក្នុងការអាស្រ័យផលនៃសិទ្ធិទាំងនេះ ៖

(ក) ក្នុងរយៈពេល១ឆ្នាំ គិតពីថ្ងៃចូលជាធរមាននៃកតិកាសញ្ញានេះចំពោះរដ្ឋភាគីពាក់ព័ន្ធ ។

(ខ) រាល់លើកដែលគណៈកម្មាធិការធ្វើសំណើ ។

២. របាយការណ៍ទាំងអស់ ត្រូវដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវបញ្ជូនរបាយការណ៍ទាំងនោះ ទៅគណៈកម្មាធិការដើម្បីពិនិត្យ ។ ប្រសិនបើមានរបាយការណ៍ ត្រូវបញ្ជាក់ពីកត្តា និងឧបសគ្គ ដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តន៏នៃកតិកាសញ្ញានេះ ។

៣. ក្រោយពីការពិគ្រោះជាមួយគណៈកម្មាធិការ អគ្គលេខាធិការអង្គការសហប្រជាជាតិ អាចបញ្ជូនទៅស្ថាប័នឯកទេសពាក់ព័ន្ធ នូវសេចក្តីចម្លងគ្រប់ភាគនៃរបាយការណ៍ដែលអាចស្ថិតក្នុងវិស័យនៃសមត្ថកិច្ចរបស់ស្ថាប័នទាំងនោះ ។

៤. គណៈកម្មាធិការ ត្រូវសិក្សារបាយការណ៍ដែលដាក់ជូនដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ។ គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍របស់ខ្លួន ព្រមទាំងយោបល់ទូទៅ ដែលគណៈកម្មាធិការពិនិត្យឃើញថា សមស្របទៅឱ្យរដ្ឋភាគីទាំងអស់ ។ គណៈកម្មាធិការ អាចបញ្ជូនយោបល់ទាំងនេះទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ដោយភ្ជាប់ជាមួយច្បាប់ចម្លងនៃរបាយការណ៍នានា ដែលគណៈកម្មាធិការបានទទួលពី រដ្ឋភាគីនៃកតិកាសញ្ញានេះ ។

៥. រដ្ឋភាគីនៃកតិកាសញ្ញានេះអាចដាក់ជូនគណៈកម្មាធិការនូវសេចក្តីសង្កេតលើការផ្តល់យោបល់ ដែលអាចត្រូវធ្វើឡើង ស្របតាមកថាខណ្ឌ៤ នៃមាត្រានេះ ។

## មាត្រា ៤១

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចប្រកាសនៅគ្រប់ពេលវេលា ស្របតាម-

មាត្រានេះ ថាខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួល និង-ពិនិត្យបណ្តឹងពីរដ្ឋភាគី ដែលអះអាងថា រដ្ឋភាគីមួយទៀត មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ស្របតាមកតិកាសញ្ញានេះ ។ បណ្តឹងនេះ អាចទទួល និងពិនិត្យបាន លុះត្រាតែរដ្ឋភាគី បានធ្វើសេចក្តីប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ចំពោះរដ្ឋនេះ ។ គណៈកម្មាធិការ មិនត្រូវទទួលបណ្តឹងរបស់រដ្ឋភាគី ដែលមិនបាន ធ្វើ-សេចក្តីប្រកាសទទួលស្គាល់ឡើយ ។ បណ្តឹងស្របតាមមាត្រានេះ ត្រូវដោះស្រាយស្របតាមនីតិវិធីខាងក្រោម ៖

(ក) បើរដ្ឋភាគីមួយនៃកតិកាសញ្ញានេះ យល់ឃើញថា រដ្ឋភាគីមួយទៀត មិនអនុវត្តបទបញ្ញត្តិនៃកតិកាសញ្ញានេះ រដ្ឋភាគីម្ខាង អាចនាំយកបញ្ហា តាមរយៈបណ្តឹងជាលាយល័ក្ខណ៍អក្សរ មកបង្ហាញឱ្យរដ្ឋភាគីម្ខាងទៀត ពិនិត្យពិចារណា ។ ក្នុងរយៈពេល ៣ខែ ក្រោយពីបានទទួលបណ្តឹងរដ្ឋចុងបណ្តឹង ត្រូវផ្តល់ការពន្យល់ ឬសេចក្តីប្រកាសជាលាយល័ក្ខណ៍អក្សរ បំភ្លឺបញ្ហាតាមកម្រិត ដែលអាចធ្វើបាន និង ដោយចំៗ ជូនរដ្ឋដើមបណ្តឹង ដែលមានយោងនីតិវិធី និងដំណោះស្រាយនៅក្នុងប្រទេសដែលបានធ្វើ ហើយដែលមិនទាន់សម្រេច ឬដែលនៅបើកចំហ ។

(ខ) បើបញ្ហាមិនត្រូវបានដោះស្រាយឱ្យពេញចិត្ត រវាងរដ្ឋជាប់ពាក់ព័ន្ធទាំងពីរ ក្នុងរយៈពេល៦ខែ ចាប់ពីថ្ងៃទទួលបណ្តឹងដំបូងដោយរដ្ឋចុងបណ្តឹង រដ្ឋណាមួយក៏បាន មានសិទ្ធិបញ្ជូនបញ្ហាទៅគណៈកម្មាធិការ ដោយជូនដំណឹងទៅគណៈកម្មាធិការ និងរដ្ឋម្ខាងទៀត ។

(គ) គណៈកម្មាធិការ អាចដោះស្រាយបញ្ហា ដែលបញ្ជូនឱ្យមកខ្លួនបាន លុះត្រាតែគណៈកម្មាធិការ បានរកឃើញថា មធ្យោបាយខាងផ្លូវច្បាប់ទាំងអស់ដែល មាននៅក្នុងប្រទេសនោះ ត្រូវបានយកមកប្រើអស់លទ្ធភាព ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិដែលទទួលស្គាល់ជាទូទៅ ។ វិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយ បន្តយូរហួសហេតុ ។

(ឃ) គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំរបស់ខ្លួនដោយសម្ងាត់ នៅពេលពិនិត្យបណ្ដឹង ស្របតាមមាត្រានេះ ។

(ង) យោងតាមបទបញ្ញត្តិក្នុងអនុកថាខណ្ឌ(គ) គណៈកម្មាធិការ ត្រូវដាក់សេវារបស់ខ្លួនឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីឈានទៅដល់ដំណោះស្រាយស្រុះស្រួលលើបញ្ហា ផ្អែកលើមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

(ច) បញ្ហាណាដែលបញ្ជូនមកគណៈកម្មាធិការស្របតាមអនុកថាខណ្ឌ(ខ) គណៈកម្មាធិការ អាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ផ្ដល់ព័ត៌មានពាក់ព័ន្ធបន្ថែម មកគណៈកម្មាធិការ ។

(ឆ) រដ្ឋភាគីពាក់ព័ន្ធ យោងតាមអនុកថាខណ្ឌ(ខ) មានសិទ្ធិមានវត្តមានតំណាងរបស់ខ្លួននៅពេលគណៈកម្មាធិការកំពុងពិនិត្យបញ្ហា និងមានសិទ្ធិស្នើយោបល់ដោយផ្ទាល់មាត់ និង/ឬជាលាយល័ក្ខណ៍អក្សរ ។

(ជ) ក្នុងរយៈពេល ១២ខែ ក្រោយពីកាលបរិច្ឆេទទទួលដំណឹង ដូចចែងក្នុងអនុកថាខណ្ឌ(ខ) គណៈកម្មាធិការ ត្រូវដាក់ជូនរបាយការណ៍មួយ ៖

(i) ប្រសិនបើដំណោះស្រាយមួយ ត្រូវបានរកឃើញ ស្របតាមបទបញ្ញត្តិនៅក្នុងអនុកថាខណ្ឌ (ង) គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្ដីថ្លែង-ការណ៍សង្ខេបស្ដីពីអង្គហេតុ និងដំណោះស្រាយដែលបានរកឃើញ ។

(ii) ប្រសិនបើដំណោះស្រាយណាមួយមិនអាចរកឃើញ ស្របតាមបទបញ្ញត្តិនៃអនុកថាខណ្ឌ (ង)ទេ គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែ-ជាសេចក្ដីថ្លែងការណ៍ សង្ខេបស្ដីពីអង្គហេតុ។ ការស្នើយោបល់ជាលាយល័ក្ខណ៍អក្សរ និងកំណត់ត្រានៃការស្នើយោបល់ផ្ទាល់មាត់ ដោយរដ្ឋភាគីពាក់ព័ន្ធ ត្រូវភ្ជាប់ទៅនឹងរបាយការណ៍ ។

នៅគ្រប់បញ្ហាទាំងអស់របាយការណ៍ ត្រូវផ្សាយឱ្យរដ្ឋភាគីពាក់ព័ន្ធបានដឹង ។

២. បទបញ្ញត្តិនៃមាត្រានេះនឹងចូលជាធរមាន នៅពេលដែលរដ្ឋភាគីចំនួន ១០ នៃកតិកាសញ្ញានេះ បានធ្វើសេចក្តីប្រកាស ស្របតាមកថាខណ្ឌ១នៃមាត្រានេះ។ សេចក្តីប្រកាសនេះ ត្រូវតំកល់ទុកដោយរដ្ឋភាគី នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវផ្ញើច្បាប់ចម្លងទៅឱ្យរដ្ឋភាគីទាំងអស់។ សេចក្តីប្រកាស អាចដកទៅវិញបានគ្រប់ពេលដោយជូនដំណឹងទៅអគ្គលេខាធិការ។ ការដកទៅវិញនេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការពិនិត្យបញ្ហាណាដែលជាកម្មវត្ថុនៃបណ្តឹងដែលផ្ញើរួចហើយ ស្របតាមមាត្រានេះឡើយ ហើយបណ្តឹងបន្ថែមពីរដ្ឋភាគី នឹងឈប់ទទួល ក្រោយពីអគ្គលេខាធិការបានទទួលការជូនដំណឹងពីការដក លើកលែងតែរដ្ឋភាគីពាក់ព័ន្ធបានធ្វើសេចក្តីប្រកាសជាថ្មី ។

## មាត្រា ៤២

១. (ក) បើបញ្ហាដែលដាក់ជូនគណៈកម្មាធិការ ស្របតាមមាត្រា៤១ មិនត្រូវបានដោះស្រាយជាទីពេញចិត្តដល់រដ្ឋភាគីពាក់ព័ន្ធទេ គណៈកម្មាធិការ ដោយមានការយល់ព្រមជាមុនពីរដ្ឋភាគីពាក់ព័ន្ធ អាចចាត់តាំងគណៈកម្មការផ្សះផ្សារចំពោះកិច្ចមួយ(បន្ទាប់ពីនេះទៅហៅថា គណៈកម្មការ)។ គណៈកម្មការ ត្រូវដាក់សេវារបស់ខ្លួន ឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីរកដំណោះស្រាយសម្រុះសម្រួលលើបញ្ហានោះ ដោយគោរពតាមកតិកាសញ្ញានេះ ។

(ខ) គណៈកម្មការត្រូវមានសមាជិក៥រូប ដែលមានការយល់ព្រមពីរដ្ឋភាគីពាក់ព័ន្ធ។ បើរដ្ឋភាគីពាក់ព័ន្ធ មិនឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ឬផ្នែកខ្លះ លើសមាសភាពគណៈកម្មការ ក្នុងរយៈពេល ៣ខែទេ សមាជិកគណៈកម្មការណា

ដែលមិនបានទទួលការយល់ព្រម ត្រូវដាក់ឱ្យជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ ដោយយកសម្លេង ភាគច្រើនពីរភាគបីនៃចំណោមសមាជិកគណៈកម្មាធិការ ។

២. សមាជិកគណៈកម្មការ ត្រូវបំពេញតួនាទីជាបុគ្គល។ សមាជិកគណៈកម្មការ មិនត្រូវជាជនជាតិនៃរដ្ឋភាគីពាក់ព័ន្ធ ឬនៃរដ្ឋដែលមិនមែនជាភាគីនៃកតិកាសញ្ញានេះ ឬនៃរដ្ឋភាគីដែលមិនបានធ្វើសេចក្តីប្រកាសដូចចែងក្នុងមាត្រា៤១ ។

៣. គណៈកម្មការ ត្រូវបោះឆ្នោតជ្រើសរើសប្រធាន និងអនុម័តបទបញ្ជាផ្ទៃក្នុង របស់ខ្លួន ។

៤. គណៈកម្មការ ត្រូវប្រជុំជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ។ ប៉ុន្តែ កិច្ចប្រជុំ អាចធ្វើទៅបាន នៅកន្លែងសមស្របដទៃទៀតដែលគណៈកម្មការអាចកំណត់ ដោយពិគ្រោះយោបល់ជាមួយ អគ្គលេខាធិការអង្គការសហប្រជាជាតិ និងរដ្ឋភាគីពាក់ព័ន្ធ។

៥. លេខាធិការដ្ឋាន ដែលមានចែងក្នុងមាត្រា៣៦ ត្រូវជួយគណៈកម្មការ ដែលបានចាត់តាំង ស្របតាមមាត្រានេះ ។

៦. ព័ត៌មានដែលគណៈកម្មាធិការ ទទួល និងប្រមូលបាន ត្រូវទុកឱ្យគណៈកម្មការប្រើប្រាស់ ហើយគណៈកម្មការ អាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

៧. នៅពេលដែលគណៈកម្មការបានពិនិត្យបញ្ហាសព្វគ្រប់ហើយ យ៉ាងយូរ ១២ខែ ក្រោយពីការសិក្សាបញ្ហាចប់ គណៈកម្មការ ត្រូវផ្ញើរបាយការណ៍ទៅប្រធានគណៈកម្មាធិការ ដើម្បីឆ្លើយឆ្លងទៅរដ្ឋភាគីពាក់ព័ន្ធ ៖

(ក) បើគណៈកម្មការមិនអាចបញ្ចប់ការពិនិត្យបញ្ហា ក្នុងរយៈពេល១២ខែ ទេ គណៈកម្មការ ត្រូវកម្រិតរបាយការណ៍ ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបស្តីពីស្ថានភាពនៃការពិនិត្យបញ្ហាតែប៉ុណ្ណោះ។

(ខ) ផ្អែកលើការគោរពសិទ្ធិមនុស្សដូចបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ បើដំណោះស្រាយស្រុះស្រួលគ្នាលើបញ្ហាអាចធ្វើបានសម្រេចហើយ នោះគណៈកម្មការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្ដីថ្លែងការណ៍សង្ខេបលើអង្គហេតុ និងដំណោះស្រាយដែលសម្រេចបាន ។

(គ) បើដំណោះស្រាយតាមលក្ខខណ្ឌនៃអនុកថាខណ្ឌ(ខ) មិនអាចសម្រេចបានទេ របាយការណ៍របស់គណៈកម្មការ ត្រូវបង្ហាញសេចក្ដីសន្និដ្ឋានលើគ្រប់ចំណុចនៃអង្គហេតុទាក់ទងនឹងបញ្ហានានារវាងរដ្ឋភាគីពាក់ព័ន្ធ និងបង្ហាញយោបល់ស្ដីពីលទ្ធភាពនៃដំណោះស្រាយ ស្រុះស្រួលគ្នាលើបញ្ហា។ របាយការណ៍នេះ ត្រូវមានផងដែរនូវការផ្ដល់យោបល់ជាលាយល័ក្ខណ៍អក្សរ និងសំណុំរឿងទាំងមូលនៃការផ្ដល់យោបល់ផ្ទាល់មាត់ដោយភាគីពាក់ព័ន្ធ ។

(ឃ) បើរបាយការណ៍របស់គណៈកម្មការ បានដាក់ជូនស្របតាមអនុកថាខណ្ឌ(គ) ខាងលើនោះ រដ្ឋភាគីពាក់ព័ន្ធ ត្រូវជំរាបទៅប្រធាននៃគណៈកម្មាធិការក្នុងរយៈពេល៣ខែ ចាប់ពីថ្ងៃបានទទួលរបាយការណ៍ ថាតើព្រមទទួលឬមិនព្រមទទួលអត្ថន័យនៃរបាយការណ៍របស់គណៈកម្មការ ។

៨. បទបញ្ញត្តិនៃមាត្រានេះ មិនប៉ះពាល់ដល់មុខការរបស់គណៈកម្មាធិការ ដូចមានចែងក្នុង-មាត្រា ៤១ ឡើយ ។

៩. ចំណាយទាំងអស់របស់សមាជិកគណៈកម្មការ ត្រូវបែងចែកស្មើគ្នារវាង រដ្ឋភាគីពាក់ព័ន្ធស្របតាមការប៉ាន់ស្មាន ដែលកំណត់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

១០. ប្រសិនបើចាំបាច់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវមានសិទ្ធិចំណាយ ជួសទៅលើសមាជិកគណៈកម្មការ មុនមានសំណងពីរដ្ឋភាគីពាក់ព័ន្ធ ស្របតាមកថាខណ្ឌ៩ នៃមាត្រានេះ ។

## មាត្រា ៤៣

សមាជិកនៃគណៈកម្មាធិការ និងគណៈកម្មការសម្រុះសម្រួលចំពោះកិច្ចដែល តែងតាំង ស្របតាមមាត្រា៤២ មានសិទ្ធិប្រើប្រាស់សម្ភារៈរូបវ័ន្ត មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៃអ្នកជំនាញការក្នុងបេសកកម្មរបស់អង្គការសហប្រជាជាតិ ដូចមានចែងក្នុងផ្នែកពាក់ព័ន្ធ នៃអនុសញ្ញាស្តីអំពីបុព្វសិទ្ធ និងអភ័យឯកសិទ្ធរបស់អង្គការសហប្រជាជាតិ ។

## មាត្រា ៤៤

បទបញ្ញត្តិសម្រាប់អនុវត្តអនុសញ្ញានេះ ត្រូវអនុវត្តដោយមិនត្រូវធ្វើឱ្យប៉ះពាល់ ដល់នីតិវិធីដែលបានចែងក្នុងវិស័យសិទ្ធិមនុស្ស ស្របតាមលិខិតុបករណ៍ផ្សេងៗ និងអនុសញ្ញា របស់សហប្រជាជាតិ និងស្ថាប័នឯកទេសឡើយ ហើយមិនត្រូវរារាំងរដ្ឋភាគីនៃអនុសញ្ញានេះ ក្នុងការប្រើនីតិវិធីដទៃទៀត ដើម្បីដោះស្រាយជម្លោះ ស្របតាមកិច្ច ព្រមព្រៀងអន្តរជាតិទូទៅ ឬពិសេស ដែលចងរដ្ឋភាគីឡើយ ។

## មាត្រា ៤៥

គណៈកម្មាធិការត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពរបស់ខ្លួនឱ្យមហា សន្និបាតអង្គការសហប្រជាជាតិ តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច។

# ផ្នែកទី ៥

## មាត្រា ៤៦

គ្មានបទបញ្ញត្តិណាមួយក្នុងកតិកាសញ្ញានេះ ត្រូវយកមកបកស្រាយធ្វើឱ្យប៉ះពាល់ ដល់បទបញ្ញត្តិទាំងឡាយ នៃធម្មនុញ្ញសហប្រជាជាតិ និងរដ្ឋធម្មនុញ្ញនៃស្ថាប័នឯកទេសនានា

ដែលកំណត់ការទទួលខុសត្រូវរបស់អង្គការនានានៃសហប្រជាជាតិ និងស្ថាប័នឯកទេស ចំពោះបញ្ហាពាក់ព័ន្ធនឹងកតិកាសញ្ញានេះឡើយ ។

## មាត្រា ៤៧

គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ ត្រូវយកមកបកស្រាយ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិពីកំណើតរបស់ប្រជាជាតិទាំងអស់ ក្នុងការអាស្រ័យផល និងប្រើប្រាស់ពេញលេញ និងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួនឡើយ ។

# ផ្នែកទី ៦

## មាត្រា ៤៨

១. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខាសម្រាប់រដ្ឋសមាជិកសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយឬជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬជារដ្ឋផ្សេងទៀត ដែលត្រូវបានអញ្ជើញដោយមហាសន្និបាតសហប្រជាជាតិ ដើម្បីក្លាយជាភាគីនៃកតិកាសញ្ញានេះ ។

២. កតិកាសញ្ញានេះជាកម្មវត្ថុនៃការឱ្យសច្ចាប័ន។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់ចូលជាសមាជិក ដូចចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

៤. ការចូលជាសមាជិក ត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ ដែលបានចុះហត្ថលេខាលើកតិកាសញ្ញានេះឬដែលបានចូលជាសមាជិកនៃកតិកាសញ្ញានេះ អំពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិក ។

## មាត្រា ៤៩

១. កតិកាសញ្ញានេះចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទី៣៥ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃកតិកាសញ្ញានេះ បន្ទាប់ពីសមាជិកទី៣៥ កតិកាសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពី-កាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ ។

## មាត្រា ៥០

បទបញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធដោយគ្មានការកម្រិត ឬលើកលែងឡើយ ។

## មាត្រា ៥១

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចស្នើធ្វើវិសោធនកម្ម និងដាក់សេចក្ដីស្នើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបញ្ជូនសេចក្ដីស្នើវិសោធនកម្មនេះ ទៅរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ ថាតើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បី

ពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើវិសោធនកម្មឬទេ ។ ក្នុងករណីមានសម្លេង ១ភាគ៣យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទ ក្រោមការឧបត្ថម្ភ របស់អង្គការសហប្រជាជាតិ។ គ្រប់វិសោធនកម្មដែលអនុម័ត ដោយមតិភាគ-ច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាត អង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មទាំងនេះ នឹងចូលជាធរមាន នៅពេលទទួលបានការយល់ព្រមពីមហាសន្និបាត អង្គការសហប្រជាជាតិ និងទទួលបានការអនុម័ត ដោយមតិភាគច្រើន២ភាគ៣នៃរដ្ឋភាគី នៃកតិកាសញ្ញានេះ ស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលដែលវិសោធនកម្មទាំងនោះចូលជាធរមានហើយ វិសោធនកម្មទាំងនោះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគី ដែលព្រមទទួលយកវិសោធនកម្មទាំងនោះ ឯរដ្ឋភាគីផ្សេងទៀតដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃ កតិកាសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានព្រមទទួលយករួចហើយ ។

**មាត្រា ៥២**

ក្រៅពីការជូនដំណឹងទាំងឡាយដែលមានចែងនៅក្នុងកថាខណ្ឌ៥នៃមាត្រា៤៨ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជម្រាបជូនរដ្ឋទាំងឡាយ ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ នូវ ៖

(ក) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការសុំចូលជាសមាជិក យោងតាមមាត្រា ៤៨ ។

(ខ) កាលបរិច្ឆេទ នៃការចូលជាធរមាននៃកតិកាសញ្ញានេះ យោងតាមមាត្រា៤៩ និងកាល-បរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មទាំងឡាយ យោងតាមមាត្រា៥១ ។

## មាត្រា ៥៣ ៥

១. កតិកាសញ្ញានេះដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញ មានតម្លៃស្មើគ្នា និងត្រូវតំកល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ជូនដល់រដ្ឋទាំងឡាយ យោងតាម-មាត្រា៤៨ ។

## ឧបសម្ព័ន្ធ ៣

# កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## បុព្វកថា

*រដ្ឋភាគីនៃកតិកាសញ្ញានេះ :*

*យល់ឃើញថា* ស្របតាមគោលការណ៍ ដែលបានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងការទទួលស្គាល់សិទ្ធិស្មើគ្នា និងមិនអាចលក់ដូរផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់ នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ទទួលស្គាល់ថា* សិទ្ធិទាំងនេះកើតចេញមកពីសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស ។

*ទទួលស្គាល់ថា* ស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឧត្តមគតិនៃមនុស្ស សេរីភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព អាចសម្រេចជោគជ័យទៅបាន លុះត្រាតែបង្កើតបានលក្ខខណ្ឌដែលឱ្យមនុស្សម្នាក់ៗ អាចប្រើប្រាស់បាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ខ្លួន ។

*យល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិ តម្រូវឱ្យរដ្ឋនានានូវកាតព្វកិច្ចលើកស្ទួយការគោរពជាសកល និងការប្រតិបត្តិនូវសិទ្ធិ និងសេរីភាពរបស់មនុស្ស ។

*យល់ថា* បុគ្គលម្នាក់ៗ មានករណីយកិច្ចចំពោះអ្នកដទៃ និងសហគមន៍ដែលខ្លួនរស់ នៅ

មានការទទួលខុសត្រូវក្នុងការខិតខំលើកស្ទួយ និងធ្វើឱ្យមានការប្រតិបត្តិសិទ្ធិដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

*ព្រមព្រៀងលើមាត្រាទាំងឡាយដូចតទៅ :*

## ផ្នែកទី ១

### មាត្រា ១

១. ប្រជាជាតិទាំងអស់មានសិទ្ធិស្វ័យសម្រេច ។ ដោយអាស្រ័យនូវសិទ្ធិនេះ ប្រជាជាតិទាំងនោះ កំណត់ដោយសេរីនូវឋានៈនយោបាយ និងខិតខំអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ខ្លួនដោយសេរី ។

២. ដើម្បីសម្រេចគោលដៅរបស់ខ្លួន ប្រជាជាតិទាំងអស់អាចចាត់ចែងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួន ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចដែលចេញ មកពីសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដែលផ្អែកលើគោលការណ៍នៃផលប្រយោជន៍ទៅវិញ ទៅមក និងគោល-ការណ៍នៃច្បាប់អន្តរជាតិ ។ គ្មានករណីណាមួយ ដែលប្រជាជាតិនីមួយៗ ត្រូវបានដកហូតមធ្យោបាយផ្ទាល់របស់ខ្លួន សម្រាប់ចិញ្ចឹមជីវិតនោះឡើយ ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ រួមទាំងរដ្ឋនានាដែលមានការទទួលខុសត្រូវគ្រប់គ្រងទឹកដីអស្វយ័ត និងទឹកដីអាណាព្យាបាល ត្រូវលើកស្ទួយធ្វើឱ្យបានសម្រេចនូវសិទ្ធិស្វ័យសម្រេច និងត្រូវគោរពសិទ្ធិនេះ ស្របតាមបទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ ។

# ផ្នែកទី ២

## មាត្រា ២

១. រដ្ឋភាគីនីមួយៗនៃកតិកាសញ្ញានេះ ដោយការប្រឹងប្រែងរបស់ខ្លួនឯងផ្ទាល់ និងតាមរយៈជំនួយ និងសហប្រតិបត្តិការអន្តរជាតិ ជាពិសេសខាងសេដ្ឋកិច្ច និង-បច្ចេកទេស សន្យាចាត់វិធានការ ប្រើប្រាស់ជាអតិបរមានូវធនធានដែលខ្លួនមានសម្រាប់ធ្វើឱ្យមានការរីកចម្រើនជាលំដាប់ ពីការសម្រេចបានដោយពេញលេញនូវសិទ្ធិទាំងអស់ ដែលទទួលស្គាល់ក្នុង កតិកាសញ្ញានេះ តាមគ្រប់មធ្យោបាយសមស្រប រួមមានជាពិសេស ការអនុម័តវិធានការខាងច្បាប់ផង ។

២. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាថា សិទ្ធិទាំងឡាយដែលចែងក្នុងកតិកាសញ្ញានេះ នឹងត្រូវប្រើប្រាស់ ដោយគ្មានការរើសអើងណាមួយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ភាសា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យ សម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ ។

៣. ប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ដោយគិតគូរឱ្យបានត្រឹមត្រូវ ដល់សិទ្ធិមនុស្ស និងសេ-ដ្ឋកិច្ចជាតិរបស់ខ្លួន អាចកំណត់ដល់កម្រិតត្រឹមណាមួយដែលខ្លួនធានាសិទ្ធិសេដ្ឋកិច្ចដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ដល់អ្នកដែលពុំមែនជាប្រជាពលរដ្ឋខ្លួន ។

## មាត្រា ៣

រដ្ឋភាគីនៃកតិកាសញ្ញានេះសន្យាធានានូវសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការអាស្រ័យផលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទាំងអស់ដែលមានចែងនៅក្នុងកតិកាសញ្ញានេះ ។

## មាត្រា ៤

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា ក្នុងការទទួលបានសិទ្ធិទាំងឡាយដែលធានាដោយរដ្ឋ ស្របតាមកតិកាសញ្ញានេះ រដ្ឋអាចដាក់សិទ្ធិទាំងនេះឱ្យមានព្រំដែនដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ ដោយឱ្យស្របទៅនឹងប្រភេទនៃសិទ្ធិទាំងនេះ និងសម្រាប់តែដើម្បីលើកស្ទួយសុខុមាលភាពទូទៅប៉ុណ្ណោះ នៅក្នុងសង្គមប្រជាធិបតេយ្យ ។

## មាត្រា ៥

១. គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ អាចត្រូវបានគេបកស្រាយតម្រូវថា រដ្ឋណាមួយ ក្រុមណាមួយ បុគ្គលណាម្នាក់ មានសិទ្ធិណាមួយ ធ្វើសកម្មភាពណាមួយ ឬ ប្រព្រឹត្តិអំពើណាមួយ សំដៅទៅបំផ្លិចបំផ្លាញសិទ្ធិ ឬសេរីភាព ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះឬសំដៅទៅដាក់កម្រិតដែលមានវិសាលភាពធំជាងកម្រិតដែលបានចែងនៅក្នុងកតិកា សញ្ញានេះ ។

២. មិនត្រូវធ្វើការរិតត្បិត ឬធ្វើបដិបញ្ញត្តិណាមួយ ទៅលើសិទ្ធិមនុស្សជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ ឬនៅជាធរមាននៅក្នុងរដ្ឋភាគីទាំងឡាយនៃកតិកាសញ្ញានេះ ដោយ អនុលោមទៅតាមច្បាប់ អនុសញ្ញា បទបញ្ជា ឬទំនៀមទំលាប់ទាំងឡាយ ដោយយកលេស ថា កតិកាសញ្ញានេះ មិនទទួលស្គាល់ ឬទទួលស្គាល់សិទ្ធិទាំងនោះនៅក្នុងកម្រិតតិចជាង ។

# ផ្នែកទី ៣

## មាត្រា ៦

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិធ្វើការងារ រួមមានសិទ្ធិរបស់មនុស្ស គ្រប់រូប មានលទ្ធភាពចិញ្ចឹមជីវិតដោយការងារដែលជ្រើសរើស ឬព្រមទទួលយកដោយសេរី និង-ចាត់វិធានការសមស្រប ដើម្បីការពារសិទ្ធិនេះ ។

២. វិធានការដែលរដ្ឋភាគីនៃកតិកាសញ្ញានេះប្រកាន់យក ដើម្បីធានាការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ ត្រូវរួមបញ្ចូល ការតម្រង់ទិសខាងបច្ចេកទេស និងវិជ្ជាជីវៈ និងកម្មវិធី បណ្ដុះបណ្ដាលគោលនយោបាយ និងបច្ចេកទេស ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍ថេរ ខាង វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការងារពេញលេ-ញដែលមានផលប្រយោជន៍ក្នុង លក្ខខណ្ឌការពារ សេរីភាពជាមូលដ្ឋានខាងនយោបាយ និងសេដ្ឋកិច្ចចំពោះបុគ្គលគ្រប់រូប ។

## មាត្រា ៧

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប ដើម្បីទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងប្រកបដោយអំណោយផល ដែលធានាជាពិសេសនូវ :

(ក) ប្រាក់កម្រៃដែលផ្ដល់ជាអប្បបរមាឱ្យអ្នកធ្វើការ នូវ:

១. ប្រាក់ឈ្នួលប្រកបដោយសមធម៌ និងប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា ដោយមិនមានការបែងចែកណាមួយ ជាពិសេសស្ត្រីត្រូវតែមានការធានានូវលក្ខខណ្ឌ ការងារដែលផ្ដល់ឱ្យពួកគេ មិនតិច-ជាងលក្ខខណ្ឌដែលបុរសបានទទួល ដោយត្រូវបានប្រាក់កម្រៃ ស្មើគ្នា ចំពោះ-

ពាះការងារដូចគ្នា ។

២. ជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនគេផ្ទាល់ និងគ្រួសារ ស្របតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ ។

(ខ) ល័ក្ខខ័ណ្ឌការងារប្រកបដោយសុវត្ថិភាព និងអនាម័យ ។

(គ) ឱកាសដូចគ្នាសម្រាប់បុគ្គលគ្រប់រូប ដើម្បីបានឡើងឋានៈក្នុងការងារ ទៅកម្រិតខ្ពស់សមស្រប ដោយមិនពិចារណាទៅលើអ្វីផ្សេងពីអតីតភាពការងារ និងសមត្ថភាព ។

(ឃ) ការសម្រាក ការលំហែ ការកម្រិតម៉ោងធ្វើការសមរម្យនិងការឈប់សម្រាក តាម-កាលកំណត់ទៀងទាត់ ដោយមានប្រាក់បៀវត្សរ៍ និងប្រាក់កម្រៃសម្រាប់ថ្ងៃបុណ្យជាតិ ។

## មាត្រា ៨

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាឱ្យបាននូវ :

(ក) សិទ្ធិសម្រាប់ជនគ្រប់រូប បង្កើតសហជីព និងចូលរួមសហជីព តាមការជ្រើសរើសរបស់ខ្លួន ដោយស្ថិតក្រោមវិធានទាំងឡាយដែលកំណត់ដោយអង្គការពាក់ព័ន្ធ ដើម្បីលើក ស្ទួយ និងការពារផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន ។ ការប្រើប្រាស់សិទ្ធិនេះ មិនអាចរឹតត្បិតបានទេ លើកលែងតែការរឹតត្បិតនោះ មានចែងនៅក្នុងច្បាប់ និងជាវិធាន ការចាំបាច់ ក្នុងសង្គមប្រជាធិបតេយ្យ ជាផលប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

(ខ) សិទ្ធិរបស់សហជីពបង្កើតសហព័ន្ធ ឬសម្ព័ន្ធជាតិ និងសិទ្ធិរបស់សហព័ន្ធ និងសម្ព័ន្ធជាតិ បង្កើត ឬចូលរួមក្នុងអង្គការសហជីពអន្តរជាតិ ។

(គ) សិទ្ធិរបស់សហជីព ធ្វើសកម្មភាពដោយសេរី ដោយគ្មានកម្រិតព្រំដែន លើក

លើកលែងតែ កម្រិតព្រំដែននោះមានចែងក្នុងច្បាប់ និងជាវិធានការចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ សម្រាប់ជាផលប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

(ឃ) សិទ្ធិធ្វើកូដកម្មដែលត្រូវប្រើប្រាស់ឱ្យស្របតាមច្បាប់របស់ប្រទេសនីមួយៗ ។

២. មាត្រានេះ មិនរារាំងដល់ការដាក់ការរឹតត្បិតស្របច្បាប់ លើការប្រើប្រាស់សិទ្ធិទាំងនេះ ដោយសមាជិកកងកម្លាំងប្រដាប់អាវុធ ឬនគរបាល ឬមុខងារសាធារណៈឡើយ ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ អនុញ្ញាតឱ្យរដ្ឋភាគីទាំងអស់នៃអនុសញ្ញាឆ្នាំ១៩៤៨ នៃអង្គការពលកម្មអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារ-សិទ្ធិសហជីព ចាត់វិធានការខាងផ្លូវច្បាប់ដែលប៉ះពាល់ ឬអនុវត្តច្បាប់ តាមបែបដែលធ្វើឱ្យប៉ះពាល់ដល់ការ ធានាទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញានោះ ។

## មាត្រា ៩

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូបទទួលបានសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គមផង ។

## មាត្រា ១០

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា :

១. កិច្ចគាំពារនិងជំនួយដ៏ទូលំទូលាយបំផុតដែលអាចធ្វើទៅបានត្រូវតែផ្តល់ឱ្យគ្រួសារដែលជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ជាពិ-

សេសសម្រាប់ការកសាង គ្រួសារ និងនៅពេលដែលគ្រួសារមានការទទួលខុសត្រូវចំពោះការថែរក្សា និងការអប់រំបុត្រ ធីតាក្នុងបន្ទុក ។ អាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងដោយមានការយល់ព្រមដោយសេរីពីអនាគត ប្តី-ប្រពន្ធ ។

២. កិច្ចគាំពារពិសេសមួយ ត្រូវផ្តល់ឱ្យម្តាយទាំងឡាយ សម្រាប់រយៈពេលសមរម្យមួយ នៅមុន និងក្រោយពេលសម្រាលកូន ។ក្នុងរយៈពេលនេះ ម្តាយជានិយោជិក ត្រូវបាន ទទួលនូវការសម្រាកមានប្រាក់ខែ ឬការសម្រាកដែលមានការផ្តល់សន្តិសុខសង្គមគ្រប់គ្រាន់ ។

៣. វិធានការការពារ និងជំនួយពិសេស ត្រូវធ្វើឡើងជាគុណប្រយោជន៍ដល់កុមារ និងយុវជនទាំងអស់ ដោយគ្មានការរើសអើងណាមួយ ដោយមូលហេតុខ្សែលោហិត ឬលក្ខខណ្ឌអ្វីផ្សេងទៀតឡើយ ។ កុមារ និងយុវជនទាំងអស់ ត្រូវទទួលបាននូវការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច និងសង្គមកិច្ច ។ ការជួលកុមារ និងយុវជនឱ្យធ្វើការ ដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌ ឬសុខភាពរបស់ពួកគេ ឬធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ឬដែលអាចធ្វើឱ្យ ខូចដល់ការលូតលាស់ធម្មតារបស់ពួកគេ ត្រូវផ្តន្ទាទោសតាមច្បាប់ ។ រដ្ឋត្រូវកំណត់អាយុជួលឱ្យធ្វើការងារ ហើយការជួលកុមារឱ្យធ្វើការងារក្រោមអាយុកំណត់នេះ ត្រូវហាមឃាត់ និង ផ្តន្ទាទោសតាមច្បាប់ ។

## មាត្រា ១១

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សំលៀក បំពាក់ និងទីលំនៅគ្រប់គ្រាន់ ព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ ។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យសម្រេចបាននូវសិទ្ធិនេះ និងទទួលស្គាល់ សារៈសំខាន់ចាំបា

ាច់នៃសហប្រតិបត្តិការអន្តរជាតិ តាមការយល់ព្រមគ្នាដោយសេរី ។

២. ដោយទទួលស្គាល់សិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូប រួចចាកផុតពីសេចក្តីស្រេកឃ្លាន រដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយខ្លួនឯង និងតាម-រយៈកិច្ចសហការអន្តរជាតិ ត្រូវចាត់ វិធានការ រួមមានកម្មវិធីពិសេសៗជាក់លាក់ដែលចាំបាច់ដូចតទៅ :

(ក) ដើម្បីធ្វើឱ្យប្រសើរដល់វិធីនៃការផលិត ការរក្សាទុក និងការចែកចាយម្ហូប អាហារ ដោយការប្រើប្រាស់ពេញលេញនូវចំណេះដឹងខាងបច្ចេកទេស និងវិទ្យាសាស្ត្រ ដោយការផ្សព្វផ្សាយគោលការណ៍នៃការអប់រំស្តីពីអាហារូបត្ថម្ភ និងដោយការអភិវឌ្ឍន៍ ឬការកែទម្រង់របបដីធ្លី ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ។

(ខ) ដើម្បីធានាការបែងចែកដោយសមធម៌ នូវធនធានស្បៀងអាហារពិភពលោក ទៅ-តាមសេចក្តីត្រូវការ ដោយគិតទៅដល់បញ្ហាទាំងឡាយដែលចោទឡើងចំពោះប្រទេសនាំចូល ក៏ដូចជាប្រទេសនាំចេញស្បៀងអាហារ ។

## មាត្រា ១២

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប មានកម្រិត សុខ-ភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ។

២. វិធានការនានា ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះចាត់ ដើម្បីធានាការប្រើសិទ្ធិ នេះឱ្យបានពេញលេញ ត្រូវរាប់បញ្ចូលនូវវិធានការដែលចាំបាច់ដើម្បីធានា :

(ក) វិធានការសម្រាប់ការកាត់បន្ថយអត្រាមរណៈ នៃទារកក្នុងពោះម្ដាយ និងមរណៈនៃកុមារ និងសម្រាប់ការរីកលូតលាស់ប្រកបដោយសុខភាពល្អរបស់កុមារ ។

(ខ) ការធ្វើឱ្យប្រសើរគ្រប់ទិដ្ឋភាពនៃអនាម័យខាងផ្នែកបរិស្ថាន និងឧស្សាហកម្ម។

(គ) វិធីបង្ការ ការព្យាបាល និងការត្រួតពិនិត្យជំងឺឆ្លង ជំងឺរាតត្បាត ជំងឺបណ្ដាល មកពីវិជ្ជាជីវៈ និងជំងឺដទៃទៀត ព្រមទាំងប្រយុទ្ធប្រឆាំងនឹងជំងឺទាំងនេះផង ។

(ឃ) ការបង្កើតលក្ខខណ្ឌសម្រាប់ធានាដល់ជនគ្រប់រូប នូវសេវាសុខាភិបាលគ្រប់ ផ្នែក និងជំនួយផ្នែកសុខាភិបាលក្នុងពេលមានជំងឺ ។

## មាត្រា ១៣

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិបុគ្គលគ្រប់រូប ដើម្បីទទួលបានការអប់រំ ។ រដ្ឋភាគី ព្រមព្រៀងគ្នាថា ការអប់រំត្រូវនាំឆ្ពោះទៅរកការរីកចម្រើនពេញលេញ នៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងអត្ថន័យនៃសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងពង្រឹងការគោរព សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។ រដ្ឋភាគី ព្រមព្រៀងគ្នាបន្ថែមទៀតថា ការអប់រំត្រូវ ធ្វើឱ្យមនុស្សគ្រប់រូប អាចដើរតួនាទីមានប្រយោជន៍ក្នុងសង្គមសេរី លើកស្ទួយការយោគយល់ ការអត់ឱន និងមិត្តភាពរវាងប្រជាជាតិ និងរវាងក្រុមពូជសាសន៍ ក្រុមជាតិពន្ធុ ឬក្រុមសាសនាទាំងអស់ ព្រមទាំងជ្រោមជ្រែងសកម្មភាពរបស់អង្គការសហប្រជាជាតិ ដើម្បីរក្សាសន្តិភាព ។

២. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា ដើម្បីសម្រេចបានការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ :

(ក) ការអប់រំកម្រិតបឋមសិក្សា ត្រូវតែជាកាតព្វកិច្ច ហើយឥតបង់ថ្លៃ សម្រាប់ទាំងអស់គ្នា ។

(ខ) ការអប់រំកម្រិតមធ្យមសិក្សា តាមទម្រង់ទ្រាយផ្សេងៗ រួមទាំងការអប់រំបច្ចេក ទេស និងវិជ្ជាជីវៈកម្រិតមធ្យម ត្រូវតែបើកឱ្យមានជាទូទៅ និងឱ្យមនុស្សគ្រប់គ្នា អាចចូល រៀនបាន តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យមានជា លំដាប់នូវការសិក្សាដោយឥតបង់ថ្លៃ ។

(គ) ការអប់រំកម្រិតឧត្តមសិក្សា ត្រូវតែបើកចំហដល់មនុស្សគ្រប់រូបដោយស្មើភាព តាមសមត្ថភាពរបស់មនុស្សម្នាក់ៗ តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យមានជាលំដាប់នូវការសិក្សាដោយឥតបង់ថ្លៃ ។

(ឃ) ការអប់រំមូលដ្ឋាន ត្រូវតែជំរុញ ឬពង្រឹង តាមគ្រប់មធ្យោបាយដែលអាចធ្វើ ទៅបាន សម្រាប់អ្នកដែលមិនបានទទួល ឬមិនបានបញ្ចប់កម្រិតបឋមសិក្សារបស់ខ្លួន ។

(ង) ត្រូវតែបន្តយ៉ាងសកម្មលើការអភិវឌ្ឍន៍បណ្តាញសិក្សាធិការគ្រប់លំដាប់ បង្កើត ប្រព័ន្ធអាហារូបករណ៍ឱ្យបានគ្រប់គ្រាន់ និងបង្កើនជាលំដាប់នូវលក្ខខណ្ឌសម្ភារៈ របស់បុគ្គលិក សិក្សា ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់មាតាបិតា និងអាណា ព្យាបាលស្របច្បាប់បើសមស្រប ដើម្បីជ្រើសរើសសាលារៀនក្រៅពីសាលារៀនសាធារណៈឱ្យ កូនរបស់ខ្លួន ប៉ុន្តែត្រូវស្របតាមវិធានអប្បបរមាដែលរដ្ឋអាចកំណត់ ឬអនុម័តក្នុងវិស័យអប់រំ និងរ៉ាប់រងការអប់រំ សាសនា និងសីលធម៌របស់កូន ស្របតាមជំនឿផ្ទាល់របស់ពួកគេ ។

៤. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ត្រូវយកមកបកស្រាយ ថាប៉ះពាល់ដល់ សេរីភាពនៃរូបវ័ន្តបុគ្គល និងនីតិបុគ្គល ក្នុងការបង្កើត

និងដឹកនាំគ្រឹះស្ថានសិក្សា លើកលែងតែ គោលការណ៍ដែលចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ ត្រូវបានគោរព និងឱ្យតែការអប់រំដែល ផ្តល់ឱ្យនៅក្នុងគ្រឹះស្ថានទាំងនោះ ស្របទៅនឹងបទដ្ឋានអប្បបរមាដែលអាចកំណត់ដោយរដ្ឋ ។

## មាត្រា ១៤

នៅពេលក្លាយជាភាគីនៃកតិកាសញ្ញានេះ រដ្ឋភាគី ដែលមិនទាន់អាចធានាការអប់រំកម្រិតបឋម ជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃ នៅក្នុងដែនដីចំណុះនៃប្រទេសខ្លួន ឬដែនដី ដែល-ស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន សន្យាបង្កើត និងអនុម័ត ក្នុងរយៈពេល២ឆ្នាំ នូវ ផែនការលំអិតនៃវិធានការចាំបាច់ ដើម្បីធ្វើឱ្យបានសម្រេចជាលំដាប់តាមចំនួនឆ្នាំសមរម្យដែលកំណត់ក្នុងផែនការនេះ នូវការអនុវត្តន៍ពេញលេញនៃគោលការណ៍អប់រំកម្រិតបឋមជាកាតព្វកិច្ច និ-ងដោយឥតបង់ថ្លៃសម្រាប់ទាំងអស់គ្នា ។

## មាត្រា ១៥

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិនៃបុគ្គលគ្រប់រូប ដើម្បី ៖

(ក) ចូលរួមក្នុងជីវភាពវប្បធម៌ ។

(ខ) ទទួលអត្ថប្រយោជន៍ពីវឌ្ឍនភាព និងការអនុវត្តន៍វិទ្យាសាស្ត្រ ។

(គ) ទទួលអត្ថប្រយោជន៍ ពីការការពារផលប្រយោជន៍ខាងសីលធម៌ និងខាង សម្ភារៈដែលកើតពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈដែលខ្លួនជាអ្នកបង្កើត ។

២. វិធានការ ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះ ប្រកាន់យក ដើម្បីធានាដល់ការ ប្រើប្រាស់ពេញលេញនូវសិទ្ធនេះ ត្រូវរួមបញ្ចូលវិធានការចាំបាច់សម្រាប់ធានាដល់ការថែរក្សា ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយខាងវិទ្យាសាស្ត្រ និងវប្បធម៌ ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពដែលមិនអាចខ្វះបានសម្រាប់ការស្រាវជ្រាវខាងវិទ្យាសាស្ត្រ និងសកម្មភាពប្រឌិតញាណ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់អត្ថប្រយោជន៍ដែលបានមកពីការលើក ទឹកចិត្ត និងការអភិវឌ្ឍន៍នៃសហប្រតិបត្តិការ និងការទាក់ទងជាអន្តរជាតិក្នុងវិស័យវិទ្យាសាស្ត្រ និងវប្បធម៌ ។

## ផ្នែកទី ៤

### មាត្រា ១៦

១. ដោយអនុលោមទៅតាមបទបញ្ញត្តិនានានៃផ្នែកនេះនៃកតិកាសញ្ញានេះ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាដាក់ជូននូវរបាយការណ៍ស្តីពីវិធានការដែលខ្លួនបានអនុម័ត និងស្តីពី ការរីកចម្រើនដែលសម្រេចបាន ដើម្បីធានាការគោរពសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយ កតិកាសញ្ញានេះ ។

២. (ក) របាយការណ៍ទាំងអស់ ត្រូវដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវបញ្ជូនច្បាប់ចម្លងនៃរបាយការណ៍ទាំងនេះ ទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីពិនិត្យ ស្របតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ ។

(ខ) អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនផងដែរ នូវច្បាប់ចម្លងនៃរបាយការណ៍ទាំងនេះ ទៅឱ្យស្ថាប័នឯកទេស ឬផ្នែកពាក់ព័ន្ធខ្លះនៃរបាយការណ៍ដែលផ្ញើមក ដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ដែលជាសមាជិកនៃស្ថាប័នឯកទេស តាមដែលរបាយការណ៍ ឬផ្នែកនៃរបាយការណ៍ មានទាក់ទងនឹងបញ្ហាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ស្ថាប័នខាងលើ ស្របតាមសារលិខិតជាបតិដ្ឋាប័នរៀង១ខ្លួន ។

## មាត្រា ១៧

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ត្រូវបង្ហាញរបាយការណ៍របស់ខ្លួនជាដំណាក់ៗ ស្របតាមកម្មវិធីដែលក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច នឹងកំណត់ក្នុងរយៈពេល១ឆ្នាំ គិតពីកាល បរិច្ឆេទដែលកតិកាសញ្ញានេះចូលជាធរមាន បន្ទាប់ពីបានពិគ្រោះប្តូរយោបល់ជាមួយរដ្ឋភាគី និងស្ថាប័នឯកទេសពាក់ព័ន្ធ ។

២. របាយការណ៍អាចប្រាប់ពីកត្តា និងការលំបាកដែលរារាំងរដ្ឋទាំងនោះ ក្នុងការបំពេញកាតព្វកិច្ចក្រោមកតិកាសញ្ញានេះ ។

៣. ក្នុងករណីដែលព័ត៌មានពាក់ព័ន្ធ ត្រូវបានដាក់ជូន អង្គការសហប្រជាជាតិ ឬស្ថាប័នឯកទេសណាមួយ ដោយរដ្ឋភាគីណាមួយ នៃកតិកាសញ្ញានេះហើយ នោះមិនចាំបាច់ បង្ហាញព័ត៌មាននោះឡើងវិញទៀតទេ គឺគ្រាន់តែយោងឱ្យច្បាស់លាស់លើព័ត៌មាននោះទៅ ជាការគ្រប់គ្រាន់ហើយ ។

## មាត្រា ១៨

ស្របតាមការទទួលខុសត្រូវរបស់ខ្លួន នៅក្រោមធម្មនុញ្ញសហប្រជាជាតិ ក្នុងវិស័យសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច អាចធ្វើការសម្របសម្រួលជាមួយស្ថាប័នឯកទេសនានា ពាក់ព័ន្ធនឹងការធ្វើរបាយការណ៍ ដែលស្ថាប័នទាំងនេះត្រូវដាក់ជូនក្រុមប្រឹក្សា ហើយដែលទាក់ទងនឹងការរីកចម្រើនដែលសម្រេចបានក្នុងការអនុវត្តនី បទបញ្ញត្តិនៃកតិកាសញ្ញានេះ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន ។ របាយការណ៍ ទាំងនេះ អាចបញ្ចូលទិន្នន័យនៃសេចក្តីសម្រេច និងអនុសាសន៍លើការអនុវត្តន៍ដែលបានអនុម័ត ដោយអង្គការមានសមត្ថកិច្ចនៃស្ថាប័នឯកទេស ។

## មាត្រា ១៩

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច អាចផ្ញើជូនគណៈកម្មការសិទ្ធិមនុស្ស ដើម្បីធ្វើការសិក្សា និងផ្តល់អនុសាសន៍ទូទៅ ឬដើម្បីជាព័ត៌មាន បើសិនជាមាន នូវរបាយការណ៍ស្តីពីសិទ្ធិមនុស្សដែលរដ្ឋនានាបានដាក់ជូន ស្របតាមមាត្រា១៦ និងមាត្រា១៧ និងរបាយការណ៍ស្តីពីសិទ្ធិមនុស្ស ដែលស្ថាប័នឯកទេសបានដាក់ជូនស្របតាមមាត្រា១៨ ។

## មាត្រា ២០

រដ្ឋភាគីនៃកតិកាសញ្ញានេះ និងស្ថាប័នឯកទេសពាក់ព័ន្ធនានា អាចជូនយោបល់ទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច លើកអនុសាសន៍ទូទៅស្របតាមមាត្រា១៩ ឬយោងតាមអនុសាសន៍ទូទៅដែលមានក្នុងរបាយការណ៍របស់គណៈកម្មការសិទ្ធិមនុស្ស ឬក្នុងឯកសារដែល មាន-ចែងក្នុងរបាយការណ៍នោះ ។

## មាត្រា ២១

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច អាចដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ម្តងម្កាលនូវរបាយការណ៍ភ្ជាប់ជាមួយអនុសាសន៍ដែលមានលក្ខណៈទូទៅ និងសេចក្តីសង្ខេបព័ត៌មានដែលទទួលបានពីរដ្ឋភាគីនៃកតិកាសញ្ញានេះ និងស្ថាប័នឯកទេសស្តីពីវិធានការដែលបានដាក់ចេញ និងការរីកចម្រើនដែលសម្រេចបាន ដើម្បីធានាការគោរពជាទូទៅ នូវសិទ្ធិដែលបាន ទទួល-ស្គាល់ក្នុងកតិកាសញ្ញានេះ ។

## មាត្រា ២២

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច អាចជំរាបជូនអង្គការដទៃទៀត នៃអង្គការសហ ប្រជាជាតិ អង្គការជាសាខា និងស្ថាប័នឯកទេសពាក់ព័ន្ធ ដែលផ្តល់ជំនួយខាងបច្ចេកទេស នូវបញ្ហាទាំងឡាយ

ដូចបានលើកឡើងក្នុងរបាយការណ៍ដែលបានបញ្ជាក់ក្នុងផ្នែកនេះ នៃកតិកា សញ្ញានេះ ហើយអាចជួយអង្គការទាំងនេះ ធ្វើការសម្រេចក្នុងរង្វង់សមត្ថកិច្ចផ្ទាល់រៀងៗខ្លួន នូវការគួរឱ្យមានវិធានការអន្តរជាតិសម្រាប់រួមចំណែកក្នុងការអនុវត្តន៏កតិកាសញ្ញានេះ ឱ្យបាន ស័ក្តិសិទ្ធិ និងជាលំដាប់ ។

## មាត្រា ២៣

រដ្ឋភាគីនៃកតិកាសញ្ញានេះ ព្រមព្រៀងគ្នាថា វិធានការលំដាប់អន្តរជាតិ ដើម្បីសម្រេចបាននូវសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញានេះ មានជាអាទិ៍ ការធ្វើអនុសញ្ញា ការអនុ ម័តអនុសាសន៍ ការឧបត្ថម្ភ ជំនួយបច្ចេកទេស និងការរៀបចំការប្រជុំថ្នាក់តំបន់ និងការ ប្រជុំផ្នែកបច្ចេកទេស សម្រាប់ពិគ្រោះយោបល់ និងសិក្សាជាមួយរដ្ឋាភិបាលពាក់ព័ន្ធ ។

## មាត្រា ២៤

គ្មានបទបញ្ញត្តិណាមួយក្នុងកតិកាសញ្ញានេះ ត្រូវយកមកបកស្រាយ ធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ និងធម្មនុញ្ញនៃស្ថាប័នឯកទេសដែលកំណត់ការទទួលខុសត្រូវរៀងៗខ្លួន របស់ស្ថាប័ននានា នៃអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេស ដែលពាក់ព័ន្ធនឹងបញ្ហាដែលដោះស្រាយក្នុងកតិកាសញ្ញានេះឡើយ ។

## មាត្រា ២៥

គ្មានបទបញ្ញត្តិណាមួយ ត្រូវយកមកបកស្រាយធ្វើឱ្យប៉ះពាល់ដល់សិទ្ធិពីកំណើតរបស់ប្រជាជាតិ ក្នុងការអាស្រ័យផល និងការប្រើប្រាស់ដោយពេញលេញ និងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួនឡើយ ។

## ផ្នែកទី ៥

### មាត្រា ២៦

១. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខា សម្រាប់រដ្ឋសមាជិកសហប្រជា ជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយ ឬជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬជារដ្ឋផ្សេងទៀត ដែលត្រូវបានអញ្ជើញដោយមហាសន្និបាតសហប្រជាជាតិ ឱ្យក្លាយជាភាគីនៃកតិកាសញ្ញានេះ ។

២. កតិកាសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ។ លិខិតុបករណ៍ឱ្យសច្ចាប័នត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យចូលជាសមាជិកដោយរដ្ឋណាមួយ ដែលមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

៤. ការចូលជាសមាជិក ត្រូវធ្វើឡើង ដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើកតិកាសញ្ញានេះ ឬដែលបានចូលជាសមាជិក នៃកតិកាសញ្ញានេះ អំពីការ តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិក ។

### មាត្រា ២៧

១. កតិកាសញ្ញានេះ ចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទី៣៥ នៅនឹងអគ្គលេខា ធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋណាមួយដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក នៃកតិកាសញ្ញានេះ បន្ទាប់ពីសមាជិកទី៣៥ កតិកាសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាល បរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ ។

### មាត្រា ២៨

បទបញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការដាក់កម្រិតព្រំដែន ឬការលើកលែងឡើយ ។

### មាត្រា ២៩

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចស្នើសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើនោះជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិ-ការអង្គការសហប្រជា ជាតិ ត្រូវបញ្ជូនសេចក្តីស្នើធ្វើវិសោធនកម្មនេះ ទៅរដ្ឋភាគីនៃកតិកាស-ញ្ញានេះ ដោយសុំឱ្យរដ្ឋ ភាគីបញ្ជាក់ថាតើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ដើម្បីពិនិត្យ និងបោះឆ្នោតលើ សេចក្តីស្នើសុំធ្វើវិសោធនកម្ម ឬទេ ។ ក្នុងករណី-មានសម្លេង១ភាគ៣យ៉ាងតិច នៃរដ្ឋភាគីទាំង អស់ ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំ សន្និសីទក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ គ្រប់វិសោធនកម្មដែលបានអនុម័ត ដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូ-វដាក់ជូនមហាសន្និបាត នៃអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មទាំងនេះ នឹងចូលជាធរមាន នៅពេលទទួលបានការយល់ព្រមពី មហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តដោយមតិភាគច្រើន២ភាគ៣នៃរដ្ឋភាគីនៃកតិកាសញ្ញានេះ ស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលដែលវិសោធនកម្មទាំងនោះ ចូលជាធរមានហើយ វិសោធនកម្មទាំង នោះ នឹងក្លាយជាកាតព្វកិច្ច សម្រាប់រដ្ឋភាគីដែលបានទទួលយល់ព្រមយកវិសោធនកម្មទាំង នោះ ឯរដ្ឋភាគីផ្សេងទៀតដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានយល់ព្រមរួចហើយ ។

## មាត្រា ៣០

ក្រៅពីការជូនដំណឹងទាំងឡាយដែលមានចែងនៅក្នុងកថាខណ្ឌ៥ នៃមាត្រា២៦ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងឡាយ ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ នូវ :

(ក) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការសុំចូលជាសមាជិក យោងតាម មាត្រា២៦ ។

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃកតិកាសញ្ញានេះ យោងតាមមាត្រា២៧ និងកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មទាំងឡាយ យោងតាមមាត្រា២៩ ។

## មាត្រា ៣១

១. កតិកាសញ្ញានេះ ដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញ មានតម្លៃស្មើគ្នា និងត្រូវតំកល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លង នៃកតិកាសញ្ញា នេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ទៅរដ្ឋទាំងឡាយ យោងតាមមាត្រា២៦ ។

# ឧបសម្ព័ន្ធ ៤ ៈ

## លិខិតុបករណ៍អន្តរជាតិដែលមាននៅលើអ៊ិនធឺណែត

លោក អ្នក អាចរកអត្ថបទខាងក្រោមនេះ តាមរយៈគេហទំព័ររបស់ការិយាល័យៀ៖ជះ្រ ៈ
http://www.ohchr.org/eng/law/index.htm

### ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ពិធីសារបន្ថែមលើកទីពីរ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានគោលដៅ លុបទោសប្រហារជីវិត

### សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស និងសម័យប្រជុំសហសវត្សរ៍

សេចក្តីប្រកាស និងកម្មវិធីសកម្មភាពនៃទីក្រុងវីយ៉ែន

សេចក្តីប្រកាសសហសវត្សរ៍របស់អង្គការសហប្រជាជាតិ

## សិទ្ធិស្វ័យសំរេច

សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការផ្តល់ឯករាជ្យភាពដល់ប្រជាជន និង ប្រទេសទាំងឡាយដែលស្ថិត ក្រោមអាណានិគម ។

សេចក្តីសំរេចចិត្តរបស់មហាសន្និបាត លេខ ១៨០៣ ១ឃ្មីច ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៦២ : "អធិបតេយ្យភាព អចិន្ត្រៃយ៍លើធនធានធម្មជាតិ " ។

អនុសញ្ញាអន្តរជាតិប្រឆាំងនឹងការជ្រើសរើស ការប្រើប្រាស់ ការផ្តល់ហិរញ្ញវត្ថុ និង-ការហ្វឹកហ្វឺនទាហានស៊ីឈ្នួយ

## សិទ្ធិជនភាគតិច និង សិទ្ធិជនជាតិដើមភាគតិច

អនុសញ្ញាស្តីពីពួកកុលសម្ព័ន្ធ និងជនជាតិដើមភាគតិច ១៩៨៩ (អនុសញ្ញា ីឡូ លេខ ១៦៩)

សេចក្តីប្រកាសស្តីពីសិទ្ធិរបស់បុគ្គលជាសមាជិកជនភាគតិចខាងជាតិ ឬជាតិពន្ធ សាសនា និងភាសា

## ការបង្ការទារុណកម្ម

អនុសញ្ញា ីឡូ លេខ១០០ ស្តីពីប្រាក់ឈ្នួលស្មើគ្នាសំរាប់កម្មករនិយោជិតបុរស - ស្ត្រី ចំពោះការងារមានតម្លៃស្មើគ្នា

អនុសញ្ញា ីឡូ លេខ១១១ ស្តីពីការរើសអើងក្នុងការងារ និងមុខរបប

អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

សេចក្តីប្រកាសស្តីពីការប្រកាន់ពូជសាសន៍ និងជាតិសាសន៍

© សហភាពអន្តរសភា (IPU) និង ការិយាល័យ
ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

២០០៥

រក្សាសិទ្ធិគ្រប់យ៉ាង ។ គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានបោះពុម្ពផ្សាយជាថ្មី រក្សាទុកក្នុងប្រព័ន្ធមួយដែលអាចដក យកមកវិញបាន ឬត្រូវបានបញ្ជូនក្នុងរូបភាពណាមួយ ឬតាមមធ្យោបាយណាមួយ ទោះជាតាមរយៈប្រព័ន្ធអេឡិកត្រូនិក មេកានិក ថតចម្លង ថតសំលេង ឬមធ្យោបាយដទៃផ្សេងទៀត ដែលគ្មានការអនុញ្ញាតជាមុនពីសហភាពអន្តរសភា និង ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សឡើយ ។

កូនសៀវភៅនេះ ត្រូវបានចែកចាយដោយមានលក្ខខណ្ឌថា មិនត្រូវបានឱ្យខ្ចី ឬចែកចាយតាមរបៀបផ្សេងពីនេះ រាប់ទាំងតាម មធ្យោយជំនួញ ដោយគ្មានការអនុញ្ញាតជាមុនពីអ្នកបោះពុម្ពផ្សាយ ក្នុងរូបភាពណាមួយដែលផ្ទុយពីលក្ខខណ្ឌខាងដើម និង លក្ខខណ្ឌថា អ្នកបោះពុម្ពផ្សាយបន្ទាប់ ត្រូវបំពេញតាមសេចក្តីតម្រូវដូចគ្នា ។

**សិទ្ធិមនុស្ស : កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ ភាសាខ្មែរ**

ISBN 978-92-9142-492-4

**សហភាពអន្តរសភា (IPU)**
Chemin du Pommier 5
CH – 1218 Le Grand-Saconnex
Tel. +4122 919 41 50
Fax.+4122 919 41 60
E-mail: postbox@mail.ipu.org
Web site: www.ipu.org

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស**
OHCHR
Palais des Nations
Avenues de la Paix 8-14
CH – 1211 Geneva 10
Tel. +4122 917 90 00
Fax. +4122 917 01 23
E-mail: publications@ohchr.org
Web site: www.ohchr.org

...平等。他们赋有理性和良心,并应以兄弟关系的精神相对待。

...EQUAL IN DIGNITY AND RIGHTS. THEY ARE ENDOWED WITH REASON AND CONSCIENCE AND SHOULD ACT TOWARDS ONE ANOTHER IN A SPIRIT OF BROTHERHOOD.

...равными в своем достоинстве и правах. Они наделены разумом и совестью и должны поступать в отношении друг друга в духе братства.

..égaux en dignité et en droits. Ils sont doués de raison et de conscience et doivent agir les uns envers les autres dans un esprit de fraternité.

...متساوين في الكرامة و الحقوق. وقد وهبوا عقلاً وضميراً وعليهم أن يعامل بعضهم بعضاً بروح الإخاء.

...iguales en dignidad y derechos y, dotados como están de razón y conciencia, deben comportarse fraternalmente los unos con los otros.

ការបោះពុម្ពសៀវភៅនេះ មានគោលដៅផ្តល់ជូនសមាជិកសភាទាំងឡាយដែលមានបំណងស្វែងយល់កាន់តែច្បាស់ថែមទៀតអំពីក្របខ័ណ្ឌដែលអង្គការសហប្រជាជាតិ និង អង្គការថ្នាក់តំបន់នានា បានបង្កើតឡើងតាំងពីឆ្នាំ១៩៤៥ ដើម្បីការពារ និងលើកស្ទួយសិទ្ធិមនុស្ស។ សៀវភៅនេះ បង្ហាញពីសញ្ញាណនៃសិទ្ធិមនុស្ស និងន័យនៃសិទ្ធិទាំងឡាយដែលបានតំកល់ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

សៀវភៅនេះ បញ្ជាក់ច្បាស់អំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស និងមានសេចក្តីណែនាំមួយចំនួនអំពីវិធានការផ្សេងៗ ដែលសភានិងសមាជិកសភាអាចចាត់អោយមានឡើង ដើម្បីរួមចំណែកដល់ការអនុវត្តន៏មុខងារភារកិច្ចរបស់ខ្លួន ។